ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# ព្រះ
# ត្រៃបិដកបាលី
# នឹង
# សេចក្ដីប្រែជាភាសាខ្មែរ
# វិនយបិដក ចុល្លវគ្គ
## តតិយភាគ
## ១១

សង្ឃភេទក្ខន្ធកៈ វត្តក្ខន្ធកៈ

បាតិមោក្ខដ្ឋបនក្ខន្ធកៈ ភិក្ខុនីខន្ធកៈ

បញ្ចសតិកក្ខន្ធកៈ នឹង សត្តសតិកក្ខន្ធកៈ

លើកទី ២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥០១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



# តតិយោ ភាគោ

## សង្ឃភេទក្ខន្ធកំ

[១] តេន សមយេន ពុទ្ធោ ភគវា អនុបិយាយំ វិហរតិ អនុបិយំ នាម មល្លានំ និគមោ ។ តេន ខោ បន សមយេន អភិញ្ញាតា អភិញ្ញាតា សក្យកុមារា ភគវន្តំ បព្វជិតំ អនុបព្វជន្តិ ។

[២] តេន ខោ បន សមយេន មហានាមោ ច សក្កោ អនុរុទ្ធោ ច សក្កោ ទ្វេ ភាតរោ ហោន្តិ ។ អនុរុទ្ធោ សក្កោ សុខុមាលោ ហោតិ ។ តស្ស តយោ បាសាទា ហោន្តិ ឯកោ ហេមន្តិកោ ឯកោ គិម្ហិកោ ឯកោ វស្សិកោ ។ សោ វស្សិកេ បាសាទេ ចត្តារោ មាសេ និប្បុរិសេហិ តុរិយេហិ បរិចារយមានោ ន ហេដ្ឋាបាសាទា[១] ឱរោហតិ។ អថ ខោ មហានាមស្ស សក្កស្ស

១ ម. ហេដ្ឋាបាសាទំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។

## វិនយបិដក ចុល្លវគ្គ

# តតិយភាគ

---

## សង្ឃភេទក្ខន្ធកៈ

(១) សម័យនោះ ព្រះពុទ្ធ មានព្រះភាគ គង់នៅក្នុងនិគម ឈ្មោះអនុបិយា ជានិគមរបស់មល្លក្សត្រ ទៀបព្រៃអនុបិយា ។ ក៏សម័យនោះឯង ពួកសក្យកុមារ សុទ្ធតែជាអ្នកមាននាមល្បីល្បាញ ចេញបួសតាមព្រះមានព្រះភាគ ដែលទ្រង់ព្រះផ្នួសហើយ ។

(២) សម័យនោះ មានសក្យៈជាបងប្អូន ២ អង្គ ឈ្មោះមហានាមសក្កៈ ១ ឈ្មោះអនុរុទ្ធសក្កៈ ១ ។ ឯអនុរុទ្ធសក្កៈជាស្តេចសុខុមាលជាតិ[១] ។ អនុរុទ្ធសក្កៈនោះ មានប្រាសាទ ៣ ខ្នង ប្រាសាទមួយសម្រាប់រដូវរងា ប្រាសាទមួយសម្រាប់រដូវក្តៅ ប្រាសាទមួយសម្រាប់រដូវភ្លៀង ។ អនុរុទ្ធសក្កៈនោះ (គង់នៅ) លើប្រាសាទសម្រាប់រដូវភ្លៀងអស់បួនខែ មានតន្ត្រីនៅចាំគាល់បម្រើ មិនមានមនុស្សប្រុស (នៅលាយ) មិនដែលយាងចុះអំពីប្រាសាទមកខាងក្រោមឡើយ ។ គ្រានោះឯង មហានាមសក្កៈ

---

១ ជាក្សត្រធ្លាប់បានសេចក្តីសុខ មិនដែលបានសេចក្តីលំបាកដោយខ្យល់និងកំដៅថ្ងៃជាដើម ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដកេ ចុល្លវគ្គោ

ឯតទហោសិ ឯតរហិ ខោ អភិញ្ញាតា អភិញ្ញាតា សក្យកុមារា ភគវន្តំ បព្វជិតំ អនុបព្វជន្តិ អម្ហាកញ្ច បន[១] កុលា នត្ថិ កោចិ អគារស្មា អនគារិយំ បព្វជិតោ យន្នូនាហំ វា បព្វជេយ្យំ អនុរុទ្ធោ វាតិ ។ អថខោ មហានាមោ សក្កោ យេន អនុរុទ្ធោ សក្កោ តេនុបសង្កមិ ឧបសង្កមិត្វា អនុរុទ្ធំ សក្កំ ឯតទវោច ឯតរហិ តាត អនុរុទ្ធ អភិញ្ញាតា អភិញ្ញាតា សក្យកុមារា ភគវន្តំ បព្វជិតំ អនុបព្វជន្តិ អម្ហាកញ្ច បន កុលា នត្ថិ កោចិ អគារស្មា អនគារិយំ បព្វជិតោ តេនហិ ត្វំ វា បព្វជ អហំ វា បព្វជិស្សាមីតិ ។ អហំ ខោ សុខុមាលោ នាហំ សក្កោមិ អគារស្មា អនគារិយំ បព្វជិតុំ ត្វំ បព្វជាហីតិ ។ ឯហិ ខោ តេ តាត អនុរុទ្ធ ឃរាវាសត្ថំ អនុសាសិស្សាមិ បឋមំ ខេត្តំ កសាបេតព្វំ កសាបេត្វា វបាបេតព្វំ វបាបេត្វា ឧទកំ អភិនេតព្វំ ឧទកំ អភិនេត្វា ឧទកំ និន្នេតព្វំ ឧទកំ និន្នេត្វា និទ្ទាបេតព្វំ[២]

១ ឱ. ម. បោត្ថកេសុ បនសទ្ទោ ន ទិស្សតិ ។ ២ ឱ. និទ្ទាបេតព្វំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



## វិនយបិដក ចុល្លវគ្គ

មានសេចក្តីត្រិះរិះដូច្នេះថា ឥឡូវនេះពួកសក្យកុមារសុទ្ធតែជាអ្នកមាននាមល្បីល្បាញ បានចេញបួសតាមព្រះមានព្រះភាគ ដែលទ្រង់ព្រះផ្នួសហើយ ចំណែកខាងត្រកូលរបស់យើងគ្មាននរណាមួយ ចេញចាកផ្ទះទៅបួសក្នុងសាសនាសោះ បើដូច្នោះគួរតែអាត្មាអញឬអនុរុទ្ធបួសក៏ខានចុះ ។ ទើបមហានាមសក្កៈចូលទៅរកអនុរុទ្ធសក្កៈ លុះចូលទៅដល់ហើយ បាននិយាយរឿងនុ៎ះចំពោះអនុរុទ្ធសក្កៈថា ម្នាលអនុរុទ្ធ ជាអនុជ ឥឡូវនេះ ពួកសក្យកុមារ សុទ្ធតែជាអ្នកមាននាមល្បីល្បាញ បានចេញបួសតាមព្រះមានព្រះភាគ ដែលទ្រង់ព្រះផ្នួសហើយ ចំណែកខាងត្រកូលរបស់យើងគ្មាននរណាមួយ ចេញចាកផ្ទះទៅបួសក្នុងសាសនាសោះ បើដូច្នោះប្អូនឯងបួស ឬអញនឹងបួសក៏បាន ។ អនុរុទ្ធឆ្លើយថា ខ្ញុំជាមនុស្សសុខុមាលជាតិ ខ្ញុំមិនអាចនឹងចេញចាកផ្ទះ ទៅបួសក្នុងសាសនាបានទេ សូមទ្រង់ស្តេចបួសចុះ ។ មហានាមសក្កៈនិយាយថា ម្នាលអនុរុទ្ធ ជាអនុជ ចូរប្អូនមកអាយ បងនឹងពន្យល់ប្រយោជន៍របស់ឃរាវាសដល់ប្អូនថា ការធ្វើស្រែនោះមុនដំបូងត្រូវភ្ជួរ ភ្ជួររួចហើយ ត្រូវព្រោះ ព្រោះរួចហើយ ត្រូវបញ្ចូលទឹក បញ្ចូលទឹករួចហើយ ត្រូវបញ្ចេញទឹក បញ្ចេញទឹករួចហើយ ត្រូវដំរះស្មៅ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



និទ្ទាបេត្វា លាវាបេតព្វំ លាវាបេត្វា ឧព្វាហាបេតព្វំ ឧព្វាហាបេត្វា(១) បុញ្ជំ ការាបេតព្វំ បុញ្ជំ ការាបេត្វា មទ្ទាបេតព្វំ មទ្ទាបេត្វា បលាលានិ ឧទ្ធរាបេតព្វានិ បលាលានិ ឧទ្ធរាបេត្វា ភុសិកា ឧទ្ធរាបេតព្វា ភុសិកំ ឧទ្ធរាបេត្វា ឱផុនាបេតព្វំ ឱផុនាបេត្វា(២) អតិហរាបេតព្វំ អតិហរាបេត្វា អាយតិម្បិ វស្សំ ឯវមេវ កាតព្វំ អាយតិម្បិ វស្សំ ឯវមេវ កាតព្វន្តិ ។ ន កម្មា ខីយន្តិ ន កម្មានំ អន្តោ បញ្ញាយតិ កទា កម្មា ខីយិស្សន្តិ កទា កម្មានំ អន្តោ បញ្ញាយិស្សតិ កទា មយំ អប្បោស្សុក្កា បញ្ចហិ កាមគុណេហិ សមប្បិតា សមង្គីភូតា បរិចារេស្សាមាតិ ។ ន ហិ តាត អនុរុទ្ធ កម្មា ខីយន្តិ ន កម្មានំ អន្តោ បញ្ញាយតិ អក្ខីណេវ(៣) កម្មេ មាតាបិតរោ(៤) ច បិតាមហា ច កាលកតាតិ ។ តេនហិ ត្វញ្ញេវ ឃរាវាសត្ថំ ឧបជានាហិ អហំ អគារស្មា អនគារិយំ បព្វជិស្សាមីតិ ។

---

១ ឱ. ឧព្វហាបេត្វា ។ ២ ឱ. ម. ឱបុនាបេតព្វំ ឱបុនាបេត្វា ។ ៣ ឱ. អក្ខីណេយេវ ។
៤ ឱ. ម. បិតរោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ រឿងអនុរុទ្ធសក្កៈ នឹងរឿងមហានាមសក្យរាជ

ដំរះស្មៅរួចហើយ ត្រូវច្រូតស្រូវ ច្រូតស្រូវហើយ ត្រូវចងកណ្ដាប់ ចងជាកណ្ដាប់ហើយ ត្រូវធ្វើឲ្យជាគំនរ ធ្វើឲ្យជាគំនរហើយ ត្រូវបោកបួបញ្ជាន់ បញ្ជាន់ហើយ ត្រូវជជុះយកចំបើង ជជុះយកចំបើងហើយ ត្រូវជជុះយកកំទេចចេញ ជជុះយកកំទេចចេញហើយ ត្រូវរោយ រោយហើយ ត្រូវជញ្ជូនយកមកទុក ជញ្ជូនយកមកទុកហើយ ត្រូវចាប់ធ្វើតែយ៉ាងនេះតទៅទៀត រាល់ៗឆ្នាំ ត្រូវចាប់ធ្វើ (សាពីដើម) តាមទំនងនេះទៀត តែរាល់ ១ ឆ្នាំ ៗ អនុរុទ្ធសក្កៈនិយាយថា ការងារមិនចេះអស់ទេ ទីបំផុតនៃការងារមិនប្រាកដទេ កាលណាទើបអស់ការងារ កាលណាទើបប្រាកដជាផុតការងារបាន កាលណាយើងនឹងថយខ្វល់ខ្វាយផ្គត់ផ្គង់ នឹងស្កប់ស្កល់បម្រើដោយកាមគុណ ៥ ៗ ម្នាលអនុរុទ្ធ ជាអនុជ ការងារមិនចេះអស់ទេ ទីបំផុតការងារក៏មិនប្រាកដ មាតាបិតាក្តី ជីតាក្តី ធ្វើមរណកាល(ទៅអស់) ឯការងារមិនចេះអស់ទេ ៗ បើដូច្នោះ អនុជឯង ចូរជ្រាបអំពីប្រយោជន៍របស់ឃរាវាសចុះ បងមុខជានឹងចេញចាកផ្ទះ ទៅបួសក្នុងសាសនា (មិនខាន) ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣) អថខោ អនុរុទ្ធោ សក្កោ យេន មាតា តេនុបសង្កមិ ឧបសង្កមិត្វា មាតរំ ឯតទវោច ឥច្ឆាមហំ អម្ម អគារស្មា អនគារិយំ បព្វជិតុំ អនុជានាហិ មំ អម្ម[១] អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ ឯវំ វុត្តេ អនុរុទ្ធស្ស សក្កស្ស មាតា អនុរុទ្ធំ សក្កំ ឯតទវោច តុម្ហេ ខោ មេ តាត អនុរុទ្ធ ទ្វេ បុត្តា បិយា មនាបា អប្បដិក្កូលា មរណេនបិ វោ អកាមកា វិនា ភវិស្សាម កឹ បនាហំ តុម្ហេ ជីវន្តេ អនុជានិស្សាមិ អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ ទុតិយម្បិ ខោ ។ បេ ។ តតិយម្បិ ខោ អនុរុទ្ធោ សក្កោ មាតរំ ឯតទវោច ឥច្ឆាមហំ អម្ម អគារស្មា អនគារិយំ បព្វជិតុំ អនុជានាហិ មំ អម្ម អគារស្មា អនគារិយំ បព្វជ្ជាយាតិ[២] ។

(៤) តេន ខោ បន សមយេន ភទ្ទិយោ សក្យរាជា សក្យានំ រជ្ជំ ការេតិ ។ សោ ច[៣] អនុរុទ្ធស្ស សក្កស្ស សហាយោ ហោតិ ។

---

១ ឱ. ម. បោត្ថកេសុ អម្មាតិ ន ទិស្សតិ ។ ២ ឥតោ បរំ ឯវំ វុត្តេ អនុរុទ្ធស្ស សក្កស្ស មាតា ឯវមាហ ។ សចេ តាត អនុរុទ្ធ ភទ្ទិយោ សក្យរាជា សក្យានំ រជ្ជំ ការេតិ អគារស្មា អនគារិយំ បព្វជតិ ។ ឯវំ បព្វជាហីតិ ឥមេ បាឋា មរម្មបោត្ថកេ ទិស្សន្តិ ។ ៣ ឱ. ម. បោត្ថកេសុ សោ ចសទ្ទោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣) ក្នុងគ្រានោះ អនុរុទ្ធសក្កៈចូលទៅរកព្រះមាតា លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះមាតាយ៉ាងនេះថា បពិត្រព្រះមាតា ខ្ញុំចង់ចេញចាកផ្ទះទៅបួសក្នុងសាសនា បពិត្រព្រះមាតា សូមព្រះមាតាអនុញ្ញាតឲ្យខ្ញុំចេញចាកផ្ទះទៅបួស ក្នុងសាសនា ។ កាលបើអនុរុទ្ធសក្កៈនិយាយយ៉ាងនេះហើយ ព្រះមាតានៃអនុរុទ្ធសក្កៈនិយាយយ៉ាងនេះថា ម្នាលអនុរុទ្ធកូន អ្នកជាបុត្រប្រុសទាំងពីររបស់យើង រមែងជាទីស្រឡាញ់ពេញចិត្ត ឥតមានស្អប់ខ្ពើមទេ សូម្បីដល់មរណភាព យើងក៏ពុំចង់ព្រាត់ប្រាសនឹងអ្នកឡើយ កាលបើអ្នករស់នៅ ៗ ឡើយ យើងធ្វើម្ដេចនឹងយល់ព្រមឲ្យអ្នកចេញចាកផ្ទះទៅបួសក្នុងសាសនាបាន ។ អនុរុទ្ធសក្កៈនិយាយនឹងព្រះមាតាយ៉ាងនេះអស់វារៈពីរដងផង ។ បេ ។ អស់វារៈបីដងផងថា បពិត្រព្រះមាតា ខ្ញុំចង់ចេញចាកផ្ទះទៅបួសក្នុងសាសនា បពិត្រព្រះមាតា សូមព្រះមាតាអនុញ្ញាត ឲ្យខ្ញុំចេញចាកផ្ទះទៅបួសក្នុងសាសនា ។

(៤) សម័យនោះឯង ភទ្ទិយសក្យរាជសោយរាជ្យជាស្ដេចរបស់សក្យៈទាំងឡាយ ។ ឯភទ្ទិយសក្យរាជនោះត្រូវជាសំឡាញ់នឹងអនុរុទ្ធសក្កៈ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ អនុរុទ្ធសក្កវត្ថុ ភទ្ទិយសក្កវត្ថុ

អថខោ អនុរុទ្ធស្ស សក្កស្ស មាតា អយំ ខោ ភទ្ទិយោ សក្យរាជា សក្យានំ រជ្ជំ ការេតិ អនុរុទ្ធស្ស សក្កស្ស សហាយោ សោ ច ឧស្សហតិ អគារស្មា អនគារិយំ បព្វជិតុន្តិ អនុរុទ្ធំ សក្កំ ឯតទវោច សចេ តាត អនុរុទ្ធ ភទ្ទិយោ សក្យរាជា អគារស្មា អនគារិយំ បព្វជតិ ឯវំ ត្វម្បិ បព្វជាហីតិ ។ អថខោ អនុរុទ្ធោ សក្កោ យេន ភទ្ទិយោ សក្យរាជា តេនុបសង្កមិ ឧបសង្កមិត្វា ភទ្ទិយំ សក្យរាជានំ ឯតទវោច មម ខោ សម្ម បព្វជ្ជា តវ បដិពទ្ធាតិ ។ សចេ តេ សម្ម បព្វជ្ជា មម បដិពទ្ធា វា[១] អប្បដិពទ្ធា វា សា ហោតុ អហំ តយា យថាសុខំ បព្វជាមីតិ ។ ឯហិ សម្ម ឧភោ អគារស្មា អនគារិយំ បព្វជិស្សាមាតិ ។ នាហំ សម្ម សក្កោមិ អគារស្មា អនគារិយំ បព្វជិតុំ យំ តេ សក្កា អញ្ញំ មយា កាតុំ ត្យាហំ ករិស្សាមិ ត្វំ បព្វជាហីតិ ។ មាតា ខោ មំ សម្ម ឯវមាហ

---

១ ឱ. ម. បោត្ថកេសុ វាសទ្ទោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ខេបកថានូក : រឿងអនុរុទ្ធសក្កៈ និងរឿងភទ្ទិយសក្យរាជ

គ្រានោះឯង ព្រះមាតារបស់អនុរុទ្ធសក្កៈទ្រង់ព្រះចិន្តាថា ព្រះភទ្ទិយសក្យរាជនេះទ្រង់សោយរាជ្យជាស្តេចរបស់ពួកសក្យៈ ស្តេចនោះជាសំឡាញ់នឹងអនុរុទ្ធសក្កៈ គង់មិនអាចចេញចាកអគារដ្ឋាន ទៅបួសក្នុងសាសនាទេ (លុះទ្រង់ព្រះចិន្តាដូច្នេះហើយ) ទើបមានព្រះសវនីយទៅនឹងអនុរុទ្ធសក្កៈទៀតថា ម្នាលអនុរុទ្ធ កូន ប្រសិនបើ ភទ្ទិយសក្យរាជ ចេញចាកផ្ទះទៅបួសក្នុងសាសនា កាលបើដូច្នេះ សឹមកូនឯងទៅបួសចុះ ។ លំដាប់នោះ អនុរុទ្ធសក្កៈចូលទៅរកព្រះភទ្ទិយសក្យរាជ លុះចូលទៅដល់ហើយទើបថ្លែងសេចក្តីនេះទៅនឹងភទ្ទិយសក្យរាជថា ម្នាលសំឡាញ់ ការបួសរបស់ខ្ញុំជាប់ទាក់ទងគ្នានឹងអ្នក ។ ភទ្ទិយសក្យរាជ ក៏ឆ្លើយតបថា ម្នាលសំឡាញ់ បើបព្វជ្ជារបស់អ្នក ជាប់ទាក់ទងគ្នានឹងខ្ញុំក្តី មិនជាប់ក្តី បព្វជ្ជានោះចូរលើកទុកចុះ យើងគង់តែនឹងបួសជាមួយអ្នកតាមសប្បាយដែរ ។ អនុរុទ្ធសក្កៈបបួលទៀតថា ម្នាលសំឡាញ់ អ្នកចូរមក យើងទាំងពីរនាក់នឹងចេញចាកផ្ទះទៅបួសក្នុងសាសនា ។ ព្រះភទ្ទិយសក្យរាជតបថា ម្នាលសំឡាញ់ ខ្ញុំមិនអាចចេញចាកផ្ទះទៅបួសក្នុងសាសនាបានទេ កិច្ចឯទៀតដែលខ្ញុំល្មមធ្វើជូនអ្នកបាន ខ្ញុំនឹងធ្វើជូនអ្នក អ្នកចូរបួសចុះ ។ អនុរុទ្ធសក្កៈនិយាយថា ម្នាលសំឡាញ់ ព្រះមាតានិយាយនឹងខ្ញុំយ៉ាងនេះថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សចេ តាត អនុរុទ្ធ ភទ្ទិយោ សក្យរាជា អគារស្មា អនគារិយំ បព្វជតិ ឯវំ ត្វំបិ បព្វជាហីតិ ។ ភាសិតា ខោ បន តេ សម្ម ឯសា វាចា សចេ តេ សម្ម បព្វជ្ជា មម បដិពទ្ធា វា អប្បដិពទ្ធា វា សា ហោតុ អហំ តយា យថាសុខំ បព្វជាមីតិ ។ ឯហិ សម្ម ឧភោ អគារស្មា អនគារិយំ បព្វជិស្សាមាតិ ។ តេន ខោ បន សមយេន មនុស្សា សច្ចភណិនោ ហោន្តិ សច្ចប្បដិញ្ញាតា(១) ។ អថខោ ភទ្ទិយោ សក្យរាជា អនុរុទ្ធំ សក្យំ ឯតទវោច អាគមេហិ សម្ម សត្ត វស្សានិ សត្តន្នំ វស្សានំ អច្ចយេន ឧភោបិ អគារស្មា អនគារិយំ បព្វជិស្សាមាតិ ។ អតិចិរំ សម្ម សត្ត វស្សានិ នាហំ សក្កោមិ សត្ត វស្សានិ អាគមេតុន្តិ ។ អាគមេហិ សម្ម ឆ វស្សានិ ។ បេ ។ បញ្ច វស្សានិ ចត្តារិ វស្សានិ តីណិ វស្សានិ ទ្វេ វស្សានិ ឯកំ វស្សំ ឯកស្ស វស្សស្ស អច្ចយេន ឧភោបិ អគារស្មា អនគារិយំ បព្វជិស្សាមាតិ ។ អតិចិរំ សម្ម ឯកំ វស្សំ នាហំ សក្កោមិ

---

១ ឱ. ម. សច្ចប្បដិញ្ញា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដក ចុល្លវគ្គ

ម្នាលអនុរុទ្ធ បើភទ្ទិយសក្យរាជចេញចាកផ្ទះទៅបួស ក្នុងសាសនា កាល បើដូច្នោះ អ្នកឯង ចូរបួសចុះ ។ ភទ្ទិយសក្យរាជ ឆ្លើយថា ម្នាល សំឡាញ់ ខ្ញុំបាននិយាយហើយទាំងចំពោះអ្នកមែនថា ម្នាលសំឡាញ់ បើ បព្វជ្ជារបស់អ្នកជាប់ទាក់ទងនឹងខ្ញុំក្តី មិនជាប់ក្តី បព្វជ្ជានោះលើកទុកទៅ ចុះ ខ្ញុំគង់តែនឹងបួសជាមួយនឹងអ្នកតាមសប្បាយដែរ ។ អនុរុទ្ធបបួលថា ម្នាលសំឡាញ់ អ្នកចូរមក យើងទាំងពីរនាក់នឹងចេញចាកផ្ទះទៅបួសក្នុង សាសនា ។ ក្នុងសម័យនោះ ពួកមនុស្ស ច្រើននិយាយពាក្យសច្ចៈ រក្សា គ្នាដោយពាក្យសច្ចៈ ។ លំដាប់នោះ ព្រះភទ្ទិយសក្យរាជតបនឹងអនុរុទ្ធសក្កៈ យ៉ាងនេះថា ម្នាលសំឡាញ់ អ្នកចូរបង្អង់ ៧ ឆ្នាំសិន លុះអំណើះ ៧ ឆ្នាំទៅ យើងទាំងពីរនាក់នឹងចេញចាកផ្ទះ ទៅបួសក្នុងសាសនា ។ អនុរុទ្ធសក្កៈ ឆ្លើយតបថា ម្នាលសំឡាញ់ ៧ ឆ្នាំនោះយូរណាស់ ខ្ញុំមិនអាចនឹងបង្អង់ ចាំដល់ ៧ ឆ្នាំទេ ។ ព្រះភទ្ទិយសក្យរាជ ឆ្លើយថា ម្នាលសំឡាញ់ អ្នក ចូររង់ចាំ ៦ ឆ្នាំចុះ ។បេ។ ៥ ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំចុះ លុះអំណើះ ១ ឆ្នាំទៅ យើងទាំងពីរនាក់នឹងចេញចាកផ្ទះទៅបួសក្នុងសាសនា។ អនុរុទ្ធ សក្កៈបបួលទៀតថា ម្នាលសំឡាញ់ ១ ឆ្នាំនោះយូរពេកណាស់ ខ្ញុំមិនអាច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ សត្តជិនវត្ថុ

ឯកំ វស្សំ អាគមេតុំ ។ អាគមេហិ សម្ម សត្ត មាសេ សត្តន្នំ មាសានំ អច្ចយេន ឧភោបិ អគារស្មា អនគារិយំ បព្វជិស្សាមាតិ ។ អតិចិរំ សម្ម សត្ត មាសា ណាហំ សក្កោមិ សត្ត មាសេ អាគមេតុំ ។ អាគមេហិ សម្ម ឆ មាសេ ។ បេ ។ បញ្ច មាសេ ចត្តារោ មាសេ តយោ មាសេ ទ្វេ មាសេ ឯកំ មាសំ អឌ្ឍមាសំ អឌ្ឍមាសស្ស អច្ចយេន ឧភោបិ អគារស្មា អនគារិយំ បព្វជិស្សាមាតិ ។ អតិចិរំ សម្ម អឌ្ឍមាសោ ណាហំ សក្កោមិ អឌ្ឍមាសំ អាគមេតុំ ។ អាគមេហិ សម្ម សត្តាហំ យាវាហំ បុត្តេ ច ភាតរោ ច រជ្ជំ និយ្យាតេស្សាមីតិ(1) ។ ន ចិរំ សម្ម សត្តាហោ អាគមេស្សាមីតិ ។

[៤] អថខោ ភទ្ទិយោ ច សក្យរាជា អនុរុទ្ធោ ច អានន្ទោ ច ភគុ ច កិមិលោ ច(2) ទេវទត្តោ ច ឧបាលិកប្បកោ សត្តមោ យថា បុរេ ច ចតុរង្គិនិយា សេនាយ ឧយ្យានភូមឹ និយ្យន្តិ ឯវមេវ ចតុរង្គិនិយា

---

១ ឱ. ម និយ្យាទេមីតិ ។ ២ ឱ ភគុ ច កិម្ពិលោ ច ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



## សង្ឃភេទក្ខន្ធកៈ ភទ្ទិយកវត្ថុ

នឹងរង់ចាំទៅដល់ ១ ឆ្នាំបានទេ ។ ព្រះភទ្ទិយសក្យរាជអង្វរទៀតថា ម្នាលសំឡាញ់ អ្នកចូរបង្អង់ ៧ ខែចុះ លុះអំណើះ ៧ ខែទៅ យើងទាំងពីរនាក់នឹងចេញចាកផ្ទះទៅបួសក្នុងសាសនា ។ អនុរុទ្ធសក្កៈតបថា ម្នាលសំឡាញ់ ៧ ខែនោះយូរណាស់ ខ្ញុំមិនអាចនឹងរង់ចាំដល់ទៅ ៧ខែបានទេ ។ ព្រះភទ្ទិយសក្យរាជអង្វរថា ម្នាលសំឡាញ់ អ្នកចូរបង្អង់ដល់ ៦ ខែ ។បេ។ ៥ ខែ ៤ ខែ ៣ ខែ ២ ខែ ១ ខែ កន្លះខែចុះ លុះអំណើះកន្លះខែទៅ សឹមយើងទាំងពីរនាក់ ចេញចាកផ្ទះទៅបួសក្នុងសាសនា ។ អនុរុទ្ធសក្កៈតបទៀតថា ម្នាលសំឡាញ់ កន្លះខែយូរពេកណាស់ ខ្ញុំមិនអាចនឹងរង់ចាំដល់កន្លះខែបានទេ ។ ព្រះភទ្ទិយសក្យរាជអង្វរចុះមកទៀតថា ម្នាលសំឡាញ់ អ្នកចូរបង្អង់ ៧ ថ្ងៃសិន ទម្រាំតែខ្ញុំនឹងប្រគល់រាជ្យសម្បត្តិឲ្យកូនឬបងប្អូន ។ អនុរុទ្ធសក្កៈទទួលព្រមថា ម្នាលសំឡាញ់ ៧ថ្ងៃនោះមិនជាយូរប៉ុន្មានទេ ខ្ញុំនឹងរង់ចាំបាន ។

(៥) គ្រានោះឯង (ពួកសក្យៈទាំង ៦ អង្គ) គឺភទ្ទិយសក្យរាជ ១ អនុរុទ្ធ ១ អានន្ទ ១ ភគ្គុ ១ កិម្ពិល ១ ទេវទត្ត ១ ជាគំរប់ ៧ នាក់ទាំងខ្ញុំព្រះកេសាឈ្មោះឧបាលិ ចេញទៅកាន់ឧទ្យាន មួយអន្លើដោយសេនាមានអង្គ ៤ ក្នុងកាលពីដើមយ៉ាងណា សក្យរាជទាំងនោះ យាងចេញទៅ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេនាយ និយ្យិំសុ ។ តេ ទូរំ គន្ត្វា សេនំ និវត្តាបេត្វា បរវិសយំ ឱក្កមិត្វា អាភរណំ ឱមុញ្ចិត្វា ឧត្តរាសង្គេន ភណ្ឌិកំ ពន្ធិត្វា ឧបាលឹ កប្បកំ ឯតទវោចុំ ហន្ទ ភណេ ឧបាលិ និវត្តស្សុ អលន្តេ ឯត្តកំ ជីវិកាយាតិ ។

[៦] អថខោ ឧបាលិស្ស កប្បកស្ស និវត្តន្តស្ស ឯតទហោសិ ចណ្ឌា ខោ សាកិយា ឥមិនា កុមារា និប្បាតិតាតិ ឃាតាបេយ្យុម្បិ មំ ឥមេ ហិ នាម សក្យ-កុមារា អគារស្មា អនគារិយំ បព្វជិស្សន្តិ កិមង្គំ បនាហន្តិ ។ សោ ភណ្ឌិកំ មុញ្ចិត្វា តំ ភណ្ឌំ រុក្ខេ អាលគ្គេត្វា យោ បស្សតិ ទិន្នំយេវ ហរតូតិ វត្វា យេន តេ សក្យកុមារា តេនុបសង្កមិ ។ អទ្ទសំសុ ខោ តេ សក្យកុមារា ឧបាលឹ កប្បកំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន ឧបាលឹ កប្បកំ ឯតទវោចុំ កិស្ស ភណេ ឧបាលិ និវត្តោសីតិ ។ ឥធ មេ អយ្យបុត្តា និវត្តន្តស្ស

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



(ដើម្បីបញ្ជាមួយអន្លើ) ដោយសេនាមានអង្គ ៤ ក៏យ៉ាងនោះដែរ ។ សក្យៈទាំងនោះ លុះយាងទៅដល់ទីឆ្ងាយ ទើបឲ្យសេនាវិលមកវិញ លុះចូលទៅដល់ដែនដទៃហើយ ទើបដោះគ្រឿងប្រដាប់រៀបជាបង្វេចដោយព្រះពស្ត្រសម្រាប់ពាក់ រួចហើយទើបមានព្រះបន្ទូលទៅនឹងខ្ជាន់ព្រះកេសឈ្មោះឧបាលិថា នែនាយឧបាលិ ណ្ហើយនាយឧបាលិ ចូរអ្នកឯងវិលទៅវិញចុះ ទ្រព្យប៉ុណ្ណោះក៏ល្មមនឹងចិញ្ចឹមជីវិតរបស់អ្នកបានហើយ ។

( ៦ ) គ្រានោះឯង កាលឧបាលិកប្បកៈកំពុងតែដើរវិលមកវិញក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកសក្យៈសុទ្ធតែជាអ្នកកាច ។ នឹងសម្លាប់អញក៏បាន ព្រោះគិតថា ឧបាលិកប្បកៈនេះហើយ សម្លាប់ព្រះរាជកុមារ អម្បាលសក្យកុមារទាំងឡាយ ម្តេចគង់ចេញចាកអគារដ្ឋាន ទៅបួសក្នុងសាសនាបាន ចំណាន់បើអញនឹងបាច់និយាយទៅថ្វី ។ ឧបាលិកប្បកៈនោះក៏ស្រាយបង្វេចចេញ ហើយព្យួររបស់នោះលើដើមឈើ ទើបនិយាយថា បើអ្នកណាឃើញ ចូររើសយករបស់ដែលអញឲ្យហើយចុះ ហើយដើរចូលទៅរកពួកសក្យកុមារវិញ ។ ពួកសក្យកុមារទាំងនោះបានឃើញឧបាលិ-កប្បកៈកំពុងដើរមកអំពីចម្ងាយហើយ ទើបនិយាយទៅនឹងឧបាលិកប្បកៈយ៉ាងនេះថា នែនាយឧបាលិ ហេតុដូចម្តេចបានជាអ្នកវិលមកវិញ ។ ឧបាលិកប្បកៈក៏ក្រាបទូលថា បពិត្រព្រះអយ្យបុត្ត កាលដែលខ្ញុំព្រះអង្គ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឯតទហោសិ ចណ្ឌា ខោ សាកិយា ឥមិនា កុមារា និប្បាតិតាតិ ឃាតាបេយ្យុំបិ មំ ឥមេ ហិ នាម សក្យកុមារា អគារស្មា អនគារិយំ បព្វជិស្សន្តិ កិមង្គំ បនាហន្តិ សោ ខោ អហំ អយ្យបុត្តា ភណ្ឌិកំ មុញ្ចិត្វា តំ ភណ្ឌំ រុក្ខេ អាលគ្គេត្វា យោ បស្សតិ ទិន្នំយេវ ហរតូតិ វត្វា តតោម្ហិ(១) បដិនិវត្តោតិ ។ សុដ្ឋុ ភណេ ឧបាលិ អកាសិ យំ បន និវត្តោ(២) ចណ្ឌា ខោ(៣) សាកិយា ឥមិនា កុមារា និប្បាតិតាតិ ឃាតាបេយ្យុំបិ តន្តិ ។

[៧] អថ ខោ តេ សក្យកុមារា ឧបាលឹ កប្បកំ អាទាយ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ សក្យកុមារា ភគវន្តំ ឯតទវោចុំ មយំ ភន្តេ សាកិយា នាម មានស្សិនោ អយំ ភន្តេ ឧបាលិ កប្បកោ អម្ហាកំ ទីឃរត្តំ បរិចារកោ ឥមំ ភគវា

---

១ ម. អាគតោម្ហិ ។ ២ ឱ. ម. យំបិ ន និវត្តោ ។ ៣ ឱ. បោត្ថកេ ខោសទ្ទោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ ការដែលពួកសក្យកុមារចូលទៅគាល់ព្រះមានព្រះភាគ

វិលអំពីទីនេះទៅ ក៏ក្ដុកមានសេចក្តីត្រិះរិះដូច្នេះថា ពួកសក្យរាជសុទ្ធតែកាច ៗ នឹងសម្លាប់ខ្ញុំព្រះអង្គចោលក៏បាន ព្រោះគិតថា ខ្ញុំព្រះអង្គនេះហើយដែលសម្លាប់ព្រះរាជកុមារ អម្បាលពួកសក្យកុមារនេះ(ម្តេចក៏)ចេញចាកគេហដ្ឋាន ទៅបួសក្នុងសាសនា ចុះនឹងចាំស្តាំទៅថ្វីដល់ខ្លួនខ្ញុំព្រះអង្គ បពិត្រព្រះអយ្យបុត្ត ខ្ញុំព្រះអង្គស្រាយបង្វិចចេញហើយ ព្យួររបស់នោះលើដើមឈើហើយនិយាយថា បើអ្នកណាឃើញ ចូររើសយករបស់ដែលអញឲ្យហើយចុះ ខ្ញុំព្រះអង្គក៏វិលអំពីទីនោះមកវិញ ៗ ពួកសក្យ-កុមារនិយាយថា នែនាយឧបាលិ ដែលអ្នកត្រឡប់មកវិញនោះឈ្មោះថាបានធ្វើប្រពៃហើយ ដ្បិតពួកសក្យៈកាច ៗ ណាស់ នឹងសម្លាប់អ្នកចោលក៏បាន ព្រោះគិតថា អ្នកនេះហើយជាអ្នកសម្លាប់ព្រះរាជកុមារទាំងឡាយ ៗ

(៧) គ្រានោះ ពួកសក្យកុមារទាំងនោះនាំឧបាលិកប្បកៈចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំចំពោះព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ៗ ពួកសក្យកុមារទាំងនោះ លុះអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំជាសក្យរាជ តែងមានមានះ បពិត្រព្រះអង្គដ៏ចំរើន ឧបាលិកប្បកៈនេះជាអ្នកធ្លាប់បម្រើយើងខ្ញុំអស់កាលជាអង្វែងមកហើយ សូមព្រះមានព្រះភាគបំបួសឧបាលិកប្បកៈ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បឋមំ បព្វាជេតុ ឥមស្ស អយំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ ករិស្សតិ ឯវំ អម្ហាកំ សាកិយានំ សាកិយមានោ និម្មានយិស្សតីតិ [១] ។ អថខោ ភគវា ឧបាលឹ កប្បកំ បឋមំ បព្វាជេសិ បច្ឆា តេ សាក្យកុមារេ ។

[៨] អថខោ អាយស្មា ភទ្ទិយោ តេនេវ អន្តរវស្សេន តិស្សោ វិជ្ជា សច្ឆាកាសិ ។ អាយស្មា អនុរុទ្ធោ ទិព្វចក្ខុំ ឧប្បាទេសិ ។ អាយស្មា អានន្ទោ សោតាបត្តិផលំ សច្ឆាកាសិ ។ ទេវទត្តោ បោថុជ្ជនិកំ ឥទ្ធឹ អភិនិប្ផាទេសិ [២] ។

[៩] តេន ខោ បន សមយេន អាយស្មា ភទ្ទិយោ អរញ្ញគតោបិ រុក្ខមូលគតោបិ សុញ្ញាគារគតោបិ អភិក្ខណំ ឧទានំ ឧទានេសិ អហោ សុខំ អហោ សុខន្តិ។ អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ

---

១ ឱ. ប. និម្មានិយិស្សតីតិ ។ ២. ឱ. ប, អភិនិព្វត្តេសិ ។

នេះមុន យើងខ្ញុំនឹងធ្វើនូវអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលីកម្ម និងសាមីចិកម្ម ចំពោះឧបាលិកប្បកៈនេះ កាលបើយើងខ្ញុំបានធ្វើយ៉ាងនេះហើយ សេចក្តីប្រកាន់ថា ខ្លួនយើងខ្ញុំជាសក្យៈនោះនឹងថយចុះទៅ ។ លំដាប់នោះឯង ព្រះមានព្រះភាគបានបំបួសឧបាលិកប្បកៈមុន ហើយទើបបំបួសពួកសក្យកុមារទាំងនោះក្រោយ ។

(៨) គ្រានោះ ព្រះភទ្ទិយៈដ៏មានអាយុ បានសម្រេចនូវវិជ្ជាបីយ៉ាង ខាងក្នុងនៃវស្សានោះឯង ។ ព្រះអនុរុទ្ធដ៏មានអាយុបានសម្រេចទិព្វចក្ខុ ។ ព្រះអានន្ទដ៏មានអាយុ បានសម្រេចសោតាបត្តិផល ។ ឯទេវទត្ត បានសម្រេចនូវឫទ្ធិជារបស់បុថុជ្ជន ។

(៩) សម័យនោះឯង ព្រះភទ្ទិយៈដ៏មានអាយុទៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី បន្លឺនូវឧទានជារឿយ ៗ ថា ឱសុខអ៊ីម្ល៉េះ ឱសុខអ៊ីម្ល៉េះ ។ លំដាប់នោះ ពួកភិក្ខុច្រើនរូបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ពួកភិក្ខុទាំងនោះ លុះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## សង្ឃភេទក្ខន្ធកេ ភទ្ទិយភិក្ខុវត្ថុ

អាយស្មា ភន្តេ ភទ្ទិយោ អរញ្ញគតោបិ រុក្ខមូលគតោបិ សុញ្ញាគារគតោបិ អភិក្ខណំ ឧទានំ ឧទានេសិ អហោ សុខំ អហោ សុខន្តិ និស្សំសយំ ខោ ភន្តេ អាយស្មា ភទ្ទិយោ អនភិរតោ ព្រហ្មចរិយំ ចរតិ តំយេវ បុរិមំ រជ្ជសុខំ សមនុស្សរន្តោ អរញ្ញគតោបិ រុក្ខមូលគតោបិ សុញ្ញាគារគតោបិ អភិក្ខណំ ឧទានំ ឧទានេសិ អហោ សុខំ អហោ សុខន្តិ ។ អថខោ ភគវា អញ្ញតរំ ភិក្ខុំ អាមន្តេសិ ឯហិ ត្វំ ភិក្ខុ មម វចនេន ភទ្ទិយំ ភិក្ខុំ អាមន្តេហិ សត្ថា តំ អាវុសោ ភទ្ទិយ អាមន្តេតីតិ ។ ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុត្វា យេនាយស្មា ភទ្ទិយោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ភទ្ទិយំ ឯតទវោច សត្ថា តំ អាវុសោ ភទ្ទិយ អាមន្តេតីតិ ។

(១០) ឯវមាវុសោតិ ខោ អាយស្មា ភទ្ទិយោ តស្ស ភិក្ខុនោ បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ រឿងជិនទាំង ៧

បពិត្រព្រះអង្គដ៏ចំរើន ព្រះភទ្ទិយៈដ៏មានអាយុ ទៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺនូវឧទានជារឿយៗថា ឱសុខអើយម្ល៉េះ ឱសុខអើយម្ល៉េះ បពិត្រព្រះអង្គដ៏ចំរើន ព្រះភទ្ទិយៈដ៏មានអាយុ ប្រាកដជាអផ្សុកនឹងប្រព្រឹត្តព្រហ្មចរិយធម៌ដោយពិត ពុំនោះសោត លោករលឹកនូវសេចក្តីសុខក្នុងរាជសម្បត្តិពីមុននោះឯង បានជាទៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺនូវឧទានជារឿយៗថា ឱសុខអើយម្ល៉េះ ឱសុខអើយម្ល៉េះ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុ ១ រូបមក ហើយបង្គាប់ថា ម្នាលភិក្ខុ អ្នកចូរមក ចូរអ្នកទៅហៅភទ្ទិយភិក្ខុតាមពាក្យតថាគតថា ម្នាលអាវុសោភទ្ទិយៈ ព្រះសាស្តាទ្រង់ឲ្យហៅអ្នក ។ ភិក្ខុនោះទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន យ៉ាងនេះហើយ ក៏ចូលទៅរកភទ្ទិយភិក្ខុដ៏មានអាយុ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះនឹងភទ្ទិយភិក្ខុដ៏មានអាយុថា ម្នាលអាវុសោភទ្ទិយៈ ព្រះសាស្តាត្រាស់ហៅអ្នក ។

(១០) ព្រះភទ្ទិយៈដ៏មានអាយុ ទទួលស្តាប់ពាក្យរបស់ភិក្ខុនោះថា ម្នាលអាវុសោ ដូច្នេះហើយ ក៏ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ ភទ្ទិយំ ភគវា ឯតទវោច សច្ចំ កិរ ត្វំ ភទ្ទិយ អរញ្ញគតោបិ រុក្ខមូលគតោបិ សុញ្ញាគារគតោបិ អភិក្ខណំ ឧទានំ ឧទានេសិ អហោ សុខំ អហោ សុខន្តិ ។ ឯវម្ភន្តេតិ ។ កឹ បន ត្វំ ភទ្ទិយ អត្ថវសំ សម្បស្សមានោ អរញ្ញគតោបិ រុក្ខមូលគតោបិ សុញ្ញាគារគតោបិ អភិក្ខណំ ឧទានំ ឧទានេសិ អហោ សុខំ អហោ សុខន្តិ ។ បុព្វេ មេ ភន្តេ រញ្ញោ សតោបិ(១) អន្តោបិ អន្តេបុរេ រក្ខា សុសំវិហិតា ហោតិ ពហិបិ អន្តេបុរេ រក្ខា សុសំវិហិតា ហោតិ អន្តោបិ នគរេ រក្ខា សុសំវិហិតា ហោតិ ពហិបិ នគរេ រក្ខា សុសំវិហិតា ហោតិ អន្តោបិ ជនបទេ រក្ខា សុសំវិហិតា ហោតិ ពហិបិ ជនបទេ រក្ខា សុសំវិហិតា ហោតិ សោ ខោ អហំ ភន្តេ ឯវំ រក្ខិតោបិ គោបិតោបិ សន្តោ ភីតោ ឧព្វិគ្គោ ឧស្សង្កី ឧត្រស្តោ វិហាសឹ ឯតរហិ ខោ បនាហំ ឯកោ(២) ភន្តេ អរញ្ញគតោបិ រុក្ខមូលគតោបិ សុញ្ញាគារគតោបិ

១ ឱ. ម. រញ្ញោ សតោ ។ ២ ឱ. ម. បោត្ថកេសុ អយំ សទ្ទោ នត្ថិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



វិនយបិដក ចុល្លវគ្គ

ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះនឹងព្រះភទ្ទិយៈដ៏មានអាយុ ដែលអង្គុយក្នុងទីដ៏សមគួរថា ម្នាលភទ្ទិយៈ បានឮថា អ្នកទៅក្នុងព្រៃក្តី ទៅក្រោមម្លប់ឈើក្តី ទៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺឧទានជារឿយ ៗ ថា ឱសុខអើយម៉្លេះ ឱសុខអើយម៉្លេះ ពិតមែនឬ ។ ភទ្ទិយភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ពិតមែន ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភទ្ទិយៈ ចុះអ្នកពិចារណាឃើញអំណាចប្រយោជន៍យ៉ាងណា បានជាអ្នកទៅក្នុងព្រៃក្តី ទៅក្រោមម្លប់ឈើក្តី ទៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺឧទានជារឿយៗ ថា ឱសុខអើយម៉្លេះ ឱសុខអើយម៉្លេះ ដូច្នេះ ។ ភទ្ទិយភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលពីដើមខ្ញុំព្រះអង្គនៅជាស្តេច ការរក្សាខាងក្នុងព្រះរាជវាំង គេបានចាត់ចែងល្អ ការរក្សាខាងក្រៅព្រះរាជវាំង គេបានចាត់ចែងល្អ ការរក្សាខាងក្នុងនគរ គេបានចាត់ចែងល្អ ការរក្សាខាងក្រៅនគរ គេបានចាត់ចែងល្អ ការរក្សាខាងក្នុងជនបទ គេបានចាត់ចែងល្អ ការរក្សាខាងក្រៅជនបទ គេក៏បានចាត់ចែងល្អ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះឯង ជាមនុស្សដែលគេរក្សាមកយ៉ាងនេះផង គ្រប់គ្រងយ៉ាងនេះផង គង់នៅមានខ្លាច ញាប់ញ័រ រន្ធត់ តក់ស្លុត បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះអង្គតែម្នាក់ឯង ក៏ទៅក្នុងព្រៃក្តី ទៅក្រោមម្លប់ឈើក្តី ទៅក្នុងផ្ទះស្ងាត់ក្តី

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អភីតោ អនុព្វិគ្គោ អនុស្សង្កី អនុត្រាស្តោ អប្បោស្សុក្កោ (១) បន្នលោមោ បរទត្តវុត្តោ មិគភូតេន ចេតសា វិហរាមីតិ ឥមំ ខោ អហំ ភន្តេ អត្ថវសំ សម្បស្សមានោ អរញ្ញគតោបិ ។ បេ ។ អភិក្ខណំ ឧទានំ ឧទានេមិ អហោ សុខំ អហោ សុខន្តិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

(១១) យស្សន្តរតោ ន សន្តិ កោបា
ឥតិភវាភវតញ្ច វីតិវត្តោ
តំ វិគតភយំ សុខិំ អសោកំ
ទេវា នានុភវន្តិ ទស្សនាយាតិ ។

(១២) អថខោ ភគវា អនុបិយាយំ យថាភិរន្តំ វិហរិត្វា យេន កោសម្ពី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន កោសម្ពី តទវសរិ ។ តត្រ សុទំ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។

---

១ ឱ. ម. ពោទ្ធកេសុ ឥតិសទ្ទោ នត្ថិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



## សង្ខេបខុទ្ទកៈ ឧទានគាថានិងរឿងទេវទត្តភិក្ខុ

ក៏ឥតខ្លាច ឥតញាប់ញ័រ ឥតរន្ធត់ តក់ស្លុតឡើយ ជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ជាមនុស្សស្រួលបរោប ចិញ្ចឹមជីវិតដោយបច្ច័យដែលបុគ្គលដទៃឲ្យ មានចិត្តដូចជាពួកសត្វម្រឹគ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គពិចារណាឃើញនូវអំណាចប្រយោជន៍យ៉ាងនេះហើយ ទើបបានទៅក្នុងព្រៃក្តី ។ បេ ។ តែងបន្លឺឧទានជារឿយ ៗ ថា ឱសុខអើយ ឱសុខអើយ ដូច្នេះ ។ លំដាប់នោះ ព្រះមានព្រះភាគជ្រាបច្បាស់នូវសេចក្តីនុះហើយ ទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

(១១) សេចក្តីក្រោធមិនមានក្នុងចិត្តរបស់អ្នកណា អ្នកនោះឈ្មោះថា កន្លងផុតនូវសេចក្តីចំរើននិងសេចក្តីវិនាស ច្រើនប្រការ ទេវតាទាំងឡាយ ក៏កម្រនឹងបានឃើញនូវអ្នកដែលមានភ័យកន្លងផុតហើយ បានប្រកបដោយសេចក្តីសុខ ឥតមានសេចក្តីសោកនោះឡើយ ។

(១២) គ្រានោះឯង ព្រះមានព្រះភាគ ព្រះអង្គគង់នៅក្នុងព្រៃអនុបិយា គួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់យាងសំដៅទៅកាន់ចារិកនគរកោសម្ពី ត្រាច់ទៅកាន់ចារិកតាមលំដាប់ ឆ្ពោះទៅនគរកោសម្ពី ។ បានឮថា ព្រះមានព្រះភាគទ្រង់សម្រេចព្រះឥរិយាបថ ក្នុងឃោសិតារាម ទៀបនគរកោសម្ពីនោះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដកេ ចុល្លវគ្គោ

(១១) អថខោ ទេវទត្តស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ កំ នុ ខោ អហំ បសាទេយ្យំ យស្មឹ មេ បសន្នេ ពហុ លាភសក្ការោ ឧប្បជ្ជេយ្យាតិ ។ អថខោ ទេវទត្តស្ស ឯតទហោសិ អយំ ខោ អជាតសត្តុ កុមារោ តរុណោ ចេវ អាយតិំ ច ភទ្រោ យន្នូនាហំ អជាតសត្តុំ កុមារំ បសាទេយ្យំ តស្មឹ មេ បសន្នេ ពហុ លាភសក្ការោ ឧប្បជ្ជិស្សតីតិ ។ អថខោ ទេវទត្តោ សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ យេន រាជគហំ តេន បក្កាមិ អនុបុព្វេន យេន រាជគហំ តទវសរិ ។ អថខោ ទេវទត្តោ សកវណ្ណំ បដិសំហរិត្វា កុមារវណ្ណំ អភិនិម្មិនិត្វា អហិមេខលិកាយ អជាតសត្តុស្ស កុមារស្ស ឧច្ឆង្គេ(១) បាតុរហោសិ ។ អថខោ អជាតសត្តុ កុមារោ ភីតោ អហោសិ ឧព្វិគ្គោ ឧស្សង្កី ឧត្រស្តោ ។ អថខោ ទេវទត្តោ អជាតសត្តុំ កុមារំ ឯតទវោច ភាយសិ មំ ត្វំ កុមារាតិ ។ អាម ភាយាមិ កោសិ ត្វន្តិ ។ អហំ ទេវទត្តោតិ ។

---

១ ឱ. ម. ឧច្ឆង្កេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[១៣] គ្រានោះ ទេវទត្តទៅក្នុងទីស្ងាត់ សម្ងំនៅក្នុងទីស្ងាត់ កើតសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា អញនឹងឲ្យអ្នកណាជ្រះថ្លាហ្ន៎ កាលបើអ្នកណាកើតចិត្តជ្រះថ្លាចំពោះអញ លាភសក្ការៈច្រើន មុខជានឹងកើតដល់អញពុំខាន ។ គ្រានោះ ទេវទត្តមានសេចក្តីត្រិះរិះដូច្នេះថា អជាតសត្តុកុមារនេះនៅក្មេងផង មានសេចក្តីចំរើនតទៅទៀតផង បើដូច្នោះគួរអញឲ្យអជាតសត្តុកុមារជ្រះថ្លា កាលបើអជាតសត្តុកុមារនោះ មានចិត្តជ្រះថ្លាចំពោះអញហើយ លាភសក្ការៈច្រើន មុខជានឹងកើតឡើងដល់អញ ។ លំដាប់នោះ ទេវទត្តរៀបចំភេសនៈប្រដាប់បាត្រនឹងចីវរ សំដៅទៅនគររាជ-គ្រឹះតាមលំដាប់លំដោយ ត្រាច់ទៅនគររាជគ្រឹះនោះ ។ គ្រានោះ ទេវទត្តដាំណងភេទខ្លួន ទើបធ្វើឫទ្ធិនិម្មិតជាក្មេងពាក់សង្វារពស់ ស្រាប់តែទៅអង្គុយលើភ្លៅអជាតសត្តុកុមារភ្លាម ។ គ្រានោះ អជាតសត្តុកុមារភ័យខ្លាចញាប់ញ័ររន្ធត់តក់ស្លុត ។ លំដាប់នោះ ទេវទត្តបាននិយាយពាក្យនេះនឹងអជាត-សត្តុកុមារថា បពិត្រកុមារ ព្រះអង្គខ្លាចអាត្មាឬ ។ អជាតសត្តុកុមារឆ្លើយថា អើខ្ញុំខ្លាច ចុះអ្នកជាអ្វី ។ ទេវទត្តថា អាត្មានេះជាភិក្ខុឈ្មោះទេវទត្ត ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



សចេ ខោ ត្វំ ភន្តេ អយ្យោ ទេវទត្តោ ឥង្ឃ សកេន វណ្ណេន បាតុភវស្សូតិ។ អថខោ ទេវទត្តោ កុមារកវណ្ណំ បដិសំហរិត្វា សង្ឃាដិបត្តចីវរធរោ អជាតសត្តុស្ស កុមារស្ស បុរតោ អដ្ឋាសិ ។ អថខោ អជាតសត្តុ កុមារោ ទេវទត្តស្ស ឥមិនា ឥទ្ធិបាដិហារិយេន អភិប្បសន្នោ បញ្ចហិ រថសតេហិ សាយំ បាតំ ឧបដ្ឋានំ គច្ឆតិ បញ្ច ច ថាលិបាកសតានិ ភត្តាភិហារោ អភិហរិយ្យតិ។ អថខោ ទេវទត្តស្ស លាភសក្ការសិលោកេន អភិភូតស្ស បរិយាទិន្នចិត្តស្ស ឯវរូបំ ឥច្ឆាគតំ ឧប្បជ្ជិ អហំ ភិក្ខុសង្ឃំ បរិហរិស្សាមីតិ សហ ចិត្តុប្បាទា ច ទេវទត្តោ តស្សា ឥទ្ធិយា បរិហាយិ ។

(១៤) តេន ខោ បន សមយេន កក្កុធោ(១) នាម កោលិយបុត្តោ អាយស្មតោ មហាមោគ្គល្លានស្ស ឧបដ្ឋាកោ អធុនា កាលកតោ អញ្ញតរំ មនោមយំ កាយំ ឧបបន្នោ ។ តស្ស ឯវរូបោ អត្តភាវប្បដិលាភោ ហោតិ សេយ្យថាបិ នាម ទ្វេ វា តីណិ វា មាគធិកានិ គាមក្ខេត្តានិ។ សោ តេន អត្តភាវប្បដិលាភេន នេវ

១ ឱ· ម· កកុធោ ។

## សង្ឃភេទក្ខន្ធកៈ រឿងកូនអ្នកស្រុកកោឡិយៈ ឈ្មោះកក្កុធៈ

អជាតសត្តុកុមារថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ឈ្មោះទេវទត្តមែន សូមផ្លាស់មកជាភេទរបស់ខ្លួនវិញមើល ។ គ្រានោះ ទេវទត្តផ្លាស់ភេទក្មេងតូចចេញហើយ ត្រឡប់មកជាភិក្ខុ ទ្រទ្រង់សង្ឃាដិបាត្រនិងចីវរ ឈរពីខាងមុខអជាតសត្តុកុមារ ។ លំដាប់នោះ អជាតសត្តុកុមារមានចិត្តជ្រះថ្លាពេក ដោយឥទ្ធិប្បាដិហារ្យនេះរបស់ទេវទត្ត ហើយតែងទៅដោយរថប្រាំរយ បម្រើតាំងល្ងាចតាំងព្រឹក តាំងឲ្យអ្នកនាំសម្រាប់ យកសម្រាប់ប្រាំរយថាសទៅផង ។ គ្រានោះ ទេវទត្តដែលលាភសក្ការៈនិងសេចក្តីសរសើរគ្របសង្កត់ហើយ ក៏មានចិត្តប្រែប្រួល កើតមានសេចក្តីប្រាថ្នាមានសភាពយ៉ាងនេះថា អញនឹងគ្រប់គ្រងនូវភិក្ខុសង្ឃ ដូច្នេះ ទេវទត្តក៏សាបសូន្យចាកឫទ្ធិនោះ ក្នុងពេលជាមួយនឹងអកុសលចិត្តកើតឡើង ។

(១៨) សម័យនោះឯង មានកូនអ្នកស្រុកកោឡិយៈម្នាក់ឈ្មោះកក្កុធៈជាឧបដ្ឋាករបស់ព្រះមហាមោគ្គល្លានដ៏មានអាយុទើបនឹងស្លាប់ភ្លាមហើយបានទៅកើតជាទេវកាយដែលសម្រេចដោយចិត្តមួយអង្គ ។ ទេវបុត្តនោះបាននូវអត្តភាពមានសភាពយ៉ាងនេះ ដូចជាបានគាមខេត្តរបស់អ្នកស្រុកមគធៈពីរបីៗ លោកមិនដែលបៀតបៀនខ្លួនឯងនឹងអ្នកដទៃ ដោយភាពបាន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អត្តានំ ន បរំ ព្យាពាធេតិ ។ អថខោ កកុធោ ទេវបុត្តោ យេនាយស្មា មហាមោគ្គល្លានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាមោគ្គល្លានំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ កកុធោ ទេវបុត្តោ អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច ទេវទត្តស្ស ភន្តេ លាភសក្ការសិលោកេន អភិភូតស្ស បរិយាទិន្នចិត្តស្ស ឯវរូបំ ឥច្ឆាគតំ ឧប្បជ្ជិ អហំ ភិក្ខុសង្ឃំ បរិហរិស្សាមីតិ សហ ចិត្តុប្បាទា ច ភន្តេ ទេវទត្តោ តស្សា ឥទ្ធិយា បរិហីនោតិ ។ ឥទមវោច កកុធោ ទេវបុត្តោ ឥទំ វត្វា អាយស្មន្តំ មហាមោគ្គល្លានំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវ អន្តរធាយិ ។

[១៤] អថខោ អាយស្មា មហាមោគ្គល្លានោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាមោគ្គល្លានោ ភគវន្តំ ឯតទវោច កកុធោ នាម ភន្តេ កោលិយបុត្តោ មម ឧបដ្ឋាកោ អធុនា កាលង្កតោ អញ្ញតរំ មនោមយំ កាយំ ឧបបន្នោ តស្ស

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អត្តភាពនោះទេ ។ គ្រានោះ កក្កុធទេវបុត្ត ចូលទៅរកព្រះមហាមោគ្គល្លានដ៏មានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមហាមោគ្គល្លានដ៏មានអាយុ ហើយទើបឈរក្នុងទីសមគួរ ។ លុះកក្កុធទេវបុត្តឈរក្នុងទីសមគួរហើយ បានថ្វាយពាក្យនេះនឹងព្រះមហាមោគ្គល្លានដ៏មានអាយុថា បពិត្រលោកម្ចាស់(ឥឡូវ) ទេវទត្តត្រូវលាភសក្ការៈ និងសេចក្តីសរសើរគ្របសង្កត់ហើយ មានចិត្តប្រែប្រួល កើតមានសេចក្តីប្រាថ្នាមានសភាពយ៉ាងនេះថា អញនឹងរក្សានូវភិក្ខុសង្ឃ បពិត្រលោកម្ចាស់ ទេវទត្តសាបសូន្យចាកឫទ្ធិនោះ ក្នុងវេលាជាមួយនឹងអកុសលចិត្តកើតឡើង ។ កក្កុធទេវបុត្តបានថ្វាយពាក្យនេះលុះថ្វាយពាក្យនេះហើយ ក៏ក្រាបថ្វាយបង្គំលាព្រះមហា-មោគ្គល្លានដ៏មានអាយុ ធ្វើប្រទក្សិណហើយស្រាប់តែបាត់ពីទីនោះទៅ ។

(១៥) គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះមហាមោគ្គល្លានដ៏មានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កូនអ្នកស្រុកកោលិយៈម្នាក់ឈ្មោះកក្កុធៈជាឧបដ្ឋាករបស់ខ្ញុំព្រះអង្គ ទើបនឹងស្លាប់អំបាញ់មិញ បានទៅកើតជាទេវ-កាយដែលសម្រេចដោយចិត្តមួយអង្គ ទេវបុត្តនោះ បានអត្តភាពយ៉ាងនេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



## សង្ឃភេទក្ខន្ធកេ កកុធទេវបុត្តវត្ថុ

ឯវរូបោ អត្តភាវប្បដិលាភោ សេយ្យថាបិ ទ្វេ វា តីណិ វា មាគធិកានិ គាមក្ខេត្តានិ សោ តេន អត្តភាវប្បដិលាភេន នេវ អត្តានំ ន បរំ ព្យាពាធេតិ អថខោ កកុធោ ទេវបុត្តោ យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ឯកមន្តំ ឋិតោ ខោ កកុធោ ទេវបុត្តោ មំ ឯតទវោច ទេវទត្តស្ស ភន្តេ លាភសក្ការសិលោកេន អភិភូតស្ស បរិយាទិន្នចិត្តស្ស ឯវរូបំ ឥច្ឆា ឧប្បន្នា អហំ ភិក្ខុសង្ឃំ បរិហរិស្សាមីតិ សហ ចិត្តុប្បាទា ច ភន្តេ ទេវទត្តោ តស្សា ឥទ្ធិយា បរិហីនោតិ ឥទមវោច ភន្តេ កកុធោ ទេវបុត្តោ ឥទំ វត្វា មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវ អន្តរធាយីតិ ។ កឹ បន តេ មោគ្គល្លាន កកុធោ ទេវបុត្តោ ចេតសា ចេតោ បរិច្ច វិទិតោ យំកិញ្ចិ កកុធោ ទេវបុត្តោ ភាសតិ សព្វន្តំ តថេវ ហោតិ នោ អញ្ញថាតិ ។ ចេតសា ចេតោ បរិច្ច វិទិតោ មេ ភន្តេ កកុធោ ទេវបុត្តោ យំកិញ្ចិ កកុធោ ទេវបុត្តោ ភាសតិ សព្វន្តំ តថេវ ហោតិ នោ អញ្ញថាតិ ។ រក្ខស្សេតំ មោគ្គល្លាន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ រឿងទេវបុត្តឈ្មោះកកុធៈ

ដូចជាបានតាមក្ខេត្តរបស់អ្នកស្រុកមគធៈពីរឬបី ទេវបុត្តនោះមិនដែលបៀត បៀនខ្លួនឯងនិងអ្នកដទៃ ដោយការបានអត្តភាពនោះទេ បពិត្រព្រះអង្គដ៏ ចំរើន គ្រានោះ កកុធទេវបុត្តចូលមករកខ្ញុំព្រះអង្គ លុះមកដល់ហើយថ្វាយ បង្គំចំពោះខ្ញុំព្រះអង្គ រួចស្រេចក៏ឈរក្នុងទីដ៏សមគួរ លុះឈរក្នុងទីដ៏សមគួរ ហើយបានថ្លែងពាក្យនេះនឹងខ្ញុំព្រះអង្គថា បពិត្រលោកម្ចាស់ (ឥឡូវនេះ) ទេវទត្តត្រូវលាភសក្ការៈនិងសេចក្តីសរសើរគ្របសង្កត់ហើយ មានចិត្តប្រែ ប្រួល កើតមានសេចក្តីប្រាថ្នាមានសភាពយ៉ាងនេះថា អញនឹងគ្រប់គ្រង នូវភិក្ខុសង្ឃ បពិត្រលោកម្ចាស់ ទេវទត្តសាបសូន្យចាកឫទ្ធិនោះ ក្នុង វេលាជាមួយនឹងអកុសលចិត្តកើតឡើង បពិត្រព្រះអង្គដ៏ចំរើន កកុធទេវ- បុត្តបានថ្លែងពាក្យនេះ លុះថ្លែងពាក្យនេះហើយ ទើបក្រាបថ្វាយបង្គំលាខ្ញុំ ព្រះអង្គ ធ្វើប្រទក្សិណហើយក៏បាត់ពីទីនោះទៅ ។ ព្រះអង្គទ្រង់ត្រាស់សួរ ថា ម្នាលមោគ្គល្លាន កកុធទេវបុត្ត អ្នកបានកំណត់ដឹងចិត្តដោយចិត្តច្បាស់ ហើយឬ កកុធទេវបុត្តនិយាយពាក្យណាមួយ ពាក្យនោះជាពាក្យពិត ឬជាពាក្យក្លែងទេ ។ ព្រះមហាមោគ្គល្លានក្រាបបង្គំទូលថា បពិត្រព្រះអង្គ ដ៏ចំរើន ខ្ញុំព្រះអង្គកំណត់ដឹងចិត្តដោយច្បាស់ថា កកុធទេវបុត្តនិយាយ ពាក្យណាមួយ ពាក្យទាំងនោះជាពាក្យពិតហើយ មិនមែនជាពាក្យក្លែង ទេ ។ ព្រះ អង្គទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន ចូរអ្នករក្សាទុកនូវសំដី នុះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



វាចំ រក្ខស្សេតំ មោគ្គល្លាន វាចំ ឥទានិ សោ មោឃ-បុរិសោ អត្តនា វ អត្តានំ បាតុករិស្សតិ ។

(១៦) បញ្ចិមេ មោគ្គល្លាន សត្ថារោ សន្តោ សំវិជ្ជ-មានា លោកស្មឹ ។ កតមេ បញ្ច ។ ឥធ មោគ្គល្លាន ឯកច្ចោ សត្ថា អបរិសុទ្ធសីលោ សមានោ បរិសុទ្ធសី-លោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ សីលំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ច[១] ។ តមេនំ សាវកា ឯវំ ជានន្តិ អយំ ខោ ភវំ សត្ថា អបរិសុទ្ធសីលោ សមានោ បរិសុទ្ធសី-លោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ សីលំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ច[២] មយញ្ចេវ ខោ បន គិហីនំ អារោ-ចេយ្យាម នាស្សស្ស មនាបំ យំ ខោ បនស្ស អមនាបំ កថន្តំ[៣] មយំ តេន សមុទាចរេយ្យាម សម្មន្នតិ ខោ បន ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជប-រិក្ខារេន យំ តុមោ[៤] ករិស្សតិ តុមោ[៥] វ តេន បញ្ញា-យិស្សតីតិ ។ ឯវរូបំ ខោ មោគ្គល្លាន សត្ថារំ សាវកា សីលតោ រក្ខន្តិ ។ ឯវរូបោ ច បន សត្ថា សាវកេហិ សីលតោ រក្ខំ បច្ចាសីសតិ ។

១-២ ឱ. ម. ពោត្ថកេសុ បសគ្គោ ន បញ្ញាយតិ ។ ៣ ឱ. កថំ នំ ។ ៤-៥ ម. តុម្ហោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ម្នាលមោគ្គល្លាន ចូរអ្នកក្រោកទុកនូវសំដីនេះចុះ ដ្បិតឥឡូវនេះ មោឃបុរសនោះ ធ្វើខ្លួនឲ្យល្បីដោយខ្លួនឯង ។

[ ១៦] ម្នាលមោគ្គល្លាន គ្រូក្នុងលោកនេះមាន ៥ ពួក ។ គ្រូទាំង ៥ ពួកនោះគឺគ្រូណាខ្លះ ។ ម្នាលមោគ្គល្លាន គ្រូពួកមួយ ក្នុងលោកនេះ មានសីលមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានសីលបរិសុទ្ធខ្លះ ថាសីលរបស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ។ សាវ័កទាំងឡាយតែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះ មានសីលមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានសីលបរិសុទ្ធខ្លះ ថាសីលរបស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ដូច្នេះ តែថាបើយើងប្រាប់ (រឿងនោះ) ដល់ពួកគ្រហស្ថ [illegible] លោកមិនគាប់ចិត្តទេ រឿងណាមិនគាប់ចិត្តដល់លោក យើងនឹងស៊ើរើរឿងលោកនោះដូចម្តេចបាន ព្រោះលោកកំពុងរាប់អាន (យើង) ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា លោកគង់នឹងប្រាកដដោយកម្មនោះមិនខាន ។ ម្នាលមោគ្គល្លាន សាវ័កទាំងឡាយតែងរក្សាគ្រូបែបនេះដោយសីល ។ ឯគ្រូបានសភាពយ៉ាងនេះ តែងនឹកសង្ឃឹមនូវការរក្សា អំពីពួកសាវ័កដោយសីល ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ បញ្ចសត្ថុកថា

[១៧] បុន ចបរំ មោគ្គល្លាន ឥធេកច្ចោ សត្ថា អបរិសុទ្ធាជីវោ សមានោ បរិសុទ្ធាជីវោម្ហីតិ បដិជានាតិ បរិសុទ្ធោ មេ អាជីវោ បរិយោទាតោ អសង្កិលិដ្ឋោតិ ច ។ តមេនំ សាវកា ឯវំ ជានន្តិ អយំ ខោ ភវំ សត្ថា អបរិសុទ្ធាជីវោ សមានោ បរិសុទ្ធាជីវោម្ហីតិ បដិជានាតិ បរិសុទ្ធោ មេ អាជីវោ បរិយោទាតោ អសង្កិលិដ្ឋោតិ ច មយំ ចេវ ខោ បន គិហីនំ អារោចេយ្យាម នាស្សស្ស មនាបំ យំ ខោ បនស្ស អមនាបំ កថន្តំ មយំ តេន សមុទាចរេយ្យាម សម្មន្នតិ ខោ បន ចីវរបិណ្ឌបាតសេ-នាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន យំ តុមោ ករិ-ស្សតិ តុមោ វ តេន បញ្ញាយិស្សតីតិ ។ ឯវរូបំ ខោ មោគ្គ-ល្លាន សត្ថារំ សាវកា អាជីវតោ រក្ខន្តិ ។ ឯវរូបោ ច បន សត្ថា សាវកេហិ អាជីវតោ រក្ខំ បច្ចាសីសតិ ។

[១៨] បុន ចបរំ មោគ្គល្លាន ឥធេកច្ចោ សត្ថា អបរិសុទ្ធធម្មទេសនោ សមានោ បរិសុទ្ធធម្មទេសនោ-ម្ហីតិ បដិជានាតិ បរិសុទ្ធា មេ ធម្មទេសនា បរិយោទាតា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



សង្ឃភេទក្ខន្ធកៈ និយាយអំពីគ្រូ ៥ ពួក

(១៧) ម្នាលមោគ្គល្លាន ពាក្យដទៃនៅមានទៀត គ្រូពួកមួយក្នុងលោកនេះ មានអាជីវៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានអាជីវៈបរិសុទ្ធខ្លះ ថាអាជីវៈរបស់អញបរិសុទ្ធផូរផង់ឥតមានសៅហ្មងខ្លះ ។ ពួកសាវ័កដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះ មានអាជីវៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានអាជីវៈបរិសុទ្ធខ្លះ ថាអាជីវៈរបស់អញបរិសុទ្ធផូរផង់ឥតមានសៅហ្មងខ្លះ ដូច្នេះ តែថាបើយើងប្រាប់ (រឿងនោះ) ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្តទេ ក៏រឿងណាមិនគាប់ចិត្តដល់លោក យើងនឹងស្តីរឿងលោកនោះដូចម្តេចបាន ព្រោះលោកគិតពុងកប់អាន(យើង) ដោយចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ច័យភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា គង់លោកនឹងប្រាកដដោយកម្មនោះមិនខាន ។ ម្នាលមោគ្គល្លាន សាវ័កទាំងឡាយតែងរក្សាគ្រូបែបនោះដោយអាជីវៈ ។ ឯគ្រូមានសភាពយ៉ាងនេះ តែងនឹកសង្ឃឹមនូវការរក្សាអំពីពួកសាវ័កដោយអាជីវៈ ។

(១៨) ម្នាលមោគ្គល្លាន ពាក្យដទៃនៅមានទៀត គ្រូពួកមួយក្នុងលោកនេះ មានធម្មទេសនាមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានធម្មទេសនាបរិសុទ្ធខ្លះ ថាធម្មទេសនារបស់អញ បរិសុទ្ធផូរផង់ ឥតមាន

អសង្កិលិដ្ឋាតិ ច ។ តមេនំ សាវកា ឯវំ ជានន្តិ អយំ ខោ ភវំ សត្ថា អបរិសុទ្ធធម្មទេសនោ សមានោ បរិសុទ្ធធម្មទេសនោម្ហីតិ បដិជានាតិ បរិសុទ្ធា មេ ធម្មទេសនា បរិយោទាតា អសង្កិលិដ្ឋាតិ ច មយំ ចេវ ខោ បន គិហីនំ អារោចេយ្យាម នាស្សស្ស មនាបំ យំ ខោ បនស្ស អមនាបំ កថន្តំ មយំ តេន សមុទាចរេយ្យាម សម្មន្នតិ ខោ បន ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន យំ តុមោ ករិស្សតិ តុមោវ តេន បញ្ញាយិស្សតីតិ ។ ឯវរូបំ ខោ មោគ្គល្លាន សត្ថារំ សាវកា ធម្មទេសនតោ រក្ខន្តិ ។ ឯវរូបោ ច បន សត្ថា សាវកេហិ ធម្មទេសនតោ រក្ខំ បច្ចាសីសតិ ។

(១៩) បុន ចបរំ មោគ្គល្លាន ឥធេកច្ចោ សត្ថា អបរិសុទ្ធវេយ្យាករណោ សមានោ បរិសុទ្ធវេយ្យាករណោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ វេយ្យាករណំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ច ។ តមេនំ សាវកា ឯវំ ជានន្តិ អយំ ខោ ភវំ សត្ថា អបរិសុទ្ធវេយ្យាករណោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សៅហ្មងខ្លះ ។ ពួកសាវ័កតែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះមានធម្មទេសនាមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានធម្មទេសនាបរិសុទ្ធខ្លះ ថាធម្មទេសនារបស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ដូច្នេះ តែថាបើយើងប្រាប់(រឿងនោះ)ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្ត ក៏រឿងណា មិនគាប់ចិត្តដល់លោក យើងនឹងសើរើរឿងលោកនោះដូចម្តេចបាន ព្រោះលោកកំពុងគាប់គាន(យើង) ដោយចីវរ បិណ្ឌបាត សេនាសនៈនិងគិលានប្បច្ច័យភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា គង់លោកនឹងប្រាកដដោយកម្មនោះមិនខាន ។ ម្នាលមោគ្គល្លាន ពួកសាវ័កតែងរក្សាគ្រូបែបនេះ ដោយធម្មទេសនា ។ ឯគ្រូបែបនេះសោត តែងនឹកសង្ឃឹមនូវការរក្សាអំពីពួកសាវ័កដោយធម្មទេសនា ។

(១៩) ម្នាលមោគ្គល្លាន ពាក្យដទៃទៅមានទៀត គ្រូពួកមួយក្នុងលោកនេះ មានវេយ្យាករណ៍មិនបរិសុទ្ធ តែប្តេជ្ញាថា អញមានវេយ្យាករណ៍បរិសុទ្ធខ្លះ ថា វេយ្យាករណ៍របស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ។ ពួកសាវ័កតែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះមានវេយ្យាករណ៍មិន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ បញ្ចសត្ថុកថា

សមានោ បរិសុទ្ធវេយ្យាករណោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ វេយ្យាករណំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ច មយំ ចេវ ខោ បន គិហីនំ អារោចេយ្យាម នាស្សស្ស មនាបំ យំ ខោ បនស្ស អមនាបំ កថន្តំ មយំ តេន សមុទាចរេយ្យាម សម្មន្នតិ ខោ បន ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន យំ តុមោ ករិស្សតិ តុមោវ តេន បញ្ញាយិស្សតីតិ ។ ឯវរូបំ ខោ មោគ្គល្លាន សត្ថារំ សាវកា វេយ្យាករណតោ រក្ខន្តិ ។ ឯវរូបោ ច បន សត្ថា សាវកេហិ វេយ្យាករណតោ រក្ខំ បច្ចាសីសតិ ។

(២០) បុន ចបរំ មោគ្គល្លាន ឥធេកច្ចោ សត្ថា អបរិសុទ្ធញាណទស្សនោ សមានោ បរិសុទ្ធញាណទស្សនោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ ញាណទស្សនំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ច ។ តមេនំ សាវកា ឯវំ ជានន្តិ អយំ ខោ ភវំ សត្ថា អបរិសុទ្ធញាណទស្សនោ សមានោ បរិសុទ្ធញាណទស្សនោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ ញាណទស្សនំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បរិសុទ្ធ តែប្តេជ្ញាថា អញមានវេយ្យាករណ៍បរិសុទ្ធខ្លះ ថាវេយ្យាករណ៍របស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ដូច្នេះ បើយើងប្រាប់ (រឿងនោះ) ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្តទេ គំរឿងណាមិនគាប់ចិត្តដល់លោក យើងនឹងសើរើរឿងលោកនោះ ដូចម្តេចបាន ព្រោះលោកកំពុងកប់កាន(យើង) ដោយចីវរ បិណ្ឌបាត សេនាសនៈនឹងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា គង់លោកនឹងប្រាកដឡើងព្រោះកម្មនោះមិនខាន ។ ម្នាលមោគ្គល្លាន ពួកសាវ័កតែងរក្សាគ្រូបែបនេះដោយវេយ្យាករណ៍ ។ ចំណែកខាងគ្រូនោះ តែងនឹងសង្ឃឹមនូវការរក្សាអំពីពួកសាវ័កដោយវេយ្យាករណ៍ ។

(៤០) ម្នាលមោគ្គល្លាន ពាក្យដទៃនៅមានទៀត គ្រូពួកមួយក្នុងលោកនេះ មានញាណទស្សនៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានញាណទស្សនៈបរិសុទ្ធខ្លះ ថាញាណទស្សនៈរបស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ។ សាវ័កតែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះមានញាណទស្សនៈមិនបរិសុទ្ធ តែប្តេជ្ញាថាអញមានញាណទស្សនៈបរិសុទ្ធខ្លះ ថាញាណទស្សនៈរបស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ដូច្នេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មយំ ចេវ ខោ គិហីនំ អារោចេយ្យាម នាស្សស្ស មនាបំ យំ ខោ បនស្ស អមនាបំ កថន្តំ មយំ តេន សមុទាចរេយ្យាម សម្មន្នតិ ខោ បន ចីវរបិណ្ឌបាតាសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន យំ តុមោ ករិស្សតិ តុមោ វ តេន បញ្ញាយិស្សតីតិ ។ ឯវរូបំ ខោ មោគ្គល្លាន សត្ថារំ សាវកា ញាណទស្សនតោ រក្ខន្តិ ។ ឯវរូបោ ច បន សត្ថា សាវកេហិ ញាណទស្សនតោ រក្ខំ បច្ចាសីសតិ ។ ឥមេ ខោ មោគ្គល្លាន បញ្ច សត្ថារោ សន្តោ សំវិជ្ជមានា លោកស្មឹ ។

[២០] អហំ ខោ បន មោគ្គល្លាន បរិសុទ្ធសីលោ សមានោ បរិសុទ្ធសីលោម្ហីតិ បដិជានាមិ បរិសុទ្ធំ មេ សីលំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ច ន ច មំ សាវកា សីលតោ រក្ខន្តិ ន ចាហំ សាវកេហិ សីលតោ រក្ខំ បច្ចាសីសាមិ ។ បរិសុទ្ធាជីវោ សមានោ ។ បេ ។ បរិសុទ្ធធម្មទេសនោ ។ បេ ។ បរិសុទ្ធវេយ្យាករណោ សមានោ ។ បេ ។ បរិសុទ្ធញាណទស្សនោ សមានោ បរិសុទ្ធញាណទស្សនោម្ហីតិ បដិជានាមិ បរិសុទ្ធំ មេ ញាណទស្សនំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បើយើងប្រាប់ (រឿងនោះ) ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្តទេ ក៏រឿងណាមិនគាប់ចិត្តដល់លោក យើងនឹងសើរើរឿងលោកនោះដូចម្តេចបាន ព្រោះលោកកំពុងរាប់អាន(យើង) ដោយចីវរ បិណ្ឌបាត សេនា-សនៈនឹងគិលានប្បច្ច័យភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា គង់លោកនឹងប្រាកដឡើងព្រោះកម្មនោះមិនខាន ។ ម្នាលមោគ្គល្លាន ពួកសាវ័កតែងរក្សាគ្រូបែបនេះដោយញាណទស្សនៈ ។ ក៏ឯគ្រូមានសភាពយ៉ាងនេះ តែងនឹកសង្ឃឹមនូវការរក្សា អំពីពួកសាវ័កដោយញាណទស្សនៈ ។ ម្នាលមោគ្គល្លាន គ្រូ ៥ ពួកនេះឯង តែងមានក្នុងលោក ។

(៤១) ម្នាលមោគ្គល្លាន ចំណែកខាងតថាគតជាបុគ្គលមានសីលបរិសុទ្ធ ប្តេជ្ញាថា តថាគតមានសីលបរិសុទ្ធខ្លះ ថាសីលរបស់តថាគតបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ។ ពួកសាវ័កមិនបានរក្សាតថាគតដោយសីលឡើយ តថាគតសោតក៏មិននឹកសង្ឃឹមនូវការរក្សាអំពីពួកសា-វ័កដោយសីលទេ ។ (តថាគត)មានអាជីវៈបរិសុទ្ធ ។បេ។ មានធម្មទេសនាបរិសុទ្ធ ។ បេ ។ មានវេយ្យាករណ៍បរិសុទ្ធ ។ បេ ។ មានញាណទស្សនៈបរិសុទ្ធ ប្តេជ្ញាថា តថាគតបានញាណទស្សនៈបរិសុទ្ធខ្លះ ថាញាណទស្សនៈ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បរិយោទាតំ អសង្កិលិដ្ឋន្តិ ច ន ច មំ សាវកា ញាណ-ទស្សនតោ រក្ខន្តិ ន ចាហំ សាវកេហិ ញាណទស្សន-តោ រក្ខំ បច្ចាសីសាមីតិ ។

(២២) អថខោ ភគវា កោសម្ពិយំ យថាភិរន្តំ វិហ-រិត្វា យេន រាជគហំ តេន ចារិកំ បក្កាមិ អនុបុព្វេន ចា-រិកំ ចរមានោ យេន រាជគហំ តទវសរិ ។ តត្រ សុទំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។

(២៣) អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុ-បសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯ-តទវោចុំ ទេវទត្តស្ស ភន្តេ អជាតសត្តុ កុមារោ បញ្ចហិ រថសតេហិ សាយំ បាតំ ឧបដ្ឋានំ គច្ឆតិ បញ្ច ច ថាលិ-បាកសតានិ ភត្តាភិហារោ អភិហរិយ្យតីតិ ។ មា ភិក្ខវេ ទេវទត្តស្ស លាភសក្ការសិលោកំ បិហយិត្ថ យាវកី-វញ្ច ភិក្ខវេ ទេវទត្តស្ស អជាតសត្តុ កុមារោ បញ្ចហិ រថសតេហិ សាយំ បាតំ ឧបដ្ឋានំ គមិស្សតិ បញ្ច ច ថាលិបាកសតានិ ភត្តាភិហារោ អភិហរិយ្យិស្សតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



របស់តថាគតបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ សាវ័កមិនរក្សាតថាគត ដោយញាណទស្សនៈទេ តថាគតសោតមិនទឹកសង្ឃឹមនូវការរក្សាអំពីពួកសាវ័កដោយញាណទស្សនៈឡើយ ។

(៤២) គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងនគរកោសម្ពី គួរតាមពុទ្ធអធ្យាស្រ័យហើយ ស្តេចទៅកាន់ចារិកនគររាជគ្រឹះ ត្រាច់ទៅកាន់ចារិកតាមលំដាប់ ដោះទៅនគររាជគ្រឹះ ។ បានឮថា ព្រះមានព្រះភាគគង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបនគររាជគ្រឹះ ។

(៤៣) លំដាប់នោះ ភិក្ខុច្រើនរូបនាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចទើបអង្គុយក្នុងទីដ៏សមគួរ ។ ភិក្ខុទាំងនោះ លុះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន អជាតសត្តុកុមារតែងទៅដោយរថ ៥ រយ បម្រើទេវទត្តទាំងល្ងាចទាំងព្រឹក ទាំងឲ្យអ្នកនាំសម្រាប់ យកសម្រាប់ ៥ រយថាសទៅប្រគេន (ទេវទត្តផង)។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលភិក្ខុទាំងឡាយ អ្នកកុំស្ងើចលាភសក្ការៈនិងសេចក្តីសរសើររបស់ទេវទត្តឡើយ ម្នាលភិក្ខុទាំងឡាយ អជាតសត្តុកុមារដែលទៅដោយរថ ៥ រយ ទៅបម្រើទេវទត្តទាំងល្ងាចទាំងព្រឹក ទាំងឲ្យអ្នកនាំសម្រាប់ យកសម្រាប់ ៥ រយថាសទៅប្រគេន (ទេវទត្ត) ដរាបណា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ហានិយេវ ភិក្ខវេ ទេវទត្តស្ស បាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ សេយ្យថាបិ ភិក្ខវេ ចណ្ឌស្ស កុក្កុរស្ស នាសាយ បិត្តំ ភិន្ទេយ្យុំ ឯវំ ហិ សោ ភិក្ខវេ កុក្កុរោ ភិយ្យោសោ មត្តាយ ចណ្ឌតរោ អស្ស ឯវមេវ ខោ ភិក្ខវេ យាវកីវញ្ច ទេវទត្តស្ស អជាតសត្តុ កុមារោ បញ្ចហិ រថសតេហិ សាយំ បាតំ ឧបដ្ឋានំ គមិស្សតិ បញ្ច ច ថាលិបាកសតានិ ភត្តាភិហារោ អភិហរិយិស្សតិ ហានិយេវ ភិក្ខវេ ទេវទត្តស្ស បាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ អត្តវធាយ ភិក្ខវេ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ បរាភវាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ សេយ្យថាបិ ភិក្ខវេ កទលី អត្តវធាយ ផលំ ទេតិ បរាភវាយ ផលំ ទេតិ ឯវមេវ ខោ ភិក្ខវេ អត្តវធាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ បរាភវាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ សេយ្យថាបិ ភិក្ខវេ វេឡុ អត្តវធាយ ផលំ ទេតិ បរាភវាយ ផលំ ទេតិ

ម្នាលភិក្ខុទាំងឡាយ សេចក្តីសាបសូន្យមុខជានឹងកើតមានដល់ទេវទត្ត (ដរាបនោះ) មិនខាន ឯការចំរើនក្នុងកុសលធម៌មិនមានឡើយ ម្នាលភិក្ខុទាំងឡាយ ដូចគេច្របាច់ទឹកប្រមាត់ (ត្រីឬខ្លាឃ្មុំ) ដាក់ក្នុងច្រមុះឆ្កែកាច ឆ្កែនោះរឹតតែកាចឡើងជាងដើម យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ក៏ដូចជាអជាតសត្តុកុមារទៅដោយរថ ៥ រយ បម្រើទេវទត្ត ទាំងល្ងាចទាំងព្រឹក ទាំងឲ្យអ្នកនាំសម្រាប់ យកសម្រាប់ ៥ រយថាសទៅប្រគេន (ទេវទត្ត) ដរាបណា សេចក្តីសាបសូន្យមុខជានឹងកើតមានដល់ទេវទត្ត (ដរាបនោះ) ពុំខាន ការចំរើនក្នុងកុសលធម៌ មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនឹងសេចក្តីសរសើរកើតឡើងហើយដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនឹងសេចក្តីសរសើរកើតឡើងហើយដល់ទេវទត្ត ដើម្បីសេចក្តីវិនាស ម្នាលភិក្ខុទាំងឡាយ ដើមចេកចេញផ្លែ ដើម្បីសម្លាប់ដើម ចេញផ្លែ ដើម្បីវិនាស យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនឹងសេចក្តីសរសើរកើតឡើងហើយដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនឹងសេចក្តីសរសើរ កើតឡើងហើយដល់ទេវទត្ត ដើម្បីសេចក្តីវិនាស ក៏ដូច្នោះដែរ ម្នាលភិក្ខុទាំងឡាយ ឫស្សីចេញផ្លែ ដើម្បីសម្លាប់ដើម ចេញផ្លែ ដើម្បីសេចក្តីវិនាសយ៉ាងណា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



## សង្ឃភេទក្ខន្ធកេ និគមគាថា

ឯវមេវ ខោ ភិក្ខវេ អត្តវធាយ ទេវទត្តស្ស លាភសក្កា-រសិលោកោ ឧទបាទិ បរាភវាយ ទេវទត្តស្ស លាភ-សក្ការសិលោកោ ឧទបាទិ សេយ្យថាបិ ភិក្ខវេ នឡោ អត្តវធាយ ផលំ ទេតិ បរាភវាយ ផលំ ទេតិ ឯវមេវ ខោ ភិក្ខវេ អត្តវធាយ ទេវទត្តស្ស លាភសក្ការសិ-លោកោ ឧទបាទិ បរាភវាយ ទេវទត្តស្ស លាភសក្កា-រសិលោកោ ឧទបាទិ សេយ្យថាបិ ភិក្ខវេ អស្សតរី អត្តវធាយ គព្ភំ គណ្ហាតិ បរាភវាយ គព្ភំ គណ្ហាតិ ឯ-វមេវ ខោ ភិក្ខវេ អត្តវធាយ ទេវទត្តស្ស លាភសក្កា-រសិលោកោ ឧទបាទិ បរាភវាយ ទេវទត្តស្ស លាភ-សក្ការសិលោកោ ឧទបាទីតិ ។

(២៦) ផលំ វេ កទលឹ ហន្តិ
ផលំ វេឡុំ ផលំ នឡំ
សក្ការោ កាបុរិសំ ហន្តិ
គព្ភោ អស្សតរឹ យថាតិ ។

**បឋមភាណវារំ និដ្ឋិតំ ។**

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ កើតឡើងហើយដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនិងសេចក្តីសរសើរកើតឡើងហើយដល់ទេវទត្ត ដើម្បីបំផ្លាញខ្លួន ក៏ដូច្នោះដែរ ម្នាលភិក្ខុទាំងឡាយ ដូចដើមបបុស ចេញផ្លែ ដើម្បីសម្លាប់ដើម ចេញផ្លែ ដើម្បីសេចក្តីវិនាស យ៉ាងណា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនិងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីបំផ្លាញខ្លួន ក៏ដូច្នោះដែរ ម្នាលភិក្ខុទាំងឡាយ ដូចមេសេះអស្សតរ មានផ្ទៃដើម្បីសម្លាប់ខ្លួន មានផ្ទៃ ដើម្បីវិនាសខ្លួន យ៉ាងណា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនិងសេចក្តីសរសើរកើតឡើងដល់ទេវទត្តដើម្បីបំផ្លាញខ្លួន ក៏ដូច្នោះដែរ ។

[២៤] ផ្លែចេកតែងសម្លាប់ដើមចេក ផ្លែឫស្សីតែងសម្លាប់
ដើមឫស្សី ផ្លែបបុសតែងសម្លាប់ដើមបបុស សក្ការៈតែង
សម្លាប់បុរសអាក្រក់ ដូចជាគភ៌តែងសម្លាប់មេសេះអស្សតរ ។

ចប់ ភាណវារៈ ទី ១ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



[២៨] តេន ខោ បន សមយេន ភគវា មហតិយា បរិសាយ បរិវុតោ ធម្មំ ទេសេន្តោ និសិន្នោ ហោតិ សរាជិកាយ[1]។ អថ ខោ ទេវទត្តោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលឹ បណាមេត្វា ភគវន្តំ ឯតទវោច ជិណ្ណោ ទានិ ភន្តេ ភគវា វុទ្ធោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ អប្បោស្សុក្កោ ទានិ ភន្តេ ភគវា ទិដ្ឋធម្មសុខវិហារមនុយុត្តោ វិហរតុ មមំ ភិក្ខុសង្ឃំ និស្សជ្ជតុ អហំ ភិក្ខុសង្ឃំ បរិហរិស្សាមីតិ ។ អលំ ទេវទត្ត មា តេ រុច្ចិ ភិក្ខុសង្ឃំ បរិហរិតុន្តិ ។ ទុតិយម្បិ ខោ ។ បេ ។ តតិយម្បិ ខោ ទេវទត្តោ ភគវន្តំ ឯតទវោច ជិណ្ណោ ទានិ ភន្តេ ភគវា វុទ្ធោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ អប្បោស្សុក្កោ ទានិ ភន្តេ ភគវា ទិដ្ឋធម្មសុខវិហារមនុយុត្តោ វិហរតុ មមំ ភិក្ខុសង្ឃំ និស្សជ្ជតុ

---

១ ឥតោ បរំ បោត្ថកេសុ បរិសាយាតិ បាឋោ ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



[ ៦៥ ] សម័យនោះឯង ព្រះមានព្រះភាគមានបរិសទ្យច្រើន ព្រមទាំងស្តេចចោមរោមជុំវិញ ព្រះអង្គកំពុងគង់សំដែងធម៌ ។ គ្រានោះ ទេវទត្ត ក្រោកចាកទីអង្គុយ ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលីឆ្ពោះទៅរក ព្រះមានព្រះភាគ ហើយក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ព្រះជរា មានព្រះជន្មច្រើនហើយ ចាស់ព្រះអង្គហើយ ទ្រង់ព្រះជន្មយូរឆ្នាំមកហើយ មានព្រះជន្មប្រែលចូលមកកាន់បច្ឆិមវ័យហើយ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ សូមព្រះមានព្រះភាគកុំខ្វល់ខ្វាយពេក សូមសម្រាកព្រះអង្គឲ្យបានសុខស្រួលក្នុងបច្ចុប្បន្ននេះចុះ សូមព្រះអង្គប្រគល់ភិក្ខុសង្ឃឲ្យមកខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងទទួលគ្រប់គ្រងភិក្ខុសង្ឃ ។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលទេវទត្ត ណើយអ្នកកុំពេញចិត្តនឹងការគ្រប់គ្រងភិក្ខុសង្ឃឡើយ ។ ទេវទត្តបានក្រាបទូលពាក្យនេះនឹងព្រះមានព្រះភាគអស់វារៈពីរដងផង ។ បេ ។ អស់វារៈបីដងផងថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ព្រះអង្គទ្រង់ព្រះជរា មានព្រះជន្មច្រើនហើយ ចាស់ព្រះអង្គហើយ ទ្រង់ព្រះជន្មយូរឆ្នាំមកហើយ មានព្រះជន្មចូលកាន់បច្ឆិមវ័យហើយ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ សូមព្រះមានព្រះភាគកុំខ្វល់ខ្វាយពេក សូមសម្រាកព្រះអង្គឲ្យបានសុខស្រួលក្នុងបច្ចុប្បន្ននេះចុះ សូមព្រះអង្គប្រគល់ភិក្ខុសង្ឃឲ្យមកខ្ញុំព្រះអង្គ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ ទេវទត្តស្ស បកាសនីយកម្មករណំ

អហំ ភិក្ខុសង្ឃំ បរិហរិស្សាមីតិ ។ សារីបុត្តមោគ្គល្លា-
នានំបិ ខោ អហំ ទេវទត្ត ភិក្ខុសង្ឃំ ន និស្សជ្ជេយ្យំ
កឹ បន តុយ្ហំ ឆវស្ស ខេឡាសកស្សាតិ[១] ។ អថខោ
ទេវទត្តោ សរាជិកាយ មំ ភគវា បរិសាយ ខេឡា-
សកវាទេន[២] អបសាទេតិ សារីបុត្តមោគ្គល្លានេ ច ឧក្កំ-
សេតីតិ កុបិតោ អនត្តមនោ ភគវន្តំ អភិវាទេត្វា
បទក្ខិណំ កត្វា បក្កាមិ ។ អយញ្ច ចរហិ[៣] ទេវ-
ទត្តស្ស ភគវតិ បឋមោ អាឃាតោ អហោសិ ។

[២៦] អថខោ ភគវា ភិក្ខូ អាមន្តេសិ តេនហិ
ភិក្ខវេ សង្ឃោ ទេវទត្តស្ស រាជគហេ បកាសនីយ-
កម្មំ ករោតុ បុព្វេ ទេវទត្តស្ស អញ្ញា បកតិ អហោសិ
ឥទានិ អញ្ញា បកតិ យំ ទេវទត្តោ ករេយ្យ កាយេន
វាចាយ ន តេន ពុទ្ធោ វា ធម្មោ វា សង្ឃោ វា
ទដ្ឋព្វោ ទេវទត្តោវ តេន ទដ្ឋព្វោតិ ។ ឯវញ្ច បន
ភិក្ខវេ កាតព្វំ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ

---

១ ឱ. ម. ខេឡាបកស្សាតិ ។ ២ ឱ. ម. ខេឡាបកវាទេន ។ ៣ ឱ. តរហិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ ការផ្ដើមកាសនិយកម្មដល់ទេវទត្ត

ខ្ញុំព្រះអង្គទីងគ្រប់គ្រងភិក្ខុសង្ឃ ។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាល ទេវទត្ត អម្បាលយ៉ាងសារីបុត្តនិងមោគ្គល្លាន មេ្តច តថាគតមិនប្រគល់ ភិក្ខុសង្ឃឲ្យ ចំណង់បើអ្នកជាមនុស្សដូជាតិអាក្រក់ ជាមនុស្សបរិភោគបត្ត-បច្ច័យដែលកើតអំពីអនេសនៈដូចជាដុំទឹកមាត់ តថាគតនឹងប្រគល់ឲ្យដូចម្ដេចបាន ។ លំដាប់នោះ ទេវទត្តមានសេចក្ដីក្រោធ អាក់អន់ចិត្តថា ព្រះមានព្រះភាគ ធ្វើអញឲ្យអាប់មុខក្នុងកណ្ដាលបរិសទ្យព្រមទាំងស្ដេច ដោយពាក្យថា(ទេវទត្តនេះ)បរិភោគបត្តបច្ច័យដែលកើតអំពីអនេសនៈដូចជាដុំទឹកមាត់ ហើយបែរទៅលើកតំកើងសារីបុត្តនិងមោគ្គល្លានវិញ ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។ នេះ ជាគំនុំជម្ពូង របស់ទេវទត្តចំពោះព្រះមានព្រះភាគ ។

(៤៦) លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ត្រូវសង្ឃធ្វើបកាសនិយកម្ម ដល់ទេវទត្តក្នុងនគររាជគ្រឹះ (ដ្បិត )កាលពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយ វាចា អំពើនោះនាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្តត្រូវគេឃើញដោយកម្មនោះតែម្យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ បកាសនិយ-កម្ម សង្ឃគប្បីធ្វើយ៉ាងនេះ។ គប្បីឲ្យភិក្ខុដែលឈ្លាសប្រតិពលប្រកាសសង្ឃ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដកេ ចុល្លវគ្គោ

ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ទេវទត្តស្ស រាជគហេ បកាសនីយកម្មំ ករេយ្យ បុព្វេ ទេវទត្តស្ស អញ្ញា បកតិ អហោសិ ឥទានិ អញ្ញា បកតិ យំ ទេវទត្តោ ករេយ្យ កាយេន វាចាយ ន តេន ពុទ្ធោ វា ធម្មោ វា សង្ឃោ វា ទដ្ឋព្វោ ទេវទត្តោវ តេន ទដ្ឋព្វោតិ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ទេវទត្តស្ស រាជគហេ បកាសនីយកម្មំ ករោតិ បុព្វេ ទេវទត្តស្ស អញ្ញា បកតិ អហោសិ ឥទានិ អញ្ញា បកតិ យំ ទេវទត្តោ ករេយ្យ កាយេន វាចាយ ន តេន ពុទ្ធោ វា ធម្មោ វា សង្ឃោ វា ទដ្ឋព្វោ ទេវទត្តោវ តេន ទដ្ឋព្វោតិ ។ យស្សាយស្មតោ ខមតិ ទេវទត្តស្ស រាជគហេ បកាសនីយកម្មស្ស ករណំ បុព្វេ ទេវទត្តស្ស អញ្ញា បកតិ អហោសិ ឥទានិ អញ្ញា បកតិ យំ ទេវទត្តោ ករេយ្យ កាយេន វាចាយ ន តេន ពុទ្ធោ វា ធម្មោ វា សង្ឃោ វា ទដ្ឋព្វោ ទេវទត្តោវ តេន ទដ្ឋព្វោតិ សោ តុណ្ហស្ស យស្ស នក្ខមតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទៀតថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីធ្វើបកាសនីយកម្មដល់ទេវទត្តក្នុងនគររាជគ្រឹះ (ថា)ពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះមានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្តត្រូវគេឃើញដោយកម្មនោះតែម្យ៉ាង ៗ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃធ្វើបកាស-នីយកម្មដល់ទេវទត្តក្នុងនគររាជគ្រឹះ (ថា)ពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្តត្រូវគេឃើញដោយកម្មនោះតែម្យ៉ាង ៗ ការធ្វើបកាសនីយកម្មដល់ទេវទត្តក្នុងនគររាជគ្រឹះថា កាលពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះមានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្តត្រូវគេឃើញដោយកម្មនោះតែម្យ៉ាង ដូច្នេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ បកាសនីយកម្មំ សារីបុត្តត្ថេ

សោ ភាសេយ្យ ។ កតំ សង្ឃេន ទេវទត្តស្ស រាជគ-
ហេ បកាសនីយកម្មំ បុព្វេ ទេវទត្តស្ស អញ្ញា បកតិ
អហោសិ ឥទានិ អញ្ញា បកតិ យំ ទេវទត្តោ ករេយ្យ
កាយេន វាចាយ ន តេន ពុទ្ធោ វា ធម្មោ វា សង្ឃោ
វា ទដ្ឋព្វោ ទេវទត្តោវ តេន ទដ្ឋព្វោតិ ។ ខមតិ សង្ឃស្ស
តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[២៧] អថខោ ភគវា អាយស្មន្តំ សារីបុត្តំ អា-
មន្តេសិ តេនហិ ត្វំ សារីបុត្ត ទេវទត្តំ រាជគហេ
បកាសេហីតិ ។ បុព្វេ មយា ភន្តេ ទេវទត្តស្ស
រាជគហេ វណ្ណោ ភាសិតោ មហិទ្ធិកោ គោធិបុត្តោ
មហានុភាវោ គោធិបុត្តោតិ កថាហំ ភន្តេ ទេវ-
ទត្តំ រាជគហេ បកាសេមីតិ ។ ននុ តយា សារីបុត្ត
ភូតោយេវ ទេវទត្តស្ស រាជគហេ វណ្ណោ ភាសិតោ
មហិទ្ធិកោ គោធិបុត្តោ មហានុភាវោ គោធិបុត្តោតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



លោកដ៏មានអាយុអង្គនោះគប្បីនិយាយឡើង ។ សង្ឃបានធ្វើបកាសនីយកម្មដល់ទេវទត្តក្នុងនគររាជគ្រឹះថា ពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះមានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្ត ត្រូវគេឃើញដោយកម្មនោះតែម្យ៉ាង ការធ្វើបកាសនីយកម្មនោះ គួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះដោយអាការស្ងៀមយ៉ាងនេះ ។

(៤៧) លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះសារីបុត្តដ៏មានអាយុមកថា ម្នាលសារីបុត្ត បើដូច្នោះ ចូរអ្នកប្រកាស (ទោស) ទេវទត្តក្នុងនគររាជគ្រឹះ ។ ព្រះសារីបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលពីមុនខ្ញុំព្រះអង្គបានប្រកាសគុណទេវទត្តក្នុងនគររាជគ្រឹះថា ទេវទត្តជាគោធិបុត្តមានឫទ្ធិច្រើន ជាគោធិបុត្តមានអានុភាពច្រើន បពិត្រព្រះអង្គដ៏ចំរើន (ឥឡូវនេះ) ខ្ញុំព្រះអង្គនឹងប្រកាស (ទោស) ទេវទត្តដូចម្តេចបាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសារីបុត្ត អ្នកបានប្រកាសគុណពិតរបស់ទេវទត្តក្នុងនគររាជគ្រឹះថា ទេវទត្តជាគោធិបុត្តមានឫទ្ធិច្រើន ជាគោធិបុត្តមានអានុភាពច្រើន ដូច្នោះហើយឬ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



ឯវំ ភន្តេតិ ។ ឯវមេវ ខោ ត្វំ សារីបុត្ត ភូតញ្ញេវ ទេវទត្តំ រាជគហេ បកាសេហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា សារីបុត្តោ ភគវតោ បច្ចស្សោសិ ។

(២៤) អថខោ ភគវា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ សារីបុត្តំ សម្មន្នតុ ទេវទត្តំ រាជគហេ បកាសេតុំ បុព្វេ ទេវទត្តស្ស អញ្ញា បកតិ អហោសិ ឥទានិ អញ្ញា បកតិ យំ ទេវទត្តោ ករេយ្យ កាយេន វាចាយ ន តេន ពុទ្ធោ វា ធម្មោ វា សង្ឃោ វា ទដ្ឋព្វោ ទេវទត្តោវ តេន ទដ្ឋព្វោតិ ។ ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ ។ បឋមំ សារីបុត្តោ យាចិតព្វោ ។ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ អាយស្មន្តំ សារីបុត្តំ សម្មន្នេយ្យ ទេវទត្តំ រាជគហេ បកាសេតុំ បុព្វេ ទេវទត្តស្ស អញ្ញា បកតិ អហោសិ ឥទានិ អញ្ញា បកតិ យំ ទេវទត្តោ ករេយ្យ កាយេន វាចាយ ន តេន ពុទ្ធោ វា ធម្មោ វា សង្ឃោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



ព្រះសារីបុត្តក្រាបបង្គំទូលថា ករុណាព្រះអង្គ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ចូរអ្នកប្រកាស ( ទោស ) ទេវទត្តឲ្យពិតយ៉ាងនោះចុះ ។ ព្រះសារីបុត្តដ៏មានអាយុក្រាបបង្គំទូលថា ករុណាព្រះអង្គ ។

(៦៨) គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរសន្មតសារីបុត្ត ដើម្បីឲ្យប្រកាស ( ទោស ) ទេវទត្តក្នុងនគររាជគ្រឹះថា ពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្តត្រូវគេឃើញដោយអំពើនោះតែម្យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតយ៉ាងនេះ ។ សង្ឃត្រូវសូមសារីបុត្តជាដំបូងសិន ។ លុះសូមរួចហើយ ត្រូវឲ្យភិក្ខុជាអ្នកឆ្លាសប្រតិពលប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មបានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតព្រះសារីបុត្តដ៏មានអាយុ ដើម្បីឲ្យប្រកាស ( ទោស ) ទេវទត្តក្នុងនគររាជគ្រឹះថា ( ដ្បិត ) ពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះមានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ ទេវទត្តវត្ថុ បកាសនីយកម្មំ

វា ទដ្ឋព្វោ ទេវទត្តោវ តេន ទដ្ឋព្វោ ។ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ អាយស្មន្តំ សារីបុត្តំ សម្មន្នតិ ទេវទត្តំ រាជគហេ បកាសេតុំ បុព្វេ ទេវទត្តស្ស អញ្ញា បកតិ អហោសិ ឥទានិ អញ្ញា បកតិ យំ ទេវទត្តោ ករេយ្យ កាយេន វាចាយ ន តេន ពុទ្ធោ វា ធម្មោ វា សង្ឃោ វា ទដ្ឋព្វោ ទេវទត្តោវ តេន ទដ្ឋព្វោតិ ។ យស្សាយស្មតោ ខមតិ អាយស្មតោ សារីបុត្តស្ស សម្មតិ ទេវទត្តំ រាជគហេ បកាសេតុំ បុព្វេ ទេវទត្តស្ស អញ្ញា បកតិ អហោសិ ឥទានិ អញ្ញា បកតិ យំ ទេវទត្តោ ករេយ្យ កាយេន វាចាយ ន តេន ពុទ្ធោ វា ធម្មោ វា សង្ឃោ វា ទដ្ឋព្វោ ទេវទត្តោវ តេន ទដ្ឋព្វោតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន អាយស្មា សារីបុត្តោ ទេវទត្តំ រាជគហេ បកាសេតុំ បុព្វេ ទេវទត្តស្ស អញ្ញា បកតិ អហោសិ ឥទានិ អញ្ញា បកតិ យំ ទេវទត្តោ ករេយ្យ កាយេន វាចាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ រឿងទេវទត្តភិក្ខុ និងបកាសនីយកម្ម

ទេវទត្តត្រូវគេឃើញដោយអំពើនោះតែម្យ៉ាង ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតព្រះសារីបុត្តដ៏មានអាយុ ឲ្យជាអ្នកប្រកាស (ទោស) ទេវទត្តក្នុងនគររាជគ្រឹះថា កាលពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះមានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្តត្រូវគេឃើញដោយអំពើនោះតែម្យ៉ាង ។ ការសន្មតព្រះសារីបុត្តដ៏មានអាយុឲ្យជាអ្នកប្រកាស (ទោស) ទេវទត្តក្នុងនគររាជគ្រឹះថា កាលពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះមានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្តត្រូវគេឃើញដោយអំពើនោះតែម្យ៉ាងដូច្នេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីនិយាយឡើង ។ សង្ឃបានសន្មតព្រះសារីបុត្តដ៏មានអាយុ ឲ្យជាអ្នកប្រកាស (ទោស) ទេវទត្តក្នុងនគររាជគ្រឹះថា ពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះមានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ន តេន ពុទ្ធោ វា ធម្មោ វា សង្ឃោ វា ទដ្ឋព្វោ ទេវទត្តោវ តេន ទដ្ឋព្វោតិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៤៩) សម្មតោ ចាយស្មា សារីបុត្តោ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ រាជគហំ បវិសិត្វា ទេវទត្តំ រាជគហេ បកាសេសិ បុព្វេ ទេវទត្តស្ស អញ្ញា បកតិ អហោសិ ឥទានិ អញ្ញា បកតិ យំ ទេវទត្តោ ករេយ្យ កាយេន វាចាយ ន តេន ពុទ្ធោ វា ធម្មោ វា សង្ឃោ វា ទដ្ឋព្វោ ទេវទត្តោវ តេន ទដ្ឋព្វោតិ ។ តត្ថ យេ តេ មនុស្សា អស្សទ្ធា អប្បសន្នា ទុព្ពុទ្ធិនោ តេ ឯវមាហំសុ ឧស្សុយ្យកា ឥមេ សមណា សក្យបុត្តិយា ទេវទត្តស្ស លាភសក្ការំ ឧស្សុយ្យន្តីតិ ។ យេ បន តេ មនុស្សា សទ្ធា បសន្នា បណ្ឌិតា សុពុទ្ធិមន្តោ[១] តេ ឯវមាហំសុ ន ខោ ឥទំ ឱរកំ ភវិស្សតិ យថា ភគវា ទេវទត្តំ រាជគហេ បកាសាបេតីតិ[២] ។

---

១ ឱ· ម· ពុទ្ធិមន្តោ ។ ២ ឱ· គតិសទ្ទោ ន បញ្ញាយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



អំពើនោះនាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្ត ត្រូវគេឃើញដោយអំពើនោះតែម្យ៉ាង ការសន្មតិនោះគួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកសេចក្តីនេះដោយអាការស្ងៀមយ៉ាងនេះ ។

[២៩] ព្រះសារីបុត្តដ៏មានអាយុដែលសង្ឃបានសន្មតរួចហើយ ក៏ចូលទៅនគររាជគ្រឹះជាមួយនឹងភិក្ខុច្រើនរូប បានប្រកាស (ទោស) ទេវទត្តក្នុងនគររាជគ្រឹះថា កាលពីដើម ទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះមានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្តត្រូវគេឃើញដោយកម្មនោះតែម្យ៉ាង ។ ក្នុងនគររាជគ្រឹះនោះ មនុស្សពួកណាដែលមិនមានសទ្ធា មិនជ្រះថ្លា ជាអ្នកឥតប្រាជ្ញា មនុស្សពួកនោះនិយាយគ្នាយ៉ាងនេះថា សមណសក្យបុត្តិយ៍ទាំងនេះ ជាអ្នកច្រណែនឈ្នានីសលាភសក្ការៈរបស់ទេវទត្ត ។ ចំណែកមនុស្សពួកណា ដែលមានសទ្ធាជ្រះថ្លា មានប្រាជ្ញាវាងវៃ មនុស្សពួកនោះនិយាយគ្នាថា ព្រះមានព្រះភាគឲ្យភិក្ខុសង្ឃប្រកាស (ទោស) ទេវទត្តក្នុងនគររាជគ្រឹះដោយកិច្ចណា កិច្ចនេះមិនមែនជាការថោកទាបទេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ ទេវទត្តវត្ថុ អជាតសត្តុកុមារវត្ថុ

(៣០) អថ ខោ ទេវទត្តោ យេន អជាតសត្តុ កុមារោ តេនុបសង្កមិ ឧបសង្កមិត្វា អជាតសត្តុំ កុមារំ ឯតទវោច បុព្វេ ខោ កុមារ មនុស្សា ទីឃាយុកា ឯតរហិ អប្បាយុកា ឋានំ ខោ បនេតំ វិជ្ជតិ យំ ត្វំ កុមារោវ សមានោ កាលំ ករេយ្យាសិ តេនហិ ត្វំ កុមារ បិតរំ ហន្ត្វា រាជា ហោហិ អហំ ភគវន្តំ ហន្ត្វា ពុទ្ធោ ភវិស្សាមីតិ ។ អថ ខោ អជាតសត្តុ កុមារោ អយ្យោ ខោ ទេវទត្តោ មហិទ្ធិកោ មហានុភាវោ ជានេយ្យាបិ[១] អយ្យោ ទេវទត្តោតិ ឩរុយា បោត្ថនិកំ ពន្ធិត្វា ទិវា ទិវស្ស ភីតោ ឧព្វិគ្គោ ឧស្សង្កី ឧត្រស្តោ សហសា អន្តេបុរំ បាវិសិ ។ អទ្ទសំសុ[២] ខោ អន្តេបុរេ ឱឡារិកា មហាមត្តា អជាតសត្តុំ កុមារំ ទិវា ទិវស្ស ភីតំ ឧព្វិគ្គំ ឧស្សង្កឹ ឧត្រស្តំ សហសា អន្តេបុរំ បវិសន្តំ ទិស្វាន អគ្គហេសុំ ។ តេ វិចិនន្តា ឩរុយា បោត្ថនិកំ ពទ្ធំ ទិស្វា អជាតសត្តុំ កុមារំ ឯតទវោចុំ កិំ ត្វំ កុមារ កត្តុកាមោសីតិ ។ បិតរំ ហន្តុកាមោម្ហីតិ[៣] ។ កេនាសិ ឧស្សាហិតោតិ ។

---

១ ឱ. ជានេយ្យាតិ ។ ម. ជានេយ្យាសិ ។ ២ ឱ. ប. អទ្ទសាសុំ ។ ៣ ឱ. បិតរំ ហិ ហន្តុកាមោតិ ។ ប. បិតរម្ហិ លន្តុកាមោតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## សង្ឃភេទក្ខន្ធកៈ រឿងទេវទត្តភិក្ខុ និងរឿងអជាតសត្តុកុមារ

(៣០) លំដាប់នោះ ទេវទត្តចូលទៅរកអជាតសត្តុកុមារ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះនឹងអជាតសត្តុកុមារថា ម្នាលកុមារ កាលពីដើម មនុស្សមានអាយុវែងវែង ឥឡូវនេះមានអាយុខ្លីណាស់ ព្រះអង្គនៅក្មេងក៏ពិត តែគង់ធ្វើមរណកាលដោយហេតុណា ហេតុនុ៎ះតែងតែមានជាប្រាកដ ម្នាលកុមារ បើដូច្នោះ ចូរព្រះអង្គសម្លាប់បិតា ហើយព្រះអង្គនឹងបានជាស្តេចទ្រង់រាជ្យ ឯអាត្មាក៏សម្លាប់ព្រះមានព្រះភាគ ហើយនឹងបានជាព្រះពុទ្ធដែរ ។ គ្រានោះ អជាតសត្តុកុមារគិតថា លោកម្ចាស់ទេវទត្តមានឫទ្ធិច្រើនផង មានអានុភាពច្រើនផង លោកម្ចាស់ទេវទត្តដឹង (ការនេះ) លុះគិតដូច្នោះហើយ ក៏សៀតកាំបិតស្នៀតបណ្តាយភ្លៅ មានសេចក្តីខ្លាច ញាប់ញ័ររន្ធត់ តក់ស្លុត ចូលទៅកាន់ព្រះរាជវាំង ដោយរួសរាន់ទាំងថ្ងៃត្រង់ ។ ពួកមហាមាត្រ ជាអ្នករក្សាព្រះរាជវាំង បានឃើញអជាតសត្តុកុមារ មានសេចក្តី ញាប់ញ័ររន្ធត់តក់ស្លុត ចូលទៅព្រះរាជវាំងដោយរួសរាន់ទាំងថ្ងៃត្រង់ ក៏នាំគ្នាចាប់ ។ ពួកមហាមាត្រទាំងនោះ ពិនិត្យមើលទៅឃើញមានសៀតកាំបិតស្នៀត បណ្តាយភ្លៅ ក៏ក្រាបទូលសួររឿងនុ៎ះនឹងអជាតសត្តុកុមារថា បពិត្រព្រះរាជកុមារ ព្រះអង្គចង់ធ្វើការអ្វី ។ អជាតសត្តុកុមារឆ្លើយថា យើងត្រូវការសម្លាប់បិតា ។ មហាមាត្រក្រាបទូលសួរថា អ្នកណាបញ្ចុះព្រះអង្គ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អយ្យេន ទេវទត្តេនាតិ ។ ឯកច្ចេ មហាមត្តា ឯវំ មតឹ អកំសុ កុមារោ ច ហន្តព្វោ ទេវទត្តោ ច សព្វេ ច ភិក្ខូ ហន្តព្វាតិ ។ ឯកច្ចេ មហាមត្តា ឯវំ មតឹ អកំសុ ន ភិក្ខូ ហន្តព្វា ន ភិក្ខូ កិញ្ចិ អបរជ្ឈន្តិ កុមារោ ច ហន្តព្វោ ទេវទត្តោ ចាតិ ។ ឯកច្ចេ មហាមត្តា ឯវំ មតឹ អកំសុ ន កុមារោ ហន្តព្វោ ន ទេវទត្តោ ន ភិក្ខូ ហន្តព្វា រញ្ញោ អារោចេតព្វំ យថា រាជា វក្ខតិ តថា ករិស្សាមាតិ ។

(៣១) អថខោ តេ មហាមត្តា អជាតសត្តុំ កុមារំ អាទាយ យេន រាជា មាគធោ សេនិយោ ពិម្ពិសារោ តេនុបសង្កមឹសុ ឧបសង្កមិត្វា រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស ឯតមត្ថំ អារោចេសុំ ។ កថំ ភណេ មហាមត្តេហិ មតិ កតាតិ ។ ឯកច្ចេ ទេវ មហាមត្តា ឯវំ មតឹ អកំសុ កុមារោ ច ហន្តព្វោ ទេវទត្តោ ច សព្វេ ច ភិក្ខូ ហន្តព្វាតិ ឯកច្ចេ មហាមត្តា ឯវំ មតឹ អកំសុ ន ភិក្ខូ ហន្តព្វា ន ភិក្ខូ កិញ្ចិ អបរជ្ឈន្តិ កុមារោ ច ហន្តព្វោ ទេវទត្តោ ចាតិ ឯកច្ចេ មហាមត្តា ឯវំ មតឹ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អជាតសត្តុកុមារឆ្លើយថា លោកម្ចាស់ទេវទត្ត (ពន្យល់យើង) ។ មហាមាត្រពួកខ្លះ វិនិច្ឆ័យយ៉ាងនេះថា ព្រះរាជកុមារ យើងត្រូវសម្លាប់ ទាំងទេវទត្តនឹងភិក្ខុទាំងពួងក៏យើងត្រូវសម្លាប់ ។ មហាមាត្រពួកខ្លះវិនិច្ឆ័យ យ៉ាងនេះថា យើងមិនត្រូវសម្លាប់ពួកភិក្ខុឡើយ ដ្បិតភិក្ខុទាំងនោះ មិនបានប្រទូស្តទេ យើងត្រូវសម្លាប់តែព្រះរាជកុមារនឹងទេវទត្ត ។ មហា-មាត្រពួកខ្លះវិនិច្ឆ័យថា កុមារក្តី ទេវទត្តក្តី ភិក្ខុទាំងឡាយក្តី យើងមិនត្រូវ សម្លាប់ទេ (រឿងនេះ) គួរយើងក្រាបទូលដល់ព្រះរាជាសិន បើព្រះរាជា មានព្រះរាជឱង្ការយ៉ាងណា សឹមយើងធ្វើយ៉ាងនោះ ។

(៣១) លំដាប់នោះ ពួកមហាមាត្រទាំងនោះនាំអជាតសត្តុកុមារចូល ទៅគាល់ព្រះបាទពិម្ពិសារមាគធសេនិយរាជ លុះចូលទៅដល់ហើយ ក៏ ក្រាបទូលរឿងនុ៎ះចំពោះព្រះបាទពិម្ពិសារមាគធសេនិយរាជ ។ ព្រះរាជា ទ្រង់ត្រាស់សួរថា ម្នាលនាយ ពួកមហាមាត្រវិនិច្ឆ័យដូចម្តេចខ្លះ ។ ពួក មហាមាត្រក្រាបទូលថា បពិត្រព្រះសម្មតិទេព មហាមាត្រពួកខ្លះវិនិច្ឆ័យ យ៉ាងនេះថា យើងត្រូវសម្លាប់ព្រះរាជកុមារផង ត្រូវសម្លាប់ទេវទត្តនឹងភិក្ខុ ទាំងអស់ផង មហាមាត្រពួកខ្លះវិនិច្ឆ័យយ៉ាងនេះថា យើងមិនត្រូវសម្លាប់ ពួកភិក្ខុឡើយ ព្រោះភិក្ខុទាំងនោះមិនបានប្រទូស្តទេ យើងត្រូវ សម្លាប់តែព្រះរាជកុមារនឹងទេវទត្ត មហាមាត្រពួកខ្លះវិនិច្ឆ័យយ៉ាងនេះថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## សង្ឃភេទក្ខន្ធកេ ទេវទត្តវត្ថុ មហាមត្តានំ មតិករណំ

អកំសុ ន កុមារោ ហន្តព្វោ ន ទេវទត្តោ ន ភិក្ខូ ហន្តព្វា រញ្ញោ អារោចេតព្វំ យថា រាជា វក្ខតិ តថា ករិស្សាមាតិ ។ កឹ ភណេ ករិស្សតិ ពុទ្ធោ វា ធម្មោ វា សង្ឃោ វា ននុ ភគវតា បដិកច្ចេវ ទេវទត្តោ រាជគហេ បកាសិតោ បុព្វេ ទេវទត្តស្ស អញ្ញា បកតិ អហោសិ ឥទានិ អញ្ញា បកតិ យំ ទេវទត្តោ ករេយ្យ កាយេន វាចាយ ន តេន ពុទ្ធោ វា ធម្មោ វា សង្ឃោ វា ទដ្ឋព្វោ ទេវទត្តោវ តេន ទដ្ឋព្វោតិ ។ តត្ថ យេ តេ មហាមត្តា ឯវំ មតឹ អកំសុ កុមារោ ច ហន្តព្វោ ទេវទត្តោ ច សព្វេ ច ភិក្ខូ ហន្តព្វាតិ តេ អដ្ឋានេ(១) អកាសិ ។ យេ តេ មហាមត្តា ឯវំ មតឹ អកំសុ ន ភិក្ខូ ហន្តព្វា ន ភិក្ខូ កិញ្ចិ អបរជ្ឈន្តិ កុមារោ ច ហន្តព្វោ ទេវទត្តោ ចាតិ តេ នីចេ ឋានេ ឋបេសិ ។ យេ តេ មហាមត្តា ឯវំ មតឹ អកំសុ ន កុមារោ ហន្តព្វោ ន ទេវទត្តោ ន ភិក្ខូ ហន្តព្វា រញ្ញោ អារោចេតព្វំ យថា រាជា វក្ខតិ តថា ករិស្សាមាតិ តេ

---

១ ឱ. អភព្វេ ។ ម. អភវេ ។

## សង្ខេបភេទក្ខន្ធកៈ រឿងទេវទត្តភិក្ខុ និងការវិច្ឆ័យនៃពួកមហាមាត្រ

កុមារក្តី ទេវទត្តក្តី ពួកភិក្ខុក្តី យើងមិនត្រូវសម្លាប់ (រឿងនេះ) គួរយើងក្រាបទូល ដល់ព្រះរាជាសិន បើព្រះរាជាមានព្រះរាជបន្ទូលយ៉ាងណា សឹមយើងធ្វើយ៉ាងនោះ ។ ព្រះរាជាទ្រង់មានព្រះបន្ទូលថា ម្នាលនាយ ព្រះពុទ្ធក្តី ព្រះធម៌ក្តី ព្រះសង្ឃក្តី នឹងធ្វើអ្វី ព្រះមានព្រះភាគទ្រង់បាត់ឲ្យភិក្ខុសង្ឃប្រកាសទោសទេវទត្តក្នុងគររាជគ្រឹះថា កាលពីដើមទេវទត្តមានប្រក្រតីផ្សេង ឥឡូវនេះ មានប្រក្រតីផ្សេង ទេវទត្តធ្វើអំពើណាដោយកាយវាចា អំពើនោះនាំគាត់ឲ្យលែងបានឃើញព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃហើយ ទេវទត្តត្រូវគេឃើញដោយកម្មនោះតែម្យ៉ាង ជាមុនរួចហើយ មិនដូច្នោះឬ ។ បណ្តាពួកមហាមាត្រទាំងនោះ មហាមាត្រពួកណា វិនិច្ឆ័យសេចក្តីថា យើងត្រូវសម្លាប់ទាំងកុមារទាំងទេវទត្ត ទាំងពួកភិក្ខុ (ព្រះរាជា) ទ្រង់ហូតឥស្សរមហាមាត្រទាំងនោះ ។ មហាមាត្រពួកណាវិនិច្ឆ័យថា យើងមិនត្រូវសម្លាប់ពួកភិក្ខុ ព្រោះពួកភិក្ខុមិនបានប្រទូស្តអ្វីទេ យើងត្រូវសម្លាប់តែព្រះរាជកុមារនឹងទេវទត្ត (ព្រះរាជា) ក៏បន្ថយឋានន្តរមហាមាត្រទាំងនោះក្នុងថ្នាក់ទាបវិញ ។ មហាមាត្រពួកណាវិនិច្ឆ័យថា កុមារក្តី ទេវទត្តក្តី ភិក្ខុទាំងឡាយក្តី យើងមិនត្រូវសម្លាប់ គួរយើងក្រាបទូលដល់ព្រះរាជាសិន បើព្រះរាជាមានព្រះរាជបន្ទូលយ៉ាងណា សឹមយើងធ្វើយ៉ាងនោះ (ព្រះរាជា) ក៏តាំងមហាមាត្រទាំងនោះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឧច្ចេ ឋានេ ឋបេសិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ អជាតសត្តុំ កុមារំ ឯតទវោច កិស្ស មំ ត្វំ កុមារ ហន្តុកាមោសីតិ ។ រជ្ជេនម្ហិ ទេវ អត្ថិកោតិ ។ សចេ ខោ ត្វំ កុមារ រជ្ជេន អត្ថិកោ ឯតំ តេ រជ្ជន្តិ អជាតសត្តុស្ស កុមារស្ស រជ្ជំ និយ្យាទេសិ ។

(៣២) អថខោ ទេវទត្តោ យេន អជាតសត្តុ កុមារោ តេនុបសង្កមិ ឧបសង្កមិត្វា អជាតសត្តុំ កុមារំ ឯតទវោច បុរិសេ មហារាជ អាណាបេហិ យេ សមណំ គោតមំ ជីវិតា វោរោបេស្សន្តីតិ ។ អថខោ អជាតសត្តុ កុមារោ មនុស្សេ អាណាបេសិ យថា ភណេ អយ្យោ ទេវទត្តោ អាហ តថា ករោថាតិ ។ អថខោ ទេវទត្តោ ឯកំ បុរិសំ អាណាបេសិ គច្ឆាវុសោ អមុកស្មឹ ឱកាសេ សមណោ គោតមោ វិហរតិ តំ ជីវិតា វោរោបេត្វា ឥមិនា មគ្គេន អាគច្ឆាតិ តស្មឹ មគ្គេ ទ្វេ បុរិសេ ឋបេសិ យោ ឥមិនា មគ្គេន ឯកោ បុរិសោ អាគច្ឆតិ តំ ជីវិតា វោរោបេត្វា ឥមិនា មគ្គេន អាគច្ឆថាតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ឲ្យឡើងបានខ្ពង់ខ្ពស់ ។ លំដាប់នោះ ព្រះបាទពិម្ពិសារមាគធសេនិយ-រាជ បានត្រាស់ព្រះតម្រាស់នេះនឹងអជាតសត្តុកុមារថា ម្នាលកុមារ អ្នកចង់សម្លាប់យើងដើម្បីអ្វី ។ អជាតសត្តុកុមារក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គត្រូវការដោយរាជសម្បត្តិ ។ ព្រះរាជាប្រគល់រាជ-សម្បត្តិដល់អជាតសត្តុកុមារថា ម្នាលកុមារ បើអ្នកត្រូវការដោយរាជសម្បត្តិ រាជសម្បត្តិនេះជារបស់អ្នកឯងហើយ ។

[៣៦] គ្រានោះ ទេវទត្តចូលទៅរកអជាតសត្តុកុមារ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងអជាតសត្តុកុមារថា បពិត្រមហារាជ សូមព្រះអង្គប្រើបុរសឲ្យទៅសម្លាប់ព្រះសមណគោតម ។ អជាតសត្តុកុមារបង្គាប់មនុស្សទាំងឡាយថា ម្នាលនាយ លោកម្ចាស់ទេវទត្ត មានថេរដីកាយ៉ាងណា ចូរអ្នកទាំងអស់គ្នា ធ្វើយ៉ាងនោះចុះ ។ គ្រានោះ ទេវទត្តបង្គាប់បុរសម្នាក់ថា ម្នាលនាយ ចូរអ្នកទៅសម្លាប់ព្រះសមណ-គោតមដែលគង់នៅក្នុងទីឯណោះ ហើយសឹមមកតាមផ្លូវនេះ បង្គាប់បុរសពីរនាក់ឲ្យឈរចាំទៀបផ្លូវនោះថា បុរសណាដែលមកតែម្នាក់ឯងតាមផ្លូវនេះ ចូរអ្នកទាំងពីរនាក់សម្លាប់បុរសនោះហើយសឹមដើរមកតាមផ្លូវនេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទកក្ខន្ធកេ ទេវទត្តវត្ថុ សត្ថុវធាយ បុរិសបេសនំ

តស្មឹ មគ្គេ ចត្តារោ បុរិសេ ឋបេសិ យេ ឥមិនា មគ្គេន ទ្វេ បុរិសា អាគច្ឆន្តិ តេ ជីវិតា វោរោបេត្វា ឥមិនា មគ្គេន អាគច្ឆថាតិ តស្មឹ មគ្គេ អដ្ឋ បុរិសេ ឋបេសិ យេ ឥមិនា មគ្គេន ចត្តារោ បុរិសា អាគច្ឆន្តិ តេ ជីវិតា វោរោបេត្វា ឥមិនា មគ្គេន អាគច្ឆថាតិ តស្មឹ មគ្គេ សោឡស បុរិសេ ឋបេសិ យេ ឥមិនា មគ្គេន អដ្ឋ បុរិសា អាគច្ឆន្តិ តេ ជីវិតា វោរោបេត្វា អាគច្ឆថាតិ ។

(៣៣) អថខោ សោ ឯកោ បុរិសោ អសិចម្មំ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ អវិទូរេ ភីតោ ឧព្វិគ្គោ ឧស្សង្កី ឧត្រស្តោ បត្ថទ្ធេន កាយេន អដ្ឋាសិ ។ អទ្ទសា ខោ ភគវា តំ បុរិសំ ភីតំ ឧព្វិគ្គំ ឧស្សង្កឹ ឧត្រស្តំ បត្ថទ្ធេន កាយេន ឋិតំ ទិស្វាន តំ បុរិសំ ឯតទវោច ឯហាវុសោ មា ភាយីតិ ។ អថខោ សោ បុរិសោ អសិចម្មំ ឯកមន្តំ ករិត្វា ធនុកលាបំ និក្ខិបិត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ បាទេសុ សិរសា និបតិត្វា ភគវន្តំ ឯតទវោច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បង្គាប់បុរស ៤ នាក់ឲ្យឈរចាំទៀបផ្លូវនោះថា (បើ)បុរសពីរនាក់ណាមកតាមផ្លូវនេះ ចូរអ្នកសម្លាប់បុរសទាំងពីរនាក់នោះហើយសឹមដើរមកតាមផ្លូវនេះ បង្គាប់បុរស ៨ នាក់ឲ្យឈរចាំទៀបផ្លូវនោះថា (បើ)បុរស៤នាក់ណាដើរមកតាមផ្លូវនេះ ចូរអ្នកសម្លាប់បុរសទាំង ៤ នាក់នោះហើយសឹមដើរមកតាមផ្លូវនេះ បង្គាប់បុរស ១៦ នាក់ឲ្យឈរចាំទៀបផ្លូវនោះថា (បើ) បុរស ៨ នាក់ណាដើរមកតាមផ្លូវនេះ ចូរអ្នកសម្លាប់បុរសទាំង៨ នាក់នោះហើយសឹមដើរមក( តាមផ្លូវនេះ) ។

( ៣៣ ) គ្រានោះ បុរសម្នាក់នោះកាន់ដាវនិងខែលស្ពាយធ្នូនិងបំពង់ព្រួញ ដើរសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ភ័យញាប់ញ័រខ្លួន តក់ស្លុត ឈរនឹងខ្លួនជិតព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ទតឃើញបុរសនោះ កំពុងភ័យញាប់ញ័រខ្លួន តក់ស្លុត ឈរគាំងខ្លួនដូច្នោះ លុះទ្រង់ទតឃើញហើយទើបត្រាស់ទៅនឹងបុរសនោះថា ម្នាលអ្នកដ៏មានអាយុ អ្នកឯងចូលមកចុះ កុំខ្លាចឡើយ ។ លំដាប់នោះ បុរសនោះទុកដាវនិងខែលក្នុងទីដ៏សមគួរ ហើយដាក់ធ្នូនិងបំពង់ព្រួញ ទើបដើរចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបចុះទៀបព្រះបាទារបស់ព្រះមានព្រះភាគដោយត្បូង ហើយក្រាបបង្គំទូលរឿងនេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យោហំ ទុដ្ឋចិត្តោ វធកចិត្តោ ឥធុបសង្កន្តោ តស្ស មេ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយាតិ ។ តគ្ឃ[១] ត្វំ អាវុសោ អច្ចយោ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យំ ត្វំ ទុដ្ឋចិត្តោ វធកចិត្តោ ឥធុបសង្កន្តោ យតោ ច ខោ ត្វំ អាវុសោ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោសិ តន្តេ មយំ បដិគ្គណ្ហាម វុឌ្ឍិ ហេសា អាវុសោ អរិយស្ស វិនយេ យោ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោតិ អាយតឹ សំវរំ អាបជ្ជតីតិ ។ អថ ខោ ភគវា តស្ស បុរិសស្ស អនុបុព្វិកថំ កថេសិ សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេសំ

---

១ ឱ. ប. តគ្ឃ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដក ចុល្លវគ្គ

ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កំហុសគ្របសង្កត់ហើយនូវខ្ញុំព្រះអង្គ តាមដោយខ្ញុំព្រះអង្គ ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស ខ្ញុំព្រះអង្គដែលមានចិត្តប្រទូស្ត មានចិត្តចង់សម្លាប់ ហើយដើរចូលមកដល់ទីនេះ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ អត់នូវកំហុសតាមទោសរបស់ខ្ញុំព្រះអង្គនោះ ដើម្បីនឹងសង្រួមតទៅទៀត ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអ្នកដ៏មានអាយុ ណ្ហើយចុះ អ្នកមានកំហុសគ្របសង្កត់ហើយ ព្រោះអ្នកឯងជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស អ្នកមានចិត្តប្រទូស្ត មានចិត្តចង់សម្លាប់ (តថាគត) ហើយដើរចូលមកដល់ទីនេះ ម្នាលអ្នកដ៏មានអាយុ បើអ្នកបានឃើញកំហុសតាមទោសខុសណាហើយ ចូរធ្វើឲ្យសមគួរតាមធម៌ តថាគតនឹងទទួលអត់ទោសរបស់អ្នកនោះ ម្នាលអ្នកដ៏មានអាយុ(បើ)អ្នកណាមួយបានឃើញកំហុសតាមទោសខុសពិតហើយសំដែង (ទោសនោះ) តាមធម៌ ដល់នូវសេចក្តីសង្រួមតទៅ នេះជាសេចក្តីចំរើនរបស់អ្នកនោះក្នុងអរិយវិន័យ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់សំដែងនូវអនុបុព្វីកថាដល់បុរសនោះ អនុបុព្វីកថានោះដូចម្តេច ព្រះអង្គទ្រង់សំដែងទានកថា សីលកថា សគ្គកថា នឹងទោសនៃកាមដែលថោកទាបសៅហ្មង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ ទេវទត្តវត្ថុ អត្ថុប្បត្តិកថា

នេក្ខម្មេ អានិសំសំ បកាសេសិ ។ យទា តំ ភគវា អញ្ញាសិ កល្លចិត្តំ មុទុចិត្តំ វិនីវរណចិត្តំ ឧទគ្គចិត្តំ បសន្នចិត្តំ អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។ សេយ្យថាបិ នាម សុទ្ធំ វត្ថំ អបគតកាឡកំ សម្មទេវ រជនំ បដិគ្គណ្ហេយ្យ(១) ឯវមេវ តស្ស បុរិសស្ស តស្មិំយេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំកិញ្ចិ សមុទយធម្មំ សព្វំ តំ និរោធធម្មន្តិ ។ អថខោ សោ បុរិសោ ទិដ្ឋធម្មោ បត្តធម្មោ វិទិតធម្មោ បរិយោគាឡ្ហធម្មោ តិណ្ណវិចិកិច្ឆោ វិគតកថំកថោ វេសារជ្ជប្បត្តោ អបរប្បច្ចយោ សត្ថុសាសនេ ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ

---

១ ម. បដិគ្គហេយ្យ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ រឿងទេវទត្តភិក្ខុ នឹងអនុបុព្វីកថា

អានិសង្សក្នុងការចេញបួស ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា បុរសនោះមានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណធម៌ មានចិត្តរីករាយ មានចិត្តជ្រះថ្លាក្នុងកាលណាហើយ ធម្មទេសនាណា ជារបស់ព្រះពុទ្ធទាំងឡាយ ដែលទ្រង់លើកឡើងសំដែងដោយព្រះអង្គឯង ព្រះអង្គក៏ប្រកាសនូវធម្មទេសនានោះគឺទុក្ខ ១ សមុទ័យ ១ និរោធ ១ មគ្គ ១ ក្នុងកាលនោះ ៗ សំពត់ស្អាតឥតមានពណ៌ខ្មៅ គួរទទួលនូវគ្រឿងជ្រលក់ដោយល្អយ៉ាងណាមិញ បុរសនោះអង្គុយលើអាសនៈនោះ កើតធម្មចក្ខុគឺសោតាបត្តិ-មគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិលថា ធម្មជាតណាមួយ តែងកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះរមែងរលត់ទៅវិញជាធម្មតា ដូច្នោះដែរ ។ លំដាប់នោះ បុរសនោះឃើញធម៌ច្បាស់ហើយ បានលុះធម៌ហើយ ដឹងធម៌ច្បាស់ហើយ មានចិត្តចុះកាន់ធម៌ស៊ប់ហើយ ឆ្លងផុតសេចក្តីសង្ស័យហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ហើយ ដល់នូវសេចក្តីក្លៀវក្លា មិនជឿបុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្តា ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធា-រេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។ អថខោ ភគវា តំ បុរិសំ ឯតទវោច មា ខោ ត្វំ អាវុ-សោ ឥមិនា មគ្គេន គច្ឆ ឥមិនា មគ្គេន គច្ឆាហីតិ អញ្ញេន មគ្គេន ឧយ្យោជេសិ ។

(៣៤) អថខោ តេ ទ្វេ បុរិសា កឹ នុ ខោ សោ ឯកោ បុរិសោ ចិរេន អាគច្ឆតីតិ បដិបថំ គច្ឆន្តា អទ្ទសំសុ ភគវន្តំ អញ្ញតរស្មឹ រុក្ខមូលេ និសិន្នំ ទិស្វាន យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិ-វាទេត្វា ឯកមន្តំ និសីទឹសុ ។ តេសំ ភគវា អនុបុព្វឹ-កថំ កថេសិ ។ បេ ។ អបរប្បច្ចយា សត្ថុសាសនេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះអង្គបានសំដែងហើយដោយអនេកបរិយាយ(យ៉ាងនេះ) គួរនាដូចជាគេបើករបស់ដែលផ្កាប់ឲ្យផ្ងារឡើង ពុំនោះ ដូចជាមនុស្សបើកបង្ហាញរបស់ដែលគេបិទបាំងទុក ពុំនោះសោត ដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ឬក៏ដូចគេទ្រោលប្រទីបក្នុងទីងងឹត ឲ្យមនុស្សដែលមានភ្នែកមើលឃើញរូបបាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹក សូមព្រះមានព្រះភាគ ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់ហើយនូវព្រះរត្នត្រ័យ ជាទីពឹងទីរលឹកស្មើដោយជីវិត តាំងអំពីថ្ងៃនេះទៅ ។ លំដាប់នោះ ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះនឹងបុរសនោះថា ម្នាលអ្នកដ៏មានអាយុ អ្នកកុំទៅតាមផ្លូវនេះ ចូរទៅតាមផ្លូវនេះវិញ ហើយក៏បញ្ជូនបុរសនោះទៅតាមផ្លូវដទៃទៅ ។

[៣៤] គ្រានោះ បុរសទាំងពីរនាក់នោះគិតគ្នាថា បុរសម្នាក់នោះដូចម្តេចក៏ក្រមកម្ល៉េះ ហើយក៏នាំគ្នាទៅកាន់ផ្លូវជួបគ្នា ប្រហាប់គេបានឃើញព្រះមានព្រះភាគ គង់ទៀបគល់ឈើមួយ លុះឃើញហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះទៅដល់ហើយ ក៏ក្រាបអភិវាទចំពោះព្រះមានព្រះភាគហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះមានព្រះភាគទ្រង់សំដែងនូវអនុបុព្វីកថាដល់បុរសទាំងពីរនាក់នោះ ។ បេ ។ បុរសទាំងពីរនាក់នោះ

## សង្ឃភេទក្ខន្ធកេ ទេវទត្តវត្ថុ អនុបុព្វិកថា

ករោន្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ ។ បេ ។ ឧបាសកោ នោ ភន្តេ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។ អថខោ ភគវា តេ បុរិសេ ឯតទវោច មា ខោ ត្វំ អាវុសោ ឥមិនា មគ្គេន គច្ឆ ឥមិនា មគ្គេន គច្ឆាតិ អញ្ញេន មគ្គេន ឧយ្យោជេសិ ។

(៣៥) អថខោ តេ ចត្តារោ បុរិសា ។ បេ ។ អថខោ តេ អដ្ឋ បុរិសា ។ បេ ។ អថខោ តេ សោឡស បុរិសា កិំ នុ ខោ តេ អដ្ឋ បុរិសា ចិរេន អាគច្ឆន្តីតិ បដិបថំ គច្ឆន្តា អទ្ទសំសុ ភគវន្តំ អញ្ញតរស្មឹ រុក្ខមូលេ និសិន្នំ ទិស្វាន យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ តេសំ ភគវា អនុបុព្វឹ កថំ កថេសិ សេយ្យថីទំ ទានកថំ សីលកថំ ។ បេ ។ អបរប្បច្ចយា សត្ថុសាសនេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



ក៏មិនជឿបុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្ដា ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ ។ បេ ។ សូមព្រះមានព្រះភាគចាំទុកនូវយើងខ្ញុំទាំងឡាយថាជាឧបាសកអ្នកដល់ហើយនូវព្រះរតនត្រ័យ ជាទីពឹងទីរលឹកស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះទៅ ។ លំដាប់នោះ ព្រះមានព្រះភាគ បានត្រាស់ព្រះតម្រាស់នេះនឹងបុរសទាំងពីរនាក់នោះថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ ពួកអ្នកកុំដើរទៅតាមផ្លូវនេះ ចូរអ្នកដើរទៅតាមផ្លូវនេះវិញ ហើយក៏បញ្ជូនទៅតាមផ្លូវដទៃទៅ ។

(៣៩) គ្រានោះ បុរស ៤ នាក់ ។ បេ ។ គ្រានោះ បុរស ៨ នាក់ ។ បេ ។ គ្រានោះ បុរស ១៦ នាក់គិតគ្នាថា បុរស៨នាក់ ដូចម្ដេចក៏ត្រ មកម្ល៉េះ ហើយទៅកាន់ផ្លូវជួបគ្នា ស្រាប់តែបានឃើញព្រះមានព្រះភាគ គង់នៅទៀបគល់ឈើមួយ លុះឃើញហើយ ក៏ចូលទៅរកព្រះមានព្រះភាគ ក្រាបអភិវាទចំពោះព្រះមានព្រះភាគហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះមានព្រះភាគ ទ្រង់សំដែងអនុបុព្វីកថាដល់បុរសទាំង ១៦ នាក់នោះ អនុបុព្វីកថានោះដូចម្ដេច គឺទានកថា សីលកថា ។ បេ ។ បុរសទាំង ១៦ នាក់នោះ មិនជឿបុគ្គលដទៃក្នុងសាសនារបស់ព្រះសាស្ដា ហើយបាន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ ។ បេ ។ ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។ អថខោ សោ ឯកោ បុរិសោ យេន ទេវទត្តោ តេនុបសង្កមិ ឧបសង្កមិត្វា ទេវទត្តំ ឯតទវោច នាហំ ភន្តេ សក្កោមិ តំ ភគវន្តំ ជីវិតា វោរោបេតុំ មហិទ្ធិកោ សោ ភគវា មហានុភាវោតិ ។ អលំ អាវុសោ មា ត្វំ សមណំ គោតមំ ជីវិតា វោរោបេសិ អហមេវ សមណំ គោតមំ ជីវិតា វោរោបេស្សាមីតិ ។

[៣៦] តេន ខោ បន សមយេន ភគវា គិជ្ឈកូដស្ស បព្វតស្ស ឆាយាយំ(១) ចង្កមតិ ។ អថខោ ទេវទត្តោ គិជ្ឈកូដំ បព្វតំ អភិរុហិត្វា(២) មហតឹ(៣) សិលំ បវិជ្ឈិ ឥមាយ សមណំ គោតមំ ជីវិតា វោរោបេស្សាមីតិ ។ ទ្វេ បព្វតកូដា សមាគន្ត្វា តំ សិលំ សម្បដិច្ឆឹសុ ។ តតោ បបដិកា ឧប្បតិត្វា ភគវតោ បាទេ រុហិរំ ឧប្បាទេសិ ។ អថខោ ភគវា ឧទ្ធំ ឧល្លោកេត្វា ទេវទត្តំ ឯតទវោច ពហុំ តយា មោឃបុរិស

១ ឱ. បច្ឆាយាយំ ។ ២ ឱ. អភិរូហិត្វា ។ ម. អារោហិត្វា ។ ៣ ឱ. មហន្តំ ។

ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ភាសិតរបស់ព្រះអង្គពី-រោះណាស់ ។ បេ ។ សូមព្រះមានព្រះភាគចាំទុកនូវយើងខ្ញុំថាជាឧបា-សក អ្នកដល់ហើយនូវព្រះរត្នត្រ័យជាទីពឹងស្មើដោយជីវិត ចាប់ដើមពីថ្ងៃនេះទៅ ។ លំដាប់នោះឯង មានបុរសម្នាក់ចូលទៅរកទេវទត្ត លុះចូលទៅដល់ហើយបាននិយាយពាក្យនេះនឹងទេវទត្តថា បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណា មិនអាចនឹងសម្លាប់ព្រះមានព្រះភាគនោះទេ ដ្បិតព្រះមានព្រះភាគនោះ មានឫទ្ធិច្រើន មានអានុភាពច្រើនណាស់ ។ ទេវទត្តនិយាយថា ណ្ហើយ អ្នកដ៏មានអាយុ បើអ្នកមិនអាចនឹងសម្លាប់ព្រះសម-ណគោតមបានទេ ទុកឲ្យយើងឯងនឹងសម្លាប់ព្រះសមណគោតមវិញ ។

[៣៦] សម័យនោះឯង ព្រះមានព្រះភាគទ្រង់ចង្រ្កម ក្នុងម្លប់ភ្នំគិជ្ឈកូដ ។ លំដាប់នោះ ទេវទត្តឡើងទៅលើ(កំពូល) ភ្នំគិជ្ឈកូដ ហើយប្រមៀលដុំថ្មធំដោយបំណងថា អញនឹងសម្លាប់ព្រះសមណគោតមដោយដុំថ្មនេះ ។ ឯកំពូលភ្នំទាំងពីរក៏មកប្រជុំគ្នានឹងដុំថ្មនោះ ។ គ្រានោះ បំណែកថ្មក៏ខ្ទាតឡើងទង្គិចធ្វើព្រះលោហិត ក្នុងព្រះបាទព្រះមានព្រះភាគ ឲ្យពុះពងឡើង ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ទតព្រះនេត្រទៅខាងលើ ហើយមានព្រះពុទ្ធដីកាទៅរកទេវទត្តថា នែមោឃបុរស

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ ទេវទត្តោ តថាគតស្ស លោហិតុប្បាទកោ

អបុញ្ញំ បសុតំ យំ ត្វំ ទុដ្ឋចិត្តោ វធកចិត្តោ តថាគតស្ស រុហិរំ ឧប្បាទេសីតិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ ឥទំ ភិក្ខវេ ទេវទត្តេន បឋមំ អានន្តរិកកម្មំ ឧបចិតំ យំ ទុដ្ឋចិត្តេន វធកចិត្តេន តថាគតស្ស រុហិរំ ឧប្បាទិ-តន្តិ ។ អស្សោសុំ ខោ ភិក្ខូ ទេវទត្តេន កិរ ភគវ-តោ វធោ បយុត្តោតិ ។ តេ ច ភិក្ខូ ភគវតោ វិហារស្ស បរិតោ បរិតោ ចង្កមន្តិ ឧច្ចាសទ្ទា មហាសទ្ទា សជ្ឈាយំ ករោន្តា ភគវតោ រក្ខាវរណគុត្តិយា ។ អស្សោសិ ខោ ភគវា ឧច្ចាសទ្ទំ មហាសទ្ទំ សជ្ឈាយសទ្ទំ សុត្វាន អា-យស្មន្តំ អានន្ទំ អាមន្តេសិ កិន្នុ ខោ សោ អានន្ទ ឧច្ចា-សទ្ទោ មហាសទ្ទោ សជ្ឈាយសទ្ទោតិ ។ អស្សោសុំ ខោ ភន្តេ ភិក្ខូ ទេវទត្តេន កិរ ភគវតោ វធោ បយុត្តោតិ តេ ច[១] ភន្តេ ភិក្ខូ ភគវតោ វិហារស្ស បរិតោ បរិតោ ចង្កមន្តិ ឧច្ចាសទ្ទា មហាសទ្ទា សជ្ឈាយំ ករោន្តា ភគវតោ រក្ខាវរណគុត្តិយា សោ ឯសោ ភគវា ឧច្ចា-

១ ឱ. តេធ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





អ្នកឯងមានចិត្តប្រទុស្ត មានចិត្តបង់សម្លាប់ ហើយធ្វើលោហិតរបស់តថាគតឲ្យពុះពងឡើងដោយអំពើណា អំពើនោះអ្នកនឹងដើមអកុសលកម្មច្រើន(១) ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តជាចិត្តប្រទុស្ត មានចិត្តបង់សម្លាប់ បានធ្វើលោហិតរបស់តថាគតឲ្យពុះពងឡើង ដោយអំពើណា អំពើនេះឈ្មោះថាអនន្តរិយកម្មដែលទេវទត្តសន្សំមកជាដំបូង ។ ភិក្ខុទាំងឡាយបានឮដំណឹងថាទេវទត្តព្យាយាមសម្លាប់ព្រះមានព្រះភាគហើយ ។ ពួកភិក្ខុទាំងនោះបង្រួមពទ្ធជុំវិញវិហារ របស់ព្រះមានព្រះភាគ នាំគ្នាស្រែកធ្វើសំឡេងតឹកកងខ្លាំង ធ្វើស្ងូរព្រួយ ដើម្បីរក្សាការពារគ្រប់គ្រងព្រះមានព្រះភាគ ។ ព្រះមានព្រះភាគបានឮសំឡេងតឹកកង សំឡេងខ្លាំង សំឡេងស្ងូរ-ព្រួយ លុះទ្រង់ឮហើយត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា ម្នាលអា-នន្ទ សំឡេងតឹកកង សំឡេងខ្លាំង សំឡេងស្ងូរព្រួយ នោះតើជាសំឡេងអ្វី ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុទាំងឡាយបានឮដំណឹងថា ទេវទត្តព្យាយាមសម្លាប់ព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុទាំងនោះក៏បង្រួមពទ្ធជុំវិញវិហារ របស់ព្រះមានព្រះភាគ នាំគ្នាស្រែកធ្វើសំឡេងតឹកកង សំឡេងខ្លាំង ធ្វើស្ងូរព្រួយ ដើម្បីរក្សាការពារគ្រប់គ្រងព្រះមានព្រះភាគ បពិត្រព្រះមានព្រះភាគ សំឡេងតឹកកង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



សទ្ទោ មហាសទ្ទោ សជ្ឈាយសទ្ទោតិ ។ តេនហានន្ទ មម វចនេន តេ ភិក្ខូ អាមន្តេហិ(១) សត្ថា អាយស្មន្តេ អាមន្តេតីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុត្វា យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច សត្ថា អាយស្មន្តេ អាមន្តេតីតិ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ អានន្ទស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ តេ ភិក្ខូ ភគវា ឯតទវោច អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ បរូបក្កមេន តថាគតំ ជីវិតា វោរោបេយ្យ ន ឧបក្កមេន ភិក្ខវេ តថាគតា បរិនិព្វាយន្តិ(២) ។ បញ្ចិមេ ភិក្ខវេ សត្ថារោ សន្តោ សំវិជ្ជមានា លោកស្មឹ កតមេ បញ្ច ឥធ ភិក្ខវេ ឯកច្ចោ សត្ថា អបរិសុទ្ធសីលោ សមានោ បរិសុទ្ធសីលោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ សីលំ

---

១ ម. អាមន្តេសិ ។ ២ ឱ. ម. អនុបក្កមេន ភិក្ខវេ តថាគតា បរិនិព្វាយន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សំឡេងខ្ពស់ សំឡេងក្រូកក្រាយនោះ គឺជាសំឡេងនោះឯង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះចូរអ្នកហៅភិក្ខុទាំងនោះមកតាមពាក្យតថាគតថា ព្រះសាស្តាឲ្យហៅលោកដ៏មានអាយុទាំងឡាយ ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ករុណាព្រះអង្គ រួចហើយក៏ចូលសំដៅទៅរកភិក្ខុទាំងឡាយ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងភិក្ខុទាំងនោះថា ព្រះសាស្តាត្រាស់ឲ្យហៅលោកដ៏មានអាយុទាំងឡាយ ។ ភិក្ខុទាំងឡាយនោះទទួលស្តាប់ពាក្យអានន្ទដ៏មានអាយុថា យ៉ាងនេះហើយអាវុសោ រួចហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបបង្គំ ចំពោះព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ បានត្រាស់ប្រាប់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកណា ព្យាយាមសម្លាប់តថាគត សេចក្តីព្យាយាមសម្លាប់របស់អ្នកនោះមិនមែនជាហេតុ មិនមែនជាឱកាស (គួរកើតបានឡើយ) ម្នាលភិក្ខុទាំងឡាយ ព្រោះព្រះតថាគតទាំងឡាយ មិនដែលបរិនិព្វាន ដោយសេចក្តីព្យាយាមរបស់អ្នកដទៃទេ ។ ម្នាលភិក្ខុទាំងឡាយ គ្រូក្នុងលោកនេះមាន ៥ ពួក គ្រូទាំង ៥ ពួកនោះគឺគ្រូណាខ្លះ ម្នាលភិក្ខុទាំងឡាយ គ្រូ ១ ពួកក្នុងលោកនេះ មានសីលមិនបរិសុទ្ធ តែប្តេជ្ញាថា អាត្មាមានសីលបរិសុទ្ធខ្លះ ជាសីល

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





បរិយោទាតំ អសង្កិលិដ្ឋន្តិ ច ។ តមេនំ សាវកា ឯវំ ជានន្តិ អយំ ខោ ភវំ សត្ថា អបរិសុទ្ធសីលោ សមានោ បរិសុទ្ធសីលោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ សីលំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ច មយញ្ចេវ ខោ បន គិហីនំ អារោចេយ្យាម នាស្សស្ស មនាបំ យំ ខោ បនស្ស អមនាបំ កថន្តំ[១] មយំ តេន សមុទាចរេយ្យាម សម្មន្នតិ ខោ បន ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន យំ តុមោ[២] ករិស្សតិ តុមោ[៣] តេន បញ្ញាយិស្សតីតិ ។ ឯវរូបំ ខោ ភិក្ខវេ សត្ថារំ សាវកា សីលតោ រក្ខន្តិ ។ ឯវរូបោ ច បន សត្ថា សាវកេហិ សីលតោ រក្ខំ បច្ចាសីសតិ ។

(៣៧) បុន ចបរំ ភិក្ខវេ ឥធេកច្ចោ សត្ថា អបរិសុទ្ធាជីវោ សមានោ បរិសុទ្ធាជីវោម្ហីតិ បដិជានាតិ ។បេ។ ឯវរូបំ ខោ ភិក្ខវេ សត្ថារំ សាវកា អាជីវតោ រក្ខន្តិ ។ ឯវរូបោ ច បន សត្ថា សាវកេហិ អាជីវតោ រក្ខំ បច្ចាសីសតិ ។

---

១ ម. កថំ នំ ។ ២-៣ ម. តុម្ហោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



របស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ។ ពួកសាវ័កតែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះ មានសីលមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានសីលបរិសុទ្ធខ្លះ ថាសីលរបស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ផូរប្តុះ បើយើងប្រាប់ (រឿងនោះ)ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្តទេ កាលរឿងណាមិនគាប់ចិត្តដល់លោក យើងនឹងសើរើរឿងលោកនោះដូចម្តេចបាន ព្រោះលោកកំពុងគ្រប់គ្រង (យើង) ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា គង់លោកនឹងប្រាកដឡើង ព្រោះកម្មនោះមិនខាន ។ ម្នាលភិក្ខុទាំងឡាយ ពួកសាវ័កតែងរក្សាគ្រូបែបនេះ ដោយសីល ។ ឯគ្រូបែបនេះ តែងនឹកសង្ឃឹមនូវការរក្សាពីពួកសាវ័កដោយសីល ។

(៣៧) ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃទៅមានទៀត គ្រូ ១ ពួកក្នុងលោកនេះមានអាជីវៈមិនបរិសុទ្ធ តែប្តេជ្ញាខ្លួនថា អញមានអាជីវៈបរិសុទ្ធខ្លះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកសាវ័កតែងរក្សាគ្រូបែបនេះដោយអាជីវៈ ។ ឯគ្រូបែបនេះ តែងនឹកសង្ឃឹមនូវការរក្សាពីពួកសាវ័កដោយអាជីវៈ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(៣៨) បុន ចបរំ ភិក្ខវេ ឥធេកច្ចោ សត្ថា អបរិសុទ្ធធម្មទេសនោ សមានោ បរិសុទ្ធធម្មទេសនោម្ហីតិ បដិជានាតិ ។ បេ ។ ឯវរូបំ ខោ ភិក្ខវេ សត្ថារំ សាវកា ធម្មទេសនតោ រក្ខន្តិ ។ ឯវរូបោ ច បន សត្ថា សាវកេហិ ធម្មទេសនតោ រក្ខំ បច្ចាសីសតិ ។

(៣៩) បុន ចបរំ ភិក្ខវេ ឥធេកច្ចោ សត្ថា អបរិសុទ្ធវេយ្យាករណោ សមានោ បរិសុទ្ធវេយ្យាករណោម្ហីតិ បដិជានាតិ ។ បេ ។ ឯវរូបំ ខោ ភិក្ខវេ សត្ថារំ សាវកា វេយ្យាករណតោ រក្ខន្តិ ។ ឯវរូបោ ច បន សត្ថា សាវកេហិ វេយ្យាករណតោ រក្ខំ បច្ចាសីសតិ ។

(៤០) បុន ចបរំ ភិក្ខវេ ឥធេកច្ចោ សត្ថា អបរិសុទ្ធញាណទស្សនោ សមានោ បរិសុទ្ធញាណទស្សនោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ ញាណទស្សនំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ច ។ តមេនំ សាវកា ឯវំ ជានន្តិ អយំ ខោ ភវំ សត្ថា អបរិសុទ្ធញាណទស្សនោ បរិសុទ្ធញាណទស្សនោម្ហីតិ បដិជានាតិ បរិសុទ្ធំ មេ ញាណទស្សនំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣៨) ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃទៅមានទៀត គ្រូ ១ ពួកក្នុងលោកនេះ មានធម្មទេសនាមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានធម្មទេសនាបរិសុទ្ធខ្លះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សាវ័កតែងរក្សាគ្រូបែបនេះដោយធម្មទេសនា ។ ឯគ្រូបែបនេះតែងនឹកសង្ឃឹមនូវការរក្សាអំពីពួកសាវ័កដោយធម្មទេសនា ។

(៣៩) ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃទៅមានទៀត គ្រូ ១ ពួកក្នុងលោកនេះមានវេយ្យាករណ៍មិនបរិសុទ្ធ តែប្តេជ្ញាថា អញមានវេយ្យា-ករណ៍បរិសុទ្ធខ្លះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកសាវ័កតែងរក្សាគ្រូបែបនេះដោយវេយ្យាករណ៍ ។ ឯគ្រូបែបនេះតែងនឹកសង្ឃឹមនូវការរក្សាអំពីពួកសាវ័កដោយវេយ្យាករណ៍ ។

(៤០) ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃទៅមានទៀត គ្រូ ១ ពួកក្នុងលោកនេះមានញាណទស្សនៈមិនបរិសុទ្ធ តែប្តេជ្ញាថា អញមានញាណ-ទស្សនៈបរិសុទ្ធខ្លះ ថាញាណទស្សនៈរបស់អញបរិសុទ្ធផូរផង់ឥតមានសៅហ្មងខ្លះ ។ សាវ័កទាំងឡាយតែងដឹងគ្រូនោះយ៉ាងនេះថា គ្រូដ៏ចំរើននេះ បានញាណទស្សនៈមិនបរិសុទ្ធតែប្តេជ្ញាថាអញបានញាណទស្សនៈបរិសុទ្ធខ្លះ ថាញាណទស្សនៈរបស់អញបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ដូច្នេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



## សង្ឃភេទក្ខន្ធកេ ទេវទត្តវត្ថុ បញ្ចសត្ថុកថា

មយញ្ចេវ ខោ បន គិហីនំ អារោចេយ្យាម នាស្សស្ស មនាបំ យំ ខោ បនស្ស អមនាបំ កថន្តំ មយន្តេន សមុទាចរេយ្យាម សម្មន្នតិ ខោ បន ចីវរបិណ្ឌបាត-សេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន យំ តុមោ ករិស្សតិ តុមោ វ តេន បញ្ញាយិស្សតីតិ ។ ឯវរូបំ ខោ ភិក្ខវេ សត្ថារំ សាវកា ញាណទស្សនតោ រក្ខន្តិ ។ ឯវរូបោ ច បន សត្ថា សាវកេហិ ញាណ-ទស្សនតោ រក្ខំ បច្ចាសីសតិ ។ ឥមេ ខោ ភិក្ខវេ បញ្ច សត្ថារោ សន្តោ សំវិជ្ជមានា លោកស្មឹ ។ អហំ ខោ បន ភិក្ខវេ បរិសុទ្ធសីលោ សមានោ បរិសុទ្ធសីលោម្ហីតិ បដិជានាមិ បរិសុទ្ធំ មេ សីលំ បរិយោទាតំ អសង្កិលិដ្ឋន្តិ ច ។ ន ច មំ សាវកា សីលតោ រក្ខន្តិ ។ ន ចាហំ សាវកេហិ សីលតោ រក្ខំ បច្ចាសីសាមិ ។ អហំ ខោ បន ភិក្ខវេ បរិ-សុទ្ធាជីវោ សមានោ ។បេ។ បរិសុទ្ធធម្មទេសនោ សមានោ ។បេ។ បរិសុទ្ធវេយ្យាករណោ ។បេ។ បរិ-សុទ្ធញាណទស្សនោ សមានោ បរិសុទ្ធញាណទស្ស-នោម្ហីតិ បដិជានាមិ បរិសុទ្ធំ មេ ញាណទស្សនំ

## សង្ឃភេទក្ខន្ធកៈ រឿងទេវទត្តភិក្ខុ និយាយអំពី គ្រូ ៥ ពួក

បើយើងប្រាប់ (រឿងនោះ) ដល់ពួកគ្រហស្ថ គង់លោកមិនគាប់ចិត្តទេ ក៏រឿងណា មិនគាប់ចិត្តដល់លោក យើងនឹងសើរើរឿងលោកនោះដូចម្ដេចបាន ព្រោះលោកកំពុងពប់កាន់យើង ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ លោកនឹងធ្វើកម្មណា គង់លោកនឹងប្រាកដឡើង ព្រោះកម្មនោះមិនខាន ។ ម្នាលភិក្ខុទាំងឡាយ ពួកសាវ័ករមែងរក្សាគ្រូបែបនេះដោយញាណទស្សនៈ ។ ក៏គ្រូបែបនេះតែងនឹកសង្ឃឹមនូវការរក្សាអំពីពួកសាវ័កដោយញាណទស្សនៈ ។ ម្នាលភិក្ខុទាំងឡាយ គ្រូទាំង ៥ ពួកនេះឯង តែងមានក្នុងលោកនេះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគត ជាអ្នកមានសីលបរិសុទ្ធ ទើបប្ដេជ្ញាថាតថាគតមានសីលបរិសុទ្ធខ្លះ ថាសីលរបស់តថាគតបរិសុទ្ធផូរផង់ ឥតមានសៅហ្មងខ្លះ ។ ឯសាវ័កទាំងឡាយមិនបានរក្សាតថាគតដោយសីលទេ ។ ចំណែកតថាគតក៏មិននឹកសង្ឃឹមនូវការរក្សាអំពីពួកសាវ័កទាំងឡាយដោយសីលឡើយ ។ ម្នាលភិក្ខុទាំងឡាយ ម៉្យាងទៀត តថាគតជាអ្នកមានអាជីវៈបរិសុទ្ធ ។បេ។ មានធម្មទេសនាបរិសុទ្ធ ។ បេ ។ មានវេយ្យាករណ៍បរិសុទ្ធ ។ បេ ។ មានញាណទស្សនៈបរិសុទ្ធ ទើបប្ដេជ្ញាថាតថាគតមានញាណទស្សនៈបរិសុទ្ធខ្លះ ថាញាណទស្សនៈរបស់តថាគតបរិសុទ្ធ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បរិយោទាតំ អសង្កិលិដ្ឋន្តិ ច ។ ន ច មំ សាវកា ញាណទស្សនតោ រក្ខន្តិ ។ ន ចាហំ សាវកេហិ ញាណទស្សនតោ រក្ខំ បច្ចាសីសាមិ ។ អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យោ បរូបក្កមេន តថាគតំ ជីវិតា វោរោបេយ្យ ន បរូបក្កមេន(១) ភិក្ខវេ តថាគតា បរិ-និព្វាយន្តិ ។ គច្ឆថ តុម្ហេ ភិក្ខវេ យថាវិហារំ អរក្ខិយា ភិក្ខវេ តថាគតាតិ ។

(៤១) តេន ខោ បន សមយេន រាជគហេ នាឡាគិរិ នាម ហត្ថី ចណ្ឌោ ហោតិ មនុស្សឃាត-កោ ។ អថ ខោ ទេវទត្តោ រាជគហំ បវិសិត្វា ហត្ថិ-សាលំ គន្ត្វា ហត្ថិភណ្ឌេ ឯតទវោច មយំ ខោ ភណេ រាជញាតកា នាម បដិពលា នីចដ្ឋានិយំ ឧច្ចដ្ឋានេ ឋបេតុំ ភត្តំបិ វេតនំបិ វឌ្ឍាបេតុំ តេនហិ ភណេ យទា សមណោ គោតមោ ឥមំ រច្ឆំ បដិបន្នោ ហោតិ

១ ឱ. ម. អនុបក្កមេន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



ផូរផង់ ឥតមានសៅហ្មងខ្លះ ។ ឯសាវ័កទាំងឡាយមិនបានរក្សាតថាគត ដោយញាណទស្សនៈឡើយ ។ ចំណែកតថាគតក៏មិនរកសង្ឃឹមនូវការរក្សាអំពីពួកសាវ័កដោយញាណទស្សនៈដែរ ។ ម្នាលភិក្ខុទាំងឡាយ អ្នកណាព្យាយាមសម្លាប់តថាគត សេចក្តីព្យាយាមសម្លាប់របស់អ្នកនោះមិនមែនជាហេតុ មិនមែនជាឱកាស (គួរឲ្យធ្វើបានឡើយ) ម្នាលភិក្ខុទាំងឡាយ ព្រោះព្រះតថាគតទាំងឡាយ មិនដែលបរិនិព្វានដោយសេចក្តីព្យាយាមរបស់បុគ្គលដទៃទេ ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទៅកាន់វិហាររបស់ខ្លួនចុះ ម្នាលភិក្ខុទាំងឡាយ ព្រោះព្រះតថាគតទាំងឡាយ មិនបាច់មានបុគ្គលរក្សាទេ ។

(៤១) ក៏សម័យនោះឯង ក្នុងនគររាជគ្រឹះ មានដំរី ១ ឈ្មោះនាឡាគិរី ជាសត្វកាចសាហាវ តែងសម្លាប់មនុស្ស ។ លំដាប់នោះ ទេវទត្តចូលទៅកាន់នគររាជគ្រឹះ ហួសទៅដល់រោងដំរី ហើយបាននិយាយពាក្យនេះនឹងពួកអ្នករក្សាដំរីថា នែនាយ យើងនេះជាព្រះញាតិនឹងស្តេច អាចតាំងអ្នកដែលនៅក្នុងតំណែងទាបឲ្យនៅក្នុងតំណែងខ្ពស់ក៏បាន អាចបង្កើនភត្តនឹងបៀវត្សក៏បាន ម្នាលនាយ បើដូច្នោះ ព្រះសមណគោតមដើរមកកាន់ច្រកនេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ ទេវទត្តវត្ថុ នាឡាគិរិហត្ថិមុញ្ចនំ

តទា ឥមំ នាឡាគិរឹ ហត្ថឹ មុញ្ចិត្វា ឥមំ រច្ឆំ បដិបា-
ទេថាតិ ។ ឯវំ ភន្តេតិ ខោ តេ ហត្ថិភណ្ឌា ទេវទត្តស្ស
បច្ចស្សោសុំ ។ អថខោ ភគវា បុព្វណ្ហសមយំ និវា-
សេត្វា បត្តចីវរមាទាយ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ
រាជគហំ បាវិសិ ។ អថខោ ភគវា តំ រច្ឆំ បដិបជ្ជិ ។
អទ្ទសំសុ ខោ តេ ហត្ថិភណ្ឌា ភគវន្តំ តំ រច្ឆំ បដិ-
បន្នំ ទិស្វាន នាឡាគិរឹ ហត្ថឹ មុញ្ចិត្វា តំ រច្ឆំ បដិបា-
ទេសុំ ។ អទ្ទសា ខោ នាឡាគិរិ ហត្ថី ភគវន្តំ ទូរតោ
វ អាគច្ឆន្តំ ទិស្វាន សោណ្ឌំ ឧស្សាបេត្វា បហដ្ឋ-
កណ្ណវាលោ យេន ភគវា តេន អភិធាវិ ។ អទ្ទសំសុ
ខោ តេ ភិក្ខូ នាឡាគិរឹ ហត្ថឹ ទូរតោ វ អាគច្ឆន្តំ ទិ-
ស្វាន ភគវន្តំ ឯតទវោចុំ អយំ ភន្តេ នាឡាគិរិ ហត្ថី
ចណ្ឌោ ផរុសោ(១) មនុស្សឃាតកោ ឥមំ រច្ឆំ បដិ-
បន្នោ បដិក្កមតុ ភន្តេ ភគវា បដិក្កមតុ សុគតោតិ ។
អាគច្ឆថ ភិក្ខវេ មា ភាយិត្ថ អដ្ឋានមេតំ ភិក្ខវេ អ-
នវកាសោ យំ បរូបក្កមេន តថាគតំ ជីវិតា វោរោ-
បេយ្យ ន បរូបក្កមេន ភិក្ខវេ តថាគតា បរិនិព្វា-

១ ឱ. ម. បោត្ថកេសុ ផរុសោតិ ន បញ្ញាយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ រឿងទេវទត្តភិក្ខុ នឹងការលែងដំរីនាឡាគិរី

ពេលណា ចូរអ្នកលែងដំរីនាឡាគិរីនេះឲ្យដើរទៅកាន់ច្រកនេះក្នុងពេលនោះ ៗ ពួកអ្នករក្សាដំរីទាំងនោះទទួលស្តាប់ពាក្យទេវទត្តថា ករុណាលោកម្ចាស់ ៗ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅកាន់នគររាជគ្រឹះជាមួយនឹងភិក្ខុទាំងឡាយជាច្រើនរូប ៗ លំដាប់នោះ ព្រះមានព្រះភាគស្តេចទៅកាន់ច្រកនោះ ៗ ឯពួកអ្នករក្សាដំរីទាំងនោះ បានឃើញព្រះមានព្រះភាគស្តេចទៅកាន់ច្រកនោះ លុះឃើញហើយក៏លែងដំរីនាឡាគិរីឲ្យដើរទៅកាន់ច្រកនោះ ៗ ដំរីនាឡាគិរីបានឃើញព្រះមានព្រះភាគស្តេចមកអំពីចម្ងាយលឹមៗ លុះឃើញហើយក៏លើកប្រមោយ សម្រឹងត្រចៀកនិងកន្ទុយ ស្ទុះទៅរកព្រះមានព្រះភាគ ៗ ពួកភិក្ខុទាំងនោះ បានឃើញដំរីនាឡាគិរីមកអំពីចម្ងាយលឹម ៗ លុះឃើញហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ដំរីនាឡាគិរីនេះកាចអាក្រក់ ជាសត្វសម្លាប់មនុស្ស (ឥឡូវ)ដើរមកកាន់ច្រកនេះហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគថយចេញ សូមព្រះសុគតស្តេចថយចេញ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកមកចុះ កុំខ្លាចឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកណាព្យាយាមសម្លាប់តថាគត សេចក្តីព្យាយាមសម្លាប់របស់អ្នកនោះមិនមែនជាហេតុ មិនមែនជាឱកាស (គួរធ្វើបានឡើយ) ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យន្តីតិ ។ ទុតិយម្បិ ខោ តេ ភិក្ខូ ។ បេ ។ តតិ-យម្បិ ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ អយំ ភន្តេ នាឡាគិរិ ហត្ថី ចណ្ឌោ ផរុសោ មនុស្សឃាតកោ ឥមំ រច្ឆំ បដិបន្នោ បដិក្កមតុ ភន្តេ ភគវា បដិក្ក-មតុ សុគតោតិ ។ អាគច្ឆថ ភិក្ខវេ មា ភាយិត្ថ អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យោ បរូបក្កមេន តថាគតំ ជីវិតា វោរោបេយ្យ ន បរូបក្កមេន ភិក្ខវេ តថាគតា បរិនិព្វាយន្តីតិ

(៤២) តេន ខោ បន សមយេន មនុស្សា បាសា-ទេសុបិ ហម្មិយេសុបិ ឆទនេសុបិ អារូឡ្ហា អច្ឆន្តិ ។ តត្ថ យេ តេ មនុស្សា អស្សទ្ធា អប្បសន្នា ទុប្បញ្ញា តេ ឯវមាហំសុ អភិរូបោ វត ភោ គោតមោ[1] មហា-សមណោ នាគេន វិហេឋិយិស្សតីតិ ។ យេ បន តេ មនុស្សា សទ្ធា បសន្នា បណ្ឌិតា ពុទ្ធិមន្តោ

១ អយំ គោតមោតិ ឱរោបិយបោត្ថកេ នត្ថិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រោះព្រះតថាគតទាំងឡាយ មិនដែលបរិនិព្វាន ដោយសេចក្តីព្យាយាមរបស់អ្នកដទៃទេ ។ ពួកភិក្ខុទាំងនោះបានក្រាបបង្គំទូលព្រះមានព្រះភាគអស់វារៈពីរដងផង ។ បេ ។ ពួកភិក្ខុទាំងនោះបានក្រាបបង្គំទូលព្រះមានព្រះភាគអស់វារៈបីដងផងថា បពិត្រព្រះអង្គដ៏ចំរើន ដំរីនាឡាគិរីនេះកាចអាក្រក់ ជាសត្វសម្លាប់មនុស្ស (ឥឡូវ) ដើរមកកាន់ច្រកនេះហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគថយចេញ សូមព្រះសុគតស្តេចថយចេញ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកមកចុះ កុំខ្លាចឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកណាព្យាយាមសម្លាប់តថាគត សេចក្តីព្យាយាមសម្លាប់របស់អ្នកនោះ មិនមែនជាហេតុ មិនមែនជាឱកាស ម្នាលភិក្ខុទាំងឡាយ ព្រោះព្រះតថាគតទាំងឡាយមិនដែលបរិនិព្វាន ដោយសេចក្តីព្យាយាមរបស់បុគ្គលដទៃទេ ។

[៤២] សម័យនោះឯង មនុស្សទាំងឡាយនាំគ្នាឡើងទៅនៅលើប្រាសាទខ្លះ លើប្រាសាទមានដំបូលត្រឹមខ្លះ លើដំបូលផ្ទះខ្លះ ។ បណ្តាពួកមនុស្សទាំងនោះ មនុស្សពួកណាមិនទាន់មានសទ្ធា មិនទាន់ជ្រះថ្លា ឥតប្រាជ្ញា មនុស្សពួកនោះនិយាយគ្នាយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន លោកសមណៈឈ្មោះគោតមមានរូបល្អណាស់ ប៉ុន្តែមុខជាត្រូវដំរីបៀតបៀន ។ ចំណែកខាងមនុស្សពួកណា មានសទ្ធាជ្រះថ្លា ជាបណ្ឌិត មានប្រាជ្ញា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តេ ឯវមាហំសុ នចិរស្ស[១] វត ភោ នាគោ នាគេន សង្គាមេស្សតីតិ ។ អថ ខោ ភគវា នាឡាគិរឹ ហត្ថឹ មេត្តេន ចិត្តេន ផរិ ។ អថ ខោ នាឡាគិរិ ហត្ថី ភគវតោ មេត្តេន ចិត្តេន ផុដ្ឋោ សោណ្ឌំ ឱរោបេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ បុរតោ អដ្ឋាសិ ។ អថ ខោ ភគវា ទក្ខិណេន ហត្ថេន នាឡាគិរិស្ស ហត្ថិស្ស កុម្ភំ បរាមសន្តោ នាឡាគិរឹ ហត្ថឹ គាថាហិ អជ្ឈភាសិ

(៤៣) មា កុញ្ជរ នាគមាសទោ
ទុក្ខំ ហិ កុញ្ជរ នាគមាសទោ ។
ន ហិ នាគហតស្ស កុញ្ជរ
សុគតិ ហោតិ ឥតោ បរំ យតោ ។
មា ច មទោ មា ច បមាទោ
ន ហិ បមត្តា សុគតឹ វជន្តិ តេ ។
ត្វញ្ញេវ[២] តថា ករិស្សសិ
យេន ត្វំ សុគតឹ គមិស្សសីតិ ។

១ ឱ. នសេទ្ធោ ឧត្តិ ។ ២ ម. តេន ត្វញ្ញេវ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មនុស្សពួកនោះនិយាយគ្នាយ៉ាងនេះថា ម្នាលគ្នាយើង មិនយូរប៉ុន្មានឡើយ មុខជាព្រះពុទ្ធនាគនឹងធ្វើសង្គ្រាមជាមួយនឹងហត្ថិនាគ (នេះ) ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ផ្សាយមេត្តាចិត្តទៅកាន់ដំរីនាឡាគិរី ។ គ្រានោះ ដំរីនាឡាគិរីដែលមេត្តាចិត្តរបស់ព្រះមានព្រះភាគពាល់ត្រូវហើយ ក៏ដាក់ប្រមោយចុះ ចូលទៅជិតព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានឈរនៅចំពោះព្រះភក្ត្រព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ យកព្រះហស្តខាងស្តាំស្ទាបពោងដំរីនាឡាគិរី ហើយសំដែងគាថាចំពោះដំរីនាឡាគិរីនោះថា

(៤៣) ម្នាលកុញ្ជរ អ្នកកុំចូលមកប៉ុនប៉ងសម្លាប់ព្រះពុទ្ធនាគឡើយ ម្នាលកុញ្ជរ ព្រោះថាការចូលមកប៉ុនប៉ងសម្លាប់ព្រះពុទ្ធនាគ ជាហេតុឲ្យកើតទុក្ខ ។ ម្នាលកុញ្ជរ កាលបើអ្នកសម្លាប់ព្រះពុទ្ធនាគហើយ ទៅអំពីជាតិនេះទៅកាន់លោកខាងមុខ (អ្នក) មិនបានទៅកើតក្នុងសុគតិទេ ។ ចូរអ្នកលែងស្រវឹង លែងប្រមាទទៅ ព្រោះថាសត្វទាំងឡាយដែលប្រមាទហើយ តែងមិនបានទៅកាន់សុគតិឡើយ ។ អ្នកនឹងទៅកាន់សុគតិ ដោយប្រការដែលអ្នកធ្វើខ្លួនឯង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[៦៦] អថខោ នាឡាគិរិ ហត្ថី សោណ្ឌាយ ភគវតោ បាទបំសូនិ គហេត្វា ឧបរិមុទ្ធនិ អាកិរិត្វា បដិកុដិកោ(១) បដិសក្កិ យាវ ភគវន្តំ អទ្ទក្ខិ ។ អថខោ នាឡាគិរិ ហត្ថី ហត្ថិសាលំ គន្ត្វា សកេ ដ្ឋានេ អដ្ឋាសិ ។ តថាទន្តោ ច បន នាឡាគិរិ ហត្ថី អហោសិ ។

[៦៧] តេន ខោ បន សមយេន មនុស្សា ឥមំ គាថំ គាយន្តិ

ទណ្ឌេនេកេ ទមយន្តិ
អង្កុសេហិ កសាហិ ច
អទណ្ឌេន អសត្ថេន
នាគោ ទន្តោ មហេសិនាតិ ។

មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ យាវ បាបោ អយំ ទេវទត្តោ អលក្ខិកោ យត្រ ហិ នាម សមណស្ស គោតមស្ស ឯវំមហិទ្ធិកស្ស ឯវំមហានុភាវស្ស វធាយ បរក្កមិស្សតីតិ ។ ទេវទត្តស្ស លាភសក្ការោ បរិហាយិ ។ ភគវតោ ច លាភសក្ការោ អភិវឌ្ឍិ ។

១ ឱ. បដិកុដិយោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៤៦) លំដាប់នោះ ដំរីនាឡាគិរីចាប់ល្អងធូលីដែលជាប់នឹងព្រះបាទព្រះមានព្រះភាគ ដោយប្រមោយ យកមករោយរាយលើក្បាល ហើយបែរមុខចំព្រះមានព្រះភាគ អន្ថយចេញមុខថយក្រោយ ដរាបតាលតែលែងឃើញព្រះមានព្រះភាគ ។ លំដាប់នោះ ដំរីនាឡាគិរីដើរទៅកាន់រោងដំរី ក៏បានឈរនៅក្នុងកន្លែងរបស់ខ្លួនដដែល ។ ព្រះមានព្រះភាគបានទូន្មានដំរីនាឡាគិរី ដោយប្រការដូច្នេះឯង ។

(៤៧) សម័យនោះឯង មនុស្សទាំងឡាយនាំគ្នាច្រៀងគាថានេះថា

ជនពួក ១ តែងទូន្មាន (ដំរី) ដោយដំបងខ្លះ ដោយកង្វេរ
ខ្លះ ដោយរំពាត់ខ្លះ (ចំណែក) ព្រះពុទ្ធដែលព្រះអង្គស្វែង
រកនូវគុណធំ ឥតមានដំបង ឥតមានគ្រឿងសស្ត្រាវុធទេ តែ
អាចទូន្មានហត្ថិនាគបាន ។

មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ទេវទត្តនេះជាមនុស្សអាក្រក់ ជាអ្នកឥតបុណ្យសោះ មិនសមបើនឹងព្យាយាមសម្លាប់ព្រះសមណគោតម ដែលមានឫទ្ធិច្រើន មានអានុភាពច្រើនយ៉ាងនេះឡើយ ។ ទេវទត្តក៏សាបសូន្យលាភសក្ការៈទៅ ។ ឯលាភសក្ការៈក៏កើតតែចំរើនឡើងដល់ព្រះមានព្រះភាគ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទកក្ខន្ធកេ ទេវទត្តវត្ថុ តិកភោជនំ

[៤៦] តេន ខោ បន សមយេន ទេវទត្តោ
បរិហីនលាភសក្ការោ សបរិសោ កុលេសុ វិញ្ញាបេត្វា
វិញ្ញាបេត្វា ភុញ្ជតិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ
កថំ ហិ នាម សមណា សក្យបុត្តិយា កុលេសុ
វិញ្ញាបេត្វា វិញ្ញាបេត្វា ភុញ្ជិស្សន្តិ កស្ស សម្បន្នំ ន
មនាបំ កស្ស សាទុំ ន រុច្ចតីតិ ។ អស្សោសុំ ខោ
ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបា-
ចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ
ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ទេវទត្តោ សបរិសោ
កុលេសុ វិញ្ញាបេត្វា វិញ្ញាបេត្វា ភុញ្ជិស្សតីតិ ។ ភគវតោ
ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ត្វំ ទេវទត្ត
សបរិសោ កុលេសុ វិញ្ញាបេត្វា វិញ្ញាបេត្វា ភុញ្ជសីតិ ។
សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា
ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ ភិក្ខូនំ កុលេសុ
តិកភោជនំ បញ្ញាបេស្សាមិ តយោ អត្ថវសេ បដិច្ច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



## សង្ឃភេទក្ខន្ធកៈ រឿងទេវទត្តភិក្ខុ នឹងតិកភោជន

[៤៦] សម័យនោះឯង ទេវទត្តព្រមទាំងបរិសទ្យសាបសូន្យលាភសក្ការៈ ហើយក៏នាំគ្នាអែអង្គាសគ្រប់ត្រកូលមកបរិភោគ ៗ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើសមណៈទាំងឡាយជាសក្យបុត្តិយ៍នាំគ្នាអែអង្គាសគ្រប់ត្រកូលយកមកឆាន់សោះ អ្នកណាមិនពេញចិត្តនឹងរបស់សម្បុណ៌ អ្នកណាមិនគាប់ចិត្តនឹងរបស់ឆ្ងាញ់ ៗ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ៗ ភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ទេវទត្តព្រមទាំងបរិសទ្យមិនសមបើនឹងអែអង្គាសគ្រប់ត្រកូលយកមកឆាន់សោះ ៗ ភិក្ខុទាំងឡាយក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលទេវទត្ត បានឮថាអ្នកព្រមទាំងបរិសទ្យអែអង្គាសគ្រប់ត្រកូលយកមកបរិភោគ ពិតមែនឬ ។ ទេវទត្តក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។ បេ ។ ព្រះពុទ្ធមានព្រះភាគទ្រង់បន្ទោសហើយ ធ្វើនូវធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងអនុញ្ញាតតិកភោជន[១] គ្រប់ត្រកូលដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ៣ យ៉ាង (គឺ) ដើម្បីនឹងផ្ចាញ់ផ្ចាល់

---

១ ភោជនដែលឆាន់បានត្រឹមបីរូប បើភិក្ខុតាំងពី ៤ រូបឡើងទៅឆាន់មិនបាន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ បេសលានំ ភិក្ខូនំ ផាសុវិហារាយ មា ភិក្ខូ បាបិច្ឆា បក្ខំ និស្សាយ សង្ឃំ ភិន្ទេយ្យុន្តិ(១) កុលានុទ្ទយតាយ(២) ច គណភោជនេ យថាធម្មោ ការេតព្វោតិ ។

(៤៧) អថ ខោ ទេវទត្តោ យេន កោកាលិកោ កដមោរកតិស្សកោ ខណ្ឌទេវិយាបុត្តោ សមុទ្ទទត្តោ តេនុបសង្កមិ ឧបសង្កមិត្វា កោកាលិកំ កដមោរក-តិស្សកំ ខណ្ឌទេវិយាបុត្តំ សមុទ្ទទត្តំ ឯតទវោច ឯថ មយំ អាវុសោ សមណស្ស គោតមស្ស សង្ឃភេទំ ក-រិស្សាម ចក្កភេទន្តិ ។ ឯវំ វុត្តេ កោកាលិកោ ទេវទត្តំ ឯតទវោច សមណោ ខោ អាវុសោ គោតមោ មហិទ្ធិកោ មហានុភាវោ កថំ មយំ សមណស្ស គោតមស្ស សង្ឃ-ភេទំ ករិស្សាម ចក្កភេទន្តិ ។ ឯថ មយំ អាវុសោ សមណំ គោតមំ ឧបសង្កមិត្វា បញ្ច វត្ថូនិ យាចិស្សាម ភន្តេ ភគវា អនេកបរិយាយេន អប្បិច្ឆស្ស សន្តុដ្ឋស្ស សល្លេ-

---

១ ឱ. ម. អា មា បាបិច្ឆា បក្ខំ និស្សាយ សង្ឃំ ភិន្ទេយ្យុំ ។ ២ ឱ. ម កុលានុទ្ទយាយ ។

ខ្ទប់បុគ្គលទាំងឡាយដែលមិនមានអៀនខ្មាស ១ ដើម្បីកិរិយានៅជាសុខស្រួលដល់ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ជាកុំឲ្យពួកភិក្ខុមានសេចក្តីប្រាថ្នាដ៏លាមក អាស្រ័យបក្ខពួកហើយនាំគ្នាបំបែកសង្ឃ ១ ដើម្បីសេចក្តីអាណិតដល់ត្រកូល ១ (វិនយធរ) ត្រូវកាត់សេចក្តីតាមអាបត្តិក្នុងគណភោជនសិក្ខាបទនុ៎ះ ។

(៤៧) គ្រានោះ ទេវទត្តដើរចូលទៅរកកោកាលិកភិក្ខុ កដមោរកតិស្សកភិក្ខុ ខណ្ឌទេវិយាបុត្តភិក្ខុ និងសមុទ្ទទត្តភិក្ខុ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះទៅនឹងកោកាលិកភិក្ខុ កដមោរកតិស្សកភិក្ខុ ខណ្ឌទេវិយាបុត្តភិក្ខុ និងសមុទ្ទទត្តភិក្ខុថា ម្នាលអាវុសោទាំងឡាយ អ្នកចូរមក ពួកយើងនឹងធ្វើការបំបែកសង្ឃនិងចំលាយចក្ររបស់ព្រះសមណគោតម ។ កាលបើទេវទត្ត និយាយយ៉ាងនេះហើយ កោកាលិកភិក្ខុក៏បាននិយាយពាក្យនេះទៅនឹងទេវទត្តថា ម្នាលអាវុសោ ព្រះសមណគោតម មានឫទ្ធិច្រើន មានអានុភាពច្រើនណាស់ ពួកយើងនឹងធ្វើការបំបែកសង្ឃនិងចំលាយចក្ររបស់ព្រះសមណគោតមដូចម្តេចបាន ។ ទេវទត្តឆ្លើយថា ម្នាលអាវុសោ ចូរអ្នកទាំងឡាយមក ពួកយើងនឹងនាំគ្នាចូលទៅគាល់ព្រះសមណគោតមហើយទូលសុំវត្ថុ ៥ ប្រការថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគតែងសរសើរគុណ នៃបុគ្គលអ្នកមានសេចក្តីប្រាថ្នាតិចអ្នកសន្តោស

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខស្ស ធុតស្ស បាសាទិកស្ស អបចយស្ស វីរិយារម្ភស្ស វណ្ណវាទី ឥមានិ ភន្តេ បញ្ច វត្ថូនិ អនេកបរិយាយេន អប្បិច្ឆតាយ សន្តុដ្ឋតាយ[១] សល្លេខាយ ធុតាយ[២] បាសាទិកតាយ អបចយាយ វីរិយារម្ភាយ សំវត្តន្តិ សាធុ ភន្តេ ភិក្ខូ យាវជីវំ អារញ្ញកា អស្សុ យោ គាមន្តំ ឱសរេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ បិណ្ឌបាតិកា អស្សុ យោ និមន្តនំ សាទិយេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ បំសុកូលិកា អស្សុ យោ គហបតិចីវរំ សាទិយេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ រុក្ខមូលិកា អស្សុ យោ ឆន្នំ ឧបគច្ឆេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ មច្ឆមំសំ ន ខាទេយ្យុំ យោ មច្ឆមំសំ ខាទេយ្យ វជ្ជំ នំ ផុសេយ្យាតិ ឥមានិ បញ្ច វត្ថូនិ[៣] សមណោ គោតមោ នានុជានិស្សតិ តេ ច[៤] មយំ ឥមេហិ បញ្ចហិ វត្ថូហិ ជនំ សញ្ញាបេស្សាមាតិ ។

---

១ ឱ. ម. សន្តុដ្ឋិយា ។ ២ ឱ. ម. ធុតតាយ ។ ៣ ឱ. ម. បោត្ថកេសុ ឥទំ បទទ្វយំ ន ទិស្សតិ ។ ៤ ឱ. ម. បោត្ថកេសុ ចសទ្ទោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ រឿងទេវទត្តភិក្ខុ សំដែងអំពីវត្ថុ ៥ ប្រការ

ផុសខាត់ចិត្ត ទ្រទ្រង់ធុតង្គវត្ត គួរជាទីជ្រះថ្លា មិនសន្សំកិលេសវដ្ដៈ ប្រារព្ធសេចក្ដីព្យាយាមៈដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន វត្ថុ ៥ប្រ-ការទាំងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាតិច ដើម្បីសន្ដោស ដើម្បីផុសខាត់ចិត្ត ដើម្បីធុតង្គវត្ត ដើម្បីសេចក្ដីជ្រះថ្លា ដើម្បីមិនសន្សំកិលេសវដ្ដៈ ដើម្បីប្រារព្ធសេចក្ដីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់មេត្តាប្រោស សូមឲ្យភិក្ខុទាំងឡាយនៅតែក្នុងព្រៃជាវត្តអស់មួយជីវិត ភិក្ខុណានៅក្នុងស្រុក ភិក្ខុនោះនឹងត្រូវទោស សូមឲ្យភិក្ខុទាំងឡាយកាន់បិណ្ឌបាតជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយការនិមន្ត ភិក្ខុនោះនឹងត្រូវទោស សូមឲ្យភិក្ខុទាំងឡាយប្រើប្រាស់តែសំពត់បង្សុកូលអស់មួយជីវិត ភិក្ខុណាត្រេកអរចំពោះគហបតិចីវរ ភិក្ខុនោះនឹងត្រូវទោស សូមឲ្យភិក្ខុទាំងឡាយនៅទៀបគល់ឈើជាវត្តអស់មួយជីវិត ភិក្ខុណាចូលទៅនៅក្នុងទីប្រក់ទីបាំង ភិក្ខុនោះនឹងត្រូវទោស សូមកុំឲ្យភិក្ខុទាំងឡាយឆាន់ត្រីនឹងសាច់អស់មួយជីវិត ភិក្ខុណាឆាន់ត្រីនឹងសាច់ ភិក្ខុនោះនឹងត្រូវទោស ព្រះសមណគោតមមុខជាមិនអនុញ្ញាតវត្ថុ ៥ ប្រការនេះឲ្យទេ ហើយពួកយើងឯងនឹងពន្យល់ជន (ឲ្យត្រេកអរនឹងយើង)ដោយវត្ថុ ៥ ប្រការនេះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សក្កា ខោ អាវុសោ ឥមេហិ បញ្ចហិ វត្ថូហិ សមណស្ស គោតមស្ស សង្ឃភេទោ កាតុំ ចក្កភេទោ លូខប្បសន្នា ហិ អាវុសោ មនុស្សាតិ ។

(៤៨) អថខោ ទេវទត្តោ សបរិសោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ទេវទត្តោ ភគវន្តំ ឯតទវោច ភគវា ភន្តេ អនេកបរិយាយេន អប្បិច្ឆស្ស សន្តុដ្ឋស្ស សល្លេខស្ស ធុតស្ស បាសាទិកស្ស អបចយស្ស វីរិយារម្ភស្ស វណ្ណវាទី ឥមានិ ភន្តេ បញ្ច វត្ថូនិ អនេកបរិយាយេន អប្បិច្ឆតាយ សន្តុដ្ឋតាយ សល្លេខាយ ធុតាយ បាសាទិកតាយ អបចយាយ វីរិយារម្ភាយ សំវត្តន្តិ សាធុ ភន្តេ ភិក្ខូ យាវជីវំ អារញ្ញកា អស្សុ យោ គាមន្តំ ឱសរេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



គោកាលិកភិក្ខុនិយាយថា ម្នាលអាវុសោ ពួកយើងអាចនឹងធ្វើការទំលាយសង្ឃ ទំលាយចក្ររបស់ព្រះសមណគោតម ដោយវត្ថុ ៥ ប្រការនេះបាន ម្នាលអាវុសោទាំងឡាយ ដ្បិតមនុស្សទាំងឡាយដែលជ្រះថ្លាដោយវត្ថុសៅហ្មង (មានច្រើន) ។

(៤៨) គ្រានោះ ទេវទត្តព្រមទាំងបរិសទ្យ ចូលទៅគាល់ព្រះមានព្រះភាគជាម្ចាស់ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំចំពោះព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះទេវទត្តអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះទ្រង់យសតែងសរសើរគុណនៃបុគ្គលអ្នកមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស ផុសខាត់ចិត្ត ទ្រទ្រង់ធុតង្គវត្ត គួរជាទីជ្រះថ្លា មិនសន្សំកិលេសវដ្ដៈ ប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន វត្ថុ ៥ ប្រការទាំងនេះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នាតិច ដើម្បីសន្តោស ដើម្បីផុសខាត់ចិត្ត ដើម្បីធុតង្គវត្ត ដើម្បីសេចក្តីជ្រះថ្លា ដើម្បីមិនសន្សំកិលេសវដ្ដៈ ដើម្បីប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់មេត្តាប្រោស សូមឲ្យភិក្ខុទាំងឡាយនៅតែក្នុងព្រៃជាវត្តអស់មួយជីវិត ភិក្ខុណានៅក្នុងស្រុក ភិក្ខុនោះនឹងត្រូវទោស សូមឲ្យភិក្ខុទាំងឡាយកាន់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ ទេវទត្តវត្ថុ បញ្ចវត្ថុយាចនា

បិណ្ឌបាតិកា អស្សុ យោ និមន្តនំ សាទិយេយ្យ វជ្ជំ
នំ ផុសេយ្យ យាវជីវំ បំសុកូលិកា អស្សុ យោ គហ-
បតិចីវរំ សាទិយេយ្យ វជ្ជំ នំ ផុសេយ្យ យាវជីវំ រុក្ខមូ-
លិកា អស្សុ យោ ឆន្នំ ឧបគច្ឆេយ្យ វជ្ជំ នំ ផុសេយ្យ
យាវជីវំ មច្ឆមំសំ ន ខាទេយ្យុំ យោ មច្ឆមំសំ ខាទេយ្យ
វជ្ជំ នំ ផុសេយ្យាតិ ។ អលំ ទេវទត្ត យោ ឥច្ឆតិ អា-
រញ្ញកោ ហោតុ យោ ឥច្ឆតិ គាមន្តេ វិហរតុ យោ ឥច្ឆតិ
បិណ្ឌបាតិកោ ហោតុ យោ ឥច្ឆតិ និមន្តនំ សាទិយតុ
យោ ឥច្ឆតិ បំសុកូលិកោ ហោតុ យោ ឥច្ឆតិ គហបតិ-
ចីវរំ សាទិយតុ អដ្ឋ មាសេ ខោ មយា ទេវទត្ត រុក្ខ-
មូលសេនាសនំ អនុញ្ញាតំ តិកោដិបរិសុទ្ធំ មច្ឆមំសំ អ-
ទិដ្ឋំ អសុតំ អបរិសង្កិតន្តិ ។ អថ ខោ ទេវទត្តោ ន ភគវា
ឥមានិ បញ្ចវត្ថូនិ អនុជានាតីតិ ហដ្ឋោ ឧទគ្គោ សបរិសោ
ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា
បក្កាមិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ រឿងទេវទត្តភិក្ខុ ការក្រាបបង្គំទូលសូមវត្ថុ ៥ ប្រការ

បិណ្ឌបាតអស់មួយជីវិត ភិក្ខុណាត្រេកអរដោយការនិមន្ត ភិក្ខុនោះនឹងត្រូវទោស សូមឲ្យភិក្ខុទាំងឡាយទ្រទ្រង់សំពត់បង្សុកូលអស់មួយជីវិត ភិក្ខុណាត្រេកអរចំពោះគហបតីចីវរ ភិក្ខុនោះនឹងត្រូវទោស សូមឲ្យភិក្ខុទាំងឡាយនៅទៀបគល់ឈើជាវត្តអស់មួយជីវិត ភិក្ខុណា ចូលទៅនៅក្នុងទីប្រក់ទីបាំង ភិក្ខុនោះនឹងត្រូវទោស សូមកុំឲ្យភិក្ខុទាំងឡាយឆាន់ត្រីនឹងសាច់អស់មួយជីវិត ភិក្ខុណា ឆាន់ត្រីនឹងសាច់ ភិក្ខុនោះនឹងត្រូវទោស ។ ព្រះអង្គទ្រង់ត្រាស់ថា កុំទេវទត្ត ភិក្ខុណាចង់នៅក្នុងព្រៃ ចូរឲ្យភិក្ខុនោះនៅចុះ ភិក្ខុណាចង់នៅក្នុងស្រុក ចូរឲ្យភិក្ខុនោះនៅចុះ ភិក្ខុណាចង់ប្រព្រឹត្តបិណ្ឌបាតជាវត្ត ចូរឲ្យភិក្ខុនោះប្រព្រឹត្តចុះ ភិក្ខុណាចង់ត្រេកអរដោយការនិមន្ត ចូរឲ្យភិក្ខុនោះត្រេកអរចុះ ភិក្ខុណាចង់ត្រេកអរនឹងគហបតីចីវរ ចូរឲ្យភិក្ខុនោះត្រេកអរចុះ ម្នាលទេវទត្ត ដ្បិតតថាគតអនុញ្ញាតសេនាសនៈទៀបគល់ឈើអស់កាល ៨ ខែហើយ ទាំងបានអនុញ្ញាតត្រីសាច់ ដែលបរិសុទ្ធដោយទីបំផុត ៣ ប្រការ គឺមិនបានឃើញ ១ មិនបានឮ ១ មិនបានរង្កៀស ១ (ឲ្យភិក្ខុទាំងឡាយឆាន់បាន) ។ លំដាប់នោះ ទេវទត្តត្រេកអររីករាយថា ព្រះមានព្រះភាគ មិនព្រមអនុញ្ញាតវត្ថុ ៥ ប្រការនេះទេ បានក្រាបថ្វាយបង្គំលាព្រះមានព្រះភាគ ព្រមទាំងបរិសទ្យ ក្រោកចាកអាសនៈ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៤៩) អថខោ ទេវទត្តោ សបរិសោ រាជគហំ បវិសិត្វា បញ្ចហិ វត្ថូហិ ជនំ សញ្ញាបេសិ មយំ អាវុសោ សមណំ គោតមំ ឧបសង្កមិត្វា បញ្ច វត្ថូនិ យាចិម្ហា ភគវា ភន្តេ អនេកបរិយាយេន អប្បិច្ឆស្ស ។ បេ ។ វីរិយារម្ភស្ស វណ្ណវាទី ឥមានិ ភន្តេ បញ្ច វត្ថូនិ អនេកបរិយាយេន អប្បិច្ឆតាយ ។ បេ ។ វីរិយារម្ភាយ សំវត្តន្តិ សាធុ ភន្តេ ភិក្ខូ យាវជីវំ អារញ្ញកា អស្សុ យោ គាមន្តំ ឱសរេយ្យ វជ្ជំ នំ ផុសេយ្យ ។ បេ ។ យាវជីវំ មច្ឆមំសំ ន ខាទេយ្យុំ យោ មច្ឆមំសំ ខាទេយ្យ វជ្ជំ នំ ផុសេយ្យាតិ ឥមានិ បញ្ច វត្ថូនិ សមណោ គោតមោ នានុជានាតិ តេ ច[១] មយំ ឥមេហិ បញ្ចហិ វត្ថូហិ សមាទាយ វត្តាមាតិ ។

(៥០) តត្ថ យេ តេ មនុស្សា អស្សទ្ធា អប្បសន្នា ទុព្ពុទ្ធិនោ តេ ឯវមាហំសុ ឥមេ ខោ សមណា

---

១ ឱ. ម. ចសទ្ទោ នបញ្ញាយតិ ។

(៨៩) គ្រានោះ ទេវទត្តព្រមទាំងបរិសទ្យចូលទៅកាន់ក្រុងរាជគ្រឹះ ពន្យល់អ្នកផងឲ្យយល់ដោយវត្ថុ ៥ ប្រការ ហើយនិយាយថា ម្នាលអាវុសោទាំងឡាយ ពួកយើងបានចូលទៅគាល់ព្រះសមណគោតម ហើយទូលសុំវត្ថុ ៥ ប្រការថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគតែងសរសើរគុណរបស់បុគ្គលជាអ្នកមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ប្រារព្ធសេចក្ដីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន វត្ថុ ៥ ប្រការទាំងនេះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីប្រាថ្នាតិច ។ បេ ។ ដើម្បីប្រារព្ធសេចក្ដីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់មេត្តាប្រោស សូមឲ្យភិក្ខុទាំងឡាយនៅតែក្នុងព្រៃជាវត្តអស់មួយជីវិត ភិក្ខុណានៅក្នុងស្រុក ភិក្ខុនោះនឹងត្រូវទោស ។ បេ ។ សូមកុំឲ្យភិក្ខុឆាន់ត្រីនឹងសាច់អស់មួយជីវិត ភិក្ខុណាឆាន់ត្រីនឹងសាច់ ភិក្ខុនោះនឹងត្រូវទោស ( ឥឡូវ ) វត្ថុ ៥ ប្រការទាំងនេះ ព្រះសមណគោតមមិនព្រមអនុញ្ញាតឲ្យទេ ពួកយើងទាំងអស់គ្នានោះនឹងសមាទានប្រព្រឹត្តវត្ថុទាំង ៥ ប្រការនេះ ។

(៩០) បណ្ដាមនុស្សទាំងនោះ មនុស្សពួកណាដែលឥតសទ្ធា មិនជ្រះថ្លា ឥតប្រាជ្ញា មនុស្សពួកនោះនិយាយគ្នាយ៉ាងនេះថា ពួកសមណៈ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ ទេវទត្តស្ស សង្ឃភេទចក្កភេទាយ បរក្កមនំ

សក្យបុត្តិយា ធុតា សល្លេខវុត្តិនោ សមណោ បន គោតមោ ពាហុល្លិកោ ពាហុល្លាយ ចេតេតីតិ ។ យេ បន តេ មនុស្សា សទ្ធា បសន្នា បណ្ឌិតា ពុទ្ធិមន្តោ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ទេវទត្តោ សង្ឃភេទាយ បរក្កមិស្សតិ ចក្កភេទាយាតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ទេវទត្តោ សង្ឃភេទាយ បរក្កមិស្សតិ ចក្កភេទាយាតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ត្វំ ទេវទត្ត សង្ឃភេទាយ បរក្កមសិ ចក្កភេទាយាតិ ។ សច្ចំ ភគវាតិ ។ អលំ ទេវទត្ត មា តេ រុច្ចិ សង្ឃភេទោ គរុកោ ខោ ទេវទត្ត សង្ឃភេទោ យោ ខោ ទេវទត្ត សមគ្គំ សង្ឃំ ភិន្ទតិ កប្បដ្ឋិតិកំ កិព្វិសំ បសវតិ កប្បំ និរយម្ហិ បច្ចតិ ។ យោ ច ខោ ទេវទត្ត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





ជាសក្យបុត្តទាំងនេះ ជាអ្នកកំចាត់បង់នូវកិលេស ជាអ្នកប្រព្រឹត្តដុសខាត់ចិត្ត ចំណែកព្រះសមណគោតម ជាអ្នកល្មោភ (ដោយបច្ច័យមានចីវរជាដើម) តែងត្រិះរិះដើម្បីសេចក្តីល្មោភ (ចីវរជាដើម) ។ ចំណែកមនុស្សពួកណាដែលមានសទ្ធាជ្រះថ្លា ជាបណ្ឌិត មានប្រាជ្ញា មនុស្សពួកនោះនាំគ្នាពោលទោស តិះដៀល បន្តុះបង្អាប់ថា ទេវទត្តមិនសមបើនឹងខំប្រឹងទំលាយសង្ឃ នឹងទំលាយចក្រសោះ ។ ភិក្ខុទាំងឡាយបានឮដំណឹងមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុពួកណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុពួកនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើទេវទត្ត ខំប្រឹងទំលាយសង្ឃ នឹងទំលាយចក្រសោះ ។ ទើបភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលទេវទត្ត ឮថាអ្នកខំប្រឹងបំបែកសង្ឃនឹងបំបែកចក្រមែនឬ ។ ទេវទត្តឆ្លើយថា បពិត្រព្រះមានព្រះភាគ ពិតមែន ។ ព្រះអង្គទ្រង់ត្រាស់ថា កុំទេវទត្ត អ្នកកុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ម្នាលទេវទត្ត ដ្បិតការបំបែកសង្ឃមានទោសជាទម្ងន់ណាស់ ម្នាលទេវទត្ត ប្រសិនបើអ្នកណាមួយបំបែកសង្ឃដែលកំពុងព្រមព្រៀងគ្នា (អ្នកនោះ) រមែងទទួលទោសលាមកអាក្រក់តាំងនៅអស់ ១ កប្ប ឆេះនៅក្នុងនរកអស់ ១ កប្ប ម្នាលទេវទត្ត បើអ្នកណាមួយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិន្នំ សង្ឃំ សមគ្គំ ករោតិ ព្រហ្មំ បុញ្ញំ បសវតិ កប្បំ សគ្គម្ហិ មោទតិ អលំ ទេវទត្ត មា តេ រុច្ចិ សង្ឃភេទោ គរុកោ ខោ ទេវទត្ត សង្ឃភេទោតិ ។

[៥១] អថខោ អាយស្មា អានន្ទោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ បាវិសិ ។ អទ្ទសា ខោ ទេវទត្តោ អាយស្មន្តំ អានន្ទំ រាជគហេ បិណ្ឌាយ ចរន្តំ ទិស្វាន យេនាយស្មា អានន្ទោ តេនុប-សង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតទវោច អជ្ជតគ្គេទានាហំ អាវុសោ អានន្ទ អញ្ញត្រេវ ភគវតា អញ្ញត្រេវ ភិក្ខុសង្ឃា ឧបោសថំ ករិស្សាមិ សង្ឃកម្មំ ករិស្សាមីតិ ។ អថខោ អាយស្មា អានន្ទោ រាជគហេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវា-ទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ធ្វើសង្ឃដែលបែកគ្នាហើយឲ្យព្រមព្រៀងគ្នាទៅវិញ (អ្នកនោះ) តែង ទទួលនូវបុណ្យដ៏ប្រសើរ ហើយនឹងរីករាយក្នុងឋានសួគ៌អស់ ១ កប្ប ណ្ហើយទេវទត្ត អ្នកកុំចូលចិត្តនឹងការបំបែកសង្ឃឡើយ ម្នាលទេវទត្ត ដ្បិតការបំបែកសង្ឃ មានទោសធ្ងន់ណាស់ ។

(៩១) គ្រានោះ ព្រះអានន្ទដ៏មានអាយុ ស្លៀកស្បង់ ប្រដាប់ បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះ ។ ទេវទត្តបានឃើញព្រះអានន្ទដ៏មានអាយុ កំពុងត្រាច់ទៅបិណ្ឌបាតក្នុងនគរ រាជគ្រឹះ លុះឃើញហើយ ក៏ចូលទៅជិតព្រះអានន្ទដ៏មានអាយុ លុះចូល ទៅដល់ហើយ បាននិយាយពាក្យនេះនឹងព្រះអានន្ទដ៏មានអាយុថា ម្នាល អានន្ទដ៏មានអាយុ ឥឡូវនេះ ខ្ញុំនឹងធ្វើឧបោសថកម្ម នឹងធ្វើសង្ឃកម្ម បែក ចេញចាកព្រះមានព្រះភាគ បែកចេញចាកភិក្ខុសង្ឃ ចាប់ដើមពីថ្ងៃនេះ រៀងទៅ ។ ព្រះអានន្ទដ៏មានអាយុ ត្រាច់ទៅបិណ្ឌបាតក្នុងនគររាជគ្រឹះ បានត្រឡប់មកពីបិណ្ឌបាត ក្នុងខាងក្រោយភត្តហើយ ក៏ចូលទៅរកព្រះ មានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះមានព្រះ ភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះអង្គុយក្នុងទីដ៏សមគួរហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ បាវិសិ អទ្ទសា ខោ មំ ភន្តេ ទេវទត្តោ រាជគហេ បិណ្ឌាយ ចរន្តំ ទិស្វាន យេនាហំ តេនុ-បសង្កមិ ឧបសង្កមិត្វា មំ ឯតទវោច អជ្ជតគ្គេទានាហំ អាវុសោ អានន្ទ អញ្ញត្រេវ ភគវតា អញ្ញត្រ ភិក្ខុសង្ឃា ឧបោសថំ ករិស្សាមិ សង្ឃកម្មំ ករិស្សាមីតិ អជ្ជ ភន្តេ ទេវទត្តោ សង្ឃំ ភិន្ទិស្សតីតិ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ ។

[៥២] សុករំ សាធុនា សាធុ
សាធុ បាបេន ទុក្ករំ ។
បាបំ បាបេន សុករំ
បាបមរិយេហិ ទុក្ករន្តិ ។

ទុតិយភាណវារំ និដ្ឋិតំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ រឿងទេវទត្តភិក្ខុ និងឧទានគាថា

ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូល ព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងបុព្វណ្ហសម័យថ្ងៃនេះ ខ្ញុំព្រះអង្គស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ទេវទត្តបានឃើញខ្ញុំព្រះអង្គកំពុងត្រាច់បិណ្ឌបាត ក្នុងនគររាជគ្រឹះ លុះឃើញហើយចូលមករកខ្ញុំព្រះអង្គ លុះមកដល់ហើយបាននិយាយពាក្យនេះនឹងខ្ញុំព្រះអង្គថា នែអាវុសោអានន្ទ ឥឡូវនេះ ខ្ញុំនឹងធ្វើឧបោសថកម្ម នឹងធ្វើសង្ឃកម្មបែកចេញចាកព្រះមានព្រះភាគ បែកចេញចាកភិក្ខុសង្ឃ ចាប់ដើមពីថ្ងៃនេះរៀងទៅហើយ បពិត្រព្រះអង្គដ៏ចំរើន ថ្ងៃនេះទេវទត្តបំបែកសង្ឃហើយ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវដំណើរនេះហើយ ទើបទ្រង់បន្លឺនូវឧទានគាថានេះ ក្នុងវេលានោះថា

(៥២) អំពើល្អ មនុស្សសប្បុរសធ្វើបានដោយងាយ អំពើល្អ មនុស្សបាប ធ្វើបានដោយក្រ ។ អំពើបាប មនុស្សបាប ធ្វើបានដោយងាយ អំពើបាប ព្រះអរិយៈទាំងឡាយ ធ្វើបានដោយក្រ ។

ចប់ ភាណវារៈ ទី ២ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



(៤៣) អថខោ ទេវទត្តោ តទហុបោសថេ ឧដ្ឋាយាសនា សលាកំ គាហេសិ មយំ អាវុសោ សមណំ គោតមំ ឧបសង្កមិត្វា បញ្ច វត្ថូនិ យាចិម្ហា ភគវា ភន្តេ អនេកបរិយាយេន អប្បិច្ឆស្ស ។ បេ ។ វីរិយារម្ភស្ស វណ្ណវាទី ឥមានិ ភន្តេ បញ្ច វត្ថូនិ អនេកបរិយាយេន អប្បិច្ឆតាយ ។ បេ ។ វីរិយារម្ភាយ សំវត្តន្តិ សាធុ ភន្តេ ភិក្ខូ យាវជីវំ អារញ្ញកា អស្សុ យោ គាមន្តំ ឱសរេយ្យ វជ្ជំ នំ ផុសេយ្យ ។ បេ ។ យាវជីវំ មច្ឆមំសំ ន ខាទេយ្យុំ យោ មច្ឆមំសំ ខាទេយ្យ វជ្ជំ នំ ផុសេយ្យាតិ ឥមានិ បញ្ច វត្ថូនិ សមណោ គោតមោ នានុជានាតិ តេ ច[១] មយំ ឥមេហិ បញ្ចហិ វត្ថូហិ សមាទាយ វត្តាម យស្សាយស្មតោ ឥមានិ បញ្ច វត្ថូនិ ខមន្តិ សោ សលាកំ គណ្ហាតូតិ ។

(៤៤) តេន ខោ បន សមយេន វេសាលិកា វជ្ជីបុត្តកា បញ្ចមត្តានិ ភិក្ខុសតានិ នវកា ចេវ ហោន្តិ អប្បកតញ្ញុនោ ច ។ តេ ច[២] អយំ ធម្មោ អយំ វិនយោ

---

១–២ ឱ. ម. ពោត្ថកេសុ ចសទ្ទោ ន ទិស្សតិ ។

[៩៣] គ្រានោះ ទេវទត្តក្រោកចាកអាសនៈ ក្នុងថ្ងៃឧបោសថនោះ ហើយបង្គាប់ភិក្ខុឲ្យចាប់ស្លាកដោយពាក្យថា ម្នាលអាវុសោ ពួកយើងបាននាំគ្នាចូលទៅគាល់ព្រះសមណគោតម ទូលសុំវត្ថុ ៥ ប្រការថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគទ្រង់សរសើរគុណ របស់បុគ្គលអ្នកប្រាថ្នាតិច ។បេ។ ប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយដ៏ច្រើន បពិត្រព្រះអង្គដ៏ចំរើន វត្ថុ ៥ ប្រការទាំងនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នាតិច ។បេ។ ដើម្បីប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយដ៏ច្រើន បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់មេត្តាប្រោស សូមឲ្យភិក្ខុទាំងឡាយនៅតែក្នុងព្រៃជាវត្តអស់ ១ ជីវិត ភិក្ខុណាទៅក្នុងស្រុក ភិក្ខុនោះនឹងត្រូវទោស ។បេ។ សូមកុំឲ្យភិក្ខុទាំងឡាយឆាន់ត្រីនិងសាច់អស់ ១ ជីវិត ភិក្ខុណាឆាន់ត្រីនិងសាច់ ភិក្ខុនោះនឹងត្រូវទោស ព្រះសមណគោតម មិនទ្រង់អនុញ្ញាតវត្ថុ ៥ ប្រការនេះទេ តែពួកយើងទាំងនោះ នឹងនាំគ្នាសមាទានប្រព្រឹត្តវត្ថុ ៥ ប្រការនេះវិញ វត្ថុ ៥ ប្រការនេះគួរដល់លោកដ៏មានអាយុអង្គណា សូមលោកដ៏មានអាយុអង្គនោះចាប់ស្លាកចុះ ។

[៩៤] សម័យនោះឯង វជ្ជីបុត្តកភិក្ខុនៅក្នុងនគរវេសាលី ប្រមាណ ៥០០ រូប ជាអ្នកទើបនឹងបួសថ្មីផង ជាអ្នកមិនដឹងប្រក្រតី ( មិនចេះវិន័យ ) ផង ។ ភិក្ខុទាំងនោះគិតគ្នាថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឥទំ សត្ថុសាសនន្តិ សលាកំ គណ្ហាតុ ។ អថខោ ទេវទត្តោ សង្ឃំ ភិន្ទិត្វា បញ្ចមត្តានិ ភិក្ខុសតានិ អា-ទាយ យេន គយាសីសំ តេន បក្កាមិ ។

(៥៥) អថខោ សារីបុត្តមោគ្គល្លានា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯ-កមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច ទេវទត្តោ ភន្តេ សង្ឃំ ភិន្ទិត្វា បញ្ចមត្តានិ ភិក្ខុសតានិ អាទាយ យេន គ-យាសីសំ តេន បក្កន្តោតិ ។ ននុ ហិ(១) នាម តុម្ហាកំ សារីបុត្តា តេសុ នវកេសុ ភិក្ខូសុ ការុញ្ញម្បិ ភវិស្សតិ គច្ឆថ តុម្ហេ សារីបុត្តា បុរា តេ ភិក្ខូ អនយព្យសនំ អាបជ្ជន្តីតិ ។ ឯវំ ភន្តេតិ ខោ សារីបុត្តមោគ្គល្លានា ភគវតោ បដិស្សុត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន គយាសីសំ តេនុបសង្កមឹសុ ។

---

១ ឱ. ម. ន ហិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ប្រដៅរបស់ព្រះសាស្តា ហើយក៏នាំគ្នាចាប់ស្លាក ។ លំដាប់នោះ ទេវទត្តបំបែកសង្ឃ ហើយនាំភិក្ខុទាំង ៥០០ រូប (នោះ) ឆ្ពោះទៅកាន់គយាសីសប្រទេស ។

(៥៥) គ្រានោះ ព្រះសារីបុត្តនឹងព្រះមោគ្គល្លាន ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបអភិវាទ ចំពោះព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ទេវទត្តបំបែកសង្ឃ ហើយនាំភិក្ខុប្រមាណ ៥០០ រូបឆ្ពោះទៅកាន់គយាសីសប្រទេសទៅហើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសារីបុត្តនិងមោគ្គល្លាន អ្នកទាំងឡាយមិនជាមានសេចក្តីអាណិតភិក្ខុដែលទើបនឹងបួសថ្មីទាំងនោះទេដឹង ម្នាលសារីបុត្តនិងមោគ្គល្លាន ចូរអ្នកទាំងឡាយនាំគ្នាទៅចុះ ភិក្ខុទាំងនោះនឹងដល់នូវសេចក្តីវិនាសក្នុងកាលជាអនាគត ។ ព្រះសារីបុត្តនិងព្រះមោគ្គល្លាន ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ករុណា ព្រះអង្គ ហើយក្រោកចាកអាសនៈ ក្រាបបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយដើរសំដៅទៅគយា-សីសប្រទេស ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៥៦) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ភគវតោ អវិទូរេ ឋិតោ រោទិតោ ហោតិ (១) ។ អថ ខោ ភគវា តំ ភិក្ខុំ ឯតទវោច កិស្ស ត្វំ ភិក្ខុ រោទសីតិ ។ យេបិ តេ ភន្តេ ភគវតោ អគ្គសាវកា សារីបុត្តមោគ្គ-ល្លានា តេបិ ទេវទត្តស្ស សន្តិកេ គច្ឆន្តិ ទេវទត្តស្ស ធម្មំ រោចេន្តាតិ ។ អដ្ឋានមេតំ ភិក្ខុ អនវកាសោ យំ សារីបុត្តមោគ្គល្លានា ទេវទត្តស្ស ធម្មំ រោចេយ្យុំ អបិច តេ គតា ភិក្ខុសញ្ញត្តិយាតិ ។

(៥៧) តេន ខោ បន សមយេន ទេវទត្តោ មហតិយា បរិសាយ បរិវុតោ ធម្មំ ទេសេន្តោ និសិន្នោ ហោតិ ។ អទ្ទសា ខោ ទេវទត្តោ សារីបុត្តមោគ្គល្លានេ ទូរតោវ អាគច្ឆន្តេ ទិស្វាន ភិក្ខូ អាមន្តេសិ បស្សថ ភិក្ខវេ យាវ ស្វាក្ខាតោ មយ្ហំ ធម្មោ យេបិ តេ សមណស្ស គោតមស្ស អគ្គសាវកា សារីបុត្តមោគ្គល្លានា តេបិ មម សន្តិកេ អាគច្ឆន្តិ មម ធម្មំ រោចេន្តាតិ ។ ឯវំ វុត្តេ កោកាលិកោ

១ ឱ· ម· ពោត្ថកេសុ ភគវតោ អវិទូរេ រោទមានោ ឋិតោ ហោតីតិ ឯវំ អាគតោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[៩៦] សម័យនោះ មានភិក្ខុមួយរូបឈរយំ នៅជិតព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះមានព្រះភាគបានត្រាស់ប្រាប់នឹងភិក្ខុនោះថា ម្នាលភិក្ខុ ហេតុអ្វី ក៏អ្នកយំ ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន អគ្គសាវ័ករបស់ព្រះមានព្រះភាគ គឺ ព្រះសារីបុត្តនឹងព្រះមោគ្គល្លានទាំងនោះ ពេញចិត្តនឹងធម៌ទេវទត្តហើយ បានជាទៅកាន់ សំណាក់ទេវទត្ត ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ សារីបុត្តនឹងមោគ្គល្លាន ពេញចិត្តនឹងធម៌ទេវទត្តដោយឧបាយណា ឧបាយនោះ មិនមែនជាហេតុ មិនមែនជាឱកាសឡើយ ឯសារីបុត្តនឹងមោគ្គល្លានទៅនោះ ដើម្បីពន្យល់ភិក្ខុផងគ្នាទេតើ ។

[៩៧] ចួនសម័យនោះឯង ទេវទត្តមានបរិស័ទច្រើនចោមរោមគ្រៀបគ្រា កំពុងអង្គុយសំដែងធម៌ ។ ទេវទត្តបានឃើញព្រះសារីបុត្តនឹងព្រះមោគ្គល្លានដើរមកអំពីចម្ងាយលើម ។ លុះឃើញហើយក៏ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកមើលចុះ ធម៌យើងសំដែងហើយដោយល្អ ទាល់តែអគ្គសាវ័ករបស់ព្រះសមណគោតមគឺសារីបុត្តនឹងមោគ្គល្លាន(ពេញចិត្តនឹងធម៌យើងហើយបានជា)មកកាន់សំណាក់យើង ។ កាលបើទេវទត្តនិយាយយ៉ាងនេះហើយ កោកាលិកភិក្ខុក៏បាននិយាយពាក្យនេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## សង្ឃភេទក្ខន្ធកេ ទេវទត្តវត្ថុ តស្ស ធម្មទេសនា

ទេវទត្តំ ឯតទវោច អាវុសោ ទេវទត្ត សារិបុត្តមោគ្គ-ល្លានេហិ[១] វិស្សាសិ បាបិច្ឆា សារិបុត្តមោគ្គល្លានា បាបិកានំ ឥច្ឆានំ វសំ គតាតិ ។ អលំ អាវុសោ ស្វាគតំ តេសំ យតោ មេ ធម្មំ រោចេន្តីតិ ។ អថខោ ទេវទត្តោ អាយស្មន្តំ សារិបុត្តំ ឧបឌ្ឍាសនេន និមន្តេសិ ឯហាវុសោ សារិបុត្ត ឥធ និសីទាហីតិ ។ អលំ អាវុសោតិ ខោ អាយស្មា សារិបុត្តោ អញ្ញតរំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។ អាយស្មាបិ ខោ មហាមោគ្គល្លានោ អញ្ញតរំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។ អថខោ ទេវទត្តោ ពហុទេវ រត្តឹ ភិក្ខូ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា អាយស្មន្តំ សារិបុត្តំ អជ្ឈេសិ វិគតថីនមិទ្ធោ ខោ អាវុសោ សារិបុត្ត ភិក្ខុសង្ឃោ បដិភាតុ តំ អាវុសោ សារិបុត្ត ភិក្ខូនំ ធម្មីកថា បិដ្ឋិ មេ អាគិលាយតិ តមហំ អាយមិស្សាមីតិ ។ ឯវមាវុសោតិ ខោ អាយស្មា សារិបុត្តោ ទេវទត្តស្ស បច្ចស្សោសិ ។ អថខោ ទេវទត្តោ ចតុគ្គុណំ សង្ឃាដឹ បញ្ញាបេត្វា ទក្ខិណេន បស្សេន សេយ្យំ កប្បេសិ ។

---

១ ឱ. ម. សារីបុត្តមោគ្គល្លានេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ រឿងទេវទត្តភិក្ខុ នឹងការសំដែងធម៌របស់លោក

នឹងទេវទត្តថា នែអាវុសោទេវទត្ត អ្នកកុំទុកចិត្តសារីបុត្តនឹងមោគ្គល្លានឡើយ (ដ្បិត) សារីបុត្តនឹងមោគ្គល្លាន (នេះ) ជាអ្នកប្រាថ្នាលាមក លុះតែអំណាចសេចក្ដីប្រាថ្នាអាក្រក់ ។ ទេវទត្តឆ្លើយថា មិនអីទេ អាវុសោ សារីបុត្តនឹងមោគ្គល្លាននោះមកដោយស្រួលទេ ព្រោះហេតុតែពេញចិត្តនឹងធម៌របស់យើងហើយ ។ ទេវទត្តនិមន្តព្រះសារីបុត្តដ៏មានអាយុ ដោយអាសនៈពាក់កណ្ដាលថា នែអាវុសោ សារីបុត្ត សូមលោកនិមន្តមកគង់លើអាសនៈនេះចុះ ។ ព្រះសារីបុត្តដ៏មានអាយុនិយាយថា ណើយអាវុសោ ដូច្នេះ រួចកាន់យកអាសនៈមួយ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ឯព្រះមហាមោគ្គល្លានដ៏មានអាយុក៏កាន់យកអាសនៈមួយហើយអង្គុយក្នុងទីសមគួរ ។ គ្រានោះទេវទត្តបានពន្យល់ភិក្ខុទាំងឡាយច្រើនឱ្យយល់ព្រម ឱ្យកាន់យកព្រម ឱ្យអាចហាន ឱ្យត្រេកអរីករាយដោយធម្មកថា ពាល់តែយប់ជ្រៅទើបនិមន្តព្រះសារីបុត្តដ៏មានអាយុថា នែអាវុសោសារីបុត្ត ភិក្ខុសង្ឃប្រាសចាកថីន-មិទ្ធហើយ ម្នាលអាវុសោ សារីបុត្ត បាអ្នកជួយបង្កុលធម្មកថាដល់ភិក្ខុទាំងឡាយផងចុះ ដ្បិតខ្ញុំឈឺខ្នងណាស់ ខ្ញុំនឹងសម្រាកបន្តិច ។ ព្រះសារីបុត្តដ៏មានអាយុ ទទួលពាក្យទេវទត្តថា អើអាវុសោ ។ ទេវទត្តក៏ក្រាលសង្ឃាដី ៤ ជាន់សម្រេចនូវសេយ្យា (សីហ៍) ផ្អៀងទៅខាងស្ដាំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តស្ស កិលន្តស្ស មុដ្ឋស្សតិស្ស អសម្បជានស្ស មុហុត្ត-កេនេវ និទ្ទា ឱក្កមិ ។

(៥៨) អថខោ អាយស្មា សារីបុត្តោ អាទេសនា-បាដិហារិយានុសាសនិយា ភិក្ខូ ធម្មិយា កថាយ ឱវទិ អនុសាសិ ។ អាយស្មា មហាមោគ្គល្លានោ ឥទ្ធិបាដិ-ហារិយានុសាសនិយា ភិក្ខូ ធម្មិយា កថាយ ឱវទិ អនុសាសិ ។ អថខោ តេសំ ភិក្ខូនំ អាយស្មតា សារីបុត្តេន អាទេសនាបាដិហារិយានុសាសនិយា អា-យស្មតា ច[១] មហាមោគ្គល្លានេន ឥទ្ធិបាដិហារិយានុ-សាសនិយា ឱវទិយមានានំ អនុសាសិយមានានំ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំកិញ្ចិ សមុទយធម្មំ សព្ពន្តំ និរោធធម្មន្តិ ។ អថខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ គច្ឆាម មយំ អាវុសោ ភគវតោ សន្តិកេ

---

១ ឱ. ម. ចសទ្ទោ ន បញ្ញាយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទេវទត្តនោះ ក៏ចួនជាអស់កំឡាំង ក្រេបក្រាំងស្មារតី មិនដឹងខ្លួនប្រាណ ក៏ដេកលក់មួយរំពេចទៅ ។

(៩៨) គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ បានទូន្មានប្រៀនប្រដៅភិក្ខុទាំងឡាយដោយធម្មីកថា ជាអាទេសនាបាដិហារ្យ[១] នឹងអនុសាសនីបាដិហារ្យ[២] ចំណែកខាងព្រះមោគ្គល្លានដ៏មានអាយុក៏ទូន្មានប្រៀនប្រដៅភិក្ខុទាំងឡាយ ដោយធម្មីកថាជាឥទ្ធិបាដិហារ្យ[៣] នឹងអនុសាសនីបាដិហារ្យ ។ លំដាប់នោះ ពួកភិក្ខុទាំងនោះដែលព្រះសារីបុត្តដ៏មានអាយុទូន្មានប្រៀនប្រដៅ (ដោយធម្មីកថា) ជាអាទេសនាបាដិហារ្យនឹងអនុសាសនីបាដិហារ្យ ដែលព្រះមោគ្គល្លានដ៏មានអាយុទូន្មានប្រៀនប្រដៅ (ដោយធម្មីកថា) ជាឥទ្ធិបាដិហារ្យនឹងអនុសាសនីបាដិហារ្យ ក៏កើតធម្មចក្ខុគឺសោតាបត្តិមគ្គប្រាសចាកធូលី ប្រាសចាកមន្ទិល (ដោយបញ្ញាថា) ធម្មជាតណាមួយមានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ រមែងរលត់ទៅវិញជាធម្មតា ។ ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោ ពួកយើងនាំគ្នាទៅកាន់សំណាក់ព្រះមានព្រះភាគ

---

១ សំដែងដឹងចិត្តរបស់បុគ្គលដទៃ ហៅថា អាទេសនាបាដិហារ្យ ។ ២ ធម្មទេសនាទាំងអស់ហៅថា អនុសាសនីបាដិហារ្យ ។ ៣ ប្រៀនប្រដៅដោយរិទ្ធិជាអស្ចារ្យហៅថា ឥទ្ធិបាដិហារ្យ (ដីកា) ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យោ តស្ស ភគវតោ ធម្មំ រោចេតិ សោ អាគច្ឆតូតិ ។ អថខោ សារីបុត្តមោគ្គល្លានា តានិ បញ្ច ភិក្ខុសតានិ អាទាយ យេន វេឡុវនំ តេនុបសង្កមឹសុ ។ អថខោ កោកាលិកោ ទេវទត្តំ ឧដ្ឋាបេសិ ឧដ្ឋេហិ អាវុសោ ទេវទត្ត នីតា តេ ភិក្ខូ សារីបុត្តមោគ្គល្លានេហិ ននុ ត្វំ អាវុសោ ទេវទត្ត មយា វុត្តោ មា អាវុសោ ទេវទត្ត សារីបុត្តមោគ្គល្លានេ វិស្សាសិ បាបិច្ឆា សារីបុត្ត-មោគ្គល្លានា បាបិកានំ ឥច្ឆានំ វសំ គតាតិ ។ អថខោ ទេវទត្តស្ស តត្ថេវ ឧណ្ហំ លោហិតំ មុខតោ ឧគ្គញ្ឆិ ។

(៤៩) អថខោ សារីបុត្តមោគ្គល្លានា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច សាធុ ភន្តេ ភេទកានុវត្តកា ភិក្ខូ បុន ឧបសម្បជ្ជេយ្យុន្តិ ។ អលំ សារីបុត្ត មា តេ រុច្ចិ ភេទកានុវត្តកានំ ភិក្ខូនំ បុន ឧបសម្បទា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



លោកអង្គណា ចូលចិត្តនឹងធម៌របស់ព្រះមានព្រះភាគនោះ ចូរលោកអង្គនោះនិមន្តមក ។ ទើបព្រះសារីបុត្តនិងព្រះមោគ្គល្លាននាំភិក្ខុទាំង ៥០០រូបនោះចូលសំដៅទៅវត្តវេឡុវ័ន ។ លំដាប់នោះ កោកាលិកភិក្ខុដាស់ទេវទត្តឲ្យក្រោកឡើងថា នែអាវុសោ ទេវទត្ត ចូរអ្នកក្រោកឡើង ដ្បិតសា-រីបុត្តនិងមោគ្គល្លាននាំភិក្ខុទាំងនោះទៅហើយ ម្នាលអាវុសោ ទេវទត្ត យើងបាននិយាយប្រាប់អ្នកថា នែទេវទត្តដ៏មានអាយុ អ្នកកុំទុកចិត្តសារីបុត្តនិងមោគ្គល្លានឡើយ ដ្បិតសារីបុត្តនិងមោគ្គល្លាន (នោះ) ជាមនុស្សប្រាថ្នាលាមក លុះក្នុងអំណាចសេចក្តីប្រាថ្នាអាក្រក់ ឥឡូវឃើញទេហ៎ ។ លំដាប់នោះ ទេវទត្តក៏ស្រាប់តែក្អួតឈាមក្តៅចេញមកពីមាត់ក្នុងទីនោះ ។

(៤៩) គ្រានោះ ព្រះសារីបុត្តនិងមោគ្គល្លាន ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះអង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះសារីបុត្តដ៏មានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស សូមឲ្យភិក្ខុទាំងឡាយដែលជាអ្នកប្រព្រឹត្តតាមភិក្ខុ ដែលបំបែកសង្ឃ ឧបសម្បទាជាថ្មីទៀត ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសារីបុត្ត អ្នកកុំចូលចិត្តនឹងការឲ្យពួកភិក្ខុជាអ្នកប្រព្រឹត្តតាមភិក្ខុ ដែលបំបែកសង្ឃ ទទួលឧបសម្បទាជាថ្មីទៀតឡើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តេនហិ ត្វំ សារីបុត្ត ភេទកានុវត្តកេ ភិក្ខូ ថុល្លច្ចយំ ទេសាបេហិ ។ កថំ បន តេ សារីបុត្ត ទេវទត្តោ បដិបជ្ជីតិ ។ យថេវ ភន្តេ ភគវា ពហុទេវ រត្តឹ ភិក្ខូ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា មំ អជ្ឈេសិ វិគតថីនមិទ្ធោ ខោ សារីបុត្ត ភិក្ខុសង្ឃោ បដិភាតុ តំ សារីបុត្ត ភិក្ខូនំ ធម្មីកថា បិដ្ឋិ មេ អាគិលាយតិ តមហំ អាយមិស្សាមីតិ ឯវមេវ ខោ ភន្តេ ទេវទត្តោ បដិបជ្ជីតិ ។

[៦០] អថខោ ភគវា ភិក្ខូ អាមន្តេសិ ភូតបុព្វំ ភិក្ខវេ អរញ្ញាយតនេ មហាសរសី តំ នាគា ឧបនិស្សាយ វិហរន្តិ ។ តេ ច[១] តំ សរសឹ ឱគាហេត្វា សោណ្ឌាយ ភិសមុឡាលំ អព្វុហិត្វា[២] សុវិក្ខាលិតំ វិក្ខាលេត្វា អកទ្ទមំ សង្ខាទិត្វា អជ្ឈោហរន្តិ ។ តេសំ តំ វណ្ណាយ ចេវ ហោតិ ពលាយ ច ។ ន ច តតោនិទានំ មរណំ វា និគច្ឆន្តិ

១ ឱ. ម. បោត្ថកេសុ ចសទ្ទោ នទិស្សតិ ។ ២ ឱ. អព្វាហិត្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



ម្នាលសារីបុត្ត បើដូច្នោះ ចូរអ្នកឲ្យភិក្ខុដែលប្រព្រឹត្តតាមភិក្ខុ ដែលបំបែកសង្ឃ (នោះ) សម្តែងអាបត្តិថុល្លច្ច័យចេញចុះ ម្នាលសារីបុត្ត ចុះទេវទត្តប្រតិបត្តិចំពោះអ្នកដូចម្តេច ។ ព្រះសារីបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគបានពន្យល់ភិក្ខុទាំងឡាយឲ្យយល់ប្រយោជន៍ ឲ្យកាន់យកព្រម ឲ្យអាចហាន ឲ្យត្រេកអរ ឲ្យរីករាយដោយធម្មីកថា ទាល់តែយប់ជ្រៅ ទើបបានភាពឆនាឲ្យព្រះអង្គថា ម្នាលសារីបុត្ត ភិក្ខុសង្ឃប្រាសចាកសេចក្តីងោយងោករបស់ហើយ ម្នាលសារីបុត្ត ចូរអ្នកបំភ្លឺធម្មីកថាចំពោះភិក្ខុទាំងឡាយនោះផងចុះ ដ្បិតតថាគតឈឺខ្នង តថាគតនឹងឈប់សម្រាកបន្តិច រឿងនេះយ៉ាងណា បពិត្រព្រះអង្គដ៏ចំរើន ទេវទត្តក៏ប្រតិបត្តិយ៉ាងនោះដែរ ។

[៦០] លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយ មានដំរីច្រើននៅអាស្រ័យនឹងស្រះធំ ១ ជិតព្រៃលោង ។ ដំរីទាំងនោះចុះកាន់ស្រះនោះ ដកយកក្រអៅឈូកដោយប្រមោយ លាងសំអាត ហើយទំពាលេបរបស់ដែលគ្មានភក់នោះទៅ ។ ក្រអៅឈូកនោះក៏នាំឲ្យមានពណ៌សម្បុរនឹងកំឡាំងដល់ដំរីទាំងនោះ ។ ដំរីទាំងនោះក៏មិនបានដល់នូវសេចក្តីស្លាប់ផង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



មរណមត្តំ វា ទុក្ខំ ។ តេសំយេវ ខោ បន ភិក្ខវេ មហានាគានំ អនុសិក្ខមានា តរុណា នាគា[១] ភិង្កច្ឆាបា តេ តំ សរសឹ ឱគ្គាហេត្វា សោណ្ឌាយ ភិសមុឡាលំ អព្ពុហិត្វា ន សុវិក្ខាលិតំ វិក្ខាលេត្វា សកទ្ទមំ សង្ខាទិត្វា អជ្ឈោហរន្តិ ។ តេសំ តំ នេវ វណ្ណាយ ហោតិ ន ពលាយ ។ តតោនិទានំ ច មរណំ វា និគច្ឆន្តិ មរណមត្តំ វា ទុក្ខំ ។ ឯវមេវ ខោ ភិក្ខវេ ទេវទត្តោ មមានុកុព្វំ កបណោ មរិស្សតីតិ ។

(៦១) មហាវរាហស្ស មហឹ វិកុព្វតោ
ភិសំ ឃសានស្ស[២] នទីសុ ជគ្គតោ
ភិង្កោវ បង្កំ អភិភក្ខយិត្វា
មមានុកុព្វំ កបណោ មរិស្សតីតិ ។

(៦២) អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតោ ភិក្ខុ ទូតេយ្យំ គន្តុមរហតិ ។ កតមេហិ អដ្ឋហិ ។ ឥធ ភិក្ខវេ

---

១ ឱ. ម. ពោត្ថកេសុ នាគាតិវចនំ ន ទិស្សតិ ។ ២ ឱ. ឃសមានស្ស ។ ម. ឃាសមានស្ស ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ខេបអដ្ឋកថា រឿងទេវទត្តភិក្ខុ និងនិគមគាថា

នូវសេចក្តីទុក្ខជិតនឹងស្លាប់ផង ព្រោះការទំពាស៊ីក្រអៅឈូកនោះទេ ។ ម្នាលភិក្ខុទាំងឡាយ បរិណកខាងពួកដំរីក្មេង គឺដំរីស្ទាវនឹងកូនដំរីតែងយកតម្រាប់ដំរីធំទាំងនោះ ក៏នាំគ្នាចុះកាន់ស្រះនោះហើយដកក្រអៅឈូកដោយប្រមាទ តែមិនបានលាងទឹកឲ្យស្អាតហើយក៏ទំពាលេបទាំងភក់ទៅ ។ ក្រអៅឈូកនោះក៏មិននាំឲ្យកើតសម្បុរនឹងកំឡាំងដល់ដំរីទាំងនោះឡើយ ។ (ដំរីស្ទាវនឹងកូនដំរីទាំងឡាយ) តែងដល់នូវសេចក្តីស្លាប់ ឬសេចក្តីទុក្ខជិតនឹងស្លាប់ ព្រោះការទំពាស៊ីរបស់មិនស្អាតនោះ ជាហេតុ (យ៉ាងណាមិញ) ម្នាលភិក្ខុទាំងឡាយ ទេវទត្តដែលធ្វើតាមតថាគត នឹងដល់សេចក្តីលំបាក ស្លាប់អសារឥតការ យ៉ាងនោះដែរ ។

(៦១) កាលដំរីធំគ្រហឹម គាស់រំលើងផែនដីទំពាស៊ីក្រអៅឈូកក្នុងស្រះ កូនដំរីធ្វើតាមដំរីធំនោះ ក៏ទំពាស៊ីក្រអៅឈូកទាំងភក់ ដល់នូវសេចក្តីស្លាប់ យ៉ាងណាមិញ ទេវទត្តដែលធ្វើតាមតថាគត ក៏ដល់សេចក្តីលំបាកហើយនឹងស្លាប់ យ៉ាងនោះដែរ ។

(៦២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយអង្គ ៨ ប្រការ ទើបគួរដល់នូវទូតកម្មបាន ។ អង្គ ៨ ប្រការនោះគឺអ្វីខ្លះ ។ ម្នាលភិក្ខុ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុ សោតា ច ហោតិ សាវេតា ច ឧគ្គហេតា ច ធា-
រេតា ច វិញ្ញាតា ច វិញ្ញាបេតា ច កុសលោ ច ស-
ហិតាសហិតស្ស នោ ច កលហការកោ ឥមេហិ
ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតោ ភិក្ខុ ទូតេយ្យំ
គន្តុមរហតិ ។

[៦៣] អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតោ សា-
រីបុត្តោ ទូតេយ្យំ គន្តុមរហតិ ។ កតមេហិ អដ្ឋហិ ។
ឥធ ភិក្ខវេ សារីបុត្តោ សោតា ច ហោតិ សាវេតា
ច ឧគ្គហេតា ច ធារេតា ច វិញ្ញាតា ច វិញ្ញាបេតា
ច កុសលោ ច សហិតាសហិតស្ស នោ ច កលហ
ការកោ ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នា
គតោ សារីបុត្តោ ទូតេយ្យំ គន្តុមរហតីតិ ។

[៦៤] យោ វេ ន ព្យថតិ បត្វា បរិសំ ឧគ្គវាទិនឹ[១]
ន ច ហាបេតិ វចនំ ន ច ឆាទេតិ សាសនំ
អសន្ទិទ្ធោ ច អក្ខាតិ បុច្ឆិតោ ន ច កុប្បតិ[២]
ស វេ តាទិសកោ ភិក្ខុ ទូតេយ្យំ គន្តុមរហតីតិ ។

---

១ ម. ឧគ្គវាទិនឹ ។ ២ ឱ. ម. បុដ្ឋោ ច ន កុប្បតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ដាប់បានដោយខ្លួនឯង ១ ញុំាងបុគ្គលដទៃឲ្យស្ដាប់បាន ១ បានរៀនយក ១ ចេះចាំទុកស្ទាត់ ១ ដឹងសេចក្ដីដោយខ្លួនឯង ១ ញុំាងបុគ្គលដទៃឲ្យដឹងសេចក្ដីនោះ ១ ឈ្លាសវៃក្នុងហេតុដែលគួរនិងមិនគួរ ១ ជាអ្នកមិនធ្វើនូវជំលោះ ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយអង្គ ៨ ប្រការនេះឯង ទើបគួរដល់នូវទូតកម្មបាន ។

(៦៣) ម្នាលភិក្ខុទាំងឡាយ សារីបុត្តប្រកបដោយអង្គ ៨ ប្រការ ទើបគួរដល់នូវទូតកម្មបាន ។ អង្គ ៨ ប្រការនោះតើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ សារីបុត្តជាអ្នកស្ដាប់បានដោយខ្លួនឯង ១ ញុំាងបុគ្គលដទៃឲ្យស្ដាប់បាន ១ បានរៀនយក ១ ចេះចាំទុកស្ទាត់ ១ ដឹងសេចក្ដីដោយខ្លួនឯង១ ញុំាងបុគ្គលដទៃឲ្យដឹងសេចក្ដី ១ ឈ្លាសវៃក្នុងហេតុដែលគួរនិងមិនគួរ១ ជាអ្នកមិនធ្វើនូវជំលោះ ១ ម្នាលភិក្ខុទាំងឡាយ សារីបុត្តប្រកបដោយអង្គ ៨ ប្រការនេះឯង ទើបគួរដល់នូវទូតកម្មបាន ។

(៦៤) ភិក្ខុណា ទៅដល់បរិសទ្យដែលពោលពាក្យបង្ក្រើប
ហើយមិនញាប់ញ័រ ១ មិនបំភ្លេចពាក្យ ១ មិនលាក់ពាក្យ
បណ្ដាំគេ ១ ប្រាប់មិនឲ្យប្រទាំពាក្យ ១ គេសួរមកហើយមិន
ខឹង ១ ភិក្ខុប្រាកដដូច្នោះនោះឯង ទើបគួរដល់ទូតកម្មបាន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ ទេវទត្តវត្ថុ អដ្ឋ អសទ្ធម្មា

[៦៨] អដ្ឋហិ ភិក្ខវេ អសទ្ធម្មេហិ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ កតមេហិ អដ្ឋហិ ។ លាភេន ភិក្ខវេ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ អលាភេន ភិក្ខវេ ។ បេ ។ យសេន ភិក្ខវេ ។ បេ ។ អយសេន ភិក្ខវេ ។ បេ ។ សក្ការេន ភិក្ខវេ ។ បេ ។ អសក្ការេន ភិក្ខវេ ។ បេ ។ បាបិច្ឆតាយ ភិក្ខវេ ។ បេ ។ បាបមិត្តតាយ ភិក្ខវេ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ អសទ្ធម្មេហិ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ សាធុ ភិក្ខវេ ភិក្ខុ ឧប្បន្នំ លាភំ អភិភុយ្យ អភិភុយ្យ វិហរេយ្យ ឧប្បន្នំ អលាភំ ។ បេ ។ ឧប្បន្នំ យសំ ឧប្បន្នំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## សង្ឃភេទក្ខន្ធកៈ រឿងទេវទត្ត និងអសទ្ធម្ម ៨ ប្រការ

[៦៥] ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវអសទ្ធម្ម (លោកធម៌) ទាំង៨ ប្រការ គ្របសង្កត់ មានចិត្តប្រែប្រួល ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ អសទ្ធម្ម ៨ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវលាភគ្របសង្កត់ មានចិត្តប្រែប្រួល ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ម្នាលភិក្ខុទាំងឡាយ ព្រោះមិនមានលាភ ។បេ។ ម្នាលភិក្ខុទាំងឡាយ ព្រោះយស ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះមិនមានយស ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះសក្ការៈ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះមិនមានសក្ការៈ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះខ្លួនមានសេចក្តីប្រាថ្នាអាក្រក់ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវភាវៈជាបាបមិត្តគ្របសង្កត់ មានចិត្តប្រែប្រួល ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវអសទ្ធម្មទាំង ៨ ប្រការនេះគ្របសង្កត់ មានចិត្តប្រែប្រួល ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់មួយកប្ប កែខ្លួនលែងបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសង្កត់សង្កិន ញាំញី នូវលាភដែលកើតឡើងហើយ នូវអលាភដែលកើតឡើងហើយ ។ បេ ។ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អយសំ ឧប្បន្នំ សក្ការំ ឧប្បន្នំ អសក្ការំ ឧប្បន្នំ បា-
បិច្ឆតំ ។ បេ ។ ឧប្បន្នំ បាបមិត្តតំ អភិភុយ្យ អភិភុយ្យ
វិហរេយ្យ កញ្ច[1] ភិក្ខវេ ភិក្ខុ អត្ថវសំ បដិច្ច ឧប្បន្នំ លា-
ភំ អភិភុយ្យ អភិភុយ្យ វិហរេយ្យ ឧប្បន្នំ អលាភំ ។ បេ ។
ឧប្បន្នំ យសំ ឧប្បន្នំ អយសំ ឧប្បន្នំ សក្ការំ ឧប្បន្នំ
អសក្ការំ ឧប្បន្នំ បាបិច្ឆតំ ។ បេ ។ ឧប្បន្នំ បាបមិត្តតំ
អភិភុយ្យ អភិភុយ្យ វិហរេយ្យ យំ ហិស្ស ភិក្ខវេ ឧប្បន្នំ
លាភំ អនភិភុយ្យ វិហរតោ ឧប្បជ្ជេយ្យុំ អាសវា វិឃា-
តបរិឡាហា ឧប្បន្នំ លាភំ អភិភុយ្យ អភិភុយ្យ វិហ-
រតោ ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ យំ
ហិស្ស ភិក្ខវេ ឧប្បន្នំ អលាភំ ។ បេ ។ ឧប្បន្នំ យសំ
ឧប្បន្នំ អយសំ ឧប្បន្នំ សក្ការំ ឧប្បន្នំ អសក្ការំ

---

១ ម. កិញ្ច ។ សព្វត្ថ កថញ្ច ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាអាក្រក់ដែលកើតឡើងហើយ ។ បេ ។ គ្របសង្កត់នូវភាវៈជាបាបមិត្តដែលកើតឡើងហើយ ជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសង្កត់សង្កិន នូវលាភដែលកើតឡើងហើយ នូវអលាភដែលកើតឡើងហើយ ។ បេ ។ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាអាក្រក់ដែលកើតឡើងហើយ ។ បេ ។ គ្របសង្កត់ នូវភាវៈជាបាបមិត្តដែលកើតឡើងហើយ ព្រោះអាស្រ័យប្រយោជន៍ដូចម្តេច ម្នាលភិក្ខុទាំងឡាយ ព្រោះថា បើភិក្ខុមិនបានសង្កត់សង្កិននូវលាភណា ដែលកើតឡើងហើយ អាសវក្កិលេសទាំងឡាយ គឺសេចក្តីចង្អៀតចង្អល់ និងសេចក្តីក្តៅក្រហាយគប្បីកើតឡើង (ដល់ភិក្ខុនោះ) កាលបើភិក្ខុបានសង្កត់សង្កិនញាំញី នូវលាភដែលកើតឡើងហើយ យ៉ាងនេះ អាសវក្កិលេសទាំងនោះ គឺសេចក្តីចង្អៀតចង្អល់និងសេចក្តីក្តៅក្រហាយ រមែងមិនមានដល់ (ភិក្ខុនោះ) ម្នាលភិក្ខុទាំងឡាយ ព្រោះថា បើភិក្ខុនោះមិនសង្កត់សង្កិន នូវអលាភណាដែលកើតឡើងហើយ ។ បេ ។ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឧប្បន្នំ បាបិច្ឆតំ ។បេ។ ឧប្បន្នំ បាបមិត្តតំ អភិភុយ្យ វិហរតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា ឧប្បន្នំ អលាភំ ឧប្បន្នំ បាបមិត្តតំ អភិភុយ្យ អភិភុយ្យ វិហរតោ ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ឥមំ ខោ ភិក្ខវេ ភិក្ខុ អត្ថវសំ បដិច្ច ឧប្បន្នំ លាភំ អភិភុយ្យ អភិភុយ្យ វិហរេយ្យ ឧប្បន្នំ អលាភំ ។បេ។ ឧប្បន្នំ យសំ ឧប្បន្នំ អយសំ ឧប្បន្នំ សក្ការំ ឧប្បន្នំ អសក្ការំ ឧប្បន្នំ បាបិច្ឆតំ ។បេ។ ឧប្បន្នំ បាបមិត្តតំ អភិភុយ្យ អភិភុយ្យ វិហរេយ្យ ។ តស្មាតិហ ភិក្ខវេ ឧប្បន្នំ លាភំ អភិភុយ្យ អភិភុយ្យ វិហរិស្សាម ។ ឧប្បន្នំ អលាភំ ។បេ។ ឧប្បន្នំ យសំ ឧប្បន្នំ អយសំ ឧប្បន្នំ សក្ការំ ឧប្បន្នំ អសក្ការំ

សេចក្តីប្រាថ្នាអាក្រក់ ដែលកើតឡើងហើយ ។ បេ ។ កាលភិក្ខុមិនសង្កត់សង្កិននូវភាវៈជាបាបមិត្តដែលកើតឡើងហើយទេ អាសវក្កិលេសទាំងឡាយ គឺសេចក្តីចង្អៀតចង្អល់និងសេចក្តីក្តៅក្រហាយ គប្បីកើតឡើងដល់ភិក្ខុនោះ កាលបើភិក្ខុបានសង្កត់សង្កិនញាំញី នូវអលាភដែលកើតឡើងហើយ នូវភាវៈជាបាបមិត្តដែលកើតឡើងហើយ អាសវក្កិលេសទាំងនោះ គឺសេចក្តីចង្អៀតចង្អល់ និងសេចក្តីក្តៅក្រហាយ រមែងមិនមាន (ដល់ភិក្ខុនោះ) យ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសង្កត់សង្កិន នូវលាភដែលកើតឡើងហើយ នូវអលាភដែលកើតឡើងហើយ ។ បេ ។ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាអាក្រក់ដែលកើតឡើងហើយ ។ បេ ។ គ្របសង្កត់ នូវភាវៈជាបាបមិត្តដែលកើតឡើងហើយ ព្រោះអាស្រ័យអំណាចប្រយោជន៍នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុដូច្នេះ ក្នុងសាសនានេះ គួរយើងទាំងឡាយសង្កត់សង្កិនញាំញី នូវលាភដែលកើតឡើងហើយ ។ គួរយើងទាំងឡាយសង្កត់សង្កិនញាំញី នូវអលាភដែលកើតឡើងហើយ ។ បេ ។ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ឧប្បន្នំ បាបិច្ឆតំ ។ បេ ។ ឧប្បន្នំ បាបមិត្តតំ អភិភុយ្យ អភិភុយ្យ វិហរិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

(៦៦) តីហិ ភិក្ខវេ អសទ្ធម្មេហិ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ កតមេហិ តីហិ ។ បាបិច្ឆតា បាបមិត្តតា ឱរមត្តកេន វិសេសាធិគមេន អន្តរា វោសានំ អាបាទិ ឥមេហិ ខោ ភិក្ខវេ តីហិ អសទ្ធម្មេហិ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោតិ(១)

(៦៧) មា ជាតុ កោចិ លោកស្មឹ
បាបិច្ឆោ ឧបបជ្ជថ(២)
តទមិនាបិ ជានាថ
បាបិច្ឆានំ យថា គតិ ។
បណ្ឌិតោតិ សមញ្ញាតោ
ភាវិតត្តោតិ សម្មតោ
ជលំវ យសសា អដ្ឋា
ទេវទត្តោតិ មេ សុតំ ។

១ ឱ. ម. កប្បដ្ឋោ អតេកិច្ឆោតិ ។ ២ ឱ. ឧបបជ្ជិថ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នូវសេចក្តីប្រាថ្នាអាក្រក់ដែលកើតឡើងហើយ ។ បេ ។ គ្របសង្កត់នូវការៈជាបាបមិត្តដែលកើតឡើងហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សា យ៉ាងនេះចុះ ។

(៦៦) ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវអសទ្ធម្ម ៣ ប្រការគ្របសង្កត់ មានចិត្តប្រែប្រួល ជាបុគ្គលទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់ ១ កប្ប កែខ្លួនលែងបាន ។ អសទ្ធម្ម ៣ ប្រការតើដូចម្តេចខ្លះ ។ (អសទ្ធម្ម ៣ ប្រការនោះគឺ) សេចក្តីប្រាថ្នាអាក្រក់ ១ ការៈជាបាប-មិត្ត ១ ដល់នូវសេចក្តីពាយមាយ ក្នុងពាក់កណ្តាល ដោយកិរិយាបាននូវគុណវិសេសត្រឹមតែឈានដ៏ថោកទាប ១ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវអសទ្ធម្មទាំង ៣ ប្រការនេះគ្របសង្កត់ហើយ មានចិត្តប្រែប្រួល ជាអ្នកទៅកើតក្នុងអបាយ កើតក្នុងនរក ឋិតនៅអស់ ១ កប្ប ។

(៦៧) បុគ្គលណាមួយជាអ្នកប្រាថ្នាលាមក សូមកុំកើតក្នុង
លោកឡើយ ដំណើរនៃបុគ្គលមានសេចក្តីប្រាថ្នាលាមកទាំង
ឡាយ យ៉ាងណា អ្នកទាំងឡាយចូរដឹងដំណើរនោះដោយ
ហេតុនេះចុះ ។ តថាគតបានឮថា ទេវទត្តអ្នកផងដឹងច្បាស់ឈ្មោះ
ថាជាបណ្ឌិត អ្នកផងសន្មតថាជាអ្នកមានចិត្តបានអប់រំហើយ
ទេវទត្តហាក់ដូចជាកាលរុងរឿង ដោយយសឋិតនៅ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ ទេវទត្តវត្ថុ ឧទានគាថា

សោ បមាទំ អនុចិណ្ណោ
អាសជ្ជ នំ តថាគតំ
អវីចិនិរយំ បត្តោ
ចតុទ្វារំ ភយានកំ ។
អទុដ្ឋស្ស ហិ យោ ទុព្ភេ(១)
បាបកម្មំ អកុព្វតោ
តមេវ បាបំ ផុសតិ
ទុដ្ឋចិត្តំ អនាទរំ ។
សមុទ្ទំ វិសកុម្ភេន
យោ មញ្ញេយ្យ បទូសិតុំ
ន សោ តេន បទូសេយ្យ
ភេស្មា ហិ ឧទធី មហា
ឯវមេវ តថាគតំ
យោ វាទេនុបហឹសតិ
សមគតំ(២) សន្តចិត្តំ
វាទោ តម្ហិ ន រូហតិ ។

---

១ ឱ. ទុព្ភោ ។ ២ ឱ. សម្មាគតំ ។ ម. សមគ្គតំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ រឿងទេវទត្ត និងឧទានគាថា

ទេវទត្តនោះឯង តែងសន្សំសេចក្តីប្រមាទរឿយ ៗ ហើយ បៀតបៀនតថាគតនោះ ក៏ធ្លាក់ទៅរងទុក្ខក្នុងនរកអវីចិ មានទ្វារ ៤ ដែលគួរខ្លាច ។ សេចក្តីពិតថា នរណាប្រទូស្តចំពោះបុគ្គលដែលមិនបានប្រទូស្ត មិនបានធ្វើអំពើអាក្រក់ បាបតែងពាល់ត្រូវនូវបុគ្គលដែលមានចិត្តប្រទូស្ត អ្នកមិនអើពើនោះវិញ ។ អ្នកណាប៉ងប្រទូស្តនូវសមុទ្រដោយថ្នាំពិស ១ ក្អម អ្នកនោះឯងមិនអាចនឹងប្រទូស្តដោយថ្នាំពិស ១ ក្អមនោះបានឡើយ ព្រោះថា សមុទ្រធំទូលាយគួរឲ្យស្ញប់ស្ញែង (សេចក្តីនេះ) មានឧបមាយ៉ាងណា មានឧប-មេយ្យដូចជានរណាប្រទូស្តនឹងតថាគត ដែលមានចិត្តស្មើ មានចិត្តស្ងប់ ដោយពាក្យពោលទោស ពាក្យជាទោសនោះមិនបានលូតលាស់ចំរើនឡើងក្នុងតថាគតនោះឡើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តាទិសំ មិត្តំ កុព្វេថ
តញ្ច សេវេយ្យ(១) បណ្ឌិតោ
យស្ស មគ្គានុគោ ភិក្ខុ
ខយំ ទុក្ខស្ស បាបុណោតិ ។

(៦៨) អថខោ អាយស្មា ឧបាលិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧបាលិ ភគវន្តំ ឯតទវោច សង្ឃរាជិ សង្ឃរាជីតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សង្ឃរាជិ ហោតិ នោ ច សង្ឃភេទោ កិត្តាវតា ច បន សង្ឃរាជិ ចេវ ហោតិ សង្ឃភេទោ ចាតិ ។ ឯកតោ ឧបាលិ ឯកោ ហោតិ ឯកតោ ទ្វេ ចតុត្ថោ អនុស្សាវេតិ សលាកំ គាហេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហថ ឥមំ រោចេថាតិ ឯវំ ខោ ឧបាលិ សង្ឃរាជិ ហោតិ នោ ច សង្ឃភេទោ ។ ឯកតោ ឧបាលិ ទ្វេ ហោន្តិ

---

១ ឱ. ឫ. សេវេថ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុដើរទៅតាមតម្រាយ នៃមិត្តណា គប្បីដល់នូវកិរិយា
ក្បៀសទៅនៃទុក្ខបាន ភិក្ខុជាបណ្ឌិត គប្បីធ្វើនូវសេចក្តីស្និទ្ធ
ស្នាលនឹងមិត្តដូច្នោះផង គប្បីសេពគប់នឹងមិត្តនោះផង ។

(៦៨) គ្រានោះ ព្រះឧបាលិដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះឧបាលិដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសេចក្តីនុះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សេចក្តីប្រេះឆានៃសង្ឃ ដែលហៅថា សង្ឃរាជិ បពិត្រព្រះអង្គដ៏ចំរើន សេចក្តីប្រេះឆានៃសង្ឃ ដែលមិនមែនជាសង្ឃភេទ ដោយហេតុប៉ុន្មានយ៉ាង សេចក្តីប្រេះឆានៃសង្ឃផង សង្ឃភេទផង ដោយហេតុប៉ុន្មានយ៉ាង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុប៉ែកម្ខាង[១] មួយរូប ភិក្ខុប៉ែកម្ខាង[២] ពីររូប ឯភិក្ខុគំរប់ ៤[៣] សូត្រឲ្យភិក្ខុចាប់ស្លាកដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ហេតុយ៉ាងនេះឯង ហៅថា សេចក្តីប្រេះឆានៃសង្ឃ មិនមែនជាសង្ឃភេទទេ ។ ម្នាលឧបាលិ ភិក្ខុប៉ែកម្ខាងពីររូប

---

១ ប៉ែកខាងធម្មវាទី ។ ២ ប៉ែកខាងធម្មវាទី ។ ៣ ជាអធម្មវាទី ។ (អដ្ឋកថា) ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឯកតោ ទ្វេ បញ្ចមោ អនុស្សាវេតិ សលាកំ គាហេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហថ ឥមំ រោចេថាតិ ឯវម្បិ ខោ ឧបាលិ សង្ឃរាជិ ហោតិ នោ ច សង្ឃភេទោ ។ ឯកតោ ឧបាលិ ទ្វេ ហោន្តិ ឯកតោ តយោ ឆដ្ឋោ អនុស្សាវេតិ សលាកំ គាហេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហថ ឥមំ រោចេថាតិ ឯវម្បិ ខោ ឧបាលិ សង្ឃរាជិ ហោតិ នោ ច សង្ឃភេទោ ។ ឯកតោ ឧបាលិ តយោ ហោន្តិ ឯកតោ តយោ សត្តមោ អនុស្សាវេតិ សលាកំ គាហេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហថ ឥមំ រោចេថាតិ ឯវម្បិ ខោ ឧបាលិ សង្ឃរាជិ ហោតិ នោ ច សង្ឃភេទោ ។ ឯកតោ ឧបាលិ តយោ ហោន្តិ ឯកតោ ចត្តារោ អដ្ឋមោ អនុស្សាវេតិ សលាកំ គាហេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហថ ឥមំ រោចេថាតិ ឯវម្បិ ខោ ឧបាលិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុប៉ែកម្ខាងពីររូប ឯភិក្ខុជាគំរប់ ៥ សូត្រឲ្យភិក្ខុចាប់ស្លាកដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះពាក្យប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ហេតុយ៉ាងនេះឯង ហៅថាសេចក្តីប្រេះធានៃសង្ឃ មិនមែនជាសង្ឃភេទ ។បេ។ ម្នាលឧបាលិ ភិក្ខុប៉ែកម្ខាងពីររូប ភិក្ខុប៉ែកម្ខាងបីរូប ឯភិក្ខុជាគំរប់ ៦ សូត្រឲ្យភិក្ខុចាប់ស្លាកដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ហេតុយ៉ាងនេះឯង ហៅថាសេចក្តីប្រេះធានៃសង្ឃ មិនមែនជាសង្ឃភេទទេ ។ ម្នាលឧបាលិ ភិក្ខុប៉ែកម្ខាង ៣ រូប ភិក្ខុប៉ែកម្ខាង ៣ រូប ឯភិក្ខុជាគំរប់៧សូត្រឲ្យភិក្ខុចាប់ស្លាកដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ហេតុយ៉ាងនេះឯង ហៅថាសេចក្តីប្រេះធានៃសង្ឃ មិនមែនជាសង្ឃ-ភេទទេ ។ ម្នាលឧបាលិ ភិក្ខុប៉ែកម្ខាង ៣ រូប ភិក្ខុប៉ែកម្ខាង ៤ រូប ឯភិក្ខុជាគំរប់ ៨ សូត្រឲ្យភិក្ខុចាប់ស្លាកដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ហេតុយ៉ាងនេះឯង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



សង្ឃរាជិ ហោតិ នោ ច សង្ឃភេទោ ។ ឯកតោ ឧបាលិ ចត្តារោ ហោន្តិ ឯកតោ ចត្តារោ បញ្ចមោ អនុស្សាវេតិ សលាកំ គាហេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហថ ឥមំ រោចេថាតិ ឯវម្បិ ខោ ឧបាលិ សង្ឃរាជិ ចេវ ហោតិ សង្ឃភេទោ ច ។ នវន្នំ វា ឧបាលិ អតិរេកនវន្នំ វា សង្ឃរាជិ ចេវ ហោតិ សង្ឃភេទោ ច ។ ន ខោ ឧបាលិ ភិក្ខុនី សង្ឃំ ភិន្ទតិ អបិច ភេទាយ បរក្កមតិ ។ ន សិក្ខមានា សង្ឃំ ភិន្ទតិ ន សាមណេរោ សង្ឃំ ភិន្ទតិ ន សាមណេរី សង្ឃំ ភិន្ទតិ ន ឧបាសកោ សង្ឃំ ភិន្ទតិ ន ឧបាសិកា សង្ឃំ ភិន្ទតិ អបិច ភេទាយ បរក្កមតិ ។ ភិក្ខុ ខោ ឧបាលិ បកតត្តោ សមានសំវាសកោ សមានសីមាយំ ឋិតោ សង្ឃំ ភិន្ទតីតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ហៅថាសេចក្តីប្រេះឆានៃសង្ឃ មិនមែនជាសង្ឃភេទទេ ។ ម្នាលឧបាលិ ភិក្ខុប៉ែកម្ខាង ៤ រូប ភិក្ខុប៉ែកម្ខាង ៤ រូប ឯភិក្ខុជាគំរប់ ៩ សូត្រឲ្យភិក្ខុចាប់ស្លាកដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ហេតុយ៉ាងនេះឯង ហៅថាសេចក្តីប្រេះឆានៃសង្ឃផង ហៅថាសង្ឃភេទផង ។ ម្នាលឧបាលិ សេចក្តីប្រេះឆានៃសង្ឃនឹងសង្ឃភេទ រមែងមានដល់ភិក្ខុ ៩ រូបក៏មាន ដល់ភិក្ខុច្រើនជាង ៩ រូបទៅក៏មាន ។ ម្នាលឧបាលិ ភិក្ខុនីមិនឈ្មោះថា បំបែកសង្ឃទេ តែបានឈ្មោះថា ព្យាយាមដើម្បីបំបែក (សង្ឃ) សិក្ខមានាក៏មិនឈ្មោះថា បំបែកសង្ឃ សាមណេរក៏មិនឈ្មោះថា បំបែកសង្ឃ សាមណេរីក៏មិនឈ្មោះថា បំបែកសង្ឃ ឧបាសកក៏មិនឈ្មោះថា បំបែកសង្ឃ ឧបាសិកាក៏មិនឈ្មោះថា បំបែកសង្ឃ តែបានឈ្មោះថា ព្យាយាមដើម្បីបំបែកសង្ឃ ។ ម្នាលឧបាលិ លុះតែភិក្ខុដែលមានខ្លួនជាប្រក្រតី(១) មានសំវាសស្មើគ្នា ឋិតនៅក្នុងសីមាជាមួយគ្នា ទើបឈ្មោះថា បំបែកសង្ឃ ។

---

១ ភិក្ខុដែលមានខ្លួនជាប្រក្រតី គឺភិក្ខុដែលសង្ឃមិនបានលើកវត្ត ឬភិក្ខុដែលបរិសុទ្ធ ឥតមានត្រូវគរុកាបត្តិណាមួយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



## សង្ឃភេទក្ខន្ធកេ ឧបាលិត្ថេរវត្ថុ សង្ឃភេទោ

[៦៩] សង្ឃភេទោ សង្ឃភេទោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សង្ឃោ ភិន្នោ ហោតីតិ ។ ឥធុបាលិ ភិក្ខូ អធម្មំ ធម្មោតិ ទីបេន្តិ ធម្មំ អធម្មោតិ ទីបេន្តិ អវិនយំ វិនយោតិ ទីបេន្តិ វិនយំ អវិនយោតិ ទីបេន្តិ អភាសិតំ អលបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេន្តិ ភាសិតំ លបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេន្តិ អនាចិណ្ណំ តថាគតេន អាចិណ្ណំ តថាគតេនាតិ ទីបេន្តិ អាចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេនាតិ ទីបេន្តិ អប្បញ្ញត្តំ តថាគតេន បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ បញ្ញត្តំ តថាគតេន អប្បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ អនាបត្តឹ អាបត្តីតិ ទីបេន្តិ អាបត្តឹ អនាបត្តីតិ ទីបេន្តិ លហុកំ អាបត្តឹ គរុកា អាបត្តីតិ ទីបេន្តិ គរុកំ អាបត្តឹ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ រឿងព្រះឧបាលិត្ថេរ នឹងសង្ឃភេទ

(៦៩) ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ការបំបែកសង្ឃ ព្រះអង្គត្រាស់ថា សង្ឃភេទ បពិត្រព្រះអង្គដ៏ចំរើន ចុះសង្ឃដែលបែកគ្នាយ ដោយហេតុប៉ុន្មានយ៉ាង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលឧបាលិ ភិក្ខុទាំងឡាយក្នុងសាសនានេះ សំដែងសភាពមិនមែនធម៌ថាជាធម៌ សំដែងធម៌ថាមិនមែនជាធម៌ សំដែងសភាពដែលមិនមែនវិន័យថាជាវិន័យ សំដែងវិន័យថាមិនមែនជាវិន័យ សំដែងធម៌វិន័យដែលតថាគតមិនបានសំដែង មិនបានពោលថា តថាគតបានសំដែងបានពោល សំដែងធម៌វិន័យដែលតថាគតបានសំដែង បានពោលថា តថាគតមិនបានសំដែង មិនបានពោលវិញ សំដែងវត្តដែលតថាគតមិនបានសន្សំមកហើយ ថាជាវត្តដែលតថាគតសន្សំមកហើយ សំដែងវត្តដែលតថាគតបានសន្សំមកហើយ ថាជាវត្តដែលតថាគតមិនបានសន្សំមកទេ សំដែងសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តថា តថាគតបានបញ្ញត្ត សំដែងសិក្ខាបទ ដែលតថាគតបានបញ្ញត្តហើយថា តថាគតមិនបានបញ្ញត្តទេ សំដែងអនាបត្តិ ថាជាអាបត្តិ សំដែងអាបត្តិថាជាអនាបត្តិ សំដែងលហុកាបត្តិ ថាជាគរុកាបត្តិ សំដែងគរុកាបត្តិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



លហុកា អាបត្តីតិ ទីបេន្តិ សាវសេសំ អាបត្តឹ អនវសេសា អាបត្តីតិ ទីបេន្តិ អនវសេសំ អាបត្តឹ សាវសេសា អាបត្តីតិ ទីបេន្តិ ទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លា អាបត្តីតិ ទីបេន្តិ អទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លា អាបត្តីតិ ទីបេន្តិ ។ ឥមេហិ អដ្ឋារសហិ វត្ថូហិ អបកស្សន្តិ[១] អវបកាសន្តិ អាវេណិកំ ឧបោសថំ[២] ករោន្តិ អាវេណិកំ បវារណំ ករោន្តិ អាវេណិកំ សង្ឃកម្មំ ករោន្តិ ឯត្តាវតា ខោ ឧបាលិ សង្ឃោ ភិន្នោ ហោតីតិ ។

(៧០) សង្ឃសាមគ្គី សង្ឃសាមគ្គីតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សង្ឃោ សមគ្គោ ហោតីតិ ។ ឥធុបាលិ ភិក្ខូ អធម្មំ អធម្មោតិ ទីបេន្តិ ធម្មំ ធម្មោតិ ទីបេន្តិ អវិនយំ អវិនយោតិ ទីបេន្តិ វិនយំ វិនយោតិ ទីបេន្តិ អភាសិតំ អលបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេន្តិ

---

១ ឱ. អបកសន្តិ ។ ២ ឱ. អាវេណិឧបោសថំ ។ ម. អវបកស្សន្តិ អាវេនិឧបោសថំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ថាជាលហុកាបត្តិ សំដែងសាវសេសាបត្តិ(១) ថាជាអនវសេសាបត្តិ(២) សំដែងអនវសេសាបត្តិ ថាជាសាវសេសាបត្តិ សំដែងទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ សំដែងអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ភិក្ខុទាំងនោះក៏ទង់ទាញគៀគរ (បរិសទ្យ) ហើយធ្វើឧបោសថផ្សេងពីគ្នា ធ្វើបវារណាផ្សេងពីគ្នា ធ្វើសង្ឃកម្មផ្សេងពីគ្នា ដោយវត្ថុ ១៨ ប្រការនេះឯង ម្នាលឧបាលិ សង្ឃដែលបែកធ្លាយ ដោយហេតុប៉ុណ្ណោះឯង ។

[៧០] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សេចក្តីព្រមព្រៀងនៃសង្ឃ ព្រះអង្គត្រាស់ថា សង្ឃសាមគ្គី បពិត្រព្រះអង្គដ៏ចំរើន សង្ឃដែលព្រមព្រៀងគ្នា ដោយហេតុប៉ុន្មានយ៉ាង ។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលឧបាលិ ភិក្ខុទាំងឡាយក្នុងសាសនានេះ សំដែងសភាពមិនមែនធម៌ថា មិនមែនធម៌ សំដែងធម៌ ថាជាធម៌ សំដែងសភាពមិនមែនជាវិន័យថា មិនមែនជាវិន័យ សំដែងវិន័យ ថាជាវិន័យ សំដែងធម៌វិន័យ ដែលតថាគតមិនបាន សំដែង មិនបានពោល ថា តថាគតមិនបានសំដែង មិនបានពោលទេ

---

១ សំដៅយកអាបត្តិ ៦ កង គឺសង្ឃាទិសេស ១ ថុល្លច្ច័យ ១ បាចិត្តិយ ១ បាដិទេសនីយៈ ១ ទុក្កដ ១ ទុព្ភាសិត ១ ។ ២ សំដៅយកបារាជិកាបត្តិ (អដ្ឋកថា) ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ ឧបាលិបុច្ឆាវត្ថុ សង្ឃសាមគ្គី

ភាសិតំ លបិតំ តថាគតេន ភាសិតំ លបិតំ ត-
ថាគតេនាតិ ទីបេន្តិ អនាចិណ្ណំ តថាគតេន អនាចិណ្ណំ
តថាគតេនាតិ ទីបេន្តិ អាចិណ្ណំ តថាគតេន អាចិណ្ណំ
តថាគតេនាតិ ទីបេន្តិ អបញ្ញត្តំ តថាគតេន អបញ្ញត្តំ
តថាគតេនាតិ ទីបេន្តិ បញ្ញត្តំ តថាគតេន បញ្ញត្តំ តថា-
គតេនាតិ ទីបេន្តិ អនាបត្តឹ អនាបត្តីតិ ទីបេន្តិ អាបត្តឹ
អាបត្តីតិ ទីបេន្តិ លហុកំ អាបត្តឹ លហុកា អាបត្តីតិ
ទីបេន្តិ គរុកំ អាបត្តឹ គរុកា អាបត្តីតិ ទីបេន្តិ សាវសេសំ
អាបត្តឹ សាវសេសា អាបត្តីតិ ទីបេន្តិ អនវសេសំ អាបត្តឹ
អនវសេសា អាបត្តីតិ ទីបេន្តិ ទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លា
អាបត្តីតិ ទីបេន្តិ អទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លា អាបត្តីតិ
ទីបេន្តិ តេ ឥមេហិ អដ្ឋារសហិ វត្ថូហិ ន អបកស្សន្តិ
ន អវបកាសន្តិ ន អាវេណិកំ ឧបោសថំ ករោន្តិ ន
អាវេណិកំ បវារណំ ករោន្តិ ន អាវេណិកំ សង្ឃកម្មំ
ករោន្តិ ឯត្តាវតា ខោ ឧបាលិ សង្ឃោ សមគ្គោ
ហោតីតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





សំដែងធម៌វិន័យដែលតថាគតបានសំដែង បានពោលថា តថាគតបានសំដែង បានពោល សំដែងវត្តដែលតថាគតមិនធ្លាប់សន្សំមក ថាជាវត្តដែលតថាគតមិនធ្លាប់សន្សំមកទេ សំដែងវត្ត ដែលតថាគតធ្លាប់សន្សំមក ថាជាវត្តដែលតថាគតធ្លាប់សន្សំមក សំដែងសិក្ខាបទដែលតថាគតមិនបានបញ្ញត្តថា តថាគតមិនបានបញ្ញត្តទេ សំដែងសិក្ខាបទដែលតថាគតបានបញ្ញត្តថា តថាគតបានបញ្ញត្ត សំដែងអនាបត្តិ ថាជាអនាបត្តិ សំដែងអាបត្តិ ថាជាអាបត្តិ សំដែងលហុកាបត្តិ ថាជាលហុកាបត្តិ សំដែងគរុកាបត្តិ ថាជាគរុកាបត្តិ សំដែងសាវសេសាបត្តិ ថាជាសាវសេសាបត្តិ សំដែងអនវសេសាបត្តិ ថាជាអនវសេសាបត្តិ សំដែងទុដ្ឋុល្លាបត្តិ (អាបត្តិបារាជិក ឬសង្ឃាទិសេស) ថាជាទុដ្ឋុល្លាបត្តិ សំដែងអទុដ្ឋុល្លាបត្តិ (អាបត្តិ ៥ កង) ថាជាអទុដ្ឋុល្លាបត្តិ ភិក្ខុទាំងនោះមិនទទួញ មិនគៀគរយក (បរិសទ្យ) ហើយមិនធ្វើឧបោសថផ្សេងគ្នា មិនធ្វើបវារណាផ្សេងគ្នា មិនធ្វើសង្ឃកម្មផ្សេងគ្នា ដោយវត្ថុទាំង ១៨ នេះ ម្នាលឧបាលិ សង្ឃឈ្មោះថា ព្រមព្រៀងគ្នាដោយហេតុប៉ុណ្ណោះឯង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



(៧១) សមគ្គំ បន ភន្តេ សង្ឃំ ភិន្ទិត្វា កឹ សោ បសវតីតិ ។ សមគ្គំ ខោ ឧបាលិ សង្ឃំ ភិន្ទិត្វា កប្បដ្ឋិតិកំ(១) កិព្វិសំ បសវតិ កប្បំ និរយម្ហិ បច្ចតីតិ ។

(៧២) អាបាយិកោ នេរយិកោ
កប្បដ្ឋោ សង្ឃភេទកោ
វគ្គរតោ អធម្មដ្ឋោ
យោគក្ខេមា បធំសតិ ។
សង្ឃំ សមគ្គំ ភិន្ទិត្វា
កប្បំ និរយម្ហិ បច្ចតីតិ ។

(៧៣) ភិន្នំ បន ភន្តេ សង្ឃំ សមគ្គំ កត្វា កឹ សោ បសវតីតិ ។ ភិន្នំ ខោ ឧបាលិ សង្ឃំ សមគ្គំ កត្វា ព្រហ្មបុញ្ញំ បសវតិ កប្បំ សគ្គម្ហិ មោទតីតិ ។

---

១ ឱ. ម. កប្បដ្ឋិកំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៧១) ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុបំបែកសង្ឃដែលកំពុងព្រមព្រៀងគ្នា ភិក្ខុនោះរមែងបាននូវផលដូចម្តេចខ្លះ ។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលឧបាលិ ភិក្ខុបំបែកសង្ឃដែលកំពុងព្រមព្រៀងគ្នា រមែងបាននូវផលដ៏ខ្លោចផ្សា តាំងនៅអស់ ១ កប្ប ឆេះនៅក្នុងនរកអស់ ១ កប្ប ។

(៧២) ភិក្ខុអ្នកបំបែកសង្ឃ ត្រេកអរក្នុងពួក មិនដំកល់ខ្លួននៅក្នុងធម៌ តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក តាំងនៅអស់ ១ កប្ប រមែងឃ្លាតចាកធម៌ជាគ្រឿងក្សេមចាកយោគៈ ។ ភិក្ខុបំបែកសង្ឃដែលកំពុងព្រមព្រៀងគ្នា រមែងឆេះនៅក្នុងនរកអស់ ១ កប្ប ។

(៧៣) ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុជាអ្នកសង្រួបសង្រួមសង្ឃដែលបែកគ្នាហើយ ឲ្យបានព្រមព្រៀងគ្នាទៅវិញ រមែងបាននូវផលដូចម្តេចខ្លះ ។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលឧបាលិ ភិក្ខុអ្នកសង្រួបសង្រួមសង្ឃដែលបែកគ្នាហើយ ឲ្យបានព្រមព្រៀងគ្នាទៅវិញ រមែងបាននូវបុណ្យដ៏ប្រសើរ រីករាយក្នុងឋានសួគ៌អស់ ១ កប្ប ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទានៗ





[៧៤] សុខា សង្ឃស្ស សាមគ្គី
សមគ្គានញ្ចនុគ្គហោ
សមគ្គរតោ ធម្មដ្ឋោ
យោគក្ខេមា ន ធំសតិ ។
សង្ឃំ សមគ្គំ កត្វាន
កប្បំ សគ្គម្ហិ មោទតីតិ ។

[៧៥] សិយា នុ ខោ ភន្តេ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោតិ ។ សិយា ឧបាលិ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោតិ ។ សិយា នុ ខោ បន ភន្តេ សង្ឃភេទកោ ន អាបាយិកោ ន នេរយិកោ ន កប្បដ្ឋោ ន អតេកិច្ឆោតិ ។ សិយា ឧបាលិ សង្ឃភេទកោ ន អាបាយិកោ ន នេរយិកោ ន កប្បដ្ឋោ ន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៧៤) សេចក្តីព្រមព្រៀងនៃពួក តែងនាំសេចក្តីសុខមកឲ្យ ភិក្ខុអ្នកអនុគ្រោះ ដល់បុគ្គលមានសេចក្តីព្រមព្រៀងគ្នាទាំងឡាយក្តី ជាអ្នកត្រេកអរក្នុងសេចក្តីព្រមព្រៀងក្តី បានដំកល់ខ្លួនក្នុងធម៌ក្តី (ភិក្ខុនោះ) មិនឃ្លាតចាកធម៌ជាគ្រឿងក្សេមចាកយោគៈឡើយ ។ ភិក្ខុអ្នកសង្រួបសង្រួមសង្ឃឲ្យបានព្រមព្រៀងគ្នា តែងរីករាយក្នុងឋានសួគ៌ អស់ ១ កប្ប ។

(៧៥) ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកបំបែកសង្ឃ ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់ ១ កប្ប កែខ្លួនលែងបាន មានឬទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃតែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់ ១ កប្ប កែខ្លួនលែងបាននោះមាន ។ ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុអ្នកបំបែកសង្ឃ មិនទៅកើតក្នុងអបាយ មិនទៅកើតក្នុងនរក មិនឋិតនៅអស់ ១ កប្ប នៅកែខ្លួនបាន មានដែរឬ ។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃ មិនទៅកើតក្នុងអបាយ មិនទៅកើតក្នុងនរក មិនឋិតនៅអស់ ១ កប្ប

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



អតេកិច្ឆោតិ ។ កតមោ បន ភន្តេ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោតិ ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ តស្មិំ អធម្មទិដ្ឋិ ភេទេ អធម្មទិដ្ឋិ វិនិធាយ ទិដ្ឋិំ វិនិធាយ ខន្តិំ វិនិធាយ រុចិំ វិនិធាយ ភាវំ អនុស្សាវេតិ សលាកំ គាហេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហថ ឥមំ រោចេថាតិ អយម្បិ ខោ ឧបាលិ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ បុន ចបរំ ឧបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ តស្មិំ អធម្មទិដ្ឋិ ភេទេ ធម្មទិដ្ឋិ វិនិធាយ ទិដ្ឋិំ វិនិធាយ ខន្តិំ វិនិធាយ រុចិំ វិនិធាយ ភាវំ អនុស្សាវេតិ សលាកំ គាហេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហថ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នៅតែខ្លួនបានក៏មានដែរ ។ ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុអ្នកបំបែកសង្ឃ ទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់ ១ កប្ប រមែងតែខ្លួនបានដូចម្តេចខ្លះ ។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងសភាពមិនមែនជាធម៌ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងធម៌នោះ ថាមិនមែនជាធម៌ មានសេចក្តីយល់ឃើញក្នុងការបំបែក ថាមិនមែនជាធម៌ បិទបាំងទិដ្ឋិ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ ហើយសូត្រឲ្យភិក្ខុចាប់ស្លាកដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃនេះឯង តែងកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់ ១ កប្ប តែខ្លួនរមែងបាន ។ ម្នាលឧបាលិ ពាក្យដទៃនៅមានទៀត ភិក្ខុសំដែងសភាពមិនមែនធម៌ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងធម៌នោះ ថាមិនមែនជាធម៌ មានសេចក្តីយល់ឃើញក្នុងការបំបែកសង្ឃ ថាជាធម៌ បិទបាំងទិដ្ឋិ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ ហើយសូត្រឲ្យភិក្ខុចាប់ស្លាកដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តា អ្នកទាំងឡាយ ចូរចាប់ស្លាកនេះចុះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឥទំ រោចេថាតិ អយម្បិ ខោ ឧបាលិ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ បុន ចបរំ ឧបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ តស្មឹ អធម្មទិដ្ឋិ ភេទេ វេមតិកោ វិនិធាយ ទិដ្ឋឹ វិនិធាយ ខន្តឹ វិនិធាយ រុចឹ វិនិធាយ ភាវំ អនុស្សាវេតិ សលាកំ គាហេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥទំ គណ្ហថ ឥទំ រោចេថាតិ អយម្បិ ខោ ឧបាលិ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ បុន ចបរំ ឧបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ តស្មឹ ធម្មទិដ្ឋិ ភេទេ អធម្មទិដ្ឋិ ។ បេ ។ តស្មឹ ធម្មទិដ្ឋិ ភេទេ វេមតិកោ ។ បេ ។ តស្មឹ វេមតិកោ ភេទេ អធម្មទិដ្ឋិ តស្មឹ វេមតិកោ ភេទេ ធម្មទិដ្ឋិ តស្មឹ វេមតិកោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ រឿងព្រះឧបាលិត្ថេរ ភិក្ខុអ្នកបំបែកសង្ឃទៅកើតក្នុងអបាយ

ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃនេះឯង តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់ ១ កប្ប កែខ្លួនលែងបាន ។ ម្នាលឧបាលិ ពាក្យដទៃនៅមានទៀត ភិក្ខុសំដែងសភាពមិនមែនធម៌ ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងធម៌នោះ ថាមិនមែនជាធម៌ មានសេចក្តីសង្ស័យក្នុងការបំបែក ហើយបិទបាំងទិដ្ឋិ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ ហើយសូត្រឲ្យភិក្ខុចាប់ស្លាកដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា លោកទាំងឡាយចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃនេះឯង តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់ ១ កប្ប កែខ្លួនលែងបាន ។ ម្នាលឧបាលិ ពាក្យដទៃនៅមានទៀត ភិក្ខុសំដែងសភាពមិនមែនធម៌ ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងធម៌នោះ ថាជាធម៌ មានសេចក្តីយល់ឃើញ ក្នុងការបំបែកថាមិនមែនជាធម៌ ។បេ។ មានសេចក្តីយល់ឃើញក្នុងធម៌នោះ មានសេចក្តីសង្ស័យក្នុងការបំបែក ។បេ។ មានសេចក្តីសង្ស័យក្នុងធម៌នោះ មានសេចក្តីយល់ឃើញក្នុងការបំបែកថាមិនមែនជាធម៌ មានសេចក្តីសង្ស័យក្នុងធម៌នោះ មានសេចក្តីយល់ឃើញក្នុងការបំបែកថាជាធម៌ មានសេចក្តីសង្ស័យក្នុងធម៌នោះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កេន វេមតិកោ វិនិធាយ ទិដ្ឋឹ វិនិធាយ ខន្តឹ វិនិធាយ រុចឹ វិនិធាយ ភាវំ អនុស្សាវេតិ សលាកំ គាហេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥទំ គណ្ហថ ឥទំ រោចេថាតិ អយម្បិ ខោ ឧបាលិ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ បុន ចបរំ ឧបាលិ ភិក្ខុ ធម្មំ អធម្មោតិ ទីបេតិ ។ បេ ។ អវិនយំ វិនយោតិ ទីបេតិ វិនយំ អវិនយោតិ ទីបេតិ អភាសិតំ អលបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេតិ ភាសិតំ លបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេតិ អនាចិណ្ណំ តថាគតេន អាចិណ្ណំ តថាគតេនាតិ ទីបេតិ អាចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេនាតិ ទីបេតិ អបញ្ញត្តំ តថាគតេន បញ្ញត្តំ តថាគតេនាតិ ទីបេតិ បញ្ញត្តំ តថាគតេន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





មានសេចក្តីសង្ស័យ ក្នុងការបំបែក ហើយមិនបាំងទិដ្ឋិ មិនបាំងសេចក្តី
គាប់ចិត្ត មិនបាំងសេចក្តីពេញចិត្ត មិនបាំងសេចក្តីពិតត្រង់ ហើយ
សូត្រឲ្យភិក្ខុចាប់ស្លាក ដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជា
ពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា លោកទាំងឡាយ ចូរចាប់ស្លាកនេះចុះ
ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃ នេះឯង
ជាអ្នកទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅរស់ ១ កប្ប កែខ្លួន
លែងបាន ។ ម្នាលឧបាលិ ពាក្យដទៃទៅមានទៀត ភិក្ខុសំដែង
ធម៌ថាមិនមែនធម៌ ។ បេ ។ សំដែងសភាវៈមិនមែនវិន័យ ថាជាវិន័យ
សំដែងវិន័យថាមិនមែនវិន័យ សំដែងធម៌វិន័យដែលតថាគតមិនបាន
សំដែង មិនបានពោល ថា តថាគតបានសំដែង បានពោល សំដែងធម៌
វិន័យដែលតថាគតបានសំដែង បានពោល ថា តថាគតមិនបានសំដែង មិន
បានពោលទេ សំដែងវត្តដែលតថាគតមិនបានសន្សំមក ថាជាវត្តដែល
តថាគតបានសន្សំមក សំដែងវត្តដែលតថាគតបានសន្សំមក ថាជាវត្ត
ដែលតថាគតមិនបានសន្សំមកទេ សំដែងសិក្ខាបទ ដែលតថាគតមិនបាន
បញ្ញត្ត ថាតថាគតបានបញ្ញត្ត សំដែងសិក្ខាបទ ដែលតថាគតបានបញ្ញត្ត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អប្បញ្ញត្តំ តថាគតេនាតិ ទីបេតិ អនាបត្តឹ អាបត្តីតិ ទីបេតិ អាបត្តឹ អនាបត្តីតិ ទីបេតិ លហុកំ អាបត្តឹ គរុកា អាបត្តីតិ ទីបេតិ គរុកំ អាបត្តឹ លហុកា អា-បត្តីតិ ទីបេតិ សាវសេសំ អាបត្តឹ អនវសេសា អាបត្តីតិ ទីបេតិ អនវសេសំ អាបត្តឹ សាវសេសា អាបត្តីតិ ទីបេតិ ទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លា អាបត្តីតិ ទីបេតិ អទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លា អាបត្តីតិ ទីបេតិ តស្មឹ អធម្មទិដ្ឋិ ភេទេ អធម្មទិដ្ឋិ តស្មឹ អធម្មទិដ្ឋិ ភេទេ ធម្មទិដ្ឋិ តស្មឹ អធម្មទិដ្ឋិ ភេទេ វេមតិកោ តស្មឹ ធម្មទិដ្ឋិ ភេទេ អធម្មទិដ្ឋិ តស្មឹ ធម្មទិដ្ឋិ ភេទេ វេមតិកោ តស្មឹ វេមតិ-កោ ភេទេ អធម្មទិដ្ឋិ តស្មឹ វេមតិកោ ភេទេ ធម្មទិដ្ឋិ តស្មឹ វេមតិកោ ភេទេ វេមតិកោ វិនិធាយ ទិដ្ឋឹ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ថាតថាគតមិនបានបញ្ញត្តទេ សំដែងអនាបត្តិ ថាជាអាបត្តិ សំដែងអា-បត្តិថាជាអនាបត្តិ សំដែងលហុកាបត្តិ ថាជាគរុកាបត្តិ សំដែងគរុកាបត្តិ ថាជាលហុកាបត្តិ សំដែងសាវសេសាបត្តិ ថាជាអនវសេសាបត្តិ សំដែង អនវសេសាបត្តិ ថាជា ហាវសេសាបត្តិ សំដែងទុដ្ឋុល្លាបត្តិ ថាមិនមែន ជាទុដ្ឋុល្លាបត្តិ សំដែងអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ មានសេចក្តីយល់ ឃើញធម៌នោះ ថាមិនមែនធម៌ មានសេចក្តីយល់ឃើញក្នុងការបំបែក ថា មិនមែនធម៌ មានសេចក្តីយល់ឃើញក្នុងធម៌នោះ ថាមិនមែនធម៌ មានសេចក្តីយល់ឃើញក្នុងការបំបែក ថាជាធម៌ មានសេចក្តីយល់ឃើញ ក្នុងធម៌នោះ ថាមិនមែនធម៌ មានសេចក្តីសង្ស័យក្នុងការបំបែក មាន សេចក្តីយល់ឃើញក្នុងធម៌នោះ ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងការ បំបែកថា មិនមែនធម៌ មានសេចក្តីយល់ឃើញក្នុងធម៌នោះ ថាជាធម៌ មាន សេចក្តីសង្ស័យ ក្នុងការបំបែក មានសេចក្តីសង្ស័យ ក្នុងធម៌នោះ មាន សេចក្តីយល់ឃើញក្នុងការបំបែក ថាមិនមែនធម៌ មានសេចក្តីសង្ស័យ ក្នុងធម៌នោះ មានសេចក្តីយល់ឃើញក្នុងការបំបែកថាជាធម៌ មានសេចក្តី សង្ស័យក្នុងធម៌នោះ មានសេចក្តីសង្ស័យ ក្នុងការបំបែក ហើយបិទបាំងទិដ្ឋិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



វិនិធាយ ខន្តឹ វិនិធាយ រុចឹ វិនិធាយ ភាវំ អនុស្សាវេតិ សលាកំ គាហេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហថ ឥមំ រោចេថាតិ អយម្បិ ខោ ឧបាលិ សង្ឃភេទកោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោតិ ។

(៧៦) កតមោ បន ភន្តេ សង្ឃភេទកោ ន អាបាយិកោ ន នេរយិកោ ន កប្បដ្ឋោ ន អតេកិច្ឆោតិ ។ ឥធុបាលិ ភិក្ខុ អធម្មំ ធម្មោតិ ទីបេតិ តស្មឹ ធម្មទិដ្ឋិ ភេទេ ធម្មទិដ្ឋិ អវិនិធាយ ទិដ្ឋឹ អវិនិធាយ ខន្តឹ អវិនិធាយ រុចឹ អវិនិធាយ ភាវំ អនុស្សាវេតិ សលាកំ គាហេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ ហើយសូត្រឲ្យភិក្ខុចាប់ស្លាកដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា លោកទាំងឡាយចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃនេះឯង តែងទៅកើតក្នុងអបាយ ទៅកើតក្នុងនរក ឋិតនៅអស់ ១ កប្ប កែខ្លួនលែងបាន ។

(៧៦) ព្រះឧបាលិត្ថេរក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុអ្នកបំបែកសង្ឃមិនទៅកើតក្នុងអបាយ មិនទៅកើតក្នុងនរក មិនឋិតនៅអស់ ១ កប្ប នៅកែខ្លួនបាននោះ ដូចម្តេចខ្លះ ។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលឧបាលិ ភិក្ខុក្នុងសាសនានេះ សំដែងសភាពមិនមែនធម៌ថាជាធម៌ មានសេចក្តីយល់ឃើញក្នុងធម៌នោះថាជាធម៌ មានសេចក្តីយល់ឃើញក្នុងការបំបែកថាជាធម៌ ហើយមិនបិទបាំងទិដ្ឋិ មិនបិទបាំងសេចក្តីគាប់ចិត្ត មិនបិទបាំងសេចក្តីពេញចិត្ត មិនបិទបាំងសេចក្តីពិតត្រង់ ហើយសូត្រឲ្យភិក្ខុចាប់ស្លាកដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា លោកទាំងឡាយចូរចាប់ស្លាកនេះចុះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកេ ឧបាលិត្ថេរវត្ថុ សង្ឃភេទកោ អាបាយិកោ

គណ្ហាថ ឥមំ រោចេថាតិ អយម្បិ ខោ ឧបាលិ សង្ឃ-ភេទកោ ន អាបាយិកោ ន នេរយិកោ ន កប្បដ្ឋោ ន អតេកិច្ឆោ ។ បុន ចបរំ ឧបាលិ ភិក្ខុ ធម្មំ អធម្មោតិ ទីបេតិ ។ បេ ។ ទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លា អាបត្តីតិ ទីបេតិ តស្មឹ ធម្មទិដ្ឋិ ភេទេ ធម្មទិដ្ឋិ អវិនិធាយ ទិដ្ឋឹ អវិនិធាយ ខន្តឹ អវិនិធាយ រុចឹ អវិនិធាយ ភាវំ អនុស្សា-វេតិ សលាកំ គាហេតិ អយំ ធម្មោ អយំ វិនយោ ឥទំ សត្ថុសាសនំ ឥមំ គណ្ហថ ឥមំ រោចេថាតិ អយម្បិ ខោ ឧបាលិ សង្ឃភេទកោ ន អាបាយិកោ ន នេ-រយិកោ ន កប្បដ្ឋោ ន អតេកិច្ឆោតិ ។

តតិយភាណវារំ និដ្ឋិតំ ។

សង្ឃភេទក្ខន្ធកំ និដ្ឋិតំ សត្តមំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ រឿងព្រះឧបាលិត្ថេរ ភិក្ខុអ្នកបំបែកសង្ឃទៅកើតក្នុងអបាយ

ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃនេះឯង មិនទៅកើតក្នុងអបាយ មិនទៅកើតក្នុងនរក មិនឋិតនៅអស់ ១ កប្ប គួរដល់កិរិយាកែប្រែបាន ។ ម្នាលឧបាលិ ពាក្យខាងមុខនៅមានទៀត ភិក្ខុសំដែងធម៌ថាមិនមែនធម៌ ។ បេ ។ សំដែងទុដ្ឋុល្លាបត្តិថាជាអទុដ្ឋុល្លាបត្តិ មានសេចក្តីយល់ឃើញ ក្នុងអធម៌នោះថាជាធម៌ មានសេចក្តីយល់ឃើញ ក្នុងការបំបែកថាជាធម៌ ហើយមិនបិទបាំងទិដ្ឋិ មិនបិទបាំងសេចក្តីគាប់ចិត្ត មិនបិទបាំងសេចក្តីពេញចិត្ត មិនបិទបាំងសេចក្តីពិតត្រង់ ហើយសូត្រឲ្យភិក្ខុចាប់ស្លាកដោយពាក្យថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា លោកទាំងឡាយ ចូរចាប់ស្លាកនេះចុះ ចូរពេញចិត្តនឹងស្លាកនេះចុះ ម្នាលឧបាលិ ភិក្ខុអ្នកបំបែកសង្ឃនេះឯង មិនទៅកើតក្នុងអបាយ មិនទៅកើតក្នុងនរក មិនឋិតនៅអស់ ១ កប្ប ជាបុគ្គលនៅកែខ្លួនបាន ។

ចប់ ភាណវារៈ ទី ៣ ។

ចប់ សង្ឃភេទក្ខន្ធកៈ ទី ៧ តែប៉ុណ្ណេះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



៥

## តស្សុទ្ទានំ

(៧៧) អនុបិយេ អភិញ្ញាតា
សុខុមាលោ ន ឥច្ឆតិ
កសា វបា អភិនិន្នេ
និទ្ទា លាវេ ច ឧព្វហោ
បុញ្ជមទ្ទបលាលញ្ច
ភុសឱផុននីហារេ(១)
អាយតឹបិ ន ខីយន្តិ
បិតរោ ច បិតាមហា
ភទ្ទិយោ អនុរុទ្ធោ ច
អានន្ទោ ភគុ កិមិលោ
សក្យមានោ វ កោសម្ពិ(២)
បរិហាយិ កក្កុធេន ច
បកាសេសិ បត្តោ ច

១ ឱ. ភុសឱបុននីហរេ ។ ម. ភុសឱធុននីហរេ ។ ២ ម. សក្យមានោ ច កោសម្ពិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដក ចុល្លវគ្គ

# ឧទ្ទាន

(បញ្ចីរឿងនៃសង្ឃភេទក្ខន្ធកៈគឺ)

[៧៧] រឿងព្រះសម្មាសម្ពុទ្ធគង់ក្នុងអនុបិយនិគម ១ រឿងពួកសក្យកុមារមានឈ្មោះល្បីល្បាញ ១ រឿងអនុរុទ្ធសក្យៈជាសុខុមាលជាតិ មិនបង់ចេញសាងផ្នួស ១ រឿងមហានាមពន្យល់អនុរុទ្ធថាការធ្វើស្រែ មុនដំបូងត្រូវភ្ជួររាស់ ១ រួចសាបព្រោះ ១ រួចបញ្ចូលទឹក ១ រួចដំរះស្មៅ ១ រួចច្រូត ១ រួចចងជាកណ្តាប់ ១ រួចគរកណ្តាប់ជាគំនរ ១ រួចបញ្ជាន់ឬបែនបោក ១ រួចជុះចំបើង ១ រួចជុះកំទេច ១ រួចរោយស្រូវ ១ រួចជញ្ជូនមកទុក ទាំងពន្យល់ថា ស្រែត្រូវតែធ្វើយ៉ាងនេះរាល់ឆ្នាំតទៅ ថាមាតាបិតានឹងជីដូនជីតា ទោះបីអនិច្ចកម្មទៅអស់ ឯការងារក៏នៅតែមិនចេះអស់ ១ រឿងភទ្ទិយៈ អនុរុទ្ធ អានន្ទ ភគ្គុ និងកិមិលៈចេញបួស ១ រឿងពួកសក្យរាជកុមារបន្ទយនូវមានះ ១ រឿងព្រះអង្គគង់នៅ (ក្នុងឃោសិតារាម) ទៀបក្រុងកោសម្ពី ១ រឿងទេវទត្តសាបសូន្យ (លាភសក្ការៈ) ១ រឿងកក្កុធទេវបុត្ត ១ រឿងព្រះសារីបុត្តត្រូវប្រកាសនូវ (ទោសទេវទត្ត) ១ រឿងទេវទត្តដឹកនាំអជាតសត្តុកុមារឲ្យសម្លាប់បិតា ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## សង្ឃភេទក្ខន្ធកេ ឧទ្ទានគាថា

បុរិសេ សេលា នាឡាគិរិ(១)
តិកបញ្ច គរុកោ ទោ
កិន្តិ ធុល្លច្ចយេន ច
តយោ អដ្ឋ បុន តីណិ
រាជិភេទា សិយា ឆុ ទោតិ ។

---

១ ម. បុរិសេន នាឡាគិរី ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សង្ឃភេទក្ខន្ធកៈ ឧទ្ទានគាថា

បញ្ជូនបុរសទាំងឡាយ ឲ្យទៅសម្លាប់ព្រះពុទ្ធអង្គ ១ ប្រមៀលថ្ម ១ លែងដំរីនាឡាគិរី ១ រឿងព្រះពុទ្ធអង្គអនុញ្ញាតតិកភោជន ១ រឿងទេវទត្តសូមវត្ថុ ៥ ប្រការ ១ រឿងព្រះពុទ្ធអង្គសំដែងថា បុគ្គលដែលបំបែកសង្ឃមានទោសជាទម្ងន់ ១ រឿងទេវទត្តបំបែកសង្ឃ ១ រឿងព្រះពុទ្ធអង្គទ្រង់បង្គាប់ឲ្យភេទានុវត្តកភិក្ខុសំដែងថុល្លច្ចយាបត្តិចេញ ១ រឿងព្រះពុទ្ធអង្គ ទ្រង់សំដែងពីភិក្ខុដែលគួរធ្វើទូតបាន លុះតែប្រកបដោយអង្គ ៨ ប្រការបើលើក ១ រឿងព្រះពុទ្ធអង្គ ទ្រង់សំដែងអសទ្ធម្ម ៣ ប្រការ ១ រឿងព្រះឧបាលិត្ថេរទូលសួរព្រះពុទ្ធអង្គពីសេចក្តីប្រេះឆានៃសង្ឃនិងការបែកធ្លាយនៃសង្ឃ ១ ពីភិក្ខុអ្នកបំបែកសង្ឃដែលទៅកើតក្នុងអបាយមានឬទេ ១ ។

---

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទានៗ



[៣៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាគន្តុកា ភិក្ខូ សឧបាហនាបិ អារាមំ បវិសន្តិ ឆត្តបគ្គហិតាបិ អារាមំ បវិសន្តិ ឱគុណ្ឋិតាបិ អារាមំ បវិសន្តិ សីសេបិ ចីវរំ ករិត្វា អារាមំ បវិសន្តិ បានីយេនបិ បាទេ ធោវន្តិ វុឌ្ឍតរេបិ អាវាសិកេ ភិក្ខូ ន អភិវាទេន្តិ នបិ(១) សេនាសនំ បុច្ឆន្តិ ។ អញ្ញតរោបិ អាគន្តុកោ ភិក្ខុ អនជ្ឈាវុត្ថំ វិហារំ ឃដិកំ ឧគ្ឃាដេត្វា កវាដំ បណាមេត្វា សហសា បាវិសិ ។ តស្ស ឧបរិបិដ្ឋិតោ អហិ ខន្ធេ បបតិ ។ សោ ភីតោ វិស្សរមកាសិ ។ ភិក្ខូ ឧបធាវិត្វា តំ ភិក្ខុំ ឯតទវោចុំ កិស្ស ត្វំ អាវុសោ វិស្សរមកាសីតិ ។ អថខោ សោ ភិក្ខុ ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម

១ ឧ. ម. បោត្ថកេសុ បិសទ្ទោ ន បញ្ញាយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



(៧៨) សម័យនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកគហបតិ ទៀបក្រុងសាវត្ថី ។ សម័យនោះឯង អាគន្តុកភិក្ខុទាំងឡាយពាក់ស្បែកជើងដើរចូលទៅកាន់អារាមខ្លះ បាំងឆត្រដើរចូលទៅកាន់អារាមខ្លះ ទទូរក្បាលដើរចូលទៅកាន់អារាមខ្លះ ទូលចីវរលើក្បាលដើរចូលទៅកាន់អារាមខ្លះ លាងជើងដោយទឹកសម្រាប់ផឹកខ្លះ មិនថ្វាយបង្គំអាវាសិកភិក្ខុ(១)ទាំងឡាយដែលចាស់ជាងខ្លួនខ្លះ មិនសួរគេសេនាសនៈខ្លះ ។ មានអាគន្តុកភិក្ខុមួយរូបទៀត បើកគន្លឹះប្រានសន្ទះទ្វារ ហើយចូលទៅកាន់វិហារដែលមិនមានអ្នកណានៅ ដោយប្រញាប់ប្រញាល់ ។ មានពស់ធ្លាក់ពីខាងលើក្របទ្វារមកត្រូវត្រង់កភិក្ខុនោះ ។ ភិក្ខុនោះខ្លាច ក៏ស្រែកក្វាត់សម្លេង ។ ភិក្ខុទាំងឡាយស្ទុះចូលទៅសួរភិក្ខុនោះថា ម្នាលអាវុសោ ហេតុអ្វីបានជាលោកស្រែកក្វាត់សម្លេងម៉្លេះ ។ លំដាប់នោះ ភិក្ខុនោះបានប្រាប់ដំណើរនោះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនគួរបើ

---

១ ភិក្ខុអ្នកនៅក្នុងអាវាស ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ អាគន្តុកវត្តបញ្ញត្តិនិទានំ

អាគន្តុកា ភិក្ខូ សឧបាហនាបិ អារាមំ បវិសន្តិ ឆត្តបគ្គហិតាបិ អារាមំ បវិសន្តិ ឱគុណ្ឋិតាបិ អារាមំ បវិសន្តិ សីសេបិ ចីវរំ ករិត្វា អារាមំ បវិសន្តិ បានីយេនបិ បាទេ ធោវន្តិ វុឌ្ឍតរេបិ អាវាសិកេ ភិក្ខូ ន អភិវាទេន្តិ នបិ សេនាសនំ បុច្ឆន្តិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ អាគន្តុកា ភិក្ខូ សឧបាហនាបិ អារាមំ បវិសន្តិ ឆត្តបគ្គហិតាបិ អារាមំ បវិសន្តិ ឱគុណ្ឋិតាបិ អារាមំ បវិសន្តិ សីសេបិ ចីវរំ ករិត្វា អារាមំ បវិសន្តិ បានីយេនបិ បាទេ ធោវន្តិ វុឌ្ឍតរេបិ អាវាសិកេ ភិក្ខូ ន អភិវាទេន្តិ នបិ សេនាសនំ បុច្ឆន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ អាគន្តុកា ភិក្ខូ សឧបាហនាបិ អារាមំ បវិសន្តិ ឆត្តបគ្គហិតាបិ អារាមំ បវិសន្តិ ឱគុណ្ឋិតាបិ អារាមំ បវិសន្តិ សីសេបិ ចីវរំ ករិត្វា អារាមំ បវិសន្តិ បានីយេនបិ បាទេ ធោវន្តិ វុឌ្ឍតរេបិ អាវាសិកេ ភិក្ខូ ន អភិវា-

## វត្តក្ខន្ធកៈ អាគន្តុកបញ្ញត្តិនិទានំ

អាគន្តុកភិក្ខុទាំងឡាយ ពាក់ស្បែកជើងដើរចូលទៅកាន់អារាមខ្លះ ប៉ាំងឆត្រដើរចូលទៅកាន់អារាមខ្លះ ទទូរក្បាលដើរចូលទៅកាន់អារាមខ្លះ ទូលចីវរលើក្បាលដើរចូលទៅកាន់អារាមខ្លះ លាងជើងដោយទឹកសម្រាប់ផឹកខ្លះ មិនថ្វាយបង្គំអាវាសិកភិក្ខុទាំងឡាយដែលចាស់ជាងខ្លួនខ្លះ មិនសួរសេនាសនៈខ្លះសោះ ។ គ្រានោះឯង ភិក្ខុទាំងនោះបានក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ ។ បេ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថាអាគន្តុកភិក្ខុទាំងឡាយពាក់ស្បែកជើងដើរចូលទៅកាន់អារាមខ្លះ ប៉ាំងឆត្រដើរចូលទៅកាន់អារាមខ្លះ ទទូរក្បាលដើរចូលទៅកាន់អារាមខ្លះ ទូលចីវរលើក្បាលដើរចូលទៅកាន់អារាមខ្លះ លាងជើងដោយទឹកសម្រាប់ផឹកខ្លះ មិនថ្វាយបង្គំអាវាសិកភិក្ខុទាំងឡាយដែលចាស់ជាងខ្លួនខ្លះ មិនសួរសេនាសនៈខ្លះ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធមានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ មិនសមបើអាគន្តុកភិក្ខុទាំងឡាយ ហ៊ានពាក់ស្បែកជើង ដើរចូលទៅកាន់អារាមខ្លះ ប៉ាំងឆត្រដើរចូលទៅកាន់អារាមខ្លះ ទទូរក្បាលដើរចូលទៅកាន់អារាមខ្លះ ទូលចីវរលើក្បាលដើរចូលទៅកាន់អារាមខ្លះ លាងជើងដោយទឹកសម្រាប់ផឹកខ្លះ មិនថ្វាយបង្គំអាវាសិកភិក្ខុទាំងឡាយដែលចាស់ជាងខ្លួនខ្លះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទេស្សន្តិ នបិ សេនាសនំ បុច្ឆិស្សន្តិ នេតំ ភិក្ខវេ អប្ប-សន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ អាគន្តុកានំ ភិក្ខូនំ វត្តំ បញ្ញាបេស្សាមិ យថា អាគន្តុកេហិ ភិក្ខូហិ សម្មា[១] វត្តិតព្វំ ។

(៣៩) អាគន្តុកេន ភិក្ខវេ ភិក្ខុនា ឥទានិ អារាមំ បវិសិស្សាមីតិ ឧបាហនា ឱមុញ្ចិត្វា នីចំ កត្វា បប្ផោ-ដេត្វា[២] គហេត្វា ឆត្តំ អបនាមេត្វា សីសំ វិវរិត្វា សីសេ[៣] ចីវរំ ខន្ធេ ករិត្វា សាធុកំ អតរមានេន អារាមោ បវិសិតព្វោ អារាមំ បវិសន្តេន សល្លក្ខេតព្វំ កត្ថ អាវាសិកា ភិក្ខូ បដិក្កមន្តីតិ យត្ថ អាវាសិកា ភិក្ខូ បដិក្កមន្តិ ឧបដ្ឋានសាលាយំ វា មណ្ឌបេ វា រុក្ខមូលេ វា តត្ថ គន្ត្វា ឯកមន្តំ បត្តោ និក្ខិបិតព្វោ ឯ-កមន្តំ ចីវរំ និក្ខិបិតព្វំ បដិរូបំ អាសនំ គហេត្វា និសី-ទិតព្វំ បានីយំ បុច្ឆិតព្វំ បរិភោជនីយំ បុច្ឆិតព្វំ កតមំ បានីយំ កតមំ បរិភោជនីយន្តិ សចេ បានីយេន អត្ថោ

---

១ ឱ· ម· ពោត្ថកេសុ សម្មាតិ បាឋោ សកលេ វត្តក្ខន្ធកេ ន ទិស្សតិ ។ ២ ឱ· បប្ផោដេត្វា ។ ៣ ឱ· ម· ពោត្ថកេសុ សីសេតិ បាឋោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មិនសួររកសេនាសនៈខ្លះ ( ដូច្នោះ ) ហោះ ម្នាលភិក្ខុទាំងឡាយ កិរិយានេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ លុះទ្រង់បន្ទោសហើយ ទើបទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តវត្តដល់អាគន្តុកភិក្ខុទាំងឡាយ តាមទំនងដែលអាគន្តុកភិក្ខុទាំងឡាយត្រូវប្រព្រឹត្តដោយប្រពៃ ។

( ៧៩ ) ម្នាលភិក្ខុទាំងឡាយ អាគន្តុកភិក្ខុគិតថា អាត្មាអញនឹងចូលទៅកាន់អារាមក្នុងកាលឥឡូវនេះ ហើយត្រូវដោះស្បែកជើងធ្វើឲ្យទាប ហើយគោះចេញ កាន់យកទៅ ហើយដម្លោះឆត្រ បើកក្បាល ដាក់ចីវរពីលើក្បាលមកលើ-កវិញ ហើយត្រូវដើរសន្សឹម ៗ ចូលទៅកាន់អារាមដោយស្រួល កាលនឹងដើរចូលទៅកាន់អារាម ត្រូវកំណត់ទុកក្នុងចិត្តថា អាវាសិកភិក្ខុទាំងឡាយប្រជុំគ្នាក្នុងទីណា ( បើ ) អាវាសិកភិក្ខុទាំងឡាយប្រជុំគ្នាក្នុងទីណា ត្រូវទៅក្នុងទីនោះ គឺក្នុងឧបដ្ឋានសាលាក្តី ក្នុងមណ្ឌបក្តី ទៀបគល់ឈើក្តី ហើយទុកដាក់បាត្រក្នុងទីដ៏សមគួរ ទុកដាក់ចីវរក្នុងទីដ៏សមគួរ កាន់យកអាសនៈដ៏សមគួរ ហើយអង្គុយ គប្បីសួររកទឹកសម្រាប់ឆាន់ គប្បីសួររកទឹកសម្រាប់ប្រើប្រាស់ថា ណាទឹកសម្រាប់ឆាន់ ណាទឹកសម្រាប់ប្រើប្រាស់ បើមានសេចក្តីត្រូវការដោយទឹកសម្រាប់ឆាន់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





ហោតិ បានីយំ គហេត្វា បាតព្វំ សចេ បរិភោជនីយេន អត្ថោ ហោតិ បរិភោជនីយំ គហេត្វា បាទា ធោវិតព្វា បាទេ ធោវន្តេន ឯកេន ហត្ថេន ឧទកំ អាសិញ្ចិតព្វំ ឯកេន ហត្ថេន បាទា ធោវិតព្វា យេន ហត្ថេន ឧទកំ អាសិញ្ចិតព្វំ ន តេនេវ ហត្ថេន បាទា ធោវិតព្វា[១] ឧបាហនបុញ្ឆនចោឡកំ បុច្ឆិត្វា ឧបាហនា បុញ្ឆិតព្វា ឧបាហនា បុញ្ឆន្តេន បឋមំ សុក្ខេន ចោឡកេន បុញ្ឆិតព្វា បច្ឆា អល្លេន ឧបាហនបុញ្ឆនចោឡកំ ធោវិត្វា បីឡេត្វា[២] ឯកមន្តំ វិស្សជ្ជេតព្វំ សចេ អាវាសិកោ ភិក្ខុ វុឌ្ឍោ ហោតិ អភិវាទេតព្វោ សចេ នវកោ ហោតិ អភិវាទាបេតព្វោ សេនាសនំ បុច្ឆិតព្វំ កតមំ មេ សេនាសនំ[៣] បាបុណាតីតិ អជ្ឈាវុដ្ឋំ វា អនជ្ឈាវុដ្ឋំ វា បុច្ឆិតព្វំ គោចរោ បុច្ឆិតព្វោ អគោចរោ បុច្ឆិតព្វោ សេក្ខសម្មតានិ កុលានិ បុច្ឆិតព្វានិ វច្ចដ្ឋានំ បុច្ឆិតព្វំ

---

១ ឱ. ម. ន តេនេវ ហត្ថេន ឧទកំ អាសិញ្ចិតព្វំ ។ ន តេនេវ ហត្ថេន បាទា ធោវិតព្វា ។ ២ ឱ. ម. បោត្ថកេសុ បីឡេត្វាតិ បាឋោ ន ទិស្សតិ ។ ៣ ម. កឹ សេនាសនំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



ត្រូវយកទឹកសម្រាប់ឆាន់ ហើយឆាន់ចុះ បើមានសេចក្តីត្រូវការដោយទឹកសម្រាប់ប្រើប្រាស់ ត្រូវយកទឹកសម្រាប់ប្រើប្រាស់លាងជើងចុះ កាលនឹងលាងជើង ត្រូវស្រោចទឹកដោយដៃម្ខាង លាងជើងដោយដៃម្ខាង បើស្រោចទឹកដោយដៃណា មិនត្រូវលាងជើងដោយដៃនោះទេ ត្រូវសួររកកំណាត់សម្ពត់សម្រាប់ជូតស្បែកជើង រួចជូតស្បែកជើងទាំងឡាយចុះ កាលដែលនឹងជូតស្បែកជើង (នោះ) មុនដំបូង ជូតដោយកំណាត់ស្ងួត ខាងក្រោយមក ត្រូវជូតដោយកំណាត់សម្ពត់ទទឹក ត្រូវលាងកំណាត់សម្ពត់សម្រាប់ជូតស្បែកជើង ហើយពូតហាលទុកក្នុងទីដ៏សមគួរ បើអាវាសិកភិក្ខុចាស់វស្សាជាង អាគន្តុកភិក្ខុត្រូវថ្វាយបង្គំ បើខ្ចីវស្សា អាគន្តុកភិក្ខុត្រូវឲ្យថ្វាយបង្គំខ្លួនវិញ អាគន្តុកភិក្ខុត្រូវសួររកសេនាសនៈថា សេនាសនៈដូចម្តេច សម្រាប់ខ្ញុំព្រះករុណា ត្រូវសួរអំពីសេនាសនៈដែលគេនៅ ហើយឬ គ្មានគេនៅទេ ត្រូវសួររកគោចរគ្រាម(១) ត្រូវសួររកអគោចរគ្រាម(២) ត្រូវសួររកសេក្ខសម្មតត្រកូល ត្រូវសួររកទីសម្រាប់បន្ទោបង់វច្ចៈ

---

១ អដ្ឋកថា ថា អាគន្តុកភិក្ខុត្រូវសួររកទីភិក្ខាចារយ៉ាងនេះថា គោចរគ្រាមនោះនៅជិតឬនៅឆ្ងាយ ត្រូវចេញទៅបិណ្ឌបាតអំពីពេលព្រឹក ឬពេលថ្ងៃ ។ ២ អគោចរគ្រាម បានដល់ភូមិ ឬស្រុករបស់ពួកមិច្ឆាទិដ្ឋិ ឬទីដែលគេឈប់ដាក់បិណ្ឌបាតហើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បស្សាវដ្ឋានំ បុច្ឆិតព្វំ ចានីយំ បុច្ឆិតព្វំ បរិភោជនីយំ បុច្ឆិតព្វំ កត្តរទណ្ឌោ បុច្ឆិតព្វោ សង្ឃស្ស កតិកសណ្ឋានំ បុច្ឆិតព្វំ កំ កាលំ បវិសិតព្វំ កំ កាលំ និក្ខមិតព្វន្តិ សចេ វិហារោ អនជ្ឈាវុត្ថោ ហោតិ កវាដំ អាកោដេត្វា មុហុត្តំ អាគមេត្វា ឃដិកំ ឧគ្ឃាដេត្វា កវាដំ បណាមេត្វា ពហិ ឋិតេន និល្លោកេតព្វោ សចេ វិហារោ ឧក្លាបោ ហោតិ មញ្ចោ វា មញ្ចេ អារោបិតោ ហោតិ បីឋេ វា បីឋំ អារោបិតំ ហោតិ សេនាសនំ ឧបរិបុញ្ជីកតំ[១] ហោតិ សចេ ឧស្សហតិ សោធេតព្វោ វិហារំ សោធេន្តេន បឋមំ ភុម្មត្ថរណំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ មញ្ចបដិបាទកា នីហរិត្វា ឯកមន្តំ និក្ខិបិតព្វា ភិសិពិម្ពោហនំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ និសីទនបច្ចត្ថរណំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ មញ្ចោ នីចំ កត្វា សាធុកំ អប្បដិឃំសន្តេន អសង្ឃដ្ដេន្តេន កវាដបិដ្ឋំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វោ បីឋំ នីចំ កត្វា សាធុកំ អប្បដិឃំសន្តេន អសង្ឃដ្ដេន្តេន កវាដបិដ្ឋំ នីហរិត្វា

១ ឧបរិបិសុកិតន្តិបិ បាឋោ ភវតិ ។ ឱ. ម. ឧបរិបុញ្ជកិតំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



ត្រូវស្វែងរកទឹកសម្រាប់បន្ទោបង់បស្សាវៈ ត្រូវស្វែងរកទឹកសម្រាប់ឆាន់ ត្រូវស្វែងរកឈើច្រត់ ត្រូវស្វែងរករបៀបនៃកតិកា គឺសេចក្តីប្តេជ្ញារបស់សង្ឃថា គួរចូលទៅក្នុងពេលណា គួរចេញមកវិញក្នុងពេលណា បើវិហារគ្មានភិក្ខុណានៅទេ អាគន្តុកភិក្ខុត្រូវគោះសន្ទះទ្វារ ហើយរង់ចាំមួយស្របក់ ដកគន្លឹះហើយច្រានសន្ទះទ្វារ ហើយឈរខាងក្រៅពិនិត្យឲ្យគ្រប់សព្វ បើវិហារមានសម្រាមក្តី គេតម្រួតគ្រែលើគ្រែក្តី គេតម្រួតតាំងលើតាំងក្តី គេបានតម្រួតសេនាសនៈគរទុកលើគ្នាក្តី បើអាគន្តុកភិក្ខុអាច (ដើម្បីសំអាតបាន) ត្រូវសំអាតចេញ កាលសំអាតវិហារ មុនដំបូង ត្រូវដញ្ចូនកម្រាលផ្ទាល់ផែនដីទៅទុកដាក់ក្នុងទីដ៏សមគួរ ត្រូវយកទ្រនាប់គ្រែទាំងឡាយទៅទុកដាក់ក្នុងទីដ៏សមគួរ ត្រូវដញ្ចូនយកពូកនឹងខ្នើយទៅទុកដាក់ក្នុងទីដ៏សមគួរ ត្រូវដញ្ចូនយកកម្រាលសម្រាប់អង្គុយទៅទុកដាក់ក្នុងទីដ៏សមគួរ អាគន្តុកភិក្ខុត្រូវលើកគ្រែបន្ទាបកុំឲ្យទង្គិច កុំឲ្យប៉ះនឹងសន្ទះទ្វារ នឹងក្របទ្វារ ហើយដញ្ចូនឲ្យស្រួលយកទៅទុកក្នុងទីដ៏សមគួរ ត្រូវលើកតាំងបន្ទាបកុំឲ្យទង្គិច កុំឲ្យប៉ះនឹងសន្ទះទ្វារនឹងក្របទ្វារ ហើយដញ្ចូនឲ្យស្រួល

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ អាគន្តុកវត្តបញ្ញត្តិ

ឯកមន្តំ និក្ខិបិតព្វំ ខេឡមល្លកោ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វោ អបស្សេនផលកំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ សចេ វិហារេ សន្តានកំ ហោតិ ឧល្លោកា បឋមំ ឱហារេតព្វំ អាលោកសន្ធិកណ្ណភាគា បមជ្ជិតព្វា សចេ គេរុកបរិកម្មកតា ភិត្តិ កណ្ណកិតា ហោតិ ចោឡកំ តេមេត្វា បីឡេត្វា បមជ្ជិតព្វា សចេ កាឡវណ្ណកតា ភូមិ កណ្ណកិតា ហោតិ ចោឡកំ តេមេត្វា បីឡេត្វា បមជ្ជិតព្វា សចេ អកតា ហោតិ ភូមិ ឧទកេន បរិប្ផោសិត្វា(១) សម្មជ្ជិតព្វា មា វិហារោ រជេន ឧហញ្ញីតិ សង្ការំ វិចិនិត្វា ឯកមន្តំ ឆឌ្ឌេតព្វំ ភូមត្ថរណំ ឱតាបេត្វា សោធេត្វា បប្ផោដេត្វា(២) អតិហរិត្វា យថាបញ្ញត្តំ(៣) បញ្ញាបេតព្វំ មញ្ចបដិបាទកា ឱតាបេត្វា បមជ្ជិត្វា អតិហរិត្វា យថាភាគំ(៤) ឋបេតព្វា មញ្ចោ ឱតាបេត្វា សោធេត្វា បប្ផោដេត្វា នីចំ កត្វា សាធុកំ អប្បដិឃំសន្តេន អសង្ឃដ្ដេន្តេន កវាដបិដ្ឋំ អតិហរិត្វា យថាភាគំ

១ ឱ. បរិប្ផោសិត្វា ។ ២ ឱ. បប្ផោដេត្វា ។ ម. បប្ឆោដេត្វា ។ ៣ ឱ. យថាភាគំ ។ ប. យថាឋានេ ។ ៤ ម. យថាឋានេ ។

## វត្តក្ខន្ធកៈ ហេតុនៃការទ្រង់បញ្ញត្តអាគន្តុកវត្ត

យកទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកកន្ថោរសម្រាប់ស្តោះទឹកមាត់ទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកផែនក្តារសម្រាប់ផ្អែកទៅទុកក្នុងទីដ៏សមគួរ បើគ្រឿងស្មុកស្មាញ (មានសំបុកកណ្តូបទឹងសរសៃពីងពាងជាដើម) មាននៅក្នុងវិហារ អាគន្តុកភិក្ខុត្រូវបោសតាំងពីពិតានមកជាមុន ចំណែកជ្រុងសន្ទះបង្អួច ត្រូវជូតសំអាត បើជញ្ជាំងដែលគេលាបដោយរង់ មានសៅហ្មងពណ៌សម្បុរ ត្រូវជ្រលក់កំណាត់សំពត់ពូតហើយសឹមជូត បើផ្ទៃគេធ្វើដោយវត្ថុមានពណ៌ខ្មៅ មានសៅហ្មងពណ៌សម្បុរ ត្រូវជ្រលក់កំណាត់សំពត់ពូតហើយសឹមជូត បើទីផ្ទៃគេមិនបានធ្វើទេ ត្រូវប្រស់ដោយទឹករួចហើយសឹមជូត ដោយគិតថា កុំឲ្យវិហារពយខ្មាំដោយធូលីឡើយ គប្បីប្រមូលសម្រាមយកទៅចោល ក្នុងទីដ៏សមគួរ លុះហាលកម្រាលផ្ទាល់ផែនដីហើយ ត្រូវបោសឲ្យស្អាត គោះឲ្យល្អរួចនាំយកមកក្រាលដូចដើមវិញ លុះហាលទ្រនាប់គ្រែហើយ ត្រូវបោសឲ្យស្អាតនាំយកមកទុកដូចដើមវិញ លុះហាលគ្រែហើយ ត្រូវបោសឲ្យស្អាត គោះឲ្យល្អ លើកបន្ទាបកុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារនិងក្របទ្វារ ហើយនាំឲ្យស្រួល យកទៅទុកដូចដើមវិញ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដកេ ចុល្លវគ្គោ

បញ្ញាបេតព្វោ បីឋំ ឱតាបេត្វា សោធេត្វា បប្ផោដេត្វា នីចំ កត្វា សាធុកំ អប្បដិឃំសន្តេន អសង្ឃដ្ដេន្តេន កវាដបិដ្ឋំ អតិហរិត្វា យថាភាគំ បញ្ញាបេតព្វំ ភិសិពិព្ពោហនំ ឱតាបេត្វា សោធេត្វា បប្ផោដេត្វា អតិហរិត្វា យថាភាគំ បញ្ញាបេតព្វំ និសីទនបច្ចត្ថរណំ ឱតាបេត្វា សោធេត្វា បប្ផោដេត្វា អតិហរិត្វា យថាភាគំ បញ្ញាបេតព្វំ ខេឡមល្លកោ ឱតាបេត្វា បមជ្ជិត្វា អតិហរិត្វា យថាភាគំ ឋបេតព្វោ អបស្សេនផលកំ ឱតាបេត្វា បមជ្ជិត្វា អតិហរិត្វា យថាភាគំ ឋបេតព្វំ បត្តចីវរំ និក្ខិបិតព្វំ បត្តំ និក្ខិបន្តេន ឯកេន ហត្ថេន បត្តំ គហេត្វា ឯកេន ហត្ថេន ហេដ្ឋាមញ្ចំ វា ហេដ្ឋាបីឋំ វា បរាមសិត្វា បត្តោ និក្ខិបិតព្វោ ន ច អនន្តរហិតាយ ភូមិយា បត្តោ និក្ខិបិតព្វោ ចីវរំ និក្ខិបន្តេន ឯកេន ហត្ថេន ចីវរំ គហេត្វា ឯកេន ហត្ថេន ចីវរវំសំ វា ចីវររជ្ជុំ វា បមជ្ជិត្វា បារតោ អន្តំ ឱរតោ ភោគំ កត្វា ចីវរំ និក្ខិបិតព្វំ សចេ បុរត្ថិមា សរជា វាតា វាយន្តិ បុរត្ថិមា វាតបានា ថកេតព្វា សចេ បច្ឆិមា សរជា វាតា វាយន្តិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដក ចុល្លវគ្គ

លុះហាលតាំងហើយ ត្រូវបោសឲ្យស្អាត គោះឲ្យល្អលើកបន្ទាបកុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារនឹងក្របទ្វារ ហើយនាំឲ្យស្រួលយកទៅទុកដូចដែលវិញ លុះហាលពូកខ្នើយហើយ ត្រូវបោសឲ្យស្អាត គោះឲ្យល្អរួចយកទៅរៀបចំទុកដូចដែលវិញ លុះហាលកម្រាលសម្រាប់អង្គុយហើយ ត្រូវបោសឲ្យស្អាតគោះឲ្យល្អយកទៅក្រាលទុកដូចដើមវិញ លុះហាលកន្ទោសសម្រាប់ស្តោះទឹកមាត់ហើយ ត្រូវជូតឲ្យស្អាតរួចយកទៅទុកដូចដែលវិញ លុះហាលផែនក្តារសម្រាប់ផ្អែកហើយ ត្រូវជូតឲ្យស្អាត រួចយកទៅទុកដូចដែលវិញ ត្រូវរៀបចំទុកដាក់បាត្រនិងចីវរ កាលនឹងទុកដាក់បាត្រ ត្រូវកាន់បាត្រដៃម្ខាង ស្ទាបក្រោមគ្រែឬក្រោមតាំងដៃម្ខាង ហើយទុកដាក់បាត្រចុះ តែមិនត្រូវទុកដាក់បាត្រ លើផ្ទៃដែលមិនស្អាតទេ កាលនឹងទុកចីវរ ត្រូវចាប់ចីវរដៃម្ខាង ជូតស្នួរចីវរឬខ្សែស្សៀងដៃម្ខាង ធ្វើជាយខាងនាយឲ្យជាផ្នត់ មកខាងអាយហើយ ទុកចីវរចុះ បើខ្យល់ប្រកបដោយធូលី បក់មកអំពីទិសខាងកើត អាគន្តុកភិក្ខុត្រូវបិទបង្អួចទិសខាងកើត បើខ្យល់ប្រកបដោយធូលី បក់មកអំពីទិសខាងលិច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ អាគន្តុកវត្តប្បញ្ញត្តិ

បច្ឆិមា វាតបានា ថកេតព្វា សចេ ឧត្តរា សរជា វាតា វាយន្តិ ឧត្តរា វាតបានា ថកេតព្វា សចេ ទក្ខិណា សរជា វាតា វាយន្តិ ទក្ខិណា វាតបានា ថកេតព្វា សចេ សីតកាលោ ហោតិ ទិវា វាតបានា វិវរិតព្វា រត្តឹ ថកេតព្វា សចេ ឧណ្ហកាលោ ហោតិ ទិវា វាតបានា ថកេតព្វា រត្តឹ វិវរិតព្វា សចេ បរិវេណំ ឧក្លាបំ ហោតិ បរិវេណំ សម្មជ្ជិតព្វំ សចេ កោដ្ឋកោ ឧក្លាបោ ហោតិ កោដ្ឋកោ សម្មជ្ជិតព្វោ សចេ ឧបដ្ឋានសាលា ឧក្លាបា ហោតិ ឧបដ្ឋានសាលា សម្មជ្ជិតព្វា សចេ អគ្គិសាលា ឧក្លាបា ហោតិ អគ្គិសាលា សម្មជ្ជិតព្វា សចេ វច្ចកុដិ ឧក្លាបា ហោតិ វច្ចកុដិ សម្មជ្ជិតព្វា សចេ បានីយំ ន ហោតិ បានីយំ ឧបដ្ឋាបេតព្វំ សចេ បរិភោជនីយំ ន ហោតិ បរិភោជនីយំ ឧបដ្ឋាបេតព្វំ សចេ អាចមនកុម្ភិយា ឧទកំ ន ហោតិ អាចមនកុម្ភិយា ឧទកំ អាសិញ្ចិតព្វំ ឥទំ ខោ ភិក្ខវេ អាគន្តុកានំ ភិក្ខូនំ វត្តំ យថា អាគន្តុកេហិ ភិក្ខូហិ សម្មា វត្តិតព្វន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ ការទ្រង់បញ្ញត្តអាគន្តុកវត្ត

ត្រូវបិទបង្អួចទិសខាងលិច បើខ្យល់ប្រកបដោយធូលី បក់មកពីទិសខាងជើង ត្រូវបិទបង្អួចទិសខាងជើង បើខ្យល់ប្រកបដោយធូលី បក់មកអំពីទិសខាងត្បូង ត្រូវបិទបង្អួចទិសខាងត្បូង បើរដូវត្រជាក់ ត្រូវបើកបង្អួចក្នុងវេលាថ្ងៃ ត្រូវបិទបង្អួចក្នុងវេលាយប់ បើរដូវក្តៅ ត្រូវបិទបង្អួចក្នុងវេលាថ្ងៃ ត្រូវបើកក្នុងវេលាយប់ បើបរិវេណមានសម្រាម ត្រូវបោសបរិវេណចេញ បើបន្ទប់ទឹកមានសម្រាម ត្រូវបោសបន្ទប់ទឹកចេញ បើឧបដ្ឋានសាលា ( រោងឆាន់ ) មានសម្រាម ត្រូវបោសឧបដ្ឋានសាលាចេញ បើរោងភ្លើងមានសម្រាម ត្រូវបោសរោងភ្លើងចេញ បើបង្គន់មានសម្រាម ត្រូវបោសបង្គន់ចេញ បើទឹកឆាន់មិនមាន ត្រូវដម្កល់ទឹកឆាន់ទុក បើទឹកសម្រាប់ប្រើប្រាស់មិនមាន ត្រូវដម្កល់ទុកនូវទឹកសម្រាប់ប្រើប្រាស់ បើទឹកក្នុងឆ្នាំងសម្រាប់ជម្រះមិនមាន ត្រូវចាក់ទឹកដាក់ទៅក្នុងឆ្នាំងសម្រាប់ជម្រះ ម្នាលភិក្ខុទាំងឡាយ នេះជាវត្តរបស់អាគន្តុកភិក្ខុទាំងឡាយ ដែលអាគន្តុកភិក្ខុទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ ។

(៥០) តេន ខោ បន សមយេន អាវាសិកា ភិក្ខូ អាគន្តុកេ ភិក្ខូ ទិស្វា នេវ អាសនំ បញ្ញាបេន្តិ ន បាទោទកំ បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបន្តិ ន បច្ចុគ្គន្ត្វា បត្តចីវរំ បដិគ្គណ្ហន្តិ ន បានីយេន បុច្ឆន្តិ ន បរិភោជនីយេន បុច្ឆន្តិ(១) វុឌ្ឍតរេបិ អាគន្តុកេ ភិក្ខូ ន អភិវាទេន្តិ ន សេនាសនំ បញ្ញាបេន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាវាសិកា ភិក្ខូ អាគន្តុកេ ភិក្ខូ ទិស្វា នេវ អាសនំ បញ្ញាបេស្សន្តិ ន បាទោទកំ បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបិស្សន្តិ ន បច្ចុគ្គន្ត្វា បត្តចីវរំ បដិគ្គហេស្សន្តិ ន បានីយេន បុច្ឆិស្សន្តិ ន បរិភោជនីយេន បុច្ឆិស្សន្តិ វុឌ្ឍតរេបិ អាគន្តុកេ ភិក្ខូ ន អភិវាទេស្សន្តិ ន សេនាសនំ បញ្ញាបេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ។ បេ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ

១ ឱ. ប. បោត្ថកេសុ ន បរិភោជនីយេន បុច្ឆន្តិ បាឋោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៨០) សម័យនោះឯង ពួកអាវាសិកភិក្ខុ ឃើញអាគន្តុកភិក្ខុទាំងឡាយហើយ មិននាំគ្នាក្រាលអាសនៈ មិនបានដម្កល់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រាប់ជើងដែលលាងហើយ ទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់លាង មិនក្រោកទៅទទួលបាត្រនឹងចីវរ មិនសួរទឹកសម្រាប់ផឹក មិនសួរទឹកសម្រាប់ប្រើប្រាស់ មិនថ្វាយបង្គំពួកអាគន្តុកភិក្ខុ ដែលចាស់ជាងខ្លួន មិនរៀបចំសេនាសនៈ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនគួរបើពួកអាវាសិកភិក្ខុ ឃើញអាគន្តុកភិក្ខុទាំងឡាយហើយ មិននាំគ្នាក្រាលអាសនៈទទួល មិនដម្កល់ទឹកលាងជើង តាំងសម្រាប់ទ្រាប់ជើងដែលលាងហើយ ទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់បានលាង មិនក្រោកទៅទទួលបាត្រនឹងចីវរ មិនសួរទឹកសម្រាប់ផឹក មិនសួរទឹកសម្រាប់ប្រើប្រាស់ មិនថ្វាយបង្គំពួកអាគន្តុកភិក្ខុ ដែលចាស់ជាងខ្លួនមិនរៀបចំសេនាសនៈសោះ ។ លំដាប់នោះ ភិក្ខុទាំងនោះក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាដំណើរនោះពិតមែនឬ ។ បេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ បេ ។ លុះទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ អាវាសិកវត្តំ

អាវាសិកានំ ភិក្ខូនំ វត្តំ បញ្ញបេស្សាមិ យថា អាវាសិកេហិ ភិក្ខូហិ សម្មា វត្តិតព្វំ ។

[៨១] អាវាសិកេន ភិក្ខវេ ភិក្ខុនា អាគន្តុកំ ភិក្ខុំ វុឌ្ឍតរំ ទិស្វា អាសនំ បញ្ញបេតព្វំ បាទោទកំ បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបិតព្វំ បច្ចុគ្គន្ត្វា បត្តចីវរំ បដិគ្គហេតព្វំ បានីយេន បុច្ឆិតព្វោ បរិភោជនីយេន បុច្ឆិតព្វោ[១] សចេ ឧស្សហតិ ឧបាហនា បុញ្ឆិតព្វា ឧបាហនា បុញ្ឆន្តេន បឋមំ សុក្ខេន ចោឡកេន បុញ្ឆិតព្វា បច្ឆា អល្លេន ឧបាហនបុញ្ឆនចោឡកំ ធោវិត្វា ឯកមន្តំ វិស្សជ្ជេតព្វំ អាគន្តុកោ វុឌ្ឍោ[២] ភិក្ខុ អភិវាទេតព្វោ សេនាសនំ បញ្ញបេតព្វំ ឯតំ តុម្ហាកំ សេនាសនំ អជ្ឈាវុត្ថំ វា អនជ្ឈាវុត្ថំ វា អាចិក្ខិតព្វំ គោចរោ អាចិក្ខិតព្វោ អគោចរោ អាចិក្ខិតព្វោ សេក្ខសម្មតានិ កុលានិ អាចិក្ខិតព្វានិ វច្ចដ្ឋានំ អាចិក្ខិតព្វំ

---

១ ឱ. ម. ពោត្ថកេសុ បរិភោជនីយេន បុច្ឆិតព្វោតិ ន ទិស្សតិ ។ ២ ឱ. ពោត្ថកេ វុឌ្ឍតរោតិ បាឋោ ន ទិស្សតិ ។ ម. អាគន្តុកោ ភិក្ខុ វុឌ្ឍតរោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ អាវាសិកវត្ត

បើដូច្នោះ តថាគតនឹងបញ្ញត្តវត្តដល់អាវាសិកភិក្ខុទាំងឡាយ តាមទំនងដែលអាវាសិកភិក្ខុទាំងឡាយត្រូវប្រព្រឹត្តដោយប្រពៃ ។

(៨១) ម្នាលភិក្ខុទាំងឡាយ អាវាសិកភិក្ខុ ឃើញអាគន្តុកភិក្ខុដែលចាស់ជាងខ្លួនហើយ ត្រូវក្រាលអាសនៈ ត្រូវដម្កល់ទុកនូវទឹកលាងជើង តាំងសម្រាប់ទ្រាប់ជើងដែលលាងហើយ ទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់បានលាង ត្រូវក្រោកទៅទទួលយកបាត្រនឹងចីវរ ត្រូវសួរទឹកសម្រាប់ផឹក ត្រូវសួរទឹកសម្រាប់ប្រើប្រាស់ បើអាវាសិកភិក្ខុមានសេចក្តីឧស្សាហ៍ ត្រូវជូតស្បែកជើង កាលនឹងជូតស្បែកជើងមុនដំបូង ត្រូវជូតដោយសំពត់ស្ងួត បន្ទាប់មក ត្រូវជូតដោយសម្ពត់ទទឹក ត្រូវលាងកំណាត់សម្ពត់សម្រាប់ជូតស្បែកជើង ហើយពូតហាលទុកក្នុងទីដ៏សមគួរ (បើ) អាគន្តុកភិក្ខុចាស់វស្សាជាង អាវាសិកភិក្ខុត្រូវថ្វាយបង្គំ ត្រូវរៀបចំសេនាសនៈដោយពាក្យថា សេនាសនៈនេះសម្រាប់លោកម្ចាស់ ត្រូវប្រាប់សេនាសនៈដែលមានគេនៅក្តី ឥតមានគេនៅក្តី ត្រូវប្រាប់គោចរគ្រាម ត្រូវប្រាប់អគោចរគ្រាម ត្រូវប្រាប់ត្រកូលទាំងឡាយដែលសង្ឃសន្មតថាជាសេក្ខៈ ត្រូវប្រាប់ទីសម្រាប់បន្ទោបង់វច្ចៈ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



បស្សាវដ្ឋានំ អាចិក្ខិតព្វំ បានីយំ អាចិក្ខិតព្វំ បរិភោជនីយំ អាចិក្ខិតព្វំ កត្តរទណ្ឌោ អាចិក្ខិតព្វោ សង្ឃស្ស កតិកសណ្ឋានំ អាចិក្ខិតព្វំ កំ កាលំ បវិសិតព្វំ កំ កាលំ និក្ខមិតព្វន្តិ សចេ នវកោ ហោតិ និសិន្នកេនេវ អាចិក្ខិតព្វំ អត្រ បត្តំ និក្ខិបាហិ អត្រ ចីវរំ និក្ខិបាហិ ឥទំ អាសនំ និសីទាហីតិ បានីយំ អាចិក្ខិតព្វំ បរិភោជនីយំ អាចិក្ខិតព្វំ ឧបាហនបុញ្ឆនចោឡកំ អាចិក្ខិតព្វំ អាគន្តុកោ នវកោ(១) ភិក្ខុ អភិវាទាបេតព្វោ សេនាសនំ អាចិក្ខិតព្វំ ឯតន្តេ សេនាសនំ បាបុណាតីតិ អជ្ឈាវុត្ថំ វា អនជ្ឈាវុត្ថំ វា អាចិក្ខិតព្វំ គោចរោ អាចិក្ខិតព្វោ អគោចរោ អាចិក្ខិតព្វោ សេក្ខសម្មតានិ កុលានិ អាចិក្ខិតព្វានិ វច្ចដ្ឋានំ អាចិក្ខិតព្វំ បស្សាវដ្ឋានំ អាចិក្ខិតព្វំ បានីយំ អាចិក្ខិតព្វំ បរិភោជនីយំ អាចិក្ខិតព្វំ កត្តរទណ្ឌោ អាចិក្ខិតព្វោ សង្ឃស្ស កតិកសណ្ឋានំ អាចិក្ខិតព្វំ កំ កាលំ បវិសិតព្វំ កំ កាលំ និក្ខមិតព្វន្តិ

---

ឱ. ម. ពោត្ថកេសុ នវកោតិ បាឋោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ត្រូវប្រាប់ទីសម្រាប់បន្ទោបង់បស្សាវៈ ត្រូវប្រាប់ទឹកសម្រាប់ឆាន់ ត្រូវប្រាប់ទឹកសម្រាប់ប្រើប្រាស់ ត្រូវប្រាប់ឈើច្រត់ ត្រូវប្រាប់របៀបកតិការបស់សង្ឃថា លោកម្ចាស់ត្រូវចូលមកក្នុងពេលនេះ ត្រូវចេញទៅក្នុងពេលនេះ បើអាគន្តុកភិក្ខុខ្ចីវស្សាជាង អាវាសិកភិក្ខុត្រូវអង្គុយប្រាប់វិញថា ចូរលោកទុកបាត្រត្រង់ទីនេះ ចូរទុកចីវរត្រង់នេះចុះ ចូរអង្គុយលើអាសនៈនេះចុះ អាវាសិកភិក្ខុត្រូវប្រាប់ទឹកសម្រាប់ឆាន់ ត្រូវប្រាប់ទឹកសម្រាប់ប្រើប្រាស់ ត្រូវប្រាប់សម្ពត់សម្រាប់ជូតស្បែកជើង បើអាគន្តុកភិក្ខុខ្ចីវស្សាជាង អាវាសិកភិក្ខុត្រូវបង្គាប់ឲ្យថ្វាយបង្គំខ្លួន ត្រូវប្រាប់សេនាសនៈថា សេនាសនៈ + នុះសម្រាប់លោក ត្រូវប្រាប់សេនាសនៈដែលមានគេនៅក្តី ឥតមានគេនៅក្តី ត្រូវប្រាប់គោចរគ្រាម ត្រូវប្រាប់អគោចរគ្រាម ត្រូវប្រាប់ត្រកូលទាំងឡាយ ដែលសង្ឃសន្មតថាជាសេក្ខៈ ត្រូវប្រាប់ទីសម្រាប់បន្ទោបង់វច្ចៈ ត្រូវប្រាប់ទីសម្រាប់បន្ទោបង់បស្សាវៈ ត្រូវប្រាប់ទឹកសម្រាប់ឆាន់ ត្រូវប្រាប់ទឹកសម្រាប់ប្រើប្រាស់ ត្រូវប្រាប់ឈើច្រត់ ត្រូវប្រាប់របៀបកតិការបស់សង្ឃថា លោកត្រូវចូលមកក្នុងពេលនេះ ត្រូវចេញទៅវិញក្នុងពេលនេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឥទំ ខោ ភិក្ខវេ អាវាសិកានំ ភិក្ខូនំ វត្តំ យថា អាវាសិកេហិ ភិក្ខូហិ សម្មា វត្តិតព្វន្តិ ។

[៨២] តេន ខោ បន សមយេន គមិកា ភិក្ខូ ទារុភណ្ឌំ មត្តិកាភណ្ឌំ អប្បដិសាមេត្វា ទ្វារវាតបានំ វិវរិត្វា សេនាសនំ អនាបុច្ឆា បក្កមន្តិ ។ ទារុភណ្ឌំ មត្តិកាភណ្ឌំ នស្សតិ ។ សេនាសនំ អគុត្តំ ភវតិ(១) ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំហិ នាម គមិកា ភិក្ខូ ទារុភណ្ឌំ មត្តិកាភណ្ឌំ អប្បដិសាមេត្វា ទ្វារវាតបានំ វិវរិត្វា សេនាសនំ អនាបុច្ឆា បក្កមិស្សន្តិ ទារុភណ្ឌំ មត្តិកាភណ្ឌំ នស្សតិ សេនាសនំ អគុត្តំ ភវតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ។ បេ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ គមិកានំ ភិក្ខូនំ វត្តំ បញ្ញាបេស្សាមិ យថា គមិកេហិ ភិក្ខូហិ សម្មា វត្តិតព្វំ ។

១ ឱ. ម. ហោតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ គមិកវត្តំ

ម្នាលភិក្ខុទាំងឡាយ នេះហើយជាវត្តរបស់អាវាសិកភិក្ខុទាំងឡាយ តាមបែបបទដែលអាវាសិកភិក្ខុទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ ។

[៨២] សម័យនោះឯង ពួកគមិកភិក្ខុ (ភិក្ខុអ្នកដំណើរ) មិនរៀបចំទុកដាក់គ្រឿងឈើ(១) នឹងគ្រឿងដី(២) បើកទ្វារនឹងបង្អួចចោល មិនអើពើនឹងសេនាសនៈ ហើយចៀសចេញទៅ ។ គ្រឿងឈើ គ្រឿងដី ក៏វិនាសអស់ទៅ ។ ឯសេនាសនៈ ក៏រកអ្នកណាគ្រប់គ្រងគ្មាន ។ ភិក្ខុទាំងឡាយណា ដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនគួរបើពួកគមិកភិក្ខុមិនរៀបចំទុកដាក់គ្រឿងឈើ គ្រឿងដី បើកទ្វារនឹងបង្អួចចោល មិនអើពើនឹងសេនាសនៈ ហើយចៀសចេញទៅសោះ ឯគ្រឿងឈើ គ្រឿងដីក៏វិនាសអស់ទៅ សេនាសនៈក៏រកអ្នកណាគ្រប់គ្រងគ្មាន ។ លំដាប់នោះ ភិក្ខុទាំងនោះ បានក្រាបបង្គំទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា រឿងនោះពិតមែនឬ ។ បេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ បេ ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះតថាគតនឹងបញ្ញត្តវត្តដល់ពួកគមិកភិក្ខុ តាមបែបបទដែលពួកគមិកភិក្ខុត្រូវប្រព្រឹត្តដោយប្រពៃ ។

---

១ អដ្ឋកថា ថាគ្រឿងឈើបានដល់គ្រែនិងតាំងជាដើម ។ ២ គ្រឿងដីបានដល់ភាជន៍សម្រាប់ជ្រលក់ជាដើម ។ ចូរមើលសេចក្តីពិស្តារក្នុងសេនាសនក្ខន្ធកៈ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊្កិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(៨៣) គមិកេន ភិក្ខវេ ភិក្ខុនា ទារុភណ្ឌំ មត្តិកាភណ្ឌំ បដិសាមេត្វា ទ្វារវាតបានំ ថកេត្វា សេនាសនំ អាបុច្ឆិតព្វំ(១) សចេ ភិក្ខុ ន ហោតិ សាមណេរោ អាបុច្ឆិតព្វោ សចេ សាមណេរោ ន ហោតិ អារាមិកោ អាបុច្ឆិតព្វោ សចេ អារាមិកោ ន ហោតិ ឧបាសកោ អាបុច្ឆិតព្វោ សចេ ន ហោតិ ភិក្ខុ វា សាមណេរោ វា អារាមិកោ វា ឧបាសកោ វា(២) ចតូសុ បាសាណកេសុ មញ្ចំ បញ្ញាបេត្វា មញ្ចេ មញ្ចំ អារោបេត្វា បីឋេ បីឋំ អារោបេត្វា សេនាសនំ ឧបរិ បុញ្ជំ ករិត្វា ទារុភណ្ឌំ មត្តិកាភណ្ឌំ បដិសាមេត្វា ទ្វារវាតបានំ ថកេត្វា បក្កមិតព្វំ សចេ វិហារោ ឱវស្សតិ សចេ ឧស្សហតិ ឆាទេតព្វោ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ វិហារោ ឆាទិយេថាតិ ឯវញ្ចេ តំ លភេថ ឥច្ចេតំ កុសលំ នោ ចេ លភេថ យោ ទេសោ អនោវស្សកោ ហោតិ តត្ថ ចតូសុ បាសាណកេសុ មញ្ចំ បញ្ញាបេត្វា មញ្ចេ មញ្ចំ អារោបេត្វា បីឋេ បីឋំ អារោបេត្វា សេនាសនំ ឧបរិ បុញ្ជំ ករិត្វា ទារុភណ្ឌំ មត្តិកាភណ្ឌំ បដិសាមេត្វា

១ ឧ· ម· អាបុច្ឆា បក្កមិតព្វំ ។ ២ ឧ· ម· ឃោត្តកេសុ សចេ សាមណេរោ ន ហោតិ អារាមិកោ អាបុច្ឆិតព្វោ សចេ ន ហោតិ ភិក្ខុ វា សាមណេរោ វា អារាមិកោ វាតិ វចនំ អាគតំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៨៣) ម្នាលភិក្ខុទាំងឡាយ គមិកភិក្ខុ ត្រូវរៀបចំទុកដាក់គ្រឿងឈើ និងគ្រឿងដី ហើយបិទទ្វារនិងបង្អួច អើពើនឹងសេនាសនៈ[1] បើមិនមានភិក្ខុទេ ត្រូវលាសាមណេរ បើមិនមានសាមណេរ ត្រូវលាអារាមិកជន បើមិនមានអារាមិកជន ត្រូវលាឧបាសក បើភិក្ខុក្តីសាមណេរក្តី អារាមិកជនក្តី ឧបាសកក្តី មិនមានទេ ត្រូវរៀបចំគ្រែលើថ្មតូច ៤ ដុំហើយតម្រួតគ្រែលើគ្រែ តម្រួតតាំងលើតាំង ធ្វើសេនាសនៈឲ្យគរលើគ្នា ហើយរៀបចំទុកដាក់គ្រឿងឈើ និងគ្រឿងដី ហើយបិទទ្វារនិងបង្អួចរួចដើរចេញទៅចុះ ប្រសិនបើវិហារលេច បើគមិកភិក្ខុអាច (ប្រក់បាន) ក៏គប្បីប្រក់ ម្យ៉ាងទៀតគប្បីធ្វើសេចក្តីខ្វល់ខ្វាយថា អាត្មាអញប្រក់វិហារដោយឧបាយដូចម្តេចហ្ន៎ បើគមិកភិក្ខុបានធ្វើសេចក្តីខ្វល់ខ្វាយយ៉ាងនេះ ការបានដូច្នេះនេះ ក៏ជាការគាប់ប្រពៃ បើមិនបានទេ ទីណាជាទីមិនលេច គមិកភិក្ខុត្រូវរៀបចំគ្រែលើថ្មតូច ៤ ដុំ ក្នុងប្រទេសនោះហើយតម្រួតគ្រែលើគ្រែ តម្រួតតាំងលើតាំងហើយធ្វើសេនាសនៈឲ្យគរលើគ្នា រៀបទុកដាក់គ្រឿងឈើនិងគ្រឿងដី

---

១ សេនាសនៈ ដែលគេទេរលើខ្នងថ្មក្តី លើសសរថ្មក្តី ដែលពួកសត្វកណ្តៀរឡើងទៅបៀតបៀនមិនបាន ទុកជាភិក្ខុមិនអើពើ ក៏មិនត្រូវអាបត្តិឡើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ គមិកវត្តំ ភត្តគ្គេ អនុមោទនា

ទ្វារវាតបានំ ថកេត្វា បក្កមិតព្វំ សចេ សព្វោ វិហារោ ឱវស្សតិ សចេ ឧស្សហតិ សេនាសនំ គាមំ អតិហរិតព្វំ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ សេនាសនំ គាមំ អតិហរិយេថាតិ ឯវញ្ចេតំ លភេថ ឥច្ចេតំ កុសលំ នោ ចេ លភេថ អជ្ឈោកាសេ ចតូសុ បាសាណកេសុ មញ្ចំ បញ្ញបេត្វា មញ្ចេ មញ្ចំ អារោបេត្វា បីឋេ បីឋំ អារោបេត្វា សេនាសនំ ឧបរិ បុញ្ជំ ករិត្វា ទារុភណ្ឌំ មត្តិកាភណ្ឌំ បដិសាមេត្វា តិណេន វា បណ្ណេន វា បដិច្ឆាទេត្វា បក្កមិតព្វំ អប្បេវ នាម អង្គានិបិ សេសេយ្យុន្តិ ឥទំ ខោ ភិក្ខវេ គមិកានំ ភិក្ខូនំ វត្តំ យថា គមិកេហិ ភិក្ខូហិ សម្មា វត្តិតព្វន្តិ ។

(៨៤) តេន ខោ បន សមយេន ភិក្ខូ ភត្តគ្គេ ន អនុមោទន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ភត្តគ្គេ ន អនុមោទិស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។

## វត្តក្ខន្ធកៈ គមិកវត្តនឹងការអនុមោទនាក្នុងរោងភត្ត

បិទទ្វារនឹងបង្អួច រួចដើរចេញទៅចុះ ប្រសិនបើវិហារលេចគ្មានសល់ បើគមិកភិក្ខុអាច (នាំយកទៅបាន) ត្រូវនាំយកសេនាសនៈទៅកាន់ស្រុក ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា អាត្មាអញនឹងនាំយកសេនាសនៈទៅកាន់ស្រុកដោយឧបាយដូចម្តេចហ្ន៎ បើគមិកភិក្ខុ បានធ្វើសេចក្តីខ្វល់ខ្វាយយ៉ាងនេះ ការបានដូច្នេះនេះជាការល្អ បើមិនបានទេ គមិកភិក្ខុត្រូវរៀបចំគ្រែលើថ្មតូច ៤ ដុំក្នុងទីវាលហើយតម្រួតគ្រែលើគ្រែ តម្រួតតាំងលើតាំង ធ្វើសេនាសនៈឲ្យគរលើគ្នា ហើយរៀបចំទុកដាក់គ្រឿងឈើ នឹងគ្រឿងដី បិទបាំងដោយស្មៅឬដោយស្លឹកឈើរួចសឹមដើរចេញទៅ ដោយធ្វើទុកក្នុងចិត្តថា ធ្វើដូចម្តេចនឹងឲ្យអវយវៈ(របស់គ្រែនឹងតាំង)ទាំងឡាយសល់នៅបាន ម្នាលភិក្ខុទាំងឡាយ នេះហើយជាវត្តរបស់ពួកគមិកភិក្ខុ តាមបែបបទដែលពួកគមិកភិក្ខុ ត្រូវប្រព្រឹត្តដោយប្រពៃ ។

[៨៤] សម័យនោះឯង ភិក្ខុទាំងឡាយមិនអនុមោទនាក្នុងរោងភត្ត ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្តិយ៍ មិនគួរបើមិនអនុមោទនាក្នុងរោងភត្តសោះ ។ កាលដែលមនុស្សទាំងឡាយកំពុងពោលទោស តិះដៀលបន្តុះបង្អាប់ ពួកភិក្ខុក៏បានឮ ។ លំដាប់នោះ ភិក្ខុទាំងនោះក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ភត្តគ្គេ អនុមោទិតុន្តិ ។

[៨៥] អថខោ ភិក្ខូនំ(១) ឯតទហោសិ កេន នុ ខោ ភត្តគ្គេ អនុមោទិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ថេរេន ភិក្ខុនា ភត្តគ្គេ អនុមោទិតុន្តិ ។

[៨៦] តេន ខោ បន សមយេន អញ្ញតរស្ស បូគស្ស សង្ឃភត្តំ ហោតិ ។ អាយស្មា សារីបុត្តោ សង្ឃត្ថេរោ ហោតិ ។ ភិក្ខូ ភគវតា អនុញ្ញាតំ ថេរេន ភិក្ខុនា ភត្តគ្គេ អនុមោទិតុន្តិ អាយស្មន្តំ សារីបុត្តំ ឯកកំ ឱហាយ បក្កមឹសុ ។ អថខោ អាយស្មា សារីបុត្តោ តេ មនុស្សេ បដិសម្មោទិត្វា បច្ឆា ឯកកោ អគមាសិ ។ អទ្ទសា ខោ ភគវា អាយស្មន្តំ សារីបុត្តំ ទូរតោ វ ឯកកំ(២) អាគច្ឆន្តំ ទិស្វាន អាយស្មន្តំ សារីបុត្តំ ឯតទវោច

---

១ ម. តេសំ ភិក្ខូនំ ។ ២ ឱ. ម. បោត្ថកេសុ ឯកកន្តិ វចនំ នត្ថិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុធ្វើអនុមោទនាក្នុងរោងភត្ត ។

[៨៥] លំដាប់នោះ ពួកភិក្ខុមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុដូចម្តេចហ្ន៎ ដែលគួរអនុមោទនាក្នុងរោងភត្តបាន ។ ភិក្ខុទាំងនោះបានក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈអនុមោទនាក្នុងរោងភត្ត ។

[៨៦] សម័យនោះឯង មានសង្ឃភត្តរបស់គណៈជនមួយពួក ។ ព្រះសារីបុត្តដ៏មានអាយុជាសង្ឃត្ថេរ ។ ភិក្ខុទាំងឡាយគិតគ្នាថា ព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុជាថេរៈអនុមោទនាក្នុងរោងភត្ត ហើយក៏ដើរចៀសចេញទៅចោលព្រះសារីបុត្តដ៏មានអាយុ ឲ្យគង់នៅតែមួយអង្គ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ(និយាយ)សំណេះសំណាលនឹងមនុស្សទាំងនោះហើយ ក៏បាននិមន្តទៅតែមួយអង្គ ក្នុងកាលជាខាងក្រោយ ។ ព្រះមានព្រះភាគទ្រង់បានទតទៅឃើញព្រះសារីបុត្តដ៏មានអាយុ កំពុងតែដើរមកតែមួយអង្គអំពីចម្ងាយ លុះទ្រង់ទតឃើញហើយក៏ត្រាស់សួរសេចក្តីនុ៎ះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ ភត្តគ្គវត្តំ

កច្ចិ សារីបុត្ត ភត្តំ ឥទ្ធំ អហោសីតិ ។ ឥទ្ធំ ខោ ភន្តេ ភត្តំ អហោសិ អបិច មំ ភិក្ខូ ឯកាកំ ឱហាយ បក្កន្តាតិ ។ អថខោ ភគវា ឯតស្មិំ និទានេ ឯតស្មិំ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ភត្តគ្គេ ចតូហិ បញ្ចហិ ថេរានុថេរេហិ ភិក្ខូហិ អាគមេតុន្តិ ។

(៨៧) តេន ខោ បន សមយេន អញ្ញតរោ ថេរោ ភត្តគ្គេ វច្ចិតោ អាគមេតិ[១] ។ សោ វច្ចំ សន្ធារេន្តោ[២] មុច្ឆិតោ បបតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សតិ ករណីយេ អនន្តរិកំ ភិក្ខុំ អាបុច្ឆិត្វា គន្តុន្តិ ។

(៨៨) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ទុន្និវត្ថា ទុប្បារុតា អនាកប្បសម្បន្នា ភត្តគ្គំ គច្ឆន្តិ វោក្កម្មបិ ថេរានំ ភិក្ខូនំ បុរតោ បុរតោ គច្ឆន្តិ ថេរេបិ ភិក្ខូ អនុបខជ្ជ និសីទន្តិ នវេបិ ភិក្ខូ អាសនេន បដិពាហន្តិ សង្ឃាដិម្បិ ឱត្ថរិត្វា អន្តរឃរេ និសីទន្តិ ។

---

១ ឱ. ប. អាគមេសិ ។ ២ ប. សន្ធារេតុំ អសក្កោន្តោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ វត្តដែលភិក្ខុត្រូវធ្វើក្នុងរោងភត្ត

នឹងព្រះសារីបុត្តដ៏មានអាយុថា ម្នាលសារីបុត្ត ចុះភត្តមានបរិបូណ៌ទេឬ ។ ព្រះសារីបុត្តដ៏មានអាយុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ភត្តមានបរិបូណ៌ទេ ប៉ុន្តែភិក្ខុទាំងឡាយ ដើរពាលខ្ញុំព្រះអង្គឲ្យនៅតែម្នាក់ឯង ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតភិក្ខុទាំងឡាយជាថេរៈនឹងអនុត្ថេរៈបួនប្រាំរូបរង់ចាំក្នុងរោងភត្ត ។

(៨៧) សម័យនោះ មានព្រះថេរៈមួយរូប ឈឺបន្ទោបង់ឧច្ចារៈហើយរង់ចាំក្នុងរោងភត្ត កាលបើព្រះថេរៈនោះខំអត់ទ្រាំឧច្ចារៈ លោកក៏ជ្រប់ដួលទៅ ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើមានកិច្ចគួរធ្វើ តថាគតអនុញ្ញាតឲ្យលាភិក្ខុ ដែលអង្គុយនៅលើអាសនៈ ជាលំដាប់ហើយទៅបាន ។

(៨៨) សម័យនោះ ពួកឆព្វគ្គិយភិក្ខុស្លៀកមិនល្អ ដណ្តប់មិនល្អ ប្រកបដោយមារយាទមិនសមគួរ ដើរទៅកាន់រោងភត្ត ដែរទៅខាងមុខ ៗ នៃពួកភិក្ខុជាថេរៈខ្លះ ចូលទៅអង្គុយជ្រៀតបៀតពួកភិក្ខុជាថេរៈខ្លះ ឃាត់ពួកភិក្ខុខ្ចីដោយអាសនៈខ្លះ អង្គុយសង្កត់សង្ឃាដិក្នុងចន្លោះផ្ទះខ្លះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ទុន្និវត្ថា ទុប្បារុតា អនាកប្បសម្បន្នា ភត្តគ្គំ គច្ឆិស្សន្តិ វោក្កម្មបិ ថេរានំ ភិក្ខូនំ បុរតោ បុរតោ គច្ឆិស្សន្តិ ថេរេបិ ភិក្ខូ អនុបខជ្ជ និសីទិស្សន្តិ នវេបិ ភិក្ខូ អាសនេន បដិពាហិស្សន្តិ សង្ឃាដិម្បិ ឱត្ថរិត្វា អន្តរឃរេ និសីទិស្សន្តីតិ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខូ ទុន្និវត្ថា ទុប្បារុតា អនាកប្បសម្បន្នា ភត្តគ្គំ គច្ឆន្តិ វោក្កម្មបិ ថេរានំ ភិក្ខូនំ បុរតោ បុរតោ គច្ឆន្តិ ថេរេបិ ភិក្ខូ អនុបខជ្ជ និសីទន្តិ នវេបិ ភិក្ខូ អាសនេន បដិពាហន្តិ សង្ឃាដិម្បិ ឱត្ថរិត្វា អន្តរឃរេ និសីទន្តីតិ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ ភិក្ខូនំ ភត្តគ្គវត្តំ បញ្ញាបេស្សាមិ យថា ភិក្ខូហិ ភត្តគ្គេ សម្មា វត្តិតព្វំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដក ចុល្លវគ្គ

ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរបើស្លៀកមិនល្អ ដណ្តប់មិនល្អ ប្រកបដោយមារយាទមិនសមគួរ ដើរទៅកាន់រោងភត្តសោះ ឆព្វគ្គិយភិក្ខុទាំងនោះដើរដែងទៅខាងមុខ ៗ នៃពួកភិក្ខុជាថេរៈខ្លះ ចូលទៅអង្គុយប្រៀតប្រៀតភិក្ខុជាថេរៈខ្លះ ឃាត់ពួកភិក្ខុថ្មីដោយអាសនៈខ្លះ អង្គុយសង្កត់សង្ឃាដីក្នុងចន្លោះផ្ទះខ្លះ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបបង្គំទូលដំណើរនុះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកឆព្វគ្គិយភិក្ខុស្លៀកមិនល្អ ដណ្តប់មិនល្អ ប្រកបដោយមារយាទមិនសមគួរ ដើរទៅកាន់រោងភត្ត ដើរដែងទៅខាងមុខ ៗ នៃពួកភិក្ខុជាថេរៈខ្លះ អង្គុយប្រៀតប្រៀតភិក្ខុជាថេរៈខ្លះ ឃាត់ពួកភិក្ខុថ្មីដោយអាសនៈខ្លះ អង្គុយសង្កត់សង្ឃាដី ក្នុងចន្លោះផ្ទះពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គ ពិតមែន ។ បេ ។ ព្រះមានព្រះភាគទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តវត្តក្នុងរោងភត្តដល់ភិក្ខុទាំងឡាយ តាមទំនងដែលភិក្ខុទាំងឡាយគប្បីប្រព្រឹត្តដោយប្រពៃក្នុងរោងភត្ត ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ ភត្តគ្គវត្តំ

[៨៩] សចេ អារាមេ កាលោ អារោចិតោ ហោតិ តិមណ្ឌលំ បដិច្ឆាទេន្តេន បរិមណ្ឌលំ និវាសេត្វា កាយពន្ធនំ ពន្ធិត្វា សគុណំ កត្វា សង្ឃាដិយោ បារុបិត្វា គណ្ឋិកំ បដិមុញ្ចិត្វា ធោវិត្វា បត្តំ គហេត្វា សាធុកំ អតរមានេន គាមោ បវិសិតព្វោ ន វោក្កម្ម ថេរានំ ភិក្ខូនំ បុរតោ បុរតោ គន្តព្វំ សុប្បដិច្ឆន្នេន អន្តរឃរេ គន្តព្វំ សុសំវុតេន អន្តរឃរេ គន្តព្វំ ឱក្ខិត្តចក្ខុនា អន្តរឃរេ គន្តព្វំ ន ឧក្ខិត្តកាយ អន្តរឃរេ គន្តព្វំ ន ឧជ្ជគ្ឃិកាយ អន្តរឃរេ គន្តព្វំ អប្បសទ្ទេន អន្តរឃរេ គន្តព្វំ ន កាយប្បចាលកំ អន្តរឃរេ គន្តព្វំ ន ពាហុប្បចាលកំ អន្តរឃរេ គន្តព្វំ ន សីសប្បចាលកំ អន្តរឃរេ គន្តព្វំ ន ខម្ភកតេន អន្តរឃរេ គន្តព្វំ ន ឱគុណ្ឋិតេន អន្តរឃរេ គន្តព្វំ ន ឧក្កុដិកាយ អន្តរឃរេ គន្តព្វំ សុប្បដិច្ឆន្នេន អន្តរឃរេ និសីទិតព្វំ សុសំវុតេន អន្តរឃរេ និសីទិតព្វំ ឱក្ខិត្តចក្ខុនា អន្តរឃរេ និសីទិតព្វំ ន ឧក្ខិត្តកាយ អន្តរឃរេ និសីទិតព្វំ ន ឧជ្ជគ្ឃិកាយ អន្តរឃរេ និសីទិតព្វំ អប្បសទ្ទេន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ វត្តដែលភិក្ខុត្រូវធ្វើក្នុងរោងភត្ត

[ ៨៩ ] បើគេប្រាប់ភត្តកាល ក្នុងអារាមហើយ ភិក្ខុត្រូវបិទបាំងមណ្ឌល ៣ គឺស្លៀកឲ្យជាបរិមណ្ឌល ក្រវាត់សម្ពត់កាយពន្ធន៍ ( វត្ថពន្ធបង្កើះ ) តម្រួតៗគ្នាសង្ឃនឹងសង្ឃាដិ ហើយឃ្លុំពាក់ក្ដុំ ហើយជូតបាត្រឲ្យស្អាតហើយកាន់យកទៅ ដើរតាមសម្រួលមិនរលះរលាំងចូលទៅកាន់ស្រុក មិនត្រូវដើរដែងទៅខាងមុខ ៗ នៃពួកភិក្ខុជាថេរៈទេ ត្រូវបិទបាំងកាយដោយល្អ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវសង្រួមប្រយ័ត្នឲ្យល្អដើរទៅក្នុងចន្លោះផ្ទះ ត្រូវមានភ្នែកសំឡឹងចុះក្រោម គឺក្រឡេកមើលប្រមាណមួយជួរទឹម ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវសើយចីវរដើរចូលទៅក្នុងចន្លោះផ្ទះ មិនត្រូវសើចខ្លាំងដើរទៅក្នុងចន្លោះផ្ទះ ត្រូវមានសំឡេងតិច ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវដើរគ្រវែងកាយទៅក្នុងចន្លោះផ្ទះ មិនត្រូវបង្វាយដៃដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវងើកងោកក្បាលដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវស្ទូមបង្កើះដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវបំពើតជើងដើរទៅក្នុងចន្លោះផ្ទះ ត្រូវបិទបាំងកាយឲ្យល្អអង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវសង្រួមប្រយ័ត្នដោយល្អ អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវមានភ្នែកសំឡឹងចុះក្រោម គឺក្រឡេកមើលប្រមាណមួយជួរទឹម អង្គុយនៅ ក្នុងចន្លោះផ្ទះ មិនត្រូវសើយចីវរអង្គុយនៅ ក្នុងចន្លោះផ្ទះ មិនត្រូវសើចខ្លាំងអង្គុយនៅ ក្នុងចន្លោះផ្ទះ ត្រូវមានសំឡេងតិច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អន្តរឃរេ និសីទិតព្វំ ន កាយប្បចាលកំ អន្តរឃរេ និសីទិតព្វំ ន ពាហុប្បចាលកំ អន្តរឃរេ និសីទិតព្វំ ន សីសប្បចាលកំ អន្តរឃរេ និសីទិតព្វំ ន ខម្ភកតេន អន្តរឃរេ និសីទិតព្វំ ន ឱគុណ្ឋិតេន អន្តរឃរេ និសីទិតព្វំ ន បល្លត្ថិកាយ អន្តរឃរេ និសីទិតព្វំ ន ថេរេ ភិក្ខូ អនុបខជ្ជ និសីទិតព្វំ ន នវា ភិក្ខូ អាសនេន បដិពាហិតព្វា ន សង្ឃាដឹ ឱត្ថរិត្វា អន្តរឃរេ និសីទិតព្វំ ឧទកេ ទីយមានេ ឧភោហិ ហត្ថេហិ បត្តំ បដិគ្គហិត្វា ឧទកំ បដិគ្គហេតព្វំ នីចំ កត្វា សាធុកំ អបរិឃំសន្តេន បត្តោ ធោវិតព្វោ សចេ ឧទកប្បដិគ្គាហកោ ហោតិ នីចំ កត្វា ឧទកប្បដិគ្គហេ ឧទកំ អាសិញ្ចិតព្វំ មា ឧទកប្បដិគ្គាហកោ ឧទកេន ឱសិញ្ចិ មា សាមន្តា ភិក្ខូ ឧទកេន ឱសិញ្ចិំសុ មា សង្ឃាដិ ឧទកេន ឱសិញ្ចីតិ សចេ ឧទកប្បដិគ្គាហកោ ន ហោតិ នីចំ កត្វា ឆមាយំ ឧទកំ អាសិញ្ចិតព្វំ មា សាមន្តា ភិក្ខូ ឧទកេន ឱសិញ្ចិំសុ មា សង្ឃាដិ ឧទកេន ឱសិញ្ចីតិ ឱទនេ ទីយមានេ ឧភោហិ ហត្ថេហិ បត្តំ បដិគ្គហេត្វា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អង្គុយនៅក្នុងចន្លោះផ្ទះ មិនត្រូវគ្រលែងកាយអង្គុយនៅក្នុងចន្លោះផ្ទះ មិនត្រូវធ្ការដៃ អង្គុយនៅក្នុងចន្លោះផ្ទះ មិនត្រូវងេកងោកក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ មិនត្រូវស្ទឹមចង្កេះអង្គុយនៅក្នុងចន្លោះផ្ទះ មិនត្រូវទទូរក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ មិនត្រូវគ្របោមក្បាលជង្គង់អង្គុយនៅក្នុងចន្លោះផ្ទះ មិនត្រូវអង្គុយ ប្រៀតបៀតពួកភិក្ខុជាថេរៈ មិនត្រូវបៀតបៀនភិក្ខុទាំងឡាយ ដោយអាសនៈ មិនត្រូវអង្គុយសង្កត់សង្ឃាដិក្នុងចន្លោះផ្ទះ កាលបើទាយកប្រគេនទឹក ត្រូវកាន់បាត្រដោយដៃទាំងពីរ ហើយទទួលយកទឹក ត្រូវបន្ទាបបាត្រឲ្យស្រួល កុំឲ្យទង្គិច (អ៊ុំ ៗ) ឡើយ ហើយលាងឲ្យស្អាត បើមានកន្ទោរដាក់ទឹក ត្រូវធ្វើឲ្យទាបហើយចាក់ទឹកទៅក្នុងកន្ទោរដាក់ទឹក ដោយតាំងចិត្តថា កុំឲ្យកន្ទោរដាក់ទឹកខ្ទាតខ្ទាយទឹកឡើយ កុំឲ្យភិក្ខុទាំងឡាយជិតខាងទទឹកដោយទឹកឡើយ កុំឲ្យសង្ឃាដិទទឹកដោយទឹកឡើយ បើគ្មានកន្ទោរដាក់ទឹកទេ ភិក្ខុត្រូវធ្វើទឹក (នោះ) ឲ្យទាបហើយស្រោចលើផែនដីដោយតាំងចិត្តថា កុំឲ្យភិក្ខុជិតខាងទាំងឡាយ ទទឹកដោយទឹកឡើយ កុំឲ្យសង្ឃាដិទទឹកដោយទឹកឡើយ បើមានទាយកប្រគេនបាយ ត្រូវកាន់បាត្រដោយដៃទាំងពីរហើយទទួលយកបាយ តែត្រូវធ្វើ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ ភត្តគ្គវត្តំ

ឱទនោ បដិគ្គហេតព្វោ សូបស្ស ឱកាសោ កាតព្វោ សចេ ហោតិ សប្បិ វា តេលំ វា ឧត្តរិភង្គំ វា ថេរេន វត្តព្វោ សព្វេសំ សមកំ សម្បាទេហីតិ សក្កច្ចំ បិណ្ឌបាតោ បដិគ្គហេតព្វោ បត្តសញ្ញិនា បិណ្ឌបាតោ បដិគ្គហេតព្វោ សមសូបកោ បិណ្ឌបាតោ បដិគ្គហេតព្វោ សមតិត្តិកោ បិណ្ឌបាតោ បដិគ្គហេតព្វោ ន តាវ ថេរេន ភុញ្ជិតព្វំ យាវ ន សព្វេសំ ឱទនោ សម្បត្តោ[1] ហោតិ សក្កច្ចំ បិណ្ឌបាតោ ភុញ្ជិតព្វោ បត្តសញ្ញិនា បិណ្ឌបាតោ ភុញ្ជិតព្វោ សបទានំ[2] បិណ្ឌបាតោ ភុញ្ជិតព្វោ សមសូបកោ បិណ្ឌបាតោ ភុញ្ជិតព្វោ ន ថូបតោ[3] ឱមទ្ទិត្វា បិណ្ឌបាតោ ភុញ្ជិតព្វោ ន សូបំ វា ព្យញ្ជនំ វា ឱទនេន បដិច្ឆាទេតព្វំ ភិយ្យោកម្យតំ ឧបាទាយ ន សូបំ វា ឱទនំ វា អគិលានេន អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិតព្វំ ន ឧជ្ឈានសញ្ញិនា បរេសំ បត្តោ ឱលោកេតព្វោ នាតិមហន្តោ កពឡោ កាតព្វោ បរិមណ្ឌលោ អាលោបោ កាតព្វោ ន អនាហដេ កពឡេ

---

១ ឱ. ប. សម្បន្នោ ។ ២ ឱ. សបទានោ ។ ៣ ថូបីកតោតិបិ បាឋោ ទិស្សតិ ។ ម. ថូបកតោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ វត្តដែលភិក្ខុត្រូវប្រព្រឹត្តក្នុងរោងភត្ត

ទឹកកាសឲ្យដាក់សម្បានផង បើមានទឹកដោះជូរក្តី ប្រេងក្តី សម្លឧត្ត–រិភង្គក្តី ភិក្ខុជាថេរៈត្រូវពោលថា ចូរអ្នកចាត់ចែងដល់ភិក្ខុគ្រប់រូប ឲ្យបានស្មើៗ គ្នា ត្រូវទទួលបិណ្ឌបាតដោយគោរព ត្រូវមានសេចក្តីសំគាល់តែក្នុងបាត្រទទួលបិណ្ឌបាត ត្រូវទទួលបិណ្ឌបាតឲ្យមានសម្លស្មើគ្នា ត្រូវទទួលបិណ្ឌបាតឲ្យស្មើតែត្រឹមកណ្តាប់មាត់បាត្រ ភិក្ខុគ្រប់រូបមិនទាន់បានបាយទុកគ្រប់គ្រាន់ត្រឹមណា ភិក្ខុជាថេរៈមិនគប្បីឆាន់ត្រឹមនោះ ត្រូវឆាន់បង្ហាន់បិណ្ឌបាតដោយគោរព ត្រូវឆាន់បង្ហាន់បិណ្ឌបាត សំគាល់តែក្នុងបាត្រ ត្រូវឆាន់បង្ហាន់បិណ្ឌបាតរាបឲ្យស្មើ ត្រូវឆាន់បង្ហាន់បិណ្ឌបាតមានសម្លស្មើគ្នា មិនត្រូវប្រមបុះអំពីកំពូលបាយ ឆាន់បង្ហាន់បិណ្ឌបាត មិនត្រូវកកាយបាយលុបសម្ល ឬម្ហូបក្រៀម ដើម្បីឲ្យបានច្រើនជាងគេ បើគ្មានជម្ងឺ មិនត្រូវសូមសម្ល ឬបាយ ដើម្បីជាប្រយោជន៍ដល់ខ្លួនហើយឆាន់ទេ មិនត្រូវសំឡឹងរំពៃមើលបាត្រភិក្ខុទាំងឡាយដទៃ ដោយគិតនឹងលើកទោសទេ មិនត្រូវធ្វើពំនូតបាយ ឲ្យធំហួសប្រមាណ ត្រូវធ្វើពំនូតបាយឲ្យជាបរិមណ្ឌល គឺធ្វើឲ្យមូល កាលបើពំនូតបាយមិនទាន់ដល់មាត់ មិនត្រូវ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មុខទ្វារំ វិវរិតព្វំ ន ភុញ្ជមានេន សព្វោ ហត្ថោ មុខេ បក្ខិបិតព្វោ ន សកពឡេន មុខេន ព្យាហរិតព្វំ ន បិណ្ឌុក្ខេបកំ ភុញ្ជិតព្វំ ន កពឡាវច្ឆេទកំ ភុញ្ជិតព្វំ ន អវគណ្ឌការកំ ភុញ្ជិតព្វំ ន ហត្ថនិទ្ធុនកំ ភុញ្ជិតព្វំ ន សិត្ថាវការកំ ភុញ្ជិតព្វំ ន ជិវ្ហានិច្ឆារកំ ភុញ្ជិតព្វំ ន ចបុចបុការកំ ភុញ្ជិតព្វំ ន សុរុសុរុការកំ ភុញ្ជិតព្វំ ន ហត្ថនិល្លេហកំ ភុញ្ជិតព្វំ ន បត្តនិល្លេហកំ ភុញ្ជិតព្វំ ន ឱដ្ឋនិល្លេហកំ ភុញ្ជិតព្វំ ន សាមិសេន ហត្ថេន បានីយថាលកោ បដិគ្គហេតព្វោ ន តាវ ថេរេន ឧទកំ បដិគ្គហេតព្វំ យាវ ន សព្វេ ភុត្តាវិនោ ហោន្តិ ឧទកេ ទីយមានេ ឧភោហិ ហត្ថេហិ បត្តំ បរិគ្គហេត្វា ឧទកំ បដិគ្គហេតព្វំ នីចំ កត្វា សាធុកំ អបរិឃំសន្តេន បត្តោ ធោវិតព្វោ សចេ ឧទកប្បដិគ្គាហកោ ហោតិ នីចំ កត្វា ឧទកប្បដិគ្គហេ ឧទកំ អាសិញ្ចិតព្វំ មា ឧទកប្បដិគ្គាហកោ ឧទកេន ឱសិញ្ចិ មា សាមន្តា ភិក្ខូ ឧទកេន ឱសិញ្ចឹសុ មា សង្ឃាដិ ឧទកេន ឱសិញ្ចិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ហារមាត់ចាំឡើយ កាលនឹងឆាន់ មិនត្រូវញាត់ម្រាមដៃទាំងអស់ទៅក្នុងមាត់ មិនត្រូវនិយាយទាំងពំនូតបាយនៅក្នុងមាត់ មិនត្រូវបោះដុំបាយ (ទៅក្នុងមាត់) ហើយឆាន់ទេ មិនត្រូវឆាន់ខាំកាត់ពំនូតបាយ (មួយកំណាត់ម្តង) មិនត្រូវឆាន់បៀមពំនូតបាយឲ្យទុលថ្ពាល់ឡើង (ដូចជាស្វា) មិនត្រូវឆាន់រលាស់ដៃបណ្តើរ មិនត្រូវឆាន់បាយឲ្យរោយរាយគ្រាប់បាយ មិនត្រូវឆាន់លៀនអណ្តាតចេញមកខាងក្រៅ (ទទួលអាហារ) មិនត្រូវឆាន់ឲ្យឮផ្លប់ៗ មិនត្រូវឆាន់ឲ្យឮគ្រូកៗ មិនត្រូវឆាន់លិទ្ធដៃ មិនត្រូវឆាន់លិទ្ធបាត្រ មិនត្រូវឆាន់លិទ្ធបបូរមាត់ មិនត្រូវទទួលកាដន៍ទឹកទាំងដៃប្រឡាក់អាមិសៈ ភិក្ខុទាំងពួងមិនទាន់ឆាន់ហើយត្រឹមណា ភិក្ខុជាថេរៈមិនគប្បីទទួលយកទឹកត្រឹមនោះ កាលបើទាយកប្រគេនទឹក ត្រូវកាន់បាត្រដោយដៃទាំងពីរ ហើយទទួលយកទឹក ត្រូវធ្វើបាត្រឲ្យទាបកុំឲ្យទង្គិច (អ្វើៗ) ហើយលាងឲ្យស្អាត បើមានកន្ទោរទឹក ត្រូវធ្វើឲ្យទាបហើយចាក់ទឹកទៅក្នុងកន្ទោរជាក់ទឹក ដោយតាំងចិត្តថា កុំឲ្យកន្ទោរជាក់ទឹកខ្ទាត់ខ្ទាយទឹកឡើយ កុំឲ្យពួកភិក្ខុជិតខាងទទឹកដោយទឹកឡើយ កុំឲ្យសង្ឃាដីទទឹកដោយទឹកឡើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ ភត្តគ្គវត្តំ

សចេ ឧទកប្បដិគ្គាហកោ ន ហោតិ នីចំ កត្វា ឆមាយំ ឧទកំ អាសិញ្ចិតព្វំ មា សាមន្តា ភិក្ខូ ឧទកេន ឱសិញ្ចិំសុ មា សង្ឃាដិំ ឧទកេន ឱសិញ្ចីតិ ន សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេតព្វំ និវត្តន្តេន នវកេហិ ភិក្ខូហិ បឋមតរំ និវត្តិតព្វំ បច្ឆា ថេរេហិ សុប្បដិច្ឆន្នេន អន្តរឃរេ គន្តព្វំ សុសំវុតេន អន្តរឃរេ គន្តព្វំ ឱក្ខិត្តចក្ខុនា អន្តរឃរេ គន្តព្វំ ន ឧក្ខិត្តកាយ អន្តរឃរេ គន្តព្វំ ន ឧជ្ជគ្ឃិកាយ អន្តរឃរេ គន្តព្វំ អប្បសទ្ទេន អន្តរឃរេ គន្តព្វំ ន កាយប្បចាលកំ អន្តរឃរេ គន្តព្វំ ន ពាហុប្បចាលកំ អន្តរឃរេ គន្តព្វំ ន សីសប្បចាលកំ អន្តរឃរេ គន្តព្វំ ន ខម្ភកតេន អន្តរឃរេ គន្តព្វំ ន ឱគុណ្ឋិតេន អន្តរឃរេ គន្តព្វំ ន ឧក្កុដិកាយ អន្តរឃរេ គន្តព្វំ ឥទំ ខោ ភិក្ខវេ ភិក្ខូនំ ភត្តគ្គវត្តំ យថា ភិក្ខូហិ ភត្តគ្គេ សម្មា វត្តិតព្វន្តិ ។

បឋមភាណវារំ និដ្ឋិតំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ វត្តដែលភិក្ខុត្រូវប្រព្រឹត្តក្នុងរោងភត្ត

បើមិនមានកន្លែងទឹកទេ ត្រូវធ្វើទឹកឲ្យទាបហើយ ចាក់លើផែនដី ដោយតាំងចិត្តថា កុំឲ្យពួកភិក្ខុជិតខាងទទឹកដោយទឹកឡើយ កុំឲ្យសង្ឃាដិទទឹកដោយទឹកឡើយ មិនត្រូវចាក់ទឹកលាងបាត្រមានទាំងគ្រាប់បាយក្នុងចន្លោះផ្ទះ កាលបើត្រឡប់វិញ ត្រូវត្រឡប់ឲ្យបានមុនពួកភិក្ខុ ត្រូវបិទបាំងកាយឲ្យល្អដើរទៅក្នុងចន្លោះផ្ទះ ក្រោយភិក្ខុជាថេរៈទាំងឡាយ ត្រូវសង្រួមប្រយ័ត្នឲ្យល្អដើរទៅក្នុងចន្លោះផ្ទះ ត្រូវមានភ្នែកសំឡឹងចុះក្រោម គឺក្រឡេកមើលប្រមាណ ១ ជួរនឹម ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវសើយចីវរដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវសើចខ្លាំងដើរទៅក្នុងចន្លោះផ្ទះ ត្រូវមានសំឡេងតិចៗ ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវដើរគ្រវែងកាយទៅក្នុងចន្លោះផ្ទះ មិនត្រូវបង្ហាយដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវងើកងោកក្បាលដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវស្ទឹមចង្កេះដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវដើរបំពើតជើងទៅក្នុងចន្លោះផ្ទះ ម្នាលភិក្ខុទាំងឡាយ នេះហើយជាវត្តរបស់ភិក្ខុទាំងឡាយ តាមទំនងដែលភិក្ខុទាំងឡាយគប្បីប្រព្រឹត្តដោយប្រពៃក្នុងរោងភត្ត ។

ភាណវារៈទី ១ ចប់ ។

## វិនយបិដកេ ចុល្លវគ្គោ

[៩០] តេន ខោ បន សមយេន បិណ្ឌចារិកា ភិក្ខូ ទុន្និវត្ថា ទុប្បារុតា អនាកប្បសម្បន្នា បិណ្ឌាយ ចរន្តិ អសល្លក្ខេត្វាបិ និវេសនំ បវិសន្តិ អសល្លក្ខេត្វាបិ និក្ខមន្តិ អតិសហសាបិ បវិសន្តិ អតិសហសាបិ និក្ខមន្តិ អតិទូរេបិ តិដ្ឋន្តិ អច្ចាសន្នេបិ តិដ្ឋន្តិ អតិចិរំបិ តិដ្ឋន្តិ អតិលហុកំបិ និវត្តន្តិ ។ អញ្ញតរោ[១] បិណ្ឌចារិកោ ភិក្ខុ អសល្លក្ខេត្វា និវេសនំ បាវិសិ ។ សោ ច[២] ទ្វារំ មញ្ញមានោ អញ្ញតរំ ឱវរកំ បាវិសិ ។ តស្មិំបិ[៣] ឱវរកេ ឥត្ថី នគ្គា ឧត្តានា និបន្នា ហោតិ ។ អទ្ទសា ខោ សោ ភិក្ខុ តំ ឥត្ថឹ នគ្គំ ឧត្តានំ និបន្នំ ទិស្វាន នយិទំ ទ្វារំ ឱវរកំ ឥទន្តិ តម្ហា ឱវរកម្ហា និក្ខមិ ។ អទ្ទសា ខោ តស្សា ឥត្ថិយា សាមិកោ តំ ឥត្ថឹ នគ្គំ ឧត្តានំ និបន្នំ ទិស្វាន ឥមិនា មេ ភិក្ខុនា បជាបតិ ទូសិតាតិ តំ ភិក្ខុំ គហេត្វា អាកោដេតិ ។ អថខោ សា ឥត្ថី តេន សទ្ទេន បដិពុជ្ឈិត្វា តំ

---

១ ឱ. ម. អញ្ញតរោបិ ។ ២ អយំ ចសទ្ទោ ឱ. ម. ពោត្ថកេសុ ន ទិស្សតិ ។ ៣ អយំ បិសទ្ទោ ឱ. ម. ពោត្ថកេសុ ន ទិស្សតិ ។

(៩០) សម័យនោះឯង ពួកភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត ស្លៀកមិនល្អ ដណ្តប់មិនល្អ ប្រកបដោយមារយាទមិនសមគួរ ត្រាច់ទៅបិណ្ឌបាត មិនបានសង្កេតហើយចូលទៅកាន់លំនៅ (ផ្ទះគេ) ខ្លះ មិនបានសង្កេតហើយចេញមកខ្លះ ចូលទៅដោយរហ័សពេកខ្លះ ចេញមកដោយរហ័សពេកខ្លះ ឈរក្នុងទីឆ្ងាយពេកខ្លះ ឈរក្នុងទីជិតពេកខ្លះ ឈរយូរពេកខ្លះ ត្រឡប់មកវិញដោយរហ័សពេកខ្លះ ។ មានភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាតមួយរូប មិនបានសង្កេតហើយដើរចូលទៅកាន់លំនៅ (គេ) ។ ភិក្ខុនោះកាលសំគាល់នូវទ្វារដើរចូលទៅកាន់បន្ទប់តូចមួយ ។ ក្នុងបន្ទប់តូចនោះសោត មានស្រីអាក្រាតដេកផ្ងារ ។ ភិក្ខុនោះក៏បានឃើញស្រីអាក្រាតដេកផ្ងារនោះ លុះឃើញហើយគិតថា នេះមិនមែនជាទ្វារទេ នេះជាបន្ទប់តូចទេតើ ហើយក៏ចេញចាកបន្ទប់តូចនោះមក ។ ស្វាមីរបស់ស្រីនោះក៏បានឃើញស្រីជាប្រពន្ធនោះអាក្រាតដេកផ្ងារ លុះឃើញហើយក៏គិតថា ភិក្ខុនេះប្រទូស្តនឹងប្រពន្ធរបស់អញហើយតើ ហើយចាប់ទះតប់ភិក្ខុនោះ ។ លំដាប់នោះ ស្រីនោះក៏ភ្ញាក់ឡើងដោយសារឮសូរសន្ធឹកនោះ ហើយបាន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



## វត្តក្ខន្ធកេ បិណ្ឌចារិកវត្តំ

បុរិសំ ឯតទវោច កិស្ស ត្វំ អយ្យ[១] ឥមំ ភិក្ខុំ អាកោដេសីតិ ។ ឥមិនាសិ ត្វំ ភិក្ខុនា ទូសិតាតិ ។ នាហំ អយ្យ[២] ឥមិនា ភិក្ខុនា ទូសិតា អការកោ សោ ភិក្ខូតិ តំ ភិក្ខុំ មុញ្ចាបេសិ ។ អថខោ សោ ភិក្ខុ អារាមំ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម បិណ្ឌចារិកា ភិក្ខូ ទុន្និវត្ថា ទុប្បារុតា អនាកប្បសម្បន្នា បិណ្ឌាយ ចរិស្សន្តិ អសល្លក្ខេត្វាបិ និវេសនំ បវិសិស្សន្តិ អសល្លក្ខេត្វាបិ និក្ខមិស្សន្តិ អតិសហសាបិ បវិសិស្សន្តិ អតិសហសាបិ និក្ខមិស្សន្តិ អតិទូរេបិ តិដ្ឋិស្សន្តិ អច្ចាសន្នេបិ តិដ្ឋិស្សន្តិ អតិចិរម្បិ តិដ្ឋិស្សន្តិ អតិលហុកម្បិ និវត្តិស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ។ បេ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ

---

១-២ ឱ· ម· អយ្យោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ វត្តរបស់ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត

សួរបុរសនោះថា នែអ្នក ហេតុអ្វីបានជាអ្នកទះតប់ភិក្ខុនេះ ។ ស្វាមីឆ្លើយថា ភិក្ខុនេះប្រទូស្តហ៍ឯងហើយ ។ ប្រពន្ធប្រាប់ថា នែអ្នក ភិក្ខុនេះមិនបានប្រទូស្តខ្ញុំទេ ភិក្ខុនោះឥតបានធ្វើ (អំពើដូច្នោះទេ) ថាហើយក៏ឲ្យប្តីលែងភិក្ខុនោះទៅ ។ ខណៈនោះ ភិក្ខុនោះបានទៅកាន់អារាមហើយប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត មិនសមបើនឹងស្លៀកមិនល្អ ដណ្តប់មិនល្អ ប្រកបដោយមារយាទមិនសមគួរត្រាច់ទៅបិណ្ឌបាត មិនបានសង្កេតហើយចូលទៅកាន់លំនៅ (គេ) ខ្លះ មិនបានសង្កេតហើយចេញមកខ្លះ ចូលទៅដោយរហ័សពេកខ្លះ ចេញមកដោយរហ័សពេកខ្លះ ឈរក្នុងទីឆ្ងាយពេកខ្លះ ឈរក្នុងទីជិតពេកខ្លះ ឈរយូរពេកខ្លះ ត្រឡប់មកដោយរហ័សពេកខ្លះ (ដូច្នេះ) សោះ ។ គ្រានោះ ភិក្ខុទាំងនោះ បានក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថារឿងនោះពិតមែនឬ ។បេ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។បេ។ លុះទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បិណ្ឌចារិកានំ ភិក្ខូនំ វត្តំ បញ្ញាបេស្សាមិ យថា បិណ្ឌ-ចារិកេហិ ភិក្ខូហិ សម្មា វត្តិតព្វំ ។

[៨១] បិណ្ឌចារិកេន ភិក្ខវេ ភិក្ខុនា សចេ គាមំ បវិសិស្សាមីតិ តិមណ្ឌលំ បដិច្ឆាទេន្តេន បរិមណ្ឌលំ និវាសេត្វា កាយពន្ធនំ ពន្ធិត្វា សគុណំ កត្វា សង្ឃា-ដិយោ បារុបិត្វា គណ្ឋិកំ បដិមុញ្ចិត្វា ធោវិត្វា បត្តំ គហេត្វា សាធុកំ អតរមានេន គាមោ បវិសិតព្វោ សុប្បដិច្ឆន្នេន អន្តរឃរេ គន្តព្វំ សុសំវុតេន អន្តរឃរេ គន្តព្វំ ឱក្ខិត្តចក្ខុនា អន្តរឃរេ គន្តព្វំ ន ឧក្ខិត្តកាយ អន្តរឃរេ គន្តព្វំ ន ឧជ្ជគ្ឃិកាយ អន្តរឃរេ គន្តព្វំ អប្បសទ្ទេន អន្តរឃរេ គន្តព្វំ ន កាយប្បចាលកំ អន្តរឃរេ គន្តព្វំ ន ពាហុប្បចាលកំ អន្តរឃរេ គន្តព្វំ ន សីសប្បចាលកំ អន្តរឃរេ គន្តព្វំ ន ខម្ភកតេន អន្តរឃរេ គន្តព្វំ ន ឱគុណ្ឋិតេន អន្តរឃរេ គន្តព្វំ ន ឧក្កុដិកាយ អន្តរឃរេ គន្តព្វំ និវេសនំ បវិសន្តេន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



គឺថាគួរនឹងបញ្ញត្តវត្តដល់ពួកភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត តាមទំនងដែលពួកភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត គប្បីប្រព្រឹត្តដោយប្រពៃបាន ។

(៩១) ម្នាលភិក្ខុទាំងឡាយ បិណ្ឌចារិកភិក្ខុ (ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌ-បាត) គិតថា អាត្មាអញនឹងចូលទៅកាន់ស្រុកក្នុងកាលឥឡូវនេះ ហើយគប្បីបិទបាំងមណ្ឌលបី គឺ ស្លៀកឲ្យជាបរិមណ្ឌល ក្រវាត់សម្ពត់កាយពន្ធន៍ (វត្ថពន្ធបង្កេះ) ហើយតម្រួតឧត្តរាសង្គៈនឹងសង្ឃាដិ ពាក់ក្ដុំហើយឃ្លុំ ដូតបាត្រឲ្យស្អាតកាន់ដើរចូលទៅកាន់ស្រុកដោយស្រួល មិនរលះរលាំង ត្រូវបិទបាំងកាយឲ្យល្អដើរទៅក្នុងចន្លោះផ្ទះ ត្រូវសង្រួមប្រយ័ត្នឲ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវមានភ្នែកសំឡឹងចុះក្រោមដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវសើយចីវរដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវសើចខ្លាំងដើរទៅក្នុងចន្លោះផ្ទះ ត្រូវមានសំឡេងតិច ៗ ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវគ្រវែងកាយដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវបង្ហោយ ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវងើកងោកក្បាលដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវស្ទឹមចង្កេះដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវបំអើតជើងដើរទៅក្នុងចន្លោះផ្ទះ កាលដែលនឹងចូលទៅកាន់លំនៅគេត្រូវកំណត់ថា អាត្មាអញនឹងចូលទៅ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សល្លក្ខេតព្វំ ឥមិនា បវិសិស្សាមិ ឥមិនា និក្ខមិស្សាមីតិ នាតិសហសា បវិសិតព្វំ នាតិសហសា និក្ខមិតព្វំ នាតិទូរេ ឋាតព្វំ នាច្ចាសន្នេ ឋាតព្វំ នាតិចិរំ ឋាតព្វំ នាតិលហុកំ និវត្តិតព្វំ ឋិតកេន សល្លក្ខេតព្វំ ភិក្ខំ ទាតុកាមា វា អទាតុកាមា វាតិ សចេ កម្មំ វា និក្ខិបតិ អាសនា វា វុដ្ឋាតិ កដច្ឆុំ វា បរាមសតិ ភាជនំ វា បរាមសតិ ឋបេតិ វា ទាតុកាមិយាតិ(១) ឋាតព្វំ ភិក្ខាយ ទិយ្យមានាយ វាមេន ហត្ថេន សង្ឃាដឹ ឧច្ចារេត្វា ទក្ខិណេន ហត្ថេន បត្តំ បណាមេត្វា ឧភោហិ ហត្ថេហិ បត្តំ បដិគ្គហេត្វា ភិក្ខា បដិគ្គហេតព្វា ន ច ភិក្ខាទាយិកាយ មុខំ ឱលោកេតព្វំ(២) សល្លក្ខេតព្វំ សូបំ ទាតុកាមា វា អទាតុកាមា វាតិ សចេ កដច្ឆុំ វា បរាមសតិ ភាជនំ វា បរាមសតិ ឋបេតិ វា ទាតុកាមិយាតិ ឋាតព្វំ ភិក្ខាយ ទិន្នាយ សង្ឃាដិយា បត្តំ បដិច្ឆាទេត្វា សាធុកំ អតរមានេន និវត្តិតព្វំ សុប្បដិច្ឆន្នេន អន្តរឃរេ គន្តព្វំ សុសំវុតេន អន្តរឃរេ គន្តព្វំ

---

១ ឱ· ទាតុកាមោ វិយាតិ ។ ម· ទាតុកាមស្សាតិ ។ ២ ឱ· ម· ឧល្លោកេតព្វំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តាមផ្លូវនេះ នឹងចេញមកវិញតាមផ្លូវនេះ មិនត្រូវដើរចូលទៅដោយរហ័សពេក មិនត្រូវចេញមកដោយរហ័សពេក មិនត្រូវឈរក្នុងទីឆ្ងាយពេក មិនត្រូវឈរក្នុងទីជិតពេក មិនត្រូវឈរយូរពេក មិនត្រូវត្រឡប់រហ័សពេក ត្រូវឈរសង្កេតថា គេមានបំណងនឹងឲ្យបង្អាន់ ឬឥតមានបំណងនឹងឲ្យទេ បើប្រសិនជាគេបញ្ឈប់ការងារ ឬគេក្រោកចាកអាសនៈ ឬចាប់វែក ឬចាប់ភាជន៍ ឬគេមានបំណងនឹងឲ្យហើយនិមន្តឲ្យរង់ចាំក្តី ដឹងដូច្នេះហើយត្រូវឈររង់ចាំ កាលបើ គេប្រគេនបង្អាន់ បិណ្ឌចារិកភិក្ខុត្រូវវែកសង្ឃាដិដោយដៃឆ្វេងបង្អោនបាត្រដោយដៃស្តាំ ហើយទ្របាត្រដោយដៃទាំងពីរទទួលយកបង្អាន់ តែកុំសំឡឹងមើលមុខស្រីដែលប្រគេន(១)បង្អាន់នោះឡើយ ត្រូវសង្កេតថា គេមានបំណងនឹងឲ្យសម្ល ឬមិនមានបំណងនឹងឲ្យទេ បើប្រសិនជាគេចាប់វែកក្តី ចាប់ភាជន៍ក្តី ឬគេមានបំណងនឹងឲ្យហើយនិមន្តឲ្យរង់ចាំក្តី បិណ្ឌចារិកភិក្ខុដឹងដូច្នេះហើយ ត្រូវឈររង់ចាំ កាលបើគេបានប្រគេនបង្អាន់ហើយ ត្រូវបិទបាំងបាត្រដោយសង្ឃាដិ ដើរត្រឡប់មកដោយស្រួល មិនរលះរលាំងត្រូវបិទបាំងកាយឲ្យល្អដើរទៅក្នុងចន្លោះផ្ទះ ត្រូវសង្រួមប្រយ័ត្នដោយល្អដើរទៅក្នុងចន្លោះផ្ទះ ត្រូវមាន

---

១ អដ្ឋកថា ថា ប្រុសក្តី ស្រីក្តី បិណ្ឌចារិកភិក្ខុមិនគប្បីមើលមុខគេក្នុងខណៈ ដែលគេប្រគេនបង្អាន់ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឱក្ខិត្តចក្ខុនា អន្តរឃរេ គន្តព្វំ ន ឧក្ខិត្តកាយ អន្តរឃរេ គន្តព្វំ ន ឧជ្ជគ្ឃិកាយ អន្តរឃរេ គន្តព្វំ អប្បសទ្ទេន អន្តរឃរេ គន្តព្វំ ន កាយប្បចាលកំ អន្តរឃរេ គន្តព្វំ ន ពាហុប្បចាលកំ អន្តរឃរេ គន្តព្វំ ន សីសប្បចាលកំ អន្តរឃរេ គន្តព្វំ ន ខម្ភកតេន អន្តរឃរេ គន្តព្វំ ន ឱគុណ្ឋិតេន អន្តរឃរេ គន្តព្វំ ន ឧក្កុដិកាយ អន្តរឃរេ គន្តព្វំ យោ បឋមំ គាមតោ បិណ្ឌាយ បដិក្កមតិ តេន អាសនំ បញ្ញាបេតព្វំ បាទោទកំ បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបិតព្វំ អវក្ការបាតិំ ធោវិត្វា ឧបដ្ឋាបេតព្វា បានីយំ បរិភោជនីយំ ឧបដ្ឋាបេតព្វំ យោ បច្ឆា គាមតោ បិណ្ឌាយ បដិក្កមតិ សចេ ហោតិ ភុត្តាវសេសោ សចេ អាកង្ខតិ ភុញ្ជិតព្វំ នោ ចេ អាកង្ខតិ អប្បហរិតេ វា ឆឌ្ឌេតព្វំ អប្បាណកេ វា ឧទកេ ឱបិលាបេតព្វំ តេន អាសនំ ឧទ្ធរិតព្វំ បាទោទកំ បាទបីឋំ បាទកឋលិកំ បដិសាមេតព្វំ អវក្ការបាតិំ ធោវិត្វា បដិសាមេតព្វា បានីយំ បរិភោជនីយំ បដិសាមេតព្វំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ក្តែកសំឡៀងចុះក្រោម ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវសើយចីវរ ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវសើចខ្លាំងដើរទៅក្នុងចន្លោះផ្ទះ ត្រូវមានសំឡេងតិចៗ ដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវគ្រវែងកាយដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវបង្វាយដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវងើកងោកក្បាលដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវស្ទឹមចង្កេះដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះ មិនត្រូវបំអើតជើងដើរទៅក្នុងចន្លោះផ្ទះ ភិក្ខុណាត្រឡប់មកពីបិណ្ឌបាតក្នុងស្រុកមុនគេ ភិក្ខុនោះត្រូវក្រាលអាសនៈ(ទុកហាំ)ត្រូវដម្កល់ទុកនូវទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រាប់ជើងដែលលាងហើយទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់លាង ត្រូវលាងភាជន៍សម្រាប់ផ្ទេរភោជន ហើយដម្កល់ទុក ត្រូវដម្កល់ទុកនូវទឹកសម្រាប់ឆាន់ និងទឹកសម្រាប់ប្រើប្រាស់ភិក្ខុណាត្រឡប់មកពីបិណ្ឌបាតក្នុងស្រុកក្រោយគេ បើមានអាហារដែលសល់អំពីបរិភោគ បើចង់ឆាន់គប្បីឆាន់ចុះ បើមិនចង់ឆាន់ទេ ត្រូវយកទៅចោលក្នុងទីដែលគ្មានវត្ថុខៀវ (មានស្មៅជាដើម) ឬយកទៅចាក់ក្នុងទឹកដែលគ្មានសត្វ ភិក្ខុនោះគប្បីសារអាសនៈទុក ត្រូវទុកដាក់នូវទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រាប់ជើងដែលលាងហើយ ទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់លាង ត្រូវលាងភាជន៍សម្រាប់ផ្ទេរភោជន ហើយរៀបចំទុកដាក់ ត្រូវទុកដាក់ទឹកសម្រាប់ឆាន់ និងទឹកសម្រាប់ប្រើប្រាស់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ បិណ្ឌចារិកវត្តំ អារញ្ញកវត្តំ

ភត្តគ្គំ សម្មជ្ជិតព្វំ យោ បស្សតិ បានីយឃដំ វា បរិភោជនីយឃដំ វា វច្ចឃដំ វា រិត្តំ តុច្ឆំ តេន ឧបដ្ឋាបេតព្វំ សចស្ស ហោតិ អវិសយ្ហំ ហត្ថវិការេន ទុតិយំ អាមន្តេត្វា ហត្ថវិលង្ឃកេន ឧបដ្ឋាបេតព្វំ ន ច តប្បច្ចយា វាចា ភិន្ទិតព្វា ឥទំ ខោ ភិក្ខវេ បិណ្ឌចារិកានំ ភិក្ខូនំ វត្តំ យថា បិណ្ឌចារិកេហិ ភិក្ខូហិ សម្មា វត្តិតព្វន្តិ ។

(៩២) តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ អរញ្ញេ វិហរន្តិ ។ តេ នេវ បានីយំ ឧបដ្ឋាបេន្តិ ន បរិភោជនីយំ ឧបដ្ឋាបេន្តិ ន អគ្គឹ ឧបដ្ឋាបេន្តិ ន អរណិសហិតំ ឧបដ្ឋាបេន្តិ ន នក្ខត្តបទានិ ជានន្តិ ន ទិសាភាគំ ជានន្តិ ។ ចោរា តត្ថ គន្ត្វា តេ ភិក្ខូ ឯតទវោចុំ អត្ថិ ភន្តេ បានីយន្តិ ។ នត្ថាវុសោតិ ។ អត្ថិ ភន្តេ បរិភោជនីយន្តិ ។ នត្ថាវុសោតិ ។ អត្ថិ ភន្តេ អគ្គីតិ ។ នត្ថាវុសោតិ ។ អត្ថិ ភន្តេ អរណិសហិតន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ត្រូវបោសរោងភត្ត ភិក្ខុណា ឃើញក្អមសម្រាប់ដាក់ទឹកឆាន់ក្តី ក្អមសម្រាប់ដាក់ទឹកប្រើប្រាស់ក្តី ក្អមសម្រាប់ដាក់ទឹកលាងវច្ចៈក្តី ដែលទទេគ្មានទឹក ភិក្ខុនោះត្រូវរកទឹកមកដម្កល់ទុក បើភិក្ខុនោះមិនអាចនឹងលើក (ដោយដៃខ្លួន) រួចទេ ត្រូវហៅរកគេជាគំរប់ពីរនាក់ ដោយហត្ថវិការ (បោយដៃ) ហើយឲ្យគេជួយលើកទៅដម្កល់ទុក តែកុំបញ្ចេញវាចា ព្រោះហេតុតែកិច្ចប៉ុណ្ណោះឡើយ ម្នាលភិក្ខុទាំងឡាយ ទាំងនេះជាវត្តរបស់បិណ្ឌបាតិកភិក្ខុទាំងឡាយ តាមទំនងដែលបិណ្ឌបាតិកភិក្ខុទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ ។

(៩២) សម័យនោះឯង មានភិក្ខុច្រើនរូបនៅក្នុងព្រៃ ។ ភិក្ខុទាំងនោះមិនដងទឹកសម្រាប់ឆាន់ទុក មិនដងទឹកសម្រាប់ប្រើប្រាស់ទុក មិនបានដម្កល់ទុកនូវភ្លើង មិនបានដម្កល់ទុកនូវពិនួតភ្លើង មិនដឹងផ្កាយនក្ខត្តឫក្ស មិនដឹងចំណែកនៃទិស ។ មានពួកចោរទៅក្នុងទីនោះ បានសួរភិក្ខុទាំងនោះថា មានទឹកផឹកឬទេ លោកម្ចាស់ ។ ភិក្ខុទាំងឡាយប្រាប់ថា គ្មានទេ អាវុសោ ។ ចោរសួរថា ចុះទឹកសម្រាប់ប្រើប្រាស់ មានឬទេ លោកម្ចាស់ ។ ភិក្ខុទាំងឡាយប្រាប់ថា គ្មានទេ អាវុសោ ។ ពួកចោរសួរថា ចុះភ្លើងមានឬទេ លោកម្ចាស់ ។ ភិក្ខុទាំងឡាយប្រាប់ថា គ្មានទេ អាវុសោ ។ ពួកចោរសួរថា ចុះឈើពិនួតភ្លើងមានឬទេ លោកម្ចាស់ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នត្ថាវុសោតិ ។ កេនជ្ជ ភន្តេ យុត្តន្តិ ។ ន ខោ មយំ អាវុសោ ជានាមាតិ ។ កតមាយំ ភន្តេ ទិសាតិ ។ ន ខោ មយំ អាវុសោ ជានាមាតិ ។ អថខោ តេ ចោរា នេវិមេសំ បានីយំ អត្ថិ ន បរិភោជនីយំ អត្ថិ ន អគ្គិ អត្ថិ ន អរណិសហិតំ អត្ថិ ន នក្ខត្តបទានិ ជានន្តិ ន ទិសាភាគំ ជានន្តិ ចោរា ឥមេ នយិមេ ភិក្ខូតិ អាកោដេត្វា បក្កមិំសុ ។ អថខោ តេ ភិក្ខូ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ អារញ្ញកានំ ភិក្ខូនំ វត្តំ បញ្ញបេស្សាមិ យថា អារញ្ញកេហិ ភិក្ខូហិ សម្មា វត្តិតព្វំ ។

[៩៣] អារញ្ញកេន ភិក្ខវេ ភិក្ខុនា កាលស្សេវ ឧដ្ឋាយ បត្តំ ថវិកាយ បក្ខិបិត្វា អំសេ អាលគ្គេត្វា ចីវរំ ខន្ធេ ករិត្វា ឧបាហនា អារោហិត្វា ទារុភណ្ឌំ

ភិក្ខុទាំងឡាយប្រាប់ថា គ្មានទេ អាវុសោ ។ ពួកចោរសួរថា ចុះក្នុងថ្ងៃនេះ ប្រកបដោយផ្កាយនក្ខត្តឫក្សអ្វី ។ ភិក្ខុទាំងឡាយប្រាប់ថា ម្នាលអាវុសោ យើងទាំងឡាយមិនដឹងទេ ។ ពួកចោរសួរថា នេះហាថាទិសអ្វី លោកម្ចាស់ ។ ភិក្ខុទាំងឡាយប្រាប់ថា យើងទាំងឡាយមិនដឹងទេ អាវុសោ ។ លំដាប់នោះ ចោរទាំងនោះនិយាយថា ទឹកសម្រាប់ផឹករបស់ភិក្ខុទាំងនេះក៏គ្មាន ទឹកសម្រាប់ប្រើប្រាស់ក៏គ្មាន ភ្លើងក៏គ្មាន ឈើពន្លួតភ្លើងក៏គ្មាន ផ្កាយនក្ខត្តឫក្សក៏មិនដឹង ចំណែកនៃទិសក៏មិនស្គាល់ ពួកនេះជាចោរទេតើ ពួកនេះមិនមែនជាភិក្ខុទេឡើយ ថាហើយក៏នាំគ្នាវាយហើយដើរចេញទៅ ។ លំដាប់នោះ ភិក្ខុទាំងនោះបានប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយបានយកសេចក្តីនុ៎ះ ក្រាបបង្គំទូលចំពោះព្រះមានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះតថាគតនឹងបញ្ញត្តវត្តដល់អារញ្ញកភិក្ខុទាំងឡាយ (ភិក្ខុអ្នកនៅក្នុងព្រៃ)តាមទំនងដែលអារញ្ញកភិក្ខុទាំងឡាយគប្បីប្រព្រឹត្តដោយប្រពៃបាន។

(៩៣) ម្នាលភិក្ខុទាំងឡាយ (អារញ្ញកភិក្ខុ) ត្រូវក្រោកឡើងអំពីព្រឹកព្រហាម ហើយប្រកបបាត្រក្នុងស្បោក រួបស្ពាយលើស្មា ធ្វើចីពរឲ្យនៅលើ-ក ពាក់ស្បែកជើងហើយរៀបចំទុកដាក់គ្រឿងឈើនិងគ្រឿង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



## វត្តក្ខន្ធកេ អារញ្ញកវត្តំ

មត្តិកាភណ្ឌំ បដិសាមេត្វា ទ្វារវាតបានំ ថកេត្វា សេ-
នាសនា ឱតរិតព្វំ ឥទានិ គាមំ បវិសិស្សាមីតិ ឧបា-
ហនា ឱមុញ្ចិត្វា នីចំ កត្វា បប្ផោដេត្វា ថវិកាយ
បក្ខិបិត្វា អំសេ អាលគ្គេត្វា តិមណ្ឌលំ បដិច្ឆាទេន្តេន
បរិមណ្ឌលំ និវាសេត្វា កាយពន្ធនំ ពន្ធិត្វា សគុណំ
កត្វា សង្ឃាដិយោ បារុបិត្វា គណ្ឋិកំ បដិមុញ្ចិត្វា
ធោវិត្វា បត្តំ គហេត្វា សាធុកំ អតរមានេន គាមោ
បវិសិតព្វោ សុបដិច្ឆន្នេន អន្តរឃរេ គន្តព្វំ សុសំវុតេន
អន្តរឃរេ គន្តព្វំ ។ បេ ។ ន ឧក្កុដិកាយ អន្តរឃរេ
គន្តព្វំ និវេសនំ បវិសន្តេន សល្លក្ខេតព្វំ ឥមិនា បវិ-
សិស្សាមិ ឥមិនា និក្ខមិស្សាមីតិ នាតិសហសា បវិ-
សិតព្វំ នាតិសហសា និក្ខមិតព្វំ នាតិទូរេ ឋាតព្វំ
នាច្ចាសន្នេ ឋាតព្វំ នាតិចិរំ ឋាតព្វំ នាតិលហុកំ និវត្តិ-
តព្វំ ឋិតកេន សល្លក្ខេតព្វំ ភិក្ខំ ទាតុកាមា វា អទា-
តុកាមា វាតិ សចេ កម្មំ វា និក្ខិបតិ អាសនា វា វុដ្ឋាតិ
កដច្ឆុំ វា បរាមសតិ ភាជនំ វា បរាមសតិ ឋបេតិ
វា ទាតុកាមិយាតិ ឋាតព្វំ ភិក្ខាយ ទីយមានាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ អារញ្ញកវត្ត

ដ៏បិទទ្វារនឹងបង្អួច រួចហើយចុះពីទីសេនាសនៈ ដោយគិតថា អាត្មាអញនឹងចូលទៅកាន់ស្រុកក្នុងកាលឥឡូវនេះ ត្រូវដោះស្បែកជើង ហើយបន្ទាបគោះប្រកដាក់ក្នុងស្បោកបាត្រហើយស្ពាយលើស្មា បិទបាំងកាយឲ្យមានមណ្ឌលបី ស្លៀកស្បង់ឲ្យជាបរិមណ្ឌល ក្រវាត់សម្ពត់កាយពន្ធន៍ តម្រួតឧត្តរាសង្គៈនឹងសង្ឃាដិ ហើយឃ្នុំពាក់ក្ដុំហើយដូតបាត្រកាន់ដើរចូលទៅក្នុងស្រុកដោយស្រួល មិនរលះរលាំង អារញ្ញកភិក្ខុ ត្រូវបិទបាំងកាយឲ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវសង្រួមប្រយ័ត្នដោយល្អដើរទៅក្នុងចន្លោះផ្ទះ ។ បេ ។ មិនត្រូវបំអើតជើង ដើរទៅក្នុងចន្លោះផ្ទះ កាលបើនឹងចូលទៅកាន់លំនៅគេ ត្រូវកំណត់ទុកក្នុងចិត្តថា អាត្មាអញនឹងចូលទៅ តាមផ្លូវនេះ នឹងចេញមកវិញ តាមផ្លូវនេះ មិនត្រូវចូលទៅដោយរហ័សពេក មិនត្រូវចេញមកវិញ ដោយរហ័សពេក មិនត្រូវឈរ ក្នុងទីឆ្ងាយពេក មិនត្រូវឈរ ក្នុងទីជិតពេក មិនត្រូវឈរយូរពេក មិនត្រូវត្រឡប់មករហ័សពេក ត្រូវឈរសង្កេតមើលថា គេចង់ឲ្យបង្ហាន់ ឬមិនចង់ឲ្យទេ បើគេបញ្ឈប់ការងារក្ដី ក្រោកអំពីអាសនៈក្ដី ចាប់កាន់វែកក្ដី ចាប់កាន់ភាជន៍ក្ដី គេចង់ប្រគេនបង្ហាន់ហើយនិមន្តឲ្យរង់ចាំក្ដី ភិក្ខុដឹងដូច្នេះហើយ គប្បីរង់ចាំ កាលបើគេប្រគេនបង្ហាន់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។




វាមេន ហត្ថេន សង្ឃាដឹ ឧច្ចារេត្វា ទក្ខិណេន ហត្ថេន បត្តំ បណាមេត្វា ឧភោហិ ហត្ថេហិ បត្តំ បដិគ្គហេត្វា ភិក្ខា បដិគ្គហេតព្វា ន ច ភិក្ខាទាយិកាយ មុខំ ឱលោកេតព្វំ សល្លក្ខេតព្វំ សូបំ វា ទាតុកាមា វា អទាតុកាមា វាតិ សចេ កដច្ឆុំ វា បរាមសតិ ភាជនំ វា បរាមសតិ ឋបេតិ វា ទាតុកាមស្សាតិ ឋាតព្វំ ភិក្ខាយ ទិន្នាយ សង្ឃាដិយា បត្តំ បដិច្ឆាទេត្វា សាធុកំ អតរមានេន និវត្តិតព្វំ សុប្បដិច្ឆន្នេន អន្តរឃរេ គន្តព្វំ ។បេ។ ន ឧក្កុដិកាយ អន្តរឃរេ គន្តព្វំ គាមតោ និក្ខមិត្វា បត្តំ ថវិកាយ បក្ខិបិត្វា អំសេ អាលគ្គេត្វា ចីវរំ សំហរិត្វា សីសេ ករិត្វា ឧបាហនា អារោហិត្វា គន្តព្វំ អារញ្ញកេន ភិក្ខុនា បានីយំ ឧបដ្ឋាបេតព្វំ បរិភោជនីយំ ឧបដ្ឋាបេតព្វំ អគ្គិ ឧបដ្ឋាបេតព្វោ អរណិសហិតំ ឧបដ្ឋាបេតព្វំ កត្តរទណ្ឌោ ឧបដ្ឋាបេតព្វោ នក្ខត្តបទានិ ឧគ្គហេតព្វានិ សកលានិ វា ឯកទេសានិ វា ទិសាកុសលេន ភវិតព្វំ ឥទំ ខោ ភិក្ខវេ អារញ្ញកានំ ភិក្ខូនំ វត្តំ យថា អារញ្ញកេហិ ភិក្ខូហិ សម្មា វត្តិតព្វន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ត្រូវយកដៃឆ្វេងវែកសង្ឃាដិ យកដៃស្តាំបង្អោនបាត្រហើយទ្របាត្រដោយដៃទាំងពីរទទួលយកបង្ហាន់ តែកុំសំឡឹងមើលមុខស្ត្រីដែលប្រគេនបង្ហាន់ឡើយ ត្រូវសង្កេតពិនិត្យមើលថា គេបង់ប្រគេនសម្លឬមិនបង់ប្រគេនទេ បើគេចាប់កាន់វែកក្តី ចាប់កាន់ភាជន៍ក្តី គេបង់ប្រគេនហើយនិមន្តឲ្យរង់ចាំក្តី ភិក្ខុដឹងដូច្នេះហើយត្រូវរង់ចាំ កាលបើគេប្រគេនបង្ហាន់ហើយត្រូវយកសង្ឃាដិបិទបាំងបាត្រ ហើយត្រឡប់ចេញមកដោយស្រួលមិនរលះរលាំង ត្រូវបិទបាំងកាយឲ្យល្អដើរទៅក្នុងចន្លោះផ្ទះ ។ បេ ។ មិនត្រូវបំអើតជើងដើរទៅក្នុងចន្លោះផ្ទះ កាលបើត្រឡប់ចេញមកពីស្រុកវិញហើយត្រូវប្រែកបាត្រក្នុងស្បោក ហើយស្ពាយលើស្មា ហើយប្រមូលចីពរទូលលើក្បាលហើយពាក់ស្បែកជើងដើរទៅ ម្នាលភិក្ខុទាំងឡាយ អារញ្ញកភិក្ខុត្រូវដងទឹកសម្រាប់ឆាន់ទុក ត្រូវដងទឹកសម្រាប់ប្រើប្រាស់ទុក ត្រូវដម្កល់ទុកនូវភ្លើង ត្រូវដម្កល់ទុកនូវឈើពិនួតភ្លើង ត្រូវដម្កល់ទុកនូវឈើច្រត់ ត្រូវរៀននូវផ្កាយនក្ខត្តឫក្ស ទាំងអស់ឬដោយឯកទេស គួរជាអ្នកឈ្លាសវៃក្នុងទិស ម្នាលភិក្ខុទាំងឡាយ ទាំងនេះជាវត្តរបស់អារញ្ញកភិក្ខុទាំងឡាយ តាមទំនងដែលអារញ្ញកភិក្ខុទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ សេនាសនវត្តំ

[៩៤] តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ អជ្ឈោកាសេ ចីវរកម្មំ ករោន្តិ ។ ឆព្វគ្គិយា ភិក្ខូ បដិវាតេ បង្គណេ[១] សេនាសនំ បប្ផោដេសុំ[២] ។ ភិក្ខូ រជេន ឱកិរិយឹសុ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ បដិវាតេ បង្គណេ សេនាសនំ បប្ផោដេស្សន្តិ[៣] ភិក្ខូ រជេន ឱកិរិយិស្សន្តីតិ[៤] ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខូ បដិវាតេ បង្គណេ សេនាសនំ បប្ផោដេន្តិ ភិក្ខូ រជេន ឱកិរិយឹសូតិ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ ភិក្ខូនំ សេនាសនវត្តំ បញ្ញាបេស្សាមិ យថា ភិក្ខូហិ សេនាសនេ សម្មា វត្តិតព្វំ ។

---

១ ម. អង្គណេ ។ ២ ឱ. បប្ផោឋេសុំ ។ ម. បប្ផោដេសុំ ។ ៣ ឱ. បប្ផោឋេស្សន្តិ ។ ម. បប្ផោដេស្សន្តិ ។ ៤ ឱ. ម. ឱកិរីសូតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ សេនាសនវត្ត

(៩៤) សម័យនោះឯង មានភិក្ខុច្រើនរូបធ្វើចីវរកម្មក្នុងទីវាល ។ ពួកឆព្វគ្គិយភិក្ខុគោះគ្រឿងសេនាសនៈ ក្នុងទីធ្លាដែលជាទីប្រាសខ្យល់ ។ ភិក្ខុទាំងឡាយប្រឡាក់ដោយធូលី ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនសមបើនឹងគោះគ្រឿងសេនាសនៈក្នុងទីធ្លាដែលជាទីប្រាសខ្យល់ ឲ្យភិក្ខុទាំងឡាយប្រឡាក់ដោយធូលីសោះឡើយ ។ ភិក្ខុទាំងឡាយនោះ បានយកសេចក្តីនុ៎ះ ក្រាបបង្គំទូលព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថាពួកឆព្វគ្គិយភិក្ខុគោះគ្រឿងសេនាសនៈក្នុងទីធ្លាដែលជាទីប្រាសខ្យល់ ឲ្យភិក្ខុទាំងឡាយប្រឡាក់ដោយធូលី ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ បេ ។ លុះទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសេនាសនវត្ត ដល់ភិក្ខុទាំងឡាយ តាមទំនងដែលភិក្ខុទាំងឡាយ គប្បីប្រព្រឹត្តដោយប្រពៃ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



[៩៨] យស្មឹ វិហារេ វិហរតិ សចេ សោ វិហារោ ឧក្លាបោ ហោតិ សចេ ឧស្សហតិ សោធេតព្វោ វិហារំ សោធេន្តេន បឋមំ បត្តចីវរំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ និសីទនបច្ចត្ថរណំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ ភិសិ-ពិម្ពោហនំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ មញ្ចោ នីចំ កត្វា សាធុកំ អបរិឃំសន្តេន អសង្ឃដ្តេន្តេន កវាដបិដ្ឋំ នីហ-រិត្វា ឯកមន្តំ និក្ខិបិតព្វោ បីឋំ នីចំ កត្វា សាធុកំ អប-រិឃំសន្តេន អសង្ឃដ្តេន្តេន កវាដបិដ្ឋំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ មញ្ចបដិបាទកា នីហរិត្វា ឯកមន្តំ និក្ខិបិ-តព្វា ខេឡមល្លកោ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វោ អ-បស្សេនផលកំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ ភុម្មត្ថរណំ យថាបញ្ញត្តំ សល្លក្ខេត្វា នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ សចេ វិហារេ សន្តានកំ ហោតិ ឧល្លោកា[១] បឋមំ ឱហារេតព្វំ អាលោកសន្ធិកណ្ណភាគា បមជ្ជិតព្វា ស-ចេ គេរុកបរិកម្មកតា ភិត្តិ កណ្ណកិតា ហោតិ ចោ-ឡកំ តេមេត្វា បីឡេត្វា បមជ្ជិតព្វា សចេ កាឡ-វណ្ណកតា ភូមិ កណ្ណកិតា ហោតិ ចោឡកំ តេមេត្វា

១ ម. ឧល្លោកោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## វិនយបិដក ចុល្លវគ្គ

(៩៤) ភិក្ខុនៅក្នុងវិហារណា បើវិហារៈនោះមានសម្រាម បើអាច (សំអាតបាន) ក៏ត្រូវសំអាត កាលដែលនឹងសំអាតវិហារ ត្រូវយកបាត្រនឹងចីវរទៅទុកក្នុងទីដ៏សមគួរជាមុន ហើយត្រូវយកនិសីទនៈនឹងកម្រាលទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកពូកនឹងខ្នើយទៅទុកក្នុងទីដ៏សមគួរ ត្រូវលើកបន្ទាបគ្រែឲ្យស្រួលកុំឲ្យទង្គិចទង្គុក កុំឲ្យប៉ះសន្ទះទ្វារនឹងក្របទ្វារ នាំយកទៅទុកក្នុងទីដ៏សមគួរ ត្រូវលើកបន្ទាបតាំងឲ្យស្រួលកុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារនឹងក្របទ្វារនាំយកទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកទ្រនាប់ជើងគ្រែទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកកន្ធោរសម្រាប់ស្ដោះទឹកមាត់ទៅទុកក្នុងទីដ៏សមគួរ ត្រូវនាំយកក្ដារសម្រាប់ផ្អែកទៅទុកក្នុងទីដ៏សមគួរ ត្រូវកំណត់ទីដែលគេក្រាលកម្រាលផែនដីយ៉ាងណា ហើយនាំយកទៅទុកក្នុងទីដ៏សមគួរ បើក្នុងវិហារស្មុកស្មាញ (មិនស្អាតដោយសារសែពីងពាងជាដើម) ភិក្ខុត្រូវបោសតាំងពីពិតានជាមុន ចំណែកជ្រុងសន្ទះបង្អួចត្រូវជូតសំអាត បើជញ្ជាំងដែលគេលាបដោយថ្នាំ មានសៅហ្មងពណ៌សម្បុរ ត្រូវជ្រលក់កំណាត់សម្ពត់ពូតហើយសឹមជូត បើទីផ្ទៃដែលគេធ្វើដោយវត្ថុមានពណ៌ខ្មៅ មានសៅហ្មងពណ៌សម្បុរ ត្រូវជ្រលក់កំណាត់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ សេនាសនវត្តំ

បីឡេត្វា បមជ្ជិតព្វា សចេ អកតា ហោតិ ភូមិ ឧទ-
កេន បរិប្ផោសិត្វា សម្មជ្ជិតព្វា មា វិហារោ រជេន
ឧហញ្ញីតិ សង្ការំ វិចិនិត្វា ឯកមន្តំ ឆឌ្ឌេតព្វំ ន ភិក្ខុ-
សាមន្តា សេនាសនំ បប្ផោដេតព្វំ ន វិហារសាមន្តា
សេនាសនំ បប្ផោដេតព្វំ ន បានីយសាមន្តា សេនា-
សនំ បប្ផោដេតព្វំ ន បរិភោជនីយសាមន្តា សេនា-
សនំ បប្ផោដេតព្វំ ន បដិវាតេ បង្គណេ(១) សេនាស-
នំ បប្ផោដេតព្វំ អធោវាតេ សេនាសនំ បប្ផោដេតព្វំ
ភុម្មត្ថរណំ ឯកមន្តំ ឱតាបេត្វា សោធេត្វា បប្ផោដេត្វា
អតិហរិត្វា យថាបញ្ញត្តំ បញ្ញាបេតព្វំ មញ្ចបដិបាទកា
ឯកមន្តំ ឱតាបេត្វា បមជ្ជិត្វា អតិហរិត្វា យថាឋានេ
ឋបេតព្វា មញ្ចោ ឯកមន្តំ ឱតាបេត្វា សោធេត្វា
បប្ផោដេត្វា នីចំ កត្វា សាធុកំ អប្បដិឃំសន្តេន
អសង្ឃដ្ដេន្តេន កវាដបិដ្ឋំ អតិហរិត្វា យថាបញ្ញត្តំ
បញ្ញាបេតព្វោ បីឋំ ឯកមន្តំ ឱតាបេត្វា សោធេត្វា
បប្ផោដេត្វា នីចំ កត្វា សាធុកំ អប្បដិឃំសន្តេន

---

១ ឱ. ម. អង្គណេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ សេនាសនវត្ត

សម្ពត់ពូតរួចសឹមជូត បើទីផ្ទៃគេមិនធ្វើទេ ភិក្ខុត្រូវប្រស់ដោយទឹកហើយ សឹមជូតដោយគិតថា កុំឲ្យវិហារប្រឡាក់ដោយធូលីឡើយ ត្រូវប្រមូលសម្រាមទៅចោលក្នុងទីដ៏សមគួរ មិនត្រូវគោះគ្រឿងសេនាសនៈជិតភិក្ខុផងគ្នា មិនត្រូវគោះគ្រឿងសេនាសនៈជិតវិហារ មិនត្រូវគោះគ្រឿងសេនាសនៈជិតទឹកសម្រាប់ឆាន់ មិនត្រូវគោះគ្រឿងសេនាសនៈជិតទឹកសម្រាប់ប្រើប្រាស់ មិនត្រូវគោះគ្រឿងសេនាសនៈ ក្នុងឆ្លាដែលជាទីប្រាសខ្យល់ ត្រូវគោះគ្រឿងសេនាសនៈ ក្នុងទីក្រោមខ្យល់ ត្រូវហាលកម្រាលផែនដីហើយជម្រះគោះ ក្នុងទីដ៏សមគួរ រួចសារយកមកក្រាលដូចដើមវិញ ត្រូវហាលទ្រនាប់ជើងគ្រែ ហើយជូតសំអាត ក្នុងទីដ៏សមគួរ រួចនាំយកមកដម្កល់ទុកដូចដែលវិញ ត្រូវហាលគ្រែហើយជម្រះគោះក្នុងទីដ៏សមគួរ ហើយលើកបន្ទាបឲ្យស្រួល កុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារនឹងក្របទ្វារ រួចនាំយកទៅទុកដូចដើមវិញ ត្រូវហាលតាំងហើយជម្រះគោះក្នុងទីដ៏សមគួរ ហើយលើកបន្ទាបឲ្យស្រួល កុំឲ្យទង្គិច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អសង្ឃដ្តេន្តេន កវាដបិដ្ឋំ អភិហរិត្វា យថាបញ្ញត្តំ
បញ្ញាបេតព្វំ ភិសិពិម្ពោហនំ ឯកមន្តំ ឱតាបេត្វា សោ-
ធេត្វា បប្ផោដេត្វា អភិហរិត្វា យថាបញ្ញត្តំ បញ្ញាបេតព្វំ
និសីទនបច្ចត្ថរណំ ឯកមន្តំ ឱតាបេត្វា សោធេត្វា
បប្ផោដេត្វា អភិហរិត្វា យថាបញ្ញត្តំ បញ្ញាបេតព្វំ ខេ-
ឡមល្លកោ ឯកមន្តំ ឱតាបេត្វា បមជ្ជិត្វា អភិហ-
រិត្វា យថាឋានេ ឋបេតព្វោ អបស្សេនផលកំ ឯក-
មន្តំ ឱតាបេត្វា បមជ្ជិត្វា អភិហរិត្វា យថាឋានេ ឋបេ-
តព្វំ បត្តចីវរំ និក្ខិបិតព្វំ បត្តំ និក្ខិបន្តេន ឯកេន ហត្ថេន
បត្តំ គហេត្វា ឯកេន ហត្ថេន ហេដ្ឋាមញ្ចំ វា
ហេដ្ឋាបីឋំ វា បរាមសិត្វា បត្តោ និក្ខិបិតព្វោ ន ច
អនន្តរហិតាយ ភូមិយា បត្តោ និក្ខិបិតព្វោ ចីវរំ និក្ខិ-
បន្តេន ឯកេន ហត្ថេន ចីវរំ គហេត្វា ឯកេន
ហត្ថេន ចីវរវំសំ វា ចីវររជ្ជុំ វា បមជ្ជិត្វា បារតោ អន្តំ
ឱរតោ ភោគំ កត្វា ចីវរំ និក្ខិបិតព្វំ សចេ បុរត្ថិមា
សរជា វាតា វាយន្តិ បុរត្ថិមា វាតបានា ថកេតព្វា
សចេ បច្ឆិមា សរជា វាតា វាយន្តិ បច្ឆិមា វាតបានា

## វិនយបិដក ចុល្លវគ្គ

កុំឲ្យប៉ះសន្ទះទ្វារនឹងគ្របទ្វារ រួចនាំយកមកទុកដូចដើមវិញ ត្រូវហាលពូកខ្នើយ ហើយជម្រះគោះ ក្នុងទីដ៏សមគួរ រួចនាំយកមករៀបចំទុកដូចដើមវិញ ត្រូវហាលកម្រាលសម្រាប់អង្គុយ ហើយជម្រះគោះ ក្នុងទីដ៏សមគួរ រួចសារយកមកក្រាលទុកដូចដើមវិញ ត្រូវហាលកន្ធោរសម្រាប់ស្តោះទឹកមាត់ក្នុងទីដ៏សមគួរ ហើយដូតរួចនាំយកមកទុកដូចដែលវិញ ត្រូវហាលផែនក្តារសម្រាប់ផ្អែក ក្នុងទីដ៏សមគួរ ហើយដូតរួចនាំយកមកទុកដូចដែលវិញ ត្រូវទុកដាក់បាត្រនិងចីវរ កាលដែលទុកដាក់បាត្រ ត្រូវកាន់បាត្រដោយដៃម្ខាង ហើយស្ទាបខាងក្រោមគ្រែ ឬខាងក្រោមតាំងដោយដៃម្ខាងសិន សឹមទុកដាក់បាត្រចុះ តែថាមិនត្រូវទុកដាក់បាត្រក្នុងទីដែលមិនស្អាតឡើយ កាលដែលនឹងទុកចីវរ ត្រូវកាន់ចីវរដោយដៃម្ខាង ហើយដូតស្នួរចីវរ ឬខ្សែស្បៀងដោយដៃម្ខាង ហើយធ្វើជាយខាងនាយឲ្យជាផ្ទត់មកខាងអាយសិន សឹមទុកចីវរចុះ បើមានខ្យល់ប្រកបដោយធូលីបក់មកអំពីទិសខាងកើត ភិក្ខុត្រូវបិទបង្អួចទិសខាងកើត បើមានខ្យល់ប្រកបដោយធូលី បក់មកពីទិសខាងលិច ត្រូវបិទបង្អួចទិសខាងលិច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ សេនាសនវត្តំ

ថកេតព្វា សចេ ឧត្តរា សរជា វាតា វាយន្តិ ឧត្តរា វាតបានា ថកេតព្វា សចេ ទក្ខិណា សរជា វាតា វា-យន្តិ ទក្ខិណា វាតបានា ថកេតព្វា សចេ សីតកាលោ ហោតិ ទិវា វាតបានា វិវរិតព្វា រត្តឹ ថកេតព្វា សចេ ឧ-ណ្ហកាលោ ហោតិ ទិវា វាតបានា ថកេតព្វា រត្តឹ វិវរិតព្វា សចេ បរិវេណំ ឧក្លាបំ ហោតិ បរិវេណំ សម្មជ្ជិតព្វំ សចេ កោដ្ឋកោ ឧក្លាបោ ហោតិ កោដ្ឋកោ សម្មជ្ជិតព្វោ សចេ ឧបដ្ឋានសាលា ឧក្លាបា ហោតិ ឧបដ្ឋានសាលា សម្មជ្ជិតព្វា សចេ អគ្គិសាលា ឧក្លាបា ហោតិ អគ្គិសា-លា សម្មជ្ជិតព្វា សចេ វច្ចកុដិ ឧក្លាបា ហោតិ វច្ចកុដិ សម្មជ្ជិតព្វា សចេ បានីយំ ន ហោតិ បានីយំ ឧបដ្ឋាបេ-តព្វំ សចេ បរិភោជនីយំ ន ហោតិ បរិភោជនីយំ ឧបដ្ឋា-បេតព្វំ សចេ អាចមនកុម្ភិយោ ឧទកំ ន ហោតិ អាចមនកុម្ភិយោ ឧទកំ អាសិញ្ចិតព្វំ សចេ វុឌ្ឍេន សទ្ធឹ ឯកវិហារេ វិហរតិ ន វុឌ្ឍំ អនាបុច្ឆា ឧទ្ទេសោ ទាតព្វោ ន បរិបុច្ឆា ទាតព្វា ន សជ្ឈាយោ កាតព្វោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## វត្តក្ខន្ធកៈ សេនាសនវត្ត

បើមានខ្យល់ប្រកបដោយធូលី បក់មកពីទិសខាងជើង ត្រូវបិទបង្អួចទិសខាងជើង បើមានខ្យល់ប្រកបដោយធូលី បក់មកពីទិសខាងត្បូង ត្រូវបិទបង្អួចទិសខាងត្បូង បើរដូវត្រជាក់ ភិក្ខុត្រូវបើកបង្អួចក្នុងវេលាថ្ងៃ បិទក្នុងវេលាយប់ បើរដូវក្តៅ ត្រូវបិទបង្អួចក្នុងវេលាថ្ងៃ បើកបង្អួចក្នុងវេលាយប់ បើបរិវេណមានសម្រាម ត្រូវបោសបរិវេណចេញ បើបន្ទប់ទឹកមានសម្រាម ត្រូវបោសបន្ទប់ទឹកចេញ បើឧបដ្ឋានសាលាមានសម្រាម ត្រូវបោសឧបដ្ឋានសាលាចេញ បើរោងភ្លើងមានសម្រាម ត្រូវបោសរោងភ្លើងចេញ បើបង្គន់មានសម្រាម ត្រូវបោសបង្គន់ចេញ បើមិនមានទឹកសម្រាប់ឆាន់ ត្រូវដងទឹកសម្រាប់ឆាន់ទុក បើមិនមានទឹកសម្រាប់ប្រើប្រាស់ ភិក្ខុត្រូវដងទឹកសម្រាប់ប្រើប្រាស់ទុក បើមិនមានទឹកក្នុងឆ្នាំងសម្រាប់ជម្រះ ត្រូវចាក់ទឹកក្នុងឆ្នាំងសម្រាប់ជម្រះទុក បើភិក្ខុថ្មីនៅក្នុងវិហារមួយជាមួយនឹងភិក្ខុចាស់ មិនទាន់បានអនុញ្ញាតពីភិក្ខុចាស់ទេ មិនត្រូវបង្រៀនបាលី មិនត្រូវបង្រៀនអដ្ឋកថា មិនត្រូវធ្វើស្វាធ្យាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



ន ធម្មោ ភាសិតព្វោ ន បទីបោ កាតព្វោ ន បទីបោ វិជ្ឈាបេតព្វោ ន វាតបានា វិវរិតព្វា ន វាតបានា ថកេតព្វា សចេ វុឌ្ឍេន សទ្ធឹ ឯកចង្កមេ ចង្កមតិ យេន វុឌ្ឍោ តេន បរិវត្តិតព្វំ ន ច វុឌ្ឍោ សង្ឃាដិកណ្ណេន ឃដ្ដេតព្វោ ឥទំ ខោ ភិក្ខវេ ភិក្ខូនំ សេនាសនវត្តំ យថា ភិក្ខូហិ សេនាសនេ សម្មាវត្តិតព្វន្តិ ។

[៩៦] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ជន្តាឃរេ ថេរេហិ ភិក្ខូហិ និវារិយមានា អនាទរិយំ បដិច្ច ពហុំ កដ្ឋំ អារោបេត្វា អគ្គឹ ទត្វា ទ្វារំ ថកេត្វា ទ្វារេ និសីទន្តិ ។ ថេរា ច[១] ភិក្ខូ ឧណ្ហាភិតត្តា ទ្វារំ អលភមានា មុច្ឆិតា បបតន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ជន្តាឃរេ ថេរេហិ ភិក្ខូហិ និវារិយមានា អនាទរិយំ បដិច្ច ពហុំ កដ្ឋំ អារោបេត្វា អគ្គឹ ទត្វា ទ្វារំ ថកេត្វា ទ្វារេ និសីទិស្សន្តិ ថេរា ច ភិក្ខូ ឧណ្ហាភិតត្តា ទ្វារំ អលភមានា មុច្ឆិតា បបតន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។

---

១ ឱ· ម· បោត្ថកេសុ ថេរា ចាតិ បទទ្វយំ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



មិនត្រូវសំដែងធម៌ មិនត្រូវអុជចង្កៀង មិនត្រូវលត់ចង្កៀង មិនត្រូវបើកបង្អួច មិនត្រូវបិទបង្អួចឡើយ បើភិក្ខុខ្ចីដើរចង្ក្រមក្នុងទីចង្ក្រមមួយជាមួយនឹងភិក្ខុចាស់ ភិក្ខុចាស់ចង្ក្រមតាមផ្លូវណា ភិក្ខុខ្ចីត្រូវដើរចៀសពីផ្លូវនោះ តែកុំឲ្យជាយសង្ឃាដីប៉ះភិក្ខុចាស់ឡើយ ម្នាលភិក្ខុទាំងឡាយ ទាំងនេះជាសេនាសនវត្តរបស់ភិក្ខុទាំងឡាយ តាមទំនងដែលភិក្ខុទាំងឡាយត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងសេនាសនៈ ។

(៩៦) សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ កាលដែលភិក្ខុទាំងឡាយជាថេរៈហាមប្រាមក្នុងផ្ទះជាទីរក្សាកាយ ក៏នៅតែមិនអើពើ នាំគ្នាគរឧសច្រើនបង្កាត់ភ្លើង ហើយបិទទ្វារអគ្គិយនៅត្រង់ទ្វារ ។ ជួនជាភិក្ខុទាំងឡាយជាថេរៈ ត្រូវកំដៅបៀតបៀនខ្លាំងណាស់ ហើយរកទ្វារចេញមកមិនបានក៏ជ្រប់ដួលទៅ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើពួកឆព្វគ្គិយភិក្ខុ កាលដែលភិក្ខុទាំងឡាយជាថេរៈហាមឃាត់ក្នុងផ្ទះជាទីរក្សាកាយក៏នៅតែមិនអើពើ នាំគ្នាគរឧសជាច្រើនបង្កាត់ភ្លើង ហើយបិទទ្វារអគ្គិយនៅត្រង់ទ្វារនោះ ជួនជាភិក្ខុទាំងឡាយជាថេរៈត្រូវកំដៅខ្លាំងណាស់ហើយរកទ្វារចេញមកមិនបានក៏ជ្រប់ដួលទៅ ។ គ្រានោះ ភិក្ខុទាំងនោះបានក្រាបបង្គំទូលដំណើរនោះចំពោះព្រះមានព្រះភាគ ។ បេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ ជន្តាឃរវត្តំ

សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខូ ជន្តាឃរេ ថេរេហិ ភិក្ខូហិ និវារិយមានា អនាទរិយំ បដិច្ច ពហុំ កដ្ឋំ អារោបេត្វា អគ្គឹ ទត្វា ទ្វារំ ថកេត្វា ទ្វារេ និសីទន្តិ ភិក្ខូ ឧណ្ហាភិតត្តា ទ្វារំ អលភមានា មុច្ឆិតា បបតន្តីតិ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ ជន្តាឃរេ ថេរេន ភិក្ខុនា និវារិយមានេន អនាទរិយំ បដិច្ច ពហុំ កដ្ឋំ អារោបេត្វា អគ្គិ ទាតព្វោ យោ ទទេយ្យ អាបត្តិ ទុក្កដស្ស ន ច ភិក្ខវេ ទ្វារំ ថកេត្វា ទ្វារេ និសីទិតព្វំ យោ និសីទេយ្យ អាបត្តិ ទុក្កដស្ស តេនហិ ភិក្ខវេ ភិក្ខូនំ ជន្តាឃរវត្តំ បញ្ញាបេស្សាមិ យថា ភិក្ខូហិ ជន្តាឃរេ សម្មា វត្តិតព្វំ ។

[៩៧] យោ បឋមំ ជន្តាឃរំ គច្ឆតិ សចេ ឆារិកា ឧស្សន្នា ហោតិ ឆារិកា ឆឌ្ឌេតព្វា សចេ ជន្តាឃរំ ឧក្លាបំ ហោតិ ជន្តាឃរំ សម្មជ្ជិតព្វំ សចេ បរិភណ្ឌំ ឧក្លាបំ ហោតិ បរិភណ្ឌំ សម្មជ្ជិតព្វំ សចេ បរិវេណំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ ជន្តាឃរវត្ត

ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកឆព្វគ្គិយភិក្ខុ កាលដែលភិក្ខុទាំងឡាយជាថេរៈហាមឃាត់ក្នុងផ្ទះជាទីរក្សាកាយ ក៏នៅតែមិនអើពើ នាំគ្នាមកគរឧសជាច្រើនបង្កាត់ភ្លើង ហើយបិទទ្វារអង្គុយនៅត្រង់ទ្វារ ភិក្ខុទាំងឡាយជាថេរៈត្រូវកំដៅបៀតបៀនខ្លាំងណាស់ រកទ្វារចេញមកមិនបានក៏ជ្រប់ដួលទៅ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ បេ ។ លុះទ្រង់បន្ទោសរួចហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ (បើ) ភិក្ខុជាថេរៈហាមឃាត់ក្នុងផ្ទះជាទីរក្សាកាយហើយ មិនត្រូវនាំគ្នាគរឧសជាច្រើនបង្កាត់ភ្លើង ព្រោះអាស្រ័យសេចក្តីមិនអើពើទេ ភិក្ខុណាបង្កាត់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុមិនត្រូវបិទទ្វារហើយអង្គុយនៅត្រង់ទ្វារឡើយ ភិក្ខុណាអង្គុយ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តជន្តាឃរវត្តដល់ភិក្ខុទាំងឡាយ តាមទំនងដែលភិក្ខុទាំងឡាយគប្បីប្រព្រឹត្តដោយប្រពៃ ក្នុងផ្ទះជាទីរក្សាកាយ ។

(៩៧) ភិក្ខុណាទៅកាន់ផ្ទះជាទីរក្សាកាយមុនគេ បើមានផេះនៅគគកុញ ភិក្ខុនោះត្រូវកើបផេះចោលចេញ បើផ្ទះជាទីរក្សាកាយមានសម្រាម ត្រូវបោសផ្ទះជាទីរក្សាកាយចេញ បើលានខាងក្រៅ (ផ្ទះជាទីរក្សាកាយ) មានសម្រាម ត្រូវបោសលានខាងក្រៅចេញ បើបរិវេណ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឧក្លាបំ ហោតិ បរិវេណំ សម្មជ្ជិតព្វំ សចេ កោដ្ឋកោ
ឧក្លាបោ ហោតិ កោដ្ឋកោ សម្មជ្ជិតព្វោ សចេ ជន្តា-
ឃរសាលា ឧក្លាបា ហោតិ ជន្តាឃរសាលា សម្មជ្ជិ-
តព្វា ចុណ្ណំ សន្នេតព្វំ មត្តិកា តេមេតព្វា ឧទកទោ-
ណិកាយ ឧទកំ អាសិញ្ចិតព្វំ ជន្តាឃរំ បវិសន្តេន
មត្តិកាយ មុខំ មក្ខេត្វា បុរតោ ច បច្ឆតោ ច បដិច្ឆា-
ទេត្វា ជន្តាឃរំ បវិសិតព្វំ ន ថេរេ ភិក្ខូ អនុបខជ្ជ
និសីទិតព្វំ ន នវា ភិក្ខូ អាសនេន បដិពាហិតព្វា
សចេ ឧស្សហតិ ជន្តាឃរេ ថេរានំ ភិក្ខូនំ បរិកម្មំ
កាតព្វំ ជន្តាឃរា និក្ខមន្តេន ជន្តាឃរបីឋំ អាទាយ
បុរតោ ច បច្ឆតោ ច បដិច្ឆាទេត្វា ជន្តាឃរា និក្ខមិតព្វំ
សចេ ឧស្សហតិ ឧទកេបិ ថេរានំ ភិក្ខូនំ បរិកម្មំ
កាតព្វំ ន ថេរានំ ភិក្ខូនំ បុរតោបិ[១] នហាយិតព្វំ
ន ឧបរិតោបិ[២] នហាយិតព្វំ នហាតេន ឧត្តរន្តេន
ឱតរន្តានំ មគ្គោ ទាតព្វោ យោ បច្ឆា ជន្តាឃរា
និក្ខមតិ សចេ ជន្តាឃរំ ចិក្ខល្លំ ហោតិ ធោវិតព្វំ

---

១ ឱ. ម. ពោត្ថកេសុ ឥធ បិសទ្ទោ នត្ថិ ។ ២ ឱ. ម. ឧបរិតោ ។

មានសម្រាម ត្រូវបោសបរិវេណចេញ បើបន្ទប់មានសម្រាម ត្រូវបោសបន្ទប់ចេញ បើពេងនៃផ្ទះជាទីក្សាកាយមានសម្រាម ត្រូវបោសពេងនៃផ្ទះជាទីក្សាកាយចេញ ត្រូវសូនគ្រឿងលំអិតទុក ត្រូវលាយដីស្អិតទុក ត្រូវដាក់ទឹកទុកក្នុងស្នូកទឹក កាលនឹងចូលទៅកាន់ផ្ទះជាទីក្សាកាយ ត្រូវលាបមុខដោយដីស្អិត ហើយបិទបាំងទាំងខាងមុខទាំងខាងក្រោយ ហើយសឹមចូលទៅកាន់ផ្ទះជាទីក្សាកាយ មិនត្រូវអង្គុយប្រៀតបៀតពួកភិក្ខុជាថេរៈ មិនត្រូវហាមឃាត់ពួកភិក្ខុថ្មីដោយអាសនៈ បើអាច (ធ្វើបរិកម្មបាន) ត្រូវធ្វើបរិកម្មដល់ភិក្ខុទាំងឡាយជាថេរៈក្នុងផ្ទះជាទីក្សាកាយ កាលភិក្ខុនឹងចេញពីផ្ទះជាទីក្សាកាយទៅ ត្រូវនាំយកតាំងសម្រាប់ផ្ទះជាទីក្សាកាយហើយបិទបាំងទាំងខាងមុខទាំងខាងក្រោយ ហើយសឹមចេញពីផ្ទះជាទីក្សាកាយ បើភិក្ខុអាច(ធ្វើបរិកម្មបាន)សូម្បីក្នុងទឹកក៏ត្រូវធ្វើបរិកម្ម ដល់ភិក្ខុទាំងឡាយជាថេរៈបានដែរ មិនត្រូវងូតទឹកពីខាងមុខពួកភិក្ខុជាថេរៈ មិនត្រូវងូតទឹកពីខាងលើខ្សែទឹក កាលភិក្ខុងូតរួចហើយឡើងមកវិញ ត្រូវបើកផ្លូវឲ្យដល់ភិក្ខុទាំងឡាយដែលកំពុងចុះទៅ ភិក្ខុណា ចេញពីផ្ទះជាទីក្សាកាយខាងក្រោយគេ បើផ្ទះជាទីក្សាកាយមានភក់ ភិក្ខុនោះត្រូវលាងចេញ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ វច្ចកុដិវត្តនិទានំ

មត្តិកាទោណិកំ ធោវិត្វា ជន្តាឃរបីឋំ បដិសាមេត្វា អគ្គឹ វិជ្ឈាបេត្វា ទ្វារំ ថកេត្វា បក្កមិតព្វំ ឥទំ ខោ ភិក្ខវេ ភិក្ខូនំ ជន្តាឃរវត្តំ យថា ភិក្ខូហិ ជន្តាឃរេ សម្មា វត្តិតព្វន្តិ ។

[៩៨] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ព្រាហ្មណជាតិកោ វច្ចំ កត្វា ន ឥច្ឆតិ អាចមេតុំ កោ ឥមំ វសលំ ទុគ្គន្ធំ អាមសិស្សតីតិ ។ តស្ស វច្ចមគ្គេ កិមិ សណ្ឋាតិ ។ អថខោ សោ ភិក្ខុ ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ កឹ បន ត្វំ អាវុសោ វច្ចំ កត្វា ន អាចមេសីតិ ។ ឯវមាវុសោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុ វច្ចំ កត្វា ន អាចមិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ត្វំ ភិក្ខុ វច្ចំ កត្វា ន អាចមេសីតិ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ និទាននៃវច្ចកុដិវត្ត

ត្រូវលាងស្នូកសម្រាប់ដាក់ដីស្អិត ហើយរៀបចំទុកដាក់តាំងសម្រាប់ផ្ទះជាទីរក្សាកាយរួចលត់ភ្លើងហើយបិទទ្វារសើមចេញមក ម្នាលភិក្ខុទាំងឡាយ ទាំងនេះជាជន្តាឃរវត្តរបស់ភិក្ខុទាំងឡាយ តាមទំនងដែលភិក្ខុទាំងឡាយត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងផ្ទះជាទីរក្សាកាយ ។

(៩៨) សម័យនោះឯង ភិក្ខុ១រូបជាតិជាព្រាហ្មណ៍បន្ទោបង់វច្ចៈហើយ មិនប្រាថ្នាដើម្បីនឹងជម្រះចេញ ដោយគិតថា នរណានឹងហ៊ានប៉ះពាល់នូវរបស់អាក្រក់មានក្លិនស្អុយនេះ ។ ដង្កូវក៏តាំងនៅក្នុងវច្ចមគ្គ របស់ភិក្ខុនោះ ។ ភិក្ខុនោះក៏ប្រាប់សេចក្ដីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយសួរថា ម្នាលលោកដ៏មានអាយុ លោកបន្ទោបង់វច្ចៈហើយមិនជម្រះចេញទេដឹង ។ ភិក្ខុនោះប្រាប់ថា ម្នាលលោកមានអាយុ យ៉ាងហ្នឹងហើយ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើភិក្ខុបន្ទោបង់វច្ចៈហើយមិនជម្រះចេញសោះ ។ ភិក្ខុទាំងឡាយនោះក៏ក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បានឮថា អ្នកបន្ទោបង់វច្ចៈហើយមិនជម្រះចេញ ពិតមែនឬ ។ ភិក្ខុនោះក្រាបបង្គំទូលថា ពិតមែន ព្រះអង្គ ។បេ។ ព្រះមានព្រះភាគទ្រង់តិះដៀលហើយធ្វើធម្មីកថា រួចត្រាស់ហៅភិក្ខុទាំងឡាយមកថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



ន ភិក្ខវេ វច្ចំ កត្វា សតិ ឧទកេ ន អាចមេតព្វំ យោ នាចមេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(៩៩) តេន ខោ បន សមយេន ភិក្ខូ វច្ចកុដិយា យថាវុឌ្ឍំ វច្ចំ ករោន្តិ ។ នវកា ភិក្ខូ បឋមតរំ អាគន្ត្វា វច្ចិតា អាគមេន្តិ ។ តេ វច្ចំ សន្ធារេន្តា មុច្ឆិតា បបតន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខូ វច្ចកុដិយា យថាវុឌ្ឍំ វច្ចំ ករោន្តិ នវកា ភិក្ខូ បឋមតរំ អាគន្ត្វា វច្ចិតា អាគមេន្តិ តេ វច្ចំ សន្ធារេន្តា មុច្ឆិតា បបតន្តីតិ ។ សច្ចំ ភគវាតិ ។ បេ ។ ន ភិក្ខវេ វច្ចកុដិយា យថាវុឌ្ឍំ វច្ចំ កាតព្វំ យោ ករេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ អាគតបដិបាដិយា វច្ចំ កាតុន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



ម្នាលភិក្ខុទាំងឡាយ ភិក្ខុបន្ទោបង់វច្ចៈហើយ បើទឹកមាន(១) ភិក្ខុកុំគប្បីមិនជម្រះចេញ ភិក្ខុណាមិនជម្រះចេញ ត្រូវអាបត្តិទុក្កដ ។

[៩៩] សម័យនោះ ភិក្ខុទាំងឡាយបន្ទោបង់វច្ចៈក្នុងវច្ចកុដិ តាមលំដាប់ចាស់ខ្ចី ។ ភិក្ខុថ្មីទាំងឡាយដែលឈឺវច្ចៈមកដល់មុនហើយរង់ចាំ ។ ភិក្ខុទាំងនោះខំអត់ទ្រាំវច្ចៈ ក៏ជ្រប់ដួលទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថា ភិក្ខុទាំងឡាយបន្ទោបង់វច្ចៈក្នុងវច្ចកុដិតាមលំដាប់ចាស់ខ្ចី ភិក្ខុខ្ចីទាំងឡាយដែលឈឺវច្ចៈមកដល់មុនហើយ រង់ចាំ ភិក្ខុទាំងនោះខំអត់ទ្រាំវច្ចៈ ក៏ជ្រប់ដួលទៅ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា ពិតមែន ព្រះអង្គ ។ បេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបន្ទោបង់វច្ចៈក្នុងវច្ចកុដិតាមលំដាប់ចាស់ខ្ចីទេ ភិក្ខុណាបន្ទោបង់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបន្ទោបង់វច្ចៈតាមលំដាប់ដែលមកដល់(២) ។

---

១ អដ្ឋកថា ថា បើមានទឹកតែគ្មានទីកំបាំង ភិក្ខុត្រូវដងទឹកដោយភាជន៍យកមកជម្រះ (ក្នុងទីកំបាំង) ។ បើគ្មានភាជន៍សម្រាប់ដងទឹក ត្រូវដងដោយបាត្រ ។ បើបាត្រក៏គ្មាន ទាំងវត្ថុឯទៀតក៏គ្មាន ។ ភិក្ខុត្រូវតាំងចិត្តថា ទីនេះស្រឡះណាស់ ខាងមុខគង់មានទឹក លុះទៅរកទឹកមិនបានក៏ដល់ពេលភិក្ខាចារ ភិក្ខុនោះនឹងជូតដោយឈើឬវត្ថុអ្វីមួយក៏បាន ។ ២ អដ្ឋកថាថា វច្ចកុដិ ១ ទីបន្ទោបង់បស្សាវៈ ១ កំពង់សម្រាប់ងូតទឹក ១ ទាំង ៣ កន្លែងនេះ គួរប្រកាន់តាមលំដាប់ភិក្ខុដែលទៅដល់ (មុនក្រោយ) ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


## វត្តក្ខន្ធកេ វច្ចកុដិវត្តនិទានំ

[១០០] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ អតិសហសាបិ វច្ចកុដឹ បវិសន្តិ ឧព្ភជិត្វាបិ បវិសន្តិ និត្ថុនន្តាបិ វច្ចំ ករោន្តិ ទន្តកដ្ឋំ ខាទន្តាបិ វច្ចំ ករោន្តិ ពហិទ្ធាបិ វច្ចបាទុកាយ វច្ចំ ករោន្តិ ពហិទ្ធាបិ បស្សាវបាទុកាយ បស្សាវំ ករោន្តិ បស្សាវទោណិកាយបិ ខេឡំ ករោន្តិ ផរុសេនបិ កដ្ឋេន អវលេខន្តិ អវលេខនកដ្ឋម្បិ វច្ចកូបម្ហិ បាតេន្តិ អតិសហសាបិ និក្ខមន្តិ ឧព្ភជិត្វាបិ និក្ខមន្តិ ចបុចបុការកាបិ អាចមេន្តិ អាចមនសរាវកេបិ ឧទកំ សេសេន្តិ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ អតិសហសាបិ វច្ចកុដឹ បវិសិស្សន្តិ ឧព្ភជិត្វាបិ បវិសិស្សន្តិ និត្ថុនន្តាបិ វច្ចំ ករិស្សន្តិ ទន្តកដ្ឋំ ខាទន្តាបិ វច្ចំ ករិស្សន្តិ ពហិទ្ធាបិ វច្ចបាទុកាយ វច្ចំ ករិស្សន្តិ ពហិទ្ធាបិ បស្សាវបាទុកាយ បស្សាវំ ករិស្សន្តិ បស្សាវទោណិកាបិ ខេឡំ ករិស្សន្តិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ និទាននៃវច្ចកុដិវត្ត

[១០០] សម័យនោះ ពួកឆព្វគ្គិយភិក្ខុ ចូលទៅកាន់វច្ចកុដិដោយរហ័សពេកខ្លះ សើយស្បង់ចូលទៅខ្លះ បន្ទោបង់វច្ចៈប្រឹងមោត់ខ្លះ បន្ទោបង់វច្ចៈទាំងទំពាឈើស្ទន់ខ្លះ បន្ទោបង់វច្ចៈខាងក្រៅទវច្ចៈខ្លះ បន្ទោបង់បស្សាវៈខាងក្រៅទបស្សាវៈខ្លះ ស្តោះទឹកមាត់ក្នុងទបស្សាវៈខ្លះ កិតដោយឈើដ៏គ្រោតគ្រាតខ្លះ ចោលឈើសម្រាប់កិតក្នុងរណ្តៅវច្ចខ្លះ ចេញមកដោយរហ័សពេកខ្លះ សើយស្បង់ចេញមកខ្លះ ជម្រះធ្វើសំឡេងព្ចបុ-ចបុខ្លះ ទុកទឹកឲ្យសល់នៅក្នុងភាជន៍សម្រាប់ជម្រះខ្លះ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើពួកឆព្វគ្គិយភិក្ខុនឹងចូលទៅកាន់វច្ចកុដិដោយរហ័សពេកខ្លះ សើយស្បង់ចូលទៅកាន់ខ្លះ ខំប្រឹងមោត់បន្ទោបង់វច្ចៈខ្លះ បន្ទោបង់វច្ចៈទាំងទំពាឈើស្ទន់ខ្លះ បន្ទោបង់វច្ចៈខាងក្រៅទវច្ចៈខ្លះ បន្ទោបង់បស្សាវៈខាងក្រៅទបស្សាវៈខ្លះ ស្តោះទឹកមាត់ក្នុងទបស្សាវៈខ្លះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


ផរុសេនបិ កដ្ឋេន អវលេខន្តិ អវលេខនកដ្ឋំបិ វច្ចកូបម្ហិ បាតេន្តិ អតិសហសាបិ និក្ខមន្តិ ឧព្ភជិត្វាបិ និក្ខមន្តិ ចបុចបុការកាបិ(១) អាចមេន្តិ អាចមនសរាវកេបិ ឧទកំ សេសេន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ។ បេ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ ភិក្ខូនំ វច្ចកុដិវត្តំ បញ្ញាបេស្សាមិ យថា ភិក្ខូហិ វច្ចកុដិយា សម្មា វត្តិតព្វំ ។

[១០១] យោ វច្ចកុដឹ គច្ឆតិ តេន(២) ពហិ ឋិតេន ឧក្កាសិតព្វំ អន្តោ និសិន្នេនបិ ឧក្កាសិតព្វំ ចីវរវំសេ វា ចីវររជ្ជុយា វា ចីវរំ និក្ខិបិត្វា សាធុកំ អតរមានេន វច្ចកុដី បវិសិតព្វា នាតិសហសា បវិសិតព្វា ន ឧព្ភជិត្វា បវិសិតព្វា វច្ចបាទុកាយ ឋិតេន ឧព្ភជិតព្វំ ន និត្ថុនន្តេន វច្ចោ កាតព្វោ ន ទន្តកដ្ឋំ ខាទន្តេន វច្ចោ កាតព្វោ ន ពហិទ្ធា វច្ចទោណិកាយ វច្ចោ កាតព្វោ

---

១ ឱ. ម. ចបុចបុការកំបិ ។ ២ តេនសទ្ទោ ឱ. ម. ពោត្ថកេសុ ន បញ្ញាយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



កិតដោយឈើដ៏គ្រោតគ្រាតខ្លះ ពោលឈើសម្រាប់កិតក្នុងរណ្ដៅវច្ចៈខ្លះ ចេញមកដោយរហ័សពេកខ្លះ សើយស្បង់ចេញមកខ្លះ ជម្រះធ្វើឲ្យឮសំឡេងចបុចបុខ្លះ ទុកទឹកឲ្យសល់នៅក្នុងភាជន៍សម្រាប់ជម្រះខ្លះ ដូច្នេះសោះ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រឿងនុ៎ះពិតមែនឬ ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា ពិតមែន ព្រះអង្គ ។ បេ ។ ព្រះមានព្រះភាគទ្រង់តិះដៀលហើយធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តនូវវច្ចកុដិវត្តដល់ភិក្ខុទាំងឡាយ តាមទំនងដែលភិក្ខុទាំងឡាយ គប្បីប្រព្រឹត្តដោយប្រពៃ ក្នុងវច្ចកុដិចុះ ។

[១០១] ភិក្ខុណា ទៅកាន់វច្ចកុដិ ភិក្ខុនោះត្រូវឈរខាងក្រៅហើយគ្រហែម ទោះបីភិក្ខុដែលអង្គុយនៅខាងក្នុងក៏ត្រូវគ្រហែមតប ភិក្ខុនោះត្រូវពាក់ចីវរលើស្មាចីវរឬខ្សែស្បៀង រួចកុំប្រញាប់ប្រញាល់ ចូលទៅកាន់វច្ចកុដិដោយស្រួល កុំចូលទៅដោយប្រញាប់ពេក មិនត្រូវសើយស្បង់ចូលទៅ ត្រូវឈរលើទ្រនាប់ជើងសម្រាប់បន្ទោបង់វច្ចៈហើយសឹមសើយស្បង់ មិនត្រូវចំប្រឹងរមាតបន្ទោបង់វច្ចៈ មិនត្រូវបន្ទោបង់វច្ចៈទាំងទំពាឈើស្ទន់ មិនត្រូវបន្ទោបង់វច្ចៈខាងក្រៅទវច្ចៈ មិនត្រូវបន្ទោបង់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



## វត្តក្ខន្ធកេ វច្ចកុដិវត្តបញ្ញត្តិ

ន ពហិទ្ធា បស្សាវទោណិកាយ បស្សាវោ កាតព្វោ ន បស្សាវទោណិកាយ ខេឡោ កាតព្វោ ន ផរុសេន កដ្ឋេន អវលេខិតព្វំ ន អវលេខនកដ្ឋំ វច្ចកូបម្ហិ បាតេ-តព្វំ វច្ចទោណិកាយ ឋិតេន បដិច្ឆាទេតព្វំ នាតិសហសា និក្ខមិតព្វំ ន ឧព្ភជិត្វា និក្ខមិតព្វំ អាចមនទោណិកាយ ឋិតេន ឧព្ភជិតព្វំ ន ចបុចបុការកេន(១) អាចមេតព្វំ ន អាចមនសរាវកេ ឧទកំ សេសេតព្វំ អាចមនទោ-ណិកាយ ឋិតេន បដិច្ឆាទេតព្វំ សចេ វច្ចកុដី ឩហតា ហោតិ ធោវិតព្វា សចេ អវលេខនបិឋរោ បូរោ ហោតិ អវលេខនកដ្ឋំ ឆឌ្ឌេតព្វំ សចេ វច្ចកុដី ឧក្លាបា ហោតិ វច្ចកុដី សម្មជ្ជិតព្វា សចេ បរិភណ្ឌំ ឧក្លាបំ ហោតិ បរិភណ្ឌំ សម្មជ្ជិតព្វំ សចេ បរិវេណំ ឧក្លាបំ ហោតិ បរិវេណំ សម្មជ្ជិតព្វំ សចេ កោដ្ឋកោ ឧក្លាបោ ហោតិ កោដ្ឋកោ សម្មជ្ជិតព្វោ សចេ អាចមនកុម្ភិយា ឧទកំ ន ហោតិ អាចមនកុម្ភិយា ឧទកំ អាសិញ្ចិតព្វំ ឥទំ ខោ ភិក្ខវេ ភិក្ខូនំ វច្ចកុដីវត្តំ យថា ភិក្ខូហិ វច្ចកុដិយា សម្មា វត្តិតព្វន្តិ ។

---

១ ឱ· ម· ចបុចបុការកំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ ការទ្រង់បញ្ញត្តវច្ចកុដិវត្ត

បស្សាវៈខាងក្រៅទបស្សាវៈ មិនត្រូវស្តោះទឹកមាត់ក្នុងទបស្សាវៈ មិនត្រូវកិតដោយឈើគ្រោតគ្រាត មិនត្រូវចោលឈើសម្រាប់កិតក្នុងរណ្តៅវច្ចៈ ត្រូវឈរលើទ្រនាប់សម្រាប់បន្ទោបង់វច្ចៈហើយសឹមបិទបាំង (ស្បង់) មិនត្រូវចេញមកដោយរួសរាន់ពេក មិនត្រូវចេញមកទាំងសើយស្បង់ ត្រូវឈរលើទ្រនាប់សម្រាប់ជម្រះហើយសឹមសើយស្បង់ មិនត្រូវជម្រះធ្វើសំឡេងឲ្យព្ចុបុចបុ មិនត្រូវទុកទឹកឲ្យសល់នៅក្នុងកាជន៍សម្រាប់ជម្រះ ត្រូវឈរលើទ្រនាប់សម្រាប់ជម្រះហើយសឹមបិទបាំង បើវច្ចកុដិប្រឡាក់ ត្រូវលាងចេញ បើកញ្ជើសម្រាប់ដាក់ឈើសម្រាប់កិតពេញ ត្រូវចាក់ឈើសម្រាប់កិតចោលចេញ បើវច្ចកុដិមានសម្រាម ត្រូវបោសវច្ចកុដិចេញ បើលានវច្ចកុដិមានសម្រាម ត្រូវបោសលានវច្ចកុដិចេញ បើបរិវេណមានសម្រាម ត្រូវបោសបរិវេណចេញ បើបន្ទប់មានសម្រាម ត្រូវបោសបន្ទប់ចេញ បើទឹកក្នុងក្អមសម្រាប់ជម្រះគ្មានទេ ត្រូវចាក់ទឹកដាក់ក្នុងក្អមសម្រាប់ជម្រះ ម្នាលភិក្ខុទាំងឡាយ ទាំងនេះជាវច្ចកុដិវត្តរបស់ភិក្ខុទាំងឡាយ តាមទំនងដែលភិក្ខុទាំងឡាយ ត្រូវប្រព្រឹត្ត ដោយប្រពៃក្នុងវច្ចកុដិចុះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដកេ ចុល្លវគ្គោ

[១០២] តេន ខោ បន សមយេន សទ្ធិវិហារិកា ឧបជ្ឈាយេសុ ន សម្មា វត្តន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សទ្ធិវិហារិកា ឧបជ្ឈាយេសុ ន សម្មា វត្តិស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ សទ្ធិវិហារិកា ឧបជ្ឈាយេសុ ន សម្មា វត្តន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ភិក្ខវេ សទ្ធិវិហារិកា ឧបជ្ឈាយេសុ ន សម្មា វត្តិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សទ្ធិវិហារិកានំ ឧបជ្ឈាយេសុ វត្តំ បញ្ញាបេស្សាមិ យថា សទ្ធិវិហារិកេហិ ឧបជ្ឈាយេសុ សម្មា វត្តិតព្វំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដក ចុល្លវគ្គ

[១០៤] សម័យនោះឯង ពួកសទ្ធិវិហារិកមិនប្រព្រឹត្តដោយប្រពៃ ក្នុងឧបជ្ឈាយ៍ទាំងឡាយ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើពួកសទ្ធិវិហារិក មិនប្រព្រឹត្ត ដោយប្រពៃក្នុងឧបជ្ឈាយ៍ទាំងឡាយសោះ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថាពួកសទ្ធិវិហារិកមិនប្រព្រឹត្តដោយប្រពៃ ក្នុងឧបជ្ឈាយ៍ទាំងឡាយ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា ពិតមែន ព្រះអង្គ ។ ព្រះពុទ្ធជាម្ចាស់ ទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ មិនសមបើសទ្ធិវិហារិកទាំងឡាយមិន ប្រព្រឹត្តដោយប្រពៃ ក្នុងឧបជ្ឈាយ៍ទាំងឡាយសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ លុះទ្រង់តិះដៀលហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តនូវឧបជ្ឈាយវត្ត ដល់សទ្ធិវិហារិកទាំងឡាយ តាមទំនងដែលសទ្ធិវិហារិកទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងឧបជ្ឈាយ៍ទាំងឡាយ ។

## វត្តក្ខន្ធកេ ឧបជ្ឈាយវត្តំ

(១០៣) សទ្ធិវិហារិកេន ភិក្ខវេ ឧបជ្ឈាយម្ហិ
សម្មា វត្តិតព្វំ ។ តត្រាយំ សម្មាវត្តនា កាលស្សេវ
ឧដ្ឋាយ ឧបាហនា ឱមុញ្ចិត្វា ឯកំសំ ឧត្តរាសង្គំ
ករិត្វា ទន្តកដ្ឋំ ទាតព្វំ មុខោទកំ ទាតព្វំ អាសនំ
បញ្ញាបេតព្វំ សចេ យាគុ ហោតិ ភាជនំ ធោវិត្វា
យាគុ ឧបនាមេតព្វា យាគុំ បីតស្ស ឧទកំ ទត្វា
ភាជនំ បដិគ្គហេត្វា នីចំ កត្វា សាធុកំ អប-
រិឃំសន្តេន ធោវិត្វា បដិសាមេតព្វំ ឧបជ្ឈាយម្ហិ វុដ្ឋិតេ
អាសនំ ឧទ្ធរិតព្វំ សចេ សោ ទេសោ ឧក្លាបោ
ហោតិ សោ ទេសោ សម្មជ្ជិតព្វោ សចេ ឧបជ្ឈាយោ
គាមំ បវិសិតុកាមោ ហោតិ និវាសនំ ទាតព្វំ បដិនិ-
វាសនំ បដិគ្គហេតព្វំ កាយពន្ធនំ ទាតព្វំ សគុណំ
កត្វា សង្ឃាដិយោ ទាតព្វា ធោវិត្វា បត្តោ សឧទកោ
ទាតព្វោ សចេ ឧបជ្ឈាយោ បច្ឆាសមណំ អាកង្ខ-
តិ តិមណ្ឌលំ បដិច្ឆាទេន្តេន បរិមណ្ឌលំ និវាសេត្វា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



## វត្តក្ខន្ធកៈ ឧបជ្ឈាយវត្ត

(១០៣) ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិក ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងឧបជ្ឈាយ៍ ។ ឯសេចក្តីប្រព្រឹត្តដោយប្រពៃក្នុងឧបជ្ឈាយ៍នោះដូច្នេះ សទ្ធិវិហារិកត្រូវក្រោកអំពីព្រឹកហើយដោះស្បែកជើង រួចធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយប្រគេនឈើស្ទន់ ប្រគេនទឹកសម្រាប់លុបមុខ ក្រាលអាសនៈ បើមានបបរ សទ្ធិវិហារិកត្រូវលាងភាជន៍ហើយបង្អោនបបរចូលទៅប្រគេន កាលបើឧបជ្ឈាយ៍ហុតបបររួចហើយ សទ្ធិវិហារិកត្រូវប្រគេនទឹក ហើយទទួលយកភាជន៍ លើកបន្ទាបឲ្យស្រួលកុំឲ្យទង្គិច (អ៊ឺៗ) ហើយលាងឲ្យស្អាត រួចរៀបចំទុកដាក់ កាលបើឧបជ្ឈាយ៍ក្រោកចេញហើយ សទ្ធិវិហារិកត្រូវសារអាសនៈចេញ បើប្រទេសនោះមានសម្រាម សទ្ធិវិហារិក ត្រូវបោសប្រទេសនោះចេញ បើឧបជ្ឈាយ៍ចង់ចូលទៅកាន់ស្រុក សទ្ធិវិហារិក ត្រូវប្រគេនស្បង់ហើយទទួលស្បង់បន្លាស់មកវិញ ត្រូវប្រគេនវត្ថពន្ធចង្កេះ ត្រូវតម្រួតឧត្តរាសង្គៈនិងសង្ឃាដិហើយប្រគេន ត្រូវជូតបាត្រដែលទឹក រួចហើយសឹមប្រគេន បើឧបជ្ឈាយ៍ចង់បានសទ្ធិវិហារិកជាបច្ឆាសមណៈ (តាមក្រោយឧបជ្ឈាយ៍) សទ្ធិវិហារិក ត្រូវបិទបាំងមណ្ឌលបី គឺ ស្លៀកស្បង់ឲ្យជាបរិមណ្ឌល

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កាយពន្ធនំ ពន្ធិត្វា សគុណំ កត្វា សង្ឃាដិយោ បារុបិត្វា គណ្ឋិកំ បដិមុញ្ចិត្វា ធោវិត្វា បត្តំ គហេត្វា ឧបជ្ឈាយស្ស បច្ឆាសមណេន ហោតព្វំ នាតិទូរេ គន្តព្វំ នាច្ចាសន្នេ គន្តព្វំ បត្តបរិយាបន្នំ បដិគ្គហេតព្វំ ន ឧបជ្ឈាយស្ស ភណមានស្ស អន្តរន្តរា កថា ឱបាតេតព្វា ឧបជ្ឈាយោ អាបត្តិសាមន្តា ភណមានោ និវារេតព្វោ និវត្តន្តេន បឋមតរំ អាគន្ត្វា អាសនំ បញ្ញបេតព្វំ បាទោទកំ បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបិតព្វំ បច្ចុគ្គន្ត្វា បត្តចីវរំ បដិគ្គហេតព្វំ បដិនិវាសនំ ទាតព្វំ និវាសនំ បដិគ្គហេតព្វំ សចេ ចីវរំ សិន្នំ ហោតិ មុហុត្តំ ឧណ្ហេ ឱតាបេតព្វំ ន ច ឧណ្ហេ ចីវរំ និទហិតព្វំ ចីវរំ សំហរិតព្វំ(១) ចីវរំ សំហរន្តេន(២) ចតុរង្គុលំ កណ្ណំ ឧស្សារេត្វា(៣) ចីវរំ សំហរិតព្វំ មា មជ្ឈេ ភង្គោ អហោសីតិ ឱភោគេ កាយពន្ធនំ កាតព្វំ សចេ បិណ្ឌបាតោ ហោតិ ឧបជ្ឈាយោ ច ភុញ្ជិតុកាមោ ហោតិ ឧទកំ ទត្វា បិណ្ឌបាតោ ឧបនាមេតព្វោ ឧបជ្ឈាយោ បានីយេន បុច្ឆិតព្វោ ភុត្តាវិស្ស ឧទកំ ទត្វា បត្តំ បដិគ្គហេត្វា

---

១ ម. សង្ឃរិតព្វំ ។ ២ ម. សង្ឃរន្តេន ។ ៣ ឱ. ប. ឧស្សាបេត្វា ។

# វិនយបិដក ចុល្លវគ្គ

ក្រវាត់វត្ថពន្ធបង្កេះ ហើយតម្រួតឧត្តរាសង្គៈនឹងសង្ឃាដិ ហើយឃ្លុំពាក់ក្ដុំ ហើយដូតបាត្រ ហើយកាន់យកទៅ ធ្វើជាបច្ឆាសមណៈ មិនត្រូវដើរឆ្ងាយពេក មិនត្រូវដើរជិតពេក ត្រូវចាំទទួលយកវត្ថុដែលគេដាក់ក្នុងបាត្រ កាលបើឧបជ្ឈាយ៍កំពុងនិយាយ សទ្ធិវិហារិកមិនត្រូវនិយាយស្កាត់ក្នុងចន្លោះៗឡើយ បើឧបជ្ឈាយ៍កំពុងនិយាយពាក្យដែលជិតនឹងត្រូវអាបត្តិ សទ្ធិវិហារិកត្រូវឃាត់ កាលវិលត្រឡប់មកវិញ សទ្ធិវិហារិកត្រូវមកឲ្យបានមុន ហើយក្រាលអាសនៈចាំ រួចដំកល់ទុកនូវទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើងដែលលាងហើយ នឹងទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់បានលាង ហើយត្រូវក្រោកទៅទទួលបាត្រនឹងចីវរ ត្រូវប្រគេនស្បង់បន្លាស់ ទទួលយកស្បង់ដែលស្លៀកមកវិញ បើចីវរទទឹក សទ្ធិវិហារិកត្រូវសំដិលក្នុងកំដៅថ្ងៃមួយស្របក់ តែមិនត្រូវទុកចីវរក្នុងកំដៅថ្ងៃ(ឲ្យយូរពេក)ត្រូវបត់ចីវរទុក កាលនឹងបត់ចីវរ ត្រូវលើកជាយឲ្យហួសពីគ្នាមានប្រមាណ ៤ ធ្នាប់ ហើយសឹមបត់ចីវរ ដោយគិតថា កុំឲ្យបាក់ផ្នត់ចីវរពាក់កណ្ដាលឡើយ ត្រូវដាក់វត្ថពន្ធបង្កេះក្នុងផ្នត់ចីវរ បើមានអាហារបិណ្ឌបាត ហើយឧបជ្ឈាយ៍ចង់ឆាន់ សទ្ធិវិហារិកត្រូវប្រគេនទឹក ហើយបង្អោនអាហារបិណ្ឌបាតចូលទៅប្រគេន ត្រូវសួរឧបជ្ឈាយ៍ដោយទឹកសម្រាប់ឆាន់ កាលបើឧបជ្ឈាយ៍ឆាន់រួចហើយ សទ្ធិវិហារិកត្រូវប្រគេនទឹក រួចទទួលយកបាត្រមកវិញ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


## វត្តក្ខន្ធកេ ឧបជ្ឈាយវត្តំ

នីចំ កត្វា សាធុកំ អប្បដិឃំសន្តេន ធោវិត្វា វោទកំ
កត្វា មុហុត្តំ ឧណ្ហេ ឱតាបេតព្វោ ន ច ឧណ្ហេ
បត្តោ និទហិតព្វោ បត្តចីវរំ និក្ខិបិតព្វំ បត្តំ និក្ខិបន្តេន
ឯកេន ហត្ថេន បត្តំ គហេត្វា ឯកេន ហត្ថេន
ហេដ្ឋាមញ្ចំ វា ហេដ្ឋាបីឋំ វា បរាមសិត្វា បត្តោ និក្ខិ-
បិតព្វោ ន ច អនន្តរហិតាយ ភូមិយា បត្តោ និក្ខិ-
បិតព្វោ ចីវរំ និក្ខិបន្តេន ឯកេន ហត្ថេន ចីវរំ គហេ-
ត្វា ឯកេន ហត្ថេន ចីវរវំសំ វា ចីវររជ្ជុំ វា បមជ្ជិត្វា
បារតោ អន្តំ ឱរតោ ភោគំ កត្វា ចីវរំ និក្ខិបិតព្វំ
ឧបជ្ឈាយម្ហិ វុដ្ឋិតេ អាសនំ ឧទ្ធរិតព្វំ បាទោទកំ
បាទបីឋំ បាទកឋលិកំ បដិសាមេតព្វំ សចេ សោ
ទេសោ ឧក្លាបោ ហោតិ សោ ទេសោ សម្មជ្ជិតព្វោ
សចេ ឧបជ្ឈាយោ នហាយិតុកាមោ ហោតិ នហានំ
បដិយាទេតព្វំ សចេ សីតេន អត្ថោ ហោតិ សីតំ
បដិយាទេតព្វំ សចេ ឧណ្ហេន អត្ថោ ហោតិ ឧណ្ហំ
បដិយាទេតព្វំ សចេ ឧបជ្ឈាយោ ជន្តាឃរំ បវិសិតុ-
កាមោ ហោតិ ចុណ្ណំ សន្នេតព្វំ មត្តិកា តេមេតព្វា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## វត្តក្ខន្ធកៈ ឧបជ្ឈាយវត្ត

កាន់បន្ទាប់កុំឲ្យទង្គិច ( អ្វី ៗ ) លាងឲ្យស្អាត ជូតឲ្យស្ងួតទឹកចេញ ហើយហាលក្នុងកំដៅថ្ងៃមួយស្របក់ តែកុំទុកបាត្រក្នុងកំដៅថ្ងៃ ( យូរពេក ) សទ្ធិវិហារិកត្រូវទុកបាត្រនិងចីវរ កាលដែលទុកបាត្រ ត្រូវយកដៃម្ខាងចាប់បាត្រ ដៃម្ខាងស្ទាបក្រោមគ្រែ ឬក្រោមតាំងសិន ហើយសឹមទុកបាត្រ តែមិនត្រូវទុកក្នុងទីដែលមិនស្អាតឡើយ កាលទុកចីវរ ត្រូវយកដៃម្ខាងចាប់ចីវរ ដៃម្ខាងជូតស្នួរចីវរ ឬខ្សែស្ពៀង រួចធ្វើជាយចីវរខាងនាយ ឲ្យជាផ្នត់មកខាងអាយ ហើយសឹមទុកចីវរចុះ កាលបើឧបជ្ឈាយ៍ក្រោកចេញហើយ សទ្ធិវិហារិកត្រូវសារអាសនៈចេញ ត្រូវទុកដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់ជើងដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់បានលាង បើប្រទេសនោះ មានសម្រាម សទ្ធិវិហារិកត្រូវបោសប្រទេសនោះចេញ បើឧបជ្ឈាយ៍ចង់ស្រង់ទឹក សទ្ធិ-វិហារិកត្រូវចាត់ចែងទឹកសម្រាប់ស្រង់ប្រគេន បើឧបជ្ឈាយ៍ត្រូវការទឹកត្រជាក់ សទ្ធិវិហារិកត្រូវចាត់ចែងទឹកត្រជាក់ប្រគេន បើឧបជ្ឈាយ៍ត្រូវការទឹកក្ដៅ សទ្ធិវិហារិកត្រូវចាត់ចែងទឹកក្ដៅប្រគេន បើឧបជ្ឈាយ៍ចង់ចូលទៅកាន់ផ្ទះជាទីរោងភ្លើង សទ្ធិវិហារិកត្រូវស្ងួនគ្រឿងលំអិត ត្រូវលាយដីស្អិត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



ជន្តាឃរបីឋំ អាទាយ ឧបជ្ឈាយស្ស បិដ្ឋិតោ បិដ្ឋិតោ គន្ត្វា ជន្តាឃរបីឋំ ទត្វា ចីវរំ បដិគ្គហេត្វា ឯកមន្តំ និក្ខិបិតព្វំ ចុណ្ណំ ទាតព្វំ មត្តិកា ទាតព្វា សចេ ឧស្សហតិ ជន្តាឃរំ បវិសិតព្វំ ជន្តាឃរំ បវិសន្តេន មត្តិកាយ មុខំ មក្ខេត្វា បុរតោ ច បច្ឆតោ ច បដិច្ឆាទេត្វា ជន្តាឃរំ បវិសិតព្វំ ន ថេរេ ភិក្ខូ អនុបខជ្ជ និសីទិតព្វំ ន នវា ភិក្ខូ អាសនេន បដិពាហិតព្វា ជន្តាឃរេ ឧបជ្ឈាយស្ស បរិកម្មំ កាតព្វំ ជន្តាឃរា និក្ខមន្តេន ជន្តាឃរបីឋំ អាទាយ បុរតោ ច បច្ឆតោ ច បដិច្ឆាទេត្វា ជន្តាឃរា និក្ខមិតព្វំ ឧទកេបិ ឧបជ្ឈាយស្ស បរិកម្មំ កាតព្វំ នហាតេន បឋមតរំ ឧត្តរិត្វា អត្តនោ គត្តំ វោទកំ កត្វា និវាសេត្វា ឧបជ្ឈាយស្ស គត្តតោ ឧទកំ បមជ្ជិតព្វំ និវាសនំ ទាតព្វំ សង្ឃាដិ ទាតព្វា ជន្តាឃរបីឋំ អាទាយ បឋមតរំ អាគន្ត្វា អាសនំ បញ្ញាបេតព្វំ បាទោទកំ បាទបីឋំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ត្រូវនាំយកតាំងសម្រាប់ផ្ទះជាទីក្ដៅកាយ ហើយដើរតាមពីខាងក្រោយ ៗ ឧបជ្ឈាយ៍ ហើយប្រគេនតាំងសម្រាប់ផ្ទះជាទីក្ដៅកាយ រួចទទួលចីវរមកទុកដាក់ ក្នុងទីដ៏សមគួរ ត្រូវប្រគេនគ្រឿងលំអិត ត្រូវប្រគេនដីស្អិត បើសទ្ធិវិហារិកអាចចូលទៅបាន ក៏គប្បីចូលទៅកាន់ផ្ទះជាទីក្ដៅកាយ កាលនឹងចូលទៅកាន់ផ្ទះជាទីក្ដៅកាយ ត្រូវលាបមុខដោយដីស្អិត ហើយបិទបាំង ( កាយ ) ពីខាងមុខខាងក្រោយ រួចសឹមចូលទៅកាន់ផ្ទះជាទីក្ដៅកាយចុះ មិនត្រូវអង្គុយជ្រៀតបៀតភិក្ខុជាថេរៈទាំងឡាយ មិនត្រូវហាមឃាត់ភិក្ខុខ្ចី ដោយអាសនៈ ត្រូវធ្វើបរិកម្មដល់ឧបជ្ឈាយ៍ក្នុងផ្ទះជាទីក្ដៅកាយ កាលឧបជ្ឈាយ៍ ដើរចេញពីផ្ទះជាទីក្ដៅកាយទៅ សទ្ធិវិហារិក ត្រូវនាំយកតាំងសម្រាប់ផ្ទះជាទីក្ដៅកាយ ហើយបិទបាំង ( កាយ ) ពីខាងមុខខាងក្រោយ រួចសឹមថយចេញពីផ្ទះជាទីក្ដៅកាយ សូម្បីក្នុងទឹកសទ្ធិវិហារិក ក៏ត្រូវតែធ្វើបរិកម្មដល់ឧបជ្ឈាយ៍ លុះស្រង់ទឹករួចហើយ ត្រូវឡើងមកមុន ហើយជូតកាយរបស់ខ្លួនឲ្យស្ងួតទឹកចេញ រួចស្លៀកស្បង់ ហើយត្រូវជូតទឹកពីកាយរបស់ឧបជ្ឈាយ៍ ត្រូវប្រគេនស្បង់ ប្រគេនសង្ឃាដិ (ទៅឧបជ្ឈាយ៍) សទ្ធិវិហារិក ត្រូវនាំយកតាំងសម្រាប់ផ្ទះជាទីក្ដៅកាយដើរចេញមកមុន ហើយរៀបចំអាសនៈចាំ ត្រូវដំកល់ទុកនូវទឹកសម្រាប់លាងជើង តាំងសម្រាប់ជើងដែលលាងហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ ឧបជ្ឈាយវត្តំ

បាទកថលិកំ ឧបនិក្ខិបិតព្វំ ឧបជ្ឈាយោ បានី-យេន បុច្ឆិតព្វោ សចេ ឧទ្ទិសាបេតុកាមោ ហោតិ ឧទ្ទិសាបេតព្វោ សចេ បរិបុច្ឆិតុកាមោ ហោតិ បរិបុច្ឆិ-តព្វោ យស្មឹ វិហារេ ឧបជ្ឈាយោ វិហរតិ សចេ សោ វិហារោ ឧក្លាបោ ហោតិ សចេ ឧស្សហតិ សោ-ធេតព្វោ វិហារំ សោធេន្តេន បឋមំ បត្តចីវរំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ និសីទនបច្ចត្ថរណំ នីហរិត្វា ឯក-មន្តំ និក្ខិបិតព្វំ ភិសិពិព្វោហនំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ មញ្ចោ នីចំ កត្វា សាធុកំ អបរិឃំសន្តេន អសង្ឃដ្ដេន្តេន កវាដបិដ្ឋំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វោ បីឋំ នីចំ កត្វា សាធុកំ អបរិឃំសន្តេន អសង្ឃដ្ដេន្តេន កវាដបិដ្ឋំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ មញ្ចប្បដិបា-ទកា នីហរិត្វា ឯកមន្តំ និក្ខិបិតព្វា ខេឡមល្លកោ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វោ អបស្សេនផលកំ នី-ហរិត្វា ឯកមន្តំ និក្ខិបិតព្វំ ភុម្មត្ថរណំ យថាបញ្ញត្តំ សល្លក្ខេត្វា នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ សចេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ ឧបជ្ឈាយវត្ត

នឹងទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង ត្រូវសួរឧបជ្ឈាយ៍ ដោយទឹកសម្រាប់ឆាន់ បើសទ្ធិវិហារិកចង់រៀនបាលី គប្បីឲ្យឧបជ្ឈាយ៍បង្រៀនចុះ បើសទ្ធិវិហារិកចង់រៀនអដ្ឋកថា គប្បីរៀនអដ្ឋកថា (នឹងឧ-បជ្ឈាយ៍)ចុះ ឧបជ្ឈាយ៍នៅក្នុងវិហារណា បើវិហារនោះមានសម្រាម បើសទ្ធិវិហារិកអាច (នឹងបោសសំអាតបាន) ត្រូវបោសសំអាតចេញ កាលនឹងបោសសំអាតវិហារ ត្រូវនាំយកបាត្រនឹងចីវរចេញមកមុន ទៅដំកល់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកកម្រាលសម្រាប់អង្គុយទៅដំកល់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកពូកនឹងខ្នើយទៅដំកល់ទុកក្នុងទីដ៏សមគួរ ត្រូវលើកគ្រែបន្ទាបកុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារនឹងក្របទ្វារ ហើយនាំយកដោយស្រួលទៅទុកក្នុងទីដ៏សមគួរ ត្រូវលើកតាំងបន្ទាបកុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារនឹងក្របទ្វារ ហើយនាំយកឲ្យស្រួលទៅដំកល់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកទ្រនាប់ជើងគ្រែទៅដំកល់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកកន្ធោរសម្រាប់ស្ដោះទឹកមាត់ទៅទុកដាក់ ក្នុងទីដ៏សមគួរ ត្រូវនាំយកក្ដារសម្រាប់ផ្អែកទៅទុកដាក់ក្នុងទីដ៏សមគួរ ត្រូវចំណាំទុកនូវកម្រាលផែនដីដែលគេក្រាលទុកនៅកន្លែងណា ហើយនាំយកទៅទុកក្នុងទីដ៏សមគួរ បើ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



វិហារេ សន្តានកំ ហោតិ ឧល្លោកា បឋមំ ឱហារេតព្វំ អាលោកសន្ធិកណ្ណភាគា បមជ្ជិតព្វា សចេ គេរុកបរិកម្មកតា ភិត្តិ កណ្ណកិតា ហោតិ ចោឡកំ តេមេត្វា បីឡេត្វា បមជ្ជិតព្វា សចេ កាឡវណ្ណកតា ភូមិ កណ្ណកិតា ហោតិ ចោឡកំ តេមេត្វា បីឡេត្វា បមជ្ជិតព្វា សចេ អកតា ហោតិ ភូមិ ឧទកេន បរិប្ផោសិត្វា(១) សម្មជ្ជិតព្វា មា វិហារោ រជេន ឩហញ្ញីតិ សង្ការំ វិចិនិត្វា ឯកមន្តំ ឆឌ្ឌេតព្វំ ភុម្មត្ថរណំ ឱតាបេត្វា សោធេត្វា បប្ផោដេត្វា អតិហរិត្វា យថាបញ្ញត្តំ បញ្ញាបេតព្វំ មញ្ចប្បដិបាទកា ឱតាបេត្វា បមជ្ជិត្វា អតិហរិត្វា យថាឋានេ ឋបេតព្វា មញ្ចោ ឱតាបេត្វា សោធេត្វា បប្ផោដេត្វា នីចំ កត្វា សាធុកំ អបរិឃំសន្តេន អសង្ឃដ្ដេន្តេន កវាដបិដ្ឋំ អតិហរិត្វា យថាបញ្ញត្តំ បញ្ញាបេតព្វោ បីឋំ ឱតាបេត្វា សោធេត្វា បប្ផោដេត្វា នីចំ កត្វា សាធុកំ អបរិឃំសន្តេន អសង្ឃដ្ដេន្តេន កវាដបិដ្ឋំ អតិហរិត្វា

---

១ ឧ. បរិប្បោសិត្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



គ្រឿងស្មុកស្មាញ (មានសរសៃពីងពាងជាដើម) មាននៅក្នុងវិហារ សទ្ធិ-វិហារិកត្រូវបោសចេញពីពិតានជាមុន ត្រូវបោសចំណែកជ្រុងសន្ទឹកបង្អួច បើជញ្ជាំងគេលាបដោយថ្នាំរួចហើយ ត្រឡប់ជាមានប្រឡាក់ដោយធូលីជាដើម សទ្ធិវិហារិកត្រូវជ្រលក់កំណាត់សំពត់ពូតហើយសឹមជូត បើផ្ទៃ (ផែនដី) ដែលគេបរិកម្មដោយវត្ថុមានពណ៌ខ្មៅរួចហើយ ត្រឡប់ជាមានប្រឡាក់ សទ្ធិវិហារិក ត្រូវជ្រលក់កំណាត់សំពត់ពូតហើយសឹមជូត បើផ្ទៃ (ផែនដី) គេមិនបានធ្វើបរិកម្មទេ សទ្ធិវិហារិក ត្រូវប្រោសទឹករួចសឹមជូត ដោយគិតថា វិហារកុំប្រឡាក់ដោយធូលីឡើយ ត្រូវប្រមូលសម្រាមយកទៅចាក់ចោល ក្នុងទីដ៏សមគួរ ត្រូវហាលកម្រាលផែនដីរួចហើយបោកជម្រះគោះ (ដីចេញឲ្យស្អាត) រួចហើយសឹមនាំយកទៅក្រាលទុកដូចដែលវិញ ត្រូវហាលទ្រនាប់ជើងគ្រែហើយជូត (ឲ្យស្អាត) ហើយនាំយកទៅដំកល់ទុកក្នុងទីដូចដែលវិញ ត្រូវហាលគ្រែរួចហើយបោសជម្រះគោះ (ឲ្យស្អាត) រួចលើកបន្ទាបកុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ នាំយកចេញដោយស្រួលហើយ តាំងទុកដូចដែលវិញ ត្រូវសំដិលហាលតាំងហើយបោសជម្រះគោះ (ឲ្យស្អាត) ហើយលើកបន្ទាបកុំឲ្យទង្គិច កុំឲ្យប៉ះសន្ទះទ្វារ និងក្របទ្វារ នាំយកដោយស្រួលហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



## វត្តក្ខន្ធកេ ឧបជ្ឈាយវត្តំ

យថាបញ្ញត្តំ បញ្ញាបេតព្វំ ភិសិពិម្ពោហនំ ឱតាបេត្វា សោធេត្វា បប្ផោដេត្វា អតិហរិត្វា យថាបញ្ញត្តំបញ្ញាបេ-តព្វំ និសីទនបច្ចត្ថរណំ ឱតាបេត្វា សោធេត្វា បប្ផោដេ-ត្វា អតិហរិត្វា យថាបញ្ញត្តំ បញ្ញាបេតព្វំ ខេឡមល្លកោ ឱតាបេត្វា បមជ្ជិត្វា អតិហរិត្វា យថាឋានេ ឋបេតព្វោ អបស្សេនផលកំ ឱតាបេត្វា បមជ្ជិត្វា អតិហរិត្វា យថា-ឋានេ ឋបេតព្វំ បត្តចីវរំ និក្ខិបិតព្វំ បត្តំ និក្ខិបន្តេន ឯ-កេន ហត្ថេន បត្តំ គហេត្វា ឯកេន ហត្ថេន ហេដ្ឋាមញ្ចំ វា ហេដ្ឋាបីឋំ វា បរាមសិត្វា បត្តោ និក្ខិបិតព្វោ ន ច អនន្តរហិតាយ ភូមិយា បត្តោ និក្ខិបិតព្វោ ចីវរំ និក្ខិ-បន្តេន ឯកេន ហត្ថេន ចីវរំ គហេត្វា ឯកេន ហត្ថេន ចីវរវំសំ វា ចីវររជ្ជុំ វា បមជ្ជិត្វា ចារតោ អន្តំ ឱរតោ ភោគំ កត្វា ចីវរំ និក្ខិបិតព្វំ សចេ បុរត្ថិមា សរជា វាតា វាយន្តិ បុរត្ថិមា វាតបានា ថកេតព្វា សចេ បច្ឆិមា សរជា វាតា វាយន្តិ បច្ឆិមា វាតបានា ថកេតព្វា សចេ ឧត្តរា សរជា វាតា វាយន្តិ ឧត្តរា វាតបានា ថកេតព្វា សចេ ទក្ខិណា សរជា វាតា វាយន្តិ

## វត្តក្ខន្ធកៈ ឧបជ្ឈាយវត្ត

រៀបចំទុកដូចដែលវិញ ត្រូវសំដិលពូកនឹងខ្នើយរួចហើយបោសគោះ (ឲ្យស្អាត ) រួចនាំយកទៅក្រាលទុកដូចដែលវិញ ត្រូវសំដិលកម្រាលសម្រាប់ទ្រាប់អង្គុយហើយបោសជម្រះគោះ ( ឲ្យស្អាត ) រួចនាំយកទៅក្រាលទុកដូចដែលវិញ ត្រូវហាលកន្ទោរសម្រាប់ស្តោះទឹកមាត់រួចជូត ( ឲ្យស្អាត ) ហើយនាំយកទៅដំកល់ទុក ក្នុងទីដូចដែលវិញ ត្រូវហាលក្តារសម្រាប់ផ្អែករួចជូតហើយនាំយកទៅទុក ក្នុងទីដូចដែលវិញ ត្រូវទុកបាត្រនឹងចីវរ (ឲ្យល្អ)កាលដែលនឹងទុកបាត្រ ត្រូវយកដៃម្ខាងចាប់បាត្រ ដៃម្ខាងស្ទាបក្រោមគ្រែ ឬក្រោមតាំងហើយសឹមទុកបាត្រ តែមិនត្រូវទុកបាត្រលើទីដែលមិនស្អាតឡើយ កាលដែលនឹងទុកចីវរ ត្រូវយកដៃម្ខាងចាប់ចីវរ ដៃម្ខាងជូតស្នរចីវរ ឬខ្សែស្បៀង ហើយបត់ជាយខាងនាយ ឲ្យជាផ្នត់មកខាងអាយ រួចសឹមទុកចីវរចុះ បើខ្យល់មានទាំងធូលីបក់មកអំពីទិសខាងកើត សទ្ធិវិហារិកត្រូវបិទបង្អួចទិសខាងកើត បើខ្យល់មានទាំងធូលីបក់មកពីទិសខាងលិច សទ្ធិវិហារិកត្រូវបិទបង្អួចទិសខាងលិច បើខ្យល់មានទាំងធូលីបក់មកពីទិសខាងជើង សទ្ធិវិហារិក ត្រូវបិទបង្អួចទិសខាងជើង បើខ្យល់មានទាំងធូលីបក់មកពីទិសខាងត្បូង សទ្ធិវិហារិក ត្រូវ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដកេ ចុល្លវគ្គោ

ទក្ខិណា វាតបានា ថកេតព្វា សចេ សីតកាលោ ហោតិ ទិវា វាតបានា វិវរិតព្វា រត្តឹ ថកេតព្វា សចេ ឧណ្ហកាលោ ហោតិ ទិវា វាតបានា ថកេតព្វា រត្តឹ វិវរិតព្វា សចេ បរិវេណំ ឧក្លាបំ ហោតិ បរិវេណំ សម្មជ្ជិតព្វំ សចេ កោដ្ឋកោ ឧក្លាបោ ហោតិ កោដ្ឋកោ សម្មជ្ជិតព្វោ សចេ ឧបដ្ឋានសាលា ឧក្លាបា ហោតិ ឧបដ្ឋានសាលា សម្មជ្ជិតព្វា សចេ អគ្គិសាលា ឧក្លាបា ហោតិ អគ្គិសាលា សម្មជ្ជិតព្វា សចេ វច្ចកុដិ ឧក្លាបា ហោតិ វច្ចកុដិ សម្មជ្ជិតព្វា សចេ បានីយំ ន ហោតិ បានីយំ ឧបដ្ឋាបេតព្វំ សចេ បរិភោជនីយំ ន ហោតិ បរិភោជនីយំ ឧបដ្ឋាបេតព្វំ សចេ អាចមនកុម្ភិយា ឧទកំ ន ហោតិ អាចមនកុម្ភិយំ ឧទកំ អាសិញ្ចិតព្វំ សចេ ឧបជ្ឈាយស្ស អនភិរតិ ឧប្បន្នា ហោតិ សទ្ធិវិហារិកេន វូបកាសេតព្វោ វូបកាសាបេតព្វោ ធម្មកថា វាស្ស កាតព្វា សចេ ឧបជ្ឈាយស្ស កុក្កុច្ចំ ឧប្បន្នំ ហោតិ សទ្ធិវិហារិកេន វិនោទេតព្វំ វិនោទាបេតព្វំ ធម្មកថា វាស្ស កាតព្វា សចេ ឧបជ្ឈាយស្ស ទិដ្ឋិគតំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បិទបង្អួចទិសខាងត្បូង បើរដូវត្រជាក់ សទ្ធិវិហារិកត្រូវបើកបង្អួចក្នុងវេលាថ្ងៃ បិទបង្អួចក្នុងវេលាយប់ បើរដូវក្តៅ សទ្ធិវិហារិកត្រូវបិទបង្អួចក្នុងវេលាថ្ងៃ បើកបង្អួចក្នុងវេលាយប់ បើទីបរិវេណមានសម្រាម ត្រូវបោសបរិវេណចេញ បើបន្ទប់មានសម្រាម ត្រូវបោសបន្ទប់ចេញ បើរោងឆាន់មានសម្រាម ត្រូវបោសរោងឆាន់ចេញ បើរោងភ្លើងមានសម្រាម ត្រូវបោសរោងភ្លើងចេញ បើបង្គន់មានសម្រាម ត្រូវបោសបង្គន់ចេញ បើគ្មានទឹកសម្រាប់ឆាន់ទេ ត្រូវដងទឹកសម្រាប់ឆាន់ទុក បើគ្មានទឹកសម្រាប់ប្រើប្រាស់ទេ ត្រូវដងទឹកសម្រាប់ប្រើប្រាស់ទុក បើទឹកក្នុងក្អមសម្រាប់ជម្រះមិនមាន សទ្ធិវិហារិក ត្រូវចាក់ទឹកទៅក្នុងក្អមសម្រាប់ជម្រះ បើសេចក្តីអផ្សុកកើតឡើងដល់ឧបជ្ឈាយ៍ សទ្ធិវិហារិកត្រូវរម្ងាប់ដោយខ្លួនឯង ឬត្រូវឲ្យគេជួយរម្ងាប់ ឬនិយាយធម្មកថាដល់ឧបជ្ឈាយ៍នោះ បើសេចក្តីសង្ស័យកើតឡើងដល់ឧបជ្ឈាយ៍ សទ្ធិវិហារិកត្រូវបន្ទោបង់ដោយខ្លួនឯង ឬត្រូវរកគេឲ្យជួយបន្ទោបង់ ឬនិយាយធម្មកថាដល់ឧបជ្ឈាយ៍នោះ បើទិដ្ឋិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ ឧបជ្ឈាយវត្តំ

ឧប្បន្នំ ហោតិ សទ្ធិវិហារិកេន វិវេចេតព្វំ វិវេចាបេតព្វំ ធម្មកថា វា អស្ស កាតព្វា សចេ ឧបជ្ឈាយោ គរុធម្មំ អជ្ឈាបន្នោ ហោតិ បរិវាសារហោ សទ្ធិវិហារិកេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ សង្ឃោ ឧបជ្ឈាយស្ស បរិវាសំ ទទេយ្យាតិ សចេ ឧបជ្ឈាយោ មូលាយ បដិកស្សនារហោ ហោតិ សទ្ធិវិហារិកេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ សង្ឃោ ឧបជ្ឈាយំ មូលាយ បដិកស្សេយ្យាតិ សចេ ឧបជ្ឈាយោ មានត្តារហោ ហោតិ សទ្ធិវិហារិកេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ សង្ឃោ ឧបជ្ឈាយស្ស មានត្តំ ទទេយ្យាតិ សចេ ឧបជ្ឈាយោ អព្ភានារហោ ហោតិ សទ្ធិវិហារិកេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ សង្ឃោ ឧបជ្ឈាយំ អព្ភេយ្យាតិ សចេ សង្ឃោ ឧបជ្ឈាយស្ស កម្មំ កត្តុកាមោ ហោតិ តជ្ជនីយំ វា និយស្សំ វា បព្វាជនីយំ វា បដិសារណីយំ វា ឧក្ខេបនីយំ វា សទ្ធិវិហារិកេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ សង្ឃោ ឧបជ្ឈាយស្ស កម្មំ ន ករេយ្យ លហុកាយ វា បរិណា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ ឧបជ្ឈាយវត្ត

អាក្រក់កើតឡើងដល់ឧបជ្ឈាយ៍ សទ្ធិវិហារិក ត្រូវជួយដោះស្រាយ ដោយខ្លួនឯង ឬត្រូវឱ្យគេជួយដោះស្រាយ ឬនិយាយធម្មកថាដល់ឧបជ្ឈាយ៍នោះ បើឧបជ្ឈាយ៍ត្រូវគរុកាបត្តិ គួរនឹងចូលបរិវាស សទ្ធិវិហារិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគួរឱ្យបរិវាសដល់ឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍ គួរដល់មូលាយបដិកស្សនៈគឺទាញមកដាក់ ក្នុងមូលាបត្តិ សទ្ធិវិហារិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីទាញឧបជ្ឈាយ៍មកដាក់ ក្នុងមូលាបត្តិ ដោយឧបាយដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍គួរដល់មានត្ត សទ្ធិវិហារិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីឱ្យមានត្ត ដល់ឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍គួរដល់អព្ភានកម្ម សទ្ធិវិហារិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីឱ្យអព្ភានកម្ម ដល់ឧបជ្ឈាយ៍ដោយឧបាយដូចម្តេចហ្ន៎ បើសង្ឃប្រាថ្នានឹងធ្វើកម្ម គឺ តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដល់ឧបជ្ឈាយ៍ សទ្ធិវិហារិក ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃមិនគប្បីធ្វើកម្ម ឬគប្បីបង្អោនទៅដើម្បីកម្មស្រាល ដល់ឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មេយ្យាតិ កតំ វា បនស្ស ហោតិ សង្ឃេន កម្មំ តជ្ជនីយំ វា និយស្សំ វា បព្វាជនីយំ វា បដិសារណីយំ វា ឧក្ខេបនីយំ វា សទ្ធិវិហារិកេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ ឧបជ្ឈាយោ សម្មា វត្តេយ្យ លោមំ បាតេយ្យ នេត្ថារំ វត្តេយ្យ សង្ឃោ តំ កម្មំ បដិប្បស្សម្ភេយ្យាតិ សចេ ឧបជ្ឈាយស្ស ចីវរំ ធោវិតព្វំ ហោតិ សទ្ធិវិហារិកេន ធោវិតព្វំ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ ឧបជ្ឈាយស្ស ចីវរំ ធោវិយេថាតិ សចេ ឧបជ្ឈាយស្ស ចីវរំ កាតព្វំ ហោតិ សទ្ធិវិហារិកេន កាតព្វំ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ ឧបជ្ឈាយស្ស ចីវរំ ករិយេថាតិ សចេ ឧបជ្ឈាយស្ស រជនំ បចិតព្វំ(១) ហោតិ សទ្ធិវិហារិកេន បចិតព្វំ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ ឧបជ្ឈាយស្ស រជនំ បចិយេថាតិ សចេ ឧបជ្ឈាយស្ស ចីវរំ រជេតព្វំ(២) ហោតិ សទ្ធិវិហារិកេន រជេតព្វំ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ ឧបជ្ឈាយស្ស ចីវរំ រជិយេថាតិ ចីវរំ រជេន្តេន(៣) សាធុកំ សម្បរិវត្តកំ សម្បរិវត្តកំ

---

១ សព្វត្ថ រជនា បចិតព្វាតិ បាឋោ បញ្ញាយតិ ។ ២ ម. រជិតព្វំ ។ ៣ ម. រជន្តេន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិន័យបិដក ចុល្លវគ្គ

ប្រសិនបើសង្ឃបានធ្វើកម្ម គឺ តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយ-កម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដល់ឧបជ្ឈាយ៍នោះរួចហើយ សទ្ធិវិហារិក ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ឧបជ្ឈាយ៍គប្បីប្រព្រឹត្តដោយប្រពៃ គប្បីសម្ងបរោម គប្បីប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម សង្ឃគប្បីរម្ងាប់កម្មនោះ ដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់ឧបជ្ឈាយ៍គួរនឹងលាង សទ្ធិវិហារិកត្រូវលាង ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា គួរនឹងលាងចីវររបស់ឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់ឧបជ្ឈាយ៍ជាសំពត់គួរធ្វើ សទ្ធិវិហារិកត្រូវធ្វើ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា គួរនឹងធ្វើចីវរដល់ឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎ បើគ្រឿងជ្រលក់របស់ឧបជ្ឈាយ៍គួរស្ងោរ សទ្ធិវិហារិក ត្រូវស្ងោរ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា នឹងគប្បីស្ងោរគ្រឿងជ្រលក់ របស់ឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់ឧបជ្ឈាយ៍គួរជ្រលក់ សទ្ធិវិហារិកត្រូវ ជ្រលក់ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា នឹងគប្បីជ្រលក់ចីវររបស់ឧបជ្ឈាយ៍ ដោយឧបាយដូចម្តេចហ្ន៎ កាលនឹងជ្រលក់ចីវរ ត្រូវជ្រលក់ប្រែត្រឡប់ឲ្យស្រួល្អ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


## វត្តក្ខន្ធកេ ឧបជ្ឈាយវត្តំ

រជេតព្វំ ន ច អច្ឆិន្នេ ថេវេ បក្កមិតព្វំ ន ឧបជ្ឈាយំ អនាបុច្ឆា ឯកច្ចស្ស បត្តោ ទាតព្វោ ន ឯកច្ចស្ស បត្តោ បដិគ្គហេតព្វោ ន ឯកច្ចស្ស ចីវរំ ទាតព្វំ ន ឯកច្ចស្ស ចីវរំ បដិគ្គហេតព្វំ ន ឯកច្ចស្ស បរិក្ខារោ ទាតព្វោ ន ឯកច្ចស្ស បរិក្ខារោ បដិគ្គហេតព្វោ ន ឯកច្ចស្ស កេសា ឆេទេតព្វា ន ឯកច្ចេន កេសា ឆេទាបេតព្វា ន ឯកច្ចស្ស បរិកម្មំ កាតព្វំ ន ឯកច្ចេន បរិកម្មំ ការាបេតព្វំ ន ឯកច្ចស្ស វេយ្យាវច្ចោ កាតព្វោ ន ឯកច្ចេន វេយ្យាវច្ចោ ការាបេតព្វោ ន ឯកច្ចស្ស បច្ឆាសមណេន ហោតព្វំ ន ឯកច្ចោ បច្ឆាសមណោ អាទាតព្វោ ន ឯកច្ចស្ស បិណ្ឌបាតោ នីហរិតព្វោ ន ឯកច្ចេន បិណ្ឌបាតោ នីហរាបេតព្វោ ន ឧបជ្ឈាយំ អនាបុច្ឆា គាមោ បវិសិតព្វោ ន សុសានំ គន្តព្វំ ន ទិសា បក្កមិតព្វា សចេ ឧបជ្ឈាយោ គិលានោ ហោតិ យាវជីវំ ឧបដ្ឋាតព្វោ វុដ្ឋានមស្ស អាគមេតព្វំ ។ ឥទំ ខោ ភិក្ខវេ សទ្ធិវិហារិកានំ ឧបជ្ឈាយេសុ វត្តំ យថា សទ្ធិវិហារិកេន ឧបជ្ឈាយេសុ សម្មា វត្តិតព្វន្តិ ។

## វត្តក្ខន្ធកៈ ឧបជ្ឈាយវត្ត

បើដំណក់ទឹកមិនទាន់ដាច់ទេ សទ្ធិវិហារិក មិនត្រូវចៀសចេញទៅឡើយ សទ្ធិវិហារិកមិនទាន់ប្រាប់ឧបជ្ឈាយ៍ មិនត្រូវឲ្យបាត្រដល់ភិក្ខុណាមួយ មិនត្រូវទទួលយកបាត្ររបស់ភិក្ខុណាមួយ មិនត្រូវឲ្យចីវរ ដល់ភិក្ខុណាមួយ មិនត្រូវទទួលចីវររបស់ភិក្ខុណាមួយ មិនត្រូវឲ្យគ្រឿងបរិក្ខារ ដល់ភិក្ខុណាមួយ មិនត្រូវទទួលបរិក្ខាររបស់ភិក្ខុណាមួយ មិនត្រូវកោរសក់ ដល់ភិក្ខុណាមួយ មិនត្រូវឲ្យភិក្ខុណាមួយកោរសក់ឲ្យ មិនត្រូវធ្វើបរិកម្ម ដល់ភិក្ខុណាមួយ មិនត្រូវឲ្យភិក្ខុណាមួយធ្វើបរិកម្ម (ដល់ខ្លួន) មិនត្រូវធ្វើសេចក្តីខ្វល់ខ្វាយដល់ភិក្ខុណាមួយ មិនត្រូវឲ្យភិក្ខុណាមួយ ធ្វើសេចក្តីខ្វល់ខ្វាយ (ដល់ខ្លួន) មិនត្រូវធ្វើជាបច្ឆាសមណៈរបស់ភិក្ខុណាមួយ មិនត្រូវយកភិក្ខុណាមួយជាបច្ឆាសមណៈ (របស់ខ្លួន) មិនត្រូវនាំបិណ្ឌបាតទៅឲ្យភិក្ខុណាមួយ មិនត្រូវឲ្យភិក្ខុណាមួយនាំបិណ្ឌបាតមកឲ្យ (ខ្លួន) សទ្ធិវិហារិកមិនបានលាឧបជ្ឈាយ៍ មិនត្រូវចូលទៅកាន់ស្រុក មិនត្រូវទៅកាន់ព្រៃស្មសាន មិនត្រូវចៀសចេញទៅកាន់ទិស បើឧបជ្ឈាយ៍មានជម្ងឺ សទ្ធិវិហារិកត្រូវនៅបម្រើអស់កាល ដែលលោកមានជីវិតរស់នៅ ត្រូវរង់ចាំលោកទាល់តែសះជាពេក ម្នាលភិក្ខុទាំងឡាយ ទាំងនេះជាឧបជ្ឈាយវត្ត របស់សទ្ធិវិហារិកទាំងឡាយ តាមទំនងដែលសទ្ធិវិហារិក ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងឧបជ្ឈាយ៍ទាំងឡាយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដកេ ចុល្លវគ្គោ

[១០៤] តេន ខោ បន សមយេន ឧបជ្ឈាយា សទ្ធិវិហារិកេសុ ន សម្មា វត្តន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឧបជ្ឈាយា សទ្ធិវិហារិកេសុ ន សម្មា វត្តិស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ឧបជ្ឈាយា សទ្ធិវិហារិកេសុ ន សម្មា វត្តន្តីតិ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ ឧបជ្ឈាយានំ សទ្ធិវិហារិកេសុ វត្តំ បញ្ញាបេស្សាមិ យថា ឧបជ្ឈាយេហិ សទ្ធិវិហារិកេសុ សម្មា វត្តិតព្វំ ។

[១០៥] ឧបជ្ឈាយេន ភិក្ខវេ សទ្ធិវិហារិកម្ហិ សម្មា វត្តិតព្វំ ។ តត្រាយំ សម្មាវត្តនា ឧបជ្ឈាយេន ភិក្ខវេ សទ្ធិវិហារិកោ សង្គហេតព្វោ អនុគ្គហេតព្វោ ឧទ្ទេសេន បរិបុច្ឆាយ ឱវាទេន អនុសាសនិយា ។ សចេ ឧបជ្ឈាយស្ស បត្តោ ហោតិ សទ្ធិវិហារិកស្ស បត្តោ ន ហោតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១០៤) សម័យនោះឯង ឧបជ្ឈាយ៍ទាំងឡាយ ពុំបានប្រព្រឹត្តដោយប្រពៃ ក្នុងសទ្ធិវិហារិកទាំងឡាយឡើយ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀលបន្តុះបង្អាប់ថា មិនសមបើឧបជ្ឈាយ៍ទាំងឡាយ មិនប្រព្រឹត្តដោយប្រពៃក្នុងសទ្ធិវិហារិកទាំងឡាយសោះ ។ ភិក្ខុទាំងនោះ ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថាឧបជ្ឈាយ៍ទាំងឡាយ មិនប្រព្រឹត្តដោយប្រពៃក្នុងសទ្ធិ-វិហារិកទាំងឡាយ ពិតមែនឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា ពិតមែនព្រះអង្គ ។បេ។ លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសទ្ធិវិហារិកវត្ត ដល់ឧបជ្ឈាយ៍ទាំងឡាយ តាមទំនងដែលឧបជ្ឈាយ៍ទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងពួកភិក្ខុជាសទ្ធិវិហារិក ។

(១០៥) ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍ត្រូវប្រព្រឹត្តដោយប្រពៃក្នុងសទ្ធិវិហារិក ។ ឯការដែលប្រព្រឹត្តដោយប្រពៃ ក្នុងសទ្ធិវិហារិកនោះដូច្នេះ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍ត្រូវសង្គ្រោះនឹងអនុគ្រោះសទ្ធិវិហា-រិក ដោយបាលី ដោយអដ្ឋកថា ដោយដំបូន្មាន ដោយការប្រៀនប្រដៅ បើឧបជ្ឈាយ៍មានបាត្រ សទ្ធិវិហារិកគ្មានបាត្រ ឧបជ្ឈាយ៍ត្រូវ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឧបជ្ឈាយេន សទ្ធិវិហារិកស្ស បត្តោ ទាតព្វោ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ សទ្ធិវិហារិកស្ស បត្តោ ឧប្បជ្ជេយ្យាតិ សចេ ឧបជ្ឈាយស្ស ចីវរំ ហោតិ សទ្ធិវិហារិកស្ស ចីវរំ ន ហោតិ ឧបជ្ឈាយេន សទ្ធិវិហារិកស្ស ចីវរំ ទាតព្វំ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ សទ្ធិវិហារិកស្ស ចីវរំ ឧប្បជ្ជេយ្យាតិ សចេ ឧបជ្ឈាយស្ស បរិក្ខារោ ហោតិ សទ្ធិវិហារិកស្ស បរិក្ខារោ ន ហោតិ ឧបជ្ឈាយេន សទ្ធិវិហារិកស្ស បរិក្ខារោ ទាតព្វោ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ សទ្ធិវិហារិកស្ស បរិក្ខារោ ឧប្បជ្ជេយ្យាតិ សចេ សទ្ធិវិហារិកោ គិលានោ ហោតិ កាលស្សេវ ឧដ្ឋាយ ទន្តកដ្ឋំ ទាតព្វំ មុខោទកំ ទាតព្វំ អាសនំ បញ្ញាបេតព្វំ សចេ យាគុ ហោតិ ភាជនំ ធោវិត្វា យាគុ ឧបនាមេតព្វា យាគុំ បីតស្ស ឧទកំ ទត្វា ភាជនំ បដិគ្គហេត្វា នីចំ កត្វា សាធុកំ អបរិឃំសន្តេន ធោវិត្វា បដិសាមេតព្វំ សទ្ធិវិហារិកម្ហិ វុដ្ឋិតេ អាសនំ ឧទ្ធរិតព្វំ សចេ សោ ទេសោ ឧក្លាបោ ហោតិ សោ ទេសោ សម្មជ្ជិតព្វោ

## វត្តក្ខន្ធកៈ ឧបជ្ឈាយវត្ត

ឲ្យបាត្រទៅសទ្ធិវិហារិក ឬត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា បាត្រគប្បីកើតដល់សទ្ធិវិហារិក ដោយឧបាយដូចម្ដេចហ្ន៎ បើឧបជ្ឈាយ៍មានចីវរ សទ្ធិវិហារិកគ្មានចីវរ ឧបជ្ឈាយ៍ត្រូវឲ្យចីវរទៅសទ្ធិវិហារិក ឬត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា ចីវរគប្បីកើតដល់សទ្ធិវិហារិក ដោយឧបាយដូចម្ដេចហ្ន៎ បើឧបជ្ឈាយ៍មានគ្រឿងបរិក្ខារ សទ្ធិវិហារិកគ្មានគ្រឿងបរិក្ខារ ឧបជ្ឈាយ៍ត្រូវឲ្យគ្រឿងបរិក្ខារទៅសទ្ធិវិហារិក ឬត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា គ្រឿងបរិក្ខារគប្បីកើតដល់សទ្ធិវិហារិក ដោយឧបាយដូចម្ដេចហ្ន៎ បើសទ្ធិវិហារិកមានជម្ងឺ ឧបជ្ឈាយ៍ត្រូវក្រោកឡើង ពីព្រឹកហើយឲ្យឈើស្ទន់ ឲ្យទឹកលុបមុខ ក្រាលអាសនៈ បើមានបបរ ត្រូវឧបជ្ឈាយ៍លាងភាជន៍ ហើយបង្អោនបបរទៅឲ្យ កាលសទ្ធិវិហារិកហុតបបររួចហើយ ឧបជ្ឈាយ៍ត្រូវឲ្យទឹក រួចទទួលភាជន៍យកមកវិញ កាន់បន្ទាបកុំឲ្យទង្គិច ( នឹងអ្វីៗ ) លាងរួចហើយទុកដាក់ឲ្យល្អ កាលបើសទ្ធិវិហារិកក្រោកចេញហើយ ឧបជ្ឈាយ៍ត្រូវសារអាសនៈទុក បើប្រទេសនោះមានសម្រាម ឧបជ្ឈាយ៍ត្រូវបោសប្រទេសនោះចេញ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សចេ សទ្ធិវិហារិកោ គាមំ បវិសិតុកាមោ ហោតិ និវា-សនំ ទាតព្វំ បដិនិវាសនំ បដិគ្គហេតព្វំ កាយពន្ធនំ ទាតព្វំ សគុណំ កត្វា សង្ឃាដិយោ ទាតព្វា ធោវិត្វា បត្តោ សោទកោ ទាតព្វោ ឯត្តាវតា និវត្តិស្សតីតិ អា-សនំ បញ្ញាបេតព្វំ បាទោទកំ បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបិតព្វំ បច្ចុគ្គន្ត្វា បត្តចីវរំ បដិគ្គហេតព្វំ បដិនិ-វាសនំ ទាតព្វំ និវាសនំ បដិគ្គហេតព្វំ សចេ ចីវរំ សិន្នំ ហោតិ មុហុត្តំ ឧណ្ហេ ឱតាបេតព្វំ ន ច ឧណ្ហេ ចីវរំ និទ-ហិតព្វំ ចីវរំ សំហរិតព្វំ(១) ចីវរំ សំហរន្តេន(២) ចតុរង្គុលំ កណ្ណំ ឧស្សារេត្វា ចីវរំ សំហរិតព្វំ(៣) មា មជ្ឈេ ភង្គោ អហោសីតិ ឱភោគេ កាយពន្ធនំ កាតព្វំ សចេ បិណ្ឌ-បាតោ ហោតិ សទ្ធិវិហារិកោ ច ភុញ្ជិតុកាមោ ហោតិ ឧទកំ ទត្វា បិណ្ឌបាតោ ឧបនាមេតព្វោ សទ្ធិវិហារិកោ បានីយេន បុច្ឆិតព្វោ ភុត្តាវិស្ស ឧទកំ ទត្វា បត្តំ បដិគ្គហេត្វា នីចំ កត្វា សាធុកំ អប្បដិឃំសន្តេន ធោវិត្វា

---

១ ម. សង្ឃរិតព្វំ ។ ២ សង្ឃរន្តេន ។ ៣ សង្ឃរិតព្វំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដក ចុល្លវគ្គ

បើសទ្ធិវិហារិក មានប្រាថ្នានឹងចូលទៅកាន់ស្រុក ឧបជ្ឈាយ៍ត្រូវឲ្យស្បង់សម្រាប់ស្លៀក ត្រូវទទួលយកស្បង់បន្លាស់មកវិញ ត្រូវឲ្យវត្ថពន្ធបង្កេះ ត្រូវផ្ទុំត្រួតឧត្តរាសង្គៈនឹងសង្ឃាដិហើយឲ្យ ត្រូវជូតបាត្រដែលទទឹកហើយសឹមឲ្យ ឧបជ្ឈាយ៍ត្រូវក្រាលអាសនៈទុកដោយគិតថា ពេលថ្មើរនេះ សទ្ធិ-វិហារិកមុខជានឹងត្រឡប់មកវិញ ត្រូវដំកល់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើងដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង ត្រូវក្រោកឡើងទៅទទួលបាត្រនឹងចីវរ ត្រូវឲ្យស្បង់បន្លាស់ហើយទទួលយកស្បង់ ដែលស្លៀកមកវិញ បើចីវរសើមឬជាំជាម (ដោយញើសក្អែល) ត្រូវសំងិលចីវរក្នុងកំដៅថ្ងៃមួយស្របក់ តែកុំទុកចីវរក្នុងកំដៅថ្ងៃ (ឲ្យយូរពេក) ត្រូវបត់ចីវរ (យកមកទុក) កាលនឹងបត់ចីវរ ត្រូវលើកដាយចីវរឲ្យហួសពីគ្នាប្រមាណ ៤ ធ្នាប់ ហើយសឹមបត់ចីវរ ដោយគិតថា កុំឲ្យបាក់ផ្នត់ពាក់កណ្តាលឡើយ ត្រូវធ្វើវត្ថពន្ធបង្កេះក្នុងផ្នត់ចីវរ បើមានអាហារបិណ្ឌបាត សទ្ធិវិហារិកត្រូវការនឹងឆាន់ ឧបជ្ឈាយ៍ត្រូវឲ្យទឹក ហើយបង្អោនអាហារបិណ្ឌបាតចូលទៅឲ្យ ត្រូវសួរសទ្ធិវិហារិកដោយទឹកឆាន់ លុះសទ្ធិវិហារិកឆាន់រួចហើយ ឧបជ្ឈាយ៍ត្រូវឲ្យទឹកហើយទទួលយកបាត្រមកវិញ កាន់បន្ទាបកុំឲ្យទង្គិច (នឹងអ្វីៗ) លាងឲ្យស្អាត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


វោទកំ កត្វា មុហុត្តំ ឧណ្ហេ ឱតាបេតព្វោ ន ច ឧណ្ហេ បត្តោ និទហិតព្វោ បត្តចីវរំ និក្ខិបិតព្វំ បត្តំ និក្ខិបន្តេន ឯកេន ហត្ថេន បត្តំ គហេត្វា ឯកេន ហត្ថេន ហេដ្ឋាមញ្ចំ វា ហេដ្ឋាបីឋំ វា បរាមសិត្វា បត្តោ និក្ខិបិតព្វោ ន ច អនន្តរហិតាយ ភូមិយា បត្តោ និក្ខិបិតព្វោ ចីវរំ និក្ខិបន្តេន ឯកេន ហត្ថេន ចីវរំ គហេត្វា ឯកេន ហត្ថេន ចីវរវំសំ វា ចីវររជ្ជុំ វា បមជ្ជិត្វា បារតោ អន្តំ ឱរតោ ភោគំ កត្វា ចីវរំ និក្ខិបិតព្វំ សទ្ធិវិហារិកម្ហិ វុដ្ឋិតេ អាសនំ ឧទ្ធរិតព្វំ បាទោទកំ បាទបីឋំ បាទកឋលិកំ បដិសាមេតព្វំ សចេ សោ ទេសោ ឧក្លាបោ ហោតិ សោ ទេសោ សម្មជ្ជិតព្វោ សចេ សទ្ធិវិហារិកោ នហាយិតុកាមោ ហោតិ នហានំ បដិយាទេតព្វំ សចេ សីតេន អត្ថោ ហោតិ សីតំ បដិយាទេតព្វំ សចេ ឧណ្ហេន អត្ថោ ហោតិ ឧណ្ហំ បដិយាទេតព្វំ សចេ សទ្ធិវិហារិកោ ជន្តាឃរំ បវិសិតុកាមោ ហោតិ ចុណ្ណំ សន្នេតព្វំ មត្តិកា តេមេតព្វា ជន្តាឃរបីឋំ អាទាយ គន្ត្វា ជន្តាឃរបីឋំ ទត្វា ចីវរំ បដិគ្គហេត្វា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ហើយជូតទឹកឲ្យស្ងួត ហើយហាលថ្ងៃមួយស្របក់ តែមិនត្រូវទុកបាត្រក្នុងកំដៅថ្ងៃ(ឲ្យយូរពេកឡើយ)ត្រូវទុកដាក់បាត្រនឹងចីវរ កាលនឹងរៀបចំទុកដាក់បាត្រ ដៃម្ខាងចាប់បាត្រ ដៃម្ខាងស្ទាបក្រោមគ្រែ ឬក្រោមតាំងហើយសឹមទុកដាក់បាត្រ តែមិនត្រូវទុកដាក់បាត្រ លើទីដែលមិនស្អាតឡើយ កាលនឹងរៀបចំទុកដាក់ចីវរ ដៃម្ខាងចាប់ចីវរ ដៃម្ខាងជូតស្នូរចីវរឬខ្សែសៀង ហើយធ្វើជាយខាងនាយ ឲ្យជាផ្នត់មកខាងអាយរួចសឹមទុកដាក់ចីវរ កាលសទ្ធិវិហារិកក្រោកឡើង ឧបជ្ឈាយ៍ត្រូវសារអាសនៈរៀបចំទុកដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើងដែលលាងហើយនឹងទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់បានលាង បើប្រទេសនោះមានសម្រាម ឧបជ្ឈាយ៍ត្រូវបោសប្រទេសនោះចេញ បើសទ្ធិវិហារិក ចង់ងូតទឹក ឧបជ្ឈាយ៍ត្រូវតាក់តែងទឹកសម្រាប់ងូតឲ្យ បើសទ្ធិវិហារិកត្រូវការទឹកត្រជាក់ ឧបជ្ឈាយ៍ត្រូវតាក់តែងទឹកត្រជាក់ឲ្យ បើសទ្ធិវិហារិកត្រូវការទឹកក្តៅ ឧបជ្ឈាយ៍ត្រូវតាក់តែងទឹកក្តៅឲ្យ បើសទ្ធិវិហារិកចង់ចូលទៅកាន់ផ្ទះជាទីរក្សាកាយ ឧបជ្ឈាយ៍ត្រូវស្ងូនគ្រឿងលំអិត ត្រូវលាយដីស្អិត ត្រូវនាំយកតាំងសម្រាប់ផ្ទះ ជាទីរក្សាកាយទៅ ហើយប្រគល់តាំងសម្រាប់ផ្ទះជាទីរក្សាកាយដល់ (សទ្ធិវិហារិក) ហើយទទួលយកចីវរមកទុកដាក់ក្នុងទី

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដកេ ចុល្លវគ្គោ

ឯកមន្តំ និក្ខិបិតព្វំ ចុណ្ណំ ទាតព្វំ មត្តិកា ទាតព្វា សចេ ឧស្សហតិ ជន្តាឃរំ បវិសិតព្វំ ជន្តាឃរំ បវិសន្តេន មត្តិកាយ មុខំ មក្ខេត្វា បុរតោ ច បច្ឆតោ ច បដិច្ឆាទេត្វា ជន្តាឃរំ បវិសិតព្វំ ន ថេរេ ភិក្ខូ អនុបខជ្ជ និសីទិតព្វំ ន នវា ភិក្ខូ អាសនេន បដិពាហិតព្វា ជន្តាឃរេ សទ្ធិវិហារិកស្ស បរិកម្មំ កាតព្វំ ជន្តាឃរា និក្ខមន្តេន ជន្តាឃរបីឋំ អាទាយ បុរតោ ច បច្ឆតោ ច បដិច្ឆាទេត្វា ជន្តាឃរា និក្ខមិតព្វំ ឧទកេបិ សទ្ធិវិហារិកស្ស បរិកម្មំ កាតព្វំ ន្ហាតេន បឋមតរំ ឧត្តរិត្វា អត្តនោ គត្តំ វោទកំ កត្វា និវាសេត្វា សទ្ធិវិហារិកស្ស គត្តតោ ឧទកំ បមជ្ជិតព្វំ និវាសនំ ទាតព្វំ សង្ឃាដិ ទាតព្វា ជន្តាឃរបីឋំ អាទាយ បឋមតរំ អាគន្ត្វា អាសនំ បញ្ញបេតព្វំ បាទោទកំ បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបិតព្វំ សទ្ធិវិហារិកោ បានីយេន បុច្ឆិតព្វោ យស្មឹ វិហារេ សទ្ធិវិហារិកោ វិហរតិ សចេ សោ វិហារោ ឧក្លាបោ ហោតិ សចេ ឧស្សហតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ដំសមគួរ ឧបជ្ឈាយ៍ត្រូវឲ្យគ្រឿងលំអិត ត្រូវឲ្យដីស្អិតដល់ (សទ្ធិវិហារិក) បើឧបជ្ឈាយ៍អាចនឹងចូលទៅកាន់ (ផ្ទះជាទីគេក្តៅកាយបាន) ត្រូវចូលទៅកាន់ផ្ទះជាទីគេក្តៅកាយចុះ កាលនឹងចូលទៅកាន់ផ្ទះជាទីគេក្តៅកាយ ត្រូវយកដីស្អិតលាបមុខ រួចបិទបាំង (កាយ) ទាំងខាងមុខ ទាំងខាងក្រោយ ហើយសឹមចូលទៅកាន់ផ្ទះជាទីគេក្តៅកាយ មិនត្រូវអង្គុយជ្រៀតបៀតពួកភិក្ខុជាថេរៈ មិនត្រូវហាមពួកភិក្ខុថ្មីដោយអាសនៈ ត្រូវធ្វើបរិកម្មដល់សទ្ធិវិហារិកក្នុងផ្ទះជាទីគេក្តៅកាយ កាលនឹងចេញពីផ្ទះជាទីគេក្តៅកាយ ត្រូវនាំយកតាំងសម្រាប់ផ្ទះជាទីគេក្តៅកាយចេញ ហើយបិទបាំង (កាយ) ទាំងខាងមុខខាងក្រោយរួចសឹមចេញពីផ្ទះជាទីគេក្តៅកាយ សូម្បីក្នុងទឹក ឧបជ្ឈាយ៍ក៏ត្រូវតែធ្វើបរិកម្មដល់សទ្ធិវិហារិកដែរ ងូតរួចហើយ ឧបជ្ឈាយ៍ត្រូវឡើងមកមុន ជូតកាយរបស់ខ្លួនឲ្យស្ងួតទឹកហើយស្លៀកស្បង់ រួចត្រូវជូតទឹកអំពីកាយរបស់សទ្ធិវិហារិក ហុចស្បង់សម្រាប់ស្លៀក ហុចសង្ឃាដីទៅឲ្យ (សទ្ធិវិហារិក) ត្រូវនាំយកតាំងសម្រាប់ផ្ទះជាទីគេក្តៅកាយចេញមកមុន ហើយក្រាលអាសនៈចាំ ត្រូវដំកល់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើងដែលលាងហើយ នឹងទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់បានលាង ត្រូវសួរសទ្ធិវិហារិកដោយទឹកសម្រាប់ផឹក សទ្ធិវិហារិកនៅក្នុងវិហារណា បើវិហារនោះមានសម្រាម បើឧបជ្ឈាយ៍អាចនឹង (បោសសំអាតបាន)

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


## វត្តក្ខន្ធកេ សទ្ធិវិហារិកវត្តំ

សោធេតព្វោ វិហារំ សោធេន្តេន បឋមំ បត្តចីវរំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ ។បេ។ សចេ អាចមនកុម្ភិយា ឧទកំ ន ហោតិ អាចមនកុម្ភិយា ឧទកំ អាសិញ្ចិតព្វំ សចេ សទ្ធិវិហារិកស្ស អនភិរតិ ឧប្បន្នា ហោតិ ឧបជ្ឈាយេន វូបកាសេតព្វោ វូបកាសាបេតព្វោ ធម្មកថា វាស្ស កាតព្វា សចេ សទ្ធិវិហារិកស្ស កុក្កុច្ចំ ឧប្បន្នំ ហោតិ ឧបជ្ឈាយេន វិនោទេតព្វំ វិនោទាបេតព្វំ ធម្មកថា វាស្ស កាតព្វា សចេ សទ្ធិវិហារិកស្ស ទិដ្ឋិគតំ ឧប្បន្នំ ហោតិ ឧបជ្ឈាយេន វិវេចេតព្វំ វិវេចាបេតព្វំ ធម្មកថា វាស្ស កាតព្វា សចេ សទ្ធិវិហារិកោ គរុធម្មំ អជ្ឈាបន្នោ ហោតិ បរិវាសារហោ ឧបជ្ឈាយេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ សង្ឃោ សទ្ធិវិហារិកស្ស បរិវាសំ ទទេយ្យាតិ សចេ សទ្ធិវិហារិកោ មូលាយ បដិកស្សនារហោ ហោតិ ឧបជ្ឈាយេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ សង្ឃោ សទ្ធិវិហារិកំ មូលាយ បដិកស្សេយ្យាតិ សចេ សទ្ធិវិហារិកោ មានត្តារហោ ហោតិ ឧបជ្ឈាយេន ឧស្សុក្កំ កាតព្វំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ត្រូវសំអាតចេញ កាលនឹងសំអាតវិហារ ត្រូវនាំយកបាត្រនិងចីវរចេញជាមុន ទៅទុកក្នុងទីដ៏សមគួរ ។ បេ ។ បើទឹកក្នុងក្អមសម្រាប់ជម្រះគ្មាន ឧបជ្ឈាយ៍ត្រូវដាក់ទឹកទៅក្នុងក្អមសម្រាប់ជម្រះ បើសេចក្តីអផ្សុកកើតឡើងដល់សទ្ធិវិហារិក ឧបជ្ឈាយ៍ត្រូវរម្ងាប់ ដោយខ្លួនឯង ឬត្រូវឲ្យគេជួយរម្ងាប់ ឬធ្វើធម្មកថាដល់សទ្ធិវិហារិកនោះ បើសេចក្តីសង្ស័យកើតឡើងដល់សទ្ធិវិហារិក ឧបជ្ឈាយ៍ត្រូវបន្ទោបង់ ដោយខ្លួនឯង ឬឲ្យគេជួយបន្ទោបង់ ឬធ្វើធម្មកថាដល់សទ្ធិវិហារិកនោះ បើទិដ្ឋិ (អាក្រក់) កើតឡើងដល់សទ្ធិវិហារិក ឧបជ្ឈាយ៍ត្រូវដោះស្រាយ ដោយខ្លួនឯង ឬឲ្យគេជួយដោះស្រាយ ឬធ្វើធម្មកថាដល់សទ្ធិវិហារិកនោះ បើសទ្ធិវិហារិកត្រូវគរុកាបត្តិគួរនឹងចូលបរិវាស ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគួរឲ្យបរិវាសដល់សទ្ធិវិហារិកដោយឧបាយដូចម្តេចហ្ន៎ បើសទ្ធិវិហារិកគួរដល់មូលាយ-បដិកស្សនៈ គឺទាញមកដាក់ក្នុងមូលាបត្តិ ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីទាញសទ្ធិវិហារិកមកដាក់ក្នុងមូលាបត្តិដោយឧបាយដូចម្តេចហ្ន៎ បើសទ្ធិវិហារិកគួរដល់មានត្ត ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដកេ ចុល្លវគ្គោ

កិន្តិ នុ ខោ សង្ឃោ សទ្ធិវិហារិកស្ស មានត្តំ ទទេយ្យាតិ សចេ សទ្ធិវិហារិកោ អព្ភានារហោ ហោតិ ឧបជ្ឈាយេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ សង្ឃោ សទ្ធិវិហារិកំ អព្ភេយ្យាតិ សចេ សង្ឃោ សទ្ធិវិហារិកស្ស កម្មំ កត្តុ-កាមោ ហោតិ តជ្ជនីយំ វា និយស្សំ វា បព្វាជនីយំ វា បដិសារណីយំ វា ឧក្ខេបនីយំ វា ឧបជ្ឈាយេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ សង្ឃោ សទ្ធិវិហារិកស្ស កម្មំ ន ករេយ្យ លហុកាយ វា បរិណាមេយ្យាតិ កតំ វា បនស្ស ហោតិ សង្ឃេន កម្មំ តជ្ជនីយំ វា និយស្សំ វា បព្វាជនីយំ វា បដិសារណីយំ វា ឧក្ខេបនីយំ វា ឧបជ្ឈា-យេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ សទ្ធិវិហារិកោ សម្មា វត្តេយ្យ លោមំ បាតេយ្យ នេត្ថារំ វត្តេយ្យ សង្ឃោ តំ កម្មំ បដិប្បស្សម្ភេយ្យាតិ សចេ សទ្ធិវិហារិកស្ស ចីវរំ ធោ-វិតព្វំ ហោតិ ឧបជ្ឈាយេន អាចិក្ខិតព្វំ ឯវំ ធោវេយ្យាសីតិ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ សទ្ធិវិហារិកស្ស ចីវរំ ធោវិយេថាតិ សចេ សទ្ធិវិហារិកស្ស ចីវរំ កាតព្វំ ហោតិ ឧបជ្ឈាយេន អាចិក្ខិតព្វំ ឯវំ ករេយ្យាសីតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សង្ឃគប្បីឲ្យមានត្តដល់សទ្ធិវិហារិក ដោយឧបាយដូចម្តេចហ្ន៎ បើសទ្ធិវិហារិកគួរដល់អព្ភានកម្ម ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យអព្ភានកម្មដល់សទ្ធិវិហារិក ដោយឧបាយដូចម្តេចហ្ន៎ បើសង្ឃចង់ធ្វើកម្ម គឺតជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដល់សទ្ធិវិហារិក ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សូមកុំឲ្យសង្ឃធ្វើកម្ម ឬបង្អោនទៅ ដើម្បីកម្មស្រាលដល់សទ្ធិវិហារិកដោយឧបាយដូចម្តេចហ្ន៎ ម្យ៉ាងទៀត តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី សង្ឃបានធ្វើដល់សទ្ធិវិហារិកនោះរួចហើយ ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សទ្ធិវិហារិកគប្បីប្រព្រឹត្តដោយប្រពៃ គប្បីស្ងប់រោម គប្បីប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម សង្ឃគប្បីរម្ងាប់នូវកម្មនោះ ដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់សទ្ធិវិហារិកគួរនឹងលាង ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកគប្បីលាងយ៉ាងនេះ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់សទ្ធិវិហារិកគួរនឹងលាង ដោយឧបាយ ដូចម្តេចហ្ន៎ បើចីវររបស់សទ្ធិវិហារិកគួរនឹងធ្វើ ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកគប្បីធ្វើចីវរយ៉ាងនេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ សទ្ធិវិហារិកវត្តំ អាចរិយវត្តំ

ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ សទ្ធិវិហារិកស្ស ចីវរំ ករិយេថាតិ សចេ សទ្ធិវិហារិកស្ស រជនំ បចិតព្វំ ហោតិ ឧបជ្ឈាយេន អាចិក្ខិតព្វំ ឯវំ បចេយ្យាសីតិ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ សទ្ធិវិហារិកស្ស រជនំ បចិយេថាតិ សចេ សទ្ធិវិហារិកស្ស ចីវរំ រជេតព្វំ ហោតិ ឧបជ្ឈាយេន អាចិក្ខិតព្វំ ឯវំ រជេយ្យាសីតិ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ សទ្ធិវិហារិកស្ស ចីវរំ រជិយេថាតិ ចីវរំ រជេន្តេន សាធុកំ សម្បរិវត្តកំ សម្បរិវត្តកំ រជេតព្វំ ន ច អច្ឆិន្នេ ថេវេ បក្កមិតព្វំ សចេ សទ្ធិវិហារិកោ គិលានោ ហោតិ យាវជីវំ ឧបដ្ឋាតព្វោ[១] វុដ្ឋានមស្ស អាគមេតព្វំ ឥទំ ខោ ភិក្ខវេ ឧបជ្ឈាយានំ សទ្ធិវិហារិកេសុ វត្តំ យថា ឧបជ្ឈាយេហិ សទ្ធិវិហារិកេសុ សម្មា វត្តិតព្វន្តិ ។

### ទុតិយភាណវារំ និដ្ឋិតំ ។

[១០៦] តេន ខោ បន សមយេន អន្តេវាសិកា អាចរិយេសុ ន សម្មា វត្តន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា

---

១ ម. ឧបដ្ឋាបេតព្វោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឬត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា ចីវររបស់សទ្ធិវិហារិកគួរនឹងធ្វើដោយឧបាយដូចម្ដេចហ្ន៎ បើគ្រឿងជ្រលក់របស់សទ្ធិវិហារិក គួរនឹងស្ងោរ ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកត្រូវស្ងោរយ៉ាងនេះ ឬត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា គ្រឿងជ្រលក់របស់សទ្ធិវិហារិកគួរនឹងស្ងោរដោយឧបាយដូចម្ដេចហ្ន៎ បើចីវររបស់សទ្ធិវិហារិកគួរនឹងជ្រលក់ ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកត្រូវជ្រលក់ចីវរយ៉ាងនេះ ឬត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា ចីវររបស់សទ្ធិវិហារិក គួរនឹងជ្រលក់ដោយឧបាយដូចម្ដេចហ្ន៎ កាលនឹងជ្រលក់ចីវរ ត្រូវជ្រលក់ប្រែត្រឡប់ឲ្យសព្វស្មើល្អ បើដំណក់ទឹកស្រក់មិនទាន់អស់ ឧបជ្ឈាយ៍កុំអាលដើរចេញ បើសទ្ធិវិហារិកមានជម្ងឺ ឧបជ្ឈាយ៍ត្រូវថែទាំដរាបអស់កាលដែលមានជីវិតរស់នៅ ត្រូវរង់ចាំដរាបសទ្ធិវិហារិកសះជាជម្ងឺ ម្នាលភិក្ខុទាំងឡាយ ទាំងនេះជាសទ្ធិវិហារិកវត្ត របស់ឧបជ្ឈាយ៍តាមទំនងដែលឧបជ្ឈាយ៍ទាំងឡាយគប្បីប្រព្រឹត្តដោយប្រពៃ ក្នុងសទ្ធិវិហារិកទាំងឡាយ ។

ចប់ ភាណវារៈជាគំរប់ពីរ ។

[១០៦] សម័យនោះឯង ពួកអន្តេវាសិកមិនបានប្រព្រឹត្តដោយប្រពៃក្នុងអាចារ្យទាំងឡាយ ។ ភិក្ខុទាំងឡាយណាមានសេចក្ដីប្រាថ្នាតិច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



។ បេ ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម អន្តេវាសិកា អាចរិយេសុ ន សម្មា វត្តិស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ អន្តេវាសិកា អាចរិយេសុ ន សម្មា វត្តន្តីតិ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ អន្តេវាសិកានំ ភិក្ខូនំ អាចរិយេសុ វត្តំ បញ្ញបេស្សាមិ យថា អន្តេវាសិកេហិ ភិក្ខូហិ[១] អាចរិយេសុ សម្មា វត្តិតព្វំ ។

(១០៧) អន្តេវាសិកេន ភិក្ខវេ អាចរិយម្ហិ សម្មា វត្តិតព្វំ ។ តត្រាយំ សម្មាវត្តនា កាលស្សេវ ឧដ្ឋាយ ឧបាហនា ឱមុញ្ចិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ទន្តកដ្ឋំ ទាតព្វំ មុខោទកំ ទាតព្វំ អាសនំ បញ្ញបេតព្វំ សចេ យាគុ ហោតិ ភាជនំ ធោវិត្វា យាគុ ឧបនាមេតព្វា យាគុំ បីតស្ស ឧទកំ ទត្វា ភាជនំ បដិគ្គហេត្វា នីចំ

---

១ ម. ភិក្ខូហីតិ បាឋោ ន បញ្ញាយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសម បើពួកអន្តេវាសិកមិនប្រព្រឹត្តដោយប្រពៃ ក្នុងអាចារ្យទាំងឡាយសោះ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកអន្តេវាសិក មិនបានប្រព្រឹត្តដោយប្រពៃ ក្នុងអាចារ្យទាំងឡាយ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា ពិតមែន ព្រះអង្គ ។ បេ ។ ទ្រង់បន្ទោសហើយ ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តអាចរិយវត្តដល់ពួកភិក្ខុជាអន្តេវាសិក តាមទំនងដែលពួកភិក្ខុជាអន្តេវាសិក ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងអាចារ្យទាំងឡាយ ។

[១០៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអន្តេវាសិក ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងអាចារ្យ ។ ឯការប្រព្រឹត្តិដោយប្រពៃ ក្នុងអាចារ្យនោះដូច្នេះ គឺអន្តេវាសិកត្រូវក្រោកអំពីព្រឹក ហើយដោះស្បែកជើង ធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ហើយប្រគេនឈើស្ទន់ ប្រគេនទឹកសម្រាប់លាងមុខ ក្រាលអាសនៈទុក បើបបរមាន អន្តេវាសិកត្រូវលាងភាជន៍ហើយបង្អោនបបរទៅប្រគេន កាលបើអាចារ្យហុតបបររួចហើយ អន្តេវាសិកត្រូវប្រគេនទឹក ហើយទទួលភាជន៍មកវិញ កាន់បន្ទាបកុំឲ្យទង្គិចដង (ស៊ូ។)

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





គន្ត្វា សាធុកំ អបរិយេសន្តេន ធោវិត្វា បដិសាមេតព្វំ
អាចរិយម្ហិ វុដ្ឋិតេ អាសនំ ឧទ្ធរិតព្វំ សចេ សោ ទេសោ
ឧក្លាបោ ហោតិ សោ ទេសោ សម្មជ្ជិតព្វោ សចេ អាចរិ-
យោ គាមំ បវិសិតុកាមោ ហោតិ និវាសនំ ទាតព្វំ បដិ-
និវាសនំ បដិគ្គហេតព្វំ កាយពន្ធនំ ទាតព្វំ សគុណំ
កត្វា សង្ឃាដិយោ ទាតព្វា ធោវិត្វា បត្តោ សឧទកោ
ទាតព្វោ សចេ អាចរិយោ បច្ឆាសមណំ អាកង្ខតិ តិ-
មណ្ឌលំ បដិច្ឆាទេន្តេន បរិមណ្ឌលំ និវាសេត្វា កាយ-
ពន្ធនំ ពន្ធិត្វា សគុណំ កត្វា សង្ឃាដិយោ បារុបិត្វា
គណ្ឋិកំ បដិមុញ្ចិត្វា ធោវិត្វា បត្តំ គហេត្វា អាចរិយស្ស
បច្ឆាសមណេន ហោតព្វំ នាតិទូរេ គន្តព្វំ នាច្ចាសន្នេ
គន្តព្វំ បត្តបរិយាបន្នំ បដិគ្គហេតព្វំ ន អាចរិយស្ស
ភណមានស្ស អន្តរន្តរា កថា ឱបាតេតព្វា អាចរិយោ
អាបត្តិសាមន្តា ភណមានោ និវារេតព្វោ និវត្តន្តេន បឋ-
មតរំ អាគន្ត្វា អាសនំ បញ្ញបេតព្វំ បាទោទកំ
បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបិតព្វំ បច្ចុគ្គន្ត្វា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ អាចរិយវត្ត

ហើយលាងឲ្យស្អាតរួចរៀបចំទុកដាក់ កាលបើអាចារ្យក្រោកចេញហើយ អន្តេវាសិកត្រូវសារអាសនៈចេញ បើប្រទេសនោះមានសម្រាម អន្តេវាសិកត្រូវបោសប្រទេសនោះចេញ បើអាចារ្យចង់ចូលទៅកាន់ស្រុក អន្តេវាសិកត្រូវប្រគេនស្បង់សម្រាប់ស្លៀក ហើយទទួលយកស្បង់បន្លាស់មកវិញ ត្រូវប្រគេនវត្ថពន្ធបង្កេះ តម្រួតឧត្តរាសង្គៈនឹងសង្ឃាដិហើយប្រគេន ត្រូវជូតបាត្រដែលទទឹកហើយសឹមប្រគេន បើអាចារ្យចង់បានភិក្ខុជាបច្ឆាស-មណៈ អន្តេវាសិកត្រូវបិទបាំងមណ្ឌលបី គឺស្លៀកស្បង់ឲ្យជាបរិមណ្ឌល ក្រវាត់វត្ថពន្ធបង្កេះ ហើយតម្រួតឧត្តរាសង្គៈនឹងសង្ឃាដិ ហើយឃ្លុំពាក់ឡេវ ក្ខុំលាងបាត្រហើយកាន់យកទៅធ្វើជាបច្ឆាសមណៈនៃអាចារ្យ កុំដើរឆ្ងាយពេក កុំដើរជិតពេក ត្រូវចាំទទួលយកវត្ថុដែលគេដាក់ចុះក្នុងបាត្រ កាលបើអាចារ្យកំពុងនិយាយ អន្តេវាសិកមិនត្រូវនិយាយស្កាត់ពាក្យក្នុងចន្លោះៗឡើយ កាលបើអាចារ្យនិយាយពាក្យដែលជិតនឹងត្រូវអាបត្តិ អន្តេវាសិកត្រូវឃាត់ កាលនឹងត្រឡប់មក អន្តេវាសិកត្រូវស្រូតមកមុន ហើយក្រាលអាសនៈចាំ ត្រូវដំកល់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើងដែលលាងហើយ នឹងទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់បានលាង រួចក្រោកទៅ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បត្តចីវរំ បដិគ្គហេតព្វំ បដិនិវាសនំ ទាតព្វំ និវាសនំ
បដិគ្គហេតព្វំ សចេ ចីវរំ សិន្នំ ហោតិ មុហុត្តំ ឧណ្ហេ
ឱតាបេតព្វំ ន ច ឧណ្ហេ ចីវរំ និទហិតព្វំ ចីវរំ សំហរិ-
តព្វំ ចីវរំ សំហរន្តេន ចតុរង្គុលំ កណ្ណំ ឧស្សាទេត្វា(១)
ចីវរំ សំហរិតព្វំ មា មជ្ឈេ ភង្គោ អហោសីតិ ឱភោ-
គេ កាយពន្ធនំ កាតព្វំ សចេ បិណ្ឌបាតោ ហោតិ
អាចរិយោ ច ភុញ្ជិតុកាមោ ហោតិ ឧទកំ ទត្វា បិណ្ឌ-
បាតោ ឧបនាមេតព្វោ អាចរិយោ បានីយេន បុច្ឆិតព្វោ
ភុត្តាវិស្ស ឧទកំ ទត្វា បត្តំ បដិគ្គហេត្វា នីចំ កត្វា សា-
ធុកំ អប្បដិឃំសន្តេន ធោវិត្វា វោទកំ កត្វា មុហុត្តំ ឧណ្ហេ
ឱតាបេតព្វោ ន ច ឧណ្ហេ បត្តោ និទហិតព្វោ បត្តចីវរំ
និក្ខិបិតព្វំ បត្តំ និក្ខិបន្តេន ឯកេន ហត្ថេន បត្តំ
គហេត្វា ឯកេន ហត្ថេន ហេដ្ឋាមញ្ចំ វា ហេដ្ឋាបីឋំ វា
បរាមសិត្វា បត្តោ និក្ខិបិតព្វោ ន ច អនន្តរហិតាយ
ភូមិយា បត្តោ និក្ខិបិតព្វោ ចីវរំ និក្ខិបន្តេន ឯកេន
ហត្ថេន ចីវរំ គហេត្វា ឯកេន ហត្ថេន ចីវរវំសំ វា
ចីវររជ្ជុំ វា បមជ្ជិត្វា បារតោ អន្តំ ឱរតោ ភោគំ កត្វា

១ ម, ឧស្សារេត្វា ។

វិនយបិដក ចុល្លវគ្គ

ទទួលបាត្រនឹងចីវរ ប្រគេនស្បង់បន្ទាស់ ទទួលយកស្បង់ដែលស្លៀកមកវិញ បើចីវរសើមបុដាំដាប ( ដោយញើស ) អន្តេវាសិកត្រូវសំដិលក្នុងទីមានកំដៅថ្ងៃមួយស្របក់ តែកុំទុកចីវរក្នុងទីមានកំដៅថ្ងៃ ( ឲ្យយូរពេក ) ត្រូវបត់ចីវរទុក កាលនឹងបត់ចីវរត្រូវលើកជាយឲ្យហួសពីគ្នាប្រ-មាណ ៤ ធ្នាប់ហើយសឹមបត់ចីវរដោយគិតថា កុំឲ្យចីវរបាក់ផ្នត់ត្រង់ពាក់កណ្ដាលឡើយ ត្រូវធ្វើវត្ថពន្ធបង្កើះក្នុងផ្នត់ចីវរ បើមានបង្ហាន់បិណ្ឌបាត ហើយអាចារ្យចង់ឆាន់ អន្តេវាសិកត្រូវប្រគេនទឹក ហើយបង្អោនបិណ្ឌបាតទៅប្រគេន ត្រូវសួរអាចារ្យដោយទឹកឆាន់ លុះអាចារ្យឆាន់រួចហើយ អន្តេវាសិកត្រូវប្រគេនទឹក ហើយទទួលយកបាត្រមកវិញ កាន់បន្ទាបកុំឲ្យទង្គិចទង្គុក ( ទឹងអ្វ៊ ៗ ) ហើយលាងឲ្យស្អាតជូតឲ្យស្ងួតទឹក រួចហាលក្នុងកំដៅថ្ងៃមួយស្របក់ តែកុំទុកបាត្រហាលក្នុងកំដៅថ្ងៃ ( ឲ្យយូរពេក ) អន្តេវាសិកត្រូវទុកបាត្រនឹងចីវរ កាលនឹងទុកដាក់បាត្រ ដៃម្ខាងចាប់បាត្រ ដៃម្ខាងស្ទាបក្រោមគ្រែ ឬក្រោមតាំង ហើយសឹមទុកបាត្រ តែមិនត្រូវទុកបាត្រក្នុងទីដែលមិនស្អាតឡើយ កាលនឹងទុកចីវរ ត្រូវយកដៃម្ខាងចាប់ចីវរ ដៃម្ខាងជូតស្នួរចីវរ ឬខ្សែស្ពៀង ធ្វើជាយខាងនាយឲ្យជាផ្នត់មកខាងអាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


## វត្តក្ខន្ធកេ អាចរិយវត្តំ

ចីវរំ និក្ខិបិតព្វំ អាចរិយម្ហិ វុដ្ឋិតេ អាសនំ ឧទ្ធរិតព្វំ
បាទោទកំ បាទបីឋំ បាទកឋលិកំ បដិសាមេតព្វំ
សចេ សោ ទេសោ ឧក្លាបោ ហោតិ សោ ទេសោ
សម្មជ្ជិតព្វោ សចេ អាចរិយោ ន្ហាយិតុកាមោ ហោតិ
ន្ហានំ បដិយាទេតព្វំ សចេ សីតេន អត្ថោ ហោតិ
សីតំ បដិយាទេតព្វំ សចេ ឧណ្ហេន អត្ថោ ហោតិ ឧណ្ហំ
បដិយាទេតព្វំ សចេ អាចរិយោ ជន្តាឃរំ បវិសិតុកា-
មោ ហោតិ ចុណ្ណំ សន្នេតព្វំ មត្តិកា តេមេតព្វា ជន្តា-
ឃរបីឋំ អាទាយ អាចរិយស្ស បិដ្ឋិតោ បិដ្ឋិតោ គន្ត្វា
ជន្តាឃរបីឋំ ទត្វា ចីវរំ បដិគ្គហេត្វា ឯកមន្តំ និក្ខិបិ-
តព្វំ ចុណ្ណំ ទាតព្វំ មត្តិកា ទាតព្វា សចេ ឧស្សហតិ
ជន្តាឃរំ បវិសិតព្វំ ជន្តាឃរំ បវិសន្តេន មត្តិកាយ មុខំ
មក្ខេត្វា បុរតោ ច បច្ឆតោ ច បដិច្ឆាទេត្វា ជន្តាឃរំ
បវិសិតព្វំ ន ថេរេ ភិក្ខូ អនុបខជ្ជ និសីទិតព្វំ ន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ អាចរិយវត្ត

ហើយសមទុកចីវរចុះ កាលបើអាចារ្យក្រោកចេញ អន្តេវាសិក ត្រូវសារអាសនៈចេញ ត្រូវទុកដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើងដែលលាងហើយ នឹងទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់បានលាង បើប្រទេសនោះមានសម្រាម អន្តេវាសិកត្រូវបោសប្រទេសនោះចេញ បើអាចារ្យចង់ស្រង់ទឹក អន្តេវាសិកត្រូវចាត់ចែងទឹកសម្រាប់ស្រង់ប្រគេន បើអាចារ្យត្រូវការទឹកត្រជាក់ អន្តេវាសិកត្រូវចាត់ចែងទឹកត្រជាក់ប្រគេន បើអាចារ្យត្រូវការទឹកក្តៅ អន្តេវាសិក ត្រូវចាត់ចែងទឹកក្តៅប្រគេន បើអាចារ្យចង់ចូលទៅកាន់ផ្ទះជាទីរក្សាកាយ អន្តេវាសិកត្រូវសូនគ្រឿងលំអិត ត្រូវលាយដីស្អិត ហើយកាន់យកតាំងសម្រាប់ផ្ទះជាទីរក្សាកាយ ដើរតាមក្រោយអាចារ្យ ហើយប្រគេនតាំងសម្រាប់ផ្ទះជាទីរក្សាកាយ រួចទទួលយកចីវរមកទុកដាក់ក្នុងទីដ៏សមគួរ ត្រូវប្រគេនគ្រឿងលំអិត ត្រូវប្រគេនដីស្អិត បើអន្តេវាសិកអាច ( នឹងចូលទៅបាន ) គប្បីចូលទៅកាន់ផ្ទះជាទីរក្សាកាយ កាលនឹងចូលទៅកាន់ផ្ទះជាទីរក្សាកាយ ត្រូវលាបមុខដោយដីស្អិត ហើយបិទបាំង ( កាយ) ទាំងខាងមុខទាំងខាងក្រោយ រួចសឹមចូលទៅកាន់ផ្ទះជាទីរក្សាកាយ មិនត្រូវអង្គុយជ្រៀតបៀតពួកភិក្ខុជាថេរៈ មិន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នវា ភិក្ខូ អាសនេន បដិពាហិតព្វា ជន្តាឃរេ អាចរិយ-
ស្ស បរិកម្មំ កាតព្វំ ជន្តាឃរា និក្ខមន្តេន ជន្តាឃរបីឋំ
អាទាយ បុរតោ ច បច្ឆតោ ច បដិច្ឆាទេត្វា ជន្តាឃរា
និក្ខមិតព្វំ ឧទកេបិ អាចរិយស្ស បរិកម្មំ កាតព្វំ ន-
ហាតេន បឋមតរំ ឧត្តរិត្វា អត្តនោ គត្តំ វោទកំ កត្វា
និវាសេត្វា អាចរិយស្ស គត្តតោ ឧទកំ បមជ្ជិតព្វំ និ-
វាសនំ ទាតព្វំ សង្ឃាដិ ទាតព្វា ជន្តាឃរបីឋំ អាទាយ
បឋមតរំ អាគន្ត្វា អាសនំ បញ្ញបេតព្វំ បាទោទកំ
បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបិតព្វំ អាចរិយោ បា-
នីយេន បុច្ឆិតព្វោ សចេ ឧទ្ទិសាបេតុកាមោ ហោតិ
ឧទ្ទិសាបេតព្វោ សចេ បរិបុច្ឆិតុកាមោ ហោតិ បរិបុច្ឆិ-
តព្វោ យស្មឹ វិហារេ អាចរិយោ វិហរតិ សចេ សោ
វិហារោ ឧក្លាបោ ហោតិ សចេ ឧស្សហតិ សោធេតព្វោ
វិហារំ សោធេន្តេន បឋមំ បត្តចីវរំ នីហរិត្វា ឯកមន្តំ
និក្ខិបិតព្វំ និសីទនបច្ចត្ថរណំ នីហរិត្វា ឯកមន្តំ និក្ខិ-
បិតព្វំ ភិសិពិម្ពោហនំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ត្រូវហាមឃាត់ពួកភិក្ខុដោយអាសនៈ ត្រូវធ្វើបរិកម្មដល់អាចារ្យក្នុងផ្ទះដាទីរក្សាកាយ កាលនឹងចេញពីផ្ទះដាទីរក្សាកាយ អន្តេវាសិកត្រូវកាន់យកតាំងសម្រាប់ផ្ទះដាទីរក្សាកាយ ហើយបិទបាំង ( កាយ ) ទាំងខាងមុខទាំងខាងក្រោយ រួចសឹមចេញពីផ្ទះដាទីរក្សាកាយ សូម្បីក្នុងទឹក អន្តេវាសិកក៏ត្រូវតែធ្វើបរិកម្មដល់អាចារ្យដែរ កាលអន្តេវាសិកងូតរួចហើយ ត្រូវឡើងមកមុន ហើយជូតកាយរបស់ខ្លួនឱ្យស្ងួតទឹក ស្លៀកស្បង់រួចត្រូវជូតទឹកពីកាយរបស់អាចារ្យ ត្រូវប្រគេនស្បង់ ប្រគេនសង្ឃាដិ ត្រូវកាន់យកតាំងសម្រាប់ផ្ទះដាទីរក្សាកាយដើរចេញមកមុន ហើយក្រាលអាសនៈចាំ ត្រូវដំកល់ទឹកសម្រាប់លាងជើង តាំងសម្រាប់ទ្រជើងដែលលាង ហើយនឹងទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់បានលាង ត្រូវសួរអាចារ្យដោយទឹកសម្រាប់ឆាន់ បើអន្តេវាសិក ចង់ឱ្យអាចារ្យបង្រៀនបាលី ត្រូវឱ្យលោកបង្រៀនចុះ បើអន្តេវាសិក ចង់រៀនអដ្ឋកថា គប្បីរៀនអដ្ឋកថា ( នឹងអាចារ្យចុះ ) អាចារ្យនៅក្នុងវិហារណា បើវិហារនោះមានសម្រាម បើអន្តេវាសិកអាច ( នឹងបោសសំអាតបាន ) ត្រូវបោសសំអាតចេញ កាលនឹងបោសសំអាតវិហារ ត្រូវនាំយកបាត្រនឹងចីវរចេញមុនទៅដំកល់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកកម្រាលសម្រាប់អង្គុយទៅដំកល់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកពូកនឹងខ្នើយទៅដំកល់ទុក ក្នុងទីដ៏សមគួរ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ អាចរិយវត្តំ

មញ្ចោ នីចំ កត្វា សាធុកំ អប្បដិឃំសន្តេន អសង្ឃដ្ដេន្តេ-
ន កវាដបិដ្ឋំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វោ បីឋំ
នីចំ កត្វា សាធុកំ អប្បដិឃំសន្តេន អសង្ឃដ្ដេន្តេន
កវាដបិដ្ឋំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ មញ្ចបដិបា-
ទកា នីហរិត្វា ឯកមន្តំ និក្ខិបិតព្វា ខេឡមល្លកោ
នីហរិត្វា ឯកមន្តំ និក្ខិបិតព្វោ អបស្សេនផលកំ នីហ-
រិត្វា ឯកមន្តំ និក្ខិបិតព្វំ ភុម្មត្ថរណំ យថាបញ្ញត្តំ សល្ល-
ក្ខេត្វា នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ សចេ វិហារេ
សន្តានកំ ហោតិ ឧល្លោកា បឋមំ ឱហារេតព្វំ អា-
លោកសន្ធិកណ្ណភាគា បមជ្ជិតព្វា សចេ គេរុកបរិ-
កម្មកតា ភិត្តិ កណ្ណកិតា ហោតិ ចោឡកំ តេ-
មេត្វា បីឡេត្វា បមជ្ជិតព្វា សចេ កាឡវណ្ណកតា
ភូមិ កណ្ណកិតា ហោតិ ចោឡកំ តេមេត្វា បីឡេត្វា
បមជ្ជិតព្វា សចេ អកតា ហោតិ ភូមិ ឧទកេន
បរិប្ផោសេត្វា សម្មជ្ជិតព្វា មា វិហារោ រជេន ឧហញ្ញីតិ
សង្ការំ វិចិនិត្វា ឯកមន្តំ ឆឌ្ឌេតព្វំ ភុម្មត្ថរណំ ឱតាបេត្វា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ អាចរិយវត្ត

ត្រូវលើកគ្រែបន្ទាបកុំឲ្យទង្គិចទង្គុក កុំឲ្យប៉ះសន្ទះទ្វារនឹងក្របទ្វារ នាំយកឲ្យស្រួលទៅដាក់ទុកក្នុងទីដ៏សមគួរ ត្រូវលើកបន្ទាបតាំងកុំឲ្យទង្គិចទង្គុក កុំឲ្យប៉ះសន្ទះទ្វារ នឹងក្របទ្វារ នាំយកឲ្យស្រួលទៅដាក់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកទ្រនាប់ជើងគ្រែទៅដាក់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកកន្ថោរសម្រាប់ស្ដោះទឹកមាត់ទៅដាក់ទុកក្នុងទីដ៏សមគួរ ត្រូវនាំយកក្ដារសម្រាប់ផ្អែកទៅដាក់ទុកក្នុងទីដ៏សមគួរ ត្រូវកំណត់ចាំទុកនូវកម្រាលផែនដីដែលគេក្រាលទុកនៅកន្លែងណា ហើយនាំយកទៅទុក ក្នុងទីដ៏សមគួរ បើក្នុងវិហារមានគ្រឿងស្មុកស្មាញ (មានសរសៃពីងពាងជាដើម) អន្តេវាសិក ត្រូវបោសពីពិតានចុះមកជាមុន ត្រូវជូតចំណែកជ្រុងសន្ទឹកបង្អួច បើជញ្ជាំងដែលគេបរិកម្មដោយថ្នាំរួចហើយ ត្រឡប់ជាមានប្រឡាក់ អន្តេវាសិក ត្រូវជ្រលក់កំណាត់សំពត់ ពូតហើយសឹមជូត បើផ្ទៃផែនដី ដែលគេបរិកម្មដោយវត្ថុមានពណ៌ខ្មៅរួចហើយ ត្រឡប់ជាមានប្រឡាក់ អន្តេវាសិក ត្រូវជ្រលក់កំណាត់សំពត់ពូតចេញរួចហើយសឹមជូត បើផ្ទៃគេមិនបានបរិកម្មទេ អន្តេវាសិក ត្រូវប្រស់ដោយទឹករួចសឹមជូត ដោយគិតថា វិហារកុំប្រឡាក់ដោយធូលីឡើយ ត្រូវប្រមូលសម្រាមយកទៅចាក់ចោលក្នុងទីដ៏សមគួរ លុះអន្តេវាសិក ហាលកម្រាលផែនដី ហើយជម្រះគោះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សោធេត្វា បប្ផោដេត្វា (១) អតិហរិត្វា យថាបញ្ញត្តំ បញ្ញបេតព្វំ មញ្ចប្បដិបាទកា ឱតាបេត្វា បមជ្ជិត្វា អតិហរិត្វា យថាឋានេ ឋបេតព្វា មញ្ចោ ឱតាបេត្វា សោធេត្វា បប្ផោដេត្វា នីចំ កត្វា សាធុកំ អប្បដិឃំសន្តេន អសង្ឃដ្ដេន្តេន កវាដបិដ្ឋំ អតិហរិត្វា យថាបញ្ញត្តំ បញ្ញបេតព្វោ បីឋំ ឱតាបេត្វា សោធេត្វា បប្ផោដេត្វា នីចំ កត្វា សាធុកំ អប្បដិឃំសន្តេន អសង្ឃដ្ដេន្តេន កវាដបិដ្ឋំ អតិហរិត្វា យថាបញ្ញត្តំ បញ្ញបេតព្វំ ភិសិពិព្វោហនំ ឱតាបេត្វា សោធេត្វា បប្ផោដេត្វា អតិហរិត្វា យថាបញ្ញត្តំ បញ្ញបេតព្វំ និសីទនប្បច្ចត្ថរណំ ឱតាបេត្វា សោធេត្វា បប្ផោដេត្វា អតិហរិត្វា យថាបញ្ញត្តំ បញ្ញបេតព្វំ ខេឡមល្លកោ ឱតាបេត្វា បមជ្ជិត្វា អតិហរិត្វា យថាឋានេ ឋបេតព្វោ អបស្សេនផលកំ ឱតាបេត្វា បមជ្ជិត្វា អតិហរិត្វា យថាឋានេ ឋបេតព្វំ បត្តចីវរំ និក្ខិបិតព្វំ បត្តំ និក្ខិបន្តេន ឯកេន ហត្ថេន បត្តំ គហេត្វា ឯកេន ហត្ថេន ហេដ្ឋាមញ្ចំ វា ហេដ្ឋាបីឋំ វា បរាមសិត្វា បត្តោ និក្ខិបិតព្វោ ន ច អនន្តរហិតាយ

---

១ ប. បប្ផោដេត្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(ដំបេញឲ្យស្អាត) រួចហើយសឹមនាំយកទៅក្រាលទុកដូចដែលវិញ ត្រូវហាលទ្រនាប់ជើងគ្រែរួចហើយជូត (ឲ្យស្អាត) ហើយនាំយកទៅដំកល់ទុកក្នុងទីដូចដែលវិញ ត្រូវហាលគ្រែរួចហើយជម្រះគោះ (ឲ្យស្អាត) រួចលើកបន្ទាបកុំឲ្យទង្គិចទង្គុក កុំឲ្យប៉ះសន្ទះទ្វារនឹងក្របទ្វារ នាំយកទៅដោយស្រួល ហើយតាំងទុកដូចដែលវិញ ត្រូវហាលតាំងរួចហើយត្រូវជម្រះគោះ (ឲ្យស្អាត) ហើយលើកបន្ទាបកុំឲ្យទង្គិចទង្គុក កុំឲ្យប៉ះសន្ទះទ្វារនឹងក្របទ្វារ នាំយកទៅដោយស្រួលតាំងទុកដូចដែលវិញ ត្រូវហាលពូកនឹងខ្នើយ ហើយជម្រះគោះ (ឲ្យស្អាត) ហើយនាំទៅរៀបចំទុកដាក់ដូចដែលវិញ ត្រូវសំដិលកម្រាលសម្រាប់ទ្រាប់អង្គុយ ហើយជម្រះគោះ (ឲ្យស្អាត) រួចនាំយកទៅក្រាលទុកដូចដែលវិញ ត្រូវហាលកន្ទោរសម្រាប់ស្ដោះទឹកមាត់ រួចហើយជូត (ឲ្យស្អាត) ហើយនាំយកទៅដំកល់ទុកក្នុងទីដូចដែលវិញ ត្រូវហាលផែនក្ដារសម្រាប់ផ្អែក រួចជូត (ឲ្យស្អាត) ហើយនាំយកទៅដំកល់ទុកក្នុងទីដូចដែលវិញ អាគន្តុកភិក្ខុ ត្រូវទុកដាក់បាត្រនឹងចីវរ កាលនឹងទុកបាត្រ ត្រូវយកដៃម្ខាងចាប់បាត្រ ដៃម្ខាងស្ទាបក្រោមគ្រែ ឬក្រោមតាំងរួចហើយសឹមទុកដាក់បាត្រ តែមិនត្រូវ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ អាចរិយវត្តំ

ភូមិយា បត្តោ និក្ខិបិតព្វោ ចីវរំ និក្ខិបន្តេន ឯកេន ហត្ថេន ចីវរំ គហេត្វា ឯកេន ហត្ថេន ចីវរវំសំ វា ចីវររជ្ជុំ វា បមជ្ជិត្វា បារតោ អន្តំ ឱរតោ ភោគំ កត្វា ចីវរំ និក្ខិបិតព្វំ សចេ បុរត្ថិមា សរជា វាតា វាយន្តិ បុរត្ថិមា វាតបានា ថកេតព្វា សចេ បច្ឆិមា សរជា វាតា វាយន្តិ បច្ឆិមា វាតបានា ថកេតព្វា សចេ ឧត្តរា សរជា វាតា វាយន្តិ ឧត្តរា វាតបានា ថកេតព្វា សចេ ទក្ខិណា សរជា វាតា វាយន្តិ ទក្ខិណា វាតបានា ថកេតព្វា សចេ សីតកាលោ ហោតិ ទិវា វាតបានា វិវរិតព្វា រត្តឹ ថកេតព្វា សចេ ឧណ្ហកាលោ ហោតិ ទិវា វាតបានា ថកេតព្វា រត្តឹ វិវរិតព្វា សចេ បរិវេណំ ឧក្លាបំ ហោតិ បរិវេណំ សម្មជ្ជិតព្វំ សចេ កោដ្ឋកោ ឧក្លាបោ ហោតិ កោដ្ឋកោ សម្មជ្ជិតព្វោ សចេ ឧបដ្ឋានសាលា ឧក្លាបា ហោតិ ឧបដ្ឋានសាលា សម្មជ្ជិតព្វា សចេ អគ្គិសាលា ឧក្លាបា ហោតិ អគ្គិសាលា សម្មជ្ជិតព្វា សចេ វច្ចកុដិ ឧក្លាបា ហោតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ អាចរិយវត្ត

ទុកបាត្រលើទីដែលមិនស្អាតឡើយ អន្តេវាសិកកាលនឹងទុកចីវរ ត្រូវយកដៃម្ខាងចាប់ចីវរ ដៃម្ខាងដូតស្នួរចីវរ ឬខ្សែស្បៀង ហើយធ្វើជាយខាងនាយឲ្យជាផ្ទត់មកខាងអាយ ហើយសឹមទុកចីវរ បើមានខ្យល់ទាំងធូលីបក់មកពីទិសខាងកើត អន្តេវាសិក ត្រូវបិទបង្អួចទិសខាងកើត បើខ្យល់មានទាំងធូលីបក់មកពីទិសខាងលិច អន្តេវាសិកត្រូវបិទបង្អួចទិសខាងលិច បើខ្យល់មានទាំងធូលីបក់មកទិសខាងជើង អន្តេវាសិកត្រូវបិទបង្អួចទិសខាងជើង បើខ្យល់មានទាំងធូលីបក់មកពីទិសខាងត្បូង អន្តេវាសិកត្រូវបិទបង្អួចទិសខាងត្បូង បើរដូវត្រជាក់ អន្តេវាសិក ត្រូវបើកបង្អួចក្នុងវេលាថ្ងៃ បិទក្នុងវេលាយប់ បើរដូវក្តៅ អន្តេវាសិក ត្រូវបិទបង្អួចក្នុងវេលាថ្ងៃ បើកក្នុងវេលាយប់ បើទីបរិវេណមានសម្រាម អន្តេវាសិកត្រូវបោសបរិវេណចេញ បើបន្ទប់មានសម្រាម អន្តេវាសិកត្រូវបោសបន្ទប់ចេញ បើរោងឆាន់មានសម្រាម អន្តេវាសិកត្រូវបោសរោងឆាន់ចេញ បើរោងភ្លើងមានសម្រាម អន្តេវាសិកត្រូវបោសរោងភ្លើងចេញ បើវច្ចកុដិមានសម្រាម អន្តេវាសិក

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



វច្ចកុដី សម្មជ្ជិតព្វា សចេ ន្ហានីយំ ហោតិ ន្ហានីយំ
ឧបដ្ឋាបេតព្វំ សចេ បរិភោជនីយំ ហោតិ បរិភោជនីយំ
ឧបដ្ឋាបេតព្វំ សចេ អាចមនកុម្ភិយា ឧទកំ ន ហោតិ
អាចមនកុម្ភិយា ឧទកំ អាសិញ្ចិតព្វំ សចេ អាចរិយស្ស
អនភិរតិ ឧប្បន្នា ហោតិ អន្តេវាសិកេន វូបកាសេតព្វោ
វូបកាសាបេតព្វោ ធម្មកថា វាស្ស កាតព្វា សចេ
អាចរិយស្ស កុក្កុច្ចំ ឧប្បន្នំ ហោតិ អន្តេវាសិកេន
វិនោទេតព្វំ វិនោទាបេតព្វំ ធម្មកថា វាស្ស កាតព្វា
សចេ អាចរិយស្ស ទិដ្ឋិគតំ ឧប្បន្នំ ហោតិ អន្តេវាសិ-
កេន វិវេចេតព្វំ វិវេចាបេតព្វំ ធម្មកថា វាស្ស កាតព្វា
សចេ អាចរិយោ គរុធម្មំ អជ្ឈាបន្នោ ហោតិ បរិវាសា-
រហោ អន្តេវាសិកេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ
សង្ឃោ អាចរិយស្ស បរិវាសំ ទទេយ្យាតិ សចេ អាច-
រិយោ មូលាយ បដិកស្សនារហោ ហោតិ អន្តេវាសិកេន
ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ សង្ឃោ អាចរិយំ
មូលាយ បដិកស្សេយ្យាតិ សចេ អាចរិយោ មានត្តា-

ត្រូវបោសវច្ចកុដិចេញ បើគ្មានទឹកសម្រាប់ឆាង អន្តេវាសិក ត្រូវដងកល់ទឹកសម្រាប់ឆាងទុក បើគ្មានទឹកសម្រាប់ប្រើប្រាស់ អន្តេវាសិក ត្រូវដងកល់ទឹកសម្រាប់ប្រើប្រាស់ បើទឹកក្នុងក្អមសម្រាប់ជម្រះគ្មាន អន្តេវាសិក ត្រូវចាក់ទឹកក្នុងក្អមសម្រាប់ជម្រះ បើសេចក្តីអផ្សុក កើតឡើងដល់អាចារ្យ អន្តេវាសិកត្រូវបំបាត់ដោយខ្លួនឯង ឬត្រូវឲ្យគេជួយបំបាត់ ឬធ្វើធម្មកថាដល់អាចារ្យនោះ បើសេចក្តីសង្ស័យ កើតឡើងដល់អាចារ្យ អន្តេវាសិកត្រូវបន្ទោបង់ដោយខ្លួនឯង ឬត្រូវឲ្យគេជួយបន្ទោបង់ ឬធ្វើធម្មកថាដល់អាចារ្យនោះ បើទិដ្ឋិ(សេចក្តីយល់ខុស) កើតឡើងដល់អាចារ្យ អន្តេវាសិកត្រូវដោះស្រាយដោយខ្លួនឯង ឬត្រូវឲ្យគេជួយដោះស្រាយ ឬធ្វើធម្មកថាដល់អាចារ្យនោះ បើអាចារ្យត្រូវគរុកាបត្តិគួរដល់បរិវាសកម្ម អន្តេវាសិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យបរិវាសកម្ម ដល់អាចារ្យដោយឧបាយដូចម្តេចហ្ន៎ បើអាចារ្យគួរដល់មូលាយបដិកស្សនៈ(ទាញមកដាក់ក្នុងមូលាបត្តិ) អន្តេវាសិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីទាញអាចារ្យមកដាក់ក្នុងមូលាបត្តិ ដោយឧបាយដូចម្តេចហ្ន៎ បើអាចារ្យគួរដល់មានត្ត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ អាចរិយវត្តំ

វេលា ហោតិ អន្តេវាសិកេន ឧស្សុក្កំ កាតព្ពំ កិន្តិ នុ ខោ សង្ឃោ អាចរិយស្ស មានត្តំ ទទេយ្យាតិ សចេ អាចរិយោ អព្ភានារហោ ហោតិ អន្តេវាសិកេន ឧស្សុក្កំ កាតព្ពំ កិន្តិ នុ ខោ សង្ឃោ អាចរិយំ អព្ភេយ្យាតិ សចេ សង្ឃោ អាចរិយស្ស កម្មំ កត្តុកាមោ ហោតិ តជ្ជនីយំ វា និយស្សំ វា បព្វាជនីយំ វា បដិសារណីយំ វា ឧក្ខេបនីយំ វា អន្តេវាសិកេន ឧស្សុក្កំ កាតព្ពំ កិន្តិ នុ ខោ សង្ឃោ អាចរិយស្ស កម្មំ ន ករេយ្យ លហុកាយ វា បរិណាមេយ្យាតិ កតំ វា បនស្ស ហោតិ សង្ឃេន កម្មំ តជ្ជនីយំ វា និយស្សំ វា បព្វាជនីយំ វា បដិសារណីយំ វា ឧក្ខេបនីយំ វា អន្តេវាសិកេន ឧស្សុក្កំ កាតព្ពំ កិន្តិ នុ ខោ អាចរិយោ សម្មា វត្តេយ្យ លោមំ បាតេយ្យ នេត្ថារំ វត្តេយ្យ សង្ឃោ តំ កម្មំ បដិប្បស្សម្ភេយ្យាតិ សចេ អាចរិយស្ស ចីវរំ ធោវិតព្ពំ ហោតិ អន្តេវាសិកេន ធោវិតព្ពំ ឧស្សុក្កំ វា កាតព្ពំ កិន្តិ នុ ខោ អាចរិយស្ស ចីវរំ ធោវិយេថាតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ អាចរិយវត្ត

អន្តេវាសិក ត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យមានត្តដល់អាចារ្យ ដោយឧបាយដូចម្ដេចហ្ន៎ បើអាចារ្យគួរដល់អព្ភានកម្ម អន្តេវាសិកត្រូវធ្វើ សេចក្ដីខ្វល់ខ្វាយថា សង្ឃគប្បីធ្វើអព្ភានកម្មដល់អាចារ្យដោយឧបាយដូច ម្ដេចហ្ន៎ បើសង្ឃមានប្រាថ្នាដើម្បីធ្វើកម្ម គឺ តជ្ជនីយកម្មក្ដី និយស្សកម្មក្ដី បព្វាជនីយកម្មក្ដី បដិសារណីយកម្មក្ដី ឧក្ខេបនីយកម្មក្ដី ដល់អាចារ្យហើយ អន្តេវាសិក ត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា សង្ឃគប្បីធ្វើកម្ម ដល់អាចារ្យ ឬសង្ឃបង្អោនទៅដើម្បីកម្មដ៏ស្រាលដល់អាចារ្យ ដោយឧបាយដូចម្ដេចហ្ន៎ មួយវិញទៀត បើកម្ម គឺ តជ្ជនីយកម្មក្ដី និយស្សកម្មក្ដី បព្វាជនីយកម្មក្ដី បដិសារណីយកម្មក្ដី ឧក្ខេបនីយកម្មក្ដី ដែលសង្ឃបានធ្វើដល់អាចារ្យ រួចហើយ អន្តេវាសិក ត្រូវធ្វើសេចក្ដីខ្វល់ខ្វាយថា អាចារ្យគប្បីប្រព្រឹត្ត ដោយប្រពៃ គប្បីសម្ងបរោម គប្បីប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួន ចេញចាកកម្ម សង្ឃគប្បីរម្ងាប់នូវកម្មនោះ ដោយឧបាយដូចម្ដេចហ្ន៎ បើ ចីវររបស់អាចារ្យគួរនឹងលាង អន្តេវាសិក ត្រូវលាងប្រគេន ឬត្រូវធ្វើ សេចក្ដីខ្វល់ខ្វាយថា ចីវររបស់អាចារ្យគួរនឹងលាងដោយឧបាយដូចម្ដេចហ្ន៎

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សចេ អាចរិយស្ស ចីវរំ កាតព្វំ ហោតិ អន្តេវាសិកេន កាតព្វំ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ អាចរិយស្ស ចីវរំ ករិយេថាតិ សចេ អាចរិយស្ស រជនំ បចិតព្វំ(១) ហោតិ អន្តេវាសិកេន បចិតព្វំ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ អាចរិយស្ស រជនំ បចិយេថាតិ សចេ អាចរិយស្ស ចីវរំ រជេតព្វំ ហោតិ អន្តេវាសិកេន រជេតព្វំ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ អាចរិយស្ស ចីវរំ រជិយេថាតិ ចីវរំ រជេន្តេន(២) សាធុកំ សម្បរិវត្តកំ សម្បរិវត្តកំ រជេតព្វំ ន ច អច្ឆិន្នេ ថេវេ បក្កមិតព្វំ ន អាចរិយំ អនាបុច្ឆា ឯកច្ចស្ស បត្តោ ទាតព្វោ ន ឯកច្ចស្ស បត្តោ បដិគ្គហេតព្វោ ន ឯកច្ចស្ស ចីវរំ ទាតព្វំ ន ឯកច្ចស្ស ចីវរំ បដិគ្គហេតព្វំ ន ឯកច្ចស្ស បរិក្ខារោ ទាតព្វោ ន ឯកច្ចស្ស បរិក្ខារោ បដិគ្គហេតព្វោ ន ឯកច្ចស្ស កេសា ឆេទេតព្វា ន ឯកច្ចេន កេសា ឆេទាបេតព្វា ន ឯកច្ចស្ស បរិកម្មំ កាតព្វំ ន ឯកច្ចេន បរិកម្មំ ការាបេតព្វំ ន ឯកច្ចស្ស វេយ្យាវច្ចោ

---

១ សព្វត្ថ រជនា បចិតព្វាតិ ឯវមេវ បញ្ញាយតិ ។ ២ ម. រជន្តេន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បើចីវររបស់អាចារ្យគ្រូនឹងធ្វើ អន្តេវាសិក ត្រូវធ្វើប្រគេន ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់អាចារ្យគ្រូនឹងធ្វើ ដោយឧបាយដូចម្តេចហ្ន៎ បើគ្រឿងជ្រលក់របស់អាចារ្យគ្រូនឹងស្ងោរ អន្តេវាសិកត្រូវស្ងោរប្រគេន ឬធ្វើសេចក្តីខ្វល់ខ្វាយថា គ្រឿងជ្រលក់របស់អាចារ្យគ្រូនឹងស្ងោរដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់អាចារ្យ គ្រូនឹងជ្រលក់ អន្តេវាសិក ត្រូវជ្រលក់ប្រគេន ឬធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់អាចារ្យគ្រូនឹងជ្រលក់ដោយឧបាយដូចម្តេចហ្ន៎ អន្តេវាសិកកាលនឹងជ្រលក់ចីវរ ត្រូវជ្រលក់ប្រែត្រឡប់ឲ្យស្រព្វល្អ មួយទៀត កាលបើដំណក់ទឹកស្រក់ពុំទាន់អស់ អន្តេវាសិកកុំអាលចៀសចេញទៅឡើយ អន្តេវាសិក មិនទាន់ប្រាប់អាចារ្យ មិនត្រូវឲ្យបាត្រ ដល់ភិក្ខុណាមួយ មិនត្រូវទទួលបាត្ររបស់ភិក្ខុណាមួយ មិនត្រូវឲ្យចីវរ ដល់ភិក្ខុណាមួយ មិនត្រូវទទួលយកចីវររបស់ភិក្ខុណាមួយ មិនត្រូវឲ្យបរិក្ខារដល់ភិក្ខុណាមួយ មិនត្រូវទទួលបរិក្ខាររបស់ភិក្ខុណាមួយ មិនត្រូវកោរសក់ឲ្យភិក្ខុណាមួយ មិនត្រូវឲ្យអ្នកណាមួយមកកោរសក់ខ្លួនឡើយ មិនត្រូវធ្វើបរិកម្ម (គក់ច្របាច់) ដល់ភិក្ខុណាមួយ មិនត្រូវឲ្យអ្នកណាមួយធ្វើបរិកម្មដល់ខ្លួន មិនត្រូវធ្វើវេយ្យាវច្ចៈ ដល់ភិក្ខុណាមួយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កាតព្វោ ន ឯកច្ចេន វេយ្យាវច្ចោ ការាបេតព្វោ ន ឯកច្ចស្ស បច្ឆាសមណេន ហោតព្វំ ន ឯកច្ចោ បច្ឆាសមណោ អាទាតព្វោ ន ឯកច្ចស្ស បិណ្ឌបាតោ នីហរិតព្វោ ន ឯកច្ចេន បិណ្ឌបាតោ នីហរាបេតព្វោ ន អាចរិយំ អនាបុច្ឆា គាមោ បវិសិតព្វោ ន សុសានំ គន្តព្វំ ន ទិសា បក្កមិតព្វា សចេ អាចរិយោ គិលានោ ហោតិ យាវជីវំ ឧបដ្ឋាតព្វោ វុដ្ឋានមស្ស អាគមេតព្វំ ឥទំ ខោ ភិក្ខវេ អន្តេវាសិកានំ អាចរិយេសុ វត្តំ យថា អន្តេវាសិកេហិ អាចរិយេសុ សម្មា វត្តិតព្វន្តិ ។

[១០៨] តេន ខោ បន សមយេន អាចរិយា អន្តេវាសិកេសុ ន សម្មា វត្តន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាចរិយា អន្តេវាសិកេសុ ន សម្មា វត្តិស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ

មិនត្រូវឲ្យភិក្ខុណាមួយ ធ្វើវេយ្យាវច្ចៈដល់ខ្លួន មិនត្រូវធ្វើជាបច្ឆាសមណៈរបស់ភិក្ខុណាមួយ មិនត្រូវកាន់យកភិក្ខុណាមួយ(ធ្វើជា)បច្ឆាសមណៈរបស់ខ្លួន មិនត្រូវនាំបិណ្ឌបាតទៅឲ្យភិក្ខុណាមួយ មិនត្រូវឲ្យភិក្ខុណាមួយ នាំបិណ្ឌបាតមកឲ្យខ្លួន អន្តេវាសិកមិនទាន់លាអាចារ្យ មិនត្រូវចូលទៅកាន់ស្រុក មិនត្រូវទៅកាន់ព្រៃស្មសាន មិនត្រូវចៀសទៅកាន់ទិស បើអាចារ្យមានជម្ងឺ អន្តេវាសិកត្រូវថែទាំអស់កាលដែលលោករស់នៅ អន្តេវាសិកត្រូវរង់ចាំត្រាតែអាចារ្យស្រះជាជម្ងឺ ម្នាលភិក្ខុទាំងឡាយ ទាំងនេះជាអាចរិយវត្តរបស់អន្តេវាសិកទាំងឡាយ តាមទំនងដែលអន្តេវាសិក ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងអាចារ្យទាំងឡាយ ។

(១០៨) សម័យនោះឯង ពួកអាចារ្យពុំបានប្រព្រឹត្តដោយប្រពៃក្នុងអន្តេវាសិកទាំងឡាយ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ល។ ភិក្ខុទាំងនោះពោលទោស តិះដៀល បន្ទះបង្អាប់ថា មិនសមបើពួកអាចារ្យមិនប្រព្រឹត្តដោយប្រពៃ ក្នុងអន្តេវាសិកទាំងឡាយសោះ ។ ភិក្ខុទាំងនោះបានក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរចំពោះភិក្ខុទាំងឡាយ ក្នុងពេលនោះថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សច្ចំ កិរ ភិក្ខវេ អាចរិយា អន្តេវាសិកេសុ ន សម្មា វត្តន្តីតិ ។ សច្ចំ ភគវាតិ ។ បេ ។ វិគរហិត្វា ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ អាចរិយានំ អន្តេវាសិកេសុ វត្តំ បញ្ញាបេស្សាមិ យថា អាចរិយេហិ អន្តេវាសិកេសុ សម្មា វត្តិតព្វំ ។

(១០៩) អាចរិយេន ភិក្ខវេ អន្តេវាសិកម្ហិ សម្មា វត្តិតព្វំ ។ តត្រាយំ សម្មាវត្តនា អាចរិយេន ភិក្ខវេ អន្តេវាសិកោ សង្គហេតព្វោ អនុគ្គហេតព្វោ ឧទ្ទេសេន បរិបុច្ឆាយ ឱវាទេន អនុសាសនិយា សចេ អាចរិយស្ស បត្តោ ហោតិ អន្តេវាសិកស្ស បត្តោ ន ហោតិ អាចរិយេន អន្តេវាសិកស្ស បត្តោ ទាតព្វោ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ អន្តេវាសិកស្ស បត្តោ ឧប្បជ្ជិយេថាតិ សចេ អាចរិយស្ស ចីវរំ ហោតិ អន្តេវាសិកស្ស ចីវរំ ន ហោតិ អាចរិយេន អន្តេវាសិកស្ស ចីវរំ ទាតព្វំ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ អន្តេវាសិកស្ស ចីវរំ ឧប្បជ្ជិយេថាតិ សចេ អាចរិយស្ស បរិក្ខារោ ហោតិ អន្តេវាសិកស្ស

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ម្នាលភិក្ខុទាំងឡាយ ពួកអាចារ្យពុំបានប្រព្រឹត្តដោយប្រពៃ ក្នុងអន្តេវាសិកទាំងឡាយ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា ពិតមែន ព្រះអង្គ ។បេ។ ព្រះសព្វញ្ញូជាម្ចាស់ ទ្រង់បន្ទោស ហើយធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តអន្តេវាសិកវត្តដល់អាចារ្យទាំងឡាយ តាមទំនងដែលអាចារ្យទាំងឡាយ ត្រូវប្រព្រឹត្តដោយប្រពៃ ក្នុងអន្តេវាសិកទាំងឡាយ ។

(១០៩) ម្នាលភិក្ខុទាំងឡាយ អាចារ្យត្រូវប្រព្រឹត្ត ដោយប្រពៃ ក្នុងអន្តេវាសិក ។ ការដែលប្រព្រឹត្តិដោយប្រពៃក្នុងអន្តេវាសិកនោះដូច្នេះ ម្នាលភិក្ខុទាំងឡាយ អាចារ្យត្រូវសង្គ្រោះ ត្រូវអនុគ្រោះអន្តេវាសិកដោយបាលី ដោយអដ្ឋកថា ដោយធម្មទាន ដោយការប្រៀនប្រដៅ បើអាចារ្យមានបាត្រ អន្តេវាសិកគ្មានបាត្រ ត្រូវអាចារ្យឲ្យបាត្រទៅអន្តេវាសិកឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា បាត្រគប្បីកើតឡើងដល់អន្តេវាសិកដោយឧបាយដូចម្តេចហ្ន៎ បើអាចារ្យមានចីវរ អន្តេវាសិកគ្មានចីវរ ត្រូវអាចារ្យឲ្យចីវរទៅអន្តេវាសិក ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ចីវរគប្បីកើតឡើងដល់អន្តេវាសិកដោយឧបាយដូចម្តេចហ្ន៎ បើអាចារ្យមានគ្រឿងបរិក្ខារ អន្តេវាសិក

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ អន្តេវាសិកវត្តំ

បរិក្ខារោ ន ហោតិ អាចរិយេន អន្តេវាសិកស្ស ប-
រិក្ខារោ ទាតព្វោ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ
អន្តេវាសិកស្ស បរិក្ខារោ ឧប្បជ្ជេយ្យាតិ សចេ អន្តេ-
វាសិកោ គិលានោ ហោតិ កាលស្សេវ ឧដ្ឋាយ ទន្ត-
កដ្ឋំ ទាតព្វំ មុខោទកំ ទាតព្វំ អាសនំ បញ្ញាបេតព្វំ
សចេ យាគុ ហោតិ ភាជនំ ធោវិត្វា យាគុ ឧបនា-
មេតព្វា យាគុំ បីតស្ស ឧទកំ ទត្វា ភាជនំ បដិគ្គហេ-
ត្វា នីចំ កត្វា សាធុកំ អបរិឃំសន្តេន ធោវិត្វា
បដិសាមេតព្វំ អន្តេវាសិកម្ហិ វុដ្ឋិតេ អាសនំ ឧទ្ធរិតព្វំ
សចេ សោ ទេសោ ឧក្លាបោ ហោតិ សោ ទេសោ
សម្មជ្ជិតព្វោ សចេ អន្តេវាសិកោ គាមំ បវិសិតុកា-
មោ ហោតិ និវាសនំ ទាតព្វំ បដិនិវាសនំ បដិគ្គហេ-
តព្វំ កាយពន្ធនំ ទាតព្វំ សគុណំ កត្វា សង្ឃា-
ដិយោ ទាតព្វា ធោវិត្វា បត្តោ សោទកោ ទាតព្វោ
ឯត្តាវតា និវត្តិស្សតីតិ អាសនំ បញ្ញាបេតព្វំ បាទោទកំ
បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបិតព្វំ បច្ចុគ្គន្ត្វា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ អន្តេវាសិកវត្ត

គ្មានគ្រឿងបរិក្ខារ ត្រូវអាចារ្យឱ្យគ្រឿងបរិក្ខារទៅអន្តេវាសិក ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា គ្រឿងបរិក្ខារគប្បីកើតឡើង ដល់អន្តេវាសិកដោយឧបាយដូចម្តេចហ្ន៎ បើអន្តេវាសិកមានជម្ងឺ អាចារ្យត្រូវក្រោកពីព្រឹកហើយឱ្យឈើស្ទន់ ឱ្យទឹកសម្រាប់លាងមុខ ក្រាលអាសនៈ បើមានបបរ អាចារ្យត្រូវលាងភាជន៍ហើយបង្អោនបបរឱ្យទៅ កាលអន្តេវាសិក ហុតបបររួចហើយ អាចារ្យត្រូវឱ្យទឹក រួចទទួលយកភាជន៍មកវិញ កាន់បន្ទាបកុំឱ្យទង្គិចទង្គុក (អ៊ី) ហើយរៀបចំទុកដាក់ឱ្យល្អ កាលបើអន្តេវាសិកក្រោកចេញហើយ អាចារ្យត្រូវសារអាសនៈចេញ បើប្រទេសនោះមានសម្រាម អាចារ្យត្រូវបោសប្រទេសនោះចេញ បើអន្តេវាសិកមានប្រាថ្នា ដើម្បីនឹងចូលទៅកាន់ស្រុក អាចារ្យត្រូវឱ្យស្បង់សម្រាប់ស្លៀកហើយទទួលយកស្បង់បន្លាស់មកវិញ ត្រូវឱ្យវត្ថពន្ធបង្កេះ ត្រូវតម្រួតឧត្តរាសង្គៈនឹងសង្ឃាដិហើយឱ្យ ត្រូវជូតបាត្រដែលទទឹកហើយសឹមឱ្យ អាចារ្យត្រូវក្រាលអាសនៈទុក ដោយគិតថា អន្តេវាសិកមុខជានឹងត្រឡប់មកវិញ ក្នុងវេលានេះ ត្រូវដំកល់ទឹកលាងជើង តាំងសម្រាប់រងជើងដែលលាងហើយ នឹងទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់បានលាង ត្រូវក្រោកទៅទទួល

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដកេ ចុល្លវគ្គោ

បត្តចីវរំ បដិគ្គហេតព្វំ បដិនិវាសនំ ទាតព្វំ និវាសនំ បដិគ្គហេតព្វំ សចេ ចីវរំ សិន្នំ ហោតិ មុហុត្តំ ឧណ្ហេ ឱតាបេតព្វំ ន ច ឧណ្ហេ ចីវរំ និទហិតព្វំ ចីវរំ សំហរិតព្វំ ចីវរំ សំហរន្តេន ចតុរង្គុលំ កណ្ណំ ឧស្សារេត្វា ចីវរំ សំហរិតព្វំ មា មជ្ឈេ ភង្គោ អហោសីតិ ឱភោគេ កាយពន្ធនំ កាតព្វំ សចេ បិណ្ឌបាតោ ហោតិ អន្តេវាសិកោ ច ភុញ្ជិតុកាមោ ហោតិ ឧទកំ ទត្វា បិណ្ឌបាតោ ឧបនាមេតព្វោ អន្តេវាសិកោ បានីយេន បុច្ឆិតព្វោ ភុត្តាវិស្ស ឧទកំ ទត្វា បត្តំ បដិគ្គហេត្វា នីចំ កត្វា សាធុកំ អប្បដិឃំសន្តេន ធោវិត្វា វោទកំ កត្វា មុហុត្តំ ឧណ្ហេ ឱតាបេតព្វោ ន ច ឧណ្ហេ បត្តោ និទហិតព្វោ បត្តចីវរំ និក្ខិបិតព្វំ បត្តំ និក្ខិបន្តេន ។ បេ ។ ចីវរំ និក្ខិបន្តេន ។ បេ ។ បារតោ អន្តំ ឱរតោ ភោគំ កត្វា ចីវរំ និក្ខិបិតព្វំ អន្តេវាសិកម្ហិ វុដ្ឋិតេ អាសនំ ឧទ្ធរិតព្វំ បាទោទកំ បាទបីឋំ បាទកឋលិកំ បដិសាមេតព្វំ សចេ សោ ទេសោ ឧក្លាបោ ហោតិ សោ ទេសោ សម្មជ្ជិតព្វោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដក ចុល្លវគ្គ

បាត្រនឹងចីវរ ត្រូវឲ្យស្បង់បន្ទាស់ហើយទទួលយកស្បង់ដែលស្លៀកមកវិញ បើចីវរសើមឬជាំជាម ( ដោយញើសក្អួល ) ត្រូវសំដិលចីវរក្នុងកំដៅថ្ងៃមួយស្របក់ តែកុំទុកចីវរក្នុងកំដៅថ្ងៃ ( ឲ្យយូរពេក ) អាចារ្យត្រូវបត់ចីវរ កាលនឹងបត់ចីវរ ត្រូវលើកជាយចីវរឲ្យហួសពីគ្នាប្រមាណ ៤ ធ្នាប់ ហើយសឹមបត់ចីវរ ដោយគិតថា កុំឲ្យបាក់ផ្នត់ពាក់កណ្ដាលឡើយ ត្រូវធ្វើវត្ថុពន្ធបង្កើះក្នុងផ្នត់ចីវរ បើអាហារបិណ្ឌបាតមាន ហើយអន្តេវាសិកត្រូវការចង់ឆាន់ អាចារ្យត្រូវឲ្យទឹកហើយបង្អោនអាហារបិណ្ឌបាតចូលទៅ អាចារ្យត្រូវសួរអន្តេវាសិកដោយទឹកឆាន់ លុះអន្តេវាសិក ឆាន់រួចហើយ អាចារ្យត្រូវឲ្យទឹកហើយទទួលយកបាត្រមកវិញ កាន់បន្ទាបកុំឲ្យទង្គិចទង្គុក ហើយលាងឲ្យស្អាត ជូតឲ្យស្ងួតទឹកចេញ ហើយហាលថ្ងៃមួយស្របក់ តែមិនត្រូវទុកបាត្រក្នុងកំដៅថ្ងៃ ( ឲ្យយូរពេក ) អាចារ្យត្រូវទុកបាត្រនឹងចីវរ កាលដែលរៀបចំទុកដាក់បាត្រ ។បេ។ កាលដែលរៀបចំទុកចីវរ ។ បេ ។ ត្រូវបត់ជាយចីវរខាងនាយឲ្យជាផ្នត់មកខាងអាយ ហើយសឹមទុកចីវរចុះ កាលអន្តេវាសិក ក្រោកចេញហើយ អាចារ្យត្រូវសារអាសនៈចេញ ត្រូវរៀបចំទុកដាក់ទឹកសម្រាប់លាងជើង តាំងសម្រាប់ជើង ជើងដែលលាងហើយ នឹងទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង បើប្រទេសនោះមានសម្រាម អាចារ្យត្រូវបោសប្រទេសនោះចេញ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ អន្តេវាសិកវត្តំ

សចេ អន្តេវាសិកោ នហាយិតុកាមោ ហោតិ នហានំ បដិយាទេតព្វំ សចេ សីតេន អត្ថោ ហោតិ សីតំ បដិយាទេតព្វំ សចេ ឧណ្ហេន អត្ថោ ហោតិ ឧណ្ហំ បដិយាទេតព្វំ សចេ អន្តេវាសិកោ ជន្តាឃរំ បវិសិតុកាមោ ហោតិ ចុណ្ណំ សន្នេតព្វំ មត្តិកា តេមេតព្វា ជន្តាឃរបីឋំ អាទាយ គន្ត្វា ជន្តាឃរបីឋំ ទត្វា ចីវរំ បដិគ្គហេត្វា ឯកមន្តំ និក្ខិបិតព្វំ ចុណ្ណំ ទាតព្វំ មត្តិកា ទាតព្វា សចេ ឧស្សហតិ ជន្តាឃរំ បវិសិតព្វំ ជន្តាឃរំ បវិសន្តេន មត្តិកាយ មុខំ មក្ខេត្វា បុរតោ ច បច្ឆតោ ច បដិច្ឆាទេត្វា ជន្តាឃរំ បវិសិតព្វំ ន ថេរេ ភិក្ខូ អនុបខជ្ជ និសីទិតព្វំ ន នវា ភិក្ខូ អាសនេន បដិពាហិតព្វា ជន្តាឃរេ អន្តេវាសិកស្ស បរិកម្មំ កាតព្វំ ជន្តាឃរា និក្ខមន្តេន ជន្តាឃរបីឋំ អាទាយ បុរតោ ច បច្ឆតោ ច បដិច្ឆាទេត្វា ជន្តាឃរា និក្ខមិតព្វំ ឧទកេបិ អន្តេវាសិកស្ស បរិកម្មំ កាតព្វំ នហាតេន បឋមតរំ ឧត្តរិត្វា អត្តនោ គត្តំ វោទកំ កត្វា និវាសេត្វា អន្តេវាសិកស្ស គត្តតោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ អន្តេវាសិកវត្ត

បើអន្តេវាសិកចង់ងូតទឹក អាចារ្យត្រូវតាក់តែងទឹកសម្រាប់ងូតឲ្យ បើអន្តេវាសិកត្រូវការដោយទឹកត្រជាក់ អាចារ្យត្រូវតាក់តែងទឹកត្រជាក់ឲ្យ បើអន្តេវាសិកត្រូវការដោយទឹកក្តៅ អាចារ្យត្រូវតាក់តែងទឹកក្តៅឲ្យ បើអន្តេវាសិកចង់ចូលទៅកាន់ផ្ទះជាទីក្យោកាយ អាចារ្យត្រូវសូនគ្រឿងលំអិត ត្រូវលាយដីស្អិត ត្រូវកាន់យកតាំងសម្រាប់ផ្ទះជាទីក្យោកាយហើយទៅ ឲ្យតាំងសម្រាប់ផ្ទះជាទីក្យោកាយ រួចហើយទទួលយកចីវរមកទុកដាក់ក្នុងទីដ៏សមគួរ ត្រូវឲ្យគ្រឿងលំអិត ត្រូវឲ្យដីស្អិត បើអាចារ្យអាច (នឹងចូលទៅបាន) ត្រូវចូលទៅកាន់ផ្ទះជាទីក្យោកាយចុះ កាលនឹងចូលទៅកាន់ផ្ទះជាទីក្យោកាយ ត្រូវយកដីស្អិតលាបមុខហើយបិទបាំងទាំងខាងមុខទាំងខាងក្រោយ ហើយសឹមចូលទៅកាន់ផ្ទះជាទីក្យោកាយ មិនត្រូវអង្គុយជ្រៀតបៀតពួកភិក្ខុជាថេរៈ មិនត្រូវហាមឃាត់ពួកភិក្ខុនវៈដោយអាសនៈ អាចារ្យត្រូវធ្វើបរិកម្មដល់អន្តេវាសិកក្នុងផ្ទះជាទីក្យោកាយ កាលនឹងចេញពីផ្ទះជាទីក្យោកាយ ត្រូវយកតាំងសម្រាប់ផ្ទះជាទីក្យោកាយ ហើយបិទបាំងទាំងខាងមុខ ទាំងខាងក្រោយ ហើយសឹមចេញពីផ្ទះជាទីក្យោកាយ សូម្បីក្នុងទឹក អាចារ្យក៏ត្រូវតែធ្វើបរិកម្មដល់អន្តេវាសិកដែរ លុះអាចារ្យងូតទឹករួចហើយ ត្រូវឡើងមកមុន ហើយជូតខ្លួនឲ្យស្ងួតទឹករួចស្លៀកស្បង់ ហើយជូតទឹកអំពីខ្លួន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឧទកំ បមជ្ជិតព្វំ និវាសនំ ទាតព្វំ សង្ឃាដិ ទាតព្វា ជន្តាឃរបីឋំ អាទាយ បឋមតរំ អាគន្ត្វា អាសនំ បញ្ញាបេតព្វំ បាទោទកំ បាទបីឋំ បាទកឋលិកំ ឧបនិក្ខិបិតព្វំ អន្តេវាសិកោ បានីយេន បុច្ឆិតព្វោ យស្មឹ វិហារេ អន្តេវាសិកោ វិហរតិ សចេ សោ វិហារោ ឧក្លាបោ ហោតិ សចេ ឧស្សហតិ សោធេតព្វោ វិហារំ សោធេន្តេន បឋមំ បត្តចីវរំ នីហរិត្វា ឯកមន្តំ និក្ខិបិតព្វំ ។ បេ ។ សចេ អាចមនកុម្ភិយា ឧទកំ ន ហោតិ អាចមនកុម្ភិយា ឧទកំ អាសិញ្ចិតព្វំ សចេ អន្តេវាសិកស្ស អនភិរតិ ឧប្បន្នា ហោតិ អាចរិយេន វូបកាសេតព្វោ វូបកាសាបេតព្វោ ធម្មកថា វាស្ស កាតព្វា សចេ អន្តេវាសិកស្ស កុក្កុច្ចំ ឧប្បន្នំ ហោតិ អាចរិយេន វិនោទេតព្វំ វិនោទាបេតព្វំ ធម្មកថា វាស្ស កាតព្វា សចេ អន្តេវាសិកស្ស ទិដ្ឋិគតំ ឧប្បន្នំ ហោតិ អាចរិយេន វិវេចេតព្វំ វិវេចាបេតព្វំ ធម្មកថា វាស្ស កាតព្វា សចេ អន្តេវាសិកោ គរុធម្មំ អជ្ឈាបន្នោ ហោតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



របស់អន្តេវាសិក ត្រូវឲ្យស្បង់សម្រាប់ស្លៀក ត្រូវឲ្យសង្ឃាដិ ត្រូវនាំយកតាំងសម្រាប់ផ្ទះដាក់ភ្លើងកាយមកមុន ហើយក្រាលអាសនៈចាំ ត្រូវដំកល់ទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើងដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់បានលាង ត្រូវសួរអន្តេវាសិក ដោយទឹកសម្រាប់ឆាន់ អន្តេវាសិកនៅក្នុងវិហារណា បើវិហារនោះមានសម្រាម បើអាចារ្យអាច (នឹងសំអាតបាន) ត្រូវសំអាត កាលនឹងសំអាតវិហារ ត្រូវនាំយកបាត្រនិងចីវរចេញមុន ទៅទុកដាក់ក្នុងទីដ៏សមគួរ ។ បេ ។ បើគ្មានទឹកក្នុងក្អមសម្រាប់ជម្រះ អាចារ្យត្រូវដាក់ទឹកទៅក្នុងក្អមសម្រាប់ជម្រះ បើសេចក្តីអផ្សុកកើតឡើងដល់អន្តេវាសិក អាចារ្យត្រូវរម្ងាប់ដោយខ្លួនឯង ឬត្រូវឲ្យគេជួយរម្ងាប់ ឬធ្វើធម្មកថាដល់អន្តេវាសិកនោះ បើសេចក្តីសង្ស័យកើតឡើងដល់អន្តេវាសិក អាចារ្យត្រូវបន្ទោបង់ដោយខ្លួនឯង ឬត្រូវឲ្យគេជួយបន្ទោបង់ ឬធ្វើធម្មកថាដល់អន្តេវាសិកនោះ បើទិដ្ឋិ (អាក្រក់) កើតឡើងដល់អន្តេវាសិក អាចារ្យត្រូវដោះស្រាយដោយខ្លួនឯង ឬត្រូវឲ្យគេជួយដោះស្រាយ ឬធ្វើធម្មកថាដល់អន្តេវាសិកនោះ បើអន្តេវាសិកត្រូវគរុកាបត្តិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ អន្តេវាសិកវត្តំ

បរិវាសារហោ អាចរិយេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ សង្ឃោ អន្តេវាសិកស្ស បរិវាសំ ទទេយ្យាតិ សចេ អន្តេវាសិកោ មូលាយ បដិកស្សនារហោ ហោតិ អាចរិយេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ សង្ឃោ អន្តេវាសិកំ មូលាយ បដិកស្សេយ្យាតិ សចេ អន្តេវាសិកោ មានត្តារហោ ហោតិ អាចរិយេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ សង្ឃោ អន្តេវាសិកស្ស មានត្តំ ទទេយ្យាតិ សចេ អន្តេវាសិកោ អព្ភានារហោ ហោតិ អាចរិយេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ សង្ឃោ អន្តេវាសិកំ អព្ភេយ្យាតិ សចេ សង្ឃោ អន្តេវាសិកស្ស កម្មំ កត្តុកាមោ ហោតិ តជ្ជនីយំ វា និយស្សំ វា បព្វាជនីយំ វា បដិសារណីយំ វា ឧក្ខេបនីយំ វា អាចរិយេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ សង្ឃោ អន្តេវាសិកស្ស កម្មំ ន ករេយ្យ លហុកាយ វា បរិណាមេយ្យាតិ កតំ វា បនស្ស ហោតិ សង្ឃេន កម្មំ តជ្ជនីយំ វា និយស្សំ វា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ អន្តេវាសិកវត្ត

គួរដល់បរិវាសកម្ម អាចារ្យត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យបរិវាស ដល់អន្តេវាសិក ដោយឧបាយដូចម្តេចហ្ន៎ បើអន្តេវាសិកគួរដល់មូលាយ-បដិកស្សនៈ ( ទាញមកដាក់ក្នុងមូលាបត្តិ ) អាចារ្យត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីទាញអន្តេវាសិកមកដាក់ក្នុងមូលាបត្តិដោយឧបាយដូចម្តេចហ្ន៎ បើអន្តេវាសិកគួរដល់មានត្ត អាចារ្យត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យមានត្តដល់អន្តេវាសិកដោយឧបាយដូចម្តេចហ្ន៎ បើអន្តេវាសិកគួរដល់អព្ភានកម្ម អាចារ្យត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃគប្បីឲ្យអព្ភាន-កម្មដល់អន្តេវាសិក ដោយឧបាយដូចម្តេចហ្ន៎ បើសង្ឃប្រាថ្នានឹងធ្វើកម្ម គឺ តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេ-បនីយកម្មក្តី ដល់អន្តេវាសិក អាចារ្យត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា សង្ឃកុំគប្បីធ្វើកម្ម ឬគប្បីបង្អោនទៅ ដើម្បីកម្មស្រាល ដល់អន្តេវាសិក ដោយឧបាយដូចម្តេចហ្ន៎ ម្យ៉ាងទៀត បើកម្ម គឺ តជ្ជនីយកម្មក្តី និយស្សកម្មក្តី

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បព្វាជនីយំ វា បដិសារណីយំ វា ឧក្ខេបនីយំ វា អាចរិ-
យេន ឧស្សុក្កំ កាតព្វំ កិន្តិ នុ ខោ អន្តេវាសិកោ
សម្មា វត្តេយ្យ លោមំ បាតេយ្យ នេត្ថារំ វត្តេយ្យ
សង្ឃោ តំ កម្មំ បដិប្បស្សម្ភេយ្យាតិ សចេ អន្តេវា-
សិកស្ស ចីវរំ ធោវិតព្វំ ហោតិ អាចរិយេន អាចិក្ខិតព្វំ
ឯវំ ធោវេយ្យាសីតិ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ
អន្តេវាសិកស្ស ចីវរំ ធោវិយេថាតិ សចេ អន្តេវាសិ-
កស្ស ចីវរំ កាតព្វំ ហោតិ អាចរិយេន អាចិក្ខិតព្វំ
ឯវំ ករេយ្យាសីតិ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ ខោ
អន្តេវាសិកស្ស ចីវរំ ករីយេថាតិ សចេ អន្តេវាសិ-
កស្ស រជនំ បចិតព្វំ ហោតិ អាចរិយេន អាចិក្ខិតព្វំ
ឯវំ បចេយ្យាសីតិ ឧស្សុក្កំ វា កាតព្វំ កិន្តិ នុ
ខោ អន្តេវាសិកស្ស រជនំ បចិយេថាតិ សចេ អន្តេ
វាសិកស្ស ចីវរំ រជេតព្វំ ហោតិ អាចរិយេន អា-
ចិក្ខិតព្វំ ឯវំ រជេយ្យាសីតិ ឧស្សុក្កំ វា កាតព្វំ កិន្តិ
នុ ខោ អន្តេវាសិកស្ស ចីវរំ រជិយេថាតិ ចីវរំ
រជេន្តេន សាធុកំ សម្បរិវត្តកំ សម្បរិវត្តកំ រជេតព្វំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បញ្ញាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី សង្ឃបានធ្វើដល់អន្តេវាសិកនោះរួចទៅហើយ អាចារ្យត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា អន្តេវាសិកគប្បីប្រព្រឹត្តដោយប្រពៃ គប្បីសម្ងបរោម គប្បីប្រព្រឹត្តតាមគួរដល់កិរិយារលាស់ខ្លួនចេញចាកកម្ម សង្ឃគប្បីរម្ងាប់កម្មនោះ ដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់អន្តេវាសិកគួរនឹងលាង អាចារ្យត្រូវប្រាប់ថា អ្នកត្រូវលាងយ៉ាងនេះ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់អន្តេវាសិក គួរនឹងលាង ដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់អន្តេវាសិកគួរនឹងធ្វើ អាចារ្យត្រូវប្រាប់ថា អ្នកត្រូវធ្វើយ៉ាងនេះ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់អន្តេវាសិក គួរនឹងធ្វើដោយឧបាយដូចម្តេចហ្ន៎ បើគ្រឿងជ្រលក់របស់អន្តេវាសិក គួរនឹងស្ងោរ អាចារ្យត្រូវប្រាប់ថា អ្នកត្រូវស្ងោរយ៉ាងនេះ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា គ្រឿងជ្រលក់របស់អន្តេវាសិក គួរនឹងស្ងោរដោយឧបាយដូចម្តេចហ្ន៎ បើចីវររបស់អន្តេវាសិក គួរនឹងជ្រលក់ អាចារ្យត្រូវប្រាប់ថា អ្នកត្រូវជ្រលក់ចីវរយ៉ាងនេះ ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា ចីវររបស់អន្តេវាសិក គួរនឹងជ្រលក់ដោយឧបាយដូចម្តេចហ្ន៎ កាលនឹងជ្រលក់ចីវរ ត្រូវជ្រលក់ប្រែត្រឡប់ ឲ្យសព្វល្អ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ ឧទ្ទានគាថា

ន ច អច្ឆិន្នេ ថេវេ បក្កមិតព្វំ សចេ អន្តេវាសិកោ គិលានោ ហោតិ យាវជីវំ ឧបដ្ឋាតព្វោ វុដ្ឋានស្ស អាគមេតព្វំ ឥទំ ខោ ភិក្ខវេ អាចរិយានំ អន្តេវាសិកេសុ វត្តំ យថា អាចរិយេហិ អន្តេវាសិកេសុ សម្មា វត្តិតព្វន្តិ ។

វត្តក្ខន្ធកំ និដ្ឋិតំ អដ្ឋមំ ។

តម្ហិ ខន្ធកេ វត្ថូ ឯកូនវីសតិ(១) វត្តា ចតុទ្ទស(២) ។

តស្សុទ្ទានំ

(១១០) សឧបាហនឆត្តា ច

ឱគុណ្ឋិ សីស បានិយំ

នាភិវាទេ ន បុច្ឆន្តិ

អហិ ឧជ្ឈន្តិ បេសលា ។

ឱមុញ្ចិ ឆត្តំ ខន្ធេ ច

---

១ ឱ. បញ្ញាស ។ ម. បញ្ចបណ្ណាស ។ ២ ឱ. ម. វត្តំ ចុទ្ទស ។

## វត្តក្ខន្ធកៈ ឧទ្ទានគាថា

បើដំណក់ទឹកស្រក់ពុំទាន់អស់ អាចារ្យកុំអាលចៀសចេញទៅ បើអន្តេវាសិកមានជម្ងឺ អាចារ្យត្រូវថែទាំ អស់កាលដែលអន្តេវាសិកមានជីវិតរស់នៅ ត្រូវរង់ចាំត្រាតែសះជាជម្ងឺ ម្នាលភិក្ខុទាំងឡាយ ទាំងនេះជាអន្តេវាសិកវត្ត របស់អាចារ្យ តាមទំនងដែលពួកអាចារ្យត្រូវប្រព្រឹត្ត ដោយប្រពៃ ក្នុងអន្តេវាសិកទាំងឡាយ ។

ចប់ វត្តក្ខន្ធកៈ ជាគំរប់ ៨ ។

ក្នុងខន្ធកៈ នេះ មានរឿង ១៩ មានវត្ត ១៤ ។

### ឧទ្ទាននៃវត្តក្ខន្ធកៈនោះ

(១១០) រឿងអាគន្តុកភិក្ខុពាក់ស្បែកជើង បាំងឆត្រ ទទូរក្បាល ដាក់ចីវរលើក្បាល លាងជើងដោយទឹកឆាន់ មិនសំពះអាវាសិកភិក្ខុដែលចាស់ជាងខ្លួន នឹងមិនសួរកន្លែងទីសេនាសនៈ រឿងពស់ធ្លាក់លើភិក្ខុ ភិក្ខុទាំងឡាយមានសីលជាទីស្រឡាញ់ តំពោលទោស (ក្នុងរឿងអម្បាលនេះ) ។ រឿងព្រះអង្គទ្រង់អនុញ្ញាតថា អាគន្តុកភិក្ខុត្រូវដោះស្បែកជើង ដំឡោះឆត្រ ដាក់ចីវរពួងស្មាហើយសន្សឹម ៗ ចូលទៅកាន់អារាម

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដកេ ចុល្លវគ្គោ

អន្តរញ្ច បដិក្កមំ

បត្តចីវរំ និក្ខិនា

បដិរូបញ្ច បុច្ឆិតា

អាសិញ្ចេ ធោវិតេន ច[១]

សុក្ខេនលេឌ្ឌុនាហានា

វុឌ្ឍា នវកោ បុច្ឆេយ្យ

អជ្ឈារុឡ្ហញ្ច គោចរ

សេក្ខា វត្វា នានិ បវិ

កត្តរំ កតិកាដ្ឋំ[២]

កាលំ មុហុត្តំ ឧក្កានោ

កុម្ភត្ថរណា នីហរេ[៣]

បដិនានោ ភិសិ ពិន្ទោ

---

១ ឱ. ម. អាសិញ្ចេយ្យ ធោវិតេន ។ ២ ឱ. ម. កតិកន្តោ ។ ៣ ឱ. កាលមុហុត្តខក្កា-យោ ភូមត្ថរណា នីហរេ ។ ម. កាលមហុត្តំ ឧក្កាយោ ហោតិ ភូមត្ថរណា នីហរេ ។

## វិនយបិដក ចុល្លវគ្គ

អាគន្តុកភិក្ខុត្រូវចូលទៅកាន់ទីដែលអាវាសិកភិក្ខុប្រជុំគ្នា ត្រូវទុកបាត្រនិងចីវរក្នុងទីសមគួរ ត្រូវកាន់យកអាសនៈដ៏សមគួរមកអង្គុយ ត្រូវសួរគេទឹកឆាន់និងទឹកសម្រាប់ប្រើប្រាស់ ត្រូវចាក់ទឹកដោយដៃម្ខាង លាងជើងដោយដៃម្ខាង ត្រូវជូតស្បែកជើងដោយសំពត់ស្ងួតមុន រួចសឹមជូតដោយសំពត់ទទឹកជាខាងក្រោយ អាវាសិកភិក្ខុចាស់ជាង អាគន្តុកភិក្ខុត្រូវសំពះ បើក្មេងជាង អាគន្តុកភិក្ខុត្រូវឲ្យអាវាសិកភិក្ខុសំពះវិញ អាគន្តុកភិក្ខុត្រូវសួរគេសេនាសនៈ ត្រូវសួរគេសេនាសនៈដែលមានគេនៅឬឥតគេនៅ ត្រូវសួរគេគោចរគ្រាមនិងអគោចរគ្រាម ត្រូវសួរគេសេក្ខត្រកូលដែលសង្ឃសន្មត ត្រូវសួរគេទីសម្រាប់បន្ទោបង់វច្ចៈនិងបស្សាវៈ ត្រូវសួរគេទឹកសម្រាប់ឆាន់ទឹកសម្រាប់ប្រើប្រាស់ ត្រូវសួរគេឈើច្រត់ ត្រូវសួរអំពីរបៀបនៃកតិការបស់សង្ឃ បើវិហារគ្មានគេនៅ ត្រូវគោះសន្ទះទ្វារ រួចឈររង់ចាំមួយស្របក់សិន បើវិហារមានសម្រាម ត្រូវបោសជម្រះចេញ ត្រូវជញ្ជូនយកកម្រាលផែនដី ទ្រនាប់ជើងគ្រែ ពូក ខ្នើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ ឧទ្ទានគាថា

មញ្ច បីឋញ្ច មល្លកំ

អបស្សេនុល្លោក កណ្ណា

គេរុកា កាឡ្យកាកតា

សង្ការំ ភុម្មត្ថរណំ

បដិឆាទកា មញ្ចកំ

បីឋំ ភិសិ និសីទនំ

មល្លកំ អបស្សេនកំ(១)

បត្តចីវរំ ភូមិ ច

ឆារត្តិំ ទ្វារកោតតោ

បុរត្ថិមា បច្ឆិមា ច

ឧត្តរា អថ ទក្ខិណា

សីតុណ្ហោ ច និវាត្តឹ

---

១ ឱ. ម. សង្ការញ្ច ភូមត្ថរណំ បដិឆាទកំ មញ្ចបីឋំ ។ ភិសិ និសីទនំ មល្លកំ អបស្សេន ប ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ ឧទ្ទានគាថា

ក្រែ តាំង កន្ទោរ នឹងផែនក្តារសម្រាប់ផ្អែក ទៅទុកក្នុងទីដ៏សមគួរ បើវិហារមានគ្រឿងស្មុកស្មាញ ភិក្ខុត្រូវបោសអំពីពិតានចុះមកជាមុន ត្រូវជូតចំណែកជ្រុងបង្អួច បើជញ្ជាំងគេបរិកម្មដោយថ្នាំមានសម្បុរសៅហ្មង បើផ្ទៃផែនដី ដែលគេបរិកម្មដោយពណ៌ខ្មៅ ភិក្ខុត្រូវជ្រលក់សំពត់ រួចពូតចេញហើយសើមជូត បើផ្ទៃដែលគេមិនបានធ្វើបរិកម្ម ភិក្ខុត្រូវប្រស់ហើយសើមជូត ត្រូវជញ្ជូនសម្រាមទៅចាក់ចោល ក្នុងទីដ៏សមគួរ ត្រូវជញ្ជូនយកកម្រាលផែនដី ទ្រនាប់ជើងគ្រែ គ្រែ តាំង ពូក ខ្នើយ កម្រាលសម្រាប់អង្គុយ កន្ទោរ នឹងក្តារសម្រាប់ផ្អែក ទៅទុកក្នុងទីដដែលវិញ ត្រូវទុកដាក់បាត្រនឹងចីវរ មិនត្រូវទុកបាត្រក្នុងទីដែលមិនស្អាត ត្រូវបត់ចីវរធ្វើជាយខាងនាយឲ្យមានផ្នត់មកខាងអាយ បើខ្យល់ប្រកបដោយធូលីបក់មកពីទិសខាងកើត ត្រូវបិទបង្អួចទិសខាងកើត បក់មកពីទិសខាងលិច ត្រូវបិទបង្អួចទិសខាងលិច បក់មកពីទិសខាងជើង ត្រូវបិទបង្អួចទិសខាងជើង បក់មកពីទិសខាងត្បូង ត្រូវបិទបង្អួចទិសខាងត្បូង បើរដូវត្រជាក់ ត្រូវបើកបង្អួចវេលាថ្ងៃ បិទវេលាយប់ បើរដូវក្តៅ ត្រូវបិទបង្អួចវេលាថ្ងៃ បើកវេលាយប់

*ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ*
*ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។*


## វិនយបិដកេ ចុល្លវគ្គោ

បរិវេណញ្ច កោដ្ឋកោ
ឧបដ្ឋានគ្គិសាលា ច
វត្ថុំ វច្ចកុដីសុ ច
ទានិ បរិកោជនិកា

កុម្ភី អាចមនេសុ ច
អធោបមេន បញ្ញត្តំ
វត្តំ អាគន្តុកេហិ មេ ។
នេវាសនំ ន ឧទកំ

ន បច្ចុ ន ច ទានីយំ
ណាកិវានេ ន បញ្ញាបេ
ឧជ្ឈាយន្តិ ច បេសលា ។
វុឌ្ឍាសនញ្ច ឧទកំ

បច្ចុគ្គន្ត្វា ច ទានិយំ
ឧទាហារេ បកាមន្តំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បរិវេណ បន្ទប់ រោងឆាន់ រោងភ្លើង វច្ចកុដិ ( បើមានសម្រាម ភិក្ខុត្រូវបោសចេញ ) ត្រូវដំកល់ទឹកសម្រាប់ឆាន់ ទឹកសម្រាប់ប្រើប្រាស់ ត្រូវដាក់ទឹកក្នុងក្អមសម្រាប់ជម្រះ ព្រះតថាគតមិនមានបុគ្គលប្រៀបផ្ទឹម បានទ្រង់បញ្ញត្តវត្ត ដែលអាគន្តុកភិក្ខុទាំងឡាយ(ត្រូវប្រព្រឹត្ត) ។ រឿងភិក្ខុម្ចាស់អាវាសមិនក្រាលអាសនៈទទួលអាគន្តុកៈ មិនដំកល់ទឹកទុក មិនក្រោកទទួលបាត្រនិងចីវរ មិនសួរដោយទឹកសម្រាប់ឆាន់ ទឹកសម្រាប់ប្រើប្រាស់ មិនថ្វាយបង្គំអាគន្តុកភិក្ខុដែលមានវស្សាចាស់ជាង មិនរៀបចំសេនាសនៈឱ្យអាគន្តុកភិក្ខុ ភិក្ខុទាំងឡាយមានសីល ជាទីស្រឡាញ់ ក៏ពោលទោសឡើង ( ក្នុងរឿងនោះ ) ។ ( ព្រះអង្គទ្រង់បញ្ញត្តថា ) អាវាសិកភិក្ខុត្រូវក្រាលអាសនៈដល់អាគន្តុកភិក្ខុដែលចាស់ជាង ត្រូវដំកល់ទឹកសម្រាប់លាងជើង ត្រូវក្រោកទៅទទួល ( បាត្រនិងចីវរ ) ត្រូវសួរ រកទឹកសម្រាប់ឆាន់ និងទឹកសម្រាប់ប្រើប្រាស់ ត្រូវជូតស្បែកជើងដោយសំពត់ស្ងួតមុន រួចជូតដោយសំពត់ទទឹកជាខាងក្រោយ ត្រូវលាងកំណាត់សំពត់សម្រាប់ជូតស្បែកជើង ពូតហើយហាលទុកក្នុងទីដ៏សមគួរ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


### វត្តក្ខន្ធកេ ឧទ្ទានគាថា

អភិភានេ ច បញ្ញាបេ
វត្ថុំ គោចរ សេក្ខោ ច
ឋានំ ទានីយ ភោជនំ
កត្តុំ កតិកំ កាលំ
ឱវកាស្ស និសិន្នោ
អភិភានយេ អាចិក្ខេ
យថា ហេដ្ឋា តថា នយេ ។
និទ្ទិដ្ឋំ សត្ថភាហេន
វត្តំ អាភាសិតេហិ មេ ។
គមិកា ទារុមត្តិកា
វិវិត្វា ន បុច្ឆិយ (១)
នស្សន្តិ ច អត្តញ្ញូ
ឱជ្ឈាយន្តិ ច បេសលា ។

---

១ ឱ. ម. គមិកា ទារុមត្តិ ច វិវិត្វា ន បុច្ឆាយ ។

## វត្តក្ខន្ធកៈ ឧទ្ទានគាថា

ត្រូវថ្វាយបង្គំភិក្ខុអាគន្តុកៈដែលចាស់ជាង ត្រូវចាត់ចែងសេនាសនៈឲ្យភិក្ខុអាគន្តុកៈ ត្រូវប្រាប់សេនាសនៈដែលមានភិក្ខុនៅ ហើយ ឬមិនមានភិក្ខុនៅ ត្រូវប្រាប់គោចរគ្រាមនិងអគោចរគ្រាម ត្រូវប្រាប់សេក្ខត្រកូលដែលសង្ឃសន្មត ត្រូវប្រាប់ទីសម្រាប់បន្ទោបង់ឧច្ចារៈនិងបស្សាវៈ ត្រូវប្រាប់ទឹកសម្រាប់ឆាន់និងទឹកសម្រាប់ប្រើប្រាស់ ត្រូវប្រាប់ឈើច្រត់ ត្រូវប្រាប់កតិកា របស់សង្ឃថា កាលនេះត្រូវចូល កាលនេះត្រូវចេញ បើភិក្ខុអាគន្តុកៈខ្ចីវស្សាជាង អាវាសិកភិក្ខុគ្រាន់តែអង្គុយប្រាប់ក៏បាន ត្រូវឲ្យថ្វាយបង្គំ ត្រូវប្រាប់សេនាសនៈ ( តអំពីនេះទៅ ) បណ្ឌិតគប្បីដឹងតាមន័យដែលបានពោលរួចមកហើយចុះ ។ ព្រះតថាគតជានាយកនៃពពួកសត្វ បានសំដែងវត្តដែលអាវាសិកភិក្ខុទាំងឡាយ ( ត្រូវប្រព្រឹត្តដោយប្រពៃ ) ។ វៀងភិក្ខុជាអ្នកដំណើរមិនរៀបចំទុកដាក់គ្រឿងឈើនិងគ្រឿងដី បើកទ្វារនិងបង្អួចចំហរចោល មិនអើពើនឹងសេនាសនៈហើយចៀសចេញទៅ ឯគ្រឿងឈើគ្រឿងដីក៏ខូចខាតអស់ទៅ សេនាសនៈក៏គ្មានអ្នករក្សា ទើបភិក្ខុមានសីលជាទីស្រឡាញ់ ក៏ពោលទោសឡើង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បដិសាមេត្វា ថកេត្វា ច
អាបុច្ឆិត្វា ច បក្កមេ(១) ។
ភិក្ខុ វា សាមណេរេ វា
អារាមិកេ ឧបាសកេ
បាសាណកេសុ ច បុញ្ជំ
បដិសាមេ ថកេយ្យ ច
សចេ ឧស្សហិ ឧស្សុក្កំ
អនោវស្ស តថេវ ច(២)
សចេ(៣) ឱវស្សតិ តាមំ
អជ្ឈោកាសេ តថេវ ច
អប្បវត្តានិ សេសេយ្យុំ
វត្តំ គមិកភិក្ខុនា ។
អនុមោទន្តិ ថេរេន
វិហារេ ចតុបញ្ចហិ

---

១ ឱ. ម. បដិសាមេត្វា ថកេត្វា អាបុច្ឆិត្វា វ បក្កមេ ។ ២ ឱ. ម. ឧស្សហតិ ឧស្សុក្កំ វា អនោវស្សេ តថេវ ច ។ ៣ ឱ. ម. សព្វេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



រឿងភិក្ខុអ្នកដំណើរត្រូវរៀបចំទុកដាក់គ្រឿងឈើ នឹងគ្រឿងដីហើយបិទទ្វារ បង្អួច អើពើនឹងសេនាសនៈរួចហើយ សឹមចៀសចេញទៅ ។ បើគ្មានភិក្ខុ ឬសាមណេរ ឬអ្នករក្សាវត្ត ឬឧបាសកទេ ភិក្ខុអ្នកដំណើរ ត្រូវរៀបចំគ្រែ លើថ្ម ៤ ដុំ ហើយផ្ទុំសេនាសនៈឲ្យគរលើគ្នា រួចសឹមទុកដាក់គ្រឿងឈើនឹងគ្រឿងដី បិទទ្វារបង្អួចរួចហើយសឹមចៀសចេញទៅ បើវិហារលេច អាគន្តុកភិក្ខុអាចនឹងប្រក់បាន ត្រូវប្រក់ ឬធ្វើសេចក្តីខ្វល់ខ្វាយ ចំណាកៀងមិនលេចអាគន្តុកភិក្ខុរៀបចំគ្រែលើថ្ម ៤ ដុំ ដូចន័យមុន បើវិហារកៀងលេចគ្មានសល់ ត្រូវនាំយកគ្រឿងសេនាសនៈទៅផ្ញើនឹងមនុស្សអ្នកស្រុក បើមិនដូច្នោះត្រូវរៀបចំគ្រែលើថ្ម ៤ ដុំក្នុងវាល ហើយត្រូវប្រតិបត្តិដូចន័យមុន ហើយចៀសចេញទៅ ដោយគិតថា ធ្វើដូចម្តេចហ្ន៎ ចំណែកផ្សេង ៗ នៃគ្រឿងឈើនឹងគ្រឿងដីគប្បីសល់នៅខ្លះ នេះជាវត្តដែលភិក្ខុអ្នកដំណើរ (ត្រូវប្រព្រឹត្ត) ។ រឿងភិក្ខុមិនអនុមោទនា ក្នុងរោងភត្ត ព្រះអង្គទ្រង់អនុញ្ញាតឲ្យភិក្ខុជាថេរៈធ្វើអនុមោទនា រឿងភិក្ខុទាំងឡាយលះបង់ព្រះសារីបុត្ត ទ្រង់អនុញ្ញាតឲ្យភិក្ខុជាថេរៈបួនប្រាំរូបរង់ចាំក្នុងរោងភត្ត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្ថុទ្ទានេ ឧទ្ទានគាថា

វឌ្ឍិតោ មុដ្ឋិតោ អាសិ
វត្តានុយោគនេសុ មេ ។
ឆព្វគ្គិយា ទុន្និវត្ថា
អថោបិ ច ទុប្បារុតា
អនាកប្បា ច ភេក្កម្ម
ថេរេ អនុបខជ្ជនំ(១)
នវេ ភិក្ខុ ច សង្ឃាដិ
ឧជ្ឈាយន្តិ ច បេសលា ។
តិមណ្ឌលំ និវាសេត្វា
កាយសកុណាតណ្ឌិកា
ន ភេក្កម្ម បដិច្ឆន្នំ
សុសំវុតោក្ខិត្តចក្ខុនា(២)
ឧក្ខិត្តោជ្ជគ្ឃិកា សទ្ទោ
តយោ ចេវ បចាលនា
ខម្ភោគុណ្ឋិ ឧក្កុដិកា
បដិច្ឆន្នំ សុសំវុតោ

---

១ ឧ. ថេរេ ច អនុបខជ្ជនេ ។ ម. ភេក្កម្មា ថេរេ ច អនុបខជ្ជិន ។ ២ ឧ. ម. សុសំវុតោក្ខិត្តចក្ខុ ។

## វត្តក្ខន្ធកៈ ឧទ្ទានគាថា

រឿងព្រះថេរៈមួយរូបឈឺ បន្ទាប់វច្ចៈខំអត់ទ្រាំទាល់តែជ្រប់ដួលទៅ នេះជាវត្តដែលព្រះតថាគត បានអនុញ្ញាតទុកក្នុងអនុមោទនាវិធី ។ រឿងពួកឆព្វគ្គិយភិក្ខុស្លៀកមិនល្អ ដណ្ដប់មិនល្អ មានមារយាទមិនសមគួរ ហើយដើរទៅខាងមុខភិក្ខុជាថេរៈ អង្គុយជ្រៀតបៀតភិក្ខុជាថេរៈ ហាមឃាត់ភិក្ខុថ្មីដោយអាសនៈ អង្គុយសង្កត់លើសង្ឃាដិក្នុងបន្ទោះផ្ទះ ភិក្ខុទាំងឡាយមានសីលជាទីស្រឡាញ់ក៏ពោលទោសឡើង ។ ( រឿងព្រះអង្គទ្រង់បញ្ញត្តវត្តក្នុងរោងភត្តថា ) ភិក្ខុត្រូវបិទបាំងមណ្ឌលបី គឺស្លៀកឲ្យជាបរិមណ្ឌល ក្រវាត់វត្ថពន្ធបង្កេះ ហើយតំរួតឧត្តរាសង្គៈនឹងសង្ឃាដិ ហើយឃ្លុំពាក់ក៏ហើយសឹមដើរចូលទៅកាន់ស្រុក មិនត្រូវដើរទៅអំពីខាងមុខភិក្ខុជាថេរៈ ត្រូវបិទបាំងកាយដោយល្អ ត្រូវសង្រួមដោយប្រពៃ ត្រូវមានភ្នែកសំឡឹងចុះក្រោម មិនត្រូវសើយចីវរ មិនត្រូវសើចព្រខ្លាំង ត្រូវមានសំឡេងតិចៗ ការកំរើក ៣ យ៉ាង គឺ ( យោងកាយ បង្វាយ ងើកងោកក្បាល ) មិនត្រូវស្ទឹមបង្កេះ មិនត្រូវទទូរក្បាល មិនត្រូវបំអែតជើង ភិក្ខុត្រូវបិទបាំងកាយដោយល្អ អង្គុយនៅក្នុងបន្ទោះផ្ទះ ត្រូវសង្រួមដោយល្អ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ឧក្ខិត្តុក្ខិត្តា ឧជ្ជគ្ឃិ
អប្បសទ្ទា តយោ ចលា
ខម្ភោ ឱគុណ្ឋិ បល្លត្ថិ(១)
អនុប្បខជ្ជ នាសនេ
ឱត្តរិត្វា ច ឧទកេ
នីចំ កត្វា ច សិញ្ចិយា(២) ។
បដិ សាមន្ត សង្ឃាដិ(៣)
ឱននេ ច បដិក្កមោ
សូបំ ឧត្តរិភង្គេន
សព្វេសំ សមកត្តិ ច
សក្កច្ចំ បត្តសញ្ញី ច
សមសូបញ្ច តិត្តិកា
ន តាវ ថេកេ កុញ្ជេយ្យ
អសម្បត្តេ ច ឱននេ

១ ឧ. ម. ខម្ភោគុណ្ឋិ បល្លត្ថិ ច ។ ២ ឧ. ម. ឧត្តរិត្វា ឧទកេ នីចំ កត្វាន សិញ្ចិយា ។ ៣ ឧ. ម. បដិ សាមន្តេ សង្ឃាដិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



ត្រូវមានភ្នែកសំឡឹងចុះក្រោម មិនត្រូវសើយចីវរ មិនត្រូវសើចខ្លាំង ត្រូវមានសំឡេងតិចៗ ការកំរើក ៣ យ៉ាងគឺ (ឃោងកាយ បង្ហាយ ងើកងោកក្បាល) មិនត្រូវស្ទឹមចង្កេះ មិនត្រូវទទូរក្បាល មិនត្រូវត្របោមក្បាលជង្គង់ មិនត្រូវអង្គុយជ្រៀតបៀតភិក្ខុជាថេរៈ មិនត្រូវហាមឃាត់ភិក្ខុថ្មីដោយអាសនៈ មិនត្រូវអង្គុយសង្កត់សង្ឃាដិ បើទាយកប្រគេនទឹក ត្រូវទ្របាត្រដោយដៃទាំងពីរ ហើយទទួលទឹក ត្រូវធ្វើឲ្យទាប ហើយលាងបាត្រឲ្យស្អាត ត្រូវចាក់ទៅក្នុងកន្ថោរទឹក ដោយគិតថា អ្នកជិតខាង កុំទទឹកដោយទឹកឡើយ សង្ឃាដិ កុំទទឹកដោយទឹកឡើយ ។ បើទាយកប្រគេនបាយ ភិក្ខុត្រូវទ្របាត្រដោយដៃទាំងពីរ ហើយទទួលយកបាយ ត្រូវទុកឱកាសដល់សម្ល បើមានសម្លខត្តិកគ្គៈជាដើម ព្រះថេរៈត្រូវប្រាប់ទាយកថា អ្នកចូរចាត់ចែងដល់ភិក្ខុគ្រប់រូបឲ្យស្មើ ៗ គ្នា ត្រូវទទួលបិណ្ឌបាតដោយគោរព ត្រូវធ្វើសេចក្ដីសំគាល់តែក្នុងបាត្រ ត្រូវទទួលបិណ្ឌបាតឲ្យមានសម្លសមគួរដល់បាយ ត្រូវទទួលបិណ្ឌបាតស្មើត្រឹមកណ្ដាប់មាត់បាត្រ បើបាយមិនទាន់គ្រប់គ្រាន់ទេ ព្រះថេរៈកុំអាលឆាន់មុន ត្រូវឆាន់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕


## វគ្គប្បទូកេ ឧទ្ទានគាថា

សក្កច្ចំ បត្តសញ្ញី ច
សបទានំ ច សូបកំ
ន ថូបតោ បដិច្ឆាទេ
វិញ្ញត្តុជ្ឈានសញ្ញិនា
មហន្ត មណ្ឌល ទ្វារំ
សព្វហត្ថោ ន ព្យាហរេ
ឧក្ខេបោ ឆេទនា គណ្ឌំ
ធុនំ សិត្ថាវការកំ
ជិវ្ហានិច្ឆារកំ ចេវ
ចបុចបុ សុរុសុរុ
ហត្ថបត្តោដ្ឋនិល្លេហំ
សាមិសេន បដិគ្គហោ
ន តាវ យោវ ន សព្វេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ ឧទ្ទានគាថា

បិណ្ឌបាតដោយគោរព ត្រូវមានសេចក្តីសំគាល់តែក្នុងបាត្រ ត្រូវឆាន់បិណ្ឌបាតរាបឲ្យស្មើ ត្រូវឆាន់បិណ្ឌបាតឲ្យមានសម្ល នឹងម្ហូបស្មើគ្នា មិនត្រូវឆាន់បិណ្ឌបាតប្រមបុះពីកំពូលបាយ មិនត្រូវកកាយបាយលុបសម្ល ឬម្ហូបដើម្បីឲ្យបានច្រើនជាងគេ ភិក្ខុមិនឈឺមិនត្រូវសូមសម្ល ឬម្ហូប ឬបាយដើម្បីខ្លួន មិនត្រូវសំគាល់ក្នុងបាត្រភិក្ខុដទៃ ដើម្បីលើកទោស មិនត្រូវធ្វើដុំបាយឲ្យធំហួសប្រមាណ ត្រូវធ្វើដុំបាយឲ្យជាបរិ-មណ្ឌល កាលដុំបាយនៅមិនទាន់ដល់មាត់ កុំហាមាត់ចាំ កុំឆាន់ញាត់ម្រាមដៃទាំងអស់ទៅក្នុងមាត់ មិនត្រូវនិយាយទាំងបាយនៅក្នុងមាត់ មិនត្រូវឆាន់បោះដុំបាយទៅក្នុងមាត់ មិនត្រូវឆាន់ខាំកាត់ដុំបាយមួយកំណាត់ម្តង មិនត្រូវឆាន់បៀមដុំបាយទុលថ្ពាល់ឡើង មិនត្រូវឆាន់រលាស់ដៃបណ្តើរ មិនត្រូវឆាន់ឲ្យជ្រុះគ្រាប់បាយ មិនត្រូវឆាន់លៀនអណ្តាត មិនត្រូវឆាន់ឲ្យឮផ្លុប់ ៗ មិនត្រូវឆាន់ឲ្យឮគ្រូក ៗ មិនត្រូវឆាន់លិទ្ធដៃ លិទ្ធបាត្រ លិទ្ធបបូរមាត់ មិនត្រូវយកដៃប្រឡាក់អាមិសៈទទួលចាប់កាន់ភាជនទឹក ភិក្ខុទាំងពួងឆាន់មិនទាន់រួច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ទីឃំ កត្វា ច សិញ្ចិយំ[១]
បដិ សាមន្ត សង្ឃាដិ
ទីឃំ កត្វា ធោយ ច
សសិត្ថកំ និវត្តន្តេ
សុប្បដិច្ឆន្ន ឧក្កុដិ
ធម្មរាជេន បញ្ញត្តំ
ឥទំ ភត្តគ្គវត្តនំ ។
ធុនិត្វា អនាកប្បា
អសល្លេក្ខត្វា សាហសា[២]
ទូរេ អច្ចេ ចិរំ លហុំ
តថេវ បិណ្ឌចារិកោ
បដិច្ឆន្នោ វ គច្ឆេយ្យ
សំវុតោក្ខិត្តចក្ខុនា[៣]

---

១ ឧ. ម. យាវ សព្វេ ឧទកេ ទីឃំ កត្វា ច សិញ្ចិយំ ។ ២ ឧ. អសល្លក្ខេ ច សហសា ។ ម. អសល្លក្ខេត្វា ច សហសា ។ ៣ ឧ. ម. បដិច្ឆន្នេន គច្ឆេយ្យ សុសំវុតោក្ខិត្តចក្ខុ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រះថេរៈកុំអាលទទួលទឹក បើគេប្រគេនទឹក ត្រូវទទួលទឹកធ្វើឲ្យទាបកុំឲ្យទង្គិចទង្គុកអ្វី ហើយលាងបាត្រឲ្យស្អាត ត្រូវចាក់ទឹកទៅក្នុងកន្ទោរទឹក ដោយគិតថា ភិក្ខុជិតខាងកុំទទឹកដោយទឹកឡើយ សង្ឃាដីកុំទទឹកដោយទឹកឡើយ បើកន្ទោរទឹកមិនមាន ត្រូវបន្ទាបភាជន៍ទឹកឲ្យទាប ហើយសឹមចាក់ទៅលើផែនដី មិនត្រូវចាក់ទឹកលាងបាត្រទាំងគ្រាប់បាយក្នុងបន្ទោះផ្ទះ ភិក្ខុបីត្រូវត្រឡប់ស្រតមកមុន ដើរក្នុងបន្ទោះផ្ទះត្រូវបិទបាំងកាយដោយល្អ មិនត្រូវបំអើតជើងដើរទៅក្នុងបន្ទោះផ្ទះ ភត្តគ្គវត្តនេះព្រះតថាគតជាធម្មរាជបានបញ្ញត្តទុកហើយ ។ រឿងបិណ្ឌ-បាតិកភិក្ខុស្លៀកមិនល្អ មានកិរិយាមិនសមគួរត្រាច់ទៅបិណ្ឌបាត មិនបានពិនិត ហើយចូលទៅកាន់ទីលំនៅគេខ្លះ ចេញមកខ្លះ ចូលដោយរហ័សពេកខ្លះ ចេញមកដោយរហ័សពេកខ្លះ ឈរឆ្ងាយពេកខ្លះ ឈរជិតពេកខ្លះ ឈរយូរពេកខ្លះ ត្រឡប់មករហ័សពេកខ្លះ រឿងបិណ្ឌបាតិកភិក្ខុ ១ រូបទៀតបានប្រព្រឹត្តដូច្នោះដែរ ( ព្រះអង្គទ្រង់បញ្ញត្តថា ) បិណ្ឌបាតិក-ភិក្ខុត្រូវបិទបាំងកាយដោយល្អ ហើយសឹមដើរទៅក្នុងបន្ទោះផ្ទះ ត្រូវសង្រួមដោយល្អ ត្រូវមានភ្នែកសំឡឹងចុះក្រោម

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## វត្តក្ខន្ធកេ ឧទ្ទានគាថា

ឧក្ខិត្តោជ្ជគ្ឃិកា សទ្ទោ
តយោ ចេវ បចាលនា
ខម្ភោគុណ្ឋិ ឧក្កុដិកា
សល្លក្ខេត្វា ច សាហសា
ទ្វារេ អច្ចុ ចិរំ លហុំ
អាសនគតំ កដច្ឆុកា
ភាជនំ ភ ឋបេសិ ច
ឧច្ចារេត្វា បណាមកា (១)
បដិគ្គហេ ន ឱលោកេ
សូបេសុបិ តថេវ ទំ
ភិក្ខុ សង្ឃាដិយា ភាជេ
បដិច្ឆេន្ន៍ គច្ឆិយំ
សំវុតោក្ខិត្តចក្ខុ ច
ឧក្ខិត្តោជ្ជគ្ឃិកាយ ច
អប្បសទ្ទោ តយោ ចាលា

---

១ ឱ. ម. បណាមេត្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ ឧទ្ទានគាថា

មិនត្រូវសើយចីវរ មិនត្រូវសើចខ្លាំង ត្រូវមានសំឡេងតិច ៗ ការកម្រើក ៣ យ៉ាង (គឺគ្រលែងកាយ បង្វាយរេករោកក្បាល) មិនត្រូវស្ទឹមបង្កេះ មិនត្រូវទទូរក្បាល មិនត្រូវដើរបំអើតជើង ត្រូវកំណត់ផ្លូវចេញផ្លូវចូល មិនត្រូវចូលទៅដោយរហ័សពេក មិនត្រូវចេញមកដោយរហ័សពេក មិនត្រូវឈរឆ្ងាយពេក ជិតពេក យូរពេក ឆាប់ពេក មិនត្រូវត្រឡប់រហ័សពេក ត្រូវកំណត់អាការរបស់ទាយក ដែលគេប្រគេនបាយ បើគេបញ្ឈប់ការងារក្ដី ក្រោកចាកអាសនៈក្ដី ចាប់វែកក្ដី ចាប់ភាជនក្ដី និមន្តឲ្យរង់ចាំក្ដី កាលគេប្រគេនបាយ ត្រូវវែកសង្ឃាដិដោយដៃឆ្វេង បង្អោនបាត្រដោយដៃស្ដាំហើយទទួលយកបាយ មិនត្រូវមើលមុខទាយក ទុកជាសម្ល(សម្លម្ហូប)ក្រៀម ក៏ត្រូវកំណត់អាការរបស់ទាយកដូចគ្នាដែរ ភិក្ខុត្រូវបិទបាំងបាត្រដោយសង្ឃាដិ ត្រូវបិទបាំងកាយដោយល្អហើយសឹមដើរទៅក្នុងចន្លោះផ្ទះ ត្រូវសង្រួមដោយល្អ ត្រូវមានភ្នែកសំឡឹងចុះក្រោម មិនត្រូវសើយចីវរ មិនត្រូវសើចខ្លាំង ត្រូវមានសំឡេងតិច ៗ ការកម្រើក ៣ យ៉ាង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



១ ភោគុណ្ឋិកា ឧក្កុដិ

បឋមាសនក្ការំ

បានីយំ បរិភោជនំ

បដ្ឋា កន្ទិត កុញ្ជេយ្យ

ឱបិលាបេយ្យ ឧទ្ធរេ

បដិសាមេយ្យ សម្មជ្ជេ

វត្តំ ចុម្ពំ ឧបដ្ឋបេ

ហត្ថការេ ន ភិន្ទេយ្យ

វត្តិនំ បិណ្ឌបាតិកេ (១) ។

បានិ ច បរិ អគ្គិ រណិ

នក្ខត្ត ទិស ចោរកា (២)

សព្វំ នត្ថីតិ កោបេត្វា

---

១ ឱ. ហត្ថិការេ ភិន្ទេយ្យ វត្តំ ច បិណ្ឌបាតិកេ ។ ម. ហត្ថិការេ ភិន្ទេយ្យ វត្តិនំ បិណ្ឌបាតិកេ ។ ២ ឱ. ម. បានិ បរិ អគ្គិ រណិ នក្ខត្ត ទិស ចោរា ច ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕


(គឺគ្រវែងកាយ បង្វាយ ងើកងោកក្បាល) មិនត្រូវស្ទឹម បង្កេះ មិនត្រូវទទូរក្បាល មិនត្រូវបំពើតជើង ភិក្ខុណាដែលត្រឡប់មកពីបិណ្ឌបាតមុនគេ ភិក្ខុនោះត្រូវក្រាលអាសនៈ ត្រូវលាងបាត្រសម្រាប់ផ្ទេរភោជនហើយដំកល់ទុក ត្រូវដំកល់ទឹកសម្រាប់ឆាន់ សម្រាប់ប្រើប្រាស់ ភិក្ខុដែលត្រឡប់ពីបិណ្ឌបាតក្រោយគេ បើមានភោជនសល់នៅត្រូវការនឹងឆាន់ក៏គប្បីឆាន់ចុះ បើមិនត្រូវការឆាន់ទេ ត្រូវយកទៅចាក់ចោលក្នុងទីដែលគ្មានវត្ថុខៀវស្រស់ឬក្នុងទីដែលគ្មានសត្វ ត្រូវសារអាសនៈចេញ ត្រូវរៀបចំទុកដាក់ទឹកសម្រាប់លាងជើងជាដើម ត្រូវបោសព្រោសរោងភត្ត បើឃើញក្អមទឹកសម្រាប់ឆាន់ក្តី ក្អមទឹកសម្រាប់ប្រើប្រាស់ក្តី ក្អមវច្ចៈក្តី គ្មានទឹកទេ ត្រូវដងដំកល់ទុក ត្រូវបោយដៃហៅគ្នា ឲ្យមកជួយលើកទឹកទៅដំកល់ទុក តែមិនត្រូវបញ្ចេញវាចា នេះជាបិណ្ឌបាតិកវត្ត ។

រឿងភិក្ខុនៅព្រៃ មិនដំកល់ទុកនូវទឹកសម្រាប់ឆាន់ ទឹកសម្រាប់ប្រើប្រាស់ ភ្លើង ពិនួតភ្លើង មិនស្គាល់ផ្កាយនក្ខត្តឫក្ស មិនស្គាល់ទិស ចោរទាំងឡាយ ក៏ទះតប់នូវភិក្ខុទាំងឡាយដែលនៅព្រៃ ព្រោះឆ្លើយថា មិនមានរបស់ទាំងអម្បាលនេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕


## វត្តក្ខន្ធកេ ឧទ្ទានគាថា

បត្តំសេ ចីវរំ តតោ
ថតានិ អំសេ លគ្គេត្វា
តិមណ្ឌលំ បរិមណ្ឌលំ
យថា បិណ្ឌចារិវត្តំ
នយេ អារញ្ញកេសុបិ
បត្តំសេ ចីវរំ សីសេ
អារោហេត្វា ច ចានិយំ
បរិភោជនិកា អគ្គិ
អរណិ ចាបិ កត្តរំ
នក្ខត្តំ សព្វទេសំ វា
ទិសាបិ កុសលោ ភវេ ។
សត្តុត្តមេន បញ្ញត្តំ
វត្តំ អារញ្ញកេសុមេ
អជ្ឈោកាសេ ឧតិរីសុ
ឧជ្ឈាយន្តិ ច បេសលា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ ឧទ្ទានគាថា

(ព្រះអង្គទ្រង់បញ្ញត្តថា) ភិក្ខុនៅព្រៃត្រូវក្រោកពីព្រឹកប្រែក បាត្រក្នុងស្បោករួចស្ពាយ ពាក់ចីវរលើស្មា ពាក់ស្បែកជើង ទុកដាក់គ្រឿងឈើគ្រឿងដី បិទទ្វារបង្អួចហើយចុះពីសេនាសនៈទៅដោយគិតថា អាត្មាអញនឹងចូលទៅកាន់ស្រុក ក្នុងកាលឥឡូវនេះ ត្រូវដោះស្បែកជើង ហើយប្រែកក្នុងថង់ ស្ពាយហើយបិទបាំងមណ្ឌលបី ស្លៀកដណ្តប់ឲ្យជាបរិមណ្ឌល ក្នុងអារញ្ញកវត្តនេះ បណ្ឌិតគប្បីដឹងសេចក្តី ដូចជាបិណ្ឌចារិកវត្តដូច្នោះ ភិក្ខុអ្នកនៅក្នុងព្រៃ លុះចេញពីស្រុកហើយ ត្រូវប្រែកបាត្រក្នុងស្បោក ហើយស្ពាយ បត់ចីវរដាក់លើក្បាល ពាក់ស្បែកជើងហើយទើបដើរចេញទៅ ភិក្ខុអ្នកនៅព្រៃត្រូវដំកល់ទឹកសម្រាប់ឆាន់ ទឹកសម្រាប់ប្រើប្រាស់ ភ្លើង ឈើពន្លួតភ្លើង ឈើប្រត់ ត្រូវរៀនផ្កាយនក្ខត្តឫក្សទាំងអស់ ឬដោយឯកទេស ត្រូវឈ្លាសក្នុងទិស ។ អារញ្ញកវត្តព្រះតថាគតជាបុគ្គលខ្ពង់ខ្ពស់ជាងសត្វ បានបញ្ញត្តទុកហើយ រឿងភិក្ខុច្រើនរប៉ធ្វើចីវរក្នុងទីវាល ពួកឆព្វគ្គិយភិក្ខុ គោះសេនាសនៈក្នុងទីធ្លាជាទីប្រាសខ្យល់ ភិក្ខុទាំងឡាយ ក៏ប្រឡាក់ដោយធូលី ភិក្ខុទាំងឡាយមានសីលជាទីស្រឡាញ់ក៏ពោលទោសឡើង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


## វិនយបិដកេ ចុល្លវគ្គោ

សចេ វិហារោ ឧក្លាបោ
បឋមំ បត្តចីវរំ
ភិសិពិម្ពោហនំ មញ្ចំ
បីឋំ ច ខេឡមល្លកំ
អបស្សេនាលោកកណ្ណា
គេរុកំ កាឡ មាកតំ
សង្ការំ ភិក្ខុសាមន្តា
សេនា វិហារធានិយំ
បរិភោជនីយសាមន្តា
បដិភាគេ ច អង្គណោ
អធោភាគេ អត្ថរណំ
បដិធានកមញ្ចកំ(១)
បីឋំ ភិសិ និសីទនំ
មល្លកំ អបស្សេនកំ(២)
បត្តចីវរំ ភូមិ ច
ធារត្តំ ឱរោភកតោ

---

១ ឱ. ម. បដិបាទកបញ្ចោ ច ។ ២ ឱ. ម. អបស្សេន ច ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



(ព្រះអង្គទ្រង់បញ្ញត្តថា) បើវិហារមានសម្រាម ភិក្ខុត្រូវបោសជម្រះចេញ កាលនឹងបោសសំអាតវិហារ ត្រូវជញ្ជូនយកបាត្រនឹងចីវរចេញជាមុន ទៅទុកដាក់ក្នុងទីដ៏សមគួរ ត្រូវនាំយកពូក ខ្នើយ គ្រែ តាំង កន្ទោរសម្រាប់ស្ដោះទឹកមាត់ ក្ដារបង្អែក (ទៅដាក់ទុកក្នុងទីដ៏សមគួរ) ត្រូវបោសអំពីពិតានជាមុនហើយសឹមបោសជ្រុងបង្អួច បើជញ្ជាំងដែលគេបរិកម្មដោយថ្នាំមានពណ៌សម្បុរសៅហ្មង បើផ្ទៃដែលគេធ្វើដោយវត្ថុមានពណ៌ខ្មៅសៅហ្មង ត្រូវជ្រលក់កំណាត់សំពត់ហើយសឹមជូត បើផ្ទៃគេមិនបានធ្វើទេ ត្រូវប្រស់ហើយសឹមជូត ត្រូវប្រមូលសម្រាមទៅចាក់ចោល មិនត្រូវគោះសេនាសនៈជិតភិក្ខុ ជិតវិហារ ជិតទឹកសម្រាប់ឆាន់ ជិតទឹកសម្រាប់ប្រើប្រាស់ក្នុងទីធ្លាជាទីប្រាសខ្យល់ ត្រូវគោះសេនាសនៈក្នុងទីក្រោមខ្យល់ កម្រាលផែនដី ទ្រនាប់ជើងគ្រែ គ្រែ តាំង ពូក ខ្នើយ កម្រាលសម្រាប់អង្គុយ កន្ទោរសម្រាប់ស្ដោះទឹកមាត់ និងក្ដារបង្អែក (បើហាលរួចហើយត្រូវជញ្ជូនយកទៅទុកក្នុងទីដដែលវិញ) ត្រូវទុកដាក់បាត្រចីវរ តែមិនត្រូវទុកបាត្រក្នុងទីដែលមិនស្អាត ត្រូវបត់ចីវរធ្វើជាយខាងនាយឲ្យជាផ្នត់មកខាងកាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ ឧទ្ទានគាថា

បុរត្ថិមា បច្ឆិមា ច
ឧត្តរា អថ ទក្ខិណា
សីតុណ្ហោ ច ទិវា រត្តឹ
បរិវេណញ្ច កោដ្ឋកោ
ឧបដ្ឋានគ្គិសាលា ច
វច្ចកុដី ច បានិយំ
អាចមកុម្ភី វុឌ្ឍេ ច
ឧទ្ទេស បរិបុច្ឆនា
សជ្ឈា ធម្មោ បទីបញ្ច
ន វិវរេ ន ច ថកេ(១)
យេន វុឌ្ឍោ បរិវត្តិ
ជាណ្ណេនបិ ន យន្តយេ
បញ្ញបេសិ មហាវីរោ
វត្តំ សេនាសនេសុ តំ ។
និរិយមានា ទ្វារំ

---

១ ឱ. ម. សជ្ឈាធម្មោ បទីបញ្ច វិជ្ឈាបេ ន វិវរេ ន បិ ថកេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



## វត្តក្ខន្ធកៈ ឧទ្ទានគាថា

បើខ្យល់ប្រកបដោយធូលីបក់មកពីទិសខាងកើត ពីទិសខាងលិច ពីទិសខាងជើង ពីទិសខាងត្បូង ត្រូវបិទបង្អួចការពារខ្យល់ បើរដូវត្រជាក់ត្រូវបើកបង្អួចក្នុងវេលាថ្ងៃ បិទក្នុងវេលាយប់ បើរដូវក្តៅត្រូវបិទបង្អួចក្នុងវេលាថ្ងៃ បើកក្នុងវេលាយប់ បើបរិវេណ បន្ទប់ រោងឆាន់ រោងភ្លើង បង្គន់ (មានសម្រាមត្រូវបោសចេញ) ត្រូវដំកល់ទឹកសម្រាប់ឆាន់ នឹងទឹកសម្រាប់ប្រើប្រាស់ ត្រូវដាក់ទឹកក្នុងក្អមសម្រាប់ជម្រះ បើនៅជាមួយនឹងភិក្ខុចាស់ជាង មិនទាន់ប្រាប់លោកជាមុន កុំបង្រៀនបាលី កុំបង្រៀនអដ្ឋកថា កុំស្វាធ្យាយធម៌ កុំសំដែងធម៌ កុំអុជប្រទីប កុំលត់ប្រទីប កុំបើកបង្អួច កុំបិទបង្អួច បើបង្រួមជាមួយនឹងភិក្ខុចាស់ ភិក្ខុចាស់បង្រួមក្នុងទីណា ភិក្ខុត្រូវផ្លាស់ទីបង្រួមកុំឲ្យប៉ះដោយសង្ឃាដិភិក្ខុចាស់ឡើយ ព្រះសម្មាសម្ពុទ្ធមានព្យាយាមធំ បានបញ្ញត្តវត្តនោះ ក្នុងសេនាសនៈទាំងឡាយ (យ៉ាងនេះ) ។ រឿងឆព្វគ្គិយភិក្ខុទាំងឡាយគរឧសជាច្រើនក្នុងផ្ទះជាទីក្យោកាយ ដុតហើយអង្គុយរាំងមាត់ទ្វារ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឧដ្ឋិតុជ្ឈគ្ឃិ បេសលា ។

ឆារិកំ ឆឌ្ឌយេ ឋត្វា

បរិភណ្ឌំ ឆាទេវ ច

បរិវេណកោដ្ឋកា សាលា

ចុណ្ណមត្តិកទោណិកា

មុខំ បុរតោ ច ថេរេ

នវេ ឧស្សារេតិ សចេ[១]

បុរតោ ឧបរិ មគ្គោ

ចិក្ខល្លំ មត្តិ បីឋកំ

វិជ្ឈាបេត្វា ថកេត្វា ច[២]

វត្តំ ជន្តាឃរេសុមេ ។

---

១ ឱ. ម. ន នវេ ឧស្សារេតិ សចេ ។ ២ ឱ. វិជ្ឈាបេត្វា ច បក្កមេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



# វិនយបិដក ចុល្លវគ្គ

ព្រះថេរៈទាំងឡាយត្រូវកំដៅខ្លាំងណាស់ មិនបានទ្វារចេញមក ក៏ជ្រប់ដួលទៅ ភិក្ខុទាំងឡាយមានសីលជាទីស្រឡាញ់ក៏ពោលទោសឡើង ។ (ព្រះអង្គទ្រង់បញ្ញត្តថា) បើផេះកកកុញច្រើន ក្នុងផ្ទះជាទីរក្សាកាយ ភិក្ខុត្រូវចាក់ផេះចោល បើផ្ទះជាទីរក្សាកាយ ទីលានខាងក្រៅបរិវេណ បន្ទប់ និងពេងនៃផ្ទះជាទីរក្សាកាយ (មានសម្រាម ត្រូវបោសចេញ) ត្រូវស្ងួនគ្រឿងលំអិត ត្រូវលាយដីស្អិត ត្រូវចាក់ទឹកក្នុងស្នូក ត្រូវលាបមុខដោយដីស្អិត ហើយបិទបាំងពីមុខពីក្រោយ ហើយសឹមចូលទៅកាន់ផ្ទះជាទីរក្សាកាយ មិនត្រូវអង្គុយជ្រៀតបៀតព្រះថេរៈ មិនត្រូវហាមឃាត់ភិក្ខុថ្មីដោយអាសនៈ បើអាចធ្វើបរិកម្មបាន ត្រូវធ្វើបរិកម្មដល់ព្រះថេរៈ មិនត្រូវងូតទឹកពីខាងមុខព្រះថេរៈ មិនត្រូវងូតទឹកពីលើខ្សែទឹក ត្រូវបើកផ្លូវឲ្យភិក្ខុដែលចុះទៅងូតទឹក ត្រូវលាងផ្ទះជាទីរក្សាកាយដែលប្រឡាក់ដោយភក់ ត្រូវលាងស្នូកសម្រាប់ដាក់ដីស្អិត ហើយទុកដាក់តាំងសម្រាប់ផ្ទះជាទីរក្សាកាយ លត់ភ្លើង បិទទ្វារ ហើយសឹមដើរចៀសចេញទៅ នេះជាវត្តដែលព្រះតថាគតបានបញ្ញត្តទុកហើយ ក្នុងផ្ទះជាទីរក្សាកាយទាំងឡាយ ។

## វគ្គុទ្ទានេ ឧទ្ទានគាថា

នាចមេតិ យថាវុឌ្ឍំ

បដិបាដិ ច សហសា

ឧព្ភជិ និត្ថុនោ កដ្ឋំ

វច្ចំ បស្សាវ ខេឡកំ

ផរុសា កូប សហសា

ឧព្ភជិ ចបុ សេសកំ(១)

ពហិ អន្តោ ច ឧក្កាសេ

រជ្ជុ អគរមានកោ(២)

សហសា ឧព្ភជិ បិតេ

និត្ថុនេ កដ្ឋវច្ចកំ(៣)

---

១ ឧ. សេធេន ។ ម. សេសេន ។ ២ ឧ. ម. អគរមានញ្ច ។ ៣ ឧ. សហសា ឧព្ភជិត្វាន និត្ថុនេ កដ្ឋ វច្ចញ្ច សកេសា ឧព្ភជិ បិតេ និត្ថុនេ កដ្ឋ វច្ចញ្ច ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ ឧទ្ទានគាថា

រឿងភិក្ខុបន្ទោបង់ឧច្ចារៈហើយមិនជម្រះចេញ រឿងភិក្ខុបន្ទោបង់ឧច្ចារៈតាមលំដាប់ចាស់ខ្ចី ទើបព្រះអង្គទ្រង់អនុញ្ញាតឲ្យបន្ទោបង់ឧច្ចារៈតាមលំដាប់ដែលមកដល់ រឿងឆព្វគ្គិយភិក្ខុចូលទៅកាន់វច្ចកុដិដោយរហ័សពេកខ្លះ សើយស្បង់ចូលទៅខ្លះ បន្ទោបង់ឧច្ចារៈរមោតខ្លះ ទំពារឈើស្ទន់បន្ទោបង់ឧច្ចារៈខ្លះ បន្ទោបង់ឧច្ចារៈខាងក្រៅទឧច្ចារៈខ្លះ បន្ទោបង់បស្សាវៈខាងក្រៅទបស្សាវៈខ្លះ ស្តោះទឹកមាត់ក្នុងទបស្សាវៈខ្លះ កិតដោយឈើគគ្រាតខ្លះ ចោលឈើសម្រាប់កិតក្នុងរណ្តៅឧច្ចារៈខ្លះ ចេញពីវច្ចកុដិ ដោយរហ័សពេកខ្លះ សើយស្បង់ចេញមកខ្លះ ជម្រះឲ្យឮចបុចបុខ្លះ ឲ្យសល់ទឹកនៅក្នុងបំពង់សម្រាប់ជម្រះខ្លះ (ទើបព្រះអង្គទ្រង់បញ្ញត្តថា) ភិក្ខុណាទៅកាន់វច្ចកុដិ ភិក្ខុនោះត្រូវឈរគ្រហែមពីខាងក្រៅ ឯភិក្ខុដែលអង្គុយនៅខាងក្នុងត្រូវគ្រហែមតប រឿងពាក់ចីវរលើស្នូរចីវរ ឬខ្សែស្បៀងចីវរ ហើយសឹមចូលទៅដោយសន្សឹម ៗ មិនត្រូវចូលទៅដោយរហ័សពេក មិនត្រូវសើយស្បង់ចូលទៅ ត្រូវឈរលើទ្រនាប់សម្រាប់បន្ទោបង់ឧច្ចារៈហើយសឹមសើយស្បង់ មិនត្រូវប្រឹងរមោតបន្ទោបង់ឧច្ចារៈ មិនត្រូវទំពារឈើស្ទន់បន្ទោបង់ឧច្ចារៈ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕


## វិនយបិដកេ ចុល្លវគ្គោ

បស្សាវខេឡ្យជរុសា

កូបំ ច វច្ចបាទុកោ

នាតិសហសា ឧព្ភុជិ

បាទុកាយ ចបុចបុ

ន សេសយេ បដិច្ឆាទេ

ឩហនា បីឋរេន ច

វច្ចកុដី បរិភណ្ឌំ

បរិវេណាញ្ច កោដ្ឋកោ

អាចមនេ ច ឧទកំ

វត្តំ វច្ចកុដី សុមេ ។

ឩទាហនា ឧទ្ធកដ្ឋំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មិនត្រូវបន្ទោបង់ឧច្ចារៈខាងក្រៅទ មិនត្រូវបន្ទោបង់បស្សាវៈខាងក្រៅទបស្សាវៈ មិនត្រូវស្តោះទឹកមាត់ក្នុងទបស្សាវៈ មិនត្រូវកិតដោយឈើគគ្រាត មិនត្រូវបោលឈើសម្រាប់កិតក្នុងរណ្តៅឧច្ចារៈ ត្រូវឈរលើទ្រនាប់សម្រាប់បន្ទោបង់ឧច្ចារៈ រួចសឹមបិទបាំងស្បង់ មិនត្រូវចេញមកដោយរហ័សពេក មិនត្រូវសើយស្បង់ចេញមក ត្រូវឈរលើទ្រនាប់សម្រាប់ជម្រះហើយសឹមសើយស្បង់ មិនត្រូវជម្រះឲ្យឮចបុចបុ មិនត្រូវទុកទឹកឲ្យសល់នៅក្នុងបំពង់សម្រាប់ជម្រះ ត្រូវឈរលើទ្រនាប់សម្រាប់ជម្រះហើយសឹមបិទបាំង ត្រូវលាងវច្ចកុដិដែលប្រឡាក់ បើកញ្ជើសម្រាប់ដាក់ឈើសម្រាប់កិតពេញហើយត្រូវនាំយកទៅចាក់ចោល បើវច្ចកុដិ លានវច្ចកុដិ បរិវេណនឹងបន្ទប់មានសម្រាម ត្រូវបោសសំអាតចេញ ត្រូវចាក់ទឹកក្នុងក្អមសម្រាប់ជម្រះ (នេះ) ជាវត្តដែលព្រះតថាគតបានបញ្ញត្តទុកក្នុងវច្ចកុដិទាំងឡាយ ៗ (រឿងព្រះអង្គទ្រង់បញ្ញត្តឧបជ្ឈាយវត្តថា) សទ្ធិវិហារិកត្រូវក្រោកអំពីព្រឹកហើយដោះស្បែកជើងធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាងហើយប្រគេនឈើស្ទន់ ប្រគេន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ ឧទ្ទានគាថា

មុខោទកញ្ច អាសនំ
យាគុ ឧទកា ធោវិត្វា (១)
ឧទ្ធរុក្ខាបតាមកំ (២)
និវាសនា កាយពន្ធា
សគុណំ បត្តសោទកំ
បច្ឆា តិមណ្ឌលោ ចេវ
បរិមណ្ឌល ពន្ធនំ
សគុណំ ធោវិត្វា បច្ឆា
នាតិទូរេ បដិគ្គហេ
ភណមានស្ស អាបត្តិ
បឋមាគន្ត្វាន អាសនំ
ឧទកំ បីឋំ កថលិ
បច្ចុគ្គន្ត្វា និវាសនំ

---

១ ឱ. ម. យាគុ ឧទកំ ធោវិត្វា ។ ២ ឱ. ម. ឧទ្ធរុក្ខាបគាមច ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ ឧទ្ទានគាថា

ទឹកលាងមុខ ក្រាលអាសនៈ ប្រគេនបបរ ប្រគេនទឹក ហើយទទួលយកភាជន៍ហើយលាងទុកដាក់ ត្រូវសារអាសនៈចេញ បើទីនោះមានសម្រាម ត្រូវបោសចេញ បើឧបជ្ឈាយ៍ចង់ចូលទៅកាន់ស្រុក សទ្ធិវិហារិកត្រូវប្រគេនស្បង់ទៅលោក ត្រូវប្រគេនវត្ថពន្ធបង្កេះ តម្រួតឲ្យត្តកសង្ឃ:និងសង្ឃាដិប្រគេន ត្រូវជូតបាត្រដែលទទឹក រួចហើយសឹមប្រគេន បើឧបជ្ឈាយ៍ចង់បានជាបច្ឆាសមណៈត្រូវបិទបាំងមណ្ឌលបី គឺស្លៀកឲ្យជាបរិមណ្ឌល ក្រវាត់វត្ថពន្ធបង្កេះ ឃុំតម្រួតឲ្យត្តកសង្ឃ:និងសង្ឃាដិ ពាក់ក្ដៅលាងបាត្រហើយកាន់យកទៅធ្វើជាបច្ឆាសមណៈបុះ មិនត្រូវដើរឆ្ងាយពេក មិនត្រូវដើរជិតពេក ត្រូវចាំទទួលរបស់ដែលគេដាក់ក្នុងបាត្ររបស់ឧបជ្ឈាយ៍ បើឧបជ្ឈាយ៍កំពុងនិយាយ មិនត្រូវនិយាយស្កាត់ បើឧបជ្ឈាយ៍និយាយពាក្យដែលជិតនឹងត្រូវអាបត្តិ ត្រូវហាម ត្រូវត្រឡប់ស្រួតមកមុន ហើយក្រាលអាសនៈចាំ ត្រូវដំកល់ទឹកសម្រាប់លាងជើង តាំងជើងដែលលាងហើយ និងទ្រនាប់សម្រាប់ជូតជើង ដែលមិនទាន់បានលាង ត្រូវក្រោកទទួលបាត្រនិងចីវរ ត្រូវប្រគេនស្បង់បន្លាស់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


## វិនយបិដកេ ចុល្លវគ្គោ

ឱតាបេ និទហិ កដ្ដោ

ឱភោតេ កុញ្ជិតុំ នមេ

ភានីយំ ឧទកំ នីចំ

មុហុត្តំ ន ច និទហោ

បត្តចីវរំ ភូមិ ច

ភារត្តំ ឱរភោកតោ

ឧទ្ធរេ បដិសាមេ ច

ឧក្កាភោ ច នហាយិតុំ

សីតំ ឧណ្ហំ ជន្តាឃរំ

ចុណ្ណំ មត្តិកាបិដ្ឋិតោ

បីឋំ ច ចីវរំ ចុណ្ណំ

មត្តិកាសុប្បហាតិ មុខំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ហើយទទួលយកស្បង់ដែលស្លៀកមកវិញ ត្រូវសំដិលចីវរក្នុងកំដៅថ្ងៃមួយស្របក់តែកុំទុកចីវរយូរពេក ត្រូវបត់ចីវរកុំឲ្យបាក់ពាក់កណ្តាល ធ្វើវត្តពន្ធក្នុងផ្នត់ចីវរ បើឧបជ្ឈាយ៍ចង់ឆាន់ ត្រូវបង្អោនបិណ្ឌបាតចូលទៅប្រគេន ត្រូវសួរទឹកឆាន់ ត្រូវប្រគេនទឹកហើយទទួលបាត្រ កាន់ឲ្យទាបស្រួល លាងហើយហាលក្នុងកំដៅថ្ងៃមួយស្របក់ តែកុំទុកយូរពេក ត្រូវទុកដាក់បាត្រនិងចីវរ មិនត្រូវទុកបាត្រក្នុងទីមិនស្អាត ត្រូវធ្វើដាយចីវរខាងនាយឲ្យជាផ្នត់មកខាងអាយ ហើយសឹមទុកដាក់ កាលឧបជ្ឈាយ៍ក្រោកឡើងហើយ ត្រូវសារអាសនៈចេញ ហើយរៀបទុកដាក់ទឹកត្រជាក់ទឹកក្តៅ បើឧបជ្ឈាយ៍ចង់ស្រង់ទឹក ត្រូវចាត់ចែងទឹកស្រង់ បើឧបជ្ឈាយ៍ចង់ចូលទៅកាន់ផ្ទះជាទីរក្សាកាយ ត្រូវសួនគ្រឿងលំអិតទុក ត្រូវលាយដីស្អិត ត្រូវកាន់យកតាំងសម្រាប់ផ្ទះជាទីរក្សាកាយ ដើរទៅពីខាងក្រោយឧបជ្ឈាយ៍ ប្រគេនតាំងហើយ ទទួលយកចីវរមកដាក់ក្នុងទីសមគួរ ត្រូវប្រគេនគ្រឿងលំអិត ត្រូវប្រគេនដីស្អិត បើសទ្ធិវិហារិកអាចនឹងចូលទៅកាន់ផ្ទះជាទីរក្សាកាយ ត្រូវលាបមុខ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## វត្តក្ខន្ធកេ ឧទ្ទានគាថា

បុរតោ ថេរេ នវេ ន ច[១]
បរិកម្មញ្ច និក្ខមេ
បុរតោ ឧទកេ ន្ហាតេ
និវាសេត្វា បដ្ឋាយ ច
និវាសនញ្ច សង្ឃាដិ
បីឋំ វា អាសនេន ច[២]
ធោតោ បីឋំ កថលិកញ្ច
ធានីយុត្តសមុដ្ឋា
ឧក្លាបុស្សុហំ សោធេយ្យ[៣]
បឋមំ បត្តចីវរំ
និសីទនប្បច្ចត្ថរណំ
ភិសិពិម្ពោហនាទិ ច
មញ្ចោ បីឋំ បដិធានំ
មល្លកំ អបស្សេនកំ

---

១ ឱ. ម. ចេវ ។ ម. នវេ ច ។ ២ ឱ. ម. បីឋកំ អាសនេន ច ។ ៣ ឱ. ម. ឧក្លាបំ សុសោធេយ្យ

## វត្តក្ខន្ធកៈ ឧទ្ទានគាថា

ដោយដៃស្អិត ហើយបិទបាំងពីមុខពីក្រោយហើយសឹមចូលទៅ មិនត្រូវអង្គុយប្រៀតប្រៀតភិក្ខុជាថេរៈ មិនត្រូវហាមឃាត់ភិក្ខុថ្មីដោយអាសនៈ ត្រូវធ្វើបរិកម្មដល់ឧបជ្ឈាយ៍ក្នុងផ្ទះជាទីរក្សាកាយ កាលនឹងចេញមកវិញ ត្រូវបិទបាំងពីមុខពីក្រោយរួចសឹមចេញមកពីផ្ទះជាទីរក្សាកាយ សូម្បីក្នុងទឹកក៏ត្រូវធ្វើបរិកម្មដល់ឧបជ្ឈាយ៍ កាលសទ្ធិវិហារិកងូតរួចហើយត្រូវឡើងមកមុន ជូតខ្លួនឲ្យស្ងួតទឹកហើយស្លៀកស្បង់រួចសឹមជូតទឹកអំពីខ្លួនរបស់ឧបជ្ឈាយ៍ ត្រូវប្រគេនស្បង់សម្រាប់ស្លៀក ត្រូវប្រគេនសង្ឃាដី ត្រូវនាំយកតាំងមកមុនហើយក្រាលអាសនៈ ត្រូវដំកល់ទឹកលាងជើង តាំងរងជើងដែលលាងហើយនឹងទ្រនាប់សម្រាប់ជូតជើងដែលមិនទាន់បានលាង សទ្ធិវិហារិកត្រូវសួរឧបជ្ឈាយ៍ ដោយទឹកឆាន់ ត្រូវឲ្យឧបជ្ឈាយ៍បង្រៀនបាលី ត្រូវឲ្យឧបជ្ឈាយ៍បង្រៀនអដ្ឋកថា បើវិហារមានសម្រាមត្រូវបោសសម្រាមចេញ កាលនឹងសំអាតវិហារត្រូវនាំយកបាត្រនឹងចីវរចេញជាមុន ទៅទុកក្នុងទីដ៏សមគួរ កម្រាលសម្រាប់អង្គុយ ពូកនិងខ្នើយ គ្រែ តាំង ទ្រនាប់ជើងគ្រែ កន្ទោរសម្រាប់ស្តោះទឹកមាត់ ក្តារសម្រាប់ផ្អែក

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កុម្ភស្ថូនកាលោភំ

តេរុក កាឞ្យកាភតា

កុម្ភត្ថរណាបដិចាធា

មញ្ចោ បីឋំ ពិម្ពោហនំ

និសីទនត្ថរណំ ចេឡ្យំ

អបស្សេ្យ បត្តចីវរំ

បុរត្ថិមា បច្ឆិមា ច(១)

ឧត្តរា អថ ទក្ខិណា

សីតុណ្ហោ ច ទិវា រត្តី

បរិវេណញ្ច កោដ្ឋកោ

ឧបដ្ឋានគ្គិសាលា ច

វច្ចុ ចានិយ កោឋនិ

---

១ ឧ. ម. បុរត្ថិ បច្ឆិមា ចេវ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កម្រាលផែនដី សទ្ធិវិហារិក ត្រូវនាំយកទៅទុកក្នុងទីដ៏សមគួរ បើវិហារមានគ្រឿងស្អុកស្អាញ មានសរសៃពីងពាងជាដើម ត្រូវបោសអំពីពិតានមកមុន ត្រូវជូតជ្រុងបង្អួច បើជញ្ជាំងដែលគេបរិកម្មដោយថ្នាំរូបហើយ ត្រឡប់ជាមានសៅហ្មង ត្រូវជ្រលក់កំណាត់សំពត់ពូតហើយសឹមជូត ត្រូវជូតផ្ទៃដែលគេធ្វើដោយវត្ថុមានពណ៌ខ្មៅ បើផ្ទៃដែលគេមិនបានធ្វើត្រូវប្រស់ទឹកហើយសឹមជូត កម្រាលផែនដី ទ្រនាប់ជើងគ្រែ គ្រែតាំង ពូកខ្នើយ កម្រាលសម្រាប់អង្គុយ កន្ទោរសម្រាប់ស្តោះទឹកមាត់ និងក្តារសម្រាប់ផ្អែក លុះសទ្ធិវិហារិកហាលរួចហើយត្រូវនាំយកទៅទុកក្នុងទីដដែលវិញ ត្រូវទុកដាក់បាត្រនិងចីវរ បើខ្យល់ប្រកបដោយធូលី បក់មកពីទិសខាងកើត ពីទិសខាងលិច ពីទិសខាងជើង ពីទិសខាងត្បូង (ត្រូវបិទបង្អួចការពារខ្យល់) បើរដូវត្រជាក់ ត្រូវបើកបង្អួចក្នុងវេលាថ្ងៃ បិទក្នុងវេលាយប់ បើរដូវក្តៅ ត្រូវបិទបង្អួចក្នុងវេលាថ្ងៃ បើកក្នុងវេលាយប់ បរិវេណ បន្ទប់ រោងឆាន់ រោងភ្លើង និងវច្ចកុដិ បើមានសម្រាម សទ្ធិវិហារិកត្រូវបោសសម្រាមចេញ ត្រូវដំកល់ទឹកសម្រាប់ឆាន់ ដំកល់ទឹកសម្រាប់ប្រើប្រាស់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកេ ឧទ្ទានគាថា

អាចមអនភិរតិ
កុក្កុច្ចំ ទិដ្ឋិកា ករុ[១]
មូលមានត្តអព្ភានំ
តជ្ជនីយំ និយស្សកំ
បព្វជ្ជា បដិសារណី
ឧក្ខេបញ្ច កតំ យទិ
ពោធេ កាតព្វជនំ[២]
រជេ សម្បវិត្តកំ
បត្តញ្ច ចីវរញ្ចាបិ
បរិក្ខារញ្ច ចេទនំ
បរិកម្មំ វេយ្យាវច្ចំ
បច្ឆា បិណ្ឌា បរិសនា[៣]
ន សុសនំ និសភា ចេវ
យាវជីវំ ឧបដ្ឋហេ
សទ្ធិវិហារិកេ នេតំ
វត្តបញ្ញាយិកានិមេ[៤] ។

---

១ ឱ. ម. អាចមំ អនភិរតិ កក្កុច្ចំ ទិដ្ឋិ ច គរុ ។ ២ ឱ. កាតព្វជញ្ញ ។ ម. កាតព្វំ ជញ្ញ ។ ៣ ឱ. ម. បិណ្ឌំ បរិសនំ ។ ៤ ឱ. ម. វត្តបញ្ញាយិកេនិមេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វត្តក្ខន្ធកៈ ឧទ្ទានគាថា

ត្រូវដាក់ទឹកក្នុងក្អមសម្រាប់ជម្រះ បើឧបជ្ឈាយ៍កើតសេចក្តីអផ្សុក ត្រូវជួយរម្ងាប់សេចក្តីអផ្សុករបស់ឧបជ្ឈាយ៍ ត្រូវជួយបន្ទោបង់សេចក្តីសង្ស័យរបស់ឧបជ្ឈាយ៍ ត្រូវជួយដោះទិដ្ឋិរបស់ឧបជ្ឈាយ៍ ត្រូវធ្វើសេចក្តីខ្វល់ខ្វាយដល់ឧបជ្ឈាយ៍ ដែលត្រូវគរុកាបត្តិ ដែលគួរដល់មូលាយបដិកស្សនៈ ដែលគួរដល់មានត្ត ដែលគួរដល់អព្ភាន បើសង្ឃធ្វើ តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី សទ្ធិវិហារិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយ ត្រូវលាងចីវររបស់ឧបជ្ឈាយ៍ ត្រូវធ្វើចីវររបស់ឧបជ្ឈាយ៍ ត្រូវស្ងោរគ្រឿងជ្រលក់ ត្រូវជ្រលក់ចីវរប្រែត្រឡប់ឲ្យសព្វល្អ មិនត្រូវទទួលបាត្រ ចីវរ បរិក្ខារ កោរសក់ ធ្វើបរិកម្ម ធ្វើវេយ្យាវច្ចៈ ធ្វើជាបច្ឆាសមណៈរបស់ភិក្ខុឯទៀត មិនត្រូវឲ្យបិណ្ឌបាតដល់ភិក្ខុណាមួយឡើយ មិនទាន់លាឧបជ្ឈាយ៍ មិនត្រូវចូលទៅកាន់ស្រុក មិនត្រូវចូលទៅកាន់ព្រៃស្មសាន មិនត្រូវចៀសចេញទៅកាន់ទិស បើឧបជ្ឈាយ៍អាពាធ ត្រូវបម្រើត្រាតែអស់ជីវិត នេះជាឧបជ្ឈាយវត្តដែលព្រះតថាគតបានបញ្ញត្តទុក ចំពោះសទ្ធិវិហារិកទាំងឡាយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕


ឱវាទសាសនន្តេសា
បុច្ឆា បត្តញ្ច ចីវរំ
បរិក្ខារំ តិណាទោ ច
ន បច្ឆាសមណោ ករេ
ឧបជ្ឈាយេសុ យាវតា(១)
ឃរំ អាចរិយេសុបិ
សទ្ធិវិហារិកេ វត្តា
តថេវ អន្តេវាសិកេ
អាគន្តុកេសុ យាវតា
បុន អាវាសិកេសុ ច ។
គមិកានុមោទនិកា
ភត្តគ្គេ បិណ្ឌចារិកេ
អារញ្ញកេសុ យំ វត្តំ
យំ ច សេនាសនេសុបិ
ជន្តាឃរេ វច្ចកុដី
ឧបជ្ឈា សទ្ធិវិហារិកេ

---

១ ឱ. ម. យាវត្តា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដក ចុល្លវគ្គ

(រឿងព្រះអង្គទ្រង់បញ្ញត្តសទ្ធិវិហារិកវត្តថា) ឧបជ្ឈាយ៍ត្រូវសង្គ្រោះអនុគ្រោះសទ្ធិវិហារិក ដោយដម្បូន្មាន ដោយពាក្យប្រដៅ ដោយបាលី ដោយអដ្ឋកថា ត្រូវឲ្យបាត្រ ឲ្យចីវរ ឲ្យបរិក្ខារ បើសទ្ធិវិហារិកមានជម្ងឺ ឧបជ្ឈាយ៍ត្រូវថែទាំ ឧបជ្ឈាយ៍មិនត្រូវធ្វើជាបច្ឆាសមណៈរបស់សទ្ធិវិហារិក ក្នុងឧបជ្ឈាយ៍វត្ត សទ្ធិវិហារិកត្រូវប្រព្រឹត្តយ៉ាងណា សូម្បីក្នុងអាចរិយវត្ត អន្តេវាសិកក៏ត្រូវប្រព្រឹត្តយ៉ាងនោះដែរ សទ្ធិវិហារិកវត្ត ឧបជ្ឈាយ៍ត្រូវប្រព្រឹត្តយ៉ាងណា អន្តេវាសិកវត្ត អាចារ្យត្រូវប្រព្រឹត្តយ៉ាងនោះដែរ ។ ក្នុងខន្ធកៈនេះមានរឿង ១៩ មានវត្ត ១៤ គឺ អាគន្តុកវត្ត ១ អាវាសិកវត្ត ១ គមិកវត្ត ១ អនុមោទនាវត្ត ១ ភត្តគ្គវត្ត ១ បិណ្ឌបាតិកវត្ត ១ អារញ្ញកវត្ត ១ សេនាសនវត្ត ១ ជន្តាឃរវត្ត ១ វច្ចកុដិវត្ត ១ ឧបជ្ឈាយវត្ត ១ សទ្ធិវិហារិកវត្ត ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕


## វត្តក្ខន្ធកេ ឧទ្ទានគាថា

អាចរិយេសុ យំ វត្តំ
តថេវ អន្តេវាសិកេ
ឯកូនវីសតិវត្ថូ
វត្តា ចោទស(១) ខន្ធកេ
វត្តំ អបរិបូរេន្តោ(២)
ន សីលំ បរិបូរតិ
អសុទ្ធសីលោ ទុប្បញ្ញោ
ចិត្តេកគ្គំ ន វិន្ទតិ
វិក្ខិត្តចិត្តោនេកគ្គោ
សម្មា ធម្មំ ន បស្សតិ
អបស្សមានោ សទ្ធម្មំ
ទុក្ខា ន បរិមុច្ចតិ ។
យំ វត្តំ បរិបូរេន្តោ
សីលម្បិ បរិបូរតិ
វិសុទ្ធសីលោ សប្បញ្ញោ
ចិត្តេកគ្គម្បិ វិន្ទតិ

---

១ ឱ. សោឡស ។ ២ ឱ. អបរិបុរេន្តោ ។

## វត្តក្ខន្ធកៈ ឧទ្ទានគាថា

អាចរិយវត្ត ១ អន្តេវាសិកវត្ត ១ ភិក្ខុណាមិនញុំាងវត្តឲ្យពេញបរិបូណ៌ទេ សីលរបស់ភិក្ខុនោះ ក៏មិនពេញបរិបូណ៌ដែរ ភិក្ខុណាមានសីលមិនបរិសុទ្ធ ខ្សត់ប្រាជ្ញា ភិក្ខុនោះក៏មិនបាននូវឯកគ្គតាចិត្តឡើយ ភិក្ខុណាមានចិត្តរវើរវាយ មានអារម្មណ៍ពាយមាយ ភិក្ខុនោះនឹងមិនបានឃើញព្រះសទ្ធម្មដោយប្រពៃ កាលបើភិក្ខុណា មិនបានឃើញព្រះសទ្ធម្មហើយ ភិក្ខុនោះនឹងមិនបានរួចផុតចាកទុក្ខ ។ ភិក្ខុណា បានញុំាងវត្តណានីមួយ ឲ្យពេញបរិបូណ៌ហើយ សីលរបស់ភិក្ខុនោះ ក៏ពេញបរិបូណ៌ ភិក្ខុណា មានសីលបរិសុទ្ធ ប្រកបដោយប្រាជ្ញា ភិក្ខុនោះ រមែងបានឯកគ្គតាចិត្ត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អវិក្ខិត្តចិត្តោ ឯកគ្គោ

សម្មា ធម្មំ វិបស្សតិ

សម្បស្សមានោ សទ្ធម្មំ

ទុក្ខា សោ បរិមុច្ចតិ ។

តស្មា ហិ វត្តំ បូរេយ្យ

ជិនបុត្តោ វិចក្ខណោ

ឱវាទំ ពុទ្ធសេដ្ឋស្ស

តតោ និព្វានមេហិតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុណាមានចិត្តមិនរវើរវាយ មានអារម្មណ៍តែមួយ ភិក្ខុនោះនឹងបានឃើញច្បាស់នូវធម៌ដោយប្រពៃ កាលបើឃើញច្បាស់នូវព្រះសទ្ធម្ម ( ដោយប្រពៃហើយ ) ភិក្ខុនោះនឹងបានផុតចាកសេចក្ដីទុក្ខ ។ ព្រោះហេតុនោះ ភិក្ខុដែលជាបុត្តនៃព្រះជិនស្រី ជាអ្នកមានប្រាជ្ញាពិចារណាឃើញច្បាស់នូវឱវាទនៃព្រះពុទ្ធដ៏ប្រសើរ គប្បីបំពេញវត្តឱ្យពេញលេញ នឹងបានសម្រេចនូវព្រះនិព្វាន ក្នុងលំដាប់នោះឯង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# បាតិមោក្ខដ្ឋបនក្ខន្ធកំ

[១១១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុ បាសាទេ ។ តេន ខោ បន សមយេន ភគវា តទហុបោសថេ បណ្ណរសេ ភិក្ខុសង្ឃបរិវុតោ និសិន្នោ ហោតិ ។ អថខោ អាយស្មា អានន្ទោ អភិក្កន្តាយ រត្តិយា និក្ខន្តេ បឋមេ យាមេ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា ភគវន្តំ ឯតទវោច អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បឋមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ ឧទ្ទិសតុ ភន្តេ ភគវា ភិក្ខូនំ បាតិមោក្ខន្តិ ។ ឯវំ វុត្តេ ភគវា តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ អាយស្មា អានន្ទោ អភិក្កន្តាយ រត្តិយា និក្ខន្តេ មជ្ឈិមេ យាមេ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិម្បណាមេត្វា ភគវន្តំ ឯតទវោច អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ មជ្ឈិមោ យាមោ ចិរនិសិន្នោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# បាតិមោក្ខដ្ឋបនក្ខន្ធកៈ

[១៦១] សម័យនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់ក្នុងប្រាសាទមិគារមាតាក្នុងបុព្វារាម ទៀបក្រុងសាវត្ថី ។ សម័យនោះឯង នាថ្ងៃបណ្ណរសីឧបោសថនោះ ព្រះមានព្រះភាគទ្រង់គង់ (ក្នុងវេលាឧបោសថ) មានភិក្ខុសង្ឃចោមរោម ។ លុះវេលារាត្រីបឋមយាមកន្លងទៅហើយ ព្រះអានន្ទដ៏មានអាយុ ក៏ក្រោកចាកអាសនៈធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង លើកអញ្ជលីប្រណម្យចំពោះព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសេចក្តីនុះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន វេលារាត្រីបឋមយាម កន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគទ្រង់សំដែងបាតិមោក្ខ ដល់ភិក្ខុទាំងឡាយ ។ កាលដែលព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគក៏គង់ស្ងៀម ។ កាលបើវេលារាត្រីមជ្ឈិមយាមកន្លងទៅហើយ ព្រះអានន្ទដ៏មានអាយុ ក្រោកចាកអាសនៈធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង លើកអញ្ជលីប្រណម្យចំពោះព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសេចក្តីនុះ ចំពោះព្រះមានព្រះភាគ អស់វារៈជាគំរប់ពីរដងទៀតថា បពិត្រព្រះអង្គដ៏ចំរើន វេលារាត្រីមជ្ឈិមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុសង្ឃោ ឧទ្ទិសតុ ភន្តេ ភគវា ភិក្ខូនំ បាតិមោក្ខន្តិ ។ ទុតិយម្បិ ខោ ភគវា តុណ្ហី អហោសិ ។ តតិយម្បិ ខោ អាយស្មា អានន្ទោ អភិក្កន្តាយ រត្តិយា និក្ខន្តេ បច្ឆិមេ យាមេ ឧទ្ធស្តេ(១) អរុណេ នន្ទិមុខិយា រត្តិយា ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិំ បណាមេត្វា ភគវន្តំ ឯតទវោច អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បច្ឆិមោ យាមោ ឧទ្ធស្តំ អរុណំ នន្ទិមុខី រត្តិ ចិរនិសិន្នោ ភិក្ខុសង្ឃោ ឧទ្ទិសតុ ភន្តេ ភគវា ភិក្ខូនំ បាតិមោក្ខន្តិ ។ អបរិសុទ្ធា អានន្ទ បរិសាតិ ។

(១១២) អថខោ អាយស្មតោ មហាមោគ្គល្លានស្ស ឯតទហោសិ កំ នុ ខោ ភគវា បុគ្គលំ សន្ធាយ ឯវមាហ អបរិសុទ្ធា អានន្ទ បរិសាតិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ សព្វាវន្តំ ភិក្ខុសង្ឃំ ចេតសា ចេតោ

១ ឱ ឧទ្ធតេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់សំដែងបាតិមោក្ខដល់ភិក្ខុទាំងឡាយ ។ ព្រះមានព្រះភាគទ្រង់គង់ស្ងៀម អស់វារៈជាគំរប់ពីរដង ។ លុះវេលារាត្រីបច្ឆិមយាមកន្លងទៅហើយ រាត្រីក៏ប្រាកដដូចជាមានមុខស្រស់ ( បំព្រង ) ក្នុងពេលដែលអរុណរះឡើង ព្រះអានន្ទដ៏មានអាយុក៏ក្រោកចាកអាសនៈ ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង លើកអញ្ជលីប្រណម្យចំពោះព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសេចក្ដីនុះ ចំពោះព្រះមានព្រះភាគ ជាគំរប់បីដងទៀតថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ រាត្រីបច្ឆិមយាមកន្លងទៅហើយ អរុណក៏រះហើយ រាត្រីក៏ប្រាកដដូចជាមានមុខស្រស់ហើយ ភិក្ខុសង្ឃក៏អង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគទ្រង់សំដែងបាតិមោក្ខដល់ភិក្ខុទាំងឡាយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ បរិសទ្យមិនបរិសុទ្ធទេ ។

(១១២) គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុមានសេចក្ដីត្រិះរិះដូច្នេះថា ព្រះមានព្រះភាគទ្រង់សំដៅយកបុគ្គលណាហ្ន៎ បានជាទ្រង់ត្រាស់ថា ម្នាលអានន្ទ បរិសទ្យមិនបរិសុទ្ធទេយ៉ាងនេះ ។ គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ស្ទង់មើលចិត្ត ( របស់សង្ឃ ) ដោយចិត្ត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បាតិមោក្ខដ្ឋបនក្ខន្ធកេ មហាមោគ្គល្លានវត្ថុ

បរិច្ច មនសាកាសិ ។ អទ្ទសា ខោ អាយស្មា មហា-
មោគ្គល្លានោ តំ បុគ្គលំ ទុស្សីលំ បាបធម្មំ អសុចិសង្ក-
ស្សរសមាចារំ បដិច្ឆន្នកម្មន្តំ អស្សមណំ សមណបដិញ្ញំ
អព្រហ្មចារឹ ព្រហ្មចារិបដិញ្ញំ អន្តោបូតឹ អវស្សុតំ កសម្ពុ-
ជាតំ មជ្ឈេ ភិក្ខុសង្ឃស្ស និសិន្នំ ទិស្វាន យេន
សោ បុគ្គលោ តេនុបសង្កមិ ឧបសង្កមិត្វា តំ បុគ្គលំ
ឯតទវោច ឧដ្ឋេហិ អាវុសោ ទិដ្ឋោសិ ភគវតា នត្ថិ តេ
ភិក្ខូហិ សទ្ធឹ សំវាសោតិ ។ ឯវំ វុត្តេ សោ បុគ្គលោ
តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ អាយស្មា មហាមោគ្គ-
ល្លានោ តំ បុគ្គលំ ឯតទវោច ឧដ្ឋេហិ អាវុសោ ទិដ្ឋោសិ
ភគវតា នត្ថិ តេ ភិក្ខូហិ សទ្ធឹ សំវាសោតិ ។ ទុតិយម្បិ
ខោ សោ បុគ្គលោ តុណ្ហី អហោសិ ។ តតិយម្បិ ខោ
អាយស្មា មហាមោគ្គល្លានោ តំ បុគ្គលំ ឯតទវោច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ជាតិមោក្ខន្ទិបនក្ខន្ធកៈ រឿងព្រះមហាមោគ្គល្លាន

(របស់លោក) ហើយធ្វើទុក្ខក្នុងចិត្តចំពោះភិក្ខុសង្ឃទាំងអស់នោះ ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ បានឃើញបុគ្គលទ្រុស្តសីលនោះ មានធម៌លាមក មានមារយាទមិនល្អ គួរឲ្យគេរង្កៀស មានអំពើអាក្រក់បិទបាំងទុក មិនមែនជាសមណៈ តែប្តេជ្ញាថាខ្លួនជាសមណៈ មិនប្រព្រឹត្តធម៌ដ៏ប្រសើរ តែប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយក្នុង មានចិត្តជោកជោយរាគៈ កខ្វក់ដូចសម្រាម អង្គុយនៅក្នុងកណ្តាលភិក្ខុសង្ឃ លុះឃើញហើយ ក៏ចូលទៅរកបុគ្គលនោះ លុះចូលទៅជិតហើយ ក៏ពោលពាក្យនេះចំពោះបុគ្គលនោះថា នែអាវុសោ អ្នកចូរក្រោកចេញ ដ្បិតព្រះមានព្រះភាគ ទ្រង់បានឃើញអ្នកឯងច្បាស់ហើយ អ្នកលែងបាននៅរួមជាមួយនឹងភិក្ខុទាំងឡាយហើយ ។ កាលដែលព្រះមហាមោគ្គល្លានពោលយ៉ាងនេះ បុគ្គលនោះក៏នៅស្ងៀម ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ បាននិយាយពាក្យនេះនឹងបុគ្គលនោះជាគំរប់ពីរដងទៀតថា នែអាវុសោ អ្នកចូរក្រោកចេញ ដ្បិតព្រះមានព្រះភាគ ទ្រង់បានឃើញអ្នកច្បាស់ហើយ អ្នកលែងបាននៅរួមជាមួយនឹងភិក្ខុទាំងឡាយហើយ ។ បុគ្គលនោះក៏នៅស្ងៀមអស់វារៈពីរដងទៀត ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ បាននិយាយពាក្យនេះនឹងបុគ្គលនោះជាគំរប់បីដងទៀត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



ឧដ្ឋេហិ អាវុសោ ទិដ្ឋោសិ ភគវតា នត្ថិ តេ ភិក្ខូហិ សទ្ធឹ សំវាសោតិ ។ តតិយម្បិ ខោ សោ បុគ្គលោ តុណ្ហី អហោសិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ តំ បុគ្គលំ ពាហាយំ គហេត្វា ពហិទ្វារកោដ្ឋកា[១] និក្ខាមេត្វា សូចិឃដិកំ ទត្វា យេន ភគវា តេ-នុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច និក្ខា-មិតោ សោ ភន្តេ បុគ្គលោ មយា បរិសុទ្ធា បរិសា ឧទ្ទិសតុ ភន្តេ ភគវា ភិក្ខូនំ បាតិមោក្ខន្តិ ។ អច្ឆរិយំ[២] មោគ្គល្លាន អព្ភុតំ មោគ្គល្លាន យាវ ពាហាគហណាបិ នាម សោ មោឃបុរិសោ អាគមិស្សតីតិ ។

(១១៣) អថខោ ភគវា ភិក្ខូ អាមន្តេសិ អដ្ឋិមេ ភិក្ខវេ មហាសមុទ្ទេ អច្ឆរិយា អព្ភុតា ធម្មា យេ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។ កតមេ អដ្ឋ ។ មហាសមុទ្ទោ ភិក្ខវេ អនុបុព្វនិន្នោ អនុបុព្វពោណោ

---

១ យាវ ពហិទ្វារកោដ្ឋកាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ អច្ឆរិយំ ខោតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ថា នែអាវុសោ អ្នកចូរក្រោកចេញ ដ្បិតព្រះមានព្រះភាគ ទ្រង់បានឃើញអ្នកឯងច្បាស់ហើយ អ្នកលែងបាននៅរួមជាមួយនឹងភិក្ខុទាំងឡាយហើយ ។ ឯបុគ្គលនោះក៏នៅស្ងៀម អស់វារៈជាគំរប់បីដងទៀត ។ តពីនោះមក ព្រះមហាមោគ្គល្លានដ៏មានអាយុ ក៏ចាប់ដៃបុគ្គលនោះទាញចេញទៅខាងក្រៅសុំទ្វារ ហើយសឹកខ្នាស់គន្លឹះទ្វារ រួចចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយបានក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន បុគ្គល (ទ្រុស្តសីល) នោះ ខ្ញុំព្រះអង្គបានបណ្តេញឲ្យដើរចេញទៅហើយ ឥឡូវនេះបរិសទ្យបរិសុទ្ធហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គទ្រង់សំដែងបាតិមោក្ខដល់ភិក្ខុទាំងឡាយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន (ហេតុនេះ) អស្ចារ្យណាស់ មិនធ្លាប់កើតមានទេ ម្នាលមោគ្គល្លាន មោឃបុរសនោះមិនសមបើនឹងមកដរាបតែគេចាប់ទាញដៃ (បណ្តេញចេញដូច្នេះ) សោះ ។

( ១១៣ ) គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ក្នុងមហាសមុទ្រមានធម្មតាមិនដែលកើតគួរអស្ចារ្យ ៨ យ៉ាងនេះ ដែលពួកអសុរឃើញហើយតែងរេករាយក្នុងមហាសមុទ្រ ។ ធម្មតាគួរអស្ចារ្យ ៨ យ៉ាងដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ មានទំនាបដោយលំដាប់ មានទីជម្រាល ដោយលំដាប់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បាតិមោក្ខដ្ឋបនក្ខន្ធកេ មហាសមុទ្ទេ អដ្ឋច្ឆរិយព្ភុតធម្មា

អនុបុព្វបព្ភារោ ន អាយតកេនេវ បបាតោ យម្បិ ភិក្ខវេ មហាសមុទ្ទោ អនុបុព្វនិន្នោ អនុបុព្វពោណោ អនុបុព្វ-បព្ភារោ ន អាយតកេនេវ បបាតោ អយំ ភិក្ខវេ មហាសមុទ្ទេ បឋមោ អច្ឆរិយោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។

(១១៤) បុន ចបរំ ភិក្ខវេ មហាសមុទ្ទោ ឋិតធម្មោ វេលំ នាតិវត្តតិ យម្បិ ភិក្ខវេ មហាសមុទ្ទោ ឋិតធម្មោ វេលំ នាតិវត្តតិ អយម្បិ(១) ភិក្ខវេ មហាសមុទ្ទេ ទុតិយោ អច្ឆរិយោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា អសុរា មហា-សមុទ្ទេ អភិរមន្តិ ។

(១១៥) បុន ចបរំ ភិក្ខវេ មហាសមុទ្ទោ ន មតេន កុណបេន សំវសតិ យំ ហោតិ មហាសមុទ្ទេ មតំ កុណបំ តំ ខិប្បញ្ញេវ តីរំ វាហេតិ ថលំ ឧស្សាទេតិ(២)

---

១ អយម្បិសទ្ទោ ឱ. ម. ក. បោត្ថកេសុ ន ទិស្សតិ ។ ២ ឱ. ម. ឧស្សារេតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មានទីទេរទៅដោយលំដាប់ មិនមែនចោតជ្រៅទៅតែម្តងដូចជាអណ្តូងទេ ម្នាលភិក្ខុទាំងឡាយ ឯមហាសមុទ្រដែលមានទំនាបដោយលំដាប់ មានទីជម្រាលដោយលំដាប់ មានទីទេរទៅដោយលំដាប់ មិនមែនចោតជ្រៅទៅតែម្តងដូចជាអណ្តូងទេ ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតាមិនដែលកើត គួរអស្ចារ្យទី១ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។

(១១៨) ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត មហាសមុទ្រមានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើងឬជោរហួសច្រាំងទៅបានទេ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រតែងមានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើងឬជោរហួសច្រាំងបានឡើយ ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតាមិនដែលកើតមាន គួរអស្ចារ្យ ទី ២ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។

(១១៩) ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត មហាសមុទ្រមិនដែលមានសាកសពស្លាប់នៅរួមបានទេ បើសាកសពស្លាប់ណាមានក្នុងមហាសមុទ្រ រលកតែងបន្សាត់សាកសពស្លាប់នោះទៅរកច្រាំង ផាត់ឡើងទៅលើគោកមួយរំពេច ម្នាលភិក្ខុទាំងឡាយ ឯមហាសមុទ្រ មិនដែលមានសាកសពស្លាប់នៅរួមបាន បើសាកសពណា មានក្នុង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យម្បិ ភិក្ខវេ មហាសមុទ្ទោ ន មតេន កុណបេន សំវសតិ យំ ហោតិ មហាសមុទ្ទេ មតំ កុណបំ តំ ខិប្បញ្ញេវ តីរំ វាហេតិ ថលំ ឧស្សារេតិ អយម្បិ ភិក្ខវេ មហាសមុទ្ទេ តតិយោ អច្ឆរិយោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។

(១១៦) បុន ចបរំ ភិក្ខវេ យា កាចិ មហានទិយោ សេយ្យថីទំ គង្គា យមុនា អចិរវតី សរភូ មហី តា មហាសមុទ្ទំ បត្តា ជហន្តិ បុរិមានិ នាមគោត្តានិ មហាសមុទ្ទោត្វេវ សង្ខ្យំ[១] គច្ឆន្តិ យម្បិ ភិក្ខវេ យា កាចិ មហានទិយោ សេយ្យថីទំ គង្គា យមុនា អចិរវតី សរភូ មហី តា មហាសមុទ្ទំ បត្តា ជហន្តិ បុរិមានិ នាមគោត្តានិ មហាសមុទ្ទោត្វេវ សង្ខ្យំ គច្ឆន្តិ អយម្បិ ភិក្ខវេ មហាសមុទ្ទេ ចតុត្ថោ អច្ឆរិយោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។

(១១៧) បុន ចបរំ ភិក្ខវេ យា កាចិ លោកេ សវន្តិយោ[២] មហាសមុទ្ទំ អប្បេន្តិ យា ច អន្តលិក្ខា ធារា

---

១ ឱ. ម. សង្ខំ ។ ២ ឱ. ម. យា ច លោកេ សវន្តិយោ ។

មហាសមុទ្រ រលកតែងបន្សាត់សាកសពស្លាប់នោះទៅរកច្រាំង ផាត់ឡើងទៅលើគោកមួយរំពេច ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតាមិនដែលកើត គួរអស្ចារ្យ ទី ៣ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។

(១១៦) ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត ទន្លេធំ ៗ ទាំងឡាយណានីមួយ ដូចជាទន្លេគង្គា យមុនា អចិរវតី សរភូ មហី ទន្លេទាំងនោះ កាលបើហូរទៅដល់មហាសមុទ្រហើយ តែងលះបង់នាមនឹងគោត្រដើម(របស់ខ្លួន)ហើយដល់នូវកិរិយារាប់បញ្ចូលថា មហាសមុទ្រតែម្យ៉ាង ម្នាលភិក្ខុទាំងឡាយ ទន្លេធំទាំងឡាយណានីមួយ ដូចជាទន្លេគង្គា យមុនា អចិរវតី សរភូ មហី ទន្លេទាំងនោះកាលបើហូរទៅដល់មហាសមុទ្រហើយ តែងលះបង់នាមនឹងគោត្រដើម(របស់ខ្លួន)ហើយដល់នូវកិរិយារាប់បញ្ចូលថា មហាសមុទ្រតែម្យ៉ាង ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតា មិនដែលកើត គួរអស្ចារ្យ ទី ៤ ក្នុងមហាសមុទ្រដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។

(១១៧) ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត ទឹកទន្លេទាំងឡាយណានីមួយ ក្នុងលោក ដែលហូរស្រោចទៅរកមហា-សមុទ្រក្តី ទ-ទឹកភ្លៀងទាំងឡាយណា ដែលហូរធ្លាក់ចុះមកពីអាកាសក្តី

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បបតន្តិ ន តេន មហាសមុទ្ទស្ស ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ យម្បិ ភិក្ខវេ យា កាចិ លោកេ សវន្តិយោ មហាសមុទ្ទំ អប្បេន្តិ យា ច អន្តលិក្ខា ធារា បបតន្តិ ន តេន មហាសមុទ្ទស្ស ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ អយម្បិ ភិក្ខវេ មហាសមុទ្ទេ បញ្ចមោ អច្ឆរិយោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។

(១១៨) បុន ចបរំ ភិក្ខវេ មហាសមុទ្ទោ ឯករសោ លោណរសោ យម្បិ ភិក្ខវេ មហាសមុទ្ទោ ឯករសោ លោណរសោ អយម្បិ ភិក្ខវេ មហាសមុទ្ទេ ឆដ្ឋោ អច្ឆរិយោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។

(១១៩) បុន ចបរំ ភិក្ខវេ មហាសមុទ្ទោ ពហុរតនោ អនេករតនោ តត្រិមានិ រតនានិ សេយ្យថីទំ មុត្តា មណិ វេឡុរិយោ សង្ខោ សិលា បវាឡំ រជតំ ជាតរូបំ លោហិតង្គោ មសារគល្លំ យម្បិ ភិក្ខវេ មហាសមុទ្ទោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មហាសមុទ្រក៏មិនប្រាកដជាស្រក ឬពេញដោយទឹកទន្លេនិង ទឹកភ្លៀងនោះឡើយ ម្នាលភិក្ខុទាំងឡាយ ទឹកទន្លេទាំងឡាយណានីមួយក្នុងលោក ដែលហូរទៅរកមហាសមុទ្រក្តី ទ–ទឹកភ្លៀងទាំងឡាយណាដែលហូរធ្លាក់ចុះមកពីអាកាសក្តី មហាសមុទ្រក៏មិនប្រាកដជាស្រកឬពេញដោយទឹកទន្លេនិង ទឹកភ្លៀងទាំងនោះ ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតាមិនដែលកើត គួរអស្ចារ្យ ទី ៤ ក្នុងមហាសមុទ្រដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។

(១១៨) ម្នាលភិក្ខុទាំងឡាយ ហេតុដទៃទៅមានតទៅទៀត មហាសមុទ្រមានរសតែមួយ គឺរសប្រៃ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រតែងមានរសតែមួយ គឺរសប្រៃ ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយនេះជាធម្មតាមិនដែលកើត គួរអស្ចារ្យ ទី ៦ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។

(១១៩) ម្នាលភិក្ខុទាំងឡាយ ហេតុដទៃទៅមានតទៅទៀត មហាសមុទ្រមានរតនៈ (ទ្រព្យជាគ្រឿងពេញចិត្ត) ច្រើនយ៉ាង មិនមែនមានតែរតនៈម្យ៉ាងទេ ឯរតនៈទាំងនេះដែលមានក្នុងមហាសមុទ្រនោះ គឺ កែវមុក្តាកែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាឡ ប្រាក់ មាស កែវក្រហម (ត្បូងទទឹម) និងកែវមរកត ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ពហុរតនោ អនេករតនោ តត្រិមានិ រតនានិ សេយ្យថីទំ មុត្តា មណិ វេឡុរិយោ សង្ខោ សិលា បវាឡំ រជតំ ជាតរូបំ លោហិតង្កោ មសារគល្លំ អយម្បិ ភិក្ខវេ មហាសមុទ្ទេ សត្តមោ អច្ឆរិយោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។

(១២០) បុន ចបរំ ភិក្ខវេ មហាសមុទ្ទោ មហតំ ភូតានំ អាវាសោ តត្រិមេ ភូតា តិមិ តិមិង្គលោ តិមិតិមិង្គលោ មហាតិមិង្គលោ[១] អសុរា នាគា គន្ធព្វា សន្តិ មហាសមុទ្ទេ យោជនសតិកាបិ អត្តភាវា ទ្វិយោជនសតិកាបិ អត្តភាវា តិយោជនសតិកាបិ អត្តភាវា ចតុយោជនសតិកាបិ អត្តភាវា បញ្ចយោជនសតិកាបិ អត្តភាវា យម្បិ ភិក្ខវេ មហាសមុទ្ទោ មហតំ ភូតានំ អាវាសោ តត្រិមេ ភូតា តិមិ តិមិង្គលោ តិមិតិមិង្គលោ មហាតិមិង្គលោ អសុរា នាគា គន្ធព្វា សន្តិ

---

១ ឱ. ម. បោត្ថកេសុ មហាតិមិង្គលោតិ បាឋោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មានរតនៈច្រើនយ៉ាង មិនមែនមានតែរតនៈម្យ៉ាងទេ ឯរតនៈទាំងនេះ ដែលមាននៅក្នុងមហាសមុទ្រនោះ គឺកែវមុក្តា កែវមណី កែវពិទូរ្យ សង្ខ សិលា កែវប្រពាឡ ប្រាក់ មាស កែវក្រហម និងកែវមរកត ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតាមិនដែលកើត គួរអស្ចារ្យ ទី ៧ ក្នុងមហាសមុទ្រដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។

[ ១២០ ] ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត មហាសមុទ្រជាទីនៅអាស្រ័យនៃពួកសត្វធំ ៗ ជាច្រើន ពួកសត្វធំៗ ទាំងនេះ (តែងនៅ) ក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គល ឈ្មោះតិមិតិមិង្គល ឈ្មោះមហាតិមិង្គល និងពួកអសុរ នាគ គន្ធព្វ ដែលមានអត្តភាព ១ រយយោជន៍ខ្លះ មានអត្តភាព ២ រយយោជន៍ខ្លះ មានអត្តភាព ៣ រយយោជន៍ខ្លះ មានអត្តភាព ៤ រយយោជន៍ខ្លះ មានអត្តភាព ៥ រយយោជន៍ខ្លះ តែងនៅក្នុងមហាសមុទ្រ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រជាទីនៅអាស្រ័យនៃពួកសត្វធំ ៗ ជាច្រើន ពួកសត្វធំ ៗ ទាំងនេះ ក្នុងមហាសមុទ្រនោះ គឺ ត្រីឈ្មោះតិមិ ឈ្មោះតិមិង្គល ឈ្មោះតិមិតិមិង្គល ឈ្មោះមហាតិមិង្គល និងពួកអសុរ នាគ គន្ធព្វ ដែលមាន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មហាសមុទ្ទេ យោជនសតិកាបិ អត្តភាវា ។ បេ ។ បញ្ចយោជនសតិកាបិ អត្តភាវា អយម្បិ ភិក្ខវេ មហាសមុទ្ទេ អដ្ឋមោ អច្ឆរិយោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ឯវមេវ ខោ ភិក្ខវេ មហាសមុទ្ទេ អដ្ឋ អច្ឆរិយា អព្ភុតា ធម្មា យេ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។

[១២១] ឯវមេវ ខោ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ អដ្ឋ អច្ឆរិយា អព្ភុតា ធម្មា យេ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។ កតមេ អដ្ឋ ។ សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ អនុបុព្វនិន្នោ អនុបុព្វពោណោ អ-នុបុព្វបព្ភារោ ន អាយតកេនេវ បបាតោ ឯវមេវ ខោ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វបដិបទា ន អាយតកេនេវ អញ្ញាបដិវេធោ យម្បិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វប្បដិបទា ន អាយតកេនេវ អញ្ញាបដិវេធោ អយំ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ បឋមោ អច្ឆរិយោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អត្តភាព ១ រយយោជន៍ខ្លះ ។ បេ ។ មានអត្តភាព ៥ រយយោជន៍ខ្លះ តែងនៅក្នុងមហាសមុទ្រ ដោយធម្មតាណា ម្នាលភិក្ខុទាំងឡាយ នេះជាធម្មតាមិនដែលកើត គួរអស្ចារ្យ ទី ៨ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយ តែងរីករាយ ក្នុងមហាសមុទ្រ ។

[១៦១] ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានសភាពមិនដែលកើត គួរអស្ចារ្យ ៨ ប្រការ ដែលភិក្ខុទាំងឡាយឃើញហើយ តែងត្រេកអរ ក្នុងធម្មវិន័យនេះ ដូចមហាសមុទ្រដែរ ។ សភាពគួរអស្ចារ្យ ៨ ប្រការនោះដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានការសិក្សាដោយលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្តីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងព្រះអរហត្តផលតែម្តងទេ ដូចមហាសមុទ្រ ដែលមានទំនាបដោយលំដាប់ មានទីជម្រាលដោយលំដាប់ មានទីទេរដោយលំដាប់ មិនមែនចោតជ្រៅទៅតែម្តងដូចអណ្តូងទេ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ តែងមានការសិក្សាដោយលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្តីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងព្រះអរហត្តផលតែម្តង ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពមិនដែលកើត គួរអស្ចារ្យ ទី ១ ក្នុងធម្មវិន័យនេះដែលភិក្ខុទាំងឡាយឃើញហើយ តែងត្រេកអរក្នុងធម្មវិន័យនេះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៦២) សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ ឋិតធម្មោ វេលំ នាតិវត្តតិ ឯវមេវ ខោ ភិក្ខវេ យំ មយា សាវកានំ សិក្ខាបទំ បញ្ញត្តំ តំ មម សាវកា ជីវិតហេតុបិ នាតិក្កមន្តិ យម្បិ ភិក្ខវេ យំ មយា សាវកានំ សិក្ខាបទំ បញ្ញត្តំ តំ មម សាវកា ជីវិតហេតុបិ នាតិក្កមន្តិ អយម្បិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ ទុតិយោ អច្ឆរិយោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។

(១៦៣) សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ ន មតេន កុណបេន សំវសតិ យំ ហោតិ មហាសមុទ្ទេ មតំ កុណបំ តំ ខិប្បញ្ញេវ តីរំ វាហេតិ ថលំ ឧស្សារេតិ ឯវមេវ ខោ ភិក្ខវេ យោ សោ បុគ្គលោ ទុស្សីលោ បាបធម្មោ អសុចិសង្កស្សរសមាចារោ បដិច្ឆន្នកម្មន្តោ អស្សមណោ សមណបដិញ្ញោ អព្រហ្មចារី ព្រហ្មចារីបដិញ្ញោ អន្តោបូតិ អវស្សុតោ កសម្ពុជាតោ ន តេន សង្ឃោ សំវសតិ ខិប្បញ្ញេវ នំ សន្និបតិត្វា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១ ២) ម្នាលភិក្ខុទាំងឡាយ សិក្ខាបទណា ដែលតថាគតបាន បញ្ញត្តដល់សាវ័កទាំងឡាយហើយ ពួកសាវ័កនៃតថាគត សូម្បីមានហេតុ ដល់ជីវិត ក៏មិនហ៊ានប្រព្រឹត្តកន្លងសិក្ខាបទនោះឡើយ ដូចមហាសមុទ្រ ដែលមានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើង ឬជោរហួសច្រាំង ទៅបាន ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ សិក្ខាបទណាដែលតថាគតបាន បញ្ញត្តដល់សាវ័កទាំងឡាយហើយ ពួកសាវ័កនៃតថាគត សូម្បីមានហេតុ ដល់ជីវិត ក៏មិនហ៊ានប្រព្រឹត្តកន្លងសិក្ខាបទនោះ ដោយសភាពណា នេះជាសភាពមិនដែលកើត គួរអស្ចារ្យ ទី ២ ក្នុងធម៌វិន័យនេះ ដែល ពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម៌វិន័យនេះ ។

(១២៣) ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ មានមារយាទមិនល្អគួរឲ្យគេរង្កៀស មានអំពើអាក្រក់បិទ បាំងទុក មិនមែនជាសមណៈ តែប្តេជ្ញាខ្លួនថាជាសមណៈ មិនមែនជាអ្នក ប្រព្រឹត្តធម៌ដ៏ប្រសើរ តែប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយក្នុង មានចិត្តជោកដោយរាគៈ កខ្វក់ដូចសម្រាម សង្ឃនៅរួមជាមួយនឹងបុគ្គល នោះមិនបាន សង្ឃប្រជុំគ្នានាំយកបុគ្គលនោះចេញមួយរំពេច បុគ្គលនោះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បាតិមោក្ខដ្ឋបនក្ខន្ធកេ ធម្មវិនយេ អច្ឆរិយព្ភុតធម្មា

ឧក្ខិបតិ កិញ្ចាបិ ខោ សោ ហោតិ មជ្ឈេ ភិក្ខុសង្ឃស្ស និសិន្នោ អថខោ សោ អារកាវ សង្ឃម្ហា សង្ឃោ ច តេន យម្បិ ភិក្ខវេ យោ សោ បុគ្គលោ ទុស្សីលោ បាបធម្មោ អសុចិសង្កស្សរសមាចារោ បដិច្ឆន្នកម្មន្តោ អស្សមណោ សមណបដិញ្ញោ អព្រហ្មចារី ព្រហ្មចារិបដិញ្ញោ អន្តោបូតិ អវស្សុតោ កសម្ពុជាតោ ន តេន សង្ឃោ សំវសតិ ខិប្បញ្ញេវ នំ សន្និបតិត្វា ឧក្ខិបតិ កិញ្ចាបិ ខោ សោ ហោតិ មជ្ឈេ ភិក្ខុសង្ឃស្ស និសិន្នោ អថខោ អារកាវ សង្ឃម្ហា សង្ឃោ ច តេន អយម្បិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ តតិយោ អច្ឆរិយោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បាតិមោក្ខដ្ឋបនក្ខន្ធកៈ សភាពមិនដែលកើតគួរអស្ចារ្យ ៨ យ៉ាង ក្នុងធម៌វិន័យ

បើទុកជាអង្គុយនៅក្នុងកណ្តាលភិក្ខុសង្ឃពិតមែន បុគ្គលនោះក៏ឈ្មោះថានៅឆ្ងាយអំពីសង្ឃ ចំណែកខាងសង្ឃ ក៏ឈ្មោះថានៅឆ្ងាយអំពីបុគ្គលនោះ ដូចមហាសមុទ្រ មិនដែលមានសាកសពស្លាប់នៅរួមបាន បើសាកសពស្លាប់ណានីមួយដែលមាន ក្នុងមហាសមុទ្រ មហាសមុទ្រតែងបន្សាត់សាកសពនោះទៅរកច្រាំង ផាត់ឡើងទៅលើគោកមួយរំពេច ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុគ្គលណាជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ មានមារយាទមិនល្អ គួរឱ្យគេរង្កៀស បិទបាំងអំពើអាក្រក់ទុក មិនមែនជាសមណៈ តែប្តេជ្ញាខ្លួនថាជាសមណៈ មិនមែនជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ តែប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយក្នុង មានចិត្តជោកដោយរាគៈ គ្រខ្វក់ដូចសម្រាម សង្ឃនៅរួមជាមួយនឹងបុគ្គលនោះមិនបាន សង្ឃតែងប្រជុំគ្នានាំយកបុគ្គលនោះចេញមួយរំពេច បុគ្គលនោះបើទុកជាអង្គុយនៅក្នុងកណ្តាលភិក្ខុសង្ឃ ដោយពិត បុគ្គលនោះក៏ឈ្មោះថានៅឆ្ងាយអំពីសង្ឃ ចំណែកខាងសង្ឃក៏ឈ្មោះថានៅឆ្ងាយអំពីបុគ្គលនោះ ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពមិនដែលកើត គួរអស្ចារ្យ ទី ៣ ក្នុងធម៌វិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម៌វិន័យនេះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៦៤) សេយ្យថាបិ ភិក្ខវេ យា កាចិ មហានទិយោ សេយ្យថីទំ គង្គា យមុនា អចិរវតី សរភូ មហី តា មហាសមុទ្ទំ បត្តា ជហន្តិ បុរិមានិ នាមគោត្តានិ មហាសមុទ្ទោត្វេវ សង្ខ្យំ[១] គច្ឆន្តិ ឯវមេវ ខោ ភិក្ខវេ ចត្តារោមេ វណ្ណា ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា តេ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិត្វា ជហន្តិ បុរិមានិ នាមគោត្តានិ សមណា សក្យបុត្តិយាត្វេវ សង្ខ្យំ[១] គច្ឆន្តិ យម្បិ ភិក្ខវេ ចត្តារោ វណ្ណា ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា តេ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិត្វា ជហន្តិ បុរិមានិ នាមគោត្តានិ សមណា សក្យបុត្តិយាត្វេវ សង្ខ្យំ[១] គច្ឆន្តិ អយម្បិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ ចតុត្ថោ អច្ឆរិយោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។

---

១- ឱ. ម. សង្ខំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៨៤) ម្នាលភិក្ខុទាំងឡាយ វណ្ណៈ ៤ ពួកនេះ គឺ ខត្តិយៈ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ វណ្ណៈទាំងនោះចេញចាកផ្ទះមកបួសក្នុងធម្មវិន័យ ដែលតថាគតសំដែងហើយ រមែងលះបង់នាមនិងគោត្រដើម (របស់ខ្លួន) ហើយដល់នូវកិរិយារាប់បញ្ចូល ថាជាសមណសក្យបុត្តិយ៍តែម្យ៉ាង ដូចទន្លេធំ ៗ ទាំងឡាយ គឺទន្លេ គង្គា យមុនា អចិរវតី សរភូ មហី ទន្លេទាំងនោះ កាលបើហូរទៅដល់មហាសមុទ្រហើយ តែងលះបង់នាមនិងគោត្រដើម (របស់ខ្លួន) ហើយដល់នូវកិរិយារាប់ថាជាមហាសមុទ្រតែម្យ៉ាង ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ វណ្ណៈទាំង ៤ ពួកនេះ គឺ ខត្តិយៈ១ ព្រាហ្មណ៍ ១ វេស្សៈ១ សុទ្ទៈ១ វណ្ណៈទាំងនោះចេញចាកផ្ទះមកបួសក្នុងធម្មវិន័យ ដែលតថាគតសំដែងហើយ ក៏រមែងលះបង់នាមនិងគោត្រដើម (របស់ខ្លួន) ហើយដល់នូវកិរិយារាប់បញ្ចូល ថាជាសមណសក្យបុត្តិយ៍តែម្យ៉ាង ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពមិនដែលកើត គួរអស្ចារ្យ ទី ៤ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយ រមែងត្រេកអរ ក្នុងធម្មវិន័យនេះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បាតិមោក្ខដ្ឋបនក្ខន្ធកេ ធម្មវិនយេ អដ្ឋច្ឆរិយព្ភុតធម្មា

(១២៥) សេយ្យថាបិ ភិក្ខវេ យា កាចិ លោកេ សវន្តិយោ មហាសមុទ្ទំ អប្បេន្តិ យា ច អន្តលិក្ខា ធារា បបតន្តិ ន តេន មហាសមុទ្ទស្ស ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ ឯវមេវ ខោ ភិក្ខវេ ពហូ ចេបិ ភិក្ខូ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយន្តិ ន តេន និព្វានធាតុយា ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ យម្បិ ភិក្ខវេ ពហូ ចេបិ ភិក្ខូ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយន្តិ ន តេន និព្វានធាតុយា ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ អយម្បិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ បញ្ចមោ អច្ឆរិយោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។

(១២៦) សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ ឯករសោ លោណរសោ ឯវមេវ ខោ ភិក្ខវេ អយំ ធម្មវិនយោ ឯករសោ វិមុត្តិរសោ យម្បិ ភិក្ខវេ ។ បេ ។ វិមុត្តិរសោ អយម្បិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ ឆដ្ឋោ អច្ឆរិយោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។

(១២៥) ម្នាលភិក្ខុទាំងឡាយ ទោះបីពួកភិក្ខុច្រើនរូប បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ និព្វានធាតុក៏មិនប្រាកដជាខ្វះឬពេញ ដោយភិក្ខុទាំងនោះឡើយ ម្នាលភិក្ខុទាំងឡាយ ដូចទឹកទន្លេទាំងឡាយណានីមួយក្នុងលោក ដែលហូរស្រោចចុះទៅកាន់មហាសមុទ្រក្តី ទ-ទឹកភ្លៀងទាំងឡាយណា ដែលហូរចុះមកពីអាកាសក្តី មហាសមុទ្រក៏មិនប្រាកដជាស្រកឬពេញដោយទឹកនោះ ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ ទុកជាពួកភិក្ខុច្រើនរូប បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ និព្វានធាតុក៏មិនប្រាកដជាខ្វះឬពេញ ដោយភិក្ខុទាំងនោះ ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពមិនដែលកើត គួរអស្ចារ្យ ទី ៥ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម្មវិន័យនេះ ។

(១២៦) ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យនេះមានរសតែមួយ គឺវិមុត្តិរស ដូចមហាសមុទ្រដែលមានរសតែមួយ គឺរសប្រៃដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ ។ បេ ។ គឺវិមុត្តិរស ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពមិនដែលកើត គួរអស្ចារ្យ ទី ៦ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម្មវិន័យនេះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[១២៧] សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ ពហុរតនោ អនេករតនោ តត្រិមានិ រតនានិ សេយ្យថីទំ មុត្តា មណិ វេឡុរិយោ សង្ខោ សិលា បវាឡំ រជតំ ជាតរូបំ លោហិតង្កោ មសារគល្លំ ឯវមេវ ខោ ភិក្ខវេ អយំ ធម្មវិនយោ ពហុរតនោ អនេករតនោ តត្រិមានិ រតនានិ សេយ្យថីទំ ចត្តារោ សតិបដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ យម្បិ ភិក្ខវេ អយំ ធម្មវិនយោ ពហុរតនោ អនេករតនោ តត្រិមានិ រតនានិ សេយ្យថីទំ ចត្តារោ សតិបដ្ឋានា ។បេ។ អរិយោ អដ្ឋង្គិកោ មគ្គោ អយម្បិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ សត្តមោ អច្ឆរិយោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដក ចុល្លវគ្គ

(១៤៧) ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យនេះ មានរតនៈ (ធម៌ជាទីរីករាយ) ច្រើនយ៉ាង មិនមែនមានត្រឹមតែមួយប៉ុណ្ណោះទេ រតនៈនេះក្នុងធម្មវិន័យនោះ គឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ និងមគ្គប្រកបដោយអង្គ ៨ ដែលជាផ្លូវដ៏ប្រសើរ ដូចមហាសមុទ្រ មានរតនៈ (ទ្រព្យជាគ្រឿងរីករាយ) ច្រើនយ៉ាង មិនមែនមានតែមួយទេ រតនៈទាំងនេះក្នុងមហាសមុទ្រនោះ គឺ កែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាឡ ប្រាក់ មាស កែវក្រហម (ត្បូងទទឹម) និងកែវមរកត ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យនេះ មានរតនៈច្រើនយ៉ាង មិនមែនមានត្រឹមតែមួយទេ រតនៈទាំងនេះក្នុងធម្មវិន័យនោះ គឺ សតិប្បដ្ឋាន ៤ ។ បេ ។ និងមគ្គប្រកបដោយអង្គ ៨ ដែលជាផ្លូវដ៏ប្រសើរដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពមិនដែលកើត គួរអស្ចារ្យ ទី ៧ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម្មវិន័យនេះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



(១២៨) សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ មហន្តានំ ភូតានំ អាវាសោ តត្រិមេ ភូតា តិមិ ។បេ។ អសុរា នាគា គន្ធព្វា សន្តិ មហាសមុទ្ទេ យោជនសតិកាបិ អត្តភាវា ទ្វិយោជនសតិកាបិ អត្តភាវា តិយោជនសតិកាបិ អត្តភាវា ចតុយោជនសតិកាបិ អត្តភាវា បញ្ចយោជនសតិកាបិ អត្តភាវា ឯវមេវ ខោ ភិក្ខវេ អយំ ធម្មវិនយោ មហន្តានំ ភូតានំ អាវាសោ តត្រិមេ ភូតា សោតាបន្នោ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ សកិទាគាមី[១] សកិទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ អនាគាមី អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ អរហា អរហត្តាយ បដិបន្នោ យម្បិ ភិក្ខវេ អយំ ធម្មវិនយោ មហន្តានំ ភូតានំ អាវាសោ តត្រិមេ ភូតា សោតាបន្នោ ។បេ។ អរហត្តាយ បដិបន្នោ អយម្បិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ អដ្ឋមោ អច្ឆរិយោ អព្ភុតោ ធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ

---

១ ឱ. ម. សកទាគាមិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បាតិមោក្ខដ្ឋបនក្ខន្ធកៈ សភាពមិនដែលកើត គួរអស្ចារ្យ ៨ យ៉ាង ក្នុងធម្មវិន័យ

(១២៨) ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យនេះជាទីនៅអាស្រ័យនៃពួកបុគ្គលធំ ៗ ជាច្រើន បុគ្គលទាំងនេះក្នុងធម្មវិន័យនោះ គឺ សោតាបន្នបុគ្គលនឹងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល សកិទាគាមិបុគ្គលនឹងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកិទាគាមិផល អនាគាមិបុគ្គលនឹងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល អរហន្តនឹងបុគ្គលដែលកំពុងប្រតិបត្តិដើម្បី (ធ្វើឲ្យជាក់ច្បាស់) នូវអរហត្តផល ដូចមហាសមុទ្រ ដែលជាទីនៅអាស្រ័យនៃពួកសត្វធំ ៗ ជាច្រើន ឯពួកសត្វទាំងនេះ ក្នុងមហាសមុទ្រនោះ គឺ ត្រីឈ្មោះតិមិ ៗ បេ ៗ នឹងពួកអសុរ នាគ គន្ធព្វ ដែលមានអត្តភាព ១ រយយោជន៍ខ្លះ មានអត្តភាព ២ រយយោជន៍ខ្លះ មានអត្តភាព ៣ រយយោជន៍ខ្លះ មានអត្តភាព ៤ រយយោជន៍ខ្លះ មានអត្តភាព ៥ រយយោជន៍ខ្លះ ដែលមាននៅក្នុងមហាសមុទ្រដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យនេះជាទីនៅអាស្រ័យនៃពួកបុគ្គលធំ ៗ ជាច្រើន ពួកបុគ្គលទាំងនេះ ក្នុងធម្មវិន័យនោះ គឺ សោតាបន្នបុគ្គល ៗ បេ ៗ នឹងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បី (ធ្វើឲ្យជាក់ច្បាស់) នូវអរហត្តផល ដោយសភាពណា ម្នាលភិក្ខុទាំងឡាយ នេះជាសភាពមិនដែលកើត គួរអស្ចារ្យ ទី ៨ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរក្នុងធម្មវិន័យនេះ ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


ឥមេ ខោ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ អដ្ឋ អច្ឆរិយា អព្ភុតា ធម្មា យេ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តីតិ ។

(៤២៩) អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

ឆន្នមតិវស្សតិ[១] វិវដំ នាតិវស្សតិ
តស្មា ឆន្នំ វិវរេថ ឯវន្តំ នាតិវស្សតីតិ ។

(៤៣០) អថខោ ភគវា ភិក្ខូ អាមន្តេសិ ន ទានាហំ ភិក្ខវេ ឥតោ បរំ ឧបោសថំ ករិស្សាមិ បាតិមោក្ខំ ឧទ្ទិសិស្សាមិ តុម្ហេវ ទានិ ភិក្ខវេ ឥតោ បរំ ឧបោសថំ ករេយ្យាថ បាតិមោក្ខំ ឧទ្ទិសេយ្យាថ អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ តថាគតោ អបរិសុទ្ធាយ បរិសាយ ឧបោសថំ ករេយ្យ បាតិមោក្ខំ ឧទ្ទិសេយ្យ

---
១ ម. សុឆន្នមតិវស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នេះឯងហើយដែលហៅថាសភាពមិនដែលកើត គួរអស្ចារ្យ ៨ប្រការក្នុងធម៌វិន័យនេះ ដែលពួកភិក្ខុឃើញហើយ តែងត្រេកអរ ក្នុងធម្មវិន័យនេះ ។

(១២៩) គ្រានោះ ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទ្រង់បន្លឺនូវឧទានវាចានេះ ក្នុងវេលានោះថា

ភិក្ខុត្រូវអាបត្តិហើយបិទបាំងអាបត្តិទុក រមែងត្រូវអាបត្តិថ្មីដទៃ
ទៀត ភិក្ខុត្រូវអាបត្តិហើយ បើកអាបត្តិ មិនត្រូវអាបត្តិដទៃ
ទៀតទេ ព្រោះហេតុនោះ កាលបើភិក្ខុ(ណាមួយ)ត្រូវអាបត្តិ
ហើយបិទបាំងអាបត្តិទុក ភិក្ខុ ( នោះ ) ត្រូវបើកអាបត្តិចេញ
ធ្វើយ៉ាងនេះ ទើបមិនត្រូវអាបត្តិនោះទៀតឡើយ ។

(១៣០) លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ តាំងអំពីថ្ងៃនេះតទៅមុខ តថាគតនឹងមិនធ្វើឧបោសថ មិនសំដែងបាតិមោក្ខទេ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ ចាប់ដើមអំពីថ្ងៃនេះតទៅមុខ ចូរអ្នកទាំងឡាយ នាំគ្នាធ្វើឧបោសថ សំដែងបាតិមោក្ខចុះ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងធ្វើឧបោសថ សំដែងបាតិមោក្ខជាមួយនឹងបរិសទ្យមិនបរិសុទ្ធដោយហេតុណា ហេតុនុ៎ះមិនមែនជាទីតាំង មិនមែនជាឱកាស

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បាតិមោក្ខដ្ឋបនក្ខន្ធកេ ឆព្វគ្គិយភិក្ខុវត្ថុ

ន ច ភិក្ខវេ ភិក្ខុនា[១] សាបត្តិកេន បាតិមោក្ខំ សោតព្វំ យោ សុណេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ យោ សាបត្តិកោ បាតិមោក្ខំ សុណាតិ តស្ស បាតិមោក្ខំ ឋបេតុំ ។ ឯវញ្ច បន ភិក្ខវេ ឋបេតព្វំ ។ តទហុបោសថេ ចាតុទ្ទសេ វា បណ្ណរសេ វា តស្មឹ បុគ្គលេ សម្មុខីភូតេ សង្ឃមជ្ឈេ ឧទាហរិតព្វំ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមោ បុគ្គលោ សាបត្តិកោ តស្ស បាតិមោក្ខំ ឋបេមិ ន តស្មឹ សម្មុខីភូតេ បាតិមោក្ខំ ឧទ្ទិសិតព្វន្តិ ។ ឋបិតំ ហោតិ បាតិមោក្ខន្តិ ។

(១៣១) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ នាម្ហេ កោចិ ជានាតីតិ សាបត្តិកាវ បាតិមោក្ខំ សុណន្តិ ។ ថេរា ភិក្ខូ បរចិត្តវិទុនោ ភិក្ខូនំ អារោចេន្តិ ឥត្ថន្នាមោ ច ឥត្ថន្នាមោ ច អាវុសោ ឆព្វគ្គិយា ភិក្ខូ នាម្ហេ កោចិ ជានាតីតិ សាបត្តិកាវ បាតិមោក្ខំ សុណន្តីតិ ។ អស្សោសុំ ខោ ឆព្វគ្គិយា ភិក្ខូ ថេរា កិរ

---

១ ឱ. ម. បោត្ថកេសុ ភិក្ខូនាតិ វចនំ ន បញ្ញាយតិ ។

## បាតិមោក្ខដ្ឋបនក្ខន្ធកៈ រឿងឆព្វគ្គិយភិក្ខុ

(លុះមិនធ្វើបានទេ) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុដែលមានអាបត្តិ មិនត្រូវស្តាប់បាតិមោក្ខទេ ភិក្ខុណាស្តាប់ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបញ្ឈប់បាតិមោក្ខដល់ភិក្ខុដែលមានអាបត្តិ ហើយមកស្តាប់បាតិមោក្ខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវបញ្ឈប់ (បាតិ-មោក្ខ) យ៉ាងនេះឯង ។ ក្នុងថ្ងៃចាតុទ្ទសីឬបណ្ណរសីឧបោសថនោះ កាលបើមានបុគ្គល គឺ ភិក្ខុនោះមក ក្នុងទីចំពោះមុខ ភិក្ខុគប្បីប្រកាសកណ្តាលជំនុំសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតបុគ្គលឈ្មោះនេះ ជាអ្នកមានអាបត្តិ ខ្ញុំនឹងបញ្ឈប់បាតិមោក្ខដល់បុគ្គលនោះ កាលបើបុគ្គលនោះនៅក្នុងទីចំពោះមុខ សង្ឃមិនគួរសំដែងបាតិមោក្ខទេ ។ សង្ឃឈ្មោះថា បញ្ឈប់បាតិមោក្ខហើយ ។

(១៣១) ក្នុងសម័យនោះ ពួកឆព្វគ្គិយភិក្ខុ សុទ្ធតែជាអ្នកមានអាបត្តិ នាំគ្នាមកស្តាប់បាតិមោក្ខ ដោយគិតថា មិនមាននរណាស្គាល់ពួកយើងទេ។ ពួកភិក្ខុជាថេរៈដែលជ្រាបច្បាស់នូវវារៈចិត្តនៃបុគ្គលដទៃ ក៏ប្រាប់ភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ ឆព្វគ្គិយភិក្ខុឈ្មោះនេះមួយ ឈ្មោះនេះមួយ សុទ្ធតែជាអ្នកមានអាបត្តិ ហើយនាំគ្នាមកស្តាប់បាតិមោក្ខ ដោយគិតថា មិនមាននរណាស្គាល់ពួកយើងទេ ។ ពួកឆព្វគ្គិយភិក្ខុបានឮ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខូ បរចិត្តវិទុនោ អម្ហេ ភិក្ខូនំ អារោចេន្តិ ឥត្ថន្នាមោ ច ឥត្ថន្នាមោ ច អាវុសោ ឆព្វគ្គិយា ភិក្ខូ ន អម្ហេ កោចិ ជានាតីតិ សាបត្តិកាវ បាតិមោក្ខំ សុណន្តីតិ ។ តេ បុរម្ហាកំ បេសលា ភិក្ខូ បាតិមោក្ខំ ឋបេន្តីតិ បដិកច្ចេវ សុទ្ធានំ ភិក្ខូនំ អនាបត្តិកានំ អវត្ថុស្មឹ អការណេ បាតិមោក្ខំ ឋបេន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ សុទ្ធានំ ភិក្ខូនំ អនាបត្តិកានំ អវត្ថុស្មឹ អការណេ បាតិមោក្ខំ ឋបេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ឆព្វគ្គិយា ភិក្ខូ សុទ្ធានំ ភិក្ខូនំ អនាបត្តិកានំ អវត្ថុស្មឹ អការណេ បាតិមោក្ខំ ឋបេន្តីតិ ។ សច្ចំ ភគវាតិ ។ បេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដំណើរថា ពួកភិក្ខុជាថេរៈដែលលោកជ្រាបច្បាស់នូវវារៈចិត្តនៃបុគ្គលដទៃប្រាប់ ( រឿង )យើងដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ ពួកឆព្វគ្គិយភិក្ខុឈ្មោះនេះមួយ ឈ្មោះនេះមួយ សុទ្ធតែជាអ្នកមានអាបត្តិហើយនាំគ្នាមកស្ដាប់បាតិមោក្ខ ដោយគិតថា មិនមាននរណា ស្គាល់ពួកយើងទេ ។ ពួកឆព្វគ្គិយភិក្ខុទាំងនោះគិតគ្នាថា កាលពីមុនភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ បញ្ឈប់បាតិមោក្ខចំពោះពួកយើង ហើយប្រញាប់បញ្ឈប់បាតិមោក្ខដល់ភិក្ខុទាំងឡាយ ដែលបរិសុទ្ធមិនមានអាបត្តិ ដោយឥតមានរឿងឥតមានហេតុ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងបញ្ឈប់បាតិមោក្ខដល់ភិក្ខុទាំងឡាយដែលបរិសុទ្ធមិនមានអាបត្តិដោយឥតមានរឿងឥតមានហេតុសោះឡើយ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលដំណើរនុ៎ះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថាពួកឆព្វគ្គិយបញ្ឈប់បាតិមោក្ខដល់ភិក្ខុទាំងឡាយដែលបរិសុទ្ធមិនមានអាបត្តិ ដោយឥតមានរឿងឥតមានហេតុ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។ បេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បាតិមោក្ខដ្ឋបនក្ខន្ធកេ បាតិមោក្ខដ្ឋបនានិ

វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ សុទ្ធានំ ភិក្ខូនំ អនាបត្តិកានំ អវត្ថុស្មឹ អការណេ បាតិមោក្ខំ ឋបេតព្វំ យោ ឋបេយ្យ អាបត្តិ ទុក្កដស្ស ។

(១៣២) ឯកំ ភិក្ខវេ អធម្មិកំ បាតិមោក្ខដ្ឋបនំ[១] ឯកំ ធម្មិកំ ។ ទ្វេ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ទ្វេ ធម្មិកានិ ។ តីណិ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ តីណិ ធម្មិកានិ ។ ចត្តារិ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ចត្តារិ ធម្មិកានិ ។ បញ្ច អធម្មិកានិ បាតិមោក្ខដ្ឋបនានិ បញ្ច ធម្មិកានិ ។ ឆ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ឆ ធម្មិកានិ ។ សត្ត អធម្មិកានិ បាតិមោក្ខដ្ឋបនានិ សត្ត ធម្មិកានិ ។ អដ្ឋ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ អដ្ឋ ធម្មិកានិ ។ នវ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ នវ ធម្មិកានិ ។ ទស អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ទស ធម្មិកានិ ។

---

១ ឱ. ម. បាតិមោក្ខឋបនំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បាតិមោក្ខដ្ឋបនក្ខន្ធកៈ ការបញ្ឈប់បាតិមោក្ខ

ព្រះមានព្រះភាគទ្រង់បន្ទោស ហើយទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបញ្ឈប់បាតិមោក្ខដល់ពួកភិក្ខុដែលបរិសុទ្ធមិនមានអាបត្តិ ដោយឥតមានរឿង ឥតមានហេតុទេ ភិក្ខុណាបញ្ឈប់ ត្រូវអាបត្តិទុក្កដ ។

[១៣៦] ម្នាលភិក្ខុទាំងឡាយ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ១ ប្រកបដោយធម៌ ១ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ២ យ៉ាង ប្រកបដោយធម៌ ២ យ៉ាង ។ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ៣ យ៉ាង ប្រកបដោយធម៌ ៣ យ៉ាង ។ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ៤ យ៉ាង ប្រកបដោយធម៌ ៤ យ៉ាង ។ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ៥ យ៉ាង ប្រកបដោយធម៌ ៥ យ៉ាង ។ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ៦ យ៉ាង ប្រកបដោយធម៌ ៦ យ៉ាង ។ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ៧ យ៉ាង ប្រកបដោយធម៌ ៧ យ៉ាង ។ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ៨ យ៉ាង ប្រកបដោយធម៌ ៨ យ៉ាង ។ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ៩ យ៉ាង ប្រកបដោយធម៌ ៩ យ៉ាង ។ ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ១០ យ៉ាង ប្រកបដោយធម៌ ១០ យ៉ាង ។

## វិនយបិដកេ ចុល្លវគ្គោ

(១៣៣) កតមំ ឯកំ អធម្មិកំ បាតិមោក្ខដ្ឋបនំ ។ អមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ ឥទំ ឯកំ អធម្មិកំ បាតិមោក្ខដ្ឋបនំ ។

(១៣៤) កតមំ ឯកំ ធម្មិកំ បាតិមោក្ខដ្ឋបនំ ។ សមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ ឥទំ ឯកំ ធម្មិកំ បាតិមោក្ខដ្ឋបនំ ។

(១៣៥) កតមានិ ទ្វេ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ អមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ អមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ ឥមានិ ទ្វេ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

(១៣៦) កតមានិ ទ្វេ ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ សមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ សមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ ឥមានិ ទ្វេ ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៣៣) ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ១ យ៉ាង ។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល នេះហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ១ យ៉ាង ។

(១៣៤) ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ ១ យ៉ាង ។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល នេះហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ ១ យ៉ាង ។

(១៣៥) ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ២ យ៉ាង ។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ២ យ៉ាង ។

(១៣៦) ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ ២ យ៉ាង ។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ ២ យ៉ាង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


(១៣៧) កតមានិ តីណិ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ អមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ អមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ អមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ ឥមានិ តីណិ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

(១៣៨) កតមានិ តីណិ ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ សមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ សមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ សមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ ឥមានិ តីណិ ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

(១៣៩) កតមានិ ចត្តារិ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ អមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ អមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ អមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ អមូលិកាយ អាជីវវិបត្តិយា បាតិមោក្ខំ ឋបេតិ ឥមានិ ចត្តារិ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បាតិមោក្ខដ្ឋបនក្ខន្ធកៈ ការបញ្ឈប់បាតិមោក្ខ ៣-៤ យ៉ាង

(១៣៧) ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ៣ យ៉ាង ។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូល ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ៣ យ៉ាង ។

(១៣៨) ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ ៣ យ៉ាង ។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូល ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌ ៣ យ៉ាង ។

(១៣៩) ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ៤ យ៉ាង ។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះអាជីវវិបត្តិមិនមានមូល ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌ ៤ យ៉ាង ។

## វិនយបិដកេ ចុល្លវគ្គោ

[១៤០] កតមានិ ចត្តារិ ធម្មិកានិ បាតិមោក្ខដ្ឋបនានិ។ សមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ សមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ សមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ សមូលិកាយ អាជីវវិបត្តិយា បាតិមោក្ខំ ឋបេតិ ឥមានិ ចត្តារិ ធម្មិកានិ បាតិមោក្ខដ្ឋបនានិ។

[១៤១] កតមានិ បញ្ច អធម្មិកានិ បាតិមោក្ខដ្ឋបនានិ។ អមូលិកេន បារាជិកេន បាតិមោក្ខំ ឋបេតិ អមូលិកេន សង្ឃាទិសេសេន បាតិមោក្ខំ ឋបេតិ អមូលិកេន បាចិត្តិយេន បាតិមោក្ខំ ឋបេតិ អមូលិកេន បាដិទេសនីយេន បាតិមោក្ខំ ឋបេតិ អមូលិកេន ទុក្កដេន បាតិមោក្ខំ ឋបេតិ ឥមានិ បញ្ច អធម្មិកានិ បាតិមោក្ខដ្ឋបនានិ។

[១៤២] កតមានិ បញ្ច ធម្មិកានិ បាតិមោក្ខដ្ឋបនានិ។ សមូលិកេន បារាជិកេន បាតិមោក្ខំ ឋបេតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដក ចុល្លវគ្គ

[ ១៤០ ] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ ៤ យ៉ាង ។ គឺភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះអាជីវវិបត្តិមានមូល ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌ ៤ យ៉ាង ។

[១៤១] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌ ៥ យ៉ាង ។ គឺភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះបារាជិកាបត្តិ មិនមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះសង្ឃាទិសេសាបត្តិមិនមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះបាចិត្តិយាបត្តិមិនមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះបាដិទេសនីយាបត្តិមិនមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះទុក្កដាបត្តិ មិនមានមូល ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌ ៥ យ៉ាង ។

[១៤២] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌ ៥ យ៉ាង ។ គឺភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះបារាជិកាបត្តិមានមូល ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


## បាតិមោក្ខដ្ឋបនក្ខន្ធកេ ឆ បាតិមោក្ខដ្ឋបនានិ

សមូលិកេន សង្ឃាទិសេសេន បាតិមោក្ខំ ឋបេតិ សមូលិកេន បាចិត្តិយេន បាតិមោក្ខំ ឋបេតិ សមូលិកេន បាដិទេសនីយេន បាតិមោក្ខំ ឋបេតិ សមូលិកេន ទុក្កដេន បាតិមោក្ខំ ឋបេតិ ឥមានិ បញ្ច ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

(១៤៣) កតមានិ ឆ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ អមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ អមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ អមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ អមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ អមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ អមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ ឥមានិ ឆ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

(១៤៤) កតមានិ ឆ ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ សមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បញ្ឈប់បាតិមោក្ខ ព្រោះសង្ឃាទិសេសាបត្តិមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះបាចិត្តិយាបត្តិមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះបាដិទេសនីយាបត្តិមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះទុក្កដាបត្តិមានមូល ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌ ៤ យ៉ាង ។

(១៨៣) ដូចម្ដេចហៅថា ការបញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌ ៦ យ៉ាង ។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូលដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូលដែលភិក្ខុធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូលដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូលដែលភិក្ខុធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូលដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូលដែលភិក្ខុធ្វើហើយ ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌ ៦ យ៉ាង ។

(១៨៤) ដូចម្ដេចហៅថា ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌ ៦ យ៉ាង ។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូលដែលភិក្ខុមិន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឋបេតិ អកតាយ សមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ សមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ សមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ សមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ សមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ ឥមានិ ឆ ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

(១៤៥) កតមានិ សត្ត អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ អមូលិកេន បារាជិកេន បាតិមោក្ខំ ឋបេតិ អមូលិកេន សង្ឃាទិសេសេន បាតិមោក្ខំ ឋបេតិ អមូលិកេន ថុល្លច្ចយេន បាតិមោក្ខំ ឋបេតិ អមូលិកេន បាចិត្តិយេន បាតិមោក្ខំ ឋបេតិ អមូលិកេន បាដិទេសនីយេន បាតិមោក្ខំ ឋបេតិ អមូលិកេន ទុក្កដេន បាតិមោក្ខំ ឋបេតិ អមូលិកេន ទុព្ភាសិតេន បាតិមោក្ខំ ឋបេតិ ឥមានិ សត្ត អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



បានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូលដែលភិក្ខុធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូលដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូលដែលភិក្ខុធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូលដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូលដែលភិក្ខុធ្វើហើយ ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌ ៦ យ៉ាង ។

(១៨៥) ដូចម្ដេចហៅថា ការបញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌ ៧ យ៉ាង ។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះបារាជិកាបត្តិមិនមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះសង្ឃាទិសេសាបត្តិមិនមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះថុល្លច្ចយាបត្តិមិនមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះបាចិត្តិយាបត្តិមិនមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះបាដិទេសនីយាបត្តិមិនមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះទុក្កដាបត្តិមិនមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះទុព្ភាសិតាបត្តិមិនមានមូល ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌ ៧ យ៉ាង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## បាតិមោក្ខដ្ឋបនក្ខន្ធកេ សត្ត អដ្ឋ បាតិមោក្ខដ្ឋបនានិ

(១៤៦) កតមានិ សត្ត ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ សមូលិកេន បារាជិកេន បាតិមោក្ខំ ឋបេតិ សមូលិកេន សង្ឃាទិសេសេន បាតិមោក្ខំ ឋបេតិ សមូលិកេន ថុល្លច្ចយេន បាតិមោក្ខំ ឋបេតិ សមូលិកេន បាចិត្តិយេន បាតិមោក្ខំ ឋបេតិ សមូលិកេន បាដិទេសនីយេន បាតិមោក្ខំ ឋបេតិ សមូលិកេន ទុក្កដេន បាតិមោក្ខំ ឋបេតិ សមូលិកេន ទុព្ភាសិតេន បាតិមោក្ខំ ឋបេតិ ឥមានិ សត្ត ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

(១៤៧) កតមានិ អដ្ឋ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ អមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ អមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ អមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ អមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ អមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ អមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ អមូលិកាយ អាជីវវិបត្តិយា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បាតិមោក្ខដ្ឋបនក្ខន្ធកៈ ការបញ្ឈប់បាតិមោក្ខ ៧-៨ យ៉ាង

(១៨៦) ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌ ៧ យ៉ាង ។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះបារាជិកាបត្តិមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះសង្ឃាទិសេសាបត្តិមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះថុល្លច្ចយាបត្តិមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះបាចិត្តិយាបត្តិមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះបាដិទេសនីយាបត្តិមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះទុក្កដាបត្តិមានមូល ១ បញ្ឈប់បាតិមោក្ខ ព្រោះទុព្ភាសិតាបត្តិមានមូល ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌ ៧ យ៉ាង ។

(១៨៧) ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌ ៨ យ៉ាង ។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល ដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល ដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូល ដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាជីវវិបត្តិមិនមានមូល ដែលភិក្ខុមិន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


បាតិមោក្ខំ ឋបេតិ អកតាយ អមូលិកាយ អាជីវវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ ឥមានិ អដ្ឋ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

(១៤៨) កតមានិ អដ្ឋ ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ សមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ សមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ សមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ សមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ សមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ សមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ សមូលិកាយ អាជីវវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ សមូលិកាយ អាជីវវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ ឥមានិ អដ្ឋ ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

(១៤៩) កតមានិ ទស អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ អមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ អមូលិកាយ សីលវិបត្តិយា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាជីវវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខមិនប្រកបដោយធម៌ ៨ យ៉ាង ។

(១៨៨) ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌ ៨ យ៉ាង ។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាជីវវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាជីវវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌ ៨ យ៉ាង ។

(១៨៩) ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌ ៩ យ៉ាង ។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល ដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បាតិមោក្ខដ្ឋបនក្ខន្ធកេ នវ បាតិមោក្ខដ្ឋបនានិ

បាតិមោក្ខំ ឋបេតិ កតាយ អមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាកតាយ អមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ អមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ អមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាកតាយ អមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ អមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ អមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាកតាយ ឥមានិ នវ អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

[១៥០] កតមានិ នវ ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ សមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ សមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ សមូលិកាយ សីលវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាកតាយ សមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ សមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បាតិមោក្ខដ្ឋបនក្ខន្ធកៈ ការបញ្ឈប់បាតិមោក្ខ ៩ យ៉ាង

ដែលភិក្ខុធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយនឹងមិនធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល ដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយនឹងមិនធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូល ដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមិនមានមូល ដែលភិក្ខុធ្វើហើយនឹងមិនធ្វើហើយ ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌ ៩ យ៉ាង ។

(១៩០) ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ ៩ យ៉ាង ។ ភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះសីលវិបត្តិមានមូល ដែលភិក្ខុធ្វើហើយនឹងមិនធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កតាយ សមូលិកាយ អាចារវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាកតាយ សមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ អកតាយ សមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាយ សមូលិកាយ ទិដ្ឋិវិបត្តិយា បាតិមោក្ខំ ឋបេតិ កតាកតាយ ឥមានិ ទស ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

(១៥១) កតមានិ ទស អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ ន បារាជិកោ តស្មឹ បរិសាយំ និសិន្នោ ហោតិ ន បារាជិកកថា វិប្បកតា ហោតិ ន សិក្ខំ បច្ចក្ខាតកោ តស្មឹ បរិសាយំ និសិន្នោ ហោតិ ន សិក្ខំ បច្ចក្ខាតកថា វិប្បកតា ហោតិ ធម្មិកំ សាមគ្គឹ ឧបេតិ ន ធម្មិកំ សាមគ្គឹ បច្ចាទិយតិ ន ធម្មិកាយ សាមគ្គិយា បច្ចាទានកថា វិប្បកតា ហោតិ ន សីលវិបត្តិយា ទិដ្ឋសុតបរិសង្កិតោ ហោតិ ន អាចារវិបត្តិយា ទិដ្ឋសុតបរិសង្កិតោ ហោតិ ន ទិដ្ឋិវិបត្តិយា ទិដ្ឋសុតបរិសង្កិតោ ហោតិ ឥមានិ ទស អធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដែលភិក្ខុធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះអាចារវិបត្តិមានមូល ដែលភិក្ខុធ្វើហើយនិងមិនធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូល ដែលភិក្ខុមិនបានធ្វើ ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូល ដែលភិក្ខុធ្វើហើយ ១ បញ្ឈប់បាតិមោក្ខ ព្រោះទិដ្ឋិវិបត្តិមានមូល ដែលភិក្ខុធ្វើហើយនិងមិនធ្វើហើយ ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌ ៩ យ៉ាង ។

[១៩១] ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌ ១០ យ៉ាង ។ មិនមានភិក្ខុត្រូវបារាជិកអង្គុយក្នុងបរិសទ្យនោះ ១ មិនមានពាក្យពណ៌នាអំពីភិក្ខុត្រូវបារាជិក ដែលសង្ឃធ្វើមិនទាន់ស្រេច ១ មិនមានភិក្ខុអ្នកបោលលាសិក្ខាអង្គុយក្នុងបរិសទ្យនោះ ១ មិនមានពាក្យពណ៌នាអំពីភិក្ខុអ្នកបោលលាសិក្ខា ដែលសង្ឃធ្វើមិនទាន់ស្រេច ១ ភិក្ខុចូលមកព្រមព្រៀងគ្នាប្រកបដោយធម៌ ១ ភិក្ខុមិនត្រឡប់សើរើសេចក្តីព្រមព្រៀងដែលប្រកបដោយធម៌ ១ មានពាក្យពណ៌នាអំពីការត្រឡប់សើរើសេចក្តីព្រមព្រៀងប្រកបដោយធម៌ ដែលសង្ឃធ្វើស្រេចហើយ ១ មិនមានភិក្ខុដែលសង្ឃឃើញ ឮ ឬរង្កៀសដោយសីលវិបត្តិ ១ មិនមានភិក្ខុដែលសង្ឃឃើញ ឮ ឬរង្កៀសដោយអាចារវិបត្តិ ១ មិនមានភិក្ខុដែលសង្ឃឃើញ ឮ ឬរង្កៀសដោយទិដ្ឋិវិបត្តិ ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌ ១០ យ៉ាង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បាតិមោក្ខដ្ឋបនក្ខន្ធកេ ទស បាតិមោក្ខដ្ឋបនានិ

(១៥២) កតមានិ ទស ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។ បារាជិកោ តស្សំ បរិសាយំ និសិន្នោ ហោតិ បារាជិកកថា វិប្បកតា ហោតិ សិក្ខំ បច្ចក្ខាតកោ តស្សំ បរិសាយំ និសិន្នោ ហោតិ សិក្ខំ បច្ចក្ខាតកកថា វិប្បកតា ហោតិ ធម្មិកំ សាមគ្គឹ ន ឧបេតិ ធម្មិកំ សាមគ្គឹ បច្ចាទិយតិ ធម្មិកាយ សាមគ្គិយា បច្ចាទានកថា ហោតិ សីលវិបត្តិយា ទិដ្ឋសុតបរិសង្កិតោ ហោតិ វិប្បកតា អាចារវិបត្តិយា ទិដ្ឋសុតបរិសង្កិតោ ហោតិ ទិដ្ឋិវិបត្តិយា ទិដ្ឋសុតបរិសង្កិតោ ហោតិ ឥមានិ ទស ធម្មិកានិ បាតិមោក្ខដ្ឋបនានិ ។

(១៥៣) កថំ បារាជិកោ តស្សំ បរិសាយំ និសិន្នោ ហោតិ ។ ឥធ ភិក្ខវេ[១] យេហិ អាការេហិ យេហិ លិង្គេហិ យេហិ និមិត្តេហិ បារាជិកស្ស ធម្មស្ស អជ្ឈាបត្តិ ហោតិ តេហិ អាការេហិ តេហិ លិង្គេហិ តេហិ និមិត្តេហិ ភិក្ខុ ភិក្ខុំ បស្សតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តំ ន ហេវ ខោ ភិក្ខុ ភិក្ខុំ បស្សតិ បារាជិកំ ធម្មំ អជ្ឈាបជ្ជន្តំ

---

១ ម. ឯត្ថន្តរេ ភិក្ខូតិ បាឋោ បញ្ញាយតិ ។

## បាតិមោក្ខដ្ឋបនក្ខន្ធកៈ ការបញ្ឈប់បាតិមោក្ខ ១០ យ៉ាង

(១៨២) ដូចម្តេចហៅថា ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌ ១០ យ៉ាង ។ មានភិក្ខុត្រូវបារាជិកអង្គុយក្នុងបរិសទ្យនោះ ១ មានពាក្យពណ៌នាអំពីភិក្ខុត្រូវបារាជិក ដែលសង្ឃធ្វើមិនទាន់ស្រេច ១ មានភិក្ខុអ្នកពោលលាសិក្ខាអង្គុយនៅក្នុងបរិសទ្យ ១ មានពាក្យពណ៌នាអំពីភិក្ខុអ្នកពោលលាសិក្ខា ដែលសង្ឃធ្វើមិនទាន់ស្រេច ១ ភិក្ខុមិនចូលមកព្រមព្រៀងគ្នាប្រកបដោយធម៌ ១ ភិក្ខុគ្រឡប់សើរើសេចក្តីព្រមព្រៀងដែលប្រកបដោយធម៌ ១ មានពាក្យពណ៌នាអំពីការគ្រឡប់សើរើសេចក្តីព្រមព្រៀងប្រកបដោយធម៌ ដែលសង្ឃបានធ្វើស្រេចហើយ ១ មានភិក្ខុដែលសង្ឃឃើញ ឮ ឬរង្កៀសដោយសីលវិបត្តិ ១ មានភិក្ខុដែលសង្ឃឃើញ ឮ ឬរង្កៀសដោយអាចារវិបត្តិ ១ មានភិក្ខុដែលសង្ឃឃើញ ឮ ឬរង្កៀសដោយទិដ្ឋិវិបត្តិ ១ នេះហៅថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ ១០ យ៉ាង ។

(១៨៣) ដូចម្តេចហៅថា ភិក្ខុត្រូវបារាជិកអង្គុយក្នុងបរិសទ្យនោះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ រមែងមានការត្រូវអាបត្តិបារាជិក ដោយអាការណា ដោយភេទណា ដោយនិមិត្តណា ឯភិក្ខុរមែងឃើញភិក្ខុដែលត្រូវអាបត្តិបារាជិក ដោយអាការនោះ ដោយភេទនោះ ដោយនិមិត្តនោះ បើភិក្ខុមិនបានឃើញភិក្ខុដែលត្រូវអាបត្តិបារាជិក (នោះ) ទេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អបិច អញ្ញោ ភិក្ខុ ភិក្ខុស្ស អារោចេតិ ឥត្ថន្នាមោ អាវុសោ ភិក្ខុ អាបត្តិំ ធម្មំ អជ្ឈាបន្នោតិ(១) ន ហេវ ខោ ភិក្ខុ ភិក្ខុំ បស្សតិ អាបត្តិំ ធម្មំ អជ្ឈាបជ្ជន្តំ ន បិ អញ្ញោ ភិក្ខុ ភិក្ខុស្ស អារោចេតិ ឥត្ថន្នាមោ អាវុសោ ភិក្ខុ អាបត្តិំ ធម្មំ អជ្ឈាបន្នោតិ(២) អបិច សោវ ភិក្ខុ ភិក្ខុស្ស អារោចេតិ អហំ អាវុសោ អាបត្តិំ ធម្មំ អជ្ឈាបន្នោតិ(៣) អាកង្ខមានោ ភិក្ខវេ ភិក្ខុ តេន ទិដ្ឋេន តេន សុតេន តាយ បរិសង្កាយ តទហុបោសថេ ចាតុទ្ទសេ វា បណ្ណរសេ វា តស្មឹ បុគ្គលេ សម្មុខីភូតេ សង្ឃមជ្ឈេ ឧទាហរេយ្យ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមោ បុគ្គលោ អាបត្តិំ ធម្មំ អជ្ឈាបន្នោ តស្ស បាតិមោក្ខំ ឋបេមិ ន តស្មឹ សម្មុខីភូតេ បាតិមោក្ខំ ឧទ្ទិសិតព្វន្តិ ។ ធម្មិកំ បាតិមោក្ខដ្ឋបនំ ។

(១៥៤) ភិក្ខុស្ស បាតិមោក្ខេ ឋបិតេ បរិសា វុដ្ឋាតិ ទសន្នំ អន្តរាយានំ អញ្ញតរេន អន្តរាយេន(៤) រាជន្តរាយេន វា ចោរន្តរាយេន វា អគ្យន្តរាយេន វា

---

១-២ អជ្ឈាបន្នោ ហោតីតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ៣ អជ្ឈាបន្នោម្ហីតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ៤ ឱ. ម. បោត្ថកេសុ អន្តរាយេនាតិ បាឋោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ក៏គង់មានភិក្ខុឯទៀតប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះត្រូវអាបត្តិបារាជិកហើយ ប្រសិនបើភិក្ខុមិនឃើញភិក្ខុដែលត្រូវអាបត្តិបារាជិកនោះទេ ទាំងភិក្ខុឯទៀត ក៏មិនបានប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះត្រូវអាបត្តិបារាជិកហើយដូច្នេះទេ ក៏ភិក្ខុនោះឯងប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិបារាជិកហើយ ដូច្នេះ (មិនខាន) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមានប្រាថ្នា ក៏គប្បីសូត្រក្នុងកណ្តាលសង្ឃចំពោះបុគ្គលដែលភិក្ខុត្រូវអាបត្តិបារាជិក ដែលនៅក្នុងទីចំពោះមុខនោះ ក្នុង ថ្ងៃចាតុទ្ទសីឬបណ្ណរសីឧបោសថនោះ ដោយការឃើញនោះ ដោយការឮនោះ ដោយការរង្កៀសនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតបុគ្គលឈ្មោះនេះត្រូវអាបត្តិបារាជិកហើយ ឥឡូវនេះខ្ញុំនឹងបញ្ឈប់បាតិមោក្ខដល់បុគ្គលនោះ កាលបើបុគ្គលនោះមកនៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខទេ ។ ការបញ្ឈប់បាតិមោក្ខនេះ ឈ្មោះថាប្រកបដោយធម៌ ។

[១៥៤] កាលបើសង្ឃបញ្ឈប់បាតិមោក្ខដល់ភិក្ខុហើយ បរិសទ្យក្រោកឡើង ព្រោះបណ្តាអន្តរាយទាំង ១០ យ៉ាង អន្តរាយណាមួយ ទោះបីអន្តរាយអំពីព្រះរាជាក្តី អន្តរាយអំពីចោរក្តី អន្តរាយអំពីភ្លើងក្តី អន្តរាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។

## ជាតិមោក្ខដ្ឋបនក្ខក្ខកេ ឆក្កំ ជាតិមោក្ខដ្ឋបនំ

ឧទកត្តកាយេន វា មនុស្សត្តកាយេន វា អមនុស្សត្ត-
កាយេន វា វាទ្យត្តកាយេន វា សិរឹសបត្តកាយេន វា ជីវិតត្ត-
កាយេន វា ព្រហ្មចរិយត្តកាយេន វា អាកង្ខមានោ ភិក្ខវេ
ភិក្ខុ តស្មឹ អាវាសេ អញ្ញតរស្មឹ វា អាវាសេ តស្មឹ
បុគ្គលេ សម្មុខីភូតេ សង្ឃមជ្ឈេ ឧទាហរេយ្យ សុណាតុ
មេ ភន្តេ សង្ឃោ ឥត្ថន្នាមស្ស បុគ្គលស្ស ជាវជិកកកថា
វិប្បកតា តំ វត្ថុំ អវិនិច្ឆិតំ យទិ សង្ឃស្ស បត្តកល្លំ
សង្ឃោ តំ វត្ថុំ វិនិច្ឆិនេយ្យាតិ ។ ឋវេញ្ញុ ឝំ លវកេជ ឥច្ចេតំ
កុសលំ ពោ ចេ លវកេជ តទហុ ពោសថេ ជាតុទ្ទសេ
វា បណ្ណរសេ វា តស្មឹ បុគ្គលេ សម្មុខីភូតេ សង្ឃមជ្ឈេ
ឧទាហរិតព្វំ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមស្ស
បុគ្គលស្ស ជាវជិកកកថា វិប្បកតា តំ វត្ថុំ អវិនិច្ឆិតំ
តស្ស ជាតិមោក្ខំ ឋបេមិ ន តស្មឹ សម្មុខីភូតេ
ជាតិមោក្ខំ ឧទ្ទិសិតព្វន្តិ ។ ឆក្កំ ជាតិមោក្ខដ្ឋបនំ ។

## បាតិមោក្ខដ្ឋបនក្ខន្ធកៈ ការបញ្ឈប់បាតិមោក្ខ ប្រកបដោយធម៌

អំពីទឹកក្តី អន្តរាយអំពីមនុស្សក្តី អន្តរាយអំពីអមនុស្សក្តី អន្តរាយអំពីសត្វ
សាហាវក្តី អន្តរាយអំពីសត្វពស់តូចនិងពស់ធំក្តី អន្តរាយជីវិតក្តី អន្តរាយ
ព្រហ្មចារិយធម៌ក្តី ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបើប្រាថ្នា ក៏គប្បីសូត្រក្នុង
កណ្តាលជំនុំសង្ឃចំពោះបុគ្គលដែលនៅក្នុងទីចំពោះមុខនោះ ក្នុងអាវាស
នោះ ក្នុងអាវាសណាមួយបានថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃ
ស្តាប់ខ្ញុំ ពាក្យពណ៌នាអំពីបារាជិករបស់បុគ្គលឈ្មោះនេះ សង្ឃផ្តើមមិនទាន់
ស្រេចនៅឡើយទេ (ព្រោះ) រឿងនោះ សង្ឃមិនទាន់វិនិច្ឆ័យដាច់ស្រេច បើ
កម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីវិនិច្ឆ័យរឿងនោះចុះ ។ បើសង្ឃ
បានវិនិច្ឆ័យរឿងនោះដាច់ស្រេច នេះជាការល្អ បើបរជាវិនិច្ឆ័យមិនបាន
វិញ ភិក្ខុត្រូវសូត្រក្នុងកណ្តាលជំនុំសង្ឃចំពោះបុគ្គលដែលនៅក្នុងទីចំពោះ
មុខនោះ ក្នុងថ្ងៃចាតុទ្ទសីឬបណ្ណរសីឧបោសថនោះថា បពិត្រព្រះសង្ឃដ៏
ចំរើន សូមសង្ឃស្តាប់ខ្ញុំ ពាក្យពណ៌នាអំពីបារាជិករបស់បុគ្គលឈ្មោះនេះ
សង្ឃផ្តើមមិនទាន់ស្រេចនៅឡើយ (ព្រោះ) រឿងនោះ សង្ឃមិនទាន់វិនិច្ឆ័យ
ដាច់ស្រេច ឥឡូវខ្ញុំនឹងបញ្ឈប់បាតិមោក្ខដល់បុគ្គលនោះ កាលបើបុគ្គល
នោះនៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខទេ ។ ការបញ្ឈប់
បាតិមោក្ខ (នេះ) ឈ្មោះថាប្រកបដោយធម៌ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៥៥) កថំ សិក្ខំ បច្ចក្ខាតកោ តស្សំ បរិសាយំ និសិន្នោ ហោតិ ។ ឥធ បន ភិក្ខវេ ភិក្ខុនា[1] យេហិ អាការេហិ យេហិ លិង្គេហិ យេហិ និមិត្តេហិ សិក្ខា បច្ចក្ខាតា ហោតិ តេហិ អាការេហិ តេហិ លិង្គេហិ តេហិ និមិត្តេហិ ភិក្ខុ ភិក្ខុំ បស្សតិ សិក្ខំ បច្ចក្ខន្តំ ន ហេវ ខោ ភិក្ខុ ភិក្ខុំ បស្សតិ សិក្ខំ បច្ចក្ខន្តំ អបិច អញ្ញោ ភិក្ខុ ភិក្ខុស្ស អារោចេតិ ឥត្ថន្នាមេន អាវុសោ ភិក្ខុនា សិក្ខា បច្ចក្ខាតាតិ ន ហេវ ខោ ភិក្ខុ ភិក្ខុំ បស្សតិ សិក្ខំ បច្ចក្ខន្តំ ន បិ អញ្ញោ ភិក្ខុ ភិក្ខុស្ស អារោចេតិ ឥត្ថន្នាមេន អាវុសោ ភិក្ខុនា សិក្ខា បច្ចក្ខាតាតិ អបិច សោវ ភិក្ខុ ភិក្ខុស្ស អារោចេតិ មយា អាវុសោ សិក្ខា បច្ចក្ខាតាតិ អាកង្ខមានោ ភិក្ខវេ ភិក្ខុ តេន ទិដ្ឋេន តេន សុតេន តាយ បរិសង្កាយ តទហុបោសថេ ចាតុទ្ទសេ វា បណ្ណរសេ វា តស្មឹ បុគ្គលេ សម្មុខីភូតេ សង្ឃមជ្ឈេ ឧទាហរេយ្យ សុណាតុ មេ ភន្តេ សង្ឃោ

---

១ ឱ. ម. ពោត្ថកេសុ ភិក្ខុនាតិ វចនំ ន ទិស្សតិ ។

## វិនយបិដក បុព្វវគ្គ

(១៥៥) ភិក្ខុអ្នកពោលលាសិក្ខា អង្គុយនៅក្នុងបរិសទ្យនោះតើដូចម្តេចៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពោលលាសិក្ខា ដោយអាការណា ដោយភេទណា ដោយនិមិត្តណា ភិក្ខុឃើញភិក្ខុកំពុងពោលលាសិក្ខា ដោយអាការនោះ ដោយភេទនោះ ដោយនិមិត្តនោះ បើភិក្ខុមិនបានឃើញភិក្ខុកំពុងពោលលាសិក្ខា (នោះ) ទេ គង់មានភិក្ខុឯទៀតប្រាប់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះពោលលាសិក្ខាហើយ បើភិក្ខុមិនឃើញភិក្ខុកំពុងពោលលាសិក្ខា ទាំងភិក្ខុឯទៀតក៏មិនប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះពោលលាសិក្ខាហើយដូច្នេះទេ ក៏គង់ភិក្ខុនោះឯងប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្ញុំពោលលាសិក្ខាហើយដូច្នេះ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុប្រាថ្នា ក៏គប្បីសូត្រក្នុងកណ្តាលជំនុំសង្ឃ ចំពោះបុគ្គលដែលនៅក្នុងទីចំពោះមុខក្នុងថ្ងៃចាតុទ្ទសីឬបណ្ណរសី ឧបោសថនោះ ដោយការឃើញនោះ ដោយការឮនោះ ដោយការរង្កៀសនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



ឥត្ថន្នាមេន បុគ្គលេន សិក្ខា បច្ចក្ខាតា តស្ស បាតិមោក្ខំ ឋបេមិ ន តស្មឹ សម្មុខីភូតេ បាតិមោក្ខំ ឧទ្ទិសិតព្វន្តិ ។ ធម្មិកំ បាតិមោក្ខដ្ឋបនំ ។

(១៥៦) ភិក្ខុស្ស បាតិមោក្ខេ ឋបិតេ បរិសា វុដ្ឋាតិ ទសន្នំ អន្តរាយានំ អញ្ញតរេន អន្តរាយេន រាជន្តរាយេន វា ។បេ។ ព្រហ្មចរិយន្តរាយេន វា អាកង្ខមានោ ភិក្ខវេ ភិក្ខុ តស្មឹ អាវាសេ អញ្ញតរស្មឹ វា អាវាសេ តស្មឹ បុគ្គលេ សម្មុខីភូតេ សង្ឃមជ្ឈេ ឧទាហរេយ្យ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមស្ស បុគ្គលស្ស សិក្ខំ បច្ចក្ខាតកថា វិប្បកតា តំ វត្ថុំ អវិនិច្ឆិតំ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ តំ វត្ថុំ វិនិច្ឆិនេយ្យាតិ ។ ឯវញ្ចេ តំ លភេថ ឥច្ចេតំ កុសលំ នោ ចេ លភេថ តទហុបោសថេ ចាតុទ្ទសេ វា បណ្ណរសេ វា តស្មឹ បុគ្គលេ សម្មុខីភូតេ សង្ឃមជ្ឈេ ឧទាហរិតព្វំ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមស្ស បុគ្គលស្ស សិក្ខំ បច្ចក្ខាតកថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ផ្សព្វផ្សាយ។

## បាតិមោក្ខដ្ឋបនក្ខន្ធកៈ ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌

បុគ្គលឈ្មោះនេះពោលលាសិក្ខាហើយ ខ្ញុំនឹងបញ្ឈប់បាតិមោក្ខដល់បុគ្គលនោះ កាលបើបុគ្គលនោះនៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខទេ ។ ការបញ្ឈប់បាតិមោក្ខ (នេះ) ឈ្មោះថាប្រកបដោយធម៌ ។

(១៩៦) កាលបើសង្ឃបញ្ឈប់បាតិមោក្ខដល់ភិក្ខុហើយ បរិសទ្យក្រោកឡើង ព្រោះអន្តរាយទាំង ១០ យ៉ាង អន្តរាយណាមួយ ទោះបីអន្តរាយអំពីព្រះរាជាក្តី ។ បេ ។ អន្តរាយព្រហ្មចរិយធម៌ក្តី ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុប្រាថ្នា គប្បីសូត្រក្នុងកណ្តាលជុំនុំសង្ឃ ចំពោះបុគ្គលដែលនៅក្នុងទីចំពោះមុខនោះ ក្នុងអាវាសនោះ ឬក្នុងអាវាសណាមួយថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ពាក្យពណ៌នាអំពីភិក្ខុអ្នកពោលលាសិក្ខានៃបុគ្គលឈ្មោះនេះ សង្ឃធ្វើមិនទាន់ស្រេចទេ (ព្រោះ) រឿងនោះ សង្ឃកាត់សេចក្តីមិនទាន់ដាច់ស្រេចនៅឡើយ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីវិនិច្ឆ័យរឿងនោះចុះ ។ បើសង្ឃបានវិនិច្ឆ័យរឿងនោះដាច់ស្រេច នេះជាការល្អ បើបរជាវិនិច្ឆ័យមិនបានវិញ ភិក្ខុត្រូវសូត្រក្នុងកណ្តាលជុំនុំសង្ឃ ចំពោះបុគ្គលដែលនៅក្នុងទីចំពោះមុខនោះ ក្នុងថ្ងៃចាតុទ្ទសីឬបណ្ណរសីឧបោសថនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ពាក្យពណ៌នាអំពីភិក្ខុអ្នកពោលលាសិក្ខា នៃបុគ្គលឈ្មោះនេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



វិប្បកតា តំ វត្ថុំ អវិនិច្ឆិតំ តស្ស បាតិមោក្ខំ ឋបេមិ ន តស្មិំ សម្មុខីភូតេ បាតិមោក្ខំ ឧទ្ទិសិតព្វន្តិ ។ ធម្មិកំ បាតិមោក្ខដ្ឋបនំ ។

(១៨៧) កតមំ ធម្មិកំ សាមគ្គិំ ន ឧបេតិ ។ ឥធ បន ភិក្ខវេ យេហិ អាការេហិ យេហិ លិង្គេហិ យេហិ និមិត្តេហិ ធម្មិកាយ សាមគ្គិយា អនុបគមនំ(១) ហោតិ តេហិ អាការេហិ តេហិ លិង្គេហិ តេហិ និមិត្តេហិ ភិក្ខុ ភិក្ខុំ បស្សតិ ធម្មិកំ សាមគ្គិំ ន ឧបេន្តំ ន ហេវ ខោ ភិក្ខុ ភិក្ខុំ បស្សតិ ធម្មិកំ សាមគ្គិំ ន ឧបេន្តំ អបិច អញ្ញោ ភិក្ខុ ភិក្ខុស្ស អារោចេតិ ឥត្ថន្នាមោ អាវុសោ ភិក្ខុ ធម្មិកំ សាមគ្គិំ ន ឧបេតីតិ ន ហេវ ខោ ភិក្ខុ ភិក្ខុំ បស្សតិ ធម្មិកំ សាមគ្គិំ ន ឧបេន្តំ នបិ អញ្ញោ ភិក្ខុ ភិក្ខុស្ស អារោចេតិ ឥត្ថន្នាមោ អាវុសោ ភិក្ខុ ធម្មិកំ សាមគ្គិំ ន ឧបេតីតិ អបិច សោ វ ភិក្ខុ ភិក្ខុស្ស អារោចេតិ អហំ អាវុសោ ធម្មិកំ សាមគ្គិំ ន ឧបេមីតិ

---

១ ម. នុបគមនំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ពុទ្ធបរិស័ទ។


សង្ឃធ្វើមិនទាន់សម្រេចទេ (ព្រោះ) រឿងនោះសង្ឃកាត់សេចក្ដីមិនទាន់ដាច់ស្រេចនៅឡើយ ខ្ញុំនឹងបញ្ជូបបាតិមោក្ខដល់បុគ្គលនោះ កាលបើបុគ្គលនោះនៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខទេ ។ ការបញ្ឈប់បាតិមោក្ខ (នេះ) ឈ្មោះថាប្រកបដោយធម៌ ។

(១៩៧) ភិក្ខុមិនបានចូលមកព្រមព្រៀងគ្នាប្រកបដោយធម៌ (នោះ) តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានកិរិយាមិនដល់សេចក្ដីព្រមព្រៀងប្រកបដោយធម៌ ដោយអាការណា ដោយភេទណា ដោយនិមិត្តណា ភិក្ខុឃើញភិក្ខុដែលមិនដល់សេចក្ដីព្រមព្រៀង ប្រកបដោយធម៌ ដោយអាការនោះ ដោយភេទនោះ ដោយនិមិត្តនោះ បើភិក្ខុមិនឃើញភិក្ខុដែលមិនដល់សេចក្ដីព្រមព្រៀង ប្រកបដោយធម៌(នោះ)ទេ តែមានភិក្ខុឯទៀតប្រាប់ដល់ភិក្ខុនេះថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ មិនដល់សេចក្ដីព្រមព្រៀងប្រកបដោយធម៌ទេ ប្រសិនបើភិក្ខុមិនបានឃើញភិក្ខុដែលមិនដល់សេចក្ដីព្រមព្រៀងប្រកបដោយធម៌ ទាំងភិក្ខុឯទៀតក៏មិនបានប្រាប់ដល់ភិក្ខុនេះថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះមិនដល់សេចក្ដីព្រមព្រៀង ប្រកបដោយធម៌ដូច្នេះទេ ក៏គង់ភិក្ខុនោះឯងប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្ញុំមិនដល់សេចក្ដីព្រមព្រៀង ប្រកបដោយធម៌ទេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាកង្ខមានោ ភិក្ខវេ ភិក្ខុ តេន ទិដ្ឋេន តេន សុតេន តាយ បរិសង្កាយ តទហុបោសថេ ចាតុទ្ទសេ វា បណ្ណរសេ វា តស្មិំ បុគ្គលេ សម្មុខីភូតេ សង្ឃមជ្ឈេ ឧទាហរេយ្យ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមោ បុគ្គលោ ធម្មិកំ សាមគ្គឹ ន ឧបេតិ តស្ស បាតិមោក្ខំ ឋបេមិ ន តស្មិំ សម្មុខីភូតេ បាតិមោក្ខំ ឧទ្ទិសិតព្វន្តិ ។ ធម្មិកំ បាតិមោក្ខដ្ឋបនំ ។

(១៥៨) កតមំ ធម្មិកំ សាមគ្គឹ បច្ចាទិយតិ ។ ឥធ បន ភិក្ខវេ យេហិ អាការេហិ យេហិ លិង្គេហិ យេហិ និមិត្តេហិ ធម្មិកាយ សាមគ្គិយា បច្ចាទានំ ហោតិ តេហិ អាការេហិ តេហិ លិង្គេហិ តេហិ និមិត្តេហិ ភិក្ខុ ភិក្ខុំ បស្សតិ ធម្មិកំ សាមគ្គឹ បច្ចាទិយន្តំ ន ហេវ ខោ ភិក្ខុ ភិក្ខុំ បស្សតិ ធម្មិកំ សាមគ្គឹ បច្ចាទិយន្តំ អបិច អញ្ញោ ភិក្ខុ ភិក្ខុស្ស អារោចេតិ ឥត្ថន្នាមោ អាវុសោ ភិក្ខុ ធម្មិកំ សាមគ្គឹ បច្ចាទិយតីតិ ន ហេវ ខោ ភិក្ខុ ភិក្ខុំ បស្សតិ ធម្មិកំ សាមគ្គឹ បច្ចាទិយន្តំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាកុសលទានៗ


## ជាតិមោក្ខដ្ឋបនក្ខន្ធកៈ ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុប្រាថ្នា ក៏គប្បីស្រែកក្នុងកណ្តាលជំនុំសង្ឃ ចំពោះបុគ្គល ដែលនៅក្នុងទីចំពោះមុខនោះ ក្នុងថ្ងៃចាតុទ្ទសី ឬបណ្ណរសី ឧបោសថនោះ ដោយការឃើញនោះ ដោយការឮនោះ ដោយការរង្កៀសនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) បុគ្គលគឺភិក្ខុឈ្មោះនេះ មិនដល់សេចក្តីព្រមព្រៀងប្រកបដោយធម៌ទេ ឥឡូវខ្ញុំនឹងបញ្ឈប់បាតិមោក្ខដល់បុគ្គលនោះ កាលបើបុគ្គលនោះនៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខទេ ។ ការបញ្ឈប់បាតិមោក្ខ (នេះ) ឈ្មោះថា ប្រកបដោយធម៌ ។

(១៤៨) ភិក្ខុត្រឡប់សើរើសេចក្តីព្រមព្រៀង ប្រកបដោយធម៌(នោះ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ រមែងមានការត្រឡប់សើរើសេចក្តីព្រមព្រៀង ប្រកបដោយធម៌ ដោយអាការណា ដោយភេទណា ដោយនិមិត្តណា ភិក្ខុឃើញភិក្ខុ ដែលត្រឡប់សើរើសេចក្តីព្រមព្រៀងប្រកបដោយធម៌ ដោយអាការនោះ ដោយភេទនោះ ដោយនិមិត្តនោះ បើភិក្ខុមិនឃើញភិក្ខុ ដែលត្រឡប់សើរើសេចក្តីព្រមព្រៀងប្រកបដោយធម៌ទេ គង់មានភិក្ខុឯទៀតប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះត្រឡប់សើរើសេចក្តីព្រមព្រៀង ប្រកបដោយធម៌ហើយ ប្រសិនបើ ភិក្ខុក៏មិនឃើញភិក្ខុ ដែលត្រឡប់សើរើសេចក្តីព្រម

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ន បិ អញ្ញោ ភិក្ខុ ភិក្ខុស្ស អារោចេតិ ឥត្ថន្នាមោ អាវុសោ ភិក្ខុ ធម្មិកំ សាមគ្គឹ បច្ចាទិយតីតិ អបិច សោវ ភិក្ខុ(១) ភិក្ខុស្ស អារោចេតិ អហំ អាវុសោ ធម្មិកំ សាមគ្គឹ បច្ចាទិយាមីតិ អាកង្ខមានោ ភិក្ខវេ ភិក្ខុ តេន ទិដ្ឋេន តេន សុតេន តាយ បរិសង្កាយ តទហុបោសថេ ចាតុទ្ទសេ វា បណ្ណរសេ វា តស្មឹ បុគ្គលេ សម្មុខីភូតេ សង្ឃមជ្ឈេ ឧទាហរេយ្យ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមោ បុគ្គលោ ធម្មិកំ សាមគ្គឹ បច្ចាទិយតិ តស្ស បាតិមោក្ខំ ឋបេមិ ន តស្មឹ សម្មុខីភូតេ បាតិមោក្ខំ ឧទ្ទិសិតព្វន្តិ ។ ធម្មិកំ បាតិមោក្ខដ្ឋបនំ ។

(១៨៩) ភិក្ខុស្ស បាតិមោក្ខេ ឋបិតេ បរិសា វុដ្ឋាតិ ទសន្នំ អន្តរាយានំ អញ្ញតរេន អន្តរាយេន រាជន្តរាយេន វា ។ បេ ។ ព្រហ្មចរិយន្តរាយេន វា អាកង្ខមានោ ភិក្ខវេ ភិក្ខុ តស្មឹ អាវាសេ អញ្ញតរស្មឹ

១ ឱ. ម. អយំ ភិក្ខុសង្ឃោ ន បញ្ញាយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ផ្សព្វផ្សាយជូនៗ


ព្រៀងប្រកបដោយធម៌ ទាំងភិក្ខុឯទៀតក៏មិនបានប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ ត្រឡប់សើរើសេចក្ដីព្រមព្រៀង ប្រកបដោយធម៌ហើយដូច្នេះទេ ក៏គង់ភិក្ខុនោះប្រាប់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្ញុំត្រឡប់សើរើសេចក្ដីព្រមព្រៀង ប្រកបដោយធម៌ហើយ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុប្រាថ្នា គប្បីសូត្រក្នុងកណ្ដាលជំនុំសង្ឃ ចំពោះបុគ្គលដែលនៅក្នុងទីចំពោះមុខនោះ ក្នុងថ្ងៃចាតុទ្ទសី ឬបណ្ណរសីឧបោសថនោះ ដោយការឃើញនោះ ដោយការឮនោះ ដោយការរង្កៀសនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ បុគ្គលៈឈ្មោះនេះ ត្រឡប់សើរើសេចក្ដីព្រមព្រៀង ប្រកបដោយធម៌ហើយ ខ្ញុំនឹងបញ្ឈប់បាតិមោក្ខដល់បុគ្គលនោះ កាលបើបុគ្គលនោះនៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខទេ ។ ការបញ្ឈប់បាតិមោក្ខ ( នេះ ) ឈ្មោះថាប្រកបដោយធម៌ ។

(១៥៩) កាលបើសង្ឃបានបញ្ឈប់បាតិមោក្ខដល់ភិក្ខុនោះហើយ បរិសទ្យក៏ក្រោកចេញ ព្រោះបណ្ដាអន្តរាយទាំង ១០ យ៉ាង អន្តរាយណាមួយ ទោះបីអន្តរាយអំពីព្រះរាជាក្ដី ។ បេ ។ អន្តរាយព្រហ្មចរិយធម៌ក្ដី ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបើប្រាថ្នា ក៏គប្បីសូត្រក្នុងកណ្ដាលជំនុំសង្ឃ ចំពោះបុគ្គលដែលនៅក្នុងទីចំពោះមុខនោះ ក្នុងអាវាសនោះ ឬក្នុងអាវាស

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

## បាតិមោក្ខដ្ឋបនក្ខន្ធកេ ធម្មិកំ បាតិមោក្ខដ្ឋបនំ

វា អាវាសេ តស្មឹ បុគ្គលេ សម្មុខីភូតេ សង្ឃមជ្ឈេ ឧទាហរេយ្យ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមស្ស បុគ្គលស្ស ធម្មិកាយ សាមគ្គិយា បច្ចាទានកថា វិប្បកតា តំ វត្ថុំ អវិនិច្ឆិតំ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ តំ វត្ថុំ វិនិច្ឆិនេយ្យាតិ ។ ឯវញ្ចេតំ លភេថ ឥច្ចេតំ កុសលំ នោ ចេ លភេថ ឧបោសថេ ចាតុទ្ទសេ វា បណ្ណរសេ វា តស្មឹ បុគ្គលេ សម្មុខីភូតេ សង្ឃមជ្ឈេ ឧទាហរិតព្វំ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមស្ស បុគ្គលស្ស ធម្មិកាយ សាមគ្គិយា បច្ចាទានកថា វិប្បកតា តំ វត្ថុំ អវិនិច្ឆិតំ តស្ស បាតិមោក្ខំ ឋបេមិ ន តស្មឹ សម្មុខីភូតេ បាតិមោក្ខំ ឧទ្ទិសិតព្វន្តិ ។ ធម្មិកំ បាតិមោក្ខដ្ឋបនំ ។

[១៦០] កថំ សីលវិបត្តិយា ទិដ្ឋសុតបរិសង្កិតោ ហោតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ យេហិ អាការេហិ យេហិ លិង្គេហិ យេហិ និមិត្តេហិ សីលវិបត្តិយា ទិដ្ឋសុតបរិសង្កិតោ ហោតិ តេហិ អាការេហិ តេហិ លិង្គេហិ តេហិ និមិត្តេហិ ភិក្ខុ ភិក្ខុំ បស្សតិ

## បាតិមោក្ខដ្ឋបនក្ខន្ធកៈ ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌

ណាមួយថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ពាក្យពណ៌នាអំពីការត្រឡប់សើរើសេចក្តីព្រមព្រៀង ប្រកបដោយធម៌នៃបុគ្គលឈ្មោះនេះ សង្ឃធ្វើមិនទាន់ស្រេចនៅឡើយ (ព្រោះ) រឿងនោះសង្ឃវិនិច្ឆ័យមិនទាន់ដាច់ស្រេច បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីវិនិច្ឆ័យរឿងនោះចុះ ។ បើសង្ឃបានវិនិច្ឆ័យរឿងនោះដាច់ស្រេច នេះក៏ជាការប្រពៃ បើបែរជាវិនិច្ឆ័យមិនបានវិញ ក្នុងថ្ងៃចាតុទ្ទសីឬបណ្ណរសីឧបោសថនោះ ភិក្ខុត្រូវសូត្រក្នុងកណ្តាលជុំនុំសង្ឃ ចំពោះបុគ្គលដែលនៅ ក្នុងទីចំពោះមុខនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ពាក្យពណ៌នាអំពីការត្រឡប់សើរើសេចក្តីព្រមព្រៀង ប្រកបដោយធម៌នៃបុគ្គលឈ្មោះនេះ សង្ឃធ្វើមិនទាន់ស្រេចនៅឡើយទេ (ព្រោះ) រឿងនោះសង្ឃវិនិច្ឆ័យមិនទាន់ដាច់ស្រេច ខ្ញុំនឹងបញ្ឈប់បាតិមោក្ខ ដល់បុគ្គលនោះ កាលបើបុគ្គលនោះនៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខទេ ។ ការបញ្ឈប់បាតិមោក្ខ (នេះ) ឈ្មោះថាប្រកបដោយធម៌ ។

(១៦០) ភិក្ខុដែលគេបានឃើញ ឮ រង្កៀសដោយសីលវិបត្តិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដែលគេបានឃើញ ឮ រង្កៀសដោយសីលវិបត្តិ ដោយអាការណា ដោយភេទណា ដោយនិមិត្តណា ភិក្ខុក៏ឃើញភិក្ខុដែលគេបានឃើញ ឮ រង្កៀស ដោយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


សីលវិបត្តិយា ទិដ្ឋសុតបរិសង្កិតំ ច ហោតិ តំ ភិក្ខុ
ភិក្ខុំ បស្សតិ សីលវិបត្តិយា ទិដ្ឋសុតបរិសង្កិតំ អបិច
អញ្ញោ ភិក្ខុ ភិក្ខុស្ស អារោចេតិ ឥត្ថន្នាមោ អាវុសោ
ភិក្ខុ សីលវិបត្តិយា ទិដ្ឋសុតបរិសង្កិតោតិ ច ហោតិ តំ
ភិក្ខុ ភិក្ខុំ បស្សតិ សីលវិបត្តិយា ទិដ្ឋសុតបរិសង្កិតំ ច
បន អញ្ញោ ភិក្ខុ ភិក្ខុស្ស អារោចេតិ ឥត្ថន្នាមោ អាវុសោ
ភិក្ខុ សីលវិបត្តិយា ទិដ្ឋសុតបរិសង្កិតោតិ អបិច សោ
វ ភិក្ខុ ភិក្ខុស្ស អារោចេតិ អហំ អាវុសោ សីល-
វិបត្តិយា ទិដ្ឋសុតបរិសង្កិតោតិ[១] អាកង្ខមានោ ភិក្ខុ-
វេ ភិក្ខុ តេន ទិដ្ឋេន តេន សុតេន តាយ បរិសង្កាយ
តទហុបោសថេ ចាតុទ្ទសេ វា បណ្ណរសេ វា តស្មឹ
បុគ្គលេ សម្មុខីភូតេ សង្ឃមជ្ឈេ ឧទាហរេយ្យ សុ-
ណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមោ បុគ្គលោ សីល-
វិបត្តិយា ទិដ្ឋសុតបរិសង្កិតោ តស្ស បាតិមោក្ខំ ឋបេ-
មិ ន តស្មឹ សម្មុខីភូតេ បាតិមោក្ខំ ឧទ្ទិសិតព្វន្តិ ។
ធម្មិកំ បាតិមោក្ខដ្ឋបនំ ។

---

១ ឱ. ម. ទិដ្ឋសុតបរិសង្កិតោម្ហីតិ ទិស្សតិ ។

## វិនយបិដក ចុល្លវគ្គ

សីលវិបត្តិ ដោយអាការនោះ ដោយភេទនោះ ដោយនិមិត្តនោះ បើភិក្ខុមិនឃើញភិក្ខុដែលគេឃើញ ឮ រង្កៀសដោយសីលវិបត្តិនោះទេ តែមានភិក្ខុឯទៀតប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ មានគេឃើញ ឮ រង្កៀសដោយសីលវិបត្តិ (ប្រសិនបើ) ភិក្ខុមិនឃើញភិក្ខុដែលមានគេឃើញ ឮ រង្កៀសដោយសីលវិបត្តិ ទាំងភិក្ខុឯទៀតក៏មិនប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ មានគេឃើញ ឮ រង្កៀសដោយសីលវិបត្តិដូច្នេះទេ ក៏គង់ភិក្ខុនោះឯងប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្លួនខ្ញុំមានគេឃើញ ឮ ឬរង្កៀសដោយសីលវិបត្តិដូច្នេះ (មិនលែង) ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុមានប្រាថ្នា ក៏គប្បីសូត្រក្នុងកណ្តាលជំនុំសង្ឃ ចំពោះបុគ្គលដែលនៅក្នុងទីចំពោះមុខនោះ ដោយការឃើញនោះ ដោយការឮនោះ ដោយការរង្កៀសនោះ ក្នុងថ្ងៃចាតុទ្ទសី ឬ បណ្ណរសីឧបោសថនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) បុគ្គលឈ្មោះនេះ មានគេឃើញ ឮ ឬរង្កៀសដោយសីលវិបត្តិ ខ្ញុំនឹងបញ្ឈប់បាតិមោក្ខ ចំពោះបុគ្គលនោះ កាលបើបុគ្គលនោះនៅក្នុងទីចំពោះមុខសង្ឃ សង្ឃមិនត្រូវសំដែងបាតិមោក្ខឡើយ ។ ការបញ្ឈប់បាតិមោក្ខ (នេះ) ឈ្មោះថាប្រកបដោយធម៌ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





(១៦១) កថំ អាចារវិបត្តិយា ទិដ្ឋសុតបរិសង្កិតោ ហោតិ ។ ឥធ បន(១) ភិក្ខវេ ភិក្ខុ យេហិ អាការេហិ យេហិ លិង្គេហិ យេហិ និមិត្តេហិ អាចារវិបត្តិយា ទិដ្ឋសុតបរិសង្កិតោ ហោតិ តេហិ អាការេហិ តេហិ លិង្គេហិ តេហិ និមិត្តេហិ ភិក្ខុ ភិក្ខុំ បស្សតិ អាចារវិបត្តិយា ទិដ្ឋសុតបរិសង្កិតំ ន ហេវ ខោ ភិក្ខុ ភិក្ខុំ បស្សតិ អាចារវិបត្តិយា ទិដ្ឋសុតបរិសង្កិតំ អបិច អញ្ញោ ភិក្ខុ ភិក្ខុស្ស អារោចេតិ ឥត្ថន្នាមោ អាវុសោ ភិក្ខុ អាចារវិបត្តិយា ទិដ្ឋសុតបរិសង្កិតោតិ ន ហេវ ខោ ភិក្ខុ ភិក្ខុំ បស្សតិ អាចារវិបត្តិយា ទិដ្ឋសុតបរិសង្កិតំ នបិ អញ្ញោ ភិក្ខុ ភិក្ខុស្ស អារោចេតិ ឥត្ថន្នាមោ អាវុសោ ភិក្ខុ អាចារវិបត្តិយា ទិដ្ឋសុតបរិសង្កិតោតិ អបិច សោវ ភិក្ខុ ភិក្ខុស្ស អារោចេតិ អហំ អាវុសោ អាចារវិបត្តិយា ទិដ្ឋសុតបរិសង្កិតោតិ អាកង្ខមានោ ភិក្ខវេ ភិក្ខុ តេន ទិដ្ឋេន តេន សុតេន តាយ បរិសង្កាយ តទហុបោសថេ ចាតុទ្ទសេ វា បណ្ណរសេ វា តស្មឹ បុគ្គលេ សម្មុខីភូតេ សង្ឃមជ្ឈេ ឧទាហរេយ្យ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមោ

១ ឱ. ម. អយំ បនសទ្ទោ នត្ថិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាទាន។

## បាតិមោក្ខដ្ឋបនក្ខន្ធកៈ ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌

( ១៦១ ) ភិក្ខុដែលមានគេឃើញ ឮ ឬរង្កៀសហើយ ដោយអាចារវិបត្តិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងមានគេឃើញ ឮ ឬរង្កៀស ដោយអាចារវិបត្តិ ដោយអាការណា ដោយភេទណា ដោយនិមិត្តណា ភិក្ខុក៏ឃើញភិក្ខុ ដែលមានគេឃើញ ឮ ឬរង្កៀសហើយ ដោយអាចារវិបត្តិ ដោយអាការនោះ ដោយភេទនោះ ដោយនិមិត្តនោះដែរ បើភិក្ខុមិនបានឃើញភិក្ខុដែលមានគេឃើញ ឮ ឬរង្កៀស ដោយអាចារវិបត្តិនោះទេ គង់មានភិក្ខុឯទៀតប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ មានគេឃើញ ឮ ឬរង្កៀស ដោយអាចារវិបត្តិដូច្នេះដែរ (ប្រសិនបើ) ភិក្ខុក៏មិនបានឃើញភិក្ខុដែលមានគេឃើញ ឮ ឬរង្កៀស ដោយអាចារវិបត្តិទេ ទាំងភិក្ខុឯទៀតក៏មិនបានប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះ មានគេឃើញ ឮ ឬរង្កៀសដោយអាចារវិបត្តិដូច្នេះទេ ក៏គង់ភិក្ខុនោះឯងប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្លួនខ្ញុំមានគេឃើញ ឮ ឬរង្កៀសដោយអាចារវិបត្តិហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបើប្រាថ្នា ក៏គប្បីសូត្រក្នុងកណ្តាលជំនុំសង្ឃ ចំពោះបុគ្គលដែលនៅក្នុងទីចំពោះមុខនោះ ដោយការឃើញនោះ ដោយការឮនោះ ដោយការរង្កៀសនោះ ក្នុងថ្ងៃចាតុទ្ទសីឬបណ្ណរសីឧបោសថនោះថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) បុគ្គលឈ្មោះនេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បុគ្គលោ អាចារវិបត្តិយា ទិដ្ឋសុតបរិសង្កិតោ តស្ស
បាតិមោក្ខំ ឋបេមិ ន តស្មិំ សម្មុខីភូតេ បាតិមោក្ខំ
ឧទ្ទិសិតព្វន្តិ ។ ធម្មិកំ បាតិមោក្ខដ្ឋបនំ ។

[១៦៤] កថំ ទិដ្ឋិវិបត្តិយា ទិដ្ឋសុតបរិសង្កិតោ
ហោតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ យេហិ អាការេហិ យេហិ
លិង្គេហិ យេហិ និមិត្តេហិ ទិដ្ឋិវិបត្តិយា ទិដ្ឋសុតបរិសង្កិ-
តោ ហោតិ តេហិ អាការេហិ តេហិ លិង្គេហិ តេហិ
និមិត្តេហិ ភិក្ខូ ភិក្ខុំ បស្សន្តិ ទិដ្ឋិវិបត្តិយា ទិដ្ឋសុត-
បរិសង្កិតំ ន ហេវ ខោ ភិក្ខូ ភិក្ខុំ បស្សន្តិ ទិដ្ឋិវិបត្តិយា
ទិដ្ឋសុតបរិសង្កិតំ អបិច អញ្ញោ ភិក្ខុ ភិក្ខុស្ស អារោ-
ចេតិ ឥត្ថន្នាមោ អាវុសោ ភិក្ខុ ទិដ្ឋិវិបត្តិយា ទិដ្ឋសុតបរិ-
សង្កិតោតិ ន ហេវ ខោ ភិក្ខូ ភិក្ខុំ បស្សន្តិ ទិដ្ឋិវិបត្តិយា
ទិដ្ឋសុតបរិសង្កិតំ ន បិ អញ្ញោ ភិក្ខុ ភិក្ខុស្ស អារោចេតិ
ឥត្ថន្នាមោ អាវុសោ ភិក្ខុ ទិដ្ឋិវិបត្តិយា ទិដ្ឋសុតបរិសង្កិ-
តោតិ អបិច សោ វ ភិក្ខុ ភិក្ខុស្ស អារោចេតិ អហំ

មានគេឃើញ ឮ ឬរង្កៀស ដោយអាចារវិបត្តិហើយ ខ្ញុំនឹងបញ្ឈប់បាតិមោក្ខចំពោះបុគ្គលនោះ កាលបើបុគ្គលនោះទៅ ក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខឡើយ ។ ការបញ្ឈប់បាតិមោក្ខ(នេះ)ឈ្មោះថា ប្រកបដោយធម៌ ។

(១៦២) ភិក្ខុដែលមានគេឃើញ ឮ ឬរង្កៀស ដោយទិដ្ឋិវិបត្តិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងមានគេឃើញ ឮ ឬរង្កៀស ដោយទិដ្ឋិវិបត្តិ ដោយអាការណា ដោយភេទណា ដោយនិមិត្តណា ភិក្ខុផងគ្នាក៏ឃើញភិក្ខុដែលមានគេឃើញ ឮ ឬរង្កៀស ដោយទិដ្ឋិវិបត្តិ ដោយអាការនោះ ដោយភេទនោះ ដោយនិមិត្តនោះដែរ បើភិក្ខុផងគ្នាមិនឃើញភិក្ខុដែលមានគេឃើញ ឮ ឬរង្កៀស ដោយទិដ្ឋិវិបត្តិទេ គង់មានភិក្ខុឯទៀតប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះមានគេឃើញ ឮ ឬរង្កៀស ដោយទិដ្ឋិវិបត្តិដូច្នេះដែរ (ប្រសិនបើ) ភិក្ខុក៏មិនឃើញភិក្ខុដែលមានគេឃើញ ឮ ឬរង្កៀស ដោយទិដ្ឋិវិបត្តិទេ ទាំងភិក្ខុឯទៀតក៏មិនប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ភិក្ខុឈ្មោះនេះមានគេឃើញ ឮ ឬរង្កៀសហើយ ដោយទិដ្ឋិវិបត្តិដូច្នេះទេ ក៏គង់ភិក្ខុនោះឯងប្រាប់ដល់ភិក្ខុផងគ្នាថា ម្នាលអាវុសោ ខ្ញុំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។

### បាតិមោក្ខដ្ឋបនក្ខន្ធកេ ឧបាលិបុច្ឆា អត្តាទានំ

អាវុសោ ទិដ្ឋិវិបត្តិយា ទិដ្ឋសុតបរិសង្កិតោតិ អាកង្ខមានោ ភិក្ខវេ ភិក្ខុ តេន ទិដ្ឋេន តេន សុតេន តាយ បរិសង្កាយ តទហុបោសថេ ចាតុទ្ទសេ វា បណ្ណរសេ វា តស្មឹ បុគ្គលេ សម្មុខីភូតេ សង្ឃមជ្ឈេ ឧទាហរេយ្យ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមោ បុគ្គលោ ទិដ្ឋិវិបត្តិយា ទិដ្ឋសុតបរិសង្កិតោ តស្ស បាតិមោក្ខំ ឋបេមិ ន តស្មឹ សម្មុខីភូតេ បាតិមោក្ខំ ឧទ្ទិសិតព្វន្តិ ។ ធម្មិកំ បាតិមោក្ខដ្ឋបនំ ។ ឥមានិ ទស ធម្មិកានិ បាតិមោក្ខដ្ឋបនានីតិ ។

### បឋមោ ភាណវារោ ។

(១៦៣) អថខោ អាយស្មា ឧបាលិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ឧបាលិ ភគវន្តំ ឯតទវោច អត្តាទានំ អាទាតុកាមេន ភន្តេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


បាតិមោក្ខដ្ឋបនក្ខន្ធកៈ ព្រះឧបាលិទូលសួរ ការកាន់យក នូវអត្តាទាន

មានគេឃើញ ឮ ឬរង្កៀប ដោយទិដ្ឋិវិបត្តិហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលបើប្រាថ្នា ក៏គប្បីសូត្រក្នុងទីកណ្តាលជំនុំសង្ឃ ចំពោះបុគ្គលដែលនៅក្នុងទីចំពោះមុខនោះ ដោយការឃើញនោះ ដោយការឮនោះ ដោយការរង្កៀសនោះ ក្នុងថ្ងៃចាតុទ្ទសីឬបណ្ណរសីឧបោសថថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ (ដ្បិត) បុគ្គលឈ្មោះនេះ មានគេឃើញ ឮ ឬរង្កៀស ដោយទិដ្ឋិវិបត្តិហើយ ខ្ញុំនឹងបញ្ឈប់បាតិមោក្ខចំពោះបុគ្គលនោះ កាលបើបុគ្គលនោះនៅក្នុងទីចំពោះមុខ សង្ឃមិនត្រូវសំដែងបាតិមោក្ខទេ ។ (នេះ) ឈ្មោះថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ ១ ទាំង ១០ នេះឈ្មោះថា ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ ។

ភាណវារៈ ជាបឋម ។

[១៦៣] គ្រានោះឯង ព្រះឧបាលិដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះមានព្រះភាគ រួចហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះឧបាលិដ៏មានអាយុ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសេចក្តីនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុដែលមានប្រាថ្នានឹងកាន់យកនូវអត្តាទាន[១]

---

១ អដ្ឋកថា ពន្យល់ថា ភិក្ខុមានប្រាថ្នានឹងជម្រះនូវសាសនា ហើយកាន់យកអធិករណ៍ណាដោយខ្លួនឯង អធិករណ៍នោះហៅថា អត្តាទាន គឺជាឈ្មោះនៃអធិករណ៍ម្យ៉ាង ដែលមានភិក្ខុហ៊ប់រងដោយខ្លួនឯង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុនា កតមង្គសមន្នាគតំ អត្តាទានំ អាទាតព្វន្តិ ។ អត្តាទានំ អាទាតុកាមេន ឧបាលិ ភិក្ខុនា បញ្ចង្គសមន្នាគតំ អត្តាទានំ អាទាតព្វំ អត្តាទានំ អាទាតុកាមេន ឧបាលិ ភិក្ខុនា ឯវំ បច្ចវេក្ខិតព្វំ យំ ខោ អហំ ឥមំ អត្តាទានំ អាទាតុកាមោ កាលោ នុ ខោ ឥមំ អត្តាទានំ អាទាតុំ ឧទាហុ នោតិ ។ សចេ ឧបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អកាលោ ឥមំ អត្តាទានំ អាទាតុំ នោ កាលោតិ ន តំ ឧបាលិ អត្តាទានំ អាទាតព្វំ ។ សចេ បនុបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ កាលោ ឥមំ អត្តាទានំ អាទាតុំ នោ អកាលោតិ តេនុបាលិ ភិក្ខុនា ឧត្តរឹ បច្ចវេក្ខិតព្វំ យំ ខោ អហំ ឥមំ អត្តាទានំ អាទាតុកាមោ ភូតំ នុ ខោ ឥទំ អត្តាទានំ ឧទាហុ នោតិ ។ សចេ ឧបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អភូតំ ឥទំ អត្តាទានំ នោ ភូតន្តិ ន តំ ឧបាលិ អត្តាទានំ អាទាតព្វំ ។ សចេ បនុបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ភូតំ ឥទំ អត្តាទានំ នោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


(ការទទួលរាប់រងអធិករណ៍ដោយខ្លួនឯង) តើត្រូវកាន់យកនូវអត្តាទានប្រកបដោយអង្គប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ (បើ) ភិក្ខុមានសេចក្តីប៉ុនប៉ងនឹងកាន់យកនូវអត្តាទាន ត្រូវកាន់យកនូវអត្តាទានដែលប្រកបដោយអង្គ ៥ ម្នាលឧបាលិ ឯភិក្ខុដែលមានសេចក្តីប៉ុនប៉ងនឹងកាន់យកនូវអត្តាទាន (នោះ) ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញមានបំណងនឹងកាន់យកនូវអត្តាទាននេះ ចុះកាលនេះ ជាកាលគួរនឹងកាន់យកនូវអត្តាទាននេះ ឬមិនគួរទេ ។ ម្នាលឧបាលិ ប្រសិនបើភិក្ខុពិចារណាទៅបានដឹងយ៉ាងនេះថា កាលនេះជាកាលមិនគួរ ជាកាលមិនទាន់នឹងកាន់យកនូវអត្តាទាននេះទេ ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ ។ ម្នាលឧបាលិ ប្រសិនជាភិក្ខុពិចារណាទៅបានដឹងយ៉ាងនេះថា កាលនេះជាកាលគួរ មិនមែនជាកាលមិនគួរនឹងកាន់យកនូវអត្តាទាននេះ ម្នាលឧបាលិ ភិក្ខុនោះត្រូវពិចារណាតទៅទៀតថា អាត្មាអញមានបំណងនឹងកាន់យកនូវអត្តាទាននេះ តើអត្តាទាននេះពិតឬទេ ។ ម្នាលឧបាលិ បើភិក្ខុពិចារណាទៅដឹងយ៉ាងនេះថា អត្តាទាននេះមិនពិត មិនប្រាកដទេ ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ ។ ម្នាលឧបាលិ ប្រសិនជាភិក្ខុពិចារណាទៅបានដឹងយ៉ាងនេះថា អត្តាទាននេះ

## បាតិមោក្ខដ្ឋបនក្ខន្ធកេ ឧបាលិបុច្ឆា ចោទនា

អភូតន្តិ តេនុបាលិ ភិក្ខុនា ឧត្តរិ បច្ចវេក្ខិតព្វំ យំ ខោ អហំ ឥមំ អត្តាទានំ អាទាតុកាមោ អត្ថសញ្ហិតំ នុ ខោ ឥទំ អត្តាទានំ ឧទាហុ នោតិ ។ សចេ ឧបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អនត្ថសញ្ហិតំ ឥទំ អត្តាទានំ នោ អត្ថសញ្ហិតន្តិ ន តំ ឧបាលិ អត្តាទានំ អាទាតព្វំ ។ សចេ បនុបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អត្ថសញ្ហិតំ ឥទំ អត្តាទានំ នោ អនត្ថសញ្ហិតន្តិ តេនុបាលិ ភិក្ខុនា ឧត្តរិ បច្ចវេក្ខិតព្វំ ឥមំ ខោ អហំ អត្តាទានំ អាទិយមានោ លភិស្សាមិ សន្ទិដ្ឋេ សម្ភត្តេ ភិក្ខូ ធម្មតោ វិនយតោ បក្ខេ ឧទាហុ នោតិ ។ សចេ ឧបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ឥមំ ខោ អហំ អត្តាទានំ អាទិយមានោ ន លភិស្សាមិ សន្ទិដ្ឋេ សម្ភត្តេ ភិក្ខូ ធម្មតោ វិនយតោ បក្ខេតិ ន តំ ឧបាលិ អត្តាទានំ អាទាតព្វំ ។ សចេ បនុបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ

ពិតប្រាកដហើយ មិនមែនមិនពិតទេ ម្នាលឧបាលិ ភិក្ខុនោះត្រូវពិចារណាតទៅទៀតថា អាត្មាអញ មានបំណងនឹងកាន់យកនូវអត្តាទាននេះ អត្តាទាននេះ តើប្រកបដោយប្រយោជន៍ ឬមិនប្រកបដោយប្រយោជន៍ទេ ។ ម្នាលឧបាលិ ប្រសិនបើភិក្ខុពិចារណាទៅ បានដឹងយ៉ាងនេះថា អត្តាទាននេះ មិនប្រកបដោយប្រយោជន៍ ជាអំពើឥតប្រយោជន៍ទេ ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ ។ ម្នាលឧបាលិ ប្រសិនជាភិក្ខុពិចារណាទៅបានដឹងយ៉ាងនេះថា អត្តាទាននេះប្រកបដោយប្រយោជន៍ មិនមែនជាអំពើឥតប្រយោជន៍ទេ ម្នាលឧបាលិ ភិក្ខុនោះត្រូវពិចារណាតទៅទៀតថា កាលបើអាត្មាអញកាន់យកនូវអត្តាទាននេះទៅ តើនឹងបានពួកភិក្ខុជាមិត្តសម្លាញ់គ្រាន់តែជួបគ្នា ឬជាមិត្តសម្លាញ់តែងនៅរួមជាមួយគ្នា ជាពួកខាងធម៌ខាងវិន័យ ឬមិនបានទេ ។ ម្នាលឧបាលិ ប្រសិនជាភិក្ខុពិចារណាទៅបានដឹងយ៉ាងនេះថា កាលបើអាត្មាអញកាន់យកនូវអត្តាទាននេះទៅហើយ នឹងមិនបានពួកភិក្ខុជាមិត្តសម្លាញ់គ្រាន់តែជួបគ្នា ឬជាមិត្តសម្លាញ់ តែងនៅរួមជាមួយគ្នា ជាពួកខាងធម៌ខាងវិន័យ(ទាំងនោះទេ)ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ ។ ម្នាលឧបាលិ ប្រសិនជាភិក្ខុពិចារណាទៅបានដឹងយ៉ាងនេះថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឥមំ ខោ អហំ អត្តាទានំ អាទិយមានោ លភិស្សាមិ សន្ទិដ្ឋេ សម្ភត្តេ ភិក្ខូ ធម្មតោ វិនយតោ បក្ខេតិ តេនុបាលិ ភិក្ខុនា ឧត្តរិំ បច្ចវេក្ខិតព្វំ ឥមំ ខោ មេ អត្តាទានំ អាទិយតោ ភវិស្សតិ សង្ឃស្ស តតោនិទានំ ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណំ ឧទាហុ នោតិ ។ សចេ ឧបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ឥមំ ខោ មេ អត្តាទានំ អាទិយតោ ភវិស្សតិ សង្ឃស្ស តតោនិទានំ ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណន្តិ ន តំ ឧបាលិ អត្តាទានំ អាទាតព្វំ ។ សចេ បនុបាលិ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ឥមំ ខោ មេ អត្តាទានំ អាទិយតោ ន ភវិស្សតិ សង្ឃស្ស តតោនិទានំ ភណ្ឌនំ កលហោ វិគ្គហោ វិវាទោ សង្ឃភេទោ សង្ឃរាជិ សង្ឃវវត្ថានំ សង្ឃនានាករណន្តិ

## វិនយបិដក ចុល្លវគ្គ

កាលបើអាត្មាអញ កាន់យកនូវអត្តាទាននេះទៅ នឹងបានពួកភិក្ខុ ជាមិត្តសម្លាញ់គ្រាន់តែជួបគ្នា ឬជាមិត្តសម្លាញ់តែងនៅរួមជាមួយគ្នា ដែលជាពួកខាងធម៌ខាងវិន័យ ម្នាលឧបាលិ ភិក្ខុនោះត្រូវពិចារណាតទៅទៀតថា កាលបើអាត្មាអញកាន់យកនូវអត្តាទាននេះទៅ ក្រែងមានការប្រកួតប្រកាន់ ការឈ្លោះ ការប្រកាន់ខុស ការទាស់ទែង ការបែកធ្លាយនៃសង្ឃ ការប្រេះឆានៃសង្ឃ ការកំណត់ផ្សេងនៃសង្ឃ ការធ្វើផ្សេង ៗ នៃសង្ឃ នឹងកើតមានដល់សង្ឃ ព្រោះហេតុនៃអត្តាទាននោះឬមិនមានទេ ។ ម្នាលឧបាលិ បើភិក្ខុពិចារណាទៅបានដឹងយ៉ាងនេះថា កាលបើអាត្មាអញកាន់យកនូវអត្តាទានទៅហើយ ការប្រកួតប្រកាន់ ការឈ្លោះ ការប្រកាន់ខុស ការទាស់ទែង ការបែកធ្លាយនៃសង្ឃ ការប្រេះឆានៃសង្ឃ ការកំណត់ផ្សេងនៃសង្ឃ ការធ្វើផ្សេងៗ នៃសង្ឃ នឹងកើតមានដល់សង្ឃ ព្រោះហេតុនៃអត្តាទាននោះ ( ជាប្រាកដ ) ម្នាលឧបាលិ ភិក្ខុមិនត្រូវកាន់យកនូវអត្តាទាននោះឡើយ ។ ម្នាលឧបាលិ បើភិក្ខុពិចារណាទៅបានដឹងយ៉ាងនេះថា កាលបើអាត្មាអញកាន់យកនូវអត្តាទាននេះទៅ ការប្រកួតប្រកាន់ ការឈ្លោះ ការប្រកាន់ខុស ការទាស់ទែង ការបែកធ្លាយនៃសង្ឃ ការប្រេះឆានៃសង្ឃ ការកំណត់ផ្សេងនៃសង្ឃ និងការធ្វើផ្សេង ៗ នៃសង្ឃ មិនកើតមានដល់សង្ឃ ព្រោះហេតុនៃអត្តាទាននោះឡើយ ម្នាលឧបាលិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បាតិមោក្ខដ្ឋបនក្ខន្ធកេ ឧបាលិបុច្ឆា ចោទនា

អាទាតព្វំ តំ ឧបាលិ អត្តាទានំ ឯវំ បញ្ចង្គសមន្នាគតំ ខោ ឧបាលិ អត្តាទានំ អាទិន្នំ បច្ឆាបិ អវិប្បដិសារករំ ភវិស្សតីតិ ។

(១៦៤) ចោទកេន ភន្តេ ភិក្ខុនា បរំ ចោទេតុកាមេន កតិ ធម្មេ អជ្ឈត្តំ បច្ចវេក្ខិត្វា បរោ ចោទេតព្វោតិ ។ ចោទកេនុបាលិ ភិក្ខុនា បរំ ចោទេតុកាមេន បញ្ច ធម្មេ អជ្ឈត្តំ បច្ចវេក្ខិត្វា បរោ ចោទេតព្វោ ចោទកេនុបាលិ ភិក្ខុនា បរំ ចោទេតុកាមេន ឯវំ បច្ចវេក្ខិតព្វំ បរិសុទ្ធកាយសមាចារោ នុ ខោម្ហិ បរិសុទ្ធេនម្ហិ កាយសមាចារេន សមន្នាគតោ អច្ឆិទ្ទេន អប្បដិមំសេន សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ ។ នោ ចេ ឧបាលិ ភិក្ខុ បរិសុទ្ធកាយសមាចារោ ហោតិ បរិសុទ្ធេន កាយសមាចារេន សមន្នាគតោ អច្ឆិទ្ទេន អប្បដិមំសេន តស្ស ភវន្តិ វត្តារោ ឥង្ឃ តាវ អាយស្មា កាយិកំ សិក្ខស្សូតិ ឥតិស្ស ភវន្តិ វត្តារោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ពុទ្ធបរិស័ទ។



ភិក្ខុត្រូវកាន់យកនូវអត្តាទាននោះចុះ ម្នាលឧបាលិ អត្តាទានប្រកបដោយអង្គ ៥ ប្រការ ដូចបានសំដែងមកនេះឯង កាលបើភិក្ខុកាន់យកហើយ នឹងមិនធ្វើឲ្យកើតសេចក្តីក្តៅក្រហាយចិត្តក្នុងកាលជាខាងក្រោយទៀយ ។

[១៦៤] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកចោទមានបំណងនឹងចោទភិក្ខុដទៃ តើត្រូវពិចារណាធម៌ចំពោះខ្លួនឯងមានប៉ុន្មានសិន ទើបគួរនឹងចោទភិក្ខុដទៃបាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ឯភិក្ខុអ្នកចោទមានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាធម៌ ៥ ប្រការចំពោះខ្លួនឯងសិន រួចសឹមចោទភិក្ខុដទៃ ម្នាលឧបាលិ ភិក្ខុអ្នកចោទមានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញមា កាយសមាចារ បរិសុទ្ធ ឬ ហ្ន៎ អាត្មាអញជាអ្នកប្រកបដោយកាយសមាចារបរិសុទ្ធ មិនធ្លុះធ្លាយ មិនមានទំនងគួរឲ្យគេចាប់ថ្នាក់បាន ធម៌នុ៎ះមានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនមានទេ ។ ម្នាលឧបាលិ បើភិក្ខុមានកាយសមាចារមិនបរិសុទ្ធទេ (តែហាក់ដូច) ជាអ្នកប្រកបដោយកាយសមាចារបរិសុទ្ធ មិនធ្លុះធ្លាយ មិនមានទំនងគួរឲ្យគេចាប់ថ្នាក់បាន ភិក្ខុនោះឯងគង់មានអ្នកផង ស្តីដាស់តឿនថា នែលោកដ៏មានអាយុ ចូរលោកសិក្សានូវសមាចារផ្លូវកាយជាមុនសិន ភិក្ខុនោះគង់មានអ្នកផង ស្តីដាស់តឿនដូចសំដែងមកនេះឯង ។

## វិនយបិដកេ ចុល្លវគ្គោ

[១៦៥] បុន ចបរំ ឧបាលិ ចោទកេន ភិក្ខុនា បរំ ចោទេតុកាមេន ឯវំ បច្ចវេក្ខិតព្វំ បរិសុទ្ធវចីសមាចារោ នុ ខោម្ហិ បរិសុទ្ធេនម្ហិ វចីសមាចារេន សមន្នាគតោ អច្ឆិទ្ទេន អប្បដិមំសេន សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ ។ នោ ចេ ឧបាលិ ភិក្ខុ បរិសុទ្ធវចីសមាចារោ ហោតិ បរិសុទ្ធេន វចីសមាចារេន សមន្នាគតោ អច្ឆិទ្ទេន អប្បដិមំសេន តស្ស ភវន្តិ វត្តារោ ឥង្ឃ តាវ អាយស្មា វាចសិកំ សិក្ខស្សូតិ ឥតិស្ស ភវន្តិ វត្តារោ ។

[១៦៦] បុន ចបរំ ឧបាលិ ចោទកេន ភិក្ខុនា បរំ ចោទេតុកាមេន ឯវំ បច្ចវេក្ខិតព្វំ មេត្តំ នុ ខោ មេ ចិត្តំ បច្ចុបដ្ឋិតំ សព្រហ្មចារីសុ អនាឃាតំ សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ ។ នោ ចេ ឧបាលិ ភិក្ខុនោ មេត្តំ ចិត្តំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អនាឃាតំ តស្ស ភវន្តិ វត្តារោ ឥង្ឃ តាវ អាយស្មា សព្រហ្មចារីសុ មេត្តំ ចិត្តំ ឧបដ្ឋាបេហីតិ ឥតិស្ស ភវន្តិ វត្តារោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ផ្សព្វផ្សាយ។




(១៦៥) ម្នាលឧបាលិ ពាក្យខាងមុខនៅមានទៀត ភិក្ខុអ្នកចោទ មានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញមានវចីសមាចារបរិសុទ្ធឬហ៎ អាត្មាអញប្រកបដោយវចីសមាចារបរិសុទ្ធ មិនធ្លុះធ្លាយ មិនមានទំនងគួរឲ្យគេចាប់ថ្នាក់បាន ធម៌នោះមានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនមានទេ ។ ម្នាលឧបាលិ បើភិក្ខុមានវចីសមាចារមិនបរិសុទ្ធទេ (គែហាក់ដូច) ជាអ្នកប្រកបដោយវចីសមាចារបរិសុទ្ធ មិនធ្លុះធ្លាយ មិនមានទំនង គួរឲ្យគេចាប់ថ្នាក់បាន ភិក្ខុនោះគង់មានអ្នកផង ស្តីថាស់តឿនថា នែលោកដ៏មានអាយុ ចូរលោកសិក្សានូវសមាចារផ្លូវវាចាជាមុនសិន ភិក្ខុនោះគង់មានអ្នកផងស្តីថាស់តឿន ដូចសំដែងមកនេះឯង ។

(១៦៦) ម្នាលឧបាលិ ពាក្យខាងមុខនៅមានទៀត ភិក្ខុអ្នកចោទ មានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា ចិត្តរបស់អាត្មាអញមានមេត្តាតាំងមាំ ទាំងមិនចងគ្រៀតចង្អល់ក្នុងសព្រហ្មចារីបុគ្គលទេឬហ៎ ធម៌នោះមានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនមានទេ ។ ម្នាលឧបាលិ បើភិក្ខុមិនមានមេត្តាចិត្តតាំងមាំ មានចិត្តចងគ្រៀតចង្អល់ ក្នុងសព្រហ្មចារី-បុគ្គល ភិក្ខុនោះគង់មានអ្នកផងស្តីថាស់តឿនថា នែលោកដ៏មានអាយុ ចូរលោកតាំងមេត្តាចិត្តឲ្យ (មាំ)ក្នុងសព្រហ្មចារីបុគ្គលចុះ ភិក្ខុនោះគង់មានអ្នកផងស្តីថាស់តឿន ដូចសំដែងមកនេះឯង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

## បាតិមោក្ខដ្ឋបនក្ខន្ធកេ ឧបាលិបុច្ឆា ចោទនា

(១៦៧) បុន ចបរំ ឧបាលិ ចោទកេន ភិក្ខុនា បរំ ចោទេតុកាមេន ឯវំ បច្ចវេក្ខិតព្វំ ពហុស្សុតោ នុ ខោម្ហិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបា មេ ធម្មា ពហុស្សុតា ហោន្តិ ធតា[១] វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ នោ ចេ ឧបាលិ ភិក្ខុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ន ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា តស្ស ភវន្តិ វត្តារោ ឥង្ឃ តាវ អាយស្មា អាគមំ បរិយាបុណស្សូតិ ឥតិស្ស ភវន្តិ វត្តារោ ។

---

១ ម. ធាតា ។

## បាតិមោក្ខដ្ឋបនក្ខន្ធកៈ ព្រះឧបាលិទូលសួរការចោទ

(១៦៧) ម្នាលឧបាលិ ពាក្យខាងមុខនៅមានទៀត ភិក្ខុអ្នកចោទ មានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា អាត្មាអញជាពហុស្សូត ទ្រទ្រង់ព្រះសូត្រ សន្សំព្រះសូត្រឬ (មួយទៀត) ធម៌ទាំងឡាយណា មានលំអបទដើម លំអបទកណ្តាល លំអបទចុង ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ធម៌ទាំងនោះ ជាធម៌ដែលអាត្មាអញបានស្តាប់ច្រើន បានទ្រទ្រង់ បានសន្សំដោយពាក្យ បានពិចារណា(មុតមាំ)ហើយគន់ចិត្ត បានយល់ត្រឹមត្រូវហើយដោយទិដ្ឋិ ធម៌នោះមានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនទាន់មានទេ ។ ម្នាលឧបាលិ ប្រសិនជាភិក្ខុមិនមែនជាពហុស្សូត មិនទ្រទ្រង់ព្រះសូត្រ មិនសន្សំព្រះសូត្រសោះទេ បើធម៌ទាំងឡាយណា មានលំអបទដើម លំអបទកណ្តាល លំអបទចុង ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ គឺភិក្ខុនោះមិនបានចេះដឹងច្រើន មិនបានទ្រទ្រង់ មិនបានសន្សំដោយពាក្យ មិនបានពិចារណា(មុតមាំ)គន់ចិត្ត មិនបានយល់ត្រឹមត្រូវដោយទិដ្ឋិទេ ភិក្ខុនោះឯង គង់មានអ្នកផងស្តីដាស់តឿនថា ម្នាលលោកដ៏មានអាយុ សូមនិមន្តលោករៀនព្រះបរិយត្តិធម៌សិនទៅ ភិក្ខុនោះគង់មានអ្នកផងស្តីដាស់តឿន ដូចសំដែងមកនេះឯង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[១៦៨] បុន ចបរំ ឧបាលិ ចោទកេន ភិក្ខុនា បរំ ចោទេតុកាមេន ឯវំ បច្ចវេក្ខិតព្វំ ឧភយានិ នុ[១] ខោ មេ បាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ[២] សុវិភត្តានិ សុប្បវត្តីនិ សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ សំវិជ្ជតិ នុ ខោ មេ ឯសោ ធម្មោ ឧទាហុ នោតិ ។ នោ ចេ ឧបាលិ ភិក្ខុនោ ឧភយានិ បាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តីនិ សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ ឥទំ បនាវុសោ កត្ថ វុត្តំ ភគវតាតិ ឥតិ បុដ្ឋោ ន សម្បាយេតិ[៣] តស្ស ភវន្តិ វត្តារោ ឥង្ឃ តាវ អាយស្មា វិនយំ បរិយាបុណស្សូតិ ឥតិស្ស ភវន្តិ វត្តារោ ។ ចោទកេនុបាលិ ភិក្ខុនា បរំ ចោទេតុកាមេន ឥមេ បញ្ច ធម្មេ អជ្ឈត្តំ បច្ចវេក្ខិត្វា បរោ ចោទេតព្វោ ។

---

១ ម. អយំ នុសទ្ទោ នត្ថិ ។ ២ ឱ. អយំ ហោន្តិសទ្ទោ ន បញ្ញាយតិ ។ ៣ ម. សម្បាទយតិ ។

(១៦៨) ម្នាលឧបាលិ ពាក្យខាងមុខនៅមានទៀត ភិក្ខុអ្នកចោទ មានបំណងនឹងចោទភិក្ខុដទៃ ត្រូវពិចារណាយ៉ាងនេះថា បាតិមោក្ខទាំងពីរ អញក៏ចេះចាំ ដោយសេចក្តីពិស្តារ ចែកចេញបានដោយប្រពៃ ចាំស្ទាត់រត់មាត់ កាត់សេចក្តីបានដោយល្អ តាមសូត្រ គឺខន្ធកៈនិងបរិវារៈ តាមអនុព្យញ្ជនៈដែរឬ ធម៌នុះមានគ្រប់គ្រាន់ដល់អាត្មាអញ ឬមិនមានទេ ។ ម្នាលឧបាលិ ប្រសិនបើបាតិមោក្ខទាំងពីរ ភិក្ខុមិនបានចេះចាំដោយសេចក្តីពិស្តារ មិនបានចែកចេញដោយប្រពៃ មិនបានចាំស្ទាត់រត់មាត់ មិនបានកាត់សេចក្តីដោយល្អ តាមសូត្រ តាមអនុព្យញ្ជនៈទេ ភិក្ខុនោះឯង បើមានគេសួរថា ម្នាលលោកដ៏មានអាយុ ចុះសិក្ខាបទនេះ ព្រះមានព្រះភាគទ្រង់ត្រាស់សំដែងក្នុងនគរណា ភិក្ខុនោះមុខជាឆ្លើយប្រាប់ទៅវិញមិនរួច ភិក្ខុនោះឯង គង់មានអ្នកផងស្តីដាស់តឿនថា ម្នាលលោកដ៏មានអាយុ សូមនិមន្តលោករៀនវិន័យសិនទៅ ភិក្ខុនោះឯង គង់មានអ្នកផងស្តីដាស់តឿន ដូចសំដែងមកនេះឯង ម្នាលឧបាលិ ភិក្ខុអ្នកចោទ មានប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវពិចារណាធម៌ ៥ ប្រការនេះ ក្នុងខ្លួនឯងសិន ហើយសឹមចោទភិក្ខុដទៃ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

## បាតិមោក្ខដ្ឋបនក្ខន្ធកេ ឧបាលិបុច្ឆា ចោទកវិប្បដិសារោ

(១៦៩) ចោទកេន ភន្តេ ភិក្ខុនា បរំ ចោទេតុកាមេន កតិ ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា បរោ ចោទេតព្វោតិ ។ ចោទកេនុបាលិ ភិក្ខុនា បរំ ចោទេតុកាមេន បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា បរោ ចោទេតព្វោ កាលេន វក្ខាមិ នោ អកាលេន ភូតេន វក្ខាមិ នោ អភូតេន សណ្ហេន វក្ខាមិ នោ ផរុសេន អត្ថសំហិតេន វក្ខាមិ នោ អនត្ថសំហិតេន មេត្តចិត្តោ វក្ខាមិ នោ ទោសន្តរោតិ ចោទកេនុបាលិ ភិក្ខុនា បរំ ចោទេតុកាមេន ឥមេ បញ្ច ធម្មេ អជ្ឈត្តំ ឧបដ្ឋាបេត្វា បរោ ចោទេតព្វោតិ ។

(១៧០) អធម្មចោទកស្ស ភន្តេ ភិក្ខុនោ កតីហាការេហិ វិប្បដិសារោ ឧបទហាតព្វោតិ ។ អធម្មចោទកស្ស ឧបាលិ ភិក្ខុនោ បញ្ចហាការេហិ វិប្បដិសារោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

## បាតិមោក្ខដ្ឋបនក្ខន្ធកៈ ព្រះឧបាលិទូលសួរហេតុវិប្បដិសារៈចំពោះភិក្ខុអ្នកចោទ

[១៦៩] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន បើភិក្ខុអ្នកចោទ មានប្រាថ្នានឹងចោទភិក្ខុដទៃ តើត្រូវតាំងធម៌ប៉ុន្មានប្រការក្នុងខ្លួនឯង ហើយទើបគួរចោទភិក្ខុដទៃបាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ ភិក្ខុអ្នកចោទ បើមានប្រាថ្នានឹងចោទភិក្ខុដទៃ លុះតែតាំងធម៌ ៥ ប្រការក្នុងខ្លួនឯង ទើបគួរចោទភិក្ខុដទៃបាន(ធម៌ ៥ ប្រការនោះគឺ) អាត្មាអញនឹងនិយាយត្រូវតាមកាលគួរ មិននិយាយខុសកាល ១ អាត្មាអញនឹងនិយាយពាក្យពិត មិននិយាយពាក្យមិនពិត ១ អាត្មាអញនឹងនិយាយពាក្យផ្អែមល្ហែម មិននិយាយពាក្យអាក្រក់ ១ អាត្មាអញនឹងនិយាយពាក្យប្រកបដោយប្រយោជន៍ មិននិយាយពាក្យឥតប្រយោជន៍១ អាត្មាអញនឹងតាំងមេត្តាចិត្តហើយសឹមនិយាយ មិននិយាយទាំងទោសចិត្ត ១ ម្នាលឧបាលិ ភិក្ខុអ្នកចោទ មានប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវតាំងធម៌ ៥ ប្រការទុកក្នុងខ្លួនឯងហើយ សឹមចោទភិក្ខុដទៃ ។

[១៧០] ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃត្រូវតាំងវិប្បដិសារៈ (សេចក្តីក្តៅក្រហាយស្តាយក្រោយ) ទុកចំពោះភិក្ខុអ្នកចោទដែលមិនប្រកបដោយធម៌ ដោយអាការប៉ុន្មានយ៉ាង ។ ព្រះអង្គទ្រង់ត្រាស់តបថា ម្នាលឧបាលិ សង្ឃត្រូវតាំងវិប្បដិសារៈទុកចំពោះភិក្ខុអ្នកចោទដែលមិនប្រកបដោយធម៌ ដោយអាការ ៥ យ៉ាងដូច្នេះថា

ឧបទហាតព្វោ អកាលេនាយស្មា ចោទេសិ នោ កាលេន អលន្តេ វិប្បដិសារាយ អភូតេនាយស្មា ចោទេសិ នោ ភូតេន អលន្តេ វិប្បដិសារាយ ផរុសេនាយស្មា ចោទេសិ នោ សណ្ហេន អលន្តេ វិប្បដិសារាយ អនត្ថសញ្ហិតេនាយស្មា ចោទេសិ នោ អត្ថសញ្ហិតេន អលន្តេ វិប្បដិសារាយ ទោសន្តរោ អាយស្មា ចោទេសិ នោ មេត្តចិត្តោ អលន្តេ វិប្បដិសារាយាតិ អធម្មចោទកស្ស ឧបាលិ ភិក្ខុនោ ឥមេហិ បញ្ចហាការេហិ វិប្បដិសារោ ឧបទហាតព្វោ ។ តំ កិស្ស ហេតុ ។ យថា ន អញ្ញោបិ ភិក្ខុ អភូតេន ចោទេតព្វំ មញ្ញេយ្យាតិ ។

(១៩១) អធម្មចុទិតស្ស បន ភន្តេ ភិក្ខុនោ កតិហាការេហិ អវិប្បដិសារោ ឧបទហាតព្វោតិ ។ អធម្មចុទិតស្ស ឧបាលិ ភិក្ខុនោ បញ្ចហាការេហិ អវិប្បដិសារោ ឧបទហាតព្វោ អកាលេនាយស្មា ចុទិតោ

នៃលោកដ៏មានអាយុ លោកចោទខុសកាល មិនមែនចោទត្រូវតាមកាលទេ លោកគួរដល់វិប្បដិសារៈហើយ ១ នៃលោកដ៏មានអាយុ លោកចោទដោយពាក្យមិនពិត មិនមែនចោទដោយពាក្យពិតទេ លោកគួរដល់វិប្បដិសារៈហើយ ១ នៃលោកដ៏មានអាយុ លោកចោទដោយពាក្យអាក្រក់ មិនមែនចោទដោយពាក្យពីរោះទេ លោកគួរដល់វិប្បដិសារៈហើយ ១ នៃលោកដ៏មានអាយុ លោកចោទប្រកបដោយកម្មឥតប្រយោជន៍ មិនមែនចោទប្រកបដោយកម្មមានប្រយោជន៍ទេ លោកគួរដល់វិប្បដិសារៈហើយ ១ នៃលោកដ៏មានអាយុ លោកជាអ្នកចោទ (គេ) ទាំងទោសចិត្ត មិនមែនចោទដោយមេត្តាចិត្តទេ លោកគួរដល់វិប្បដិសារៈហើយ ១ ម្នាលឧបាលិ សង្ឃគប្បីតាំងវិប្បដិសារៈទុក ចំពោះភិក្ខុអ្នកចោទដែលមិនប្រកបដោយធម៌ ដោយអាការ៥យ៉ាងនេះឯង ។ សេចក្តីនោះ ព្រោះហេតុអ្វី ។ ព្រោះថាភិក្ខុដទៃ មិនត្រូវសំគាល់ភិក្ខុផងគ្នា ដែលត្រូវគេចោទដោយពាក្យមិនពិត(នោះទេ) ។

(១៧១) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះសង្ឃគប្បីតាំងអវិប្បដិសារៈ(សេចក្តីមិនក្តៅក្រហាយ)ទុក ចំពោះភិក្ខុដែលគេចោទមិនប្រកបដោយធម៌ ដោយអាការប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧបាលិ សង្ឃគប្បីតាំងអវិប្បដិសារៈទុក ចំពោះភិក្ខុដែលគេចោទមិនប្រកបដោយធម៌ ដោយអាការ៥ យ៉ាងដូច្នេះថា នៃលោកដ៏មានអាយុ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នោ កាលេន អលន្តេ អវិប្បដិសារាយ អភូតេនា-យស្មា ចុទិតោ នោ ភូតេន អលន្តេ អវិប្បដិសារាយ ផរុសេនាយស្មា ចុទិតោ នោ សណ្ហេន អលន្តេ អវិប្បដិសារាយ អនត្ថសញ្ហិតេនាយស្មា ចុទិតោ នោ អត្ថសញ្ហិតេន អលន្តេ អវិប្បដិសារាយ ទោសន្តរេនា-យស្មា ចុទិតោ នោ មេត្តចិត្តេន អលន្តេ អវិប្បដិសា-រាយាតិ អធម្មចុទិតស្ស ឧបាលិ ភិក្ខុនោ ឥមេហិ បញ្ចហាការេហិ អវិប្បដិសារោ ឧបទហាតព្វោតិ ។

(១៧២) ធម្មចោទកស្ស ភន្តេ ភិក្ខុនោ កតីហា-ការេហិ អវិប្បដិសារោ ឧបទហាតព្វោតិ ។ ធម្មចោទ-កស្ស ឧបាលិ ភិក្ខុនោ បញ្ចហាការេហិ អវិប្បដិសា-រោ ឧបទហាតព្វោ កាលេនាយស្មា ចោទេសិ នោ អកាលេន អលន្តេ អវិប្បដិសារាយ ភូតេនាយស្មា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ផ្សព្វផ្សាយជាធម្មទាន។


គេចោទលោកខុសកាល មិនមែនត្រូវតាមកាលទេ លោកគួរដល់អវិប្បដិសារៈ ១ នៃលោកដ៏មានអាយុ គេចោទលោកដោយពាក្យមិនពិត មិនមែនតាមពិតទេ លោកគួរដល់អវិប្បដិសារៈ ១ នៃលោកដ៏មានអាយុ គេចោទលោកដោយពាក្យអាក្រក់ មិនមែនដោយពាក្យពីរោះទេ លោកគួរដល់អវិប្បដិសារៈ ១ នៃលោកដ៏មានអាយុ គេចោទលោកដោយពាក្យមិនប្រកបដោយប្រយោជន៍ មិនមែនដោយពាក្យប្រកបដោយប្រយោជន៍ទេ លោកគួរដល់អវិប្បដិសារៈ ១ នៃលោកដ៏មានអាយុ គេចោទលោកដោយទោសចិត្ត មិនមែនដោយមេត្តាចិត្តទេ លោកគួរដល់អវិប្បដិសារៈ ១ ម្នាលឧបាលិ សង្ឃគប្បីតាំងអវិប្បដិសារៈទុក ចំពោះភិក្ខុដែលគេចោទមិនប្រកបដោយធម៌ ដោយអាការ ៥ យ៉ាងនេះឯង ។

(១៧៤) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃគប្បីតាំងអវិប្បដិសារៈទុក ចំពោះភិក្ខុអ្នកចោទដែលប្រកបដោយធម៌ដោយអាការប៉ុន្មានយ៉ាង ។ ព្រះអង្គត្រាស់ថា ម្នាលឧបាលិ សង្ឃគប្បីតាំងអវិប្បដិសារៈទុក ចំពោះភិក្ខុអ្នកចោទដែលប្រកបដោយធម៌ ដោយអាការ៥ យ៉ាងដូច្នេះថា នៃលោកដ៏មានអាយុ លោកចោទគេត្រូវតាមកាលគួរហើយ មិនមែនចោទខុសកាលទេ លោកគួរដល់អវិប្បដិសារៈ ១ នៃលោក

ចោទេសិ នោ អភូតេន អលន្តេ អវិប្បដិសារាយ សណ្ហេ-
នាយស្មា ចោទេសិ នោ ផរុសេន អលន្តេ អវិប្បដិសា-
រាយ អត្ថសញ្ហិតេនាយស្មា ចោទេសិ នោ អនត្ថសញ្ហិ-
តេន អលន្តេ អវិប្បដិសារាយ មេត្តចិត្តោ អាយស្មា
ចោទេសិ នោ ទោសន្តរោ(១) អលន្តេ អវិប្បដិសារា-
យាតិ ធម្មចោទកស្ស ឧបាលិ ភិក្ខុនោ ឥមេហិ
បញ្ចហាការេហិ អវិប្បដិសារោ ឧបទហាតព្វោ ។ តំ
កិស្ស ហេតុ ។ យថា អញ្ញោបិ ភិក្ខុ ភូតេន ចោ-
ទេតព្វំ មញ្ញេយ្យាតិ ។

(១៧៣) ធម្មចុទិតស្ស បន ភន្តេ ភិក្ខុនោ កតី-
ហាការេហិ វិប្បដិសារោ ឧបទហាតព្វោតិ ។ ធម្មចុ-
ទិតស្ស ឧបាលិ ភិក្ខុនោ បញ្ចហាការេហិ វិប្បដិសា-
រោ ឧបទហាតព្វោ កាលេនាយស្មា ចុទិតោ នោ
អកាលេន អលន្តេ វិប្បដិសារាយ ភូតេនាយស្មា

---

១ មេត្តចិត្តេនាយស្មា ចោទេសិ នោ ទោសន្តរេនាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់...ទ។


ដ៏មានអាយុ លោកចោទគេដោយពាក្យពិតហើយ មិនមែនចោទដោយពាក្យមិនពិតទេ លោកគួរដល់អវិប្បដិសារៈ ១ នៃលោកដ៏មានអាយុ លោកចោទគេដោយពាក្យពីរោះហើយ មិនមែនចោទដោយពាក្យអាក្រក់ទេ លោកគួរដល់អវិប្បដិសារៈ ១ នៃលោកដ៏មានអាយុ លោកចោទគេដោយពាក្យប្រកបដោយប្រយោជន៍ មិនមែនចោទដោយពាក្យ មិនប្រកបដោយប្រយោជន៍ទេ លោកគួរដល់អវិប្បដិសារៈ ១ នៃលោកដ៏មានអាយុ លោកជាអ្នកតាំងមេត្តាចិត្តហើយទើបចោទ មិនមែនចោទទាំងទោសចិត្តទេ លោកគួរដល់អវិប្បដិសារៈ ១ ម្នាលឧបាលិ សង្ឃគប្បីតាំងអវិប្បដិសារៈទុក ចំពោះភិក្ខុអ្នកចោទដែលប្រកបដោយធម៌ ដោយអាការ ៥ យ៉ាងនេះឯង ។ សេចក្តីនោះព្រោះហេតុអ្វី ។ ព្រោះថា ភិក្ខុដទៃ គប្បីសំគាល់ភិក្ខុផងគ្នាដែលគេចោទដោយពាក្យពិត ។

(១៧៣) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សង្ឃគប្បីតាំងវិប្បដិសារៈទុក ចំពោះភិក្ខុដែលគេចោទ ប្រកបដោយធម៌ ដោយអាការប៉ុន្មានយ៉ាង ។ ព្រះអង្គត្រាស់ថា ម្នាលឧបាលិ សង្ឃគប្បីតាំងវិប្បដិសារៈទុក ចំពោះភិក្ខុដែលគេចោទប្រកបដោយធម៌ ដោយអាការ ៥ យ៉ាងដូច្នេះថា ម្នាលលោកដ៏មានអាយុ គេចោទលោកត្រូវតាមកាលហើយ មិនមែនចោទដោយខុសកាលទេ លោកគួរដល់វិប្បដិសារៈហើយ ១ នៃលោកដ៏មានអាយុ គេចោទលោកដោយពាក្យពិតហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ចុទិតោ នោ អភូតេន អលន្តេ វិប្បដិសារាយ សណ្ហេនាយស្មា ចុទិតោ នោ ផរុសេន អលន្តេ វិប្បដិសារាយ អត្ថសញ្ហិតេនាយស្មា ចុទិតោ នោ អត្ថសញ្ហិតេន អលន្តេ វិប្បដិសារាយ មេត្តចិត្តេនាយស្មា ចុទិតោ នោ ទោសន្តរេន អលន្តេ វិប្បដិសារាយាតិ ធម្មចុទិតស្ស ឧបាលិ ភិក្ខុនោ ឥមេហិ បញ្ចហាការេហិ វិប្បដិសារោ ឧបទហាតព្វោតិ ។

(១៧៤) ចោទកេន ភន្តេ ភិក្ខុនា បរំ ចោទេតុកាមេន កតិ ធម្មេ អជ្ឈត្តំ មនសិករិត្វា បរោ ចោទេតព្វោតិ ។ ចោទកេនុបាលិ ភិក្ខុនា បរំ ចោទេតុកាមេន បញ្ចធម្មេ អជ្ឈត្តំ មនសិករិត្វា បរោ ចោទេតព្វោ ការុញ្ញតា ហិតេសិតា អនុកម្បិតា[១]

១ ឱ. ម. អនុកម្បតា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាសម្បត្តិ

មិនមែនចោទដោយពាក្យមិនពិតទេ លោកគួរផ្តល់វិប្បដិសារៈហើយ ១ ម្នាលលោកដ៏មានអាយុ គេចោទលោកដោយពាក្យពីរោះហើយ មិនមែនចោទដោយពាក្យអាក្រក់ទេ លោកគួរផ្តល់វិប្បដិសារៈហើយ ១ ម្នាលលោកដ៏មានអាយុ គេចោទលោកដោយពាក្យប្រកបដោយប្រយោជន៍ហើយ មិនមែនចោទដោយពាក្យមិនប្រកបដោយប្រយោជន៍ទេ លោកគួរផ្តល់វិប្បដិសារៈហើយ ១ ម្នាលលោកដ៏មានអាយុ គេចោទលោកដោយមេត្តាចិត្តហើយ មិនមែនចោទដោយទោសចិត្តទេ លោកគួរផ្តល់វិប្បដិសារៈហើយ១ ម្នាលឧបាលិ សង្ឃគប្បីតាំងវិប្បដិសារៈទុកចំពោះភិក្ខុដែលគេចោទប្រកបដោយធម៌ ដោយអាការ ៥ យ៉ាងនេះឯង ។

(១៧៤) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុអ្នកចោទ មានប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវធ្វើទុកក្នុងចិត្តនូវធម៌មានប៉ុន្មានក្នុងខ្លួនឯងហើយ ទើបចោទភិក្ខុដទៃបាន ។ ព្រះអង្គត្រាស់តបថា ម្នាលឧបាលិ ភិក្ខុអ្នកចោទមានប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវធ្វើទុកក្នុងចិត្តនូវធម៌ ៥ យ៉ាង ក្នុងខ្លួនឯងសិន ទើបចោទភិក្ខុដទៃបាន (ធម៌ ៥ យ៉ាងនោះគឺ ) ជាអ្នកមានចិត្តករុណា១ អ្នកស្វែងរកប្រយោជន៍១ អ្នកទំនុកបម្រុង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាបត្តិវុដ្ឋានតា វិនយបុរេក្ខារតាតិ ចោទកេនុបាលិ ភិក្ខុនា បរំ ចោទេតុកាមេន ឥមេ បញ្ច ធម្មេ អជ្ឈត្តំ មនសិករិត្វា បរោ ចោទេតព្វោតិ ។

(១៧៨) ចុទិតេន ភន្តេ ភិក្ខុនា កតីសុ ធម្មេសុ បតិដ្ឋាតព្វន្តិ ។ ចុទិតេនុបាលិ ភិក្ខុនា ទ្វីសុ ធម្មេសុ បតិដ្ឋាតព្វំ សច្ចេ ច អកុប្បេ ចាតិ ។

បាតិមោក្ខដ្ឋបនក្ខន្ធកំ និដ្ឋិតំ នវមំ ។

ឥមម្ហិ ខន្ធកេ វត្ថូ តឹស ។

ភាណវារា ទ្វេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



(ដោយប្រយោជន៍នោះ) ១ អ្នកប៉ងឲ្យភិក្ខុដទៃរួចចាកអាបត្តិ ១ យកវិន័យជាប្រធាន ១ ម្នាលឧបាលិ ភិក្ខុអ្នកចោទ មានប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវធ្វើទុកក្នុងចិត្តនូវធម៌ ៥ យ៉ាងនេះឯង ក្នុងខ្លួនឯងសិន ទើបចោទភិក្ខុដទៃបាន ។

(១៧៥) ព្រះឧបាលិក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះភិក្ខុដែលគេចោទវិញ ត្រូវតាំងនៅក្នុងធម៌ប៉ុន្មានយ៉ាង ។ ព្រះអង្គត្រាស់ថា ម្នាលឧបាលិ ភិក្ខុដែលគេចោទត្រូវតាំងនៅក្នុងធម៌ ២ យ៉ាង គឺ សេចក្តីពិតត្រង់ ១ សេចក្តីមិនក្រោធ ១ ។

ចប់ បាតិមោក្ខដ្ឋបនក្ខន្ធកៈ ទី ៩ ។

ក្នុងខន្ធកៈនេះ មានរឿង ៣ ។

ចប់ ភាណវារៈ ២ ប្រការ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ថ្វាយលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


## បាតិមោក្ខដ្ឋបនក្ខន្ធកេ ឧទ្ទានគាថា

### តស្សុទ្ទានំ

(១៧៦) ឧបោសថេ យាវតិកំ
បាបភិក្ខុ ន និក្ខមិ(១)
មោគ្គល្លានេន និវុត្តោ(២)
អច្ឆរំ ជិនសាសនេ
និន្នោនុបុព្វសិក្ខា ច
ឋិតធម្មោ នតិក្កម
កុណបុក្ខិបតិ សន្ទ្យោ
សវន្តិយោ ជហន្តិ ច
សវន្តិ បរិនិព្វន្តិ
ឯការស វិមុត្តិ ច
ពហុ ធម្មវិនយោបិ
ភូតដ្ឋារិយបុគ្គលា

---

១ ឧ. និក្ខមតិ ។ ២ ឱ. និច្ឆុទ្ធោ ។ ម. និច្ឆុទ្ធោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាប្រយោជន៍។ 

## បាតិមោក្ខដ្ឋបនក្ខន្ធកៈ ឧទ្ទានគាថា

ឧទ្ទាននៃបាតិមោក្ខដ្ឋបនក្ខន្ធកៈនោះ ដូច្នេះ

[១៧៦] រឿងព្រះមានព្រះភាគ គង់ក្នុងរោងឧបោសថ ១ រឿងព្រះអានន្ទក្រាបបង្គំទូលអស់វារៈ ៣ ដង ១ រឿងភិក្ខុបាប មិនចេញពីរោងឧបោសថ ១ រឿងព្រះមោគ្គល្លានបណ្តេញភិក្ខុបាបចេញ ១ រឿងក្នុងសាសនារបស់ព្រះជិនស្រី មានអច្ឆរិយព្ភូតធម៌ (៨ យ៉ាង) មានសិក្ខាជាលំដាប់ ដូចមហាសមុទ្រមានទំនាបជាលំដាប់ ពួកសាវ័ក មិនប្រព្រឹត្តកន្លងសិក្ខាបទ ដូចមហាសមុទ្រ មានទឹកតាំងនៅនឹងជាធម្មតា សង្ឃរមែងលើកបុគ្គលអាក្រក់ចេញ ដូចរលកសមុទ្រដែលផាត់សាកសពស្លាប់ទៅលើគោក (វណ្ណៈ ៤ ពួក) ដែលចេញបួសហើយ តែងលះបង់នាមនឹងគោត្រដើម ដូចទន្លេធំ ៗ តែងលះបង់នាមនឹងគោត្រដើម ពួកភិក្ខុដែលបរិនិព្វាន ព្រះនិព្វានក៏មិនប្រាកដជាខ្វះឬពេញ ព្រះធម៌វិន័យមានរសតែមួយ គឺវិមុត្តិរស ដូចមហាសមុទ្រមានរសតែមួយគឺរសប្រៃ ព្រះធម៌វិន័យមានគុណសម្បត្តិជាគ្រឿងត្រេកអរច្រើន ដូចមហាសមុទ្រមានរតនៈច្រើនយ៉ាង ព្រះធម៌វិន័យជាទីអាស្រ័យនៅនៃព្រះអរិយបុគ្គល ៨ ពួក ដូចមហាសមុទ្រជាទីនៅអាស្រ័យនៃសត្វ

## វិនយបិដកេ ចុល្លវគ្គោ

សមុទ្ទំ ឧបមំ កត្វា
ញាបេសិ សាសនេ គុណំ(១) ។
ឧបោសថេ បាតិមោក្ខំ
ន អម្ហេ កោចិ ជានាតិ
បដិកច្ចេវ ឧជ្ឈន្តិ
ឃាតោ ទ្វេ តីណិ ចាតុកេ(២)
បញ្ច ឆ សត្ត អដ្ឋានិ
នវ(៣) ច ទសមានិ ច ។
សីល អាចារ ទិដ្ឋិ ច
អាជីវញ្ចតុភាគិកោ(៤) ។
បារាជិកញ្ច សង្ឃាទិ
បាចិត្តិ បាដិទេសនិ
ទុក្កដំ បញ្ចភាគេសុ
សីលាចារវិបត្តិ ច
អកតាយ កតាយ ច
ឆព្ភាគេសុ យថាវិធិ(៥) ។

---

១ ឱ. ម. ញាបេសិ សាសនេ គុណំ ។ ២ ឱ. ម. ចត្តារិ ។ ៣ ឱ. នវ ។ ៤ ឱ. អាជីវំ ចតុភាគិកេ ។ ៥ ឱ. ម. យថា ឋិតិ ។

## វិនយបិដក បុណ្ណវគ្គ

ធំ ៗ ១ រឿងព្រះមានព្រះភាគធ្វើសេចក្ដីប្រៀបធៀបនឹងមហាសមុទ្រ ហើយទ្រង់តម្កល់គុណទុកក្នុងសាសនា ១ ។ រឿងព្រះមានព្រះភាគ ទ្រង់អនុញ្ញាត ឲ្យសំដែងបាតិមោក្ខ ក្នុងថ្ងៃឧបោសថ ១ រឿងព្រះមានព្រះភាគទ្រង់អនុញ្ញាត ឲ្យបញ្ឈប់បាតិមោក្ខ ១ រឿងឆព្វគ្គិយភិក្ខុត្រូវអាបត្តិហើយ ចូលទៅស្ដាប់បាតិមោក្ខដោយប្ដេជ្ញាខ្លួនថា គ្មាននរណាមួយ ស្គាល់យើងឡើយ ១ រឿងឆព្វគ្គិយភិក្ខុបញ្ឈប់បាតិមោក្ខ ដោយប្រញាប់ប្រញាល់ ១ រឿងពួកភិក្ខុពោលទោស (ព្រោះបញ្ឈប់បាតិ-មោក្ខ) ១ រឿងបញ្ឈប់បាតិមោក្ខ មិនប្រកបដោយធម៌និងប្រកបដោយធម៌ មាន ១-២-៣-៤-៥-៦-៧-៨-៩-១០ យ៉ាងក៏មាន ១ ។ រឿងភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះវិបត្តិមានចំណែក ៤ ប្រការ គឺ សីលវិបត្តិ អាចារវិបត្តិ ទិដ្ឋិវិបត្តិ អាជីវ-វិបត្តិ ១ ។ រឿងភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះវិបត្តិមានចំណែក ៥ ប្រការគឺ បារាជិកាបត្តិ សង្ឃាទិសេសាបត្តិ បាចិត្តិយាបត្តិ បាដិទេសនីយាបត្តិ ទុក្កដាបត្តិ ១ រឿងភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះវិបត្តិមានចំណែក ៦ ប្រការ គឺ សីលវិបត្តិ អាចារវិបត្តិ (ទិដ្ឋិ-វិបត្តិ) ក្នុងមួយ ៗ បែកជាពីរ គឺបែកទៅជាភិក្ខុមិនធ្វើនិងធ្វើ ១ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

## បាតិមោក្ខដ្ឋបនក្ខន្ធកេ ឧទ្ទានគាថា

បារាជិកំ ច សង្ឃាទិ
ថុល្លបាចិត្តិយេន ច
បាដិទេសនីយញ្ចេវ
ទុក្កដញ្ច ទុព្ភាសិតំ
សីលាចារវិបត្តិ ច
អាជីវញ្ច វិបត្តិយោ
អដ្ឋាកតាយ កាតេន
សីលាចារ ច ទិដ្ឋិយា (១)
អកតាយ កតាយោបិ
កតាកតាយមេវ ច
ឃរំ ចរិជា វុត្តា
យថាកុតេន ញាយតោ ។
បារាជិកោ វិប្បកតា (២)
បច្ចក្ខាតោ តថេវ ច
ឧបេតិ បច្ចាទិយតិ
បច្ចាទានកថាយ ច (៣)

---

១ ឱ. ម. សីលាចារវិបត្តិ ច ទិដ្ឋិអាជីវវិបត្តិ យា ច អដ្ឋា កតាកតេ តេនេកា សីលា-ចារទិដ្ឋិយា ។ ២ ឱ. ម. វិប្បកតោ ។ ៣ ឱ. ម. បច្ចាទានកថា ច យា ។

# បាតិមោក្ខដ្ឋបនក្ខន្ធកៈ ឧទ្ទានគាថា

រឿងភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះអាបត្តិ ( មានចំណែក ៧ យ៉ាង ) គឺបារាជិកាបត្តិ សង្ឃាទិសេសាបត្តិ ថុល្លច្ចយាបត្តិ បាចិត្តិយាបត្តិ បាដិទេសនីយាបត្តិ ទុក្កដាបត្តិ ទុព្ភាសិតាបត្តិ ១ រឿងភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះវិបត្តិមានចំណែក ៤ យ៉ាង គឺ សីលវិបត្តិ អាចារវិបត្តិ(ទិដ្ឋិវិបត្តិ)អាជីវវិបត្តិ (ក្នុងមួយៗចែកជា ២ គឺចែកជា ) ភិក្ខុមិនធ្វើនឹងធ្វើ ២ រឿងភិក្ខុបញ្ឈប់បាតិមោក្ខ ព្រោះវិបត្តិ ៩ យ៉ាង ដែលព្រះមានព្រះភាគ ទ្រង់ជ្រាបពិត ហើយ ទ្រង់ត្រាស់ដូច្នេះថា សីលវិបត្តិ អាចារវិបត្តិ ទិដ្ឋិវិបត្តិ ( ក្នុងមួយ ៗ ចែកជា ៣ ៗ គឺ ចែកជា ) ភិក្ខុមិនធ្វើនឹងធ្វើ ទាំងធ្វើនឹងមិនធ្វើ ១ ៗ រឿងអ្នកប្រាជ្ញត្រូវដឹងថា ការបញ្ឈប់បាតិមោក្ខនោះ ដោយហេតុ ១០ យ៉ាង គឺ មានភិក្ខុត្រូវបារាជិក (អង្គុយក្នុងបរិសទ្យនោះ) បារាជិកកថា សង្ឃធ្វើមិនទាន់ស្រេច ភិក្ខុពោលលាសិក្ខា អង្គុយក្នុងបរិសទ្យនោះ បច្ចក្ខាតកថា សង្ឃធ្វើមិនទាន់ស្រេច ភិក្ខុព្រមព្រៀងគ្នា ភិក្ខុត្រឡប់សេចក្តីព្រមព្រៀងវិញ បច្ចាទានកថា សង្ឃធ្វើ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



សីលាចារវិបត្តិ ច
តថា(១) ទិដ្ឋិវិបត្តិយោ
ទិដ្ឋសុតបរិសង្កិតំ(២)
ទសធា តំ វិជានថ ។
ភិក្ខុ វិបស្សតិ ភិក្ខុំ
អញ្ញោ ចារោចយតិ តំ
សុទ្ធេ វ តស្ស អក្ខាតិ
បាតិមោក្ខំ ឋបេតិ សោ ។
វុដ្ឋាតិ អន្តរាយេន
រាជា ចោរអគ្គុទកា
មនុស្សាមនុស្សា វាឡ
សិរឹសបា ច ជីវិតំ
ព្រហ្មចារី ច ទសន្នំ
តស្មិំ អញ្ញតរេសុ វា(៣)
ធម្មិកាធម្មិកា ចេវ
យថាមគ្គេន ជានថ ។

---

១ ឱ. ម. យថា ។ ២ ឱ.ម. ទិដ្ឋិសុតបរិសង្កិ ។ ៣ ឱ. ម. ភិក្ខុ វិបស្សតិ ភិក្ខុំ វិបស្សញ្ញោ ជាភេចតិ តំ សុទ្ធេ វ តស្ស អក្ខាតិ ជាតិមោក្ខំ ឋបេតិ សោ ។ វុដ្ឋាតិ អន្តរាយេន រាជចោ-រគ្គុទកា ច មនុស្សអមនុស្សា ច វាឡសិរិសបាជីវិ ព្រហ្មំ ទសន្នញ្ញតរេកេន តស្មិំ អញ្ញតរេសុ វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន 



មិនទាន់ស្រេច ភិក្ខុមានគេឃើញ ឮ ឬរង្កៀសដោយសីល-វិបត្តិ ដោយអាចារវិបត្តិ ដោយទិដ្ឋិវិបត្តិ ១ ៗ រឿង (ភិក្ខុត្រូវអាបត្តិបារាជិក អង្គុយក្នុងបរិសទ្យ) ជានិងមានភិក្ខុផងគ្នាឃើញភិក្ខុត្រូវអាបត្តិបារាជិក (នោះ) បើមិនដូច្នោះគង់មានភិក្ខុឯទៀតប្រាប់ដំណើរនោះដល់ភិក្ខុផងគ្នា ឬភិក្ខុនោះប្រាប់ដល់ភិក្ខុបរិសុទ្ធដោយខ្លួនឯង ១ រឿងភិក្ខុបញ្ឈប់បាតិមោក្ខចំពោះភិក្ខុនោះ ១ ៗ រឿងបរិសទ្យក្រោកដើរចេញ ព្រោះអន្តរាយ ១០យ៉ាង អន្តរាយណាមួយ គឺអន្តរាយអំពីព្រះរាជា ចោរ ភ្លើង ទឹក មនុស្ស អមនុស្ស សត្វសាហាវ ពស់តូចធំ ជីវិត និងព្រហ្មចរិយ. ១ ការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ និងមិនប្រកបដោយធម៌(នេះ)ភិក្ខុគប្បីដឹងតាមសមគួរដល់៖បាយបុះ ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទានៗ

## បាតិមោក្ខដ្ឋបនក្ខន្ធកេ ឧទ្ទានគាថា

កាលភូតត្ថសញ្ហិតំ

វទិស្សាមិ ករិស្សតិ

កាយវាចសិកា មេត្តា

ពាហុសច្ចភិយោគិតុ(១) ។

កាលភូតេន សណ្ហេន

អត្ថមេត្តេន ចោទយេ

វិប្បដិសារី អធម្មេន

---

១ ឧ. ម. ពាហុសច្ចំ អភិយោគិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាទានៗ


## បាតិមោក្ខដ្ឋបនក្ខន្ធកៈ ឧទ្ទានគាថា

រឿង (ព្រះមានព្រះភាគទ្រង់សំដែងថា បើមានភិក្ខុប៉ង នឹងកាន់យកនូវអត្តាទាន ត្រូវកាន់យកអត្តាទានដែលប្រកបដោយអង្គ ៥ ប្រការ) គឺ កាលគួរ អធិករណ៍ពិតប្រាកដ អធិករណ៍ប្រកបដោយប្រយោជន៍ បានភិក្ខុដែលជាបក្សខាងធម៌វិន័យមកជាមិត្តសម្លាញ់ មិនមានហេតុមានសេចក្ដីប្រកាន់ជាដើម ១ រឿង (ព្រះមានព្រះភាគទ្រង់សំដែងថា ភិក្ខុអ្នកចោទ ប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវពិចារណាធម៌ ៥ យ៉ាង ចំពោះខ្លួនឯងជាមុន) ថា អាត្មាអញមានកាយសមាចារបរិសុទ្ធដែរឬទេ មានវចីសមាចារបរិសុទ្ធដែរឬទេ មានមេត្តាចិត្តតាំងមាំដែរឬទេ ជាពហុស្សូតដែរឬទេ ជាអ្នកស្ទាត់ជំនាញក្នុងបាតិមោក្ខទាំងពីរដែរឬទេ ១ ៗ រឿង (ព្រះមានព្រះភាគទ្រង់សំដែងថា ភិក្ខុអ្នកចោទ ប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវតាំងខ្លួនឲ្យមាំក្នុងធម៌ ៥ យ៉ាង គឺ ជាអ្នកនិយាយត្រូវតាមកាលគួរ និយាយពាក្យពិត និយាយពាក្យពីរោះ និយាយពាក្យប្រកបដោយប្រយោជន៍ ចោទដោយមេត្តាចិត្ត) ១ រឿង (ព្រះមានព្រះភាគទ្រង់សំដែងថា ភិក្ខុគួរតាំងនូវវិប្បដិសារៈទុក ចំពោះភិក្ខុអ្នកចោទមិនប្រកបដោយធម៌ ៥ យ៉ាង ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



តថេភបិ វិនោទយេ(១)

ធម្មចោទចុទិតស្ស

វិនោទេ វិប្បដិសារេ ។

ករុណា ហិតានុកម្បា

វុដ្ឋានម្បិ បុរក្ខិតា(២) ។

ចោទកស្ស បដិបត្តិ

សម្ពុទ្ធេន បកាសិតា(៣)

សច្ចេ ចេវ អកុប្បេ ច

ចុទិតស្សេស(៤) ធម្មតាតិ ។

---

១ ឧ. ម. វិប្បដិសារកម្មេន តហិ ភាតា វិនោទយេ ។ ២ ឧ. ម. ធម្មចោទចុទិតស្ស វិនោ-ទេតិ វិប្បដិសារេ ករុណា ហិតានុកម្បី វុដ្ឋាន បុរេក្ខារតា ។ ៣ ឧ. ម. បកាសិតំ ។ ៤ ឧ. ម. ចុទិតស្សេវ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


## វិនយបិដក ចុល្លវគ្គ

រឿងសង្ឃគួរបន្ទោបង់វិប្បដិសារៈចំពោះភិក្ខុដែលចោទប្រកបដោយធម៌ ៤ យ៉ាងដូចគ្នា ១ រឿងព្រះមានព្រះភាគទ្រង់សំដែងថា ភិក្ខុគួរតាំងអវិប្បដិសារៈចំពោះភិក្ខុដែលគេចោទប្រកបដោយធម៌ ដោយអាការ ៤ យ៉ាង ១ រឿងព្រះមានព្រះភាគទ្រង់សំដែងថា ភិក្ខុអ្នកចោទ ប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវតាំងធម៌ ៤ យ៉ាង ទុកក្នុងចិត្ត គឺ ជាអ្នកមានសេចក្ដីករុណា ស្វែងរកប្រយោជន៍ មានសេចក្ដីអនុគ្រោះ (ដោយប្រយោជន៍នោះ) ប៉ុនប៉ងឲ្យភិក្ខុដទៃរួចចាកអាបត្តិ យកវិន័យជាប្រធាន ១ រឿងព្រះសម្ពុទ្ធទ្រង់សំដែងសេចក្ដីប្រតិបត្តិ របស់ភិក្ខុអ្នកត្រូវចោទ តាំងខ្លួនក្នុងធម៌ ២ យ៉ាង គឺ ពាក្យពិតត្រង់នឹងសេចក្ដីមិនក្រោធ ១ នេះជាធម្មតា របស់ភិក្ខុដែលត្រូវគេចោទ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# ភិក្ខុនីខន្ធកំ

(១៧៧) តេន សមយេន ពុទ្ធោ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថ ខោ មហាបជាបតី គោតមី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច សាធុ ភន្តេ លភេយ្យ មាតុគាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ អលំ គោតមិ មា តេ រុច្ចិ មាតុគាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជាតិ ។ ទុតិយម្បិ ខោ ។បេ។ តតិយម្បិ ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច សាធុ ភន្តេ លភេយ្យ មាតុគាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ អលំ គោតមិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# ភិក្ខុនីខន្ធកៈ

[១៧៧] សម័យនោះ ព្រះពុទ្ធមានព្រះភាគទ្រង់គង់ ក្នុងនិគ្រោធារាម ក្បែរក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ លំដាប់នោះឯង ព្រះនាងមហាបជាបតីគោតមី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះព្រះនាងមហាបជាបតីគោតមី ឋិតនៅក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់សូមអង្វរ មាតុគ្រាមគួរនឹងបានចេញចាកផ្ទះ ចូលទៅកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ថា កុំឡើយ ព្រះនាងគោតមី ព្រះនាងកុំគាប់ព្រះទ័យឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ (នោះ) ឡើយ ។ ព្រះនាងមហាបជាបតីគោតមី បានក្រាបបង្គំទូលសូម អស់វារៈជាគំរប់ពីរដងផង ។ បេ ។ ព្រះនាងមហាបជាបតីគោតមី បានក្រាបបង្គំទូលព្រះមានព្រះភាគ អស់វារៈជាគំរប់បីដងផងយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់សូមអង្វរ មាតុគ្រាមគួរនឹងបានចេញចាកផ្ទះ ចូលទៅកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ថា កុំឡើយ ព្រះនាង

មា តេ រុច្ចិ មាតុគាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជាតិ ។ អថ ខោ មហាបជាបតី គោតមី ន ភគវា អនុជានាតិ មាតុគាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ទុក្ខី ទុម្មនា អស្សុមុខី រុទមានា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

(១៧៨) អថ ខោ ភគវា កបិលវត្ថុស្មឹ យថាភិរន្តំ វិហរិត្វា យេន វេសាលី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន វេសាលី តទវសរិ ។ តត្រ សុទំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថ ខោ មហាបជាបតី គោតមី កេសេ ឆេទាបេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា សម្ពហុលាហិ សាកិយានីហិ សទ្ធឹ យេន វេសាលី តេន បក្កាមិ អនុបុព្វេន យេន វេសាលី មហាវនំ កូដាគារសាលា តេនុបសង្កមិ ។ អថ ខោ មហាបជាបតី គោតមី សូនេហិ បាទេហិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



គោតមី ព្រះនាងកុំគាប់ព្រះទ័យឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ (នោះ) ឡើយ ។ លំដាប់នោះឯង ព្រះនាងមហាបជាបតីគោតមី បាន (ក្រាបថា) ព្រះមានព្រះភាគមិនទ្រង់អនុញ្ញាតឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយ (ដូច្នោះ) ក៏ជាទុក្ខ តូចព្រះទ័យ ស្រក់ទឹកព្រះនេត្រ ទ្រង់ព្រះកន្សែង ហើយក្រាបថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណរួចចៀសចេញទៅ ។

(១៧៨) លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់គង់ក្នុងក្រុងកបិលព័ស្តុ តាមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយយាងចេញទៅកាន់ចារិកនគរវេសាលី លុះយាងទៅកាន់ចារិកដោយលំដាប់ ក៏បានទៅដល់នគរវេសាលីនោះឯង ។ មានសេចក្តីដំណាលថា ព្រះមានព្រះភាគ ទ្រង់គង់ក្នុងកូដាគារសាលា នាព្រៃមហាវ័ន ទៀបក្រុងវេសាលីនោះ ។ លំដាប់នោះឯង ព្រះនាងមហាបជាបតីគោតមី ឲ្យគេកោរព្រះកេសាហើយស្លៀកសំពត់ជ្រលក់ដោយទឹកអម្ចត់ ក៏ទ្រង់យាងសំដៅទៅនគរវេសាលី ចូលទៅកាន់កូដាគារសាលា នាព្រៃមហាវ័ន ទៀបក្រុងវេសាលីនោះតាមលំដាប់ ជាមួយនឹងពួកនាងសាកិយានីជាច្រើន ។ លំដាប់នោះឯង ព្រះនាងមហាបជាបតីគោតមី មានព្រះបាទទាំងពីរពុះពង មានព្រះអង្គ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

## ភិក្ខុនីខន្ធកេ មហាបជាបតីគោតមីវត្ថុ

រជោកិណ្ណេន គត្តេន ទុក្ខី ទុម្មនា អស្សុមុខី រុទមានា ពហិទ្វារកោដ្ឋកេ អដ្ឋាសិ ។ អទ្ទសា ខោ អាយស្មា អានន្ទោ មហាបជាបតឹ គោតមឹ សុនេហិ បាទេហិ រជោកិណ្ណេន គត្តេន ទុក្ខឹ ទុម្មនំ អស្សុមុខឹ រុទមានំ ពហិទ្វារកោដ្ឋកេ ឋិតំ ទិស្វាន មហាបជាបតឹ គោតមឹ ឯតទវោច កិស្សុ ត្វំ គោតមិ សុនេហិ បាទេហិ រជោកិណ្ណេន គត្តេន ទុក្ខី ទុម្មនា អស្សុមុខី រុទមានា ពហិទ្វារកោដ្ឋកេ ឋិតាតិ ។ តថា ហិ បន ភន្តេ អានន្ទ ន ភគវា អនុជានាតិ មាតុគាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ តេនហិ គោតមិ មុហុត្តំ ត្វំ ឥធេវ តាវ ហោហិ យាវាហំ ភគវន្តំ យាចាមិ មាតុគាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។

## ភិក្ខុនីខន្ធកៈ រឿងព្រះនាងមហាបជាបតីគោតមី

ប្រឡាក់ដោយធូលី ជាទុក្ខតូចព្រះទ័យស្រក់ទឹកព្រះនេត្រ ឈរទ្រង់ព្រះកន្សែងទៀបគ្រាំងទ្វារខាងក្រៅ ។ ព្រះអានន្ទដ៏មានអាយុបានឃើញព្រះនាងមហាបជាបតីគោតមី មានព្រះបាទទាំងគូពុះពង មានព្រះអង្គប្រឡាក់ដោយធូលី ជាទុក្ខតូចព្រះទ័យស្រក់ទឹកព្រះនេត្រ កំពុងតែឈរទ្រង់ព្រះកន្សែងទៀបគ្រាំងទ្វារខាងក្រៅ លុះបានឃើញហើយ ក៏ពោលពាក្យនេះនឹងព្រះនាងមហាបជាបតីគោតមីថា បពិត្រព្រះនាងគោតមី ហេតុអ្វីបានជាព្រះនាងមានព្រះបាទទាំងគូពុះពង មានព្រះអង្គប្រឡាក់ដោយធូលី ជាទុក្ខតូចព្រះទ័យស្រក់ទឹកព្រះនេត្រ ឈរទ្រង់ព្រះកន្សែង ទៀបគ្រាំងទ្វារខាងក្រៅដូច្នេះ ។ ព្រះនាងមហាបជាបតីគោតមីឆ្លើយតបថា បពិត្រព្រះអានន្ទដ៏ចំរើន បានជាដូច្នោះ ព្រោះតែព្រះមានព្រះភាគ មិនទ្រង់អនុញ្ញាតឲ្យមាតុគ្រាមចេញចាកផ្ទះមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ហើយផងសោះ ។ ព្រះអានន្ទដ៏មានអាយុមានវាចាថា បពិត្រព្រះនាងគោតមី បើដូច្នោះ សូមព្រះនាងទ្រង់ចាំអាត្មាភាពក្នុងទីនេះមួយរំពេចសិនចុះ ទំរាំអាត្មាភាពទៅក្រាបបង្គំទូលសុំព្រះមានព្រះភាគ ឲ្យមាតុគ្រាមបានចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគតជ្រាបច្បាស់ហើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដកេ ចុល្លវគ្គោ

(១៧៩) អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឯសា ភន្តេ មហាបជាបតី គោតមី សូនេហិ បាទេហិ រជោកិណ្ណេន គត្តេន ទុក្ខី ទុម្មនា អស្សុមុខី រុទមានា ពហិទ្វារកោដ្ឋកេ ឋិតា ន ភគវា អនុជានាតិ មាតុគាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ សាធុ ភន្តេ លភេយ្យ មាតុគាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ អលំ អានន្ទ មា តេ រុច្ចិ មាតុគាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជាតិ ។ ទុតិយម្បិ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សាធុ ភន្តេ លភេយ្យ មាតុគាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ម្ចាស់ទូទៅ។ 



(១៧៩) លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះនាងមហាបជាបតីគោតមីនេះ មានព្រះបាទទាំងគូពរពង មានព្រះអង្គប្រឡាក់ដោយធូលី ជាទុក្ខ តូចព្រះទ័យ ស្រក់ទឹកព្រះនេត្រ ឈរទ្រង់ព្រះកន្សែងទៀបក្លោងទ្វារខាងក្រៅ (ព្រោះជ្រាបថា) ព្រះមានព្រះភាគមិនទ្រង់អនុញ្ញាត ឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយ បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាមបានចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយផង ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ថា កុំឡើយ អានន្ទ អ្នកកុំចូលចិត្តឲ្យមាតុគ្រាមចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ (នោះ) ឡើយ ។ ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគ ជាគំរប់ពីរដងផងថា បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាមបានចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយផងចុះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

## ភិក្ខុនីខន្ធកេ មហាបជាបតីគោតមីវត្ថុ

អលំ អានន្ទ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជាតិ ។ តតិយម្បិ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អ-គារស្មា អនគារិយំ បព្វជ្ជន្តិ ។ អលំ អានន្ទ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជាតិ ។ អថខោ អាយស្មា អានន្ទោ ន ភគវា អនុជានាតិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជំ យន្នូនាហំ អញ្ញេនបិ បរិយាយេន ភគវន្តំ យាចេយ្យំ មាតុគ្គាមស្ស តថាគត-ប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ អថខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ភព្វោ នុ ខោ ភន្តេ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិត្វា សោតាបត្តិផលំ វា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ផ្សព្វផ្សាយ។

## ភិក្ខុនីខន្ធកៈ រឿងព្រះនាងមហាបជាបតីគោតមី

ព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ថា កុំឡើយ អានន្ទ អ្នកកុំចូលចិត្តឲ្យមាតុគ្រាម ចេញចាកផ្ទះចូលមកកាន់ផ្នួសក្នុងធម្មវិន័យដែលតថាគតជ្រាបច្បាស់ហើយ (នោះ)ឡើយ ។ ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគជាគំរប់ពីរដងផងថា បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោសឲ្យមាតុគ្រាមបានចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយផងចុះ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ថា កុំឡើយ អានន្ទ អ្នកកុំចូលចិត្តឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ (នោះ) ឡើយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុត្រិះរិះថា ឥឡូវនេះ ព្រះមានព្រះភាគមិនទ្រង់អនុញ្ញាតឲ្យមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយទេ បើដូច្នេះគួរតែអាត្មាអញក្រាបបង្គំទូលសូមព្រះមានព្រះភាគ ដោយបរិយាយដទៃ ១ ទៀត ដើម្បីឲ្យមាតុគ្រាមចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុបានក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន (បើ) មាតុគ្រាមចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយ តើអាចដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផលខ្លះ

សកិទាគាមិផលំ វា អនាគាមិផលំ វា អរហត្តផលំ វា សច្ឆិកាតុន្តិ ។ ភព្វោ អានន្ទ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិត្វា សោតាបត្តិផលំបិ សកិទាគាមិផលំបិ អនាគាមិផលំបិ អរហត្តផលំបិ សច្ឆិកាតុន្តិ ។ សចេ ភន្តេ ភព្វោ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិត្វា សោតាបត្តិផលំបិ សកិទាគាមិផលំបិ អនាគាមិផលំបិ អរហត្តផលំបិ សច្ឆិកាតុំ ពហុបការា ភន្តេ មហាបជាបតី គោតមី ភគវតោ មាតុច្ឆា អាបាទិកា បោសិកា ខីរស្ស ទាយិកា ភគវន្តំ ជនេត្តិយា កាលកតាយ ថញ្ញំ បាយេសិ សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។

(១៨០) សចេ អានន្ទ មហាបជាបតី គោតមី អដ្ឋ គរុធម្មេ បដិគ្គណ្ហាតិ សា វស្សា ហោតុ ឧបសម្បទា

សកទាគាមិផលខ្លះ អនាគាមិផលខ្លះ អរហត្តផលខ្លះ បានដែរឬទេ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលអានន្ទ (បើ) មាតុគ្រាមចេញចាកផ្ទះចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ ក៏អាចដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផលខ្លះ សកទាគាមិផលខ្លះ អនាគាមិផលខ្លះ អរហត្តផលខ្លះបាន ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន បើមាតុគ្រាមចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងធម្មវិន័យដែលព្រះតថាគតជ្រាបច្បាស់ហើយ អាចដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផលខ្លះ សកទាគាមិផលខ្លះ អនាគាមិផលខ្លះ អរហត្តផលខ្លះ បានដែរ បពិត្រព្រះអង្គដ៏ចំរើន ព្រះនាងមហាបជាបតីគោតមី មានឧបការៈច្រើន ជាព្រះមាតុច្ឆានៃព្រះមានព្រះភាគ ព្រះនាងបានទ្រាំទ្រថែរក្សាថ្វាយទឹកក្សីរ កាលព្រះមាតាទ្រង់ទិវង្គតទៅ ព្រះនាងបានបំបៅព្រះអង្គ(តរៀងមក) បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាមបានចេញចាកផ្ទះចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយផងចុះ ។

(១៨០) ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលអានន្ទ បើព្រះនាងមហាបជាបតីគោតមី ទទួលប្រតិបត្តិតាមគរុធម៌ទាំង ៨ បាន ឧបសម្បទានោះ ចូរសម្រេចដល់ព្រះនាងចុះ ( ឯគរុធម៌ ៨ នោះ ) គឺ ភិក្ខុនីសូម្បី

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

## ភិក្ខុនីខន្ធកេ អដ្ឋ គរុធម្មា

វស្សសតូបសម្បន្នាយ ភិក្ខុនិយា តទហុបសម្បន្នស្ស ភិក្ខុនោ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ កាតព្វំ អយំ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ន ភិក្ខុនិយា អភិក្ខុកេ អាវាសេ វស្សំ វសិតព្វំ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ អន្វឌ្ឍមាសំ ភិក្ខុនិយា ភិក្ខុសង្ឃតោ ទ្វេ ធម្មា បច្ចាសីសិតព្វា ឧបោសថបុច្ឆកញ្ច ឱវាទុបសង្កមនញ្ច អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ វស្សំវុដ្ឋាយ ភិក្ខុនិយា ឧភតោសង្ឃេ តីហិ ឋានេហិ បវារេតព្វំ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ គរុធម្មំ អជ្ឈាបន្នាយ ភិក្ខុនិយា ឧភតោសង្ឃេ បក្ខមានត្តំ ចរិតព្វំ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ សិក្ខមានាយ ឧភតោសង្ឃេ ឧបសម្បទា បរិយេសិតព្វា

**ភិក្ខុនីខន្ធកៈ គរុធម៌ ៨**

ឧបសម្បទា បានមួយវស្សាហើយ ក៏ត្រូវតែថ្វាយបង្គំ ក្រោកទទួល ធ្វើអញ្ជលិកម្ម សាមីចិកម្ម ចំពោះភិក្ខុដែលទើបនឹងបានឧបសម្បទា ក្នុងថ្ងៃនោះ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីមិនត្រូវនៅចាំវស្សាក្នុងអាវាសដែលគ្មានភិក្ខុឡើយ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីត្រូវប្រាថ្នាធម៌ពីរប្រការ គឺ សួរឧបោសថ ចូលទៅស្តាប់ឱវាទ អំពីសំណាក់ភិក្ខុសង្ឃរាល់កន្លះខែ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីនៅចាំវស្សារួចហើយត្រូវបវារណាក្នុងសំណាក់សង្ឃទាំង ២ ពួក ដោយស្ថានទាំង ៣ គឺ ឃើញក្តី ឮក្តី រង្កៀសក្តី ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីត្រូវគរុកាបត្តិហើយ គប្បីប្រព្រឹត្តបក្ខមានត្ត ក្នុងសំណាក់សង្ឃទាំង ២ ពួក ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីត្រូវជួយស្វែងរកឧបសម្បទា ក្នុងសំណាក់សង្ឃទាំង ២ ពួក ដល់សិក្ខមានាដែលបានសិក្សាសិក្ខា ក្នុងធម៌ទាំង ៦ ប្រការគ្រប់ ២ ឆ្នាំហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ន ភិក្ខុនិយា កេនចិ បរិយាយេន ភិក្ខុ អក្កោសិតព្វោ បរិភាសិតព្វោ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ អជ្ជតគ្គេ ឱវដោ ភិក្ខុនីនំ ភិក្ខូសុ វចនបថោ អនោវដោ ភិក្ខូនំ ភិក្ខុនីសុ វចនបថោ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ សចេ អានន្ទ មហាបជាបតី គោតមី ឥមេ អដ្ឋ គរុធម្មេ បដិគ្គណ្ហាតិ សាវស្សា ហោតុ ឧបសម្បទាតិ ។

(១៨១) អថខោ អាយស្មា អានន្ទោ ភគវតោ សន្តិកេ អដ្ឋ គរុធម្មេ ឧគ្គហេត្វា យេន មហាបជាបតី គោតមី តេនុបសង្កមិ ឧបសង្កមិត្វា មហាបជាបតឹ គោតមឹ ឯតទវោច សចេ ខោ ត្វំ គោតមិ អដ្ឋ គរុធម្មេ បដិគ្គណ្ហេយ្យាសិ សាវ តេ ភវិស្សតិ ឧបសម្បទា វស្សសតុបសម្បន្នាយ ភិក្ខុនិយា តទហុបសម្បន្នស្ស ភិក្ខុនោ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ កាតព្វំ

## វិនយបិដក ចុល្លវគ្គ

ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីមិនត្រូវជេរ មិនត្រូវប្រទេចភិក្ខុ ដោយបរិយាយណាមួយឡើយ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ តាំងពីថ្ងៃ ( ដែលបានឧបសម្បទានេះទៅ ) ភិក្ខុនីត្រូវតែស្តាប់បង្គាប់ភិក្ខុ ឯភិក្ខុមិនត្រូវស្តាប់បង្គាប់ភិក្ខុនីវិញទេ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ម្នាលអានន្ទ បើព្រះនាងមហាបជាបតីគោតមី ទទួលប្រតិបត្តិតាមគរុធម៌ទាំង ៨ នេះបាន ឧបសម្បទានោះ ចូរសម្រេច ដល់ព្រះនាងចុះ ។

( ១៨១ ) លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានរៀនគរុធម៌ទាំង ៨ ក្នុងសំណាក់ព្រះមានព្រះភាគ ( ចាំស្ទាត់ហើយ ) ក៏ចូលទៅរកព្រះនាងមហាបជាបតីគោតមី លុះចូលទៅដល់ហើយ ពោលពាក្យនេះនឹងព្រះនាងមហាបជាបតីគោតមីថា បពិត្រព្រះនាងគោតមី បើព្រះនាងទទួលប្រតិបត្តិតាមគរុធម៌ទាំង ៨ បាន ឧបសម្បទានោះ ទើបបានសម្រេចដល់ព្រះនាង ( ឯគរុធម៌ទាំង ៨ នោះគឺ ) ភិក្ខុនីសូម្បីបានឧបសម្បទាមួយរយវស្សាហើយ ក៏ត្រូវតែថ្វាយបង្គំ ក្រោកទទួល ធ្វើអញ្ជលីកម្ម សាមីចិកម្ម ចំពោះភិក្ខុដែលទើបនឹងបួសក្នុងថ្ងៃនោះ ធម៌នេះ ភិក្ខុនីត្រូវ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

## ភិក្ខុនីខន្ធកេ អដ្ឋ គរុធម្មា

អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ន ភិក្ខុនិយា អភិក្ខុកេ អាវាសេ វស្សំ វសិតព្វំ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ អន្វឌ្ឍមាសំ ភិក្ខុនិយោ ភិក្ខុសង្ឃតោ ទ្វេ ធម្មា បច្ចាសីសិតព្វា ឧបោសថបុច្ឆកញ្ច ឱវាទូបសង្កមនញ្ច អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ វស្សំ វុដ្ឋាយ ភិក្ខុនិយា ឧភតោសង្ឃេ តីហិ ឋានេហិ បវារេតព្វំ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ គរុធម្មំ អជ្ឈាបន្នាយ ភិក្ខុនិយា ឧភតោសង្ឃេ បក្ខមានត្តំ ចរិតព្វំ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ សិក្ខមានាយ ឧភតោសង្ឃេ ឧបសម្បទា បរិយេសិតព្វា អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ន ភិក្ខុនិយា

## ភិក្ខុនីខន្ធកៈ គរុធម៌ ៨

ធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីមិនត្រូវនៅចាំវស្សាក្នុងអាវាសដែលគ្មានភិក្ខុទេ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីត្រូវប្រាថ្នាធម៌ពីរប្រការ គឺ សួរបាតិមោក្ខ ចូលទៅស្តាប់ឱវាទ អំពីសំណាក់ភិក្ខុសង្ឃរាល់កន្លះខែ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីនៅចាំវស្សារួចហើយត្រូវបវារណាក្នុងសំណាក់សង្ឃទាំង ២ ពួក ដោយស្ថានទាំង ៣ គឺឃើញក្តី ឮក្តី រង្កៀសក្តី ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីត្រូវគរុកាបត្តិហើយ គប្បីប្រព្រឹត្តបក្ខមានត្តក្នុងសំណាក់សង្ឃទាំង ២ ពួក ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីត្រូវជួយស្វែងរកឧបសម្បទា ក្នុងសំណាក់សង្ឃទាំង ២ ពួក ដល់សិក្ខមានាដែលបានសិក្សាសិក្ខាក្នុងធម៌ទាំង ៦ ប្រការគ្រប់ ២ ឆ្នាំហើយ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ភិក្ខុនីមិន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កេនចិ បរិយាយេន ភិក្ខុ អក្កោសិតព្វោ បរិភាសិតព្វោ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ អជ្ជតគ្គេ ឱវដោ ភិក្ខុនីនំ ភិក្ខូសុ វចនបថោ អនោវដោ ភិក្ខូនំ ភិក្ខុនីសុ វចនបថោ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ សចេ ខោ ត្វំ គោតមិ ឥមេ អដ្ឋ គរុធម្មេ បដិគ្គណ្ហេយ្យាសិ សាវ តេ ភវិស្សតិ ឧបសម្បទាតិ ។ សេយ្យថាបិ ភន្តេ អានន្ទ ឥត្ថី វា បុរិសោ វា ទហរោ យុវា មណ្ឌនជាតិកោ សីសំនហាតោ ឧប្បលមាលំ វា វស្សិកមាលំ វា អធិមុត្តកមាលំ វា[១] លភិត្វា ឧភោហិ ហត្ថេហិ បដិគ្គហេត្វា ឧត្តមង្គេ សិរស្មិ បតិដ្ឋាបេយ្យ ឯវមេវ ខោ អហំ ភន្តេ អានន្ទ ឥមេ អដ្ឋ គរុធម្មេ បដិគ្គណ្ហាមិ យាវជីវំ អនតិក្កមនីយេតិ ។

(១៨២) អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា

---

១ ឱ. ម. អតិមុត្តកមាលំ វា ។

ត្រូវដែរ មិនត្រូវប្រទេចភិក្ខុដោយបរិយាយណាមួយឡើយ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ តាំងពីថ្ងៃ (ដែលបានឧបសម្បទានេះទៅ) ភិក្ខុនីត្រូវស្តាប់បង្គាប់ភិក្ខុ ឯភិក្ខុមិនត្រូវស្តាប់បង្គាប់ភិក្ខុនីវិញទេ ធម៌នេះភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ បពិត្រព្រះនាងគោតមី បើព្រះនាងទទួលប្រព្រឹត្តគរុធម៌ទាំង ៨ នេះបាន ឧបសម្បទានោះ នឹងសម្រេចដល់ព្រះនាងមិនខាន ។ ព្រះនាងមហាបជាបតីគោតមីឆ្លើយតបថា បពិត្រព្រះអានន្ទដ៏ចំរើន ស្ត្រីឬបុរសនៅក្រមុំកំឡោះ តែងចូលចិត្តស្អិតស្អាងខ្លួន សិតសក់ស្អាតហើយ បានកម្រងផ្កាឧប្បលក្តី ផ្កាម្លិះក្តី ផ្កាដែលមានក្លិនក្រអូបណាស់ក្តី ហើយទទួលយកដោយដៃទាំងពីរ តម្កល់ទុកលើអវយវៈដ៏ឧត្តម គឺ ត្បូង យ៉ាងណាមិញ បពិត្រព្រះអានន្ទដ៏ចំរើន ខ្ញុំនឹងទទួលប្រតិបត្តិតាមគរុធម៌ទាំង ៨ នេះ (ដោយសេចក្តីពេញចិត្ត) ហើយមិនប្រព្រឹត្តកន្លង ដរាបអស់ជីវិត ដូច្នោះដែរ ។

[១៨២] លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ

## ភិក្ខុនីខន្ធកំ ព្រហ្មចរិយំ អចិរដ្ឋិតិកំ

ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច បដិគ្គហិតា ភន្តេ មហាបជាបតិយា គោតមិយា អដ្ឋ គរុធម្មា ឧបសម្បន្នា ភគវតោ មាតុច្ឆាតិ[១] ។ សចេ បនានន្ទ[២] នាលភិស្ស មាតុគាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជំ ចិរដ្ឋិតិកំ អានន្ទ ព្រហ្មចរិយំ អភវិស្ស វស្សសហស្សំ សទ្ធម្មោ តិដ្ឋេយ្យ យតោ ច ខោ អានន្ទ មាតុគាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិតោ ន ទានិ អានន្ទ ព្រហ្មចរិយំ ចិរដ្ឋិតិកំ ភវិស្សតិ[៣] បញ្ចេវ ទានិ អានន្ទ វស្សសតានិ សទ្ធម្មោ ឋស្សតិ សេយ្យថាបិ អានន្ទ យានិ កានិចិ កុលានិ ពហុត្ថិកានិ[៤] អប្បបុរិសកានិ តានិ សុប្បធំសិយានិ ហោន្តិ ចោរេហិ កុម្ភថេនកេហិ ឯវមេវ ខោ អានន្ទ យស្មឹ ធម្មវិនយេ លភតិ មាតុគាមោ អគារស្មា អនគារិយំ បព្វជ្ជំ ន តំ ព្រហ្មចរិយំ ចិរដ្ឋិតិកំ

---

១ មាតុច្ឆាយាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២. ឱ. ម. សចេ អានន្ទ ។ ៣ ឯត្ថន្តរេ ឥទានិ អានន្ទ វស្សសហស្សានិ សទ្ធម្មោ តិដ្ឋេយ្យាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ៤ ឱ. ម. ពហុត្ថិកានិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន

## ភិក្ខុនីខន្ធកៈ ព្រហ្មចារ្យមិនបានតាំងនៅយូរអង្វែង

ហើយគង់ក្នុងទីដ៏សមគួរ ៗ ព្រះអានន្ទមានអាយុ លុះគង់ក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន គរុធម៌ទាំង ៨ យ៉ាង ព្រះនាងមហាបជាបតីគោតមី បានទទួលហើយ ព្រះមាតុច្ឆានៃព្រះមានព្រះភាគ បានឧបសម្បទារួចហើយ ៗ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលអានន្ទ បើប្រសិនណាជាមាតុគ្រាម មិនបានចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយទេ ម្នាលអានន្ទ ព្រហ្មចារ្យនឹងបានតាំងនៅជាអង្វែង ព្រះសទ្ធម្មគឺអរហត្តផល ក៏នឹងបានតាំងនៅអស់ ១ ពាន់ឆ្នាំ ម្នាលអានន្ទ តែកាលណាមាតុគ្រាមចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ ម្នាលអានន្ទ ឥឡូវនេះ ព្រហ្មចារ្យមិនបានតាំងនៅយូរអង្វែងទេ ម្នាលអានន្ទ ឥឡូវនេះ ព្រះសទ្ធម្មនឹងឋិតនៅបានត្រឹមតែប្រាំរយឆ្នាំវិញ ម្នាលអានន្ទ មាតុគ្រាមបានចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងធម្មវិ-ន័យគឺព្រហ្មចារ្យណា ព្រហ្មចារ្យនោះ មិនបានតាំងនៅយូរអង្វែងទេ ម្នាលអានន្ទ ប្រៀបដូចត្រកូលទាំងឡាយណានីមួយ ដែលមានស្ត្រីច្រើនមានប្រុសតិច ត្រកូលទាំងនោះ ពួកចោរលួចភ្ជួរឆ្នាំង ក៏អាចចូលមកបំផ្លាញបានដោយងាយ ម្នាលអានន្ទ មាតុគ្រាមបានចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ គឺព្រហ្មចារ្យណា ព្រហ្មចារ្យនោះ មិនតាំងនៅយូរអង្វែងទេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ហោតិ សេយ្យថាបិ អានន្ទ សម្បន្នេ សាលិក្ខេត្តេ សេតដ្ឋិកា នាម រោគជាតិ និបតតិ ឯវំ តំ សាលិក្ខេត្តំ ន ចិរដ្ឋិតិកំ ហោតិ ឯវមេវ ខោ អានន្ទ យស្មឹ ធម្មវិនយេ លភតិ មាតុគ្គាមោ អគារស្មា អនគារិយំ បព្វជ្ជំ ន តំ ព្រហ្មចរិយំ ចិរដ្ឋិតិកំ ហោតិ សេយ្យថាបិ អានន្ទ សម្បន្នេ ឧច្ឆុក្ខេត្តេ មញ្ជេដ្ឋិកា នាម រោគជាតិ និបតតិ ឯវំ តំ ឧច្ឆុក្ខេត្តំ ន ចិរដ្ឋិតិកំ ហោតិ ឯវមេវ ខោ អានន្ទ យស្មឹ ធម្មវិនយេ លភតិ មាតុគ្គាមោ អគារស្មា អនគារិយំ បព្វជ្ជំ ន តំ ព្រហ្មចរិយំ ចរដ្ឋិតិកំ ហោតិ សេយ្យថាបិ អានន្ទ បុរិសោ មហតោ តឡាកស្ស បដិកច្ចេវ អាឡឹ(១) ពន្ធេយ្យ យាវទេវ ឧទកស្ស អនតិក្កមនាយ ឯវមេវ ខោ អានន្ទ មយា បដិកច្ចេវ ភិក្ខុនីនំ អដ្ឋ គរុធម្មា បញ្ញត្តា យាវជីវំ អនតិក្កមនីយាតិ ។

ភិក្ខុនីនំ អដ្ឋ គរុធម្មា និដ្ឋិតា ។

---

១ ឱ. ម. អាឡឹ ។

ម្នាលអានន្ទ ប្រៀបដូចជារោគជាតិ ឈ្មោះសេតដ្ឋិកា (គ្រាប) ធ្លាក់ចុះក្នុងស្រែស្រូវណា ដែលកំពុងតែលូតលាស់ល្អ ស្រែស្រូវនោះ មិនបានតាំងនៅយូរអង្វែង ដោយប្រការដូច្នេះ ម្នាលអានន្ទ មាតុគ្រាម បានចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងធម្មវិន័យ គឺព្រហ្មចារ្យណា ព្រហ្មចារ្យនោះ មិនបានតាំងនៅយូរអង្វែងទេ ម្នាលអានន្ទ ប្រៀបដូចរោគជាតិឈ្មោះមញ្ជេដ្ឋិកា (ដង្កូវគ្រាប) ធ្លាក់ចុះ ក្នុងច្បារអំពៅណា ដែលកំពុងតែលូតលាស់ល្អ ច្បារអំពៅនោះ មិនបានតាំងនៅអង្វែង ដោយប្រការដូច្នេះ ម្នាលអានន្ទ គរុធម៌ ៨ ប្រការ ដែលតថាគតបានបញ្ញត្តហើយ ចំពោះភិក្ខុនីជាតម្បូង ដើម្បីមិនឲ្យ(ភិក្ខុនី)ប្រព្រឹត្តកន្លងដរាបដល់អស់ជីវិត ម្នាលអានន្ទ ប្រៀបដូចជាបុរសប្រញាប់លើកទំនប់ទប់ទឹកស្រះដ៏ធំ ដើម្បីនឹងទប់ទឹកមិនឲ្យហូរចេញទៅជាដរាប ។

ចប់ គរុធម៌ទាំង ៨ របស់ពួកភិក្ខុនី ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៨៣) អថខោ មហាបជាបតី គោតមី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច កថាហំ ភន្តេ ឥមាសុ សាកិយានីសុ បដិបជ្ជាមីតិ ។ អថខោ ភគវា មហាបជាបតឹ គោតមឹ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ មហាបជាបតី គោតមី ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ភិក្ខូហិ ភិក្ខុនិយោ ឧបសម្បាទេតុន្តិ ។

(១៨៤) អថខោ តា ភិក្ខុនិយោ មហាបជាបតឹ គោតមឹ ឯតទវោចុំ អយ្យា អនុបសម្បន្នា មយញ្ចម្ហា[១] ឧបសម្បន្នា ឯវំ ហិ ភគវតា បញ្ញត្តំ ភិក្ខូហិ ភិក្ខុនិយោ

---

១ ឱ. មយម្ហា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។ 

## ភិក្ខុនីខន្ធកៈ រឿងព្រះនាងមហាបជាបតីគោតមី និងការសូមពរ

(១៨៣) លំដាប់នោះ ព្រះនាងមហាបជាបតីគោតមី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចក៏គង់ក្នុងទីសមគួរ ។ លុះព្រះនាងមហាបជាបតីគោតមី គង់ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលពាក្យនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងប្រតិបត្តិដូចម្តេច ក្នុងនាងសាកិយានីទាំងនេះ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ពន្យល់ព្រះនាងមហាបជាបតីគោតមីឲ្យឃើញតាម ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ។ ឯព្រះនាងមហាបជាបតីគោតមី ដែលព្រះមានព្រះភាគបានពន្យល់ ឲ្យឃើញតាម ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថារួច ក៏ក្រាបថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថាត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយឲ្យឧបសម្បទាដល់ពួកភិក្ខុនីបាន ។

(១៨៤) លំដាប់នោះ ភិក្ខុនីទាំងនោះ បាននិយាយពាក្យនេះនឹងព្រះនាងមហាបជាបតីគោតមីថា ព្រះនាងជាម្ចាស់ ជាអនុបសម្បន្នា (មិនបានឧបសម្បទាទេ) យើងខ្ញុំទាំងឡាយ ទើបជាឧបសម្បន្នា (បានឧបសម្បទា) ដ្បិតព្រះមានព្រះភាគបានទ្រង់បញ្ញត្តដូច្នេះថា ភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



ឧបសម្បាទេតព្វាតិ ។ អថខោ មហាបជាបតី គោតមី យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ មហាបជាបតី គោតមី អាយស្មន្តំ អានន្ទំ ឯតទវោច ឥមា មំ ភន្តេ អានន្ទ ភិក្ខុនិយោ ឯវមាហំសុ អយ្យា អនុបសម្បន្នា មយញ្ច ឧបសម្បន្នា ឯវំ ហិ ភគវតា បញ្ញត្តំ ភិក្ខូហិ ភិក្ខុនិយោ ឧបសម្បាទេតព្វាតិ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច មហាបជាបតី ភន្តេ គោតមី ឯវមាហ ឥមា មំ ភន្តេ អានន្ទ ភិក្ខុនិយោ ឯវមាហំសុ អយ្យា អនុបសម្បន្នា មយញ្ច ឧបសម្បន្នា ឯវំ ហិ ភគវតា បញ្ញត្តំ ភិក្ខូហិ ភិក្ខុនិយោ ឧបសម្បាទេតព្វាតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន

## វិនយបិដក ចុល្លវគ្គ

ត្រូវឲ្យឧបសម្បទាដល់ភិក្ខុនីទាំងឡាយ ។ គ្រានោះ ព្រះនាងមហាបជា-បតីគោតមី ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះអានន្ទមានអាយុ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះនាងមហាប-ជាបតីគោតមី អង្គុយក្នុងទីសមគួរហើយ បាននិយាយពាក្យនេះនឹងព្រះអានន្ទមានអាយុថា បពិត្រព្រះអានន្ទដ៏ចម្រើន ភិក្ខុនីទាំងនេះ នាំគ្នាមកនិយាយនឹងខ្ញុំ យ៉ាងនេះថា ព្រះនាងជាម្ចាស់ ជាអនុបសម្បន្នា យើងខ្ញុំទាំងឡាយ ទើបជាឧបសម្បន្នា ដ្បិតព្រះមានព្រះភាគ បានទ្រង់បញ្ញត្តដូច្នេះថា ភិក្ខុទាំងឡាយ ត្រូវឲ្យឧបសម្បទាដល់ពួកភិក្ខុនី ។ ព្រះអានន្ទមានអាយុ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ ព្រះអានន្ទមានអាយុ លុះគង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតីគោតមី បានមកនិយាយនឹងខ្ញុំព្រះអង្គ យ៉ាងនេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ភិក្ខុនីទាំងនេះ មកនិយាយនឹងខ្ញុំថា ព្រះនាងជាម្ចាស់ ជាអនុបសម្បន្នា យើងខ្ញុំទាំងឡាយ ទើបជាឧបសម្បន្នា ដ្បិតព្រះមានព្រះភាគ ទ្រង់បានបញ្ញត្តដូច្នេះថា ភិក្ខុទាំងឡាយ ត្រូវឲ្យឧបសម្បទា ដល់ពួកភិក្ខុនី ។

## ភិក្ខុនីខន្ធកំ មហាបជាបតីគោតមីវត្ថុ វរយាចនា

យទគ្គេន អានន្ទ មហាបជាបតិយា គោតមិយា អដ្ឋ
គរុធម្មា បដិគ្គហិតា តទេវស្សា ឧបសម្បន្នាតិ ។

(១៨៤) អថខោ មហាបជាបតី គោតមី យេនាយស្មា
អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ
អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ
មហាបជាបតី គោតមី អាយស្មន្តំ អានន្ទំ ឯតទវោច
ឯកាហំ ភន្តេ អានន្ទ ភគវន្តំ វរំ យាចាមិ សាធុ ភន្តេ
ភគវា អនុជានេយ្យ ភិក្ខូនញ្ច ភិក្ខុនីនញ្ច យថាវុឌ្ឍំ
អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មន្តិ ។ អថខោ
អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្ក-
មិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ
និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច
មហាបជាបតី ភន្តេ គោតមី ឯវមាហ ឯកាហំ ភន្តេ

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលអានន្ទ គរុធម៌ទាំង ៨ យ៉ាង ដែលព្រះនាងមហាបជាបតីគោតមីបានទទួលហើយ ដោយចំណែកណា ចំណែកនោះឯង ជាឧបសម្បទារបស់ព្រះនាងមហាបជាបតីគោតមីនោះ ។

(១៨៥) គ្រានោះ ព្រះនាងមហាបជាបតីគោតមី ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះអានន្ទមានអាយុ ហើយឈរក្នុងទីដ៏សមគួរ ។ ព្រះនាងមហាបជាបតីគោតមី លុះឈរក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះ នឹងព្រះអានន្ទមានអាយុថា បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំម្ចាស់តែម្នាក់ឯង នឹងសូមពរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់សូមអង្វរ សូមព្រះមានព្រះភាគ ទ្រង់អនុញ្ញាតការថ្វាយបង្គំ ការក្រោកទទួល ការធ្វើអញ្ជលីនិងសាមីចិកម្ម ដល់ពួកភិក្ខុផង ដល់ពួកភិក្ខុនីផង តាមលំដាប់វស្សាចាស់ខ្ចី ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំចំពោះព្រះមានព្រះភាគ រួចឈរក្នុងទីដ៏សមគួរ ។ ព្រះអានន្ទមានអាយុ លុះឈរក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតីគោតមី ពោល(នឹងខ្ញុំព្រះអង្គ) យ៉ាងនេះថា បពិត្រព្រះអានន្ទដ៏ចម្រើន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អានន្ទ ភគវន្តំ វំ យាចាមិ សាធុ ភន្តេ ភគវា អនុជានេយ្យ ភិក្ខូនញ្ច ភិក្ខុនីនញ្ច យថាវុឌ្ឍំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មន្តិ ។ អដ្ឋានមេតំ អានន្ទ អនវកាសោ យំ តថាគតោ អនុជានេយ្យ មាតុគាមស្ស អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ ឥមេ ហិ នាម អានន្ទ អញ្ញតិត្ថិយា ទុរក្ខាតធម្មា មាតុគាមស្ស អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ ន ករិស្សន្តិ កិមង្គំ បន តថាគតោ អនុជានិស្សតិ មាតុគាមស្ស អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មន្តិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ន ភិក្ខវេ មាតុគាមស្ស អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ កាតព្វំ យោ ករេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(១៨៦) អថខោ មហាបជាបតី គោតមី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា

ខ្ញុំម្ចាស់តែម្នាក់ឯង នឹងសូមពរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់សូមអង្វរ សូមព្រះមានព្រះភាគ ទ្រង់អនុញ្ញាត នូវការថ្វាយបង្គំ ការក្រោកទទួល ការធ្វើអញ្ជលី និងសាមីចិកម្ម ដល់ពួកភិក្ខុផង ដល់ពួកភិក្ខុនីផង តាមលំដាប់វស្សាចាស់ខ្ចី ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលអានន្ទ ការសូមនេះ មិនមែនជាហេតុជាបច្ច័យទេ ត្រង់ពាក្យដែលថា ឲ្យតថាគតអនុញ្ញាត នូវការថ្វាយបង្គំ ការក្រោកទទួល ការធ្វើអញ្ជលី និងសាមីចិកម្ម ដល់មាតុគ្រាម (នោះ) ម្នាលអានន្ទ អម្បាលដូចជាពួកតិរ្ថិយដទៃអស់នេះ ដែលជាអ្នកពោលធម៌អាក្រក់ ម្តេចគង់តែមិនធ្វើ នូវការថ្វាយបង្គំ ការក្រោកទទួល ការធ្វើអញ្ជលី និងសាមីចិកម្ម ចំពោះមា-តុគ្រាមដែរ ចំណង់បើតថាគត នឹងអនុញ្ញាត នូវការថ្វាយបង្គំ ការក្រោកទទួល ការធ្វើអញ្ជលី និងសាមីចិកម្ម ដល់មាតុគ្រាម ដូចម្តេចបាន ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើនូវធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើ នូវការថ្វាយបង្គំ ការក្រោកទទួល ការធ្វើអញ្ជលី និងសាមីចិកម្ម ចំពោះមាតុគ្រាមឡើយ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ ។

[១៨៦] គ្រានោះ ព្រះនាងមហាបជាបតីគោតមី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំ រួចគង់ក្នុងទី

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

### ភិក្ខុនីខន្ធកំ មហាបជាបតីគោតមីវត្ថុ វិយាបនា

ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច យានិ តានិ ភន្តេ ភិក្ខុនីនំ សិក្ខាបទានិ ភិក្ខូហិ សាធារណានិ កថំ មយំ ភន្តេ តេសុ សិក្ខាបទេសុ បដិបជ្ជាមាតិ ។ យានិ តានិ គោតមិ ភិក្ខុនីនំ សិក្ខាបទានិ ភិក្ខូហិ សាធារណានិ យថា ភិក្ខូ សិក្ខន្តិ តថា តេសុ សិក្ខាបទេសុ សិក្ខថាតិ ។ យានិ បន តានិ ភន្តេ ភិក្ខុនីនំ សិក្ខាបទានិ ភិក្ខូហិ អសាធារណានិ កថំ មយំ ភន្តេ តេសុ សិក្ខាបទេសុ បដិបជ្ជាមាតិ ។ យានិ តានិ គោតមិ ភិក្ខុនីនំ សិក្ខាបទានិ ភិក្ខូហិ អសាធារណានិ យថាបញ្ញត្តេសុ សិក្ខាបទេសុ សិក្ខថាតិ ។

(១៨៧) អថខោ មហាបជាបតី គោតមី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា

ដ៏សមគួរ ។ លុះព្រះនាងមហាបជាបតីគោតមី គង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏-ចម្រើន សិក្ខាបទទាំងឡាយណា ជារបស់ពួកភិក្ខុនី ដែលទូទៅដល់ពួកភិក្ខុផង តើខ្ញុំម្ចាស់នឹងប្រតិបត្តិក្នុងសិក្ខាបទទាំងនោះដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រះនាងគោតមី សិក្ខាបទទាំងឡាយណា ជារបស់ពួកភិក្ខុនី ដែលទូទៅដល់ពួកភិក្ខុផង ពួកភិក្ខុសិក្សាយ៉ាងណា ពួកភិក្ខុនីក៏ត្រូវសិក្សាក្នុងសិក្ខាបទទាំងនោះ យ៉ាងនោះដែរ ។ ព្រះនាងមហាបជា-បតីគោតមី ក្រាបបង្គំទូលសួរទៀតថា បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត សិក្ខាបទទាំងឡាយណា សម្រាប់ពួកភិក្ខុនី មិនទូទៅដល់ពួកភិក្ខុផង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់នឹងប្រតិបត្តិក្នុងសិក្ខាបទទាំងនោះ ដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រះនាងគោតមី សិក្ខាបទទាំងឡាយណា សម្រាប់ភិក្ខុនី មិនទូទៅដល់ពួកភិក្ខុផង ពួកភិក្ខុនីត្រូវសិក្សាក្នុងសិក្ខា-បទទាំងឡាយ ដូចតថាគតបានបញ្ញត្តទុកមកហើយចុះ ។

[១៨៧] គ្រានោះ ព្រះនាងមហាបជាបតីគោតមី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំចំពោះព្រះមាន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច សាធុ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកា(១) វូបកដ្ឋា អប្បមត្តា អាតាបិនី បហិតត្តា វិហរេយ្យន្តិ ។ យេ ខោ ត្វំ គោតមិ ធម្មេ ជានេយ្យាសិ ឥមេ ធម្មា សរាគាយ សំវត្តន្តិ នោ វិរាគាយ សញ្ញោគាយ សំវត្តន្តិ នោ វិសញ្ញោគាយ អាចយាយ សំវត្តន្តិ នោ អបចយាយ មហិច្ឆតាយ សំវត្តន្តិ នោ អប្បិច្ឆតាយ អសន្តុដ្ឋិយា សំវត្តន្តិ នោ សន្តុដ្ឋិយា សង្គណិកាយ សំវត្តន្តិ នោ បវិវេកាយ កោសជ្ជាយ សំវត្តន្តិ នោ

---

១ ម. ឯកាកិ សព្វេ ឥត្ថិ ។

## វិនយបិដក ចុល្លវគ្គ

ព្រះភាគ រួចគង់ក្នុងទីសមគួរ ។ ព្រះនាងមហាបជាបតីគោតមី លុះគង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ ខ្ញុំព្រះអង្គតែម្នាក់ឯង ចៀសចេញអំពីពួក (ហើយទៅនៅក្នុងទីស្ងាត់) មិនមានសេចក្ដីប្រមាទ មានតែសេចក្ដីព្យាយាមកម្ដៅកិលេស(ឲ្យរីងស្ងួត) មានចិត្តបញ្ជូនទៅក្នុងកម្មដ្ឋាន ព្រោះស្ដាប់ធម៌ណារបស់ព្រះមានព្រះភាគ សូមព្រះមានព្រះភាគទ្រង់សម្ដែងធម៌ (នោះ) ដោយសង្ខេប (ដល់ខ្ញុំម្ចាស់) ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រះនាងគោតមី ព្រះនាងគប្បីដឹងនូវធម៌ទាំងឡាយណាថា ធម៌ទាំងនេះ ប្រព្រឹត្តទៅដើម្បីការប្រកបដោយតម្រេក មិនប្រព្រឹត្តទៅដើម្បីការប្រាសចាកតម្រេក ប្រព្រឹត្តទៅដើម្បីការប្រកបក្នុងវដ្ដៈ មិនប្រព្រឹត្តទៅដើម្បីការប្រាសចាកការប្រកបក្នុងវដ្ដៈ ប្រព្រឹត្តទៅដើម្បីការសន្សំកិលេស-វដ្ដៈ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកការសន្សំកិលេសវដ្ដៈ ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាច្រើន មិនប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាតិច ប្រព្រឹត្តទៅដើម្បីសេចក្ដីមិនសន្ដោស មិនប្រព្រឹត្តទៅដើម្បីសេចក្ដីសន្ដោស ប្រព្រឹត្តទៅដើម្បីការច្រឡូកច្រឡំដោយពួក មិនប្រព្រឹត្តទៅដើម្បីការស្ងប់ស្ងាត់ចាកពួក ប្រព្រឹត្តទៅដើម្បីសេចក្ដីខ្ជិលច្រអូស មិនប្រព្រឹត្តទៅដើម្បីប្រារព្ធ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



វីរិយារម្ភាយ ទុព្ភរតាយ សំវត្តន្តិ នោ សុភរតាយ ឯកំ-
សេន គោតមិ ធារេយ្យាសិ នេសោ ធម្មោ នេសោ វិន-
យោ នេតំ សត្ថុសាសនន្តិ យេ ច ខោ ត្វំ គោតមិ
ធម្មេ ជានេយ្យាសិ ឥមេ ធម្មា វិរាគាយ សំវត្តន្តិ នោ
សរាគាយ វិសញ្ញោគាយ សំវត្តន្តិ នោ សញ្ញោគាយ
អបចយាយ សំវត្តន្តិ នោ អាចយាយ អប្បិច្ឆតាយ
សំវត្តន្តិ នោ មហិច្ឆតាយ សន្តុដ្ឋិយា សំវត្តន្តិ នោ អ-
សន្តុដ្ឋិយា បវិវេកាយ សំវត្តន្តិ នោ សង្គណិកាយ វីរិ-
យារម្ភាយ សំវត្តន្តិ នោ កោសជ្ជាយ សុភរតាយ សំ-
វត្តន្តិ នោ ទុព្ភរតាយ ឯកំសេន គោតមិ ធារេយ្យាសិ
ឯសោ ធម្មោ ឯសោ វិនយោ ឯតំ សត្ថុសាសនន្តិ ។

## ភិក្ខុនីវគ្គ: លក្ខណៈនៃការវិនិច្ឆ័យធម្មវិន័យ

សេចក្តីព្យាយាម ប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយក្រ មិនប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយងាយ ម្នាលព្រះនាងគោតមី ព្រះនាងគប្បីចាំទុកដោយចំណែកមួយថា នេះមិនមែនជាធម៌ នេះមិនមែនជាវិន័យ នេះមិនមែនជាពាក្យប្រដៅរបស់ព្រះសាស្តាទេ ម្នាលព្រះនាងគោតមី មួយវិញទៀត ព្រះនាងគប្បីដឹងនូវធម៌ណា ថា ធម៌ទាំងនេះ ប្រព្រឹត្តទៅដើម្បីការប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីការប្រកបដោយតម្រេក ប្រព្រឹត្តទៅដើម្បីការប្រាសចាកការប្រកបក្នុងវដ្តៈ មិនប្រព្រឹត្តទៅដើម្បីការប្រកបក្នុងវដ្តៈ ប្រព្រឹត្តទៅដើម្បីការមិនសន្សំកិលេសវដ្តៈ មិនប្រព្រឹត្តទៅដើម្បីការសន្សំកិលេសវដ្តៈ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច មិនប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាច្រើន ប្រព្រឹត្តទៅដើម្បីសេចក្តីសន្តោស មិនប្រព្រឹត្តទៅដើម្បីសេចក្តីមិនសន្តោស ប្រព្រឹត្តទៅដើម្បីការស្ងប់ស្ងាត់ចាកពួក មិនប្រព្រឹត្តទៅដើម្បីការច្រឡូកច្រឡំដោយពួក ប្រព្រឹត្តទៅដើម្បីការប្រារព្ធសេចក្តីព្យាយាម មិនប្រព្រឹត្តទៅដើម្បីសេចក្តីខ្ជិលច្រអូស ប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយងាយ មិនប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយក្រ ម្នាលព្រះនាងគោតមី ព្រះនាងគប្បីចាំទុក ដោយចំណែកមួយថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រដៅរបស់ព្រះសាស្តាហើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[១៨៨] តេន ខោ បន សមយេន ភិក្ខូ ភិក្ខុនីនំ បាតិមោក្ខំ ន ឧទ្ទិសន្តិ(១) ។ បេ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ ភិក្ខុនីនំ បាតិមោក្ខំ ឧទ្ទិសិតុន្តិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កេន នុ ខោ ភិក្ខុនីនំ បាតិមោក្ខំ ឧទ្ទិសិតព្វន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ អនុជានាមិ ភិក្ខវេ ភិក្ខូហិ ភិក្ខុនីនំ បាតិមោក្ខំ ឧទ្ទិសិតុន្តិ ។

[១៨៩] តេន ខោ បន សមយេន ភិក្ខូ ភិក្ខុនូបស្សយំ ឧបសង្កមិត្វា ភិក្ខុនីនំ បាតិមោក្ខំ ឧទ្ទិសន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ជាយាយោ ឥមា ឥមេសំ ជារិយោ ឥមា ឥមេសំ ឥទានិ ឥមេ ឥមាហិ សទ្ធឹ អភិរមិស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ ន ភិក្ខវេ ភិក្ខូហិ ភិក្ខុនីនំ បាតិមោក្ខំ ឧទ្ទិសិតព្វំ យោ ឧទ្ទិសេយ្យ

---

១ ឱ. ម. ពោត្ថកេសុ តេន ខោ បន សមយេន ភិក្ខុនីនំ បាតិមោក្ខំ ន ឧទ្ទិស្សិយតីតិ រូបំ អាគតំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

## វិនយបិដក ចុល្លវគ្គ

(១៨៨) សម័យនោះឯង ភិក្ខុទាំងឡាយមិនបានសម្តែងបាតិមោក្ខដល់ពួកភិក្ខុនី ។ បេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសម្តែងបាតិមោក្ខដល់ពួកភិក្ខុនី ។ គ្រានោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា អ្នកណាហ្ន៎ គួរសម្តែងបាតិមោក្ខដល់ពួកភិក្ខុនី ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយសម្តែងបាតិមោក្ខដល់ពួកភិក្ខុនី ។

(១៨៩) សម័យនោះឯង ភិក្ខុទាំងឡាយទៅកាន់លំនៅរបស់ភិក្ខុនី ហើយសម្តែងបាតិមោក្ខដល់ពួកភិក្ខុនី ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងនេះជាប្រពន្ធរបស់ភិក្ខុទាំងនេះ ភិក្ខុនីទាំងនេះជាសហាយរបស់ភិក្ខុទាំងនេះ ឥឡូវនេះ ភិក្ខុទាំងនេះមុខជានឹងត្រេកអរជាមួយនឹងភិក្ខុនីទាំងនេះ(ទៀត) ។ កាលដែលមនុស្សទាំងនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងនោះក៏បានឮច្បាស់ ។ លំដាប់នោះ ភិក្ខុទាំងនោះបានក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមិនត្រូវសម្តែងបាតិមោក្ខ ដល់ពួកភិក្ខុនីឡើយ ភិក្ខុណាសម្តែង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

## ភិក្ខុនីខន្ធកេ អាបត្តិប្បដិគ្គហណំ

អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ភិក្ខុនីហិ ភិក្ខុនីនំ បាតិមោក្ខំ ឧទ្ទិសិតុន្តិ ។ ភិក្ខុនិយោ ន ជានន្តិ ឯវំ(១) បាតិមោក្ខំ ឧទ្ទិសិតព្វន្តិ ។ បេ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ ភិក្ខូហិ ភិក្ខុនីនំ អាចិក្ខិតុំ ឯវំ បាតិមោក្ខំ ឧទ្ទិសេយ្យាថាតិ ។

(១៩០) តេន ខោ បន សមយេន ភិក្ខុនិយោ អាបត្តឹ ន បដិករោន្តិ ។ បេ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ភិក្ខុនិយា អាបត្តិ ន បដិកាតព្វា យា ន បដិករេយ្យ អាបត្តិ ទុក្កដស្សាតិ ។ ភិក្ខុនិយោ ន ជានន្តិ ឯវំបិ អាបត្តិ បដិកាតព្វាតិ ។ បេ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ ភិក្ខូហិ ភិក្ខុនីនំ អាចិក្ខិតុំ ឯវំ អាបត្តឹ បដិករេយ្យាថាតិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កេន នុ ខោ ភិក្ខុនីនំ អាបត្តិ បដិគ្គហេតព្វាតិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ ភិក្ខូហិ ភិក្ខុនីនំ អាបត្តឹ បដិគ្គហេតុន្តិ ។

---

១ ម. ឯវំបិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាទាន។


ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីសម្តែងបាតិមោក្ខដល់ភិក្ខុនីផងគ្នាចុះ ។ ភិក្ខុនីទាំងឡាយមិនបានដឹងថា ភិក្ខុនីត្រូវសម្តែងបាតិមោក្ខយ៉ាងនេះ ។ បេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រាប់ដល់ភិក្ខុនីថា នាងទាំងឡាយត្រូវសម្តែងបាតិមោក្ខយ៉ាងនេះ ។

[១៩០] ក្នុងសម័យនោះឯង ភិក្ខុនីទាំងឡាយមិនបានសម្តែងអាបត្តិចេញ ។ បេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនមែនមិនត្រូវសម្តែងអាបត្តិចេញទេ ភិក្ខុនីណាមិនសម្តែង ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីទាំងឡាយមិនបានដឹងថា ភិក្ខុនីត្រូវសម្តែងអាបត្តិយ៉ាងនេះ ។បេ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយប្រាប់ដល់ភិក្ខុនីថា នាងទាំងឡាយត្រូវសម្តែងអាបត្តិយ៉ាងនេះ ។ លំដាប់នោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា អ្នកណាហ្ន៎ គួរនឹងទទួលអាបត្តិ របស់ពួកភិក្ខុនី ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទទួលអាបត្តិរបស់ភិក្ខុនី ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[១៩១] តេន ខោ បន សមយេន ភិក្ខុនិយោ រថិកាយបិ ព្យូហេបិ សិង្ឃាដកេបិ ភិក្ខុំ បស្សិត្វា បត្តំ ភូមិយំ និក្ខិបិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា អាបត្តឹ បដិករោន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ជាយាយោ ឥមា ឥមេសំ ជារិយោ ឥមា ឥមេសំ រត្តឹ វិមានេត្វា ឥទានិ ខមាបេន្តីតិ ។ បេ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ភិក្ខូហិ ភិក្ខុនីនំ អាបត្តិ បដិគ្គហេតព្វា យោ បដិគ្គណ្ហេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ភិក្ខុនីហិ ភិក្ខុនីនំ អាបត្តឹ បដិគ្គហេតុន្តិ ។ ភិក្ខុនិយោ ន ជានន្តិ ឯវំបិ អាបត្តិ បដិគ្គហេតព្វាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ ភិក្ខូហិ ភិក្ខុនីនំ អាចិក្ខិតុំ ឯវំ អាបត្តឹ បដិគ្គណ្ហេយ្យាថាតិ ។

[១៩២] តេន ខោ បន សមយេន ភិក្ខូហិ[១] ភិក្ខុនីនំ កម្មំ ន ករីយតិ ។ បេ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ

១ ឱ. ម. ពោត្ថកេសុ ភិក្ខូហីតិ សទ្ទោ ន បញ្ញាយតិ ។

[១៩១] សម័យនោះ ភិក្ខុនីទាំងឡាយបានឃើញភិក្ខុ (កំពុងដើរ) ក្នុងច្រកហួតខ្លះ ក្នុងច្រកទាល់ខ្លះ ក្នុងផ្លូវបែកជាបីខ្លះ ក៏ដាក់បាត្រលើផែនដីហើយធ្វើចីពរឆៀងស្មាម្ខាង អង្គុយច្រហោងផ្គងអញ្ជលីសម្តែងអាបត្តិ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងនេះជាភរិយារបស់ភិក្ខុទាំងនេះ ភិក្ខុនីទាំងនេះជាសហាយរបស់ភិក្ខុទាំងនេះ ក្នុងវេលាយប់ប្រទូស្តគ្នា គឺរួមដំណេកជាមួយគ្នា ឥឡូវនេះមកខមាទោសនឹងគ្នា ។ បេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទទួលអាបត្តិរបស់ភិក្ខុនីទេ ភិក្ខុណាទទួល ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យតែភិក្ខុនីទទួលអាបត្តិរបស់ពួកភិក្ខុនីផងគ្នា ។ ភិក្ខុនីទាំងឡាយមិនបានដឹងថា ភិក្ខុនីត្រូវទទួលអាបត្តិយ៉ាងនេះ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រាប់ដល់ភិក្ខុនីទាំងឡាយថា នាងទាំងឡាយត្រូវទទួលអាបត្តិយ៉ាងនេះ ។

[១៩២] សម័យនោះឯង ភិក្ខុទាំងឡាយមិនបានធ្វើកម្ម (មានតជ្ជនីយកម្មជាដើម) ដល់ភិក្ខុនី ។ បេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

## ភិក្ខុនីខន្ធកេ ភិក្ខុនីនំ កម្មករណំ

ភិក្ខុនីនំ កម្មំ កាតុន្តិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កេន នុ ខោ ភិក្ខុនីនំ កម្មំ កាតព្វន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភិក្ខូហិ ភិក្ខុនីនំ កម្មំ កាតុន្តិ ។

(១៩៣) តេន ខោ បន សមយេន កតកម្មា ភិក្ខុនិយោ រថិយាយបិ ព្យូហេបិ សិង្ឃាដកេបិ ភិក្ខុំ បស្សិត្វា បត្តំ កុម្មិយំ និក្ខិបិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ខមាបេន្តិ ឯវំ នុន(១) ន កាតព្វន្តិ មញ្ញមានា ។ មនុស្សា តថេវ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ជាយាយោ ឥមា ឥមេសំ ជារិយោ ឥមា ឥមេសំ រត្តិំ វិមានេត្វា ឥទានិ ខមាបេន្តីតិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខូហិ ភិក្ខុនីនំ កម្មំ កាតព្វំ យោ ករេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ភិក្ខុនីហិ ភិក្ខុនីនំ កម្មំ កាតុន្តិ ។ ភិក្ខុនិយោ ន ជានន្តិ ឯវំ កម្មំ កាតព្វន្តិ ។

១ ឱ. នូន ។ ម. ននុ ។

## ភិក្ខុនីខន្ធកៈ ការធ្វើកម្មដល់ពួកភិក្ខុនី

តថាគតអនុញ្ញាតឲ្យធ្វើកម្មដល់ភិក្ខុនីទាំងឡាយ ។ លំដាប់នោះ ភិក្ខុទាំងឡាយក៏មានសេចក្តីត្រិះរិះដូច្នេះថា អ្នកណាហ្ន៎ គួរនឹងធ្វើកម្មដល់ភិក្ខុនី ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុធ្វើកម្មដល់ពួកភិក្ខុនី ។

(១៩៣) សម័យនោះឯង ពួកភិក្ខុនីដែលភិក្ខុបានធ្វើកម្មរួចហើយ លុះឃើញភិក្ខុ(កំពុងដើរ)ក្នុងច្រករហូតខ្លះ ក្នុងច្រកទាល់ខ្លះ ក្នុងផ្លូវបែកជាបីខ្លះ ក៏ដាក់បាត្រលើផែនដី ហើយធ្វើចីពរឆៀងស្មាម្ខាងអង្គុយច្រហោងផ្គងអញ្ជលីខមាទោសថា សូមលោកម្ចាស់ទាំងឡាយ សំគាល់ថា យើងលែងធ្វើយ៉ាងនេះទៀតហើយ ។ មនុស្សទាំងឡាយ (បានឃើញ) ដូច្នោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងនេះជាប្រពន្ធរបស់ភិក្ខុទាំងនេះ ភិក្ខុនីទាំងនេះជាសហាយរបស់ភិក្ខុទាំងនេះ ក្នុងពេលយប់ប្រទូស្តគ្នា គឺរួមដំណេកជាមួយគ្នា ឥឡូវនេះមកខមាទោសនឹងគ្នា ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើកម្មដល់ភិក្ខុនីឡើយ ភិក្ខុណាធ្វើ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីធ្វើកម្មដល់ភិក្ខុនីផងគ្នា ។ ភិក្ខុនីទាំងឡាយមិនបានដឹងថា ភិក្ខុនីត្រូវធ្វើកម្មយ៉ាងនេះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភិក្ខូហិ ភិក្ខុនីនំ អាចិក្ខិតុំ ឯវំ កម្មំ ករេយ្យាថាតិ ។

[១៩៤] តេន ខោ បន សមយេន ភិក្ខុនិយោ សង្ឃមជ្ឈេ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ន សក្កោន្តិ តំ(១) អធិករណំ វូបសមេតុំ ។ បេ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភិក្ខូហិ ភិក្ខុនីនំ អធិករណំ វូបសមេតុន្តិ ។

[១៩៥] តេន ខោ បន សមយេន ភិក្ខូ ភិក្ខុនីនំ អធិករណំ វូបសមេន្តិ ។ តស្មឹ ខោ បន អធិករណេ វិនិច្ឆយមានេ ទិស្សន្តិ ភិក្ខុនិយោ កម្មប្បត្តាយោបិ អាបត្តិគាមិនិយោបិ ។ ភិក្ខុនិយោ ឯវមាហំសុ សាធុ ភន្តេ អយ្យាវ ភិក្ខុនីនំ កម្មំ ករោន្តុ អយ្យាវ ភិក្ខុនីនំ អាបត្តឹ បដិគ្គណ្ហន្តុ ឯវំ ហិ ភគវតា បញ្ញត្តំ ភិក្ខូហិ ភិក្ខុនីនំ អធិករណំ វូបសមេតព្វន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ

---

១ ម. តមិំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុប្រាប់ដល់ភិក្ខុនីទាំងឡាយថា នាងទាំងឡាយត្រូវធ្វើកម្មយ៉ាងនេះ ។

(១៩៨) សម័យនោះឯង ភិក្ខុនីទាំងឡាយ បង្កហេតុឈ្លោះទាស់ទែងជជែកគ្នាកណ្តាលជំនុំសង្ឃ ពោលចាក់ដោតគ្នាដោយលំពែងគឺមាត់ មិនមានអ្នកណាអាចរម្ងាប់នូវអធិករណ៍នោះបានឡើយ ។ បេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុរម្ងាប់អធិករណ៍របស់ពួកភិក្ខុនី ។

(១៩៩) សម័យនោះឯង ភិក្ខុទាំងឡាយ តែងរម្ងាប់អធិករណ៍របស់ពួកភិក្ខុនី ។ កាលបើភិក្ខុបានវិនិច្ឆ័យអធិករណ៍នោះហើយ ភិក្ខុនីទាំងឡាយគួរដល់កម្មខ្លះ គួរដល់អាបត្តិខ្លះ ។ ភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ សូមលោកម្ចាស់ទាំងឡាយមេត្តាធ្វើកម្មដល់ភិក្ខុនីចុះ សូមលោកម្ចាស់ទទួលអាបត្តិរបស់ភិក្ខុនីចុះ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តយ៉ាងនេះថា ភិក្ខុត្រូវរម្ងាប់អធិករណ៍របស់ពួកភិក្ខុនី ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

## ភិក្ខុនីខន្ធកេ អាបត្តិប្បដិគ្គហណំ ឧប្បលវណ្ណាយ អន្តេវាសិនីវត្ថុ

ភិក្ខូហិ ភិក្ខុនីនំ កម្មំ អារោបេត្វា ភិក្ខុនីនំ និយ្យាតេតុំ ភិក្ខុនីហិ ភិក្ខុនីនំ កម្មំ កាតុំ ភិក្ខូហិ ភិក្ខុនីនំ អាបត្តឹ អារោបេត្វា ភិក្ខុនីនំ និយ្យាតេតុំ ភិក្ខុនីហិ ភិក្ខុនីនំ អាបត្តឹ បដិគ្គហេតុន្តិ ។

[១៩៦] តេន ខោ បន សមយេន ឧប្បលវណ្ណាយ ភិក្ខុនិយា អន្តេវាសិនី ភិក្ខុនី សត្ត វស្សានិ ភគវន្តំ អនុពន្ធា ហោតិ វិនយំ បរិយាបុណន្តី ។ តស្សា មុដ្ឋស្សតិនិយា គហិតោ គហិតោ មុស្សតិ ។ អស្សោសិ ខោ សា ភិក្ខុនី ភគវា កិរ សាវត្ថឹ គន្តុកាមោតិ ។ អថខោ តស្សា ភិក្ខុនិយា ឯតទហោសិ អហំ ខោ សត្ត វស្សានិ ភគវន្តំ អនុពន្ធី(១) វិនយំ បរិយាបុណន្តី តស្សា មេ មុដ្ឋស្សតិនិយា គហិតោ គហិតោ មុស្សតិ ទុក្ករំ ខោ បន មាតុគាមេន យាវជីវំ សត្ថារំ អនុពន្ធិតុំ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ អថខោ សា ភិក្ខុនី ភិក្ខុនីនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ

---

១ ឱ. អនុពទ្ធា ។ ម. អនុពន្ធា ។

## ភិក្ខុនីខន្ធកៈ ការទទួលអាបត្តិ និងរឿងភិក្ខុនីជាសិស្សរបស់ឧប្បលវណ្ណា

ឲ្យភិក្ខុលើកកម្មរបស់ពួកភិក្ខុនី ហើយប្រគល់ឲ្យភិក្ខុនី ឲ្យភិក្ខុនីធ្វើកម្មដល់ភិក្ខុនីផងគ្នា ឲ្យភិក្ខុលើកអាបត្តិរបស់ភិក្ខុនី ហើយប្រគល់ឲ្យភិក្ខុនីទទួលអាបត្តិរបស់ភិក្ខុនីផងគ្នា ។

(១៩៦) សម័យនោះឯង ភិក្ខុនីជាសិស្សរបស់ឧប្បលវណ្ណាភិក្ខុនី ទៅតាមព្រះមានព្រះភាគ រៀនវិន័យអស់ ៧ ឆ្នាំ ។ ភិក្ខុនីនោះច្រើនភ្លេចស្មារតី វិន័យដែលបានរៀនមកហើយ ក៏បេះតែភ្លេចទៅវិញ ។ ភិក្ខុនីនោះឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់មានបំណងនឹងស្តេចទៅ កាន់នគរសាវត្ថី ។ លំដាប់នោះ ភិក្ខុនីនោះក៏មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញនេះបានទៅតាមព្រះមានព្រះភាគ រៀនវិន័យអស់៧ឆ្នាំហើយ អាត្មាអញនេះជាមនុស្សភ្លេចច្រើន វិន័យដែលបានរៀនហើយ បេះតែភ្លេចទៅវិញ ធម្មតាមាតុគ្រាមនឹងដើរតាមព្រះសាស្តាអស់មួយជីវិត ក៏លំបាកពេកណាស់ បើដូច្នោះ អាត្មាអញនឹងប្រតិបត្តិយ៉ាងណា ។ លំដាប់នោះ ភិក្ខុនីនោះប្រាប់រឿងនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយដំណាលរឿងនុ៎ះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អារោចេសុំ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ ភិក្ខូហិ ភិក្ខុនីនំ វិនយំ វាចេតុន្តិ ។

## បឋមភាណវារំ ។

[១៩៧] អថខោ ភគវា វេសាលិយំ យថាភិរន្តំ វិហរិត្វា យេន សាវត្ថី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន សាវត្ថី តទវសរិ ។ តត្រ សុទំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ភិក្ខុនិយោ កទ្ទមោទកេន ឱសិញ្ចន្តិ អប្បេវនាម អម្ហេសុ សារជ្ជេយ្យុន្តិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ភិក្ខុនា ភិក្ខុនិយោ កទ្ទមោទកេន ឱសិញ្ចិតព្វា យោ ឱសិញ្ចេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ តស្ស ភិក្ខុនោ ទណ្ឌកម្មំ កាតុន្តិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កិន្នុ ខោ ទណ្ឌកម្មំ កាតព្វន្តិ ។

ប្រាប់ពួកភិក្ខុ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យពួកភិក្ខុបង្ហាញវិន័យដល់ពួកភិក្ខុនីបាន ។

ភាណវារៈ ទី ១ ។

[ ១៩៧ ] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងក្រុងវេសាលី គួរតាមពុទ្ធអធ្យាស្រ័យហើយ ក៏ស្តេចទៅកាន់ចារិកនគរសាវត្ថី កាលត្រាច់ទៅកាន់ចារិកតាមលំដាប់ ទ្រង់ស្តេចទៅកាន់នគរសាវត្ថីនោះ ។ មានសេចក្តីដំណាលថា ព្រះមានព្រះភាគទ្រង់គង់ ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបនគរសាវត្ថីនោះ ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសាចកក់នឹងទឹកទៅលើពួកភិក្ខុនី ដោយគិតថា ធ្វើដូចម្តេចហ្ន៎ នឹងបានពួកភិក្ខុនីត្រេកអរក្នុងពួកយើង ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសាចកក់នឹងទឹកទៅលើពួកភិក្ខុនីទេ ភិក្ខុណាសាច ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុសង្ឃ) ធ្វើទណ្ឌកម្មដល់ភិក្ខុនោះ ។ ភិក្ខុទាំងឡាយក៏មានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុសង្ឃត្រូវធ្វើទណ្ឌកម្មដូចម្តេចហ្ន៎ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕


តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អវន្ទិយោ សោ ភិក្ខវេ ភិក្ខុ ភិក្ខុនីសង្ឃេន កាតព្វោតិ ។

[១៩៨] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ កាយំ វិវរិត្វា ភិក្ខុនីនំ ទស្សេន្តិ ឩរុំ វិវរិត្វា ភិក្ខុនីនំ ទស្សេន្តិ អង្គជាតំ វិវរិត្វា ភិក្ខុនីនំ ទស្សេន្តិ ភិក្ខុនិយោ ឱភាសេន្តិ ភិក្ខុនីហិ សទ្ធឹ សម្បយោជេន្តិ អប្បេវនាម អម្ហេសុ សារជ្ជេយ្យុន្តិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ភិក្ខុនា កាយោ វិវរិត្វា ភិក្ខុនីនំ ទស្សេតព្វោ ន ឩរុ វិវរិត្វា ភិក្ខុនីនំ ទស្សេតព្វោ ន អង្គជាតំ វិវរិត្វា ភិក្ខុនីនំ ទស្សេតព្វំ ន ភិក្ខុនិយោ ឱភាសិតព្វា ន ភិក្ខុនីហិ សទ្ធឹ សម្បយោជេតព្វំ យោ សម្បយោជេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ តស្ស ភិក្ខុនោ ទណ្ឌកម្មំ កាតុន្តិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កិន្នុ ខោ ទណ្ឌកម្មំ កាតព្វន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អវន្ទិយោ សោ ភិក្ខវេ ភិក្ខុ ភិក្ខុនីសង្ឃេន កាតព្វោតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ផ្សាយ។


## ភិក្ខុនីខន្ធកៈ ការបង្ហាញកាយជាដើម ទណ្ឌកម្ម និង អវន្ទិយបុគ្គល

ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីសង្ឃគប្បីធ្វើភិក្ខុនោះឲ្យជាអវន្ទិយបុគ្គល (បុគ្គលដែលមិនគួរឲ្យភិក្ខុនីសំពះ) ។

[១៩៨] សម័យនោះ ពួកឆព្វគ្គិយភិក្ខុបើកកាយបង្ហាញពួកភិក្ខុនី លាតភ្លៅបង្ហាញពួកភិក្ខុនី បើកអង្គជាតបង្ហាញពួកភិក្ខុនី ចំអកចំអន់ពួកភិក្ខុនី (ដោយអសទ្ធម្ម) ផ្សំផ្គុំ (ពួកបុរសលេង) ជាមួយនឹងពួកភិក្ខុនីដោយគិតថា ធ្វើដូចម្តេច នឹងបានពួកភិក្ខុនីត្រេកអរក្នុងពួកយើង ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបើកកាយបង្ហាញពួកភិក្ខុនី មិនត្រូវលាតភ្លៅបង្ហាញពួកភិក្ខុនី មិនត្រូវបើកអង្គជាតបង្ហាញពួកភិក្ខុនី មិនត្រូវចំអកចំអន់ពួកភិក្ខុនី (ដោយអសទ្ធម្ម) មិនត្រូវផ្សំផ្គុំ (ពួកបុរសលេង) ជាមួយនឹងពួកភិក្ខុនីទេ ភិក្ខុណាផ្សំផ្គុំលេង ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុសង្ឃ) ធ្វើទណ្ឌកម្មដល់ភិក្ខុនោះ ។ លំដាប់នោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុសង្ឃត្រូវធ្វើទណ្ឌកម្មដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីសង្ឃគប្បីធ្វើភិក្ខុនោះឲ្យជាអវន្ទិយបុគ្គល ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(១៩៩) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ ភិក្ខូ កទ្ទមោទកេន ឱសិញ្ចន្តិ អប្បេវនាម អម្ហេសុ សារជ្ជេយ្យុន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ភិក្ខុនិយា ភិក្ខូ កទ្ទមោទកេន ឱសិញ្ចិតព្វា យា ឱសិញ្ចេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ តស្សា ភិក្ខុនិយា ទណ្ឌកម្មំ កាតុន្តិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កិន្នុ ខោ ទណ្ឌកម្មំ កាតព្វន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អាវរណំ កាតុន្តិ ។ អាវរណេ កតេ ន អាទិយន្តិ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឱវាទំ ឋបេតុន្តិ ។

(២០០) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ កាយំ វិវរិត្វា ភិក្ខូនំ ទស្សេន្តិ ថនំ វិវរិត្វា ភិក្ខូនំ ទស្សេន្តិ ឩរុំ វិវរិត្វា ភិក្ខូនំ ទស្សេន្តិ អង្គជាតំ វិវរិត្វា

## វិនយបិដក ចុល្លវគ្គ

(១៩៩) សម័យនោះឯង ឆព្វគ្គិយាភិក្ខុនី សាចកក់និងទឹកទៅលើពួកភិក្ខុ ដោយគិតថា ធ្វើដូចម្តេចហ្ន៎ នឹងបានពួកភិក្ខុត្រេកអរមករកពួកយើង ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវសាចកក់និងទឹកទៅលើពួកភិក្ខុទេ ភិក្ខុនីណាសាច ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុនីសង្ឃ) ធ្វើទណ្ឌកម្មដល់ភិក្ខុនីនោះ ។ គ្រានោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុនីសង្ឃត្រូវធ្វើទណ្ឌកម្មដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុនីសង្ឃ) ធ្វើអាវរណកម្ម គឺ ហាមប្រាម ។ លុះហាមប្រាមហើយ ភិក្ខុនីទាំងឡាយមិនទទួលយកដោយស្រុះស្រួល ។ ភិក្ខុទាំងឡាយនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុនីសង្ឃ) បញ្ឈប់ឱវាទ ។

(២០០) សម័យនោះឯង ឆព្វគ្គិយាភិក្ខុនី បើកកាយបង្ហាញពួកភិក្ខុ បើកដោះបង្ហាញពួកភិក្ខុ បើកភ្លៅបង្ហាញពួកភិក្ខុ បើកអង្គជាតបង្ហាញ

### ភិក្ខុនីខន្ធកេ កាយាទិទេសនា ទណ្ឌកម្មំ ឱវាទដ្ឋបនំ

ភិក្ខូនំ ទស្សេន្តិ ភិក្ខូ ឱភាសេន្តិ ភិក្ខូហិ សទ្ធឹ សម្បយោជេន្តិ អប្បេវនាម អម្ហេសុ សារជ្ជេយ្យុន្តិ ។ បេ ។ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ភិក្ខុនិយា កាយោ វិវរិត្វា ភិក្ខូនំ ទស្សេតព្វោ ន ថនំ វិវរិត្វា ភិក្ខូនំ ទស្សេតព្វំ ន ឩរុ វិវរិត្វា ភិក្ខូនំ ទស្សេតព្វា[១] ន អង្គជាតំ វិវរិត្វា ភិក្ខូនំ ទស្សេតព្វំ ន ភិក្ខូ ឱភាសិតព្វា ន ភិក្ខូហិ សទ្ធឹ សម្បយោជេតព្វំ យោ សម្បយោជេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ តស្សា ភិក្ខុនិយា ទណ្ឌកម្មំ កាតុន្តិ ។ អថខោ ភិក្ខូនំ ឯតទហោសិ កិន្នុ ខោ ទណ្ឌកម្មំ កាតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ អាវរណំ កាតុន្តិ ។ អាវរណេ កតេ ន អាទិយន្តិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ អនុជានាមិ ភិក្ខវេ ឱវាទំ ឋបេតុន្តិ ។

---

១ ម. ន ថនោ វិវរិត្វា ភិក្ខូនំ ទស្សេតព្វោ ន ឩរុំ វិវរិត្វា ភិក្ខូនំ ទស្សេតព្វំ ។

## ភិក្ខុនីខន្ធកៈ ការបង្ហាញកាយជាដើម ទណ្ឌកម្ម នឹង ការបញ្ឈប់ឱវាទ

ពួកភិក្ខុ ចំអកចំអន់ពួកភិក្ខុ ( ដោយអសទ្ធម្ម ) ផ្សំផ្គុំ (ពួកភិក្ខុនីលេង ) ជាមួយនឹងពួកភិក្ខុដោយគិតថា ធ្វើដូចម្តេចហ្ន៎ នឹងបានពួកភិក្ខុត្រេកអរមករកពួកយើង ។ បេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវបើកកាយបង្ហាញពួកភិក្ខុ មិនត្រូវបើកដោះបង្ហាញពួកភិក្ខុ មិនត្រូវបើកភ្លៅបង្ហាញពួកភិក្ខុ មិនត្រូវបើកអង្គជាតបង្ហាញពួកភិក្ខុ មិនត្រូវចំអកចំអន់ពួកភិក្ខុ ( ដោយអសទ្ធម្ម ) មិនត្រូវផ្សំផ្គុំ ( ពួកភិក្ខុនីលេង ) ជាមួយនឹងពួកភិក្ខុទេ ភិក្ខុនីណាផ្សំផ្គុំលេង ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ ( ភិក្ខុនីសង្ឃ ) ធ្វើទណ្ឌកម្មដល់ភិក្ខុនីនោះ ។ គ្រានោះ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា ភិក្ខុនីសង្ឃត្រូវធ្វើទណ្ឌកម្មដូចម្តេចហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ ( ភិក្ខុនីសង្ឃ) ធ្វើអាវរណកម្ម (ដល់ភិក្ខុនីទាំងឡាយ) ។ លុះធ្វើអាវរណកម្មហើយ ភិក្ខុនីទាំងឡាយ ក៏មិនទទួលដោយស្រុះស្រួល ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ ( ភិក្ខុនីសង្ឃ ) បញ្ឈប់ឱវាទ ។

## វិនយបិដកេ ចុល្លវគ្គោ

[២០១] អថខោ ភិក្ខូនំ ឯតទហោសិ កប្បតិ នុ ខោ ឱវាទដ្ឋបិតាយ ភិក្ខុនិយា សទ្ធឹ ឧបោសថំ កាតុំ ន នុ ខោ កប្បតីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ឱវាទដ្ឋបិតាយ ភិក្ខុនិយា សទ្ធឹ ឧបោសថោ កាតព្វោ យាវ ន តំ អធិករណំ វូបសម្មតីតិ[១] ។

[២០២] តេន ខោ បន សមយេន អាយស្មា ឧទាយិ ឱវាទំ ឋបេត្វា ចារិកំ បក្កាមិ ។ ភិក្ខុនិយោ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យោ ឧទាយិ ឱវាទំ ឋបេត្វា ចារិកំ បក្កមិស្សតីតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ឱវាទំ ឋបេត្វា ចារិកំ បក្កមិតព្វំ[២] យោ បក្កមេយ្យ អាបត្តិ ទុក្កដស្សាតិ ។

---

១ ឧ. ម. វូបសន្តំ ហោតីតិ ។ ២ ឧ. ចារិកា បក្កមិតព្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២០១) លំដាប់នោះភិក្ខុទាំងឡាយមានសេចក្ដីត្រិះរិះដូច្នេះថា ការធ្វើឧបោសថកម្មជាមួយនឹងភិក្ខុនី ដែលភិក្ខុនីសង្ឃបញ្ឈប់ឱវាទហើយ គួរដែរឬមិនគួរទេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីសង្ឃមិនត្រូវធ្វើឧបោសថកម្មជាមួយនឹងភិក្ខុនី ដែលភិក្ខុនីសង្ឃបញ្ឈប់ឱវាទទេ ដ្បិតអធិករណ៍នោះមិនទាន់រម្ងាប់នៅឡើយ ។

(២០២) សម័យនោះ ឧទាយីដ៏មានអាយុបញ្ឈប់ឱវាទហើយចេញទៅកាន់ទីចារិក ។ ភិក្ខុនីទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ឧទាយីមិនសមបើនឹងបញ្ឈប់ឱវាទ ហើយចេញទៅកាន់ទីចារិកសោះ ។បេ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបញ្ឈប់ឱវាទ ហើយចេញទៅកាន់ទីចារិកទេ ភិក្ខុណាចៀសចេញទៅ ត្រូវអាបត្តិទុក្កដ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

## ភិក្ខុនីខន្ធកេ ពាលានំ ឱវាទដ្ឋបនាទិ

[២០៣] តេន ខោ បន សមយេន ភិក្ខូ[១] ពាលា អព្យត្តា ឱវាទំ ឋបេន្តិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ពាលេន អព្យត្តេន ឱវាទោ ឋបេតព្វោ យោ ឋបេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[២០៤] តេន ខោ បន សមយេន ភិក្ខូ អវត្ថុស្មឹ អការណេ ឱវាទំ ឋបេន្តិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ អវត្ថុស្មឹ អការណេ ឱវាទោ ឋបេតព្វោ យោ ឋបេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[២០៥] តេន ខោ បន សមយេន ភិក្ខូ ឱវាទំ ឋបេត្វា វិនិច្ឆយំ ន ទេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ឱវាទំ ឋបេត្វា វិនិច្ឆយោ ន ទាតព្វោ យោ ន ទទេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[២០៦] តេន ខោ បន សមយេន ភិក្ខុនិយោ ឱវាទំ ន គច្ឆន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា ឱវាទោ ន គន្តព្វោ យា ន គច្ឆេយ្យ យថាធម្មោ ការេតព្វោតិ ។

---

១ ឱ. ម. បោត្ថកេសុ ភិក្ខូតិ សទ្ទោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជា

## ភិក្ខុនីខន្ធកៈ ការបញ្ឈប់ឱវាទរបស់ពួកភិក្ខុល្ងង់ជាដើម

(២០៣) សម័យនោះ មានពួកភិក្ខុល្ងង់ មិនឈ្លាសបញ្ឈប់ឱវាទ ។បេ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុល្ងង់មិនឈ្លាស មិនត្រូវបញ្ឈប់ឱវាទទេ ភិក្ខុណាបញ្ឈប់ ត្រូវអាបត្តិទុក្កដ ។

(២០៤) សម័យនោះ ពួកភិក្ខុបញ្ឈប់ឱវាទ ក្នុងទីដែលមិនមានរឿង មិនមានហេតុ ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបញ្ឈប់ឱវាទ ក្នុងទីដែលឥតរឿងឥតហេតុទេ ភិក្ខុណាបញ្ឈប់ ត្រូវអាបត្តិទុក្កដ ។

(២០៥) សម័យនោះឯង ភិក្ខុទាំងឡាយបញ្ឈប់ឱវាទហើយមិនឲ្យវិនិច្ឆ័យ(មិនជំនុំជម្រះ) ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបញ្ឈប់ឱវាទ ហើយមិនឲ្យវិនិច្ឆ័យទេ ភិក្ខុណាមិនឲ្យ ត្រូវអាបត្តិទុក្កដ ។

(២០៦) សម័យនោះ ភិក្ខុនីទាំងឡាយមិនទៅទទួលឱវាទ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវមិនទៅទទួលឱវាទទេ ភិក្ខុនីណាមិនទៅទទួល វិន័យធរត្រូវវិនិច្ឆ័យតាមអាបត្តិ ។

(២០៧) តេន ខោ បន សមយេន សព្វោ ភិក្ខុនីសង្ឃោ ឱវាទំ គច្ឆតិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ជាយាយោ ឥមា ឥមេសំ ជារិយោ ឥមា ឥមេសំ ឥទានិ ឥមេ ឥមាហិ សទ្ធឹ អភិរមិស្សន្តីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ សព្វេន ភិក្ខុនីសង្ឃេន ឱវាទោ គន្តព្វោ គច្ឆេយ្យ ចេ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ចតូហិ បញ្ចហិ ភិក្ខុនីហិ ឱវាទំ គន្តុន្តិ ។

(២០៨) តេន ខោ បន សមយេន ចតស្សោ បញ្ច ភិក្ខុនិយោ ឱវាទំ គច្ឆន្តិ ។ មនុស្សា តថេវ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ជាយាយោ ឥមា ឥមេសំ ជារិយោ ឥមា ឥមេសំ ឥទានិ ឥមេ ឥមាហិ សទ្ធឹ អភិរមិស្សន្តីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ចតូហិ បញ្ចហិ ភិក្ខុនីហិ ឱវាទោ គន្តព្វោ គច្ឆេយ្យុំ ចេ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ទ្វីហិ តីហិ ភិក្ខុនីហិ[១] ឱវាទំ គន្តុំ ។ ឯកំ ភិក្ខុំ ឧបសង្កមិត្វា

---

១ ឱ. ម. ទ្វេ តិស្សោ ភិក្ខុនិយោ ។

## វិនយបិដក ចុល្លវគ្គ

(២០៧) សម័យនោះឯង ភិក្ខុនីសង្ឃទាំងអស់ នាំគ្នាទៅទទួលនិមន្ត ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងនេះជាប្រពន្ធរបស់ភិក្ខុទាំងនេះ ភិក្ខុនីទាំងនេះ ជាសហាយរបស់ភិក្ខុទាំងនេះ ឥឡូវនេះ ភិក្ខុទាំងនេះនឹងត្រេកត្រអាល ជាមួយនឹងភិក្ខុនីទាំងនេះ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីសង្ឃមិនត្រូវទៅទទួលនិមន្ត (ព្រមគ្នា) ទាំងអស់ទេ បើទៅ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនី បួនឬប្រាំរូប ទៅទទួលនិមន្ត (ម្ដងៗបាន) ។

(២០៨) សម័យនោះឯង ភិក្ខុនីបួនប្រាំរូបនាំគ្នាទៅទទួលនិមន្ត ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ដូច្នោះទៀតថា ភិក្ខុនីទាំងនេះជាប្រពន្ធរបស់ភិក្ខុទាំងនេះ ភិក្ខុនីទាំងនេះ ជាសហាយរបស់ភិក្ខុទាំងនេះ ឥឡូវនេះ ភិក្ខុទាំងនេះមកត្រេកត្រអាល ជាមួយនឹងភិក្ខុនីទាំងឡាយនេះ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីបួនប្រាំរូបមិនត្រូវទៅទទួលនិមន្តទេ បើទៅ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីពីរឬបីរូបទៅទទួលនិមន្ត ។ ភិក្ខុនីសង្ឃ ត្រូវចូលទៅរកភិក្ខុ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ថ្វាយជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



## ភិក្ខុនីខន្ធកេ ភិក្ខុនោវាទកសម្មុតិ

ឯកំសំ ឧត្តរាសង្គំ ករិត្វា បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ ភិក្ខុនីសង្ឃោ អយ្យ ភិក្ខុសង្ឃស្ស បាទេ វន្ទតិ ឱវាទុបសង្កមនញ្ច យាចតិ លភតុ កិរ អយ្យ ភិក្ខុនីសង្ឃោ ឱវាទុបសង្កមនន្តិ ។ តេន ភិក្ខុនា បាតិមោក្ខុទ្ទេសកោ ឧបសង្កមិត្វា ឯវមស្ស វចនីយោ ភិក្ខុនីសង្ឃោ ភន្តេ ភិក្ខុសង្ឃស្ស បាទេ វន្ទតិ ឱវាទុបសង្កមនញ្ច យាចតិ លភតុ កិរ ភន្តេ ភិក្ខុនីសង្ឃោ ឱវាទុបសង្កមនន្តិ ។ បាតិមោក្ខុទ្ទេសកេន[១] វត្តព្វោ អត្ថិ កោចិ ភិក្ខុ ភិក្ខុនោវាទកោ សម្មតោតិ ។ សចេ ហោតិ កោចិ ភិក្ខុ ភិក្ខុនោវាទកោ សម្មតោ បាតិមោក្ខុទ្ទេសកេន វត្តព្វោ ឥត្ថន្នាមោ ភិក្ខុ ភិក្ខុនោវាទកោ សម្មតោ តំ ភិក្ខុនីសង្ឃោ ឧបសង្កមតូតិ ។ សចេ ន ហោតិ កោចិ ភិក្ខុ ភិក្ខុនោវាទកោ សម្មតោ បាតិមោក្ខុទ្ទេសកេន វត្តព្វោ កោ អាយស្មា ឧស្សហតិ ភិក្ខុនិយោ ឱវទិតុន្តិ ។ សចេ កោចិ ឧស្សហតិ ភិក្ខុនិយោ ឱវទិតុំ សោ ច ហោតិ អដ្ឋហង្គេហិ

១ បាតិមោក្ខុទ្ទេសកេន ភិក្ខុនាតិ កត្ថចិ ពោត្ថកេ ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ពុទ្ធបរិស័ទ។

## ភិក្ខុនីវិភង្គៈ ការសន្មតិភិក្ខុឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី

១) បេ ។ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាងក្រាបថ្វាយបង្គំបាទា ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ ភិក្ខុនីសង្ឃ ថ្វាយបង្គំបាទានៃភិក្ខុសង្ឃផង សូមចូលមកទទួលយកឱវាទផង បពិត្រ លោកម្ចាស់ ឮថាភិក្ខុនីសង្ឃត្រូវបានចូលមកទទួលយកឱវាទ ។ ភិក្ខុនោះ គប្បីចូលទៅរកភិក្ខុអ្នកសម្តែងបាតិមោក្ខ ហើយពោលយ៉ាងនេះថា បពិត្រ លោកម្ចាស់ ភិក្ខុនីសង្ឃថ្វាយបង្គំបាទានៃភិក្ខុសង្ឃផង ចូលមកទទួលឱវាទ ផង បពិត្រលោកម្ចាស់ ឮថាភិក្ខុនីសង្ឃត្រូវបានចូលមកទទួលឱវាទ ។ ភិក្ខុសម្តែងបាតិមោក្ខគប្បីពោលថា មានភិក្ខុណានីមួយ ដែលសង្ឃ បានសន្មតឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនីដែរឬ ។ បើមានភិក្ខុណាមួយ ដែល សង្ឃបានសន្មតឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី ត្រូវភិក្ខុអ្នកសម្តែងបាតិមោក្ខ និយាយថា ភិក្ខុឈ្មោះនេះ ដែលសង្ឃបានសន្មតឲ្យជាអ្នកឲ្យឱវាទដល់ ភិក្ខុនី ភិក្ខុនីសង្ឃចូរចូលទៅរកភិក្ខុនោះចុះ ។ បើមិនមានភិក្ខុណាមួយ ដែលសង្ឃបានសន្មតឲ្យជាអ្នកឲ្យឱវាទ ដល់ភិក្ខុនីទេ ត្រូវភិក្ខុអ្នកសម្តែង បាតិមោក្ខនិយាយថា លោកដ៏មានអាយុអង្គណាអាចទូន្មានភិក្ខុនីបាន ។ បើភិក្ខុណាមួយអាចទូន្មានភិក្ខុនីបាន ទាំងភិក្ខុនោះ ក៏ប្រកបដោយអង្គ ៨

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សមន្នាគតោ សម្មន្និត្វា វត្តព្វោ ឥត្ថន្នាមោ ភិក្ខុ ភិក្ខុនោវាទកោ សម្មតោ តំ ភិក្ខុនីសង្ឃោ ឧបសង្កមតូតិ ។ សចេ ន កោចិ ឧស្សហតិ ភិក្ខុនិយោ ឱវទិតុំ បាតិមោក្ខុទ្ទេសកេន វត្តព្វោ នត្ថិ កោចិ ភិក្ខុ ភិក្ខុនោវាទកោ សម្មតោ បាសាទិកេន ភិក្ខុនីសង្ឃោ សម្បាទេតូតិ ។

(២០៩) តេន ខោ បន សមយេន ភិក្ខូ ឱវាទំ ន គណ្ហន្តិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ឱវាទោ ន គហេតព្វោ យោ ន គណ្ហេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២១០) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ពាលោ ហោតិ ។ តំ ភិក្ខុនិយោ ឧបសង្កមិត្វា ឯតទវោចុំ ឱវាទំ អយ្យ គណ្ហាហីតិ ។ អហម្ហិ[1] ភគិនី ពាលោ កថាហំ ឱវាទំ គណ្ហាមីតិ ។ គណ្ហាហាយ្យ ឱវាទំ ឯវំ ហិ ភគវតា បញ្ញត្តំ ភិក្ខូហិ ភិក្ខុនីនំ ឱវាទោ គហេតព្វោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។

---

១ ឱ. ម. អហញ្ហិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។




ប្រការផង ដែលសង្ឃបានសន្មតថា ភិក្ខុឈ្មោះនេះ សង្ឃបានសន្មតឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនីហើយ ភិក្ខុនីសង្ឃត្រូវចូលទៅរកភិក្ខុនោះចុះ ។ បើមិនមានភិក្ខុណាមួយ អាចនឹងទូន្មានភិក្ខុនីបានទេ ភិក្ខុអ្នកសម្តែងបាតិមោក្ខគប្បីប្រាប់ថា ភិក្ខុណាមួយដែលសង្ឃសន្មត ឲ្យជាអ្នកទូន្មានភិក្ខុនីនោះមិនមានទេ ចូរភិក្ខុនីសង្ឃសម្រេចប្រយោជន៍ ដោយសេចក្តីជ្រះថ្លាចុះ ។

(២០៩) សម័យនោះឯង ភិក្ខុទាំងឡាយ មិនព្រមទទួលឲ្យឱវាទ ។បេ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រកែកមិនព្រមទទួលឲ្យឱវាទទេ ភិក្ខុណាមិនព្រមទទួល ត្រូវអាបត្តិទុក្កដ ។

(២១០) សម័យនោះ មានភិក្ខុ ១ រូបល្ងង់ ។ ភិក្ខុនីទាំងឡាយនាំគ្នាចូលទៅរកភិក្ខុនោះហើយ ពោលពាក្យនេះថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទទួលឲ្យឱវាទចុះ ។ ភិក្ខុនោះឆ្លើយថា ម្នាលនាង យើងជាមនុស្សល្ងង់ យើងទទួលឲ្យឱវាទដូចម្តេចបាន ។ ពួកភិក្ខុនីពោលថា បពិត្រលោកម្ចាស់ សូមលោកទទួលឲ្យឱវាទចុះ ដ្បិតហេតុនេះ ព្រះមានព្រះភាគទ្រង់បញ្ញត្តថា ត្រូវភិក្ខុទទួលឲ្យឱវាទដល់ភិក្ខុនី ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនុជានាមិ ភិក្ខវេ ឋបេត្វា ពាលំ អវសេសេហិ ឱវាទំ គហេតុន្តិ ។

(២១១) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ តំ ភិក្ខុនិយោ ឧបសង្កមិត្វា ឯតទវោចុំ ឱវាទំ អយ្យ គណ្ហាហីតិ ។ អហម្បិ ភគិនី គិលានោ កថាហំ ឱវាទំ គណ្ហាមីតិ ។ គណ្ហាហយ្យ ឱវាទំ ឯវំ ហិ ភគវតា បញ្ញត្តំ ឋបេត្វា ពាលំ អវសេសេហិ ឱវាទោ គហេតព្វោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឋបេត្វា ពាលំ ឋបេត្វា គិលានំ អវសេសេហិ ឱវាទំ គហេតុន្តិ ។

(២១២) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គមិកោ ហោតិ ។ តំ ភិក្ខុនិយោ ឧបសង្កមិត្វា ឯតទវោចុំ ឱវាទំ អយ្យ គណ្ហាហីតិ ។ អហម្បិ ភគិនី

## ភិក្ខុនីខន្ធកៈ ការទទួលឱវាទនៃភិក្ខុទាំងឡាយ

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបញ្ឈប់ភិក្ខុល្ងង់ ឲ្យភិក្ខុក្រៅពីនេះទទួលឲ្យឱវាទបាន ។

(២១២) សម័យនោះឯង មានភិក្ខុ១រូបមានជម្ងឺ ។ ភិក្ខុនីទាំងឡាយនាំគ្នាចូលទៅរកភិក្ខុនោះហើយនិយាយពាក្យនេះថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទទួលឲ្យឱវាទ ។ ភិក្ខុនោះឆ្លើយថា ម្នាលនាង យើងជាមនុស្សមានជម្ងឺ យើងទទួលឲ្យឱវាទដូចម្តេចបាន ។ ភិក្ខុនីទាំងឡាយនិយាយថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទទួលឲ្យឱវាទ ដ្បិតហេតុនេះ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តថា ឲ្យបញ្ឈប់ភិក្ខុល្ងង់ ឲ្យភិក្ខុក្រៅពីនេះទទួលឲ្យឱវាទបាន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបញ្ឈប់ភិក្ខុល្ងង់ និងភិក្ខុឈឺ ឲ្យភិក្ខុក្រៅពីនេះ ទទួលឲ្យឱវាទបាន ។

(២១២) សម័យនោះឯង មានភិក្ខុ ១ រូបជាអ្នកដំណើរ ។ ភិក្ខុនីទាំងឡាយចូលទៅរកភិក្ខុនោះ ហើយនិយាយពាក្យនេះថា បពិត្រលោកម្ចាស់ សូមមេត្តាទទួលឲ្យឱវាទ ។ ភិក្ខុនោះឆ្លើយថា ម្នាលនាង យើង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



គមិកោ កថាហំ ឱវាទំ គណ្ហាមីតិ។ គណ្ហាហយ្យ ឱវាទំ ឯវំ ហិ ភគវតា បញ្ញត្តំ ឋបេត្វា ពាលំ ឋបេត្វា គិលានំ អវសេសេហិ ឱវាទោ គហេតព្វោតិ។ ភគវតោ ឯតមត្ថំ អារោចេសុំ។ បេ។ អនុជានាមិ ភិក្ខវេ ឋបេត្វា ពាលំ ឋបេត្វា គិលានំ ឋបេត្វា គមិកំ អវសេសេហិ ឱវាទំ គហេតុន្តិ។

[២១៣] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អរញ្ញេ វិហរតិ។ តំ ភិក្ខុនិយោ ឧបសង្កមិត្វា ឯតទវោចុំ ឱវាទំ អយ្យ គណ្ហាហីតិ។ អហំ ហិ ភគិនី អរញ្ញេ វិហា-រាមិ កថាហំ ឱវាទំ គណ្ហាមីតិ។ គណ្ហាហយ្យ ឱវាទំ ឯវំ ហិ ភគវតា បញ្ញត្តំ ឋបេត្វា ពាលំ ឋបេត្វា គិលានំ ឋបេត្វា គមិកំ អវសេសេហិ ឱវាទោ គហេតព្វោតិ។ ភគវតោ ឯតមត្ថំ អារោចេសុំ។ អនុជានាមិ ភិក្ខវេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាពុទ្ធបូជា ។


ជាអ្នកដំណើរ យើងទទួលឲ្យឱវាទដូចម្តេចបាន ។ ភិក្ខុនីទាំងឡាយពោលថា បពិត្រលោកម្ចាស់ សូមមេត្តាទទួលឲ្យឱវាទ ដ្បិតហេតុនេះព្រះមានព្រះភាគទ្រង់បញ្ញត្តថា លើកលែងតែភិក្ខុល្ងង់ លើកលែងតែភិក្ខុឈឺចេញ ត្រូវឲ្យភិក្ខុក្រៅពីនេះទទួលឲ្យឱវាទបាន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យលើកលែងភិក្ខុល្ងង់ លើកលែងភិក្ខុឈឺ នឹងភិក្ខុអ្នកដំណើរ ឲ្យភិក្ខុដែលក្រៅពីនេះទទួលឲ្យឱវាទបាន ។

[២១៣] សម័យនោះឯង មានភិក្ខុ១រូបជាអ្នកនៅក្នុងព្រៃ ។ ភិក្ខុនីទាំងឡាយចូលទៅរកភិក្ខុនោះ ហើយនិយាយពាក្យនេះថា បពិត្រលោកម្ចាស់ សូមមេត្តាទទួលឲ្យឱវាទ ។ ភិក្ខុនោះឆ្លើយថា ម្នាលនាង ដ្បិតយើងជាអ្នកនៅក្នុងព្រៃ យើងនឹងទទួលឲ្យឱវាទដូចម្តេចបាន ។ ភិក្ខុនីទាំងឡាយនិយាយថា បពិត្រលោកម្ចាស់ សូមមេត្តាទទួលឲ្យឱវាទ ដ្បិតហេតុនេះ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តឲ្យលើកលែងតែភិក្ខុល្ងង់ លើកលែងតែភិក្ខុឈឺ នឹងលើកលែងតែភិក្ខុអ្នកដំណើរចេញ ឲ្យភិក្ខុក្រៅពីនេះទទួលឲ្យឱវាទបាន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។

## ភិក្ខុនីវគ្គេ ឱវាទំ គហេត្វា អនារោចនាទិ

អារញ្ញកេន ភិក្ខុនា ឱវាទំ គហេតុំ សង្កេតញ្ច កាតុំ អត្រ បដិហរិស្សាមីតិ ។

[២១៤] តេន ខោ បន សមយេន ភិក្ខូ ឱវាទំ គហេត្វា ន អារោចេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ឱវាទោ ន អារោចេតព្វោ យោ ន អារោចេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[២១៥] តេន ខោ បន សមយេន ភិក្ខូ ឱវាទំ គហេត្វា ន បច្ចាហរន្តិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ឱវាទោ ន បច្ចាហរិតព្វោ យោ ន បច្ចាហរេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[២១៦] តេន ខោ បន សមយេន ភិក្ខុនិយោ សង្កេតំ ន គច្ឆន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយោ សង្កេតំ ន គន្តព្វំ យោ ន គច្ឆេយ្យ អាបត្តិ ទុក្កដស្សាតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


## ភិក្ខុនីខន្ធកៈ ការទទួលឲ្យឱវាទហើយមិនមកប្រាប់ជាដើម

តថាគតអនុញ្ញាតឲ្យភិក្ខុអ្នកនៅក្នុងព្រៃ ទទួលឲ្យឱវាទផង ឲ្យធ្វើសង្កេត (សេចក្តីកំណត់)ផង ថា អាត្មាអញនឹងផ្លាស់ទៅក្នុងទីនោះ ។

(២១៨) សម័យនោះឯង ភិក្ខុទាំងឡាយទទួលឲ្យឱវាទ ហើយមិនបានប្រាប់ដល់ (ភិក្ខុអ្នកសំដែងបាតិមោក្ខ) ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវភិក្ខុមិនប្រាប់ឱវាទ (ដល់ភិក្ខុនី) ទេ ភិក្ខុណាមិនប្រាប់ ត្រូវអាបត្តិទុក្កដ ។

(២១៩) សម័យនោះឯង ភិក្ខុទាំងឡាយទទួលឲ្យឱវាទហើយ មិនផ្លាស់ទី (តាមសង្កេត) ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវមិនផ្លាស់ទី (តាមសង្កេត) ទេ ភិក្ខុណាមិនផ្លាស់ ត្រូវអាបត្តិទុក្កដ ។

(២១៦) សម័យនោះឯង ភិក្ខុនីទាំងឡាយ មិនទៅកាន់ទីដែលសង្ឃកំណត់ហើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវខានទៅកាន់ទីដែលសង្ឃកំណត់ហើយទេ ភិក្ខុនីណាមិនទៅ ត្រូវអាបត្តិទុក្កដ ។

[២១៧] តេន ខោ បន សមយេន ភិក្ខុនិយោ ទីឃានិ កាយពន្ធនានិ ធារេន្តិ តេហេវ ផាសុកេ(១) នាមេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។បេ។ សេយ្យថាបិ គិហិកាមភោគិនិយោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា ទីឃំ កាយពន្ធនំ ធារេតព្វំ យា ធារេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ ភិក្ខុនិយា ឯកបរិយាយកតំ(២) កាយពន្ធនំ ន ច តេន ផាសុកា(៣) នាមេតព្វា យា នាមេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[២១៨] តេន ខោ បន សមយេន ភិក្ខុនិយោ វិលីវេន បដ្ដេន ផាសុកេ នាមេន្តិ ចម្មបដ្ដេន ផាសុកេ នាមេន្តិ ទុស្សបដ្ដេន ផាសុកេ នាមេន្តិ ទុស្សវេណិយា ផាសុកេ នាមេន្តិ ទុស្សវដ្ដិយា ផាសុកេ នាមេន្តិ ចោឡបដ្ដេន ផាសុកេ នាមេន្តិ ចោឡវេណិយា ផាសុកេ នាមេន្តិ ចោឡវដ្ដិយា ផាសុកេ នាមេន្តិ សុត្តវេណិយា ផាសុកេ នាមេន្តិ សុត្តវដ្ដិយា ផាសុកេ នាមេន្តិ ។ មនុស្សា ឧជ្ឈា-

---

១ ឱ. ផាសុកេ ។ ២ ឱ. ម. ឯកបរិយាកតំ ។ ៣ ឱ. ផាសុកា ។ ៣ ម. ជង្ឃន្តិ ។

(២១៧) សម័យនោះឯង ភិក្ខុទាំងឡាយទ្រទ្រង់វត្ថពន្ធបង្កេះវែងៗ ចងរឹតឆ្អឹងជំនីរដោយវត្ថពន្ធបង្កេះនោះ(១) ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចពួកស្រីគ្រហស្ថអ្នកបរិភោគកាម ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទ្រទ្រង់វត្ថពន្ធបង្កេះវែងទេ ភិក្ខុណាទ្រទ្រង់ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតវត្ថពន្ធបង្កេះល្មមព័ទ្ធតែ ១ ជុំបាន មិនត្រូវចងរឹតឆ្អឹងជំនីរដោយវត្ថពន្ធបង្កេះនោះទេ ភិក្ខុណាចងរឹត ត្រូវអាបត្តិទុក្កដ ។

(២១៨) សម័យនោះឯង ភិក្ខុទាំងឡាយ ចងរឹតឆ្អឹងជំនីរដោយផ្ទាំងដែលធ្វើអំពីបន្ទោះឫស្សី ចងរឹតឆ្អឹងជំនីរដោយផ្ទាំងស្បែក ចងរឹតឆ្អឹងជំនីរដោយផ្ទាំងសំពត់ស ចងរឹតឆ្អឹងជំនីរដោយសំណុំសំពត់ស ចងរឹតឆ្អឹងជំនីរដោយខ្នាញ់សំពត់ស ចងរឹតឆ្អឹងជំនីរ ដោយផ្ទាំងសំពត់មានពណ៌ ចងរឹតឆ្អឹងជំនីរដោយសំណុំសំពត់មានពណ៌ ចងរឹតឆ្អឹងជំនីរដោយខ្នាញ់សំពត់មានពណ៌ ចងរឹតឆ្អឹងជំនីរដោយសំណុំសំពត់សូត្រ ចងរឹតឆ្អឹងជំនីរដោយខ្នាញ់សំពត់សូត្រ ។ មនុស្សទាំងឡាយក៏ពោលទោស

---

១ អដ្ឋកថា ពន្យល់ថា ចងរឹតឆ្អឹងជំនីរឲ្យទន់ដោយវត្ថពន្ធបង្កេះ ហាក់ដូចជានាងទារិកាជាគ្រហស្ថរុំដោយសំពត់ចោមពុង គឺ សំពត់បិទដោះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហិកាមភោគិនិយោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា វិលីវេន បដ្ដេន ផាសុកា នាមេតព្វា ន ចម្មបដ្ដេន ផាសុកា នាមេតព្វា ន ទុស្សបដ្ដេន ផាសុកា នាមេតព្វា ន ទុស្សវេណិយា ផាសុកា នាមេតព្វា ន ទុស្សវដ្ដិយា ផាសុកា នាមេតព្វា ន ចោឡបដ្ដេន ផាសុកា នាមេតព្វា ន ចោឡវេណិយា ផាសុកា នាមេតព្វា ន ចោឡវដ្ដិយា ផាសុកា នាមេតព្វា ន សុត្តវេណិយា ផាសុកា នាមេតព្វា ន សុត្តវដ្ដិយា ផាសុកា នាមេតព្វា យា នាមេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២១៩) តេន ខោ បន សមយេន ភិក្ខុនិយោ អដ្ឋិល្លេន ជឃនំ(១) ឃំសាបេន្តិ គោហនុកេន ជឃនំ កោដ្ដាបេន្តិ ហត្ថំ កោដ្ដាបេន្តិ ហត្ថកោច្ឆំ កោដ្ដាបេន្តិ បាទំ កោដ្ដាបេន្តិ បាទកោច្ឆំ កោដ្ដាបេន្តិ ឩរុំ កោដ្ដាបេន្តិ មុខំ កោដ្ដាបេន្តិ ទន្តមំសំ កោដ្ដាបេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហិកាមភោគិនិយោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។

១ ម. ជង្ឃនំ ។

## ភិក្ខុនីខន្ធកៈ ការឲ្យដំត្រគាកដោយឈើមានសណ្ឋានដូចឆ្អឹងគោជាដើម

តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចជាពួកគ្រហស្ថអ្នកបរិភោគកាម ។ ភិក្ខុនីទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវចងរឹតឆ្អឹងជំនីរដោយផ្ទាំងដែលធ្វើពីបន្ទោះឫស្សី មិនត្រូវចងរឹតឆ្អឹងជំនីរដោយផ្ទាំងស្បែក មិនត្រូវចងរឹតឆ្អឹងជំនីរដោយផ្ទាំងសំពត់ស មិនត្រូវចងរឹតឆ្អឹងជំនីរដោយសំណុំសំពត់ស មិនត្រូវចងរឹតឆ្អឹងជំនីរដោយខ្នាញ់សំពត់ស មិនត្រូវចងរឹតឆ្អឹងជំនីរដោយផ្ទាំងសំពត់មានពណ៌ មិនត្រូវចងរឹតឆ្អឹងជំនីរដោយសំណុំសំពត់មានពណ៌ មិនត្រូវចងរឹតឆ្អឹងជំនីរដោយខ្នាញ់សំពត់មានពណ៌ មិនត្រូវចងរឹតឆ្អឹងជំនីរដោយសំណុំសំពត់សូត្រទេ ភិក្ខុនីណាចងរឹត ត្រូវអាបត្តិទុក្កដ ។

[២១៩] សម័យនោះឯង ភិក្ខុនីទាំងឡាយឲ្យគេដំត្រគាកដោយឈើមានសណ្ឋានដូចឆ្អឹងស្មងគោ ឲ្យគេដំត្រគាក ឲ្យគេដំដៃ ឲ្យគេដំខ្នងដៃ ឲ្យគេដំជើង ឲ្យគេដំខ្នងជើង ឲ្យគេដំភ្លៅ ឲ្យគេដំមុខ ឲ្យគេដំសាច់ជើងធ្មេញ ដោយឈើមានសណ្ឋានដូចឆ្អឹងចង្កាគោ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចជាពួកស្រីគ្រហស្ថអ្នកបរិភោគកាម ។ ភិក្ខុនីទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។

## វិនយបិដកេ ចុល្លវគ្គោ

ន ភិក្ខវេ ភិក្ខុនិយា អដ្ឋិល្លេន ជឃនំ ឃំសាបេតព្វំ ន គោហនុកេន ជឃនំ កោដ្ដាបេតព្វំ ន ហត្ថោ កោដ្ដាបេតព្វោ ន ហត្ថកោច្ឆោ កោដ្ដាបេតព្វោ ន បាទោ កោដ្ដាបេតព្វោ ន បាទកោច្ឆោ កោដ្ដាបេតព្វោ ន ឩរុ កោដ្ដាបេតព្វោ ន មុខំ កោដ្ដាបេតព្វំ ន ទន្តមំសំ កោដ្ដាបេតព្វំ យា កោដ្ដាបេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២២០) តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ មុខំ អាលិម្បន្តិ មុខំ ឧម្មទ្ទេន្តិ មុខំ ចុណ្ណេន្តិ មនោសិលិកាយ មុខំ លញ្ឆេន្តិ អង្គរាគំ ករោន្តិ មុខរាគំ ករោន្តិ អង្គរាគមុខរាគំ ករោន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហិកាមភោគិនិយោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា មុខំ អាលិម្បិតព្វំ ន មុខំ ឧម្មទ្ទិតព្វំ ន មុខំ ចុណ្ណេតព្វំ ន មនោសិលិកាយ មុខំ លញ្ឆេតព្វំ ន អង្គរាគោ កាតព្វោ ន មុខរាគោ កាតព្វោ ន អង្គរាគមុខរាគោ កាតព្វោ យា ករេយ្យ អាបត្តិ ទុក្កដស្សាតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវឲ្យគេជំត្រគាក ដោយឈើមានសណ្ឋានដូចឆ្អឹងស្មងគោ មិនត្រូវឲ្យគេជំត្រគាក មិនត្រូវឲ្យគេជំដៃ មិនត្រូវឲ្យគេជំខ្នងដៃ មិនត្រូវឲ្យគេជំជើង មិនត្រូវឲ្យគេជំខ្នងជើង មិនត្រូវឲ្យគេជំភ្លៅ មិនត្រូវឲ្យគេជំមុខ មិនត្រូវឲ្យគេជំសាច់ជើងធ្មេញ ដោយឈើមានសណ្ឋានដូចឆ្អឹងបង្កាគោទេ ភិក្ខុនីណាឲ្យគេជំ ត្រូវអាបត្តិទុក្កដ ។

[២៨០] សម័យនោះឯង ពួកឆព្វគ្គិយាភិក្ខុនី លាបមុខ ប្រស់មុខ ខាត់មុខ ចឹមមុខ ស្រឡាបខ្លួន ស្រឡាបមុខ ស្រឡាបទាំងខ្លួន ទាំងមុខ ដោយគ្រឿងលាបលាយដោយមនោសិលា ( ម្សៅលាប ) ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចជាពួកស្រីគ្រហស្ថអ្នកបរិភោគកាម ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវលាបមុខ មិនត្រូវប្រស់មុខ មិនត្រូវខាត់មុខ មិនត្រូវចឹមមុខ មិនត្រូវស្រឡាបខ្លួន មិនត្រូវស្រឡាបមុខ មិនត្រូវស្រឡាបទាំងខ្លួនទាំងមុខ ដោយគ្រឿងលាបលាយដោយមនោសិលាទេ ភិក្ខុនីណាធ្វើ ត្រូវអាបត្តិទុក្កដ ។

## ភិក្ខុនីខន្ធកេ អវង្គករណាទិកំ

[៤២១] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុ-
និយោ អវង្គំ ការេន្តិ វិសេសកំ ការេន្តិ ឱលោកន-
កេន ឱលោកេន្តិ សាលោកេ តិដ្ឋន្តិ សមជ្ជំ(១) ការា-
បេន្តិ វេសឹ វុដ្ឋាបេន្តិ បានាគារំ ឋបេន្តិ សូនំ ឋបេន្តិ
អាបណំ បសារេន្តិ វឌ្ឍឹ បយោជេន្តិ វណិជ្ជំ បយោជេន្តិ
ទាសំ ឧបដ្ឋាបេន្តិ ទាសឹ ឧបដ្ឋាបេន្តិ កម្មការំ ឧបដ្ឋា-
បេន្តិ កម្មការឹ ឧបដ្ឋាបេន្តិ តិរច្ឆានគតំ ឧបដ្ឋាបេន្តិ
ហរីតកបក្កិកំ(២) បកិណន្តិ នមតកំ ធារេន្តិ ។ ម-
នុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យ-
ថាបិ គិហិកាមភោគិនិយោតិ ។ ភគវតោ ឯតមត្ថំ អា-
រោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា អវង្គំ កាតព្វំ ន
វិសេសកំ កាតព្វំ ន ឱលោកនកេន ឱលោកេតព្វំ ន
សាលោកេ ឋាតព្វំ(៣) ន សមជ្ជំ ការាបេតព្វំ ន វេសី
វុដ្ឋាបេតព្វា ន បានាគារំ ឋបេតព្វំ ន សូនំ ឋបេតព្វំ(៤)
ន អាបណោ បសារេតព្វោ ន វឌ្ឍិ បយោជេតព្វា ន
វណិជ្ជា បយោជេតព្វា ន ទាសោ ឧបដ្ឋាបេតព្វោ

---

១ ម. អាលោកេ តិដ្ឋន្តិ នច្ចំ ។ ២ ឱ. ហរីតកបណ្ណិកំ ។ ម. ហរិតកបណ្ណិយំ ។
៣ ឱ. ម. តិដ្ឋិតព្វំ ។ ៤ ឱ. សូនា ឋបេតព្វា ។ ម. សូនោ ឋបេតព្វោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកៈ ការធ្វើគំនូសខាងក្រោមមាត់ជាដើម

[៦២១] សម័យនោះឯង ពួកឆព្វគ្គិយាភិក្ខុនី ធ្វើនូវគំនូសខាងក្រោមមាត់[១] ធ្វើគំនូសប៉ែក ៗ ត្រង់ថ្ពាល់ ក្រឡេកមើលតាមបង្អួច ឈរត្រង់ទ្វារបង្ហាញកាយពាក់កណ្ដាល ប្រើឲ្យគេលេងមហោស្រព បំបួសស្រីផ្កាមាស តាំងរោងស្រា តាំងរោងលក់សាច់ បើកពនផ្សារ ដំឡើងថ្ងៃ (ទំនិញ) ប្រកបជំនួញ ឲ្យខ្ញុំប្រុសបំរើ ឲ្យខ្ញុំស្រីបំរើ ឲ្យកូនឈ្នួលប្រុសបំរើ ឲ្យកូនឈ្នួលស្រីបំរើ ឲ្យសត្វតិរច្ឆានបំរើ លក់វត្ថុខ្ចីទិញវត្ថុ (តាំងពនផ្សារលក់ដូររបស់រាយរង) ទ្រទ្រង់កំពលស្នាប់ដោយពេមចៀម ៗ មនុស្សទាំងឡាយតិះដៀលទោស តិះដៀល បន្ទះបង្អាប់ថា ៗ បេ ៗ ដូចជាពួកស្រីគ្រហស្ថអ្នកបរិភោគកាម ៗ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុះចំពោះព្រះមានព្រះភាគ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវធ្វើគំនូសក្រោមមាត់ មិនត្រូវធ្វើគំនូសប៉ែក ៗ ត្រង់ថ្ពាល់ មិនត្រូវក្រឡេកមើលតាមបង្អួច មិនត្រូវឈរត្រង់មាត់ទ្វារ បង្ហាញកាយពាក់កណ្ដាល មិនត្រូវប្រើគេឲ្យលេងមហោស្រព មិនត្រូវបំបួសស្រីផ្កាមាស មិនត្រូវតាំងរោងស្រា មិនត្រូវតាំងរោងលក់សាច់ មិនត្រូវបើកពនផ្សារ មិនត្រូវដំឡើងថ្ងៃ (ទំនិញ) មិនត្រូវប្រកបជំនួញ មិនត្រូវឲ្យខ្ញុំប្រុសបំរើ

---

១ អដ្ឋកថា ពន្យល់ថា ពួកភិក្ខុនីយកថ្នាំបន្តក់ភ្នែកទៅធ្វើគំនូសខាងក្រោមមាត់ត្រង់កន្លែងណាដែលវៀច ៗ ឬ ខូង ៗ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ន ទាសី ឧបដ្ឋាបេតព្វា ន កម្មការោ ឧបដ្ឋាបេតព្វោ ន កម្មការី ឧបដ្ឋាបេតព្វា ន តិរច្ឆានគតោ ឧបដ្ឋាបេតព្វោ ន ហរិតកបត្តិកំ បកិណិតព្វំ ន នមតកំ ធារេតព្វំ យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[២២២] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ សព្វនីលកានិ ចីវរានិ ធារេន្តិ សព្វបីតកានិ ចីវរានិ ធារេន្តិ សព្វលោហិតកានិ ចីវរានិ ធារេន្តិ សព្វមញ្ជេដ្ឋកានិ ចីវរានិ ធារេន្តិ សព្វកណ្ហានិ ចីវរានិ ធារេន្តិ សព្វមហារង្គរត្តានិ ចីវរានិ ធារេន្តិ សព្វមហានាមរត្តានិ ចីវរានិ ធារេន្តិ អច្ឆិន្នទសានិ ចីវរានិ ធារេន្តិ ទីឃទសានិ ចីវរានិ ធារេន្តិ បុប្ផទសានិ ចីវរានិ ធារេន្តិ ផលទសានិ ចីវរានិ ធារេន្តិ កញ្ចុកំ ធារេន្តិ តិរីដំ(១) ធារេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហិកាមភោគិនិយោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា សព្វនីលកានិ ចីវរានិ ធារេតព្វានិ ន សព្វបីតកានិ ចីវរានិ

១ ឱ. តិរីដកំ ។ ម. តិរិដកំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ផ្សាយធម្មទានៗ




មិនត្រូវឲ្យខ្ញុំស្រីបំរើ មិនត្រូវឲ្យកូនឈ្នួលប្រុសបំរើ មិនត្រូវឲ្យកូនឈ្នួលស្រីបំរើ មិនត្រូវឲ្យសត្វតិរច្ឆានបំរើ មិនត្រូវលក់វត្ថុខ្ទីងវត្ថុ (តាំងពានផ្សារលក់ដូររបស់ពាយរង) មិនត្រូវទ្រទ្រង់កំពលស្លាប់ដោយពោមបៀមទេ ភិក្ខុនីណាទ្រទ្រង់ ត្រូវអាបត្តិទុក្កដ ។

(៦២២) សម័យនោះឯង ពួកឆព្វគ្គិយាភិក្ខុនី ទ្រទ្រង់ចីវរខៀវសុទ្ធ ទ្រទ្រង់ចីវរលឿងខ្ចីសុទ្ធ ទ្រទ្រង់ចីវរក្រហមសុទ្ធ ទ្រទ្រង់ចីវរហង្សបាទសុទ្ធ ទ្រទ្រង់ចីវរខ្មៅសុទ្ធ ទ្រទ្រង់ចីវរក្រហមក្រមៅសុទ្ធ ទ្រទ្រង់ចីវរលឿងទុំសុទ្ធ ទ្រទ្រង់ចីវរមានជាយមិនបានកាត់ដាច់ ទ្រទ្រង់ចីវរមានជាយវែង ទ្រទ្រង់ចីវរមានជាយវិចិត្រដោយផ្កាឈើ ទ្រទ្រង់ចីវរមានជាយវិចិត្រដោយផ្លែឈើ ទ្រទ្រង់អាវបំពង់វែង ទ្រទ្រង់មួក ។ មនុស្សទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចជាពួកស្រីគ្រហស្ថអ្នកបរិភោគកាម ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុះ បំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវទ្រទ្រង់ចីវរខៀវសុទ្ធ មិនត្រូវទ្រទ្រង់ចីវរលឿងខ្ចីសុទ្ធ

ធារេតព្វានិ ន សព្វលោហិតកានិ ចីវរានិ ធារេតព្វានិ ន សព្វមញ្ជេដ្ឋកានិ ចីវរានិ ធារេតព្វានិ ន សព្វកណ្ហានិ ចីវរានិ ធារេតព្វានិ ន សព្វមហារង្គរត្តានិ ចីវរានិ ធារេតព្វានិ ន សព្វមហានាមរត្តានិ ចីវរានិ ធារេតព្វានិ ន អច្ឆិន្នទសានិ ចីវរានិ ធារេតព្វានិ ន ទីឃទសានិ ចីវរានិ ធារេតព្វានិ ន បុប្ផទសានិ ចីវរានិ ធារេតព្វានិ ន ផលទសានិ ចីវរានិ ធារេតព្វានិ ន កញ្ចុកំ ធារេតព្វំ ន តិរីដំ ធារេតព្វំ យោ ធារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[២២៣] តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី កាលំ ករោន្តី ឯវមាហ មមច្ចយេន មយ្ហំ បរិក្ខារោ សង្ឃស្ស ហោតូតិ ។ តត្ថ ភិក្ខូ ច ភិក្ខុនិយោ ច វិវទន្តិ អម្ហាកំ ហោតិ អម្ហាកំ ហោតីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ភិក្ខុនី ចេ ភិក្ខវេ កាលំ ករោន្តី ឯវំ វទេយ្យ មមច្ចយេន មយ្ហំ បរិក្ខារោ សង្ឃស្ស ហោតូតិ អនិស្សរោ តត្ថ ភិក្ខុសង្ឃោ ភិក្ខុនីសង្ឃស្សេវេតំ(១) ។ សិក្ខមានា ចេ ភិក្ខវេ ។ បេ ។

១ ឱ. ម. ភិក្ខុនីសង្ឃស្សេវ តំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



មិនត្រូវទ្រទ្រង់ចីវរក្រហមសុទ្ធ មិនត្រូវទ្រទ្រង់ចីវរហង្សបាទសុទ្ធ មិនត្រូវទ្រទ្រង់ចីវរខ្មៅសុទ្ធ មិនត្រូវទ្រទ្រង់ចីវរក្រហមក្រមៅសុទ្ធ មិនត្រូវទ្រទ្រង់ចីវរលឿងទុំសុទ្ធ មិនត្រូវទ្រទ្រង់ចីវរ មានជាយមិនបានកាត់ជាប់ មិនត្រូវទ្រទ្រង់ចីវរ មានជាយវែង មិនត្រូវទ្រទ្រង់ចីវរ មានជាយវិចិត្រដោយផ្កាឈើ មិនត្រូវទ្រទ្រង់ចីវរ មានជាយវិចិត្រដោយផ្លែឈើ មិនត្រូវទ្រទ្រង់អាវបំពង់វែង មិនត្រូវទ្រទ្រង់មួកទេ ភិក្ខុនីណាទ្រទ្រង់ ត្រូវអាបត្តិទុក្កដ ។

(៤២៣) សម័យនោះឯង មានភិក្ខុនី ១ រូប កាលដែលទៀបនឹងធ្វើមរណកាល បានផ្តាំយ៉ាងនេះថា អំណើះអំពីខ្ញុំទៅ បរិក្ខាររបស់ខ្ញុំ ចូរបានទៅជារបស់សង្ឃចុះ ។ ភិក្ខុនឹងភិក្ខុនីទាំងឡាយ ក្នុងទីនោះជជែកគ្នាថា បរិក្ខារនេះត្រូវបានយើង បរិក្ខារនេះត្រូវបានយើង ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុនី កាលដែលទៀបនឹងធ្វើមរណកាល បានផ្តាំយ៉ាងនេះថា អំណើះអំពីខ្ញុំទៅ បរិក្ខាររបស់ខ្ញុំ ចូរបានទៅជារបស់សង្ឃចុះដូច្នេះ ភិក្ខុសង្ឃមិនជាឥស្សរៈលើបរិក្ខារនោះទេ បរិក្ខារនុ៎ះត្រូវបានជារបស់ភិក្ខុនីសង្ឃ ។ ម្នាលភិក្ខុទាំងឡាយ បើសិក្ខាមានា ។ បេ ។

សាមណេរី ចេ ភិក្ខវេ កាលំ ករោន្តី ឯវំ វទេយ្យ មមច្ចយេន មយ្ហំ បរិក្ខារោ សង្ឃស្ស ហោតូតិ អនិស្សរោ តត្ថ ភិក្ខុសង្ឃោ ភិក្ខុនីសង្ឃស្សេវេតំ ។ ភិក្ខុ ចេ ភិក្ខវេ កាលំ ករោន្តោ ឯវំ វទេយ្យ មមច្ចយេន មយ្ហំ បរិក្ខារោ សង្ឃស្ស ហោតូតិ អនិស្សរោ តត្ថ ភិក្ខុនីសង្ឃោ ភិក្ខុសង្ឃស្សេវេតំ ។ សាមណេរោ ចេ ភិក្ខវេ ។បេ។ ឧបាសកោ ចេ ភិក្ខវេ ។បេ។ ឧបាសិកា ចេ ភិក្ខវេ ។បេ។ អញ្ញោ ចេ ភិក្ខវេ កោចិ កាលំ ករោន្តោ ឯវំ វទេយ្យ មមច្ចយេន មយ្ហំ បរិក្ខារោ សង្ឃស្ស ហោតូតិ អនិស្សរោ តត្ថ ភិក្ខុនីសង្ឃោ ភិក្ខុសង្ឃស្សេវេតន្តិ ។

(២២៤) តេន ខោ បន សមយេន អញ្ញតរា ឥត្ថី[១] បុរាណមល្លី ភិក្ខុនីសុ បព្វជិតា ហោតិ ។ សា រថិកាយ ទុព្វលកំ ភិក្ខុំ បស្សិត្វា អំសកូដេន បហារំ ទត្វា បវត្តេសិ ។ ភិក្ខូ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ

---

១ ឱ. ម. បោត្ថកេសុ ឥត្ថីសទ្ទោ ន បញ្ញាយតិ ។

ម្នាលភិក្ខុទាំងឡាយ បើសាមណេរ កាលដែលទៀបនឹងមរណកាល បានផ្តាំយ៉ាងនេះថា អំណើះអំពីខ្ញុំទៅ បរិក្ខាររបស់ខ្ញុំ ចូរបានទៅជារបស់សង្ឃចុះ យ៉ាងនេះ ភិក្ខុសង្ឃមិនជាធំក្នុងបរិក្ខារនោះទេ បរិក្ខារនុ៎ះត្រូវបានជារបស់ភិក្ខុនីសង្ឃ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុ កាលដែលទៀបនឹងមរណកាលហើយ បានផ្តាំយ៉ាងនេះថា អំណើះអំពីខ្ញុំទៅ បរិក្ខាររបស់ខ្ញុំ ចូរបានទៅជារបស់សង្ឃចុះ យ៉ាងនេះ ភិក្ខុនីសង្ឃមិនជាធំលើបរិក្ខារនោះទេ បរិក្ខារនុ៎ះត្រូវបានជារបស់ភិក្ខុសង្ឃ ។ ម្នាលភិក្ខុទាំងឡាយ បើសាមណេរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បើឧបាសក ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បើឧបាសិកា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បើនរណា ១ ដទៃ កាលដែលទៀបនឹងធ្វើមរណកាលហើយ បានផ្តាំយ៉ាងនេះថា អំណើះអំពីខ្ញុំទៅ បរិក្ខាររបស់ខ្ញុំ ចូរបានទៅជារបស់សង្ឃចុះ យ៉ាងនេះ ភិក្ខុនីសង្ឃមិនជាធំលើបរិក្ខារនោះទេ បរិក្ខារនុ៎ះត្រូវបានជារបស់ភិក្ខុសង្ឃ ។

[ ២២៤ ] សម័យនោះឯង មានស្ត្រីម្នាក់ជាភរិយាចាស់របស់ស្តេចមល្លៈ ចូលមកបួសក្នុងសំណាក់ភិក្ខុនី ។ ភិក្ខុនី ( បួសថ្មី ) នោះបានឃើញភិក្ខុ ១ រូប មានកម្លាំងថយដើរទៅតាមច្រក ប៉ះដោយចង្កួយស្មា ភិក្ខុនោះក៏ដួលចុះទៅ ។ ភិក្ខុទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


កថំ ហិ នាម ភិក្ខុនី ភិក្ខុស្ស បហារំ ទស្សតីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា ភិក្ខុស្ស បហារោ ទាតព្វោ យោ ទទេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ភិក្ខុនិយា ភិក្ខុំ បស្សិត្វា ទូរតោវ ឱក្កមិត្វា មគ្គំ ទាតុន្តិ ។

(២២៥) តេន ខោ បន សមយេន អញ្ញតរា ឥត្ថី បវុត្ថ-បតិកា ជារេន គព្ភិនី ហោតិ ។ សា គព្ភំ បាតេត្វា កុលុ-បកំ ភិក្ខុនឹ ឯតទវោច ហន្ទយ្យេ ឥមំ គព្ភំ បត្តេន នីហរាតិ ។ អថខោ សា ភិក្ខុនី តំ គព្ភំ បត្តេ បក្ខិបិត្វា សង្ឃាដិយា បដិច្ឆាទេត្វា អគមាសិ ។ តេន ខោ បន ស-មយេន អញ្ញតរេន បិណ្ឌចារិកេន ភិក្ខុនា សមាទានំ កតំ ហោតិ យំ យ្វាហំ(១) បឋមំ ភិក្ខំ លភិស្សាមិ ន តំ(២) អទត្វា ភិក្ខុស្ស វា ភិក្ខុនិយា វា បរិភុញ្ជិស្សា-មីតិ ។ អថខោ សោ ភិក្ខុ តំ ភិក្ខុនឹ បស្សិត្វា ឯតទ-វោច ហន្ទ ភគិនិ ភិក្ខំ បដិគ្គណ្ហាតិ ។ អលំ អយ្យាតិ ។ ទុតិយម្បិ ខោ សោ ភិក្ខុ តំ ភិក្ខុនឹ ឯតទវោច ហន្ទ

---

១ ឱ. ម. យាហំ ។ ២ តំសទ្ទោ ឱ. ម. បោត្ថកេសុ ន ទិស្សតិ ។

## ភិក្ខុនីខន្ធកៈ ការដាក់កូនខ្ចីក្នុងបាត្រនាំទៅ

មិនសមបើភិក្ខុនីនឹងដើរទៅប៉ះភិក្ខុទេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវឲ្យប៉ះភិក្ខុឡើយ ភិក្ខុនីណាឲ្យប៉ះ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីដែលឃើញភិក្ខុហើយ ត្រូវចៀសចេញអំពីចម្ងាយ បើកផ្លូវឲ្យ ។

[២២៥] សម័យនោះ មានស្ត្រីម្នាក់ជាស្រីប្តីលែងហើយ មានផ្ទៃដោយសហាយ ។ ស្រីនោះរំលូតកូនចេញហើយ បាននិយាយពាក្យនេះនឹងភិក្ខុនីជាកុលុបគី (១) ថា បពិត្រលោកម្ចាស់ លោកម្ចាស់សូមដាក់កូនខ្ចីនេះក្នុងបាត្រយកទៅចុះ ។ ភិក្ខុនីនោះដាក់កូនខ្ចីនោះក្នុងបាត្រ ហើយបិទបាំងនឹងសង្ឃាដីដើរទៅ ។ សម័យនោះឯង មានបិណ្ឌចារិកភិក្ខុ ១ រូប សមាទានថា បើអាត្មាអញបានបង្ហាន់ជាដម្បូងណា ហើយមិនទាន់បានឲ្យបង្ហាន់នោះដល់ភិក្ខុក្តី ភិក្ខុនីក្តី អាត្មាអញក៏មិនបរិភោគ ។ លំដាប់នោះ ភិក្ខុនោះបានឃើញភិក្ខុនីនោះហើយ និយាយពាក្យនេះថា ហ៎នាង នាងទទួលយកបង្ហាន់ចុះ ។ ភិក្ខុនីឆ្លើយថា ណ្ហើយ លោកម្ចាស់ ។ ភិក្ខុនោះនិយាយពាក្យនេះនឹងភិក្ខុនីនោះអស់វារៈពីរដងថា ហ៎នាង ចូរនាង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


ភគិនិ ភិក្ខំ បដិគ្គណ្ហាតិ ។ អលំ អយ្យោតិ ។ តតិយម្បិ ខោ សោ ភិក្ខុ តំ ភិក្ខុនឹ ឯតទវោច ហន្ទ ភគិនិ ភិក្ខំ បដិគ្គណ្ហាតិ ។ អលំ អយ្យោតិ ។ មយា ខោ ភគិនិ ស-មាទានំ កតំ យំ យ្វាហំ បឋមំ ភិក្ខំ លភិស្សាមិ ន តំ អទត្វា ភិក្ខុស្ស វា ភិក្ខុនិយា វា បរិភុញ្ជិស្សាមីតិ ហន្ទ ភគិនិ ភិក្ខំ បដិគ្គណ្ហាតិ ។ អថខោ សា ភិក្ខុនី តេន ភិក្ខុនា និប្បីឡិយមានា នីហរិត្វា បត្តំ ទស្សេសិ បស្ស អយ្យ បត្តេ ភត្តំ មា កស្សចិ អារោចេសីតិ ។ អថខោ សោ ភិក្ខុ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភិក្ខុនី បត្តេន ភត្តំ នីហរិស្សតីតិ ។ អថខោ សោ ភិក្ខុ ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនី បត្តេន ភត្តំ នីហរិស្សតីតិ ។ ភគវតោ ឯត-មត្ថំ អារោចេសុំ ។បេ។ ន ភិក្ខវេ ភិក្ខុនិយា បត្តេន ភត្តំ នីហរិតព្វំ យា នីហរេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ភិក្ខុនិយា ភិក្ខុំ បស្សិត្វា នីហរិត្វា បត្តំ ទស្សេតុន្តិ ។

ទទួលយកបង្ហាន់ទៅចុះ ។ ភិក្ខុនីឆ្លើយថា ណ្ហើយ លោកម្ចាស់ ។ ភិក្ខុនោះនិយាយពាក្យនេះនឹងភិក្ខុនីនោះអស់វារៈបីដងថា ហឹនាង ចូរនាងទទួលយកបង្ហាន់ទៅចុះ ។ ភិក្ខុនីឆ្លើយថា ណ្ហើយ លោកម្ចាស់ ។ ភិក្ខុប្រាប់ថា ម្នាលនាង យើងបានសមាទានថា (បើ) អាត្មាអញបានបង្ហាន់ណាជាដម្បូង ហើយមិនទាន់បានឲ្យបង្ហាន់នោះ ដល់ភិក្ខុក្ដី ដល់ភិក្ខុនីក្ដី អាត្មាអញក៏មិនឆាន់បង្ហាន់នោះទេ ម្នាលនាង ហឹចូរនាងទទួលយកបង្ហាន់នេះទៅចុះ ។ គ្រានោះ ភិក្ខុនីនោះ កាលបើភិក្ខុនោះបង្ខំ (ឲ្យទទួល) ក៏បង្ហាញបាត្រថា បពិត្រលោកម្ចាស់ សូមនិមន្តមើលកូនខ្ចីក្នុងបាត្រ (តែ) សូមលោកម្ចាស់កុំប្រាប់នរណាឡើយ ។ លំដាប់នោះ ភិក្ខុនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើភិក្ខុនីដាក់កូនខ្ចីក្នុងបាត្រសោះ ។ ទើបភិក្ខុនោះប្រាប់រឿងនុ៎ះ ដល់ភិក្ខុទាំងឡាយ ។ ភិក្ខុណាមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើភិក្ខុនីដាក់កូនខ្ចីក្នុងបាត្រសោះ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវដាក់កូនខ្ចីក្នុងបាត្រទេ ភិក្ខុនីណាដាក់យកទៅ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីឃើញភិក្ខុហើយត្រូវបើកបាត្របង្ហាញ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

## ភិក្ខុនីខន្ធកេ បុរិសព្យញ្ជនឧបនិជ្ឈានំ

[២២៦] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ ភិក្ខុំ បស្សិត្វា បរិវត្តេត្វា បត្តមូលំ ទស្សេន្តិ ។ តេ[១] ភិក្ខូ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខុនិយោ ភិក្ខុំ បស្សិត្វា បរិវត្តេត្វា បត្តមូលំ ទស្សេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ភិក្ខុនិយា ភិក្ខុំ បស្សិត្វា បរិវត្តេត្វា បត្តមូលំ ទស្សេតព្វំ យា ទស្សេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ភិក្ខុនិយា ភិក្ខុំ បស្សិត្វា ឧក្កុជ្ជិត្វា បត្តំ ទស្សេតុំ យញ្ច បត្តេ អាមិសំ ហោតិ តេន ច ភិក្ខុ និមន្តេតព្វោតិ ។

[២២៧] តេន ខោ បន សមយេន សាវត្ថិយា[២] រថិកាយ បុរិសព្យញ្ជនំ ឆឌ្ឌិតំ ហោតិ ។ តំ ភិក្ខុនិយោ សក្កច្ចំ ឧបនិជ្ឈាយឹសុ ។ មនុស្សា ឧក្កុដ្ឋិមកំសុ ។ តា ភិក្ខុនិយោ មង្កូ អហេសុំ ។ អថខោ តា ភិក្ខុនិយោ ឧបស្សយំ គន្ត្វា ភិក្ខុនីនំ ឯតមត្ថំ អារោចេសុំ ។ យា តា ភិក្ខុនិយោ អប្បិច្ឆា ។ បេ ។ តា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ បុរិស-

---

១ ឱ. ម. ពោត្ថកេសុ តេសទ្ទោ ន បញ្ញាយតិ ។ ២ ឱ. ម. សាវត្ថិយំ ។

## ភិក្ខុនីខន្ធកៈ ការគយគន់និមិត្តរបស់បុរស

(៤២៦) សម័យនោះឯង ពួកឆព្វគ្គិយាភិក្ខុនីបានឃើញភិក្ខុហើយផ្កូរបាត្រប្រាប់ថ្ងៃបាត្រ ។ ភិក្ខុទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើពួកឆព្វគ្គិយាភិក្ខុនី ឃើញភិក្ខុហើយផ្កូរបាត្រ រួបប្រាប់ថ្ងៃបាត្រសោះ ។ ទើបភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវឃើញភិក្ខុហើយផ្កូរបាត្រ រួបប្រាប់ថ្ងៃបាត្រទេ ភិក្ខុនីណាប្រាប់ថ្ងៃ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីឃើញភិក្ខុហើយបើកបាត្របង្ហាញ ប្រសិនបើមានអាមិសៈណានៅក្នុងបាត្រ ត្រូវនិមន្តភិក្ខុ ដោយអាមិសៈនោះចុះ ។

(៤២៧) សម័យនោះឯង មាននិមិត្តរបស់បុរសដែលគេចោលក្នុងប្រកក្នុងក្រុងសាវត្ថី ។ ភិក្ខុនីទាំងឡាយ ចូលទៅគយគន់និមិត្តនោះដោយផ្ចិតផ្ចង់ៗ មនុស្សទាំងឡាយធ្វើសម្លេងហ៊ោ ។ ភិក្ខុនីទាំងនោះក៏មានសេចក្តីអៀនខ្មាសៗ ទើបភិក្ខុនីទាំងអម្បាលនោះ ចូលទៅកាន់លំនៅ(ភិក្ខុនី)ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីផងគ្នា ។ ភិក្ខុនីណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុនីទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើភិក្ខុនី

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្យញ្ជនំ ឧបនិជ្ឈាយិស្សន្តីតិ ។ អថខោ តា ភិក្ខុនិ-យោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា បុរិស-ព្យញ្ជនំ ឧបនិជ្ឈាយិតព្វំ យោ ឧបនិជ្ឈាយេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២២៨) តេន ខោ បន សមយេន មនុស្សា ភិក្ខូនំ អាមិសំ ទេន្តិ ។ ភិក្ខូ(១) ភិក្ខុនីនំ ទេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភទន្តា អត្តនោ បរិភោគត្ថាយ ទិន្នំ អញ្ញេសំ ទស្សន្តិ ។ មយម្បិ ជានាម(២) ទានំ ទាតុន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ អត្តនោ បរិភោគត្ថាយ ទិន្នំ អញ្ញេសំ ទាតព្វំ យោ ទទេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២២៩) តេន ខោ សមយេន ភិក្ខូនំ អាមិសំ ឧស្សន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។

១ ភិក្ខូ ហាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ម. បយោជ្យេ ន ជានាម ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។


ទាំងឡាយ ចូលទៅគយគន់និមិត្ត របស់បុរសនោះ ។ ភិក្ខុនីទាំងនោះក៏ប្រាប់រឿងនុ៎ះដល់ភិក្ខុទាំងឡាយ ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវគយគន់មើលនិមិត្តរបស់បុរស ភិក្ខុនីណាចូលទៅគយគន់មើល ត្រូវអាបត្តិទុក្កដ ។

[២២៨] សម័យនោះឯង មនុស្សទាំងឡាយឲ្យអាមិសៈដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុក៏ឲ្យអាមិសៈ (នោះ) ទៅពួកភិក្ខុនី ។ មនុស្សទាំងឡាយនាំគ្នាពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើលោកម្ចាស់ទាំងនេះឲ្យ (អាមិសៈ) ដែលគេឲ្យសម្រាប់ឆាន់ខ្លួនឯងទៅអ្នកឯទៀតទេ យើងទាំងឡាយមិនចេះឲ្យទានឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យ (អាមិសៈ) ដែលគេឲ្យសម្រាប់ឆាន់ទៅអ្នកឯទៀតទេ ភិក្ខុណាឲ្យ ត្រូវអាបត្តិទុក្កដ ។

[២២៩] សម័យនោះឯង អាមិសៈរបស់ពួកភិក្ខុ ក៏សម្បូណ៌ច្រើនឡើង ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

ភិក្ខុនីខន្ធកេ សន្និធិប្បដិគ្គហាបនាទិកំ

អនុជានាមិ ភិក្ខវេ សង្ឃស្ស ទាតុន្តិ ។ ពាឡ្ហតរំ ឧស្សន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បុគ្គលិកម្បិ ទាតុន្តិ ។

[២៣០] តេន ខោ បន សមយេន ភិក្ខូនំ សន្និធិកតំ អាមិសំ ឧស្សន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភិក្ខូនំ សន្និធឹ ភិក្ខុនីហិ ភិក្ខូហិ បដិគ្គហាបេត្វា បរិភុញ្ជិតុន្តិ ។

[២៣១] តេន ខោ បន សមយេន មនុស្សា ភិក្ខុនីនំ អាមិសំ ទេន្តិ ។ ភិក្ខុនិយោ ភិក្ខូនំ ទេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុនិយោ អត្តនោ បរិភោគត្ថាយ ទិន្នំ អញ្ញេសំ ទស្សន្តិ ន មយម្បិ ជានាម ទានំ ទាតុន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា អត្តនោ បរិភោគត្ថាយ ទិន្នំ អញ្ញេសំ ទាតព្វំ យោ ទទេយ្យ អាបត្តិ ទុក្កដស្សាតិ ។

## ភិក្ខុនីខន្ធកៈ ការឲ្យទទួលការសន្សំ(របស់ភិក្ខុទាំងឡាយ)ជាដើម

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ ៗ (អាមិសៈ) ដល់សង្ឃ ។ អាមិសៈក៏កាន់តែសម្បូណ៌ច្រើនណាស់ទៅទៀត ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ ។ អាមិសៈទៅជារបស់បុគ្គលក៏បាន ។

(២៣០) សម័យនោះឯង ពួកភិក្ខុធ្វើការសន្សំអាមិសៈជាច្រើន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនី ឬភិក្ខុ ឲ្យគេទទួលការសន្សំរបស់ភិក្ខុទាំងឡាយបរិភោគចុះ ។

(២៣១) សម័យនោះឯង មនុស្សទាំងឡាយឲ្យអាមិសៈដល់ពួកភិក្ខុនី ។ ភិក្ខុនីទាំងឡាយឲ្យ (អាមិសៈ) នោះដល់ពួកភិក្ខុ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើភិក្ខុនីទាំងឡាយ ឲ្យអាមិសៈដែលគេឲ្យសម្រាប់បរិភោគខ្លួនឯងដល់ភិក្ខុឯទៀតសោះ យើងរាល់គ្នាមិនចេះឲ្យទានឬ ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវឲ្យអាមិសៈ ដែលគេឲ្យសម្រាប់បរិភោគខ្លួនឯង ដល់ភិក្ខុឯទៀតទេ ភិក្ខុនីណាឲ្យ ត្រូវអាបត្តិទុក្កដ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





(២៣២) តេន ខោ បន សមយេន ភិក្ខុនីនំ អាមិសំ ឧស្សន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សង្ឃស្ស ទាតុន្តិ ។ ពាឡ្ហតរំ ឧស្សន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បុគ្គលិកម្បិ ទាតុន្តិ ។

(២៣៣) តេន ខោ បន សមយេន ភិក្ខុនីនំ សន្និធិកតំ អាមិសំ ឧស្សន្នំ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភិក្ខុនីនំ សន្និធិំ ភិក្ខូហិ ភិក្ខុនីហិ បដិគ្គហាបេត្វា បរិភុញ្ជិតុន្តិ ។

(២៣៤) តេន ខោ បន សមយេន ភិក្ខូនំ សេនាសនំ ឧស្សន្នំ ហោតិ ភិក្ខុនីនំ សេនាសនំ[១] ន ហោតិ ។ ភិក្ខុនិយោ ភិក្ខូនំ សន្តិកេ ទូតំ បាហេសុំ សាធុ ភន្តេ អយ្យា អម្ហាកំ សេនាសនំ ទេន្តុ តាវកាលិកន្តិ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភិក្ខុនីនំ សេនាសនំ ទាតុំ តាវកាលិកន្តិ ។

---

១ ម. ពោត្ថកេសុ សេនាសនន្តិ ឥទំ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


(២៣២) សម័យនោះឯង អាមិសៈរបស់ភិក្ខុនីសម្បូណ៌ច្រើនឡើង ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ ( ភិក្ខុនី ) ឲ្យអាមិសៈដល់សង្ឃ ( អាមិសៈ ) ក៏កាន់តែសម្បូណ៌ច្រើនឡើងទៀត ៗ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ ៗ អាមិសៈទៅជារបស់បុគ្គលក៏បាន ។

( ២៣៣ ) សម័យនោះឯង ភិក្ខុនីធ្វើការសន្សំអាមិសៈដែលកាន់តែសម្បូណ៌ឡើង ៗ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឬភិក្ខុនី ឲ្យទទួលការសន្សំរបស់ភិក្ខុនីបរិភោគចុះ ។

(២៣៤) សម័យនោះឯងសេនាសនៈសម្បូណ៌ឡើងដល់ពួកភិក្ខុ ៗ សេនាសនៈមិនកើតឡើងដល់ពួកភិក្ខុនី ៗ ភិក្ខុនីទាំងឡាយក៏បញ្ជូនទូតទៅកាន់សំណាក់ពួកភិក្ខុថា បពិត្រលោកម្ចាស់ទាំងឡាយ សូមលោកម្ចាស់ឲ្យសេនាសនៈដល់យើងឲ្យជារបស់ខ្ចី ៗ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យខ្ចីសេនាសនៈដល់ពួកភិក្ខុនីជារបស់ខ្ចីបាន ។

## ភិក្ខុនីខន្ធកេ អាវសថចីវរាទិកានុជាននំ

[២៣៨] តេន ខោ បន សមយេន ឧតុនិយោ ភិក្ខុនិយោ ឱនទ្ធមញ្ចំ ឱនទ្ធបីឋំ អភិនិសីទន្តិបិ អភិនិបជ្ជន្តិបិ ។ សេនាសនំ លោហិតេន មក្ខិយតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា ឱនទ្ធមញ្ចំ ឱនទ្ធបីឋំ អភិនិសីទិតព្វំ អភិនិបជ្ជិតព្វំ យា អភិនិសីទេយ្យ វា អភិនិបជ្ជេយ្យ វា អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ អាវសថចីវរន្តិ ។ អាវសថចីវរំ លោហិតេន មក្ខិយតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អាណិចោឡកន្តិ ។ ចោឡកំ និបតតិ[1] ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សុត្តកេន ពន្ធិត្វា ឩរុយា ពន្ធិតុន្តិ ។ សុត្តកំ ឆិជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សំវេល្លិយំ កដិសុត្តកន្តិ ។

---

១ ឱ. និប្បតតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់[illegible]។

## ភិក្ខុនីខន្ធកៈ ការទ្រង់អនុញ្ញាតនូវចីវរក្នុងរោងទានជាដើម

(២៣៥) សម័យនោះឯង ភិក្ខុនីទាំងឡាយមានរដូវ អង្គុយសង្កត់ខ្លះ ដេកសង្កត់ខ្លះ នូវគ្រែដែលគេញាត់ភ្ជាប់នឹងតាំងដែលគេញាត់ភ្ជាប់ ។ សេនាសនៈក៏ប្រឡាក់ដោយឈាម ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវអង្គុយសង្កត់ ដេកសង្កត់ នូវគ្រែដែលគេញាត់ភ្ជាប់ នូវតាំងដែលគេញាត់ភ្ជាប់ទេ ភិក្ខុនីណាអង្គុយសង្កត់ក្តី ដេកសង្កត់ក្តី ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវចីវរក្នុងរោងទាន ។ ចីវរក្នុងរោងទានក៏ប្រឡាក់ដោយឈាម ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលរឿងនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវសំពត់ទ្រនាប់ ។ សំពត់ទ្រនាប់ក៏របូតចុះ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចង (សំពត់ទ្រនាប់) ដោយសរសៃអំបោះហើយចងភ្ជាប់នឹងភ្លៅចុះ ។ សរសៃអំបោះក៏ដាច់ទៅ ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សែក្រវាត់សម្រាប់បង្ខកក្បិន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[២៣៦] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ សព្វកាលំ កដិសុត្តកំ ធារេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហិកាមភោគិនិយោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា សព្វកាលំ កដិសុត្តកំ ធារេតព្វំ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ឧតុនិយា កដិសុត្តកន្តិ ។

## ទុតិយភាណវារំ ។

[២៣៧] តេន ខោ បន សមយេន ឧបសម្បន្នាយោ ទិស្សន្តិ អនិមិត្តាបិ និមិត្តមត្តាបិ អលោហិតាបិ ធុវលោហិតាបិ ធុវចោឡាបិ បគ្ឃរន្តីបិ សិខរិណីបិ[១] ឥត្ថិបណ្ឌកាបិ[២] វេបុរិសិកាបិ សម្ភិន្នាបិ ឧភតោព្យញ្ជនកាបិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧបសម្បាទេន្តិយា ចតុវីសតិ អន្តរាយិកេ ធម្មេ បុច្ឆិតុំ ។ ឯវញ្ច បន ភិក្ខវេ បុច្ឆិតព្វា

១ ម. សិខរណីបិ ។ ២. ឥត្ថិបណ្ឌិកាបិ ។

(៤៣៦) សម័យនោះឯង ឆព្វគ្គិយាភិក្ខុនី ទ្រទ្រង់ខ្សែក្រវាត់សព្វកាល ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចជាពួកស្រីគ្រហស្ថអ្នកបរិភោគកាម ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវប្រើខ្សែក្រវាត់សព្វកាលទេ ភិក្ខុនីណាប្រើ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតខ្សែក្រវាត់ដល់ភិក្ខុនីដែលមានរដូវ ។

ចប់ ភាណវារៈ ទី ២ ។

(៤៣៧) សម័យនោះឯង ឧបសម្បន្នាភិក្ខុនីទាំងឡាយ គ្មាននិមិត្តខ្លះ មានហេតុគ្រាន់តែជានិមិត្តខ្លះ មិនមានឈាមរដូវខ្លះ មានឈាមរដូវជានិច្ចខ្លះ មានសំពត់ទ្រនាប់ជានិច្ចខ្លះ មានឈាមរដូវហូរខ្លះ ជាសិខរណីខ្លះ ជាស្រីខ្ទើយខ្លះ មានរូបដូចប្រុសខ្លះ ទ្វារមគ្គ (ទាំង ២) រលាយចូលគ្នាខ្លះ ជាឧភតោព្យញ្ជនកាខ្លះ ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលរឿងនុះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ (ភិក្ខុនី)សួរនូវអន្តរាយិកធម៌ ២៤ ប្រការចំពោះស្ត្រីដែលមកសូមឧបសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុសួរភិក្ខុនី

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

## ភិក្ខុនីខន្ធកេ ចតុព្វីសន្តរាយិកធម្មា

នត្ថិ អនិមិត្តា នត្ថិ និមិត្តមត្តា នត្ថិ អលោហិតា នត្ថិ ធុវលោហិតា នត្ថិ ធុវចោឡា នត្ថិ បគ្ឃរន្តី នត្ថិ សិខរិណី នត្ថិ ឥត្ថីបណ្ឌកា នត្ថិ វេបុរិសិកា នត្ថិ សម្ភិន្នា នត្ថិ ឧភតោព្យញ្ជនកា[១] សន្តិ តេ ឯវរូបា អាពាធា កុដ្ឋំ គណ្ឌោ កិលាសោ សោសោ អបមារោ មនុស្សាសិ ឥត្ថីសិ ភុជិស្សាសិ អនណាសិ នត្ថិ រាជភដី អនុញ្ញាតាសិ មាតាបិតូហិ សាមិកេន បរិបុណ្ណវីសតិវស្សាសិ បរិបុណ្ណន្តេ បត្តចីវរំ កិន្នាមាសិ កានាមា តេ បវត្តិនីតិ ។

(២៦៨) តេន ខោ បន សមយេន ភិក្ខូ ភិក្ខុនីនំ អន្តរាយិកេ ធម្មេ បុច្ឆន្តិ ។ ឧបសម្បទាបេក្ខាយោ វិត្ថាយន្តិ មង្កូ ហោន្តិ ន សក្កោន្តិ វិស្សជ្ជេតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ

---

១ ឧ. ឧភតោវ្យញ្ជនា ។ ម. ឧភតោព្យញ្ជនា ។

យ៉ាងនេះថា នាងមិនមែនឥតនិមិត្តទេឬ នាងមិនមែនមានហេតុគ្រាន់តែជានិមិត្តទេឬ នាងមិនមែនមិនមានឈាមទេ ឬ នាងមិនមានឈាមជានិច្ចទេឬ នាងមិនមែនមានសំពត់ទ្រនាប់ជានិច្ចទេឬ នាងមិនមែនមានឈាមរដូវហូរជានិច្ចទេឬ នាងមិនមែនជាសិខរិណីទេឬ នាងមិនមែនជាស្ត្រីខ្ទើយទេឬ នាងមិនមែនជាស្ត្រីមានរូបដូចប្រុសទេឬ នាងឥតមានទ្វារមគ្គរលាយចូលគ្នាទេឬ នាងមិនមែនជាឧភតោព្យញ្ជនកាទេឬ (ម្យ៉ាងទៀត) អាពាធយ៉ាងនេះ គឺ ឃ្លង់ ពក ស្រែង ស្រកីអណ្តាន ឆ្កួតជ្រូក នាងមានឬទេ នាងជាមនុស្សឬ នាងជាស្ត្រីឬ នាងជាអ្នកជាឬ នាងមិនមានជំពាក់បំណុលគេទេឬ នាងមិនមែនជាអ្នកបំរើព្រះរាជាទេឬ មាតាបិតានិងប្តី (របស់នាង) បានអនុញ្ញាតហើយឬ នាងមានអាយុគ្រប់ ២០ ឆ្នាំហើយឬ នាងមានបាត្រនិងចីវរគ្រប់គ្រាន់ហើយឬ នាងឈ្មោះអ្វី បវត្តិនី (ឧបជ្ឈាយ៍) របស់នាងឈ្មោះអ្វី ។

(២៣៨) សម័យនោះឯង ភិក្ខុទាំងឡាយសួរអន្តរាយិកធម៌ចំពោះពួកភិក្ខុនី ។ ឧបសម្បទាបេក្ខាទាំងឡាយអៀនខ្មាសមានមុខឱនចុះ មិនអាចនឹងឆ្លើយប្រាប់បាន ។ ពួកភិក្ខុក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឯកតោ ឧបសម្បន្នាយ ភិក្ខុនីសង្ឃេ វិសុទ្ធាយ ភិក្ខុសង្ឃេ ឧបសម្បាទេតុន្តិ[១] ។

[២៣៩] តេន ខោ បន សមយេន ភិក្ខុនិយោ អននុសិដ្ឋាយោ[២] ឧបសម្បទាបេក្ខាយោ អន្តរាយិកេ ធម្មេ បុច្ឆន្តិ ។ ឧបសម្បទាបេក្ខាយោ វិត្ថាយន្តិ មង្កូ ហោន្តិ ន សក្កោន្តិ វិស្សជ្ជេតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បឋមំ អនុសាសិត្វា បច្ឆា អន្តរាយិកេ ធម្មេ បុច្ឆិតុន្តិ ។ តត្ថេវ សង្ឃមជ្ឈេ អនុសាសន្តិ ។ ឧបសម្បទាបេក្ខាយោ តថេវ វិត្ថាយន្តិ មង្កូ ហោន្តិ ន សក្កោន្តិ វិស្សជ្ជេតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឯកមន្តំ អនុសាសិត្វា សង្ឃមជ្ឈេ អន្តរាយិកេ ធម្មេ បុច្ឆិតុំ ។ ឯវញ្ច បន ភិក្ខវេ អនុសាសិតព្វា ។ បឋមំ ឧបជ្ឈំ គាហាបេតព្វា ឧបជ្ឈំ គាហាបេត្វា បត្តចីវរំ អាចិក្ខិតព្វំ អយន្តេ បត្តោ អយំ សង្ឃាដិ អយំ ឧត្តរាសង្គោ អយំ អន្តរវាសកោ ឥទំ សង្កច្ចិកំ[៣]

---

១ ឱ. ឧបសម្បទេន្តិ ។ ២ ឱ. ម. អននុសិដ្ឋា ។ ៣ ម. **សង្កច្ចិកំ** ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដើម្បីឲ្យឧបសម្បទាក្នុងសំណាក់ភិក្ខុសង្ឃ ដល់ភិក្ខុនីដែលបានឧបសម្បទា ដោយចំណែកម្ខាងជំបរិសុទ្ធក្នុងភិក្ខុនីសង្ឃរួច (ម្តង) ហើយ ។

(៦៣៩) សម័យនោះឯង ពួកភិក្ខុនី មិនបានប្រៀនប្រដៅឧបសម្បទាបេក្ខាសោះទេ គ្រាន់តែសាកសួរអន្តរាយិកធម៌ ។ ឧបសម្បទាបេក្ខាក៏អៀនខ្មាសមានមុខខ្ទេចុះមិនអាចនឹងឆ្លើយប្រាប់បាន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យប្រៀនប្រដៅជាមុនសិន ហើយសឹមសួរអន្តរាយិកធម៌ជាក្រោយ ។ ពួកភិក្ខុក៏ប្រៀនប្រដៅ (ឧបសម្បទាបេក្ខា) ក្នុងកណ្តាលជំនុំសង្ឃនោះ ។ ឧបសម្បទាបេក្ខានៅតែអៀនខ្មាសមានមុខខ្ទេចុះ មិនអាចឆ្លើយប្រាប់បានដូច្នោះទៀត ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលរឿងនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យប្រៀនប្រដៅក្នុងទីដ៏សមគួរ ហើយសឹមសួរអន្តរាយិកធម៌ ក្នុងកណ្តាលជំនុំសង្ឃ ។ ម្នាលភិក្ខុទាំងឡាយ (ភិក្ខុនី) ត្រូវប្រៀនប្រដៅឧបសម្បទាបេក្ខាយ៉ាងនេះ ។ មុនដំបូងត្រូវភិក្ខុនីឲ្យឧបសម្បទាបេក្ខា កាន់យកឧបជ្ឈាយ៍ លុះឲ្យកាន់យកឧបជ្ឈាយ៍ហើយ គប្បីប្រាប់បាត្រនិងចីវរថា នេះជាបាត្រ នេះជាសង្ឃាដី នេះជាចីពរ នេះជាស្បង់ នេះជាសំពត់ពុង[1]

---

១ តាមទំនងពាក្យខ្មែរខ្លះ គួរប្រែថា អៀម ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកេ អត្តសម្មតិ បរសម្មតិ

អយំ ឧទកសាដិកា គច្ឆ អមុម្ហិ ឱកាសេ តិដ្ឋាហីតិ ។ ពាលា អព្យត្តា អនុសាសន្តិ ។ ទុរនុសិដ្ឋា[១] ឧបសម្បទាបេក្ខាយោ វិត្ថាយន្តិ មង្កុ ហោន្តិ ន សក្កោន្តិ វិស្សជ្ជេតុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ពាលាយ អព្យត្តាយ អនុសាសិតព្វា យា អនុសាសេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ព្យត្តាយ ភិក្ខុនិយា បដិពលាយ អនុសាសិតុន្តិ ។ អសម្មតា អនុសាសន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ អសម្មតាយ អនុសាសិតព្វា យា អនុសាសេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ សម្មតាយ អនុសាសិតុំ ។ ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វា ។ អត្តនា វា អត្តានំ សម្មន្និតព្វំ បរាយ វា បរា សម្មន្និតព្វា ។

---

១ ឱ. ម. អនុសិដ្ឋា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕





នេះជាសំពត់ផ្លូតទឹករបស់នាង នាងចូរទៅឈរ ក្នុងទីឱកាសឯណោះ ។ (វេលានោះ) ភិក្ខុនីល្ងង់មិនឆ្លាសទៅប្រដៅ ។ ឧបសម្បទាបេក្ខាទាំងឡាយ ដែលភិក្ខុនីមិនឆ្លាសប្រដៅមិនស្រួល ក៏នៅតែរឹងខ្លួនអៀនខ្មាស មិនអាចនឹងឆ្លើយប្រាប់បាន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីដែលល្ងង់មិនឆ្លាសមិនត្រូវប្រដៅឧបសម្បទាបេក្ខាទេ ភិក្ខុនីណាប្រដៅ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីដែលឆ្លាសប្រតិពលប្រដៅ (ឧបសម្បទាបេក្ខា) បាន ។ ភិក្ខុនីដែលសង្ឃមិនបានសន្មត ក៏ទៅប្រៀនប្រដៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីដែលសង្ឃមិនបានសន្មត មិនត្រូវប្រៀនប្រដៅឧបសម្បទាបេក្ខាទេ ភិក្ខុនីណាប្រៀនប្រដៅ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនី ដែលសង្ឃសន្មតហើយ (នោះ) ប្រៀនប្រដៅបាន ។ ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីសន្មតយ៉ាងនេះ ។ ខ្លួនឯងគប្បីសន្មតខ្លួនឯងក៏បាន ភិក្ខុនីដទៃគប្បីសន្មតភិក្ខុនីដទៃក៏បាន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(២៤០) កថញ្ច អត្តនា វា អត្តានំ សម្មន្និតព្វំ ។ ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ ឥត្ថន្នាមាយ អយ្យាយ ឧបសម្បទាបេក្ខា ។ យទិ សង្ឃស្ស បត្តកល្លំ អហំ ឥត្ថន្នាមំ អនុសាសេយ្យន្តិ ។ ឯវំ អត្តនា វា[១] អត្តានំ សម្មន្និតព្វំ ។

(២៤១) កថញ្ច បរាយ[២] បរា សម្មន្និតព្វា ។ ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ ឧបសម្បទាបេក្ខា ។ យទិ សង្ឃស្ស បត្តកល្លំ ឥត្ថន្នាមា ឥត្ថន្នាមំ អនុសាសេយ្យាតិ ។ ឯវំ បរាយ បរា សម្មន្និតព្វា ។

(២៤២) តាយ សម្មតាយ ភិក្ខុនិយា ឧបសម្បទាបេក្ខា ឧបសង្កមិត្វា ឯវមស្ស វចនីយា សុណាសិ ឥត្ថន្នាមេ អយន្តេ សច្ចកាលោ ភូតកាលោ យំ ជាតំ តំ សង្ឃមជ្ឈេ បុច្ឆន្តេ សន្តំ អត្ថីតិ វត្តព្វំ អសន្តំ នត្ថីតិ

១ ឱ. ម. ភិ ។ ២ ឱ. ម. បរាយ ភិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[៤៤០] ខ្លួនឯងគប្បីសន្មតខ្លួនឯងយ៉ាងណា ។ ភិក្ខុនីដែលឆ្លាសប្រតិពលត្រូវប្រកាសសង្ឃថា បពិត្រព្រះនាងជាម្ចាស់ សូមព្រះសង្ឃស្តាប់ខ្ញុំ (ដ្បិត) ឧបសម្បទាបេក្ខា (ជាសិស្ស) របស់នាងជាម្ចាស់ឈ្មោះនេះ ។ បើកម្មមានកាលគួរដល់សង្ឃហើយ ខ្ញុំម្ចាស់គប្បីប្រៀនប្រដៅ ឧបសម្បទាបេក្ខាឈ្មោះនេះ ។ ខ្លួនឯងគប្បីសន្មតខ្លួនឯងយ៉ាងនេះ ។

[៤៤១] ភិក្ខុនីដទៃគប្បីសន្មតភិក្ខុនីដទៃ យ៉ាងណា ។ ភិក្ខុនីដែលឆ្លាសប្រតិពលគប្បីញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះនាងជាម្ចាស់ សូមព្រះសង្ឃស្តាប់ខ្ញុំ លោកម្ចាស់ឈ្មោះនេះជាឧបសម្បទាបេក្ខា របស់ភិក្ខុនីឈ្មោះនេះ ។ បើកម្មមានកាលគួរដល់សង្ឃហើយ ភិក្ខុនីឈ្មោះនេះគប្បីប្រៀនប្រដៅឧបសម្បទាបេក្ខាឈ្មោះនេះ ។ ភិក្ខុនីដទៃគប្បីសន្មតភិក្ខុនីដទៃ ដោយអាការយ៉ាងនេះ ។

[៤៤២] ភិក្ខុនីដែលសង្ឃសន្មតហើយនោះ គប្បីចូលទៅរកឧបសម្បទាបេក្ខា ហើយពោលយ៉ាងនេះថា នែនាងឈ្មោះនេះ នាងស្តាប់ហ្ន៎ កាលនេះជាកាលពិត ជាកាលមែនរបស់នាងហើយ របស់ណាដែលកើតហើយ ខ្ញុំសួររបស់នោះចំពោះនាងក្នុងកណ្តាលជំនុំសង្ឃ ហេតុដែលមាន នាងត្រូវនិយាយថាមាន ហេតុដែលមិនមាន នាងត្រូវនិយាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកេ ញត្តិចតុត្ថកម្មឧបសម្បទា

វត្តព្វំ មា ខោ វិត្ថាសិ មា ខោ មង្កុ អហោសិ ឯវន្តំ បុច្ឆិ-
ស្សន្តិ នសិ អនិមិត្តា នសិ និមិត្តមត្តា នសិ អលោ-
ហិតា នសិ ធុវលោហិតា នសិ ធុវចោឡា នសិ បគ្ឃ-
រន្តី នសិ សិខរិណី នសិ ឥត្ថីបណ្ឌកា នសិ វេបុរិសិកា
នសិ សម្ភិន្នា នសិ ឧភតោព្យញ្ជនកា សន្តិ តេ ឯវរូបា
អាពាធា កុដ្ឋំ គណ្ឌោ កិលាសោ សោសោ អបមារោ
មនុស្សាសិ ឥត្ថីសិ ភុជិស្សាសិ អនណាសិ នសិ រាជ-
ភដី អនុញ្ញាតាសិ មាតាបិតូហិ សាមិកេន បរិបុណ្ណវី-
សតិវស្សាសិ បរិបុណ្ណន្តេ បត្តចីវរំ កិន្នាមាសិ កានាមា
តេ បវត្តិនីតិ ។ ឯកតោ អាគច្ឆន្តិ ។ បេ ។ ន ឯកតោ
អាគន្តព្វំ ។ អនុសាសិកាយ បឋមតរំ អាគន្ត្វា សង្ឃោ
ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ ឥត្ថន្នាមា ឥត្ថ-
ន្នាមាយ អយ្យាយ ឧបសម្បទាបេក្ខា អនុសិដ្ឋា សា
មយា ។ យទិ សង្ឃស្ស បត្តកល្លំ ឥត្ថន្នាមា

## ភិក្ខុនីខន្ធកៈ ញត្តិចតុត្ថកម្មឧបសម្បទា

ជាមិនមាន នាងកុំរង្វើនឡើយ កុំអៀនខ្មាសឡើយ ខ្ញុំនឹងសួរនាងយ៉ាងនេះថា នាងមិនមែនឥតនិមិត្តទេឬ នាងមិនមែនមានហេតុគ្រាន់តែជានិមិត្តទេឬ នាងមិនមែនឥតឈាមទេឬ នាងមិនមានឈាមជានិច្ចទេឬ នាងមិនមែនមានសំពត់ទ្រនាប់ជានិច្ចទេឬ នាងមិនមែនមានឈាមរដូវហូរជានិច្ចទេឬ នាងមិនមែនជាសិខរិណីទេឬ នាងមិនមែនជាស្ត្រីខ្ទើយទេឬ នាងមិនមែនមានរូបដូចប្រុសទេឬ នាងមិនមានទ្វារមគ្គលាយចូលគ្នាទេឬ នាងមិនមែនជាឧភតោព្យញ្ជនកាទេឬ នាងមានអាពាធយ៉ាងនេះគឺ ឃ្លង់ ពក ស្រែង រឹងរៃ ឆ្កួតជ្រូកដែរឬ នាងជាមនុស្សឬ នាងជាស្ត្រីឬ នាងជាអ្នកជាឬ នាងជាស្ត្រីឥតបំពាក់បំណុលគេទេឬ នាងមិនមែនជាអ្នកបំរើព្រះរាជាទេឬ មាតាបិតានឹងប្តីរបស់នាងបានអនុញ្ញាតហើយឬ នាងមានអាយុគ្រប់ ២០ ឆ្នាំហើយឬ នាងមានបាត្រនឹងចីវរ គ្រប់គ្រាន់ហើយឬ នាងឈ្មោះអ្វី បវត្តិនីរបស់នាងឈ្មោះអ្វី ។ ភិក្ខុនីជាអ្នកប្រៀនប្រដៅ នឹងឧបសម្បទាបេក្ខាមកជាមួយគ្នា ។ បេ ។ មិនគប្បីមកជាមួយគ្នាទេ ។ ភិក្ខុនីជាអ្នកប្រៀនប្រដៅគប្បីមកមុនបង្អស់ ហើយផ្តៀងសង្ឃឲ្យដឹងថា បពិត្រព្រះនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ដ្បិតនាងសិក្ខមានាឈ្មោះនេះជាឧបសម្បទាបេក្ខារបស់នាងជាម្ចាស់ឈ្មោះនេះ ខ្ញុំម្ចាស់បានប្រៀនប្រដៅហើយ ។ បើកម្មមានកាលគួរដល់សង្ឃហើយ ឧបសម្បទាបេក្ខាឈ្មោះនេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



អាគច្ឆេយ្យាតិ ។ អាគច្ឆាហីតិ វត្តព្វា ។ ឯកំសំ ឧត្តរាសង្គំ ការាបេត្វា ភិក្ខូនំ បាទេ វន្ទាបេត្វា ឧក្កុដិកំ និសីទាបេត្វា អញ្ជលឹ បគ្គណ្ហាបេត្វា ឧបសម្បទំ យាចាបេតព្វា សង្ឃំ អយ្យេ ឧបសម្បទំ យាចាមិ ឧល្លុម្បតុ មំ អយ្យេ សង្ឃោ អនុកម្បំ ឧបាទាយ ទុតិយម្បិ អយ្យេ សង្ឃំ ឧបសម្បទំ យាចាមិ ឧល្លុម្បតុ មំ អយ្យេ សង្ឃោ អនុកម្បំ ឧបាទាយ តតិយម្បិ អយ្យេ សង្ឃំ ឧបសម្បទំ យាចាមិ ឧល្លុម្បតុ មំ អយ្យេ សង្ឃោ អនុកម្បំ ឧបាទាយាតិ ។ ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ ឧបសម្បទាបេក្ខា យទិ សង្ឃស្ស បត្តកល្លំ អហំ ឥត្ថន្នាមំ អន្តរាយិកេ ធម្មេ បុច្ឆេយ្យន្តិ ។ សុណសិ ឥត្ថន្នាមេ អយន្តេ សច្ចកាលោ ភូតកាលោ យំ ជាតំ តំ បុច្ឆាមិ សន្តំ អត្ថីតិ វត្តព្វំ អសន្តំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



គប្បីមក ៗ ភិក្ខុនីអ្នកប្រៀនប្រដៅគប្បីពោលថា នាងចូរមក ៗ ត្រូវភិក្ខុនីអ្នកប្រៀនប្រដៅឲ្យឧបសម្បទាបេក្ខានោះ ធ្វើចីពរឆៀងស្មាម្ខាង ឲ្យថ្វាយបង្គំបាទាភិក្ខុនីទាំងឡាយ ឲ្យអង្គុយច្រហោងផ្គងអញ្ជលីឡើងហើយ ឲ្យសូមឧបសម្បទាថា បពិត្រនាងជាម្ចាស់ ខ្ញុំម្ចាស់សូមឧបសម្បទានឹងសង្ឃ បពិត្រនាងជាម្ចាស់ សូមសង្ឃអាស្រ័យសេចក្ដីអនុគ្រោះស្រោចស្រង់ខ្ញុំផង បពិត្រនាងជាម្ចាស់ ខ្ញុំម្ចាស់សូមឧបសម្បទានឹងសង្ឃ អស់វារៈពីរដងផង បពិត្រនាងជាម្ចាស់ សូមសង្ឃអាស្រ័យសេចក្ដីអនុគ្រោះស្រោចស្រង់ខ្ញុំផង បពិត្រនាងជាម្ចាស់ ខ្ញុំម្ចាស់សូមឧបសម្បទានឹងសង្ឃ អស់វារៈបីដងផង បពិត្រនាងជាម្ចាស់ សូមសង្ឃអាស្រ័យសេចក្ដីអនុគ្រោះស្រោចស្រង់ខ្ញុំផង ៗ ភិក្ខុនីដែលឆ្លាសប្រតិពលគប្បីផ្ដៀងសង្ឃឲ្យដឹងថា បពិត្រនាងជាម្ចាស់ សូមសង្ឃស្ដាប់ខ្ញុំ ដ្បិតនាងឈ្មោះនេះ នេះជាឧបសម្បទាបេក្ខារបស់នាងជាម្ចាស់ឈ្មោះនេះ បើកម្មមានកាលគួរដល់សង្ឃហើយ ខ្ញុំគួរសួរអន្តរាយិកធម៌នឹងឧបសម្បទាបេក្ខាឈ្មោះនេះ ៗ នែនាងឈ្មោះនេះ នាងស្ដាប់ហ្ន៎ កាលនេះជាកាលពិត ជាកាលមែនរបស់នាងហើយ ហេតុណាដែលកើតហើយ ខ្ញុំសួរចំពោះហេតុនោះ ហេតុដែលមាន នាងគប្បីឆ្លើយថាមាន ហេតុដែលគ្មាន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកេ ញត្តិចតុត្ថកម្មុបសម្បទា

នត្ថីតិ វត្តព្វំ នសិ អនិមិត្តា នសិ និមិត្តមត្តា ។បេ។ កិន្នាមាសិ កានាមា តេ បវត្តិនីតិ។ ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ ឧបសម្បទាបេក្ខា បរិសុទ្ធា អន្តរាយិកេហិ ធម្មេហិ ។ បរិបុណ្ណាស្សា បត្តចីវរំ ។ ឥត្ថន្នាមា សង្ឃំ ឧបសម្បទំ យាចតិ ឥត្ថន្នាមាយ អយ្យាយ បវត្តិនិយា ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ឧបសម្បាទេយ្យ ឥត្ថន្នាមាយ អយ្យាយ បវត្តិនិយា ។ ឯសា ញត្តិ ។ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ ឧបសម្បទាបេក្ខា បរិសុទ្ធា អន្តរាយិកេហិ ធម្មេហិ ។ បរិបុណ្ណាស្សា បត្តចីវរំ ។ ឥត្ថន្នាមា សង្ឃំ ឧបសម្បទំ យាចតិ ឥត្ថន្នាមាយ អយ្យាយ បវត្តិនិយា ។ សង្ឃោ ឥត្ថន្នាមំ ឧបសម្បាទេតិ ឥត្ថន្នាមាយ អយ្យាយ បវត្តិនិយា ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ ឧបសម្បទា ឥត្ថន្នាមាយ អយ្យាយ បវត្តិនិយា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកៈ ញត្តិចតុត្ថកម្មឧបសម្បទា

នាងគប្បីឆ្លើយថាគ្មាន នាងមិនមែនឥតនិមិត្តទេឬ នាងមិនមែនមានហេតុគ្រាន់តែជានិមិត្តទេឬ ។ បេ ។ នាងឈ្មោះអ្វី បវត្តិនីរបស់នាងឈ្មោះអ្វី ។ ភិក្ខុនីដែលឈ្លាសប្រតិពលគប្បីផ្តៀងសង្ឃឲ្យដឹងថា បពិត្រនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ ដ្បិតនាងឈ្មោះនេះនេះ ជាឧប-សម្បទាបេក្ខា របស់នាងជាម្ចាស់ឈ្មោះនេះ បរិសុទ្ធចាកអន្តរាយិកធម៌ទាំងឡាយហើយ ។ បាត្រនិងចីវររបស់នាងនេះមានគ្រប់គ្រាន់ហើយ ។ ឥឡូវ ឧបសម្បទាបេក្ខាឈ្មោះនេះ មាននាងជាម្ចាស់ឈ្មោះនេះជាបវត្តិនីមកសូមឧបសម្បទានឹងសង្ឃ ។ បើកម្មមានកាលគួរដល់សង្ឃហើយសង្ឃគប្បីញ៉ាំងឧបសម្បទាបេក្ខាឈ្មោះនេះ មាននាងជាម្ចាស់ឈ្មោះនេះជាបវត្តិនីឲ្យបានឧបសម្បទា ។ នេះជាញត្តិ ។ បពិត្រនាងជាម្ចាស់សូមសង្ឃស្តាប់ខ្ញុំ ដ្បិតនាងឈ្មោះនេះនេះ ជាឧបសម្បទាបេក្ខា របស់នាងជាម្ចាស់ឈ្មោះនេះ បរិសុទ្ធចាកអន្តរាយិកធម៌ទាំងឡាយហើយ ។ បាត្រនិងចីវររបស់នាងនេះមានគ្រប់គ្រាន់ហើយ ។ ឥឡូវឧបសម្បទា-បេក្ខាឈ្មោះនេះ មាននាងជាម្ចាស់ឈ្មោះនេះជាបវត្តិនី មកសូមឧបសម្បទានឹងសង្ឃ ។ ឥឡូវសង្ឃញ៉ាំងឧបសម្បទាបេក្ខាឈ្មោះនេះ មាននាងជាម្ចាស់ឈ្មោះនេះជាបវត្តិនីឲ្យបានឧបសម្បទា ។ ឧបសម្បទារបស់ឧប-សម្បទាបេក្ខាឈ្មោះនេះ មាននាងជាម្ចាស់ឈ្មោះនេះជាបវត្តិនី គួរដល់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ ឧបសម្បទាបេក្ខា បរិសុទ្ធា អន្តរាយិកេហិ ធម្មេហិ ។ បរិបុណ្ណស្សា បត្តចីវរំ ។ ឥត្ថន្នាមា សង្ឃំ ឧបសម្បទំ យាចតិ ឥត្ថន្នាមាយ អយ្យាយ បវត្តិនិយា ។ សង្ឃោ ឥត្ថន្នាមំ ឧបសម្បាទេតិ ឥត្ថន្នាមាយ អយ្យាយ បវត្តិនិយា ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ ឧបសម្បទា ឥត្ថន្នាមាយ អយ្យាយ បវត្តិនិយា សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ ។ ឧបសម្បន្នា សង្ឃេន ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ បវត្តិនិយា ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះគប្បីស្ងៀម មិនគួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះគប្បីឆ្លើយមក ។ ខ្ញុំប្រកាសសេចក្តីនេះអស់វារៈពីរដងផង ។ បេ ។ ខ្ញុំប្រកាសសេចក្តីនេះ អស់វារៈបីដងផងជាបពិត្រនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ នាងឈ្មោះនេះនេះ ជាឧបសម្បទាបេក្ខា របស់នាងជាម្ចាស់ឈ្មោះនេះ បរិសុទ្ធចាកអន្តរាយិកធម៌ទាំងឡាយហើយ ។ បាត្រនឹងចីវររបស់នាងនេះ មានគ្រប់គ្រាន់ហើយ ។ ឥឡូវឧបសម្បទាបេក្ខាឈ្មោះនេះ មាននាងជាម្ចាស់ឈ្មោះនេះជាបវត្តិនី មកសូមឧបសម្បទានឹងសង្ឃ ។ ឥឡូវសង្ឃញ៉ាំងឧបសម្បទាបេក្ខាឈ្មោះនេះ របស់នាងជាម្ចាស់ឈ្មោះនេះ ជាបវត្តិនីឲ្យបានឧបសម្បទា ។ ឧបសម្បទារបស់ឧបសម្បទាបេក្ខាឈ្មោះនេះ មាននាងជាម្ចាស់ឈ្មោះនេះជាបវត្តិនី គួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនេះគប្បីស្ងៀម មិនគួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះគប្បីឆ្លើយមក ។ ឧបសម្បទាបេក្ខាឈ្មោះនេះ មាននាងជាម្ចាស់ឈ្មោះនេះជាបវត្តិនី សង្ឃបានឲ្យឧបសម្បទាហើយ ។ ការឲ្យឧបសម្បទានេះ គួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំម្ចាស់សូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


## ភិក្ខុនីខន្ធកេ បុនបិ ញត្តិចតុត្ថកម្មឧបសម្បទា

[២៤៣] តាវទេវ តំ(១) អាទាយ ភិក្ខុសង្ឃំ ឧបសង្ក-មិត្វា ឯកំសំ ឧត្តរាសង្គំ ការាបេត្វា ភិក្ខូនំ បាទេ វន្ទា-បេត្វា ឧក្កុដិកំ និសីទាបេត្វា អញ្ជលឹ បគ្គណ្ហាបេត្វា ឧបសម្បទំ យាចាបេតព្វា អហំ អយ្យា ឥត្ថន្នាមា ឥត្ថន្នា-មាយ អយ្យាយ ឧបសម្បទាបេក្ខា ឯកតោ ឧបសម្បន្នា ភិក្ខុនីសង្ឃេ វិសុទ្ធា សង្ឃំ អយ្យា ឧបសម្បទំ យាចាមិ ឧល្លុម្បតុ មំ អយ្យា សង្ឃោ អនុកម្បំ ឧបាទាយ ។ អហំ អយ្យា ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ ឧបសម្ប-ទាបេក្ខា ឯកតោ ឧបសម្បន្នា ភិក្ខុនីសង្ឃេ វិសុទ្ធា ទុតិយម្បិ អយ្យា សង្ឃំ ឧបសម្បទំ យាចាមិ ឧល្លុម្បតុ មំ អយ្យា សង្ឃោ អនុកម្បំ ឧបាទាយ ។ អហំ អយ្យា ឥត្ថន្នាមា ឥត្ថន្នាមាយ អយ្យាយ ឧបសម្បទា-បេក្ខា ឯកតោ ឧបសម្បន្នា ភិក្ខុនីសង្ឃេ វិសុទ្ធា

---

១ ឆ. ម. តំសទ្ទោ នត្ថិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកៈ ញត្តិចតុត្ថកម្មឧបសម្បទានិងសេចក្តី

(៤៤៣) ភិក្ខុនីអ្នកប្រៀនប្រដៅ គប្បីនាំយកឧបសម្បទាបេក្ខានោះ ចូលទៅរកភិក្ខុសង្ឃ ឲ្យធ្វើចីវរឆៀងស្មាម្ខាង ឲ្យក្រាបថ្វាយបង្គំបាទាភិក្ខុទាំងឡាយ ឲ្យអង្គុយច្រហោងផ្គងអញ្ជលីឡើង ហើយឲ្យសូមឧបសម្បទាក្នុងខណៈនោះថា បពិត្រលោកជាម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់ឈ្មោះនេះ ជាឧបសម្បទាបេក្ខារបស់នាងជាម្ចាស់ឈ្មោះនេះ បានឧបសម្បទាដោយចំណែកម្ខាងហើយ បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់មកសូមឧបសម្បទានឹងភិក្ខុសង្ឃ(ម្តងទៀត) បពិត្រលោកម្ចាស់ទាំងឡាយ សូមសង្ឃអាស្រ័យសេចក្តីអនុគ្រោះហើយស្រោចស្រង់ខ្ញុំផង ។ បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់ឈ្មោះនេះ ជាឧបសម្បទាបេក្ខារបស់នាងជាម្ចាស់ឈ្មោះនេះ បានឧបសម្បទាដោយចំណែកម្ខាងហើយ បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់មកសូមឧបសម្បទានឹងភិក្ខុសង្ឃ (ម្តងទៀត) អស់វារៈពីរដងផង បពិត្រលោកម្ចាស់ទាំងឡាយ សូមសង្ឃអាស្រ័យសេចក្តីអនុគ្រោះហើយស្រោចស្រង់ខ្ញុំផង ។ បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់ឈ្មោះនេះ ជាឧបសម្បទាបេក្ខារបស់នាងជាម្ចាស់ឈ្មោះនេះ បានឧបសម្បទាដោយចំណែកម្ខាងហើយ បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ បពិត្រលោកជាម្ចាស់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



តតិយម្បិ អយ្យា សង្ឃំ ឧបសម្បទំ យាចាមិ ឧល្លុម្បតុ មំ អយ្យា សង្ឃោ អនុកម្បំ ឧបាទាយាតិ ។

[៨២២] ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ ឧបសម្បទាបេក្ខា ឯកតោឧបសម្បន្នា ភិក្ខុនីសង្ឃេ វិសុទ្ធា ឥត្ថន្នាមា សង្ឃំ ឧបសម្បទំ យាចតិ ឥត្ថន្នាមាយ បវត្តិនិយា ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ឧបសម្បាទេយ្យ ឥត្ថន្នាមាយ បវត្តិនិយា ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ ឧបសម្បទាបេក្ខា ឯកតោ ឧបសម្បន្នា ភិក្ខុនីសង្ឃេ វិសុទ្ធា ឥត្ថន្នាមា សង្ឃំ ឧបសម្បទំ យាចតិ ឥត្ថន្នាមាយ បវត្តិនិយា ។ សង្ឃោ ឥត្ថន្នាមំ ឧបសម្បាទេតិ ឥត្ថន្នាមាយ បវត្តិនិយា ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមាយ ឧបសម្បទា ឥត្ថន្នាមាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទាំងឡាយ ខ្ញុំម្ចាស់មកសូមឧបសម្បទានឹងភិក្ខុសង្ឃ (ម្តងទៀត) អស់វារៈបីដងផង បពិត្រលោកម្ចាស់ទាំងឡាយ សូមសង្ឃអាស្រ័យសេចក្តីអនុគ្រោះស្រោចស្រង់ខ្ញុំផង ។

[៦៨៨] ភិក្ខុដែលឆ្លាសប្រតិពល គប្បីប្រកាសសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ(ដទៃ) ឧបសម្បទាបេក្ខាឈ្មោះនេះនេះ ជាឧបសម្បទាបេក្ខារបស់ភិក្ខុនីឈ្មោះនេះ បានឧបសម្បទាដោយចំណែកម្ខាងហើយ បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ ឥឡូវឧបសម្បទាបេក្ខាឈ្មោះនេះមានភិក្ខុនីឈ្មោះនេះជាបវត្តិនី (ឧបជ្ឈាយ៍) មកសូមឧបសម្បទានឹងសង្ឃ (ម្តងទៀត) ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីញុំាងឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនីឲ្យបានឧបសម្បទា ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឧបសម្បទាបេក្ខាឈ្មោះនេះនេះ ជាឧបសម្បទាបេក្ខារបស់ភិក្ខុនីឈ្មោះនេះ បានឧបសម្បទាដោយចំណែកម្ខាងហើយ បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ ឥឡូវឧបសម្បទាបេក្ខាឈ្មោះនេះមានភិក្ខុនីឈ្មោះនេះជាបវត្តិនី មកសូមឧបសម្បទានឹងសង្ឃ (ម្តងទៀត) ។ សង្ឃញុំាងឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនីឲ្យបានឧបសម្បទា ។ ឧបសម្បទារបស់ឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី គួរដល់លោកដ៏មានអាយុអង្គណា

## ភិក្ខុនីខន្ធកេ បុនបិ ញត្តិចតុត្ថកម្មឧបសម្បទា

បវត្តិនិយា សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ សុណាតុ មេ អយ្យេ សង្ឃោ អយំ ឥត្ថន្នាមា ឥត្ថន្នាមាយ ឧបសម្បទាបេក្ខា ឯកតោ ឧបសម្បន្នា ភិក្ខុនីសង្ឃេ វិសុទ្ធា ឥត្ថន្នាមា សង្ឃំ ឧបសម្បទំ យាចតិ ឥត្ថន្នាមាយ បវត្តិនិយា ។ សង្ឃោ ឥត្ថន្នាមំ ឧបសម្បាទេតិ ឥត្ថន្នាមាយ បវត្តិនិយា ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមាយ ឧបសម្បទា ឥត្ថន្នាមាយ បវត្តិនិយា សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ឧបសម្បន្នា សង្ឃេន ឥត្ថន្នាមា ឥត្ថន្នាមាយ បវត្តិនិយា ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

ភិក្ខុនីខន្ធកៈ ញត្តិចតុត្ថកម្មឧបសម្បទាដដែលទៀត

លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីឆ្លើយមក ។ ខ្ញុំប្រកាសសេចក្តីនេះអស់វារៈពីរដងផង ។បេ។ ខ្ញុំប្រកាសសេចក្តីនេះអស់វារៈបីដងផងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧបសម្បទាបេក្ខាឈ្មោះនេះនេះ ជាឧបសម្បទាបេក្ខារបស់ភិក្ខុនីឈ្មោះនេះ បានឧបសម្បទាដោយចំណែកម្ខាងហើយ បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ ឥឡូវឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី មកសូមឧបសម្បទានឹងសង្ឃ (ម្តងទៀត) ។ សង្ឃញុំាងឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី ឲ្យបានឧបសម្បទា ។ ឧបសម្បទារបស់ឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីឆ្លើយមក ។ ឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុ-នីឈ្មោះនេះជាបវត្តិនី សង្ឃបានឲ្យឧបសម្បទាហើយ ។ កម្មនេះសមគួរដល់សង្ឃហើយ ហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំសេចក្តីនេះទុក ដោយអាការស្ងៀមយ៉ាងនេះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[២៤៥] តាវទេវ ឆាយា មេតព្វា ឧតុប្បមាណំ អាចិក្ខិតព្វំ ទិវសភាគោ អាចិក្ខិតព្វោ សង្គីតិ អាចិក្ខិតព្វា ភិក្ខុនិយោ វត្តព្វា ឥមិស្សា តយោ ច និស្សយេ អដ្ឋ ច អករណីយានិ អាចិក្ខេយ្យាថាតិ ។

[២៤៦] តេន ខោ បន សមយេន ភិក្ខុនិយោ ភត្តគ្គេ អាសនំ សង្កាយន្តិយោ កាលំ វីតិនាមេសុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អដ្ឋន្នំ ភិក្ខុនីនំ យថាវុឌ្ឍំ អវសេសានំ យថាគតិកន្តិ ។

[២៤៧] តេន ខោ បន សមយេន ភិក្ខុនិយោ ភគវតា អនុញ្ញាតំ អដ្ឋន្នំ ភិក្ខុនីនំ យថាវុឌ្ឍំ អវសេសានំ យថាគតិកន្តិ សព្វត្ថ អដ្ឋេវ[១] ភិក្ខុនិយោ យថាវុឌ្ឍំ បដិពាហន្តិ អវសេសាយោ យថាគតិកំ ។

---

១ ឱ. ម. អដ្ឋា វ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[៦៤៥] ឧបជ្ឈាយ៍ គប្បីវាស់ស្រមោល គប្បីប្រាប់ប្រមាណនៃរដូវ គប្បីប្រាប់ចំណែកថ្ងៃ គប្បីប្រាប់សង្គីតិ គប្បីប្រាប់ពួកភិក្ខុនីថា នាងទាំងឡាយ ចូរប្រាប់និស្ស័យ ៣ យ៉ាងផង ប្រាប់អករណីយកិច្ច ៨ យ៉ាងផង ដល់ភិក្ខុនីថ្មីនេះ ។

[៦៤៦] សម័យនោះឯង ភិក្ខុនីទាំងឡាយ រវល់រៀបចំអាសនៈ(១) ក្នុងរោងភត្ត ធ្វើភត្តកាលឲ្យកន្លងហួសទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតលំដាប់ទីចាស់ខ្ចីដល់ភិក្ខុនីទាំងឡាយ ៨ រូប និងទីសមគួរតាមដំណើរមុនក្រោយ ដល់ភិក្ខុនីទាំងឡាយក្រៅពីនោះ ។

[៦៤៧] សម័យនោះឯង ភិក្ខុនីទាំងឡាយដឹងថា ព្រះមានព្រះភាគទ្រង់អនុញ្ញាតលំដាប់ទីចាស់ខ្ចី ដល់ភិក្ខុនី ៨ រូប និងទីដ៏សមគួរតាមដំណើរមុនក្រោយ ដល់ភិក្ខុនីទាំងឡាយ ក្រៅពីនោះដូច្នេះហើយ ក៏ឃាត់លំដាប់ទីចាស់ខ្ចីចំពោះភិក្ខុនី ៨ រូប ឃាត់នូវទីដ៏សមគួរតាមដំណើរមុនក្រោយ ចំពោះភិក្ខុនីទាំងឡាយក្រៅពីនោះគ្រប់កន្លែង ។

---

១ ក្នុងអដ្ឋកថាប្រាប់សេចក្តីថា រវល់រៀបចំអាសនៈ គឺត្រូវប្រាប់ឲ្យភិក្ខុនីដទៃក្រោកចេញ ហើយឲ្យភិក្ខុនីឯទៀតអង្គុយ ត្រង់កន្លែងនោះយ៉ាងនេះ ទាល់តែហួសពេលឆាន់ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភត្តគ្គេ អដ្ឋន្នំ ភិក្ខុនីនំ យថាវុឌ្ឍំ អវសេសានំ យថា- គតិកំ អញ្ញត្ថ[១] យថាវុឌ្ឍំ ន បដិពាហិតព្វំ យោ បដិពាហេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២៤៨) តេន ខោ បន សមយេន ភិក្ខុនិយោ ន បវារេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា ន បវារេតព្វំ យា ន បវារេយ្យ យថាធម្មោ ការេតព្វោតិ ។

(២៤៩) តេន ខោ បន សមយេន ភិក្ខុនិយោ អត្តនា បវារេត្វា ភិក្ខុសង្ឃំ[២] ន បវារេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា អត្តនា បវារេត្វា ភិក្ខុសង្ឃោ ន បវារេតព្វោ[៣] យា ន បវារេយ្យ យថាធម្មោ ការេតព្វោតិ ។

(២៥០) តេន ខោ បន សមយេន ភិក្ខុនិយោ ភិក្ខូហិ សទ្ធឹ ឯកតោ បវារេន្តិយោ កោលាហលំ អកំសុ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ

---

១ ឥតោ បរំ សព្វត្ថាតិ បាឋោ ឧ. ម. បោត្ថកេសុ ទិស្សតិ ។ ២ ឧ. ភិក្ខុសង្ឃោ ។
៣ ឧ. ភិក្ខុសង្ឃោ ន បវារេតព្វំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវលំដាប់ទីចាស់ខ្ចីចំពោះភិក្ខុនី ៨ រូប នឹងទីតាមលំដាប់មុនក្រោយ ដល់ភិក្ខុនីទាំងឡាយក្រៅពីនោះក្នុងពេលឆាន់ កន្លែងដទៃទៀត ភិក្ខុនីមិនត្រូវឃាត់លំដាប់ទីចាស់ខ្ចីទេ ភិក្ខុនីណាឃាត់ ត្រូវអាបត្តិទុក្កដ ។

(៤៤៨) សម័យនោះឯង ពួកភិក្ខុនីមិនបានបវារណា ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវមិនបវារណាទេ ភិក្ខុនីណាមិនបវារណា វិន័យធរ ត្រូវវិនិច្ឆ័យតាមអាបត្តិ ។

(៤៤៩) សម័យនោះឯង ភិក្ខុនីទាំងឡាយ បវារណាដោយខ្លួនឯង មិនបវារណានឹងភិក្ខុសង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវបវារណាដោយខ្លួនឯង មិនត្រូវមិនបវារណានឹងភិក្ខុសង្ឃទេ ភិក្ខុនីណាមិនបវារណា វិន័យធរត្រូវវិនិច្ឆ័យតាមអាបត្តិ ។

(៤៥០) សម័យនោះឯង ភិក្ខុនីទាំងឡាយបវារណា ក្នុងទីមួយជាមួយនឹងពួកភិក្ខុហើយធ្វើកោលាហល ។ ពួកភិក្ខុក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



ភិក្ខុនិយោ ភិក្ខូហិ សទ្ធឹ ឯកតោ បវារេតព្វំ យោ បវារេយ្យ អាបត្តិ ទុក្កដស្សាតិ ។

(២៨១) តេន ខោ បន សមយេន ភិក្ខុនិយោ បុរេភត្តំ បវារេន្តិយោ កាលំ វីតិនាមេសុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភិក្ខុនិយោ បច្ឆាភត្តំ បវារេតុន្តិ ។ បច្ឆាភត្តំ បវារេន្តិយោបិ(១) វិកាលេ អហេសុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អជ្ជតនា ភិក្ខុនីសង្ឃំ បវារេត្វា(២) អបរជ្ជុ ភិក្ខុសង្ឃំ បវារេតុន្តិ ។

(២៨២) តេន ខោ បន សមយេន សព្វោ ភិក្ខុនិសង្ឃោ បវារេន្តោ កោលាហលំ អកាសិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឯកំ ភិក្ខុនឹ ព្យត្តំ បដិពលំ សម្មន្និតុំ ភិក្ខុនីសង្ឃស្ស អត្ថាយ ភិក្ខុសង្ឃំ បវារេតុំ ។ ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វា បឋមំ ភិក្ខុនី យាចិតព្វា យាចិត្វា ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ

---

១ ឱ. ម. បោត្ថកេ បិសទ្ទោ ន ទិស្សតិ ។ ២ ឱ. អជ្ជតនា បវារេត្វា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុនីមិនត្រូវបវារណា ក្នុងទីមួយជាមួយនឹងពួកភិក្ខុទេ ភិក្ខុនីណាបវារណា ត្រូវអាបត្តិទុក្កដ ។

[២៧១] សម័យនោះឯង ភិក្ខុនីទាំងឡាយ បវារណាមុនភត្ត ធ្វើភត្តកាលឲ្យកន្លងហួសទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីបវារណាក្រោយភត្តវិញ ។ ភិក្ខុនីក៏បវារណា ក្រោយភត្តក្នុងវេលាវិកាល ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីបវារណានឹងភិក្ខុនីសង្ឃក្នុងថ្ងៃនេះ ហើយបវារណានឹងភិក្ខុសង្ឃក្នុងថ្ងៃស្អែកទៀត ។

[២៧២] សម័យនោះឯង ភិក្ខុនីសង្ឃទាំងអស់ នាំគ្នាបវារណាហើយ ធ្វើឲ្យកើតកោលាហល ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុនី ១ រូប ដែលឆ្លាសប្រតិពល ឲ្យបវារណានឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃ (ជំនួសភិក្ខុនីសង្ឃ) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីត្រូវសន្មតយ៉ាងនេះ គប្បីសូមភិក្ខុនីជាមុន លុះសូមរួចហើយ ត្រូវភិក្ខុនីដែលឆ្លាសប្រតិពល ប្រកាសសង្ឃថា បពិត្រនាងជាម្ចាស់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុនឹ សម្មន្នេយ្យ ភិក្ខុនីសង្ឃស្ស អត្ថាយ ភិក្ខុសង្ឃំ បវារេតុំ ។ ឯសា ញត្តិ ។ សុណាតុ មេ អយ្យេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុនឹ សម្មន្នតិ ភិក្ខុនីសង្ឃស្ស អត្ថាយ ភិក្ខុសង្ឃំ បវារេតុំ ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ ភិក្ខុនិយា សម្មតិ ភិក្ខុនីសង្ឃស្ស អត្ថាយ ភិក្ខុសង្ឃំ បវារេតុំ សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ ។ សម្មតា សង្ឃេន ឥត្ថន្នាមា ភិក្ខុនី ភិក្ខុនីសង្ឃស្ស អត្ថាយ ភិក្ខុសង្ឃំ បវារេតុំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[២៤៣] តាយ សម្មតាយ ភិក្ខុនិយា ភិក្ខុនីសង្ឃំ អាទាយ ភិក្ខុសង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ភិក្ខូនំ បាទេ វន្ទិត្វា(១) ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ ភិក្ខុនីសង្ឃោ អយ្យា ភិក្ខុសង្ឃំ បវារេតិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទតុ(២) អយ្យា ភិក្ខុសង្ឃោ ភិក្ខុនីសង្ឃំ

---

១ វន្ទាបេត្វាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ម. វទតុ មំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកៈ ការបវារណារបស់ភិក្ខុនីសង្ឃ

សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសន្មត ភិក្ខុនីឈ្មោះនេះ ឲ្យជាអ្នកបវារណានឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃ ។ នេះជាញត្តិ ។ បពិត្រនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ សង្ឃនឹងសន្មតភិក្ខុនីឈ្មោះនេះ ឲ្យជាអ្នកបវារណានឹងភិក្ខុសង្ឃ ដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃ ។ ការសន្មតិភិក្ខុនីឈ្មោះនេះ ឲ្យជាអ្នកបវារណានឹងភិក្ខុសង្ឃដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃ សមគួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះគប្បីស្ងៀម មិនសមគួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះគប្បីឆ្លើយមក ។ ភិក្ខុនីឈ្មោះនេះ សង្ឃបានសន្មតឲ្យជាអ្នកបវារណានឹងភិក្ខុសង្ឃដើម្បីប្រយោជន៍ដល់ភិក្ខុនីសង្ឃហើយ ។ ការសន្មតិសមគួរដល់សង្ឃ ព្រោះហេតុនោះបានសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

(២៤៣) ភិក្ខុនីដែលសង្ឃ សន្មតហើយនោះ គប្បីនាំភិក្ខុនីសង្ឃចូលទៅរកភិក្ខុសង្ឃ ធ្វើចីពរឆៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុទាំងឡាយ ហើយអង្គុយប្រហោង ផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ ឥឡូវនេះភិក្ខុនីសង្ឃបវារណានឹងភិក្ខុសង្ឃដោយឃើញក្តី ដោយឮក្តី ដោយរង្កៀសក្តី បពិត្រលោកម្ចាស់ទាំងឡាយ សូមភិក្ខុសង្ឃអាស្រ័យសេចក្តីអនុគ្រោះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សតិ ។ ទុតិយម្បិ អយ្យា ។ បេ ។ តតិយម្បិ អយ្យា ភិក្ខុនីសង្ឃោ ភិក្ខុសង្ឃំ បវារេតិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទតុ អយ្យា ភិក្ខុសង្ឃោ ភិក្ខុនីសង្ឃំ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សតីតិ ។

[២៥៤] តេន ខោ បន សមយេន ភិក្ខុនិយោ ភិក្ខូនំ ឧបោសថំ ឋបេន្តិ បវារណំ ឋបេន្តិ សវចនីយំ ករោន្តិ អនុវាទំ បដ្ឋបេន្តិ ឱកាសំ ការេន្តិ ចោទេន្តិ សារេន្តិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ភិក្ខុនិយា ភិក្ខុស្ស ឧបោសថោ ឋបេតព្វោ ឋបិតោបិ អដ្ឋបិតោ ឋបេន្តិយា អាបត្តិ ទុក្កដស្ស ។ ន បវារណា ឋបេតព្វា ឋបិតាបិ អដ្ឋបិតា ឋបេន្តិយា អាបត្តិ ទុក្កដស្ស ។ ន សវចនីយំ កាតព្វំ កតម្បិ អកតំ ករោន្តិយា អាបត្តិ ទុក្កដស្ស ។ ន អនុវាទោ បដ្ឋបេតព្វោ បដ្ឋបិតោបិ អប្បដ្ឋបិតោ បដ្ឋបេន្តិយា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



ពោលដាស់តឿនភិក្ខុនីសង្ឃ កាលបើឃើញច្បាស់ហើយ នឹងសម្តែងចេញ ។ បពិត្រលោកម្ចាស់ទាំងឡាយ ។ បេ ។ បពិត្រលោកម្ចាស់ទាំងឡាយ ភិក្ខុនីសង្ឃសូមបវារណានឹងភិក្ខុសង្ឃដោយឃើញក្តី ដោយឮក្តី ដោយរង្កៀសក្តី បពិត្រលោកម្ចាស់ទាំងឡាយ សូមភិក្ខុសង្ឃអាស្រ័យសេចក្តីអនុគ្រោះ ពោលដាស់តឿនភិក្ខុនីសង្ឃ កាលបើឃើញច្បាស់ហើយ នឹងសម្តែងចេញ ។

[២៥៦] សម័យនោះឯង ភិក្ខុនីទាំងឡាយ ឃាត់ឧបោសថ ឃាត់បវារណារបស់ពួកភិក្ខុ ធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍) ផ្តើមអនុវាទាធិករណ៍ ឲ្យភិក្ខុធ្វើឱកាស (ដើម្បីចោទ) ចោទ (ភិក្ខុ) រំលឹក (ភិក្ខុ) ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវឃាត់ឧបោសថរបស់ភិក្ខុ សូម្បីឃាត់ហើយ ក៏ឈ្មោះថាមិនបានឃាត់ឡើយ កាលបើឃាត់ ត្រូវអាបត្តិទុក្កដ ភិក្ខុនីមិនត្រូវឃាត់បវារណា សូម្បីឃាត់ហើយក៏ឈ្មោះថាមិនបានឃាត់ កាលបើឃាត់ ត្រូវអាបត្តិទុក្កដ ភិក្ខុនីមិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍) សូម្បីធ្វើហើយ ក៏ឈ្មោះថាមិនបានធ្វើ កាលបើធ្វើ ត្រូវអាបត្តិទុក្កដ ភិក្ខុនីមិនត្រូវផ្តើមអនុវាទាធិករណ៍ សូម្បីផ្តើមហើយ ក៏ឈ្មោះថាមិនបានផ្តើម កាលបើផ្តើម

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាបត្តិ ទុក្កដស្ស ន ឱកាសោ ការេតព្វោ ការិតោបិ អការិតោ ការេន្តិយា អាបត្តិ ទុក្កដស្ស ន ចោទេតព្វោ ចោទិតោបិ អចោទិតោ ចោទេន្តិយា អាបត្តិ ទុក្កដស្ស ន សារេតព្វោ សារិតោបិ អស្សារិតោ[១] សារេន្តិយា អាបត្តិ ទុក្កដស្សាតិ ។

[២៥៥] តេន ខោ បន សមយេន ភិក្ខូ ភិក្ខុនីនំ ឧបោសថំ ឋបេន្តិ បវារណំ ឋបេន្តិ សវចនីយំ ករោន្តិ អនុវាទំ បដ្ឋបេន្តិ ឱកាសំ ការេន្តិ ចោទេន្តិ សារេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភិក្ខុនា ភិក្ខុនិយា ឧបោសថំ ឋបេតុំ ឋបិតោបិ សុដ្ឋបិតោ ឋបេន្តស្ស អនាបត្តិ បវារណំ ឋបេតុំ ឋបិតាបិ សុដ្ឋបិតា ឋបេន្តស្ស អនាបត្តិ សវចនីយំ កាតុំ កតំបិ សុកតំ ករោន្តស្ស អនាបត្តិ អនុវាទំ បដ្ឋបេតុំ បដ្ឋបិតោបិ សុប្បដ្ឋបិតោ[២] បដ្ឋបេន្តស្ស អនាបត្តិ ឱកាសំ ការេតុំ ការិតោបិ សុការិ-

១ ឱ. ម. អសារិតោ ។ ២ ឱ. ម. សុបដ្ឋបិតោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកៈ ការឃាត់ឧបោសថជាដើម

ត្រូវអាបត្តិទុក្កដ ភិក្ខុនីមិនត្រូវឲ្យគេធ្វើឱកាស(ដើម្បីចោទ)បើទុកជាឲ្យគេធ្វើហើយក៏ឈ្មោះថាមិនបានឲ្យធ្វើ កាលបើឲ្យធ្វើ ត្រូវអាបត្តិទុក្កដ ភិក្ខុនីមិនត្រូវចោទភិក្ខុទេ បើទុកជាចោទហើយ ក៏ឈ្មោះថាមិនបានចោទ កាលបើចោទ ត្រូវអាបត្តិទុក្កដ ភិក្ខុនីមិនត្រូវរំលឹកពួកភិក្ខុទេ ទោះបីរំលឹកហើយ ក៏ឈ្មោះថាមិនបានរំលឹក កាលបើរំលឹក ត្រូវអាបត្តិទុក្កដ ។

(២៨៥) សម័យនោះឯង ភិក្ខុទាំងឡាយឃាត់ឧបោសថ ឃាត់បវារណារបស់ពួកភិក្ខុនី ធ្វើជាអ្នកមានមាត់ពាក្យ(ក្នុងអធិករណ៍)ផ្តើមអនុវាទាធិករណ៍ ឲ្យភិក្ខុនីធ្វើឱកាស (ដើម្បីចោទ)ចោទ (ភិក្ខុនី) រំលឹក (ភិក្ខុនី) ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឃាត់ឧបោសថដល់ភិក្ខុនី ឧបោសថដែលឃាត់ហើយ ក៏ឈ្មោះថាឃាត់ដោយប្រពៃ ភិក្ខុដែលឃាត់មិនត្រូវអាបត្តិ ឲ្យភិក្ខុឃាត់បវារណា បវារណាដែលឃាត់ហើយក៏ឈ្មោះថាឃាត់ដោយប្រពៃ ភិក្ខុដែលឃាត់មិនត្រូវអាបត្តិ ឲ្យភិក្ខុធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍) ទោះបីភិក្ខុធ្វើហើយ ក៏ឈ្មោះថាធ្វើដោយប្រពៃ ភិក្ខុដែលធ្វើ មិនត្រូវអាបត្តិ ឲ្យភិក្ខុផ្តើមអនុវាទាធិករណ៍ ទោះបីភិក្ខុផ្តើមហើយ ក៏ឈ្មោះថាផ្តើមឡើងដោយប្រពៃ ភិក្ខុដែលផ្តើម មិនត្រូវអាបត្តិ ឲ្យភិក្ខុបើកឱកាស ( ដើម្បីចោទ ) ទោះបីភិក្ខុបើកហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


តោ ការេតព្វស្ស អាបត្តិ ធោនេតុំ ធោនិតាបិ សុធោនិតា ធោនេតព្វស្ស អាបត្តិ សារេតុំ សារិតាបិ សុស្សារិតា សារេតព្វស្ស អាបត្តីតិ ។

[២៥៦] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខុនិយោ យានេន យាយន្តិ ឥត្ថីយុត្តេនបិ បុរិសន្តរេន បុរិសយុត្តេនបិ ឥត្ថន្តរេន ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គង្គាមហិកាយាតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា យានេន យាយិតព្វំ យា យាយេយ្យ យថាធម្មោ ការេតព្វោតិ ។

[២៥៧] តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី គិលានា ហោតិ ន សក្កោតិ បទសា គន្តុំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភិក្ខុនិយា គិលានាយ យានេន យាយិតុន្តិ[១] ។ អថខោ ភិក្ខុនីនំ ឯតទហោសិ ឥត្ថីយុត្តំ នុ ខោ

១ ឱ. ម. អនុជានាមិ ភិក្ខវេ គិលានាយ យានន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ក៏ឈ្មោះថាបើកដោយប្រពៃ ភិក្ខុដែលបើក មិនត្រូវអាបត្តិ ឲ្យភិក្ខុចោទ (ភិក្ខុនី) ពោះបើភិក្ខុចោទហើយ ក៏ឈ្មោះថាចោទដោយប្រពៃ ភិក្ខុដែលចោទ មិនត្រូវអាបត្តិ ឲ្យភិក្ខុរំលឹក (ភិក្ខុនី) ពោះបើភិក្ខុរំលឹកហើយ ក៏ឈ្មោះថារំលឹកដោយប្រពៃ ភិក្ខុដែលរំលឹក មិនត្រូវអាបត្តិឡើយ ។

[៤៨៦] សម័យនោះឯង ឆព្វគ្គិយាភិក្ខុនីទៅដោយយានដែលទឹមគោញីមានប្រុសជាអ្នកបរខ្លះ ដែលទឹមគោឈ្មោលមានស្រីជាអ្នកបរខ្លះ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចជាស្រីអ្នកលេងទឹកក្នុងទន្លេគង្គានឹងទន្លេមហី ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវទៅដោយយានទេ ភិក្ខុនីណាទៅ វិន័យធរត្រូវវិនិច្ឆ័យតាមអាបត្តិ ។

[៤៨៧] សម័យនោះឯង ភិក្ខុនី ១ រូបមានជម្ងឺមិនអាចនឹងដើរទៅដោយជើងបាន ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីដែលមានជម្ងឺទៅដោយយានបាន ។ លំដាប់នោះ ភិក្ខុនីទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា (ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតយាន)

## ភិក្ខុនីខន្ធកេ សិវិកាទិកានុជាននំ

បុរិសយុត្តំ នុ ខោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឥត្ថីយុត្តំ បុរិសយុត្តំ ហត្ថវដ្ដកន្តិ ។

[២៥៨] តេន ខោ បន សមយេន អញ្ញតរិស្សា ភិក្ខុនិយា យានុគ្ឃាតេន ពាឡ្ហតរំ អផាសុកំ អហោសិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សិវិកំ បាដង្កិន្តិ ។

[២៥៩] តេន ខោ បន សមយេន អឌ្ឍកាសី គណិកា ភិក្ខុនីសុ បព្វជិតា ហោតិ ។ សា ច[1] សាវត្ថឹ គន្តុកាមា ហោតិ ភគវតោ សន្តិកេ ឧបសម្បជ្ជិស្សាមីតិ ។ អស្សោសុំ ខោ ធុត្តា អឌ្ឍកាសី កិរ គណិកា សាវត្ថឹ គន្តុកាមាតិ ។ តេ មគ្គេ បរិយុដ្ឋឹសុ ។ អស្សោសិ ខោ អឌ្ឍកាសី គណិកា ធុត្តា កិរ មគ្គេ បរិយុដ្ឋិតាតិ ភគវតោ សន្តិកេ ទូតំ បាហេសិ អហំ ហិ ឧបសម្បជ្ជិតុកាមា កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ អថខោ ភគវា ឯតស្មឹ និទានេ

១ ឱ. ម. បោត្ថកេសុ ចសទ្ទោ ន បញ្ញាយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដែលទឹមគោញី ឬយានដែលទឹមគោឈ្មោលហ្ន៎+ ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលសេចក្ដី+នុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតយានដែលទឹមគោញី ដែល ទឹមគោឈ្មោលនិងយានដែលអូសដោយដៃ ( មានស្រី ឬប្រុស ជាអ្នក អូស ) ។

(២៥៨) សម័យនោះឯង មានភិក្ខុនី ១ រូប កើតសេចក្ដីមិនសប្បាយ ជាខ្លាំងដោយសារទេះទង្គិច ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដី+នុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែស្នែង និងអង្រឹងស្នែង ។

(២៥៩) សម័យនោះឯង មានស្រីផ្កាមាសឈ្មោះអឌ្ឍកាសី មក បួសក្នុងសំណាក់ពួកភិក្ខុនី ។ នាងអឌ្ឍកាសីនោះ ចង់ទៅនគរសាវត្ថី ដោយគិតថា អាត្មាអញនឹងបានឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះ ភាគ ។ ពួកអ្នកលេងបានឮដំណឹងថា នាងអឌ្ឍកាសីស្រីផ្កាមាសចង់ទៅ នគរសាវត្ថី ។ ពួកអ្នកលេងទាំងនោះ ក៏ចាំស្ទាក់ត្រង់កណ្ដាលផ្លូវ ។ នាង អឌ្ឍកាសីស្រីផ្កាមាសបានឮដំណឹងថា ពួកអ្នកលេងចាំស្ទាក់ត្រង់កណ្ដាល ផ្លូវដូច្នោះ ក៏បញ្ជូនទូតទៅក្រាបបង្គំទូលព្រះមានព្រះភាគថា ដ្បិតខ្ញុំម្ចាស់ ចង់ឧបសម្បទា តើខ្ញុំម្ចាស់នឹងប្រតិបត្តិយ៉ាងណា ។ ព្រោះនិទាននេះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ទូតេនបិ ឧបសម្បាទេតុន្តិ ។ ភិក្ខុទូតេន ឧបសម្បាទេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុទូតេន ឧបសម្បាទេតព្វា យោ ឧបសម្បាទេយ្យ អាបត្តិ ទុក្កដស្សាតិ ។ សិក្ខមានាទូតេន ឧបសម្បាទេន្តិ ។ បេ ។ សាមណេរទូតេន ឧបសម្បាទេន្តិ ។ បេ ។ សាមណេរីទូតេន ឧបសម្បាទេន្តិ ។ បេ ។ ពាលាយ អព្យត្តាយ ទូតេន ឧបសម្បាទេន្តិ ។ ន ភិក្ខវេ ពាលាយ អព្យត្តាយ ទូតេន ឧបសម្បាទេតព្វា យោ ឧបសម្បាទេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ ព្យត្តាយ ភិក្ខុនិយា បដិពលាយ ទូតេន ឧបសម្បាទេតុំ ។ តាយ ទូតាយ ភិក្ខុនិយា សង្ឃំ ឧបសង្កមិត្វា ឯកំសំ ឧត្តរាសង្គំ ករិត្វា ភិក្ខូនំ បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ ឥត្ថន្នាមា អយ្យា ឥត្ថន្នាមាយ អយ្យាយ ឧបសម្បទាបេក្ខា ឯកតោ ឧបសម្បន្នា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដំណើរនេះ ទើបព្រះមានព្រះភាគធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឲ្យឧបសម្បទាសូម្បីដោយទូតក៏បាន ។ ភិក្ខុទាំងឡាយក៏ឲ្យឧបសម្បទា (ដល់ភិក្ខុនី) ដោយភិក្ខុទូត ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យឧបសម្បទា (ដល់ភិក្ខុនី) ដោយភិក្ខុទូតទេ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំងឡាយ ក៏ឲ្យឧបសម្បទា(ដល់ភិក្ខុនី)ដោយសិក្ខមានាទូត ។ បេ ។ ឲ្យឧបសម្បទាដោយសាមណេរទូត ។ បេ ។ ឲ្យឧបសម្បទាដោយសាមណេរីទូត ។ បេ ។ ឲ្យឧបសម្បទាដល់ឧបសម្បទាបេក្ខាដែលល្ងង់មិនឆ្លាសដោយទូត ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឲ្យឧបសម្បទា ដល់ឧបសម្បទាបេក្ខា ដែលល្ងង់មិនឆ្លាសដោយទូតទេ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឲ្យឧបសម្បទាដល់ភិក្ខុនីដែលឆ្លាសប្រតិពលដោយទូតបាន ។ ភិក្ខុនីជាទូតនោះ គប្បីចូលទៅរកសង្ឃ ធ្វើចីពរឆៀងស្មាម្ខាង ក្រាបថ្វាយបង្គំបាទានៃភិក្ខុទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលីឡើង ពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ទាំងឡាយ ឧបសម្បទាបេក្ខាឈ្មោះនេះ របស់ភិក្ខុនីឈ្មោះនេះ បានឧបសម្បទាដោយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកេ ទូតេន ញត្តិចតុត្ថកម្មឧបសម្បទា

ភិក្ខុនីសង្ឃេ វិសុទ្ធា សា កេនចិទេវ អន្តរាយេន
នាគច្ឆតិ ឥត្ថន្នាមា អយ្យា សង្ឃំ ឧបសម្បទំ យាចតិ
ឧល្លុម្បតុ តំ អយ្យា សង្ឃោ អនុកម្បំ ឧបាទាយ ។ ឥត្ថ-
ន្នាមា អយ្យា ឥត្ថន្នាមាយ អយ្យាយ ឧបសម្បទាបេក្ខា
ឯកតោ ឧបសម្បន្នា ភិក្ខុនីសង្ឃេ វិសុទ្ធា សា
កេនចិទេវ អន្តរាយេន នាគច្ឆតិ ទុតិយម្បិ អយ្យា
ឥត្ថន្នាមា សង្ឃំ ឧបសម្បទំ យាចតិ ឧល្លុម្បតុ តំ
អយ្យា សង្ឃោ អនុកម្បំ ឧបាទាយ ។ ឥត្ថន្នាមា
អយ្យា ឥត្ថន្នាមាយ អយ្យាយ ឧបសម្បទាបេក្ខា ឯក-
តោ ឧបសម្បន្នា ភិក្ខុនីសង្ឃេ វិសុទ្ធា សា កេនចិទេវ
អន្តរាយេន នាគច្ឆតិ តតិយម្បិ អយ្យា ឥត្ថន្នាមា
សង្ឃំ ឧបសម្បទំ យាចតិ ឧល្លុម្បតុ តំ អយ្យា
សង្ឃោ អនុកម្បំ ឧបាទាយាតិ ។

ចំណែកម្ខាង បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ ឧបសម្បទាបេក្ខានោះ មកពុំបាន ព្រោះមានអន្តរាយណាមួយ បពិត្រលោកម្ចាស់ទាំងឡាយ ឥឡូវ ឧបសម្បទាបេក្ខាឈ្មោះនេះ សូមឧបសម្បទានឹងសង្ឃ (ម្តងទៀត) បពិត្រលោកម្ចាស់ទាំងឡាយ សូមព្រះសង្ឃអាស្រ័យសេចក្តីអនុគ្រោះស្រោចស្រង់ឧបសម្បទាបេក្ខានោះ ។ បពិត្រលោកម្ចាស់ទាំងឡាយ ឧបសម្បទាបេក្ខាឈ្មោះនេះ របស់នាងជាម្ចាស់ឈ្មោះនេះ បានឧបសម្បទាដោយចំណែកម្ខាង បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ ឥឡូវ ឧបសម្បទាបេក្ខានោះ មកពុំបាន ព្រោះមានអន្តរាយណាមួយ បពិត្រលោកម្ចាស់ទាំងឡាយ ឧបសម្បទាបេក្ខាឈ្មោះនេះ សូមឧបសម្បទានឹងសង្ឃ (ម្តងទៀត) បពិត្រលោកម្ចាស់ទាំងឡាយ សូមព្រះសង្ឃអាស្រ័យសេចក្តីអនុគ្រោះស្រោចស្រង់នូវឧបសម្បទាបេក្ខានោះ អស់វារៈពីរដងផង ។ បពិត្រលោកម្ចាស់ទាំងឡាយ ឧបសម្បទាបេក្ខាឈ្មោះនេះ របស់នាងជាម្ចាស់ឈ្មោះនេះ បានឧបសម្បទាដោយចំណែកម្ខាង បរិសុទ្ធក្នុងភិក្ខុនីសង្ឃហើយ ឥឡូវ ឧបសម្បទាបេក្ខានោះ មកពុំបាន ព្រោះមានអន្តរាយណាមួយ បពិត្រលោកម្ចាស់ទាំងឡាយ ឧបសម្បទាបេក្ខាឈ្មោះនេះ សូមឧបសម្បទានឹងសង្ឃ (ម្តងទៀត) បពិត្រលោកម្ចាស់ទាំងឡាយ សូមព្រះសង្ឃអាស្រ័យសេចក្តីអនុគ្រោះស្រោចស្រង់ ឧបសម្បទាបេក្ខានោះអស់វារៈបីដងផង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។


## វិនយបិដកេ ចុល្លវគ្គោ

[២៦០] ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមា ឥត្ថន្នាមាយ ឧបសម្បទាបេក្ខា ឯកតោ ឧបសម្បន្នា ភិក្ខុនីសង្ឃេ វិសុទ្ធា សា កេនចិទេវ អន្តរាយេន នាគច្ឆតិ ឥត្ថន្នាមា សង្ឃំ ឧបសម្បទំ យាចតិ ឥត្ថន្នាមាយ បវត្តិនិយា ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ឧបសម្បាទេយ្យ ឥត្ថន្នាមាយ បវត្តិនិយា ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមា ឥត្ថន្នាមាយ ឧបសម្បទាបេក្ខា ឯកតោ ឧបសម្បន្នា ភិក្ខុនីសង្ឃេ វិសុទ្ធា សា កេនចិទេវ អន្តរាយេន នាគច្ឆតិ ឥត្ថន្នាមា សង្ឃំ ឧបសម្បទំ យាចតិ ឥត្ថន្នាមាយ បវត្តិនិយា សង្ឃោ ឥត្ថន្នាមំ ឧបសម្បាទេតិ ឥត្ថន្នាមាយ បវត្តិនិយា ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមាយ ឧបសម្បទា ឥត្ថន្នាមាយ បវត្តិនិយា សោ តុណ្ហស្ស

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



(៤៦០) ភិក្ខុដែលឆ្លាសប្រតិពល គប្បីប្រកាសសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឧបសម្បទាបេក្ខាឈ្មោះនេះ របស់ភិក្ខុនីឈ្មោះនេះ បានឧបសម្បទាដោយចំណែកម្ខាង បរិសុទ្ធក្នុងសំណាក់ភិក្ខុនីសង្ឃហើយ ឥឡូវឧបសម្បទាបេក្ខានោះមកពុំបាន ព្រោះមានអន្តរាយណាមួយ ឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី សូមឧបសម្បទានឹងសង្ឃ (ម្តងទៀត) ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីញ៉ាំងឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនីឲ្យបានឧបសម្បទា ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឧបសម្បទាបេក្ខាឈ្មោះនេះ របស់ភិក្ខុនីឈ្មោះនេះ បានឧបសម្បទាដោយចំណែកម្ខាង បរិសុទ្ធក្នុងសំណាក់ភិក្ខុនីសង្ឃហើយ ឥឡូវឧបសម្បទាបេក្ខានោះ មកពុំបាន ព្រោះមានអន្តរាយណាមួយ ឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី សូមឧបសម្បទានឹងសង្ឃ (ម្តងទៀត) ឥឡូវនេះសង្ឃញ៉ាំងឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនីឲ្យបានឧបសម្បទា ។ ឧបសម្បទានៃឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនីសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមា ឥត្ថន្នាមាយ ឧបសម្បទាបេក្ខា ឯកតោ ឧបសម្បន្នា ភិក្ខុនីសង្ឃេ វិសុទ្ធា សា កេនចិទេវ អន្តរាយេន នាគច្ឆតិ ឥត្ថន្នាមា សង្ឃំ ឧបសម្បទំ យាចតិ ឥត្ថន្នាមាយ បវត្តិនិយា ។ សង្ឃោ ឥត្ថន្នាមំ ឧបសម្បាទេតិ ឥត្ថន្នាមាយ បវត្តិនិយា ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមាយ ឧបសម្បទា ឥត្ថន្នាមាយ បវត្តិនិយា សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ឧបសម្បន្នា សង្ឃេន ឥត្ថន្នាមា ឥត្ថន្នាមាយ បវត្តិនិយា ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ តាវទេវ ឆាយា មេតព្វា ឧតុប្បមាណំ អាចិក្ខិតព្វំ ទិវសភាគោ អាចិក្ខិតព្វោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



មិនសមគួរ ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីឆ្លើយមក ។ ខ្ញុំប្រកាសសេចក្តីនេះអស់វារៈពីរដងផង ។ បេ ។ ខ្ញុំប្រកាសសេចក្តីនេះអស់វារៈបីដងផងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ឧបសម្បទាបេក្ខាឈ្មោះនេះ របស់ភិក្ខុនីឈ្មោះនេះបានឧបសម្បទាដោយចំណែកម្ខាង បរិសុទ្ធក្នុងសំណាក់នៃភិក្ខុនីសង្ឃហើយ ឥឡូវឧបសម្បទាបេក្ខានោះមកពុំបាន ព្រោះមានអន្តរាយណាមួយ ឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី សូមឧបសម្បទានឹងសង្ឃ (ម្តងទៀត) ។ ឥឡូវនេះសង្ឃញុំាងឧបសម្បទាបេក្ខាឈ្មោះនេះមានភិក្ខុនីឈ្មោះនេះជាបវត្តិនី ឲ្យបានឧបសម្បទា ។ ឧបសម្បទានៃឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម មិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីឆ្លើយមក ។ ឧបសម្បទាបេក្ខាឈ្មោះនេះ មានភិក្ខុនីឈ្មោះនេះជាបវត្តិនី សង្ឃបានឲ្យឧបសម្បទាហើយ ។ ឧបសម្បទាកម្មនេះសមគួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។ ភិក្ខុត្រូវវាស់ស្រមោល ប្រាប់ប្រមាណរដូវ ប្រាប់ចំណែកថ្ងៃ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សន្តីតិ អាចិក្ខិតព្វា ភិក្ខុនិយោ វត្តព្វា តស្សា តយោ ច និស្សយេ អដ្ឋ ច អករណីយានិ អាចិក្ខេយ្យាថាតិ ។

[២៦១] តេន ខោ បន សមយេន ភិក្ខុនិយោ អរញ្ញេ វិហរន្តិ ។ ធុត្តា ទូសេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា អរញ្ញេ វត្ថព្វំ យោ វសេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[២៦២] តេន ខោ បន សមយេន អញ្ញតរេន ឧបា-សកេន ភិក្ខុនីសង្ឃស្ស ឧទ្ទោសិតោ ទិន្នោ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧទ្ទោសិតន្តិ ។ ឧទ្ទោសិតោ ន សម្មតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧបស្ស-យន្តិ ។ ឧបស្សយោ ន សម្មតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ នវកម្មន្តិ ។ នវកម្មំ ន សម្មតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជា-នាមិ ភិក្ខវេ បុគ្គលិកម្បិ កាតុន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ប្រាប់សង្ខិត នឹងត្រូវប្រាប់ពួកភិក្ខុនីថា នាងទាំងឡាយត្រូវប្រាប់និស្ស័យ ៣ យ៉ាងផង អករណីយកិច្ច ៨ យ៉ាងផង ដល់ភិក្ខុនីថ្មីនោះ ។

[២៦១] សម័យនោះឯង ភិក្ខុនីទាំងឡាយទៅនៅក្នុងព្រៃ ។ ពួកអ្នកលេងតែងប្រទូស្ត ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវនៅក្នុងព្រៃទេ ភិក្ខុនីណានៅ ត្រូវអាបត្តិទុក្កដ ។

[២៦២] សម័យនោះឯង ឧបាសកម្នាក់ ប្រគេនឃ្លាំង(សម្រាប់ដាក់របស់) ដល់ភិក្ខុនីសង្ឃ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឃ្លាំង ។ ឃ្លាំងក៏មិនគ្រប់គ្រាន់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផ្ទះ ។ ផ្ទះក៏នៅតែមិនគ្រប់គ្រាន់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនវកម្ម (ការធ្វើថ្មី) ។ នវកម្មក៏នៅតែមិនគ្រប់គ្រាន់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យធ្វើនវកម្មនោះទៅជារបស់បុគ្គលវិញ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកេ អញ្ញតរិត្ថីវត្ថុ ភិក្ខុនីសម្មុតិ

[៤៦៣] តេន ខោ បន សមយេន អញ្ញតរា ឥត្ថី សន្និសិន្នគព្ភា ភិក្ខុនីសុ បព្វជិតា ហោតិ។ តស្សា បព្វជិតាយ គព្ភោ វុដ្ឋាសិ។ អថខោ តស្សា ភិក្ខុនិយា ឯតទហោសិ កថំ នុ ខោ មយា ឥមស្មឹ ទារកេ បដិបជ្ជិតព្វន្តិ។ ភគវតោ ឯតមត្ថំ អារោចេសុំ។ អនុជានាមិ ភិក្ខវេ បោសេតុំ យាវ សោ ទារកោ វិញ្ញុតំ បាបុណាតីតិ។ អថខោ តស្សា ភិក្ខុនិយា ឯតទហោសិ មយា ច ន លព្ភា ឯកិកាយ វត្ថុំ អញ្ញាយ ច ភិក្ខុនិយា ន លព្ភា ទារកេន សហវត្ថុំ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ។ ភគវតោ ឯតមត្ថំ អារោចេសុំ។ អនុជានាមិ ភិក្ខវេ ឯកំ ភិក្ខុនឹ សម្មន្និត្វា តស្សា ភិក្ខុនិយា ទុតិយំ ទាតុំ។ ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វា។ បឋមំ ភិក្ខុនី យាចិតព្វា យាចិត្វា ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុនឹ សម្មន្នេយ្យ ឥត្ថន្នាមាយ ភិក្ខុនិយា ទុតិយំ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកៈ រឿងស្រីម្នាក់ នឹងការសន្មតិភិក្ខុនី

(៦៦៣) សម័យនោះឯង មានស្ត្រី ១ នាក់ មានគភ៌នៅខ្ចី បួសមកបួសក្នុងសំណាក់ភិក្ខុនី ៗ លុះស្ត្រីនោះបួសហើយ គភ៌ក៏ប្រសូតមក ៗ ភិក្ខុនីនោះមានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញនឹងថែរក្សាទារកនេះ ដោយប្រការដូចម្តេច ៗ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចិញ្ចឹមដរាបតែទារកនោះបានដឹងក្តី ៗ ទើបភិក្ខុនីនោះ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញម្នាក់ឯងនៅជាមួយនឹងក្មេងប្រុសមិនបាន ទាំងភិក្ខុនីឯទៀត ក៏នៅជាមួយនឹងក្មេងប្រុសមិនបាន តើអាត្មាអញត្រូវថែរក្សាដូចម្តេច ៗ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុនី ១ រូប ឲ្យបានជាគំរប់ពីរនឹងភិក្ខុនីនោះ ៗ ម្នាលភិក្ខុទាំងឡាយ ត្រូវសន្មតយ៉ាងនេះ ៗ ត្រូវសូមភិក្ខុនីជាមុន លុះសូមរួចហើយគប្បីឲ្យភិក្ខុនីដែលឈ្លាសប្រតិពល ប្រកាសសង្ឃថា បពិត្រព្រះនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរ ដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុនីឈ្មោះនេះ ឲ្យបានជាគំរប់ពីរនឹងភិក្ខុនីឈ្មោះនេះ ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឯសា ញត្តិ ។ សុណាតុ មេ អយ្យេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុនឹ សម្មន្នតិ ឥត្ថន្នាមាយ ភិក្ខុនិយា ទុតិយំ ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ ភិក្ខុនិយា សម្មុតិ ឥត្ថន្នាមាយ ភិក្ខុនិយា ទុតិយាយ សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ។ សម្មតា សង្ឃេន ឥត្ថន្នាមា ភិក្ខុនី ឥត្ថន្នាមាយ ភិក្ខុនិយា ទុតិយា ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ អថ ខោ តស្សា ទុតិយិកាយ ភិក្ខុនិយា ឯតទហោសិ កថំ នុ ខោ មយា ឥមស្មិំ ទារកេ បដិបជ្ជិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឋបេត្វា សាគារំ យថា អញ្ញេ(១) បុរិសេ បដិបជ្ជតិ(២) ឯវំ តស្មិំ ទារកេ បដិបជ្ជិតុន្តិ ។

[២៦៨] តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី គរុធម្មំ អជ្ឈាបន្នា ហោតិ មានត្តចារិនី ។ អថ ខោ តស្សា ភិក្ខុនិយា ឯតទហោសិ មយា ច ន លព្ភា ឯកិកាយ វត្ថុំ អញ្ញាយ ច ភិក្ខុនិយា ន លព្ភា សហ មយា វត្ថុំ

១ អញ្ញស្មិំ ។ ២ ខ. ម. បដិបជ្ជន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នេះជាញត្តិ ។ បពិត្រព្រះនាងជាម្ចាស់ សូមសង្ឃស្តាប់ខ្ញុំ សង្ឃសន្មតភិក្ខុនីឈ្មោះនេះឲ្យបានជាគំរប់ពីរនឹងភិក្ខុនីឈ្មោះនេះ ។ ការសន្មតភិក្ខុនីឈ្មោះនេះ ឲ្យជាគំរប់ពីរនឹងភិក្ខុនីឈ្មោះនេះ សមគួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះ គប្បីស្ងៀម មិនសមគួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះគប្បីឆ្លើយមក ។ ភិក្ខុនីឈ្មោះនេះ សង្ឃបានសន្មតឲ្យជាគំរប់ពីរនឹងភិក្ខុនីឈ្មោះនេះហើយ ។ ការសន្មតនេះ សមគួរដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមយ៉ាងនេះ ។ លំដាប់នោះ ភិក្ខុនីជាគំរប់ពីររបស់ភិក្ខុនីនោះ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញត្រូវថែរក្សាកូនទារកនោះដូចម្តេច ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យថែរក្សាកូនទារកនោះដូចជាប្រតិបត្តិកូនប្រុសដទៃដែរ វៀរលែងតែការដេកក្នុងផ្ទះជាមួយគ្នាចេញ ។

[២៦៤] សម័យនោះឯង មានភិក្ខុនី ១ រូប ត្រូវគរុកាបត្តិហើយនៅប្រព្រឹត្តមានត្ត ។ ភិក្ខុនីនោះក៏មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញម្នាក់ឯងនៅមិនបាន ទាំងភិក្ខុនីឯទៀត ក៏នៅជាមួយអាត្មាអញមិនបាន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឯកំ ភិក្ខុនឹ សម្មន្និត្វា តស្សា ភិក្ខុនិយា ទុតិយំ ទាតុំ ។ ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វា ។ បឋមំ ភិក្ខុនី យាចិតព្វា យាចិត្វា ព្យត្តាយ ភិក្ខុនិយា បដិពលាយ សង្ឃោ ញាបេតព្វោ សុណាតុ មេ អយ្យេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុនឹ សម្មន្នេយ្យ ឥត្ថន្នាមាយ ភិក្ខុនិយា ទុតិយំ ។ ឯសា ញត្តិ ។ សុណាតុ មេ អយ្យេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុនឹ សម្មន្នតិ ឥត្ថន្នាមាយ ភិក្ខុនិយា ទុតិយំ ។ យស្សា អយ្យាយ ខមតិ ឥត្ថន្នាមាយ ភិក្ខុនិយា សម្មតិ ឥត្ថន្នាមាយ ភិក្ខុនិយា ទុតិយាយ សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ ។ សម្មតា សង្ឃេន ឥត្ថន្នាមា ភិក្ខុនី ឥត្ថន្នាមាយ ភិក្ខុនិយា ទុតិយា ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[២៦៩] តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី សិក្ខំ អបច្ចក្ខាយ(១) វិព្ភមិ ។ សា បុន បច្ចាគន្ត្វា

១ ខ. ម. បច្ចក្ខាយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



អាត្មាអញគួរប្រតិបត្តិដូចម្ដេចហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុនី ១ រូបឲ្យជាគំរប់ពីរនឹងភិក្ខុនីនោះ ។ ម្នាលភិក្ខុទាំងឡាយ គប្បីសន្មតយ៉ាងនេះ ។ ត្រូវសូមភិក្ខុនីជាមុនសិន លុះសូមរួចហើយ ភិក្ខុនីដែលឈ្លាសប្រតិពល គប្បីផ្ទៀងសង្ឃថា បពិត្រនាងជាម្ចាស់ សូមសង្ឃស្ដាប់ខ្ញុំ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុនីឈ្មោះនេះ ឲ្យជាគំរប់ពីរនឹងភិក្ខុនីឈ្មោះនេះ ។ នេះជាញត្តិ ។ បពិត្រនាងជាម្ចាស់ សូមព្រះសង្ឃស្ដាប់ខ្ញុំ ឥឡូវនេះ សង្ឃសន្មតភិក្ខុនីឈ្មោះនេះ ឲ្យជាគំរប់ពីរនឹងភិក្ខុនីឈ្មោះនេះ ។ ការសន្មតភិក្ខុនីឈ្មោះនេះ ឲ្យជាគំរប់ពីរនឹងភិក្ខុនីឈ្មោះនេះ គួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះគប្បីស្ងៀម មិនគួរដល់នាងជាម្ចាស់អង្គណា នាងជាម្ចាស់អង្គនោះគប្បីនិយាយឡើង ។ ភិក្ខុនីឈ្មោះនេះ សង្ឃបានសន្មតឲ្យជាគំរប់ពីរនឹងភិក្ខុនីឈ្មោះនេះហើយ ។ ការសន្មតនេះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំដំណើរនេះទុក ដោយអាការស្ងៀមយ៉ាងនេះ ។

(៦៦៩) សម័យនោះឯង មានភិក្ខុនី ១ រូប មិនបានពោលលាសិក្ខា ហើយស្រាប់តែសឹកចេញទៅ ។ នាងនោះ ក៏ត្រឡប់មក

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុនិយា ឧបសម្បទំ យាចិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា សិក្ខាបច្ចក្ខានំ យទេវ សា វិព្ភន្តា តទេវ សា ភិក្ខុនីតិ ។

(២៦៦) តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី សកាសាវា តិត្ថាយតនំ សង្កមិ ។ សា បុន បច្ចាគន្ត្វា ភិក្ខុនិយោ ឧបសម្បទំ យាចិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ យា សា ភិក្ខវេ ភិក្ខុនី សកាសាវា តិត្ថាយតនំ សង្កន្តា សា អាគតា ន ឧបសម្បាទេតព្វាតិ ។

(២៦៧) តេន ខោ បន សមយេន ភិក្ខុនិយោ បុរិសេហិ អភិវាទនំ កេសច្ឆេទនំ នខច្ឆេទនំ វណប្ប-ដិកម្មំ កុក្កុច្ចាយន្តា ន សាទិយន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សាទិយិតុន្តិ ។

សូមឧបសម្បទានឹងភិក្ខុនីទាំងឡាយវិញ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ(បើ)ភិក្ខុនីមិនបានពោលលាសិក្ខាទេ ភិក្ខុនីនោះសឹកចេញទៅ ព្រោះហេតុណា នាងនោះមិនហៅថា ភិក្ខុនី ព្រោះតែហេតុនោះឯង ។

(៤៦៦) សម័យនោះឯង មានភិក្ខុនី ១ រូបចូលទៅកាន់លទ្ធិតិរ្ថិយទាំងសំពត់កាសាវៈ នាងនោះក៏ត្រឡប់មកសូមឧបសម្បទានឹងភិក្ខុនីទាំងឡាយវិញ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីណាចូលទៅកាន់តិរ្ថិយទាំងសំពត់កាសាវៈ ហើយនាងនោះត្រឡប់មកវិញ សង្ឃមិនត្រូវឲ្យឧបសម្បទាទេ ។

(៤៦៧) សម័យនោះឯង ភិក្ខុនីទាំងឡាយមានសេចក្តីរង្កៀសមិនត្រេកអរចំពោះកិរិយាថ្វាយបង្គំ ការកោរសក់ ការកាត់ក្រចក ចំពោះការរក្សាដំបៅមួយអន្លើដោយបុរសទាំងឡាយ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីត្រេកអរបាន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកេ ភិក្ខុនីនំ បល្លង្កេន និសីទនាទិ

[២៦៨] តេន ខោ បន សមយេន ភិក្ខុនិយោ បល្លង្កេន និសីទន្តិ បណ្ហិសម្ផស្សំ សាទិយន្តិ[១] ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា បល្លង្កេន និសីទិតព្វំ យា និសីទេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[២៦៩] តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី គិលានា ហោតិ ។ តស្សា វិនា បល្លង្កា[២] ន ផាសុ ហោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភិក្ខុនិយា អឌ្ឍបល្លង្កន្តិ ។

[២៧០] តេន ខោ បន សមយេន ភិក្ខុនិយោ វច្ចកុដិយា វច្ចំ ករោន្តិ ។ ឆព្ពគ្គិយា ភិក្ខុនិយោ តត្ថេវ គព្ភំ បាតេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា វច្ចកុដិយា វច្ចោ កាតព្វោ យា ករេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ ហេដ្ឋាវិវដេ ឧបរិបដិច្ឆន្នេ វច្ចំ កាតុន្តិ ។

[២៧១] តេន ខោ បន សមយេន ភិក្ខុនិយោ ចុណ្ណេន នហាយន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ

---

១ ឱ. សាទិយន្តា ។ ២ ឱ. ម. បល្លង្កេន ។

## ភិក្ខុនីខន្ធកៈ រឿងពួកភិក្ខុនីអង្គុយពែនភ្នែនជាដើម

[២៦៨] សម័យនោះឯង ភិក្ខុនីទាំងឡាយអង្គុយពែនភ្នែនហើយ ក៏ត្រេកអរនឹងសម្ផស្សកែងជើង ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវអង្គុយពែនភ្នែនឡើយ ភិក្ខុនីណាអង្គុយ ត្រូវអាបត្តិទុក្កដ ។

[២៦៩] សម័យនោះឯង មានភិក្ខុនី ១ រូបឈឺ ។ ភិក្ខុនីនោះ បើវៀរពែនភ្នែនមិនមានសេចក្តីសប្បាយ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីអង្គុយពែនជើងម្ខាងបាន ។

[២៧០] សម័យនោះឯង ភិក្ខុនីទាំងឡាយ បន្ទោបង់វច្ចៈក្នុងបង្គន់ ។ ឯពួកឆព្វគ្គិយាភិក្ខុនីក៏ទៅរំលូតគភ៌ (កូន) ក្នុងបង្គន់នោះឯង ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវបន្ទោបង់វច្ចៈក្នុងបង្គន់ ភិក្ខុនីណាបន្ទោបង់ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីបន្ទោបង់វច្ចៈទៅក្នុងទីខាងក្រោម ដែលមិនមានបិទបាំង មានបិទបាំងតែខាងលើជុំវិញ ។

[២៧១] សម័យនោះឯង ភិក្ខុនីទាំងឡាយ ងូតទឹកដោយគ្រឿងលំអិត ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



។ បេ ។ សេយ្យថាបិ គិហិកាមភោគិនិយោតិ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា ចុណ្ណេន នហាយិតព្វំ យោ នហាយេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ កុក្កុសំ មត្តិកន្តិ ។

[២៧២] តេន ខោ បន សមយេន ភិក្ខុនិយោ វាសិតកាយ[1] មត្តិកាយ នហាយន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហិ-កាមភោគិនិយោតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា វាសិតកាយ មត្តិកាយ នហា-យិតព្វំ យោ នហាយេយ្យ អាបត្តិ ទុក្កដស្ស អនុជា-នាមិ ភិក្ខវេ បកតិមត្តិកន្តិ ។

(១៧៣] តេន ខោ បន សមយេន ភិក្ខុនិយោ ជន្តាឃរេ នហាយន្តិយោ កោលាហលំ អកំសុ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា ជន្តាឃរេ នហាយិតព្វំ យោ នហាយេយ្យ អាបត្តិ ទុក្កដស្សាតិ ។

---

១ ឱ. ម. វាសិតិកាយ ។

។ បេ ។ ដូចជាស្រីគ្រហស្ថអ្នកបរិភោគកាម ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវងូតទឹកដោយគ្រឿងលំអិតទេ ភិក្ខុនីណាងូត ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវកុណ្ឌកនិងដីស្អិត ។

(២៧២) សម័យនោះឯង ភិក្ខុនីទាំងឡាយ ងូតទឹកដោយដីស្អិតដែលគេអប់ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចជាស្រីគ្រហស្ថអ្នកបរិភោគកាម ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវងូតទឹកដោយដីស្អិតដែលគេអប់ទេ ភិក្ខុនីណាងូត ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវដីស្អិតប្រក្រតី ។

(២៧៣) សម័យនោះឯង ភិក្ខុនីទាំងឡាយ ងូតទឹកក្នុងរោងសម្រាប់ក្តៅកាយ ហើយធ្វើនូវកោលាហល ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវងូតទឹកក្នុងរោងសម្រាប់ក្តៅកាយទេ ភិក្ខុនីណាងូត ត្រូវអាបត្តិទុក្កដ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកេ ភិក្ខុនីនំ នហាយនំ

[២៧៤] តេន ខោ បន សមយេន ភិក្ខុនិយោ បដិសោតេ នហាយន្តិ ធារាសម្ផស្សំ សាទិយន្តិ[១] ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា បដិសោតេ នហាយិតព្វំ យា នហាយេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[២៧៥] តេន ខោ បន សមយេន ភិក្ខុនិយោ អតិត្ថេ នហាយន្តិ ។ ធុត្តា ទូសេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន ភិក្ខវេ ភិក្ខុនិយា អតិត្ថេ នហាយិតព្វំ យា នហាយេយ្យ អាបត្តិ ទុក្កដស្សាតិ ។

[២៧៦] តេន ខោ បន សមយេន ភិក្ខុនិយោ បុរិសតិត្ថេ នហាយន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ ។ បេ ។ សេយ្យថាបិ គិហិកាមភោគិនិយោតិ ។ បេ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ ន ភិក្ខវេ ភិក្ខុនិយា បុរិសតិត្ថេ នហាយិតព្វំ យា នហាយេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ មហិលាតិត្ថេ នហាយិតុន្តិ ។

តតិយភាណវារំ ។

ភិក្ខុនីខន្ធកេ និដ្ឋិតំ ទសមំ ។

ឥមម្ហិ ខន្ធកេ វត្ថុ ឯកសតំ ៨ ។

---

១ ឱ. សាទិយន្តា ។

## ភិក្ខុនីខន្ធកៈ ការងូតទឹករបស់ពួកភិក្ខុនី

[២៧៤] សម័យនោះឯង ភិក្ខុនីទាំងឡាយងូតទឹក(បែរមុខទៅ) ក្នុងទីច្រាសខ្សែទឹក ហើយត្រេកអរនឹងសម្ផស្សខ្សែទឹក ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវងូតទឹក (បែរមុខទៅ) កាន់ទីច្រាសខ្សែទឹក ភិក្ខុនីណាងូត ត្រូវអាបត្តិទុក្កដ ។

[២៧៥] សម័យនោះឯង ភិក្ខុនីទាំងឡាយ ងូតទឹកក្នុងទីដែលមិនមែនជាកំពង់ ។ ពួកអ្នកលេងទៅប្រទូស្ត (ធ្វើអសទ្ធម្ម) ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវងូតទឹកក្នុងទីមិនមែនជាកំពង់ ភិក្ខុនីណាងូត ត្រូវអាបត្តិទុក្កដ ។

[២៧៦] សម័យនោះឯង ភិក្ខុនីទាំងឡាយ ងូតទឹកក្នុងកំពង់ទឹកសម្រាប់បុរស ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ។ បេ ។ ដូចជាស្រីគ្រហស្ថអ្នកបរិភោគកាម ។ បេ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីមិនត្រូវងូតទឹក ក្នុងកំពង់សម្រាប់បុរសទេ ភិក្ខុនីណាងូត ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីងូតទឹកក្នុងកំពង់សម្រាប់ស្រីជាប្រសើរ គឺភិក្ខុនីផងគ្នា ។

ភាណវារៈ ទី ៣ ។

ចប់ ភិក្ខុនីខន្ធកៈ ទី ១០ ។

ក្នុងខន្ធកៈនេះ មានរឿង ១០៦ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តស្សុទ្ទានំ

[២៧៧] បព្វជ្ជំ គោតមី យាចិ
នានុញ្ញាសិ តថាគតោ
កបិលវត្ថុ វេសាលី
អគមាសិ វិនាយកោ ។
រជោកិណ្ណា(១) កោដ្ឋកេសុ
អានន្ទស្ស បវេទយិ ។
ករោតិ នយតោ យាចិ
មាតាតិ បោសិកាតិ ច ។
វស្សសតំ តទហុ ច
អកិត្ត បច្ចាសីសនា
បវារណា គរុធម្មា

---

១ ឱ· ម· រជោកិណ្ណោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ទុក្ខានុគីបញ្ញើរឿងនៃភិក្ខុនីខន្ធកៈ នោះគឺ

( ៤៧៧ ) រឿងព្រះនាងបជាបតីគោតមីសូមបព្វជ្ជា ព្រះតថាគត ជាវិនាយកមិនទ្រង់អនុញ្ញាត ហើយស្តេចចេញចាកក្រុងកបិលពស្តុទៅកាន់ក្រុងវេសាលី ១ ។ រឿងព្រះនាងបជាបតីគោតមី មានព្រះអង្គប្រឡាក់ដោយធូលី ទ្រង់ព្រះសណ្ឋិតទៀបគោងទ្វារហើយទូលសេចក្តីនុះ ចំពោះព្រះអានន្ទ ១ ។ រឿងព្រះអានន្ទទូលសូមបព្វជ្ជា ឲ្យព្រះនាងគោតមី តាមន័យដែលព្រះអង្គថា គួរនឹងបានសម្រេចមគ្គផលដែរ ដោយពោលអាងថា ព្រះនាងគោតមី ជាព្រះមាតុច្ឆាផង ជាអ្នកបំប៉ៅព្រះអង្គផង ។ រឿងព្រះសាស្តាទ្រង់សម្តែងគរុធម៌ ៨ ប្រការ គឺភិក្ខុនីសូម្បីមានវស្សា ១ រយ ក៏ត្រូវគោរពភិក្ខុ ដែលទើបបានឧបសម្បទាក្នុងថ្ងៃនោះ ១ ភិក្ខុនីមិនត្រូវនៅចាំវស្សាក្នុងអាវាសគ្មានភិក្ខុ ១ ភិក្ខុនីត្រូវស្វែងរកធម៌ពីរប្រការ អំពីសំណាក់ភិក្ខុសង្ឃ ១ ភិក្ខុនីត្រូវបវារណា ក្នុងឧភតោសង្ឃ ១ ភិក្ខុនីត្រូវគរុកាបត្តិហើយ ត្រូវប្រព្រឹត្តបក្ខមានត្ត ក្នុងឧភតោសង្ឃ ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកេ ឧទ្ទានគាថា

ទេ្វ វស្សា អនោក្កាសញា

ឱរោធា ច អដ្ឋ ធម្មា(១)

យាវតីកទុក្កដា ។

កុជម្ហា បដិក្កមោ

សា វស្សា ឧបសម្បន្នា ។

វស្សសហស្សំ បញ្ញេវ

កុម្ភថេនកា សេតដ្ឋិ

មញ្ជេដ្ឋិកា ឧបមាកិ

ឃរំ សន្ធម្ហីសញា

ឆាន្សី ពន្ធេយ្យុបមាហិ(២)

បុន សន្ធម្មសណ្ឋិតិ

ឧបសម្បានេតុំ អយ្យា

---

១ ឱ. ឱភាវេនន្តិ តេ ធម្មា ។ ម. ឱភាវេន អន្តិ ធម្មា ។ ២ ឱ. ម. អាឡី ពន្ធេយ្យ ជា ឯវ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកៈ ឧទ្ទានគាថា

ភិក្ខុនីត្រូវស្វែងរកឧបសម្បទា ឲ្យនាងសិក្ខមានា ដែលបានសិក្សាធម៌ ៦ ប្រការ អស់ពីរវស្សាក្នុងសំណាក់ឧភតោសង្ឃ ១ ភិក្ខុនីមិនត្រូវជេរប្រទេចភិក្ខុ ១ ភិក្ខុនីមិនត្រូវឲ្យឱវាទដល់ភិក្ខុ ១ ភិក្ខុនីត្រូវប្រព្រឹត្តតាមគរុធម៌ ៨ ប្រការដរាបអស់ជីវិត ១ ។ រឿងព្រះអានន្ទរៀនគរុធម៌ ៨ ប្រការ ហើយប្រាប់ដល់ព្រះនាង-បជាបតីគោតមីថា បើព្រះនាងទទួលប្រព្រឹត្តគរុធម៌ ៨ ប្រការ នាងនឹងបានឧបសម្បទា ១ ។ រឿងព្រះមានព្រះភាគត្រាស់ថា បើមិនមានស្រីបួសទេ ព្រះសទ្ធម្មនឹងឋិតនៅអស់១ពាន់ឆ្នាំ កាលបើមានស្រីបួស ព្រះសទ្ធម្មនឹងឋិតនៅបានត្រឹមតែប្រាំរយឆ្នាំ ប្រៀបដូចចោរលួចផ្ទាំង ឬប្រៀបដូចគ្រាដែលស៊ីស្រូវ ពុំនោះសោត ដូចជាគ្រាក្រើនដែលស៊ីអំពៅ ឯមាតុគ្រាមតែងបៀតបៀននូវព្រះសទ្ធម្ម យ៉ាងនោះដែរ មួយវិញទៀតបុរសទប់ទឹកឲ្យជាប់នៅយ៉ាងណា គរុធម៌ ៨ ប្រការ ដែលព្រះអង្គបញ្ញត្តទុកមក ក៏ញុំាងព្រះសទ្ធម្មឲ្យឋិតថេរ យ៉ាងនោះដែរ ១ រឿងព្រះមានព្រះភាគទ្រង់អនុញ្ញាតឧបសម្បទាដល់ភិក្ខុនី ១ រឿងពួកភិក្ខុនីនិយាយនឹងព្រះនាងបជាបតីគោតមីថា ព្រះនាងជាម្ចាស់ មិនទាន់បានឧបសម្បទានៅឡើយ ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យថាវុឌ្ឍា ភិភនា

ន ករិស្សន្តិ តមេវ

សាធារណា សាធារណំ

ឱភំគ ធាតិមោក្ខញ្ច

កេន នុ ខោ ឧបស្សយំ

ន ឋានន្តិ ច អាចិក្ខិ

ន ការេន្តិ ច ភិក្ខូហិ

បដិគ្គហេតុំ ភិក្ខូហិ

ភិក្ខុនីហិ បដិគ្គហោ

អាចិក្ខិ កម្មំ ភិក្ខូហិ

ឧជ្ឈាយន្តិ ភិក្ខូហិ ភ

អាចិក្ខិតុំ កណ្ឋានញ្ច

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



រឿងព្រះនាងបជាបតីគោតមី ទូលសូមឲ្យទ្រង់អនុញ្ញាត ការគោរពដល់ភិក្ខុ ភិក្ខុនី តាមលំដាប់ចាស់ខ្ចី ហើយព្រះអង្គទ្រង់ឃាត់ថាមិនបាច់តថាគតអនុញ្ញាតទេ ១ រឿងព្រះនាងបជាបតីគោតមីទូលសួរអំពីសាធារណៈនិងអសាធារណសិក្ខាបទ ១ រឿងទ្រង់ប្រទានឱវាទ ១ រឿងទ្រង់អនុញ្ញាតបាតិមោក្ខ ១ រឿងពួកភិក្ខុសង្ស័យថា ត្រូវនរណា សម្តែងបាតិមោក្ខ ១ រឿងភិក្ខុចូលទៅកាន់សំណាក់ភិក្ខុនី ១ រឿងពួកភិក្ខុនីមិនបេះបាតិមោក្ខ ១ រឿងទ្រង់អនុញ្ញាត ឲ្យភិក្ខុប្រាប់បាតិ-មោក្ខុទ្ទេស ១ រឿងភិក្ខុនីមិនសំដែងអាបត្តិ ១ រឿងទ្រង់អនុញ្ញាតឲ្យពួកភិក្ខុទទួលអាបត្តិរបស់ពួកភិក្ខុនី ១ រឿងទ្រង់អនុញ្ញាតឲ្យពួកភិក្ខុប្រាប់ដល់ការសំដែងអាបត្តិដល់ពួកភិក្ខុនី១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុនីផងគ្នាទទួលអាបត្តិ ១ រឿងទ្រង់អនុញ្ញាតឲ្យពួកភិក្ខុប្រាប់ការទទួលអាបត្តិ ដល់ពួកភិក្ខុនី ១ រឿងទ្រង់អនុញ្ញាត ឲ្យពួកភិក្ខុធ្វើកម្មដល់ពួកភិក្ខុនី ១ រឿងមនុស្សទាំងឡាយពោលទោសថា ភិក្ខុនីទាំងនេះជាប្រពន្ធរបស់ភិក្ខុ ១ រឿងទ្រង់អនុញ្ញាតឲ្យពួកភិក្ខុប្រាប់ការធ្វើកម្មដល់ពួកភិក្ខុនី ១ រឿងភិក្ខុនីឈ្លោះគ្នាកណ្តាលសង្ឃ ១ រឿង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



### ភិក្ខុនីខន្ធកេ ឧទ្ទានគាថា

ហោបេត្វា ឧប្បលាយ ច

សាវត្ថិយា កទ្ទមោទកេ[១]

អវង្គិ កាយ ឩរុ ច

អង្គជាតំ ច ឱភាសំ

សម្បយោជេន្តិ វត្តិកា

អវង្គយោ នណ្ហាកម្មំ

ភិក្ខុនិយោ តថា បុន

អាវរណញ្ច ឱភានំ

ធុទោ កាប្បតិ[២] បក្កមិ

ពាលាវត្ថុ វិនិច្ឆយា

ឱភានំ សង្ឃោ បញ្ចហិ

ធុវេ តិស្ឃេ ន តណ្ហាទិ

---

១ ឱ. ម. កទ្ទមោទ ។ ២ ឱ. ម. កប្បតិ ធុ ទោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកៈ ឧទ្ទានគាថា

ទ្រង់អនុញ្ញាតឲ្យភិក្ខុលើកកម្មរបស់ភិក្ខុនី ប្រគល់ឲ្យភិក្ខុនីផងគ្នា ១ រឿងភិក្ខុនីជាកូនសិស្សនាងឧប្បលវណ្ណា ១ រឿងទ្រង់គង់នៅក្នុងក្រុងសាវត្ថី ១ រឿងពួកភិក្ខុ សាចពួកភិក្ខុនីដោយភក់និងទឹក ១ រឿងអវន្ទិយភិក្ខុមិនគួរឲ្យពួកភិក្ខុនីថ្វាយបង្គំ ១ រឿងពួកភិក្ខុ សើយកាយ សើយភ្លៅ បញ្ចេញអង្គ-ជាត បំអកបំអន់ពួកភិក្ខុនី ផ្សំផ្គុំភិក្ខុជាមួយនឹងពួកភិក្ខុនី ១ រឿងទ្រង់អនុញ្ញាត ឲ្យធ្វើទណ្ឌកម្ម មិនឲ្យភិក្ខុនីសំពះពួកភិក្ខុ ១ រឿងភិក្ខុនីសាចទឹកនឹងភក់លើពួកភិក្ខុ ១ រឿងទ្រង់អនុញ្ញាតឲ្យធ្វើអាវរណកម្ម ១ រឿងទ្រង់អនុញ្ញាតឲ្យបញ្ឈប់ឱវាទ ១ រឿងពួកភិក្ខុគិតថា កាលធ្វើឧបោសថជាមួយនឹងភិក្ខុនីដែលឃាត់ឱវាទហើយគួរឬមិនគួរ ១ រឿងឧទាយីឃាត់ឱវាទហើយ ចៀសចេញទៅកាន់ចារិក ១ រឿងភិក្ខុល្ងង់ឃាត់ឱវាទ១ រឿងពួកភិក្ខុឃាត់ឱវាទដោយឥតរឿង១ រឿងពួកភិក្ខុឃាត់ឱវាទហើយមិនឲ្យវិនិច្ឆ័យ ១ រឿងភិក្ខុនីសង្ឃទៅទទួលយកឱវាទ ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុនី ៤-៥ រូបទៅទទួលយកឱវាទ ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុនី ២-៣ រូបទៅទទួលយកឱវាទ ១ រឿងពួកភិក្ខុមិនទទួលឲ្យឱវាទ ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ពាលាភិលានគាមិកំ
អរញ្ញ៍ នាគោបេន្តិ ច
បុន បច្ចាគច្ឆន្តិ ច(១)
ទីឃំ វិលិវចម្មញ្ច
ទុស្សា ច វេណិ វដ្តិ ច
ចោឡវេណិ ច វដ្តិ ច
សុត្តវេណិ ច វដ្តិកា
អដ្ឋិល្លំ គោហនុកេន
ហត្ថកោច្ឆំ បទំ(២) តថា
ខុរ មុខំ ទន្តមំសំ
អាលិម្បោ មទ្ទុ ចុណ្ណនា
លញ្ចេន្តិ អង្គរាគញ្ច
មុខរាគំ តថា ទុវេ
អវង្គំ វិសេសោ លោកោ
សាលោកេន សនច្ចំ(៣)

---

១ ឱ. ម. អារញ្ញកា នាគោបេន្តិ ន បច្ចាគច្ឆន្តិ ច ។ ២ ឱ. ម. បរិ ។ ៣ ឱ. ម. សនច្ចេន បិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុទទួលឲ្យឱវាទភិក្ខុនី រឿងលែងតែភិក្ខុល្ងង់ ភិក្ខុឈឺ និងភិក្ខុអ្នកដំណើរ ១ រឿងទ្រង់អនុញ្ញាតឲ្យភិក្ខុដែលនៅក្នុងព្រៃឲ្យឱវាទ ១ រឿងពួកភិក្ខុទទួលឲ្យឱវាទហើយមិនបានប្រាប់ ១ រឿងពួកភិក្ខុទទួលឲ្យឱវាទហើយ មិនប្រគល់មកវិញ ១ រឿងពួកភិក្ខុនីប្រើវត្ថពន្ធចង្កេះវែង ១ រឿងពួកភិក្ខុនីចងរឹតឆ្អឹងជំនីរ ដោយផ្ដាំងដែលធ្វើពីបន្ទោះឫស្សីខ្លះ ដោយស្បែកខ្លះ ដោយសំពត់សខ្លះ ដោយសំណុំសំពត់សខ្លះ ដោយខ្នាញ់សំពត់សខ្លះ ដោយផ្ដាំងសំពត់មានពណ៌ផ្សេង ៗ ខ្លះ ដោយសំណុំសំពត់មានពណ៌ខ្លះ ដោយខ្នាញ់សំពត់មានពណ៌ខ្លះ ដោយសំណុំសូត្រខ្លះ ដោយខ្នាញ់សំពត់សូត្រខ្លះ ១ រឿងពួកភិក្ខុនីប្រើឲ្យគេដំត្រគាកដោយឈើដូចឆ្អឹងស្មងគោខ្លះ ដូចចង្កាគោខ្លះ ឲ្យគេដំដៃខ្លះ ខ្នងដៃខ្លះ ខ្នងជើងខ្លះ ភ្លៅខ្លះ មុខខ្លះ សាច់ធ្មេញខ្លះ ដោយឈើដូចគ្នា ពួកភិក្ខុនីលាបមុខខ្លះ ប្រសមុខខ្លះ ខាត់មុខខ្លះ ផ្ចិតមុខខ្លះ ស្រឡាបមុខខ្លះ ស្រឡាបទាំងខ្លួនទាំងមុខខ្លះ ១ រឿងភិក្ខុនីធ្វើគំនូសក្រោមមាត់ខ្លះ ធ្វើគំនូសប៉ែក ៗ ត្រង់ថ្ពាល់ខ្លះ ក្រឡេកមើលតាមបង្អួចខ្លះ ឈរត្រង់មាត់ទ្វារបង្ហាញកាយខ្លះ ប្រើគេឲ្យលេង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកេ ឧទ្ទានគាថា

វេសិ ទាទាការំ សុធំ
អាបណំ វឌ្ឍិ វាណិជា
ទាសំ ទាសី កម្មការំ
កម្មការី ឧបដ្ឋយំ[១]
តិរច្ឆាន ហារិតកិ
សព្វារយន្តិ នមតកំ
នីលំ បីតំ លោហិតកំ
មញ្ជេដ្ឋកណ្ហចីវរា
មហារង្គ មហានាមា ច
អច្ឆិន្នា[២] ទីឃមេវ ច
បុប្ផ ផល កញ្ចុកញ្ចុ
តិរីដញ្ចេវ ធារយុំ ។
ភិក្ខុនិសិក្ខមានាយ
សាមណេរាយ អច្ចយេ[៣]
និយ្យាទិតេ បរិក្ខារេ
ភិក្ខុនិយោ[៤] ច ឥស្សរា

១ ឱ. ឧបដ្ឋភំ ។ ២ ឱ. ម. មហានាម អច្ឆិនា ។ ៣ ឱ. អបច្ចយេ ។ ៤ ឱ. ភិក្ខុនី ចេវ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកៈ ឧទ្ទានគាថា

មះហាស្រពខ្លះ បំបួសស្រីពេស្យាខ្លះ តាំងពេងលក់សុរាខ្លះ តាំងពេងលក់សាច់ខ្លះ បើកពនផ្សារខ្លះ ដំឡើងថ្លៃរបស់ខ្លះ ប្រកបជំនួញផ្សេង ៗ ខ្លះ ឲ្យខ្ញុំប្រុសបម្រើខ្លះ ឲ្យខ្ញុំស្រីបម្រើខ្លះ ឲ្យកូនឈ្នួលប្រុសបម្រើខ្លះ ឲ្យកូនឈ្នួលស្រីបម្រើខ្លះ ឲ្យសត្វតិរច្ឆានបម្រើខ្លះ តាំងពនលក់វត្ថុខ្ចីនិងវត្ថុទំខ្លះ ប្រើកម្រាលស្នាប់ ដោយពោមបៀមខ្លះ ១ រឿងភិក្ខុនីប្រើចីវរពណ៌ខៀវសុទ្ធខ្លះ លឿងខ្ចីសុទ្ធខ្លះ ក្រហមសុទ្ធខ្លះ ហង្សបាទសុទ្ធខ្លះ ខ្មៅសុទ្ធខ្លះ ក្រហមក្រមៅសុទ្ធខ្លះ លឿងទុំសុទ្ធខ្លះ មានជាយមិនបានកាត់ជាប់ខ្លះ វែងខ្លះ រំលេចដោយផ្កាឈើខ្លះ រំលេចដោយផ្លែឈើខ្លះ ពាក់អាវបំពង់វែងខ្លះ ពាក់មួកខ្លះ ១ ។ រឿងភិក្ខុនីនឹងសិក្ខមានា នឹងសាមណេរី ធ្វើមរណកាលទៅត្រូវភិក្ខុនីសង្ឃជាឥស្សរៈលើគ្រឿងបរិក្ខារ ដែលភិក្ខុនីជាដើមនោះប្រគល់ឲ្យ ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុស្ស សាមណេរស្ស
ឧបាសកស្សុបាសិកា
អញ្ញេសញ្ច បរិក្ខារេ
និយ្យាតេ ភិក្ខូ[១] ឥស្សរា ។
មហគ្ឃា កុត្តំ បត្តមូលំ
ព្យញ្ជនំ អាមិសេន ច
ឧស្សន្នញ្ច ពាឡ្ហតំ
សន្និធិកតអាមិសំ
ភិក្ខូនំ យោនិសំ ហោដ្ឋំ
ភិក្ខុនីនំ តថា ការេ ។
សេនាសនំ ឧតុនិយោ
មក្ខិយតិ បជានិ ច
និដ្ឋិត[២] សព្វកាលញ្ច
អនិមិត្តាបិ និស្សរេ
និមិត្តាលោហិតា ចេវ
តថេវ ធុវលោហិតា

---

១ ឱ. ម. និយ្យទេ ភិក្ខុ ។ ២ ឱ. ម. និដ្ឋិទ្ធិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



រឿងភិក្ខុ សាមណេរ ឧបាសក ឧបាសិកានឹងជនឯទៀត ធ្វើមរណកាលទៅ ត្រូវពួកភិក្ខុជាឥស្សរៈលើគ្រឿងបរិក្ខារ ដែលភិក្ខុជាដើមនោះប្រគល់ឲ្យ ១ ។ រឿងមល្លភិក្ខុប្រហារភិក្ខុនី ១ រឿងភិក្ខុនីមួយរូប ដាក់កូនខ្ចី ក្នុងបាត្រ ១ រឿងពួកភិក្ខុនីផ្លាស់ប្តូរបាត្រហើយ ប្រាប់ថ្លៃឈ្នួលបាត្រ ១ រឿងភិក្ខុនីគន់មើលនិមិត្តរបស់បុរស ១ រឿងមនុស្សទាំងឡាយ ប្រគេនអាមិសៈដល់ពួកភិក្ខុ ១ រឿងអាមិសៈក៏សម្បូណ៌ច្រើនឡើង ១ រឿងពួកភិក្ខុ សន្សំអាមិសៈទុក ១ រឿងមនុស្សទាំងឡាយឲ្យអាមិសៈ ដល់ពួកភិក្ខុយ៉ាងណា ឲ្យដល់ភិក្ខុនីខាងក្រោយក៏ដូចគ្នា ១ ។ រឿងសេនាសនៈរបស់ភិក្ខុ សម្បូណ៌ឡើង ១ រឿងពួកភិក្ខុនី មានរដូវធ្លាក់ប្រឡាក់សំពត់ ១ រឿងភិក្ខុនីមានសំពត់ទ្រនាប់ជាប់ជាប ១ រឿងភិក្ខុនី ប្រើខ្សែក្រវាត់គ្រប់កាល ១ រឿងភិក្ខុនីគ្មាននិមិត្តខ្លះ មានហេតុបន្តិចគ្រាន់តែជាស្លាមខ្លះ មិនមានរដូវខ្លះ មានឈាមរដូវ ធ្លាក់ជានិច្ចខ្លះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


## ភិក្ខុនីខន្ធកេ ឧទ្ទានគាថា

ធុវចោឡបគ្ឃរន្តិ(១)
សិខរណិត្ថិ បណ្ឌកា
វេបុរិសី ច សម្ភិន្នា
ឧភតោព្យញ្ជនាបិ ច(២)
អនិមិត្តាទិតោ កត្វា
យាវ ឧភយព្យញ្ជនា(៣)
ឃតំ បេយ្យាលតោ ហេដ្ឋំ
កុដ្ឋំ គណ្ឌោ កិលាសិ ច
សោសាបមារេ មានុសី
ឥត្ថីសិ ភុជិស្សាសិ ច
អនណា ន រាជភដី
អនុញ្ញាតា ច វីសតិ
បរិបុណ្ណា ច កិន្នាមា
កា នាមា តេ បវត្តិនី
ចតុវីសន្តរាយានំ
បុច្ឆិត្វា ឧបសម្បទា ។

---

១ ឧ. ធុវចោឡំ បគ្ឃរណិ ។ ២ ឧ. ម. ឧភតោព្យញ្ជនា ច យា ។ ៣ ឧ. ម. ឧភតោព្យញ្ជនា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកៈ ឧទ្ទានគាថា

មានសំពត់ទ្រនាប់ជានិច្ចខ្លះ មានឈាមរដូវហូរខ្លះ ជាសិខរិណីខ្លះ ជាស្រីខ្ទើយខ្លះ ជាស្រីមានទ្រង់ដូចប្រុសខ្លះ មានទ្វារមគ្គលាយចូលគ្នាខ្លះ ជាឧភតោព្យញ្ជនកាខ្លះ តាំងពីរឿងភិក្ខុនីគ្មាននិមិត្ត រហូតដល់ឧភតោព្យញ្ជនកា ពាក្យខាងក្រោមបេយ្យាលនុ៎ះ មានរឿងភិក្ខុសួរអន្តរាយិកធម៌ ២៤ ប្រការ បំពោះឧបសម្បទាបេក្ខាថា នាងមានរោគឃ្លង់ឬ នាងមានរោគពកឬ នាងមានរោគស្រែងឬ នាងមានរោគរីងរៃឬ នាងមានរោគឆ្កួតជ្រូកឬ នាងជាស្រីមនុស្សឬ នាងជាស្រីពិតឬ នាងជាអ្នកជាឬ នាងគ្មានបំពាក់បំណុលគេទេឬ នាងមិនមែនជាស្រីខ្ញុំរាជការទេឬ នាងមានមាតាបិតានិងស្វាមីអនុញ្ញាតហើយឬ នាងមានវស្សាគ្រប់២០ហើយឬ នាងមានបាត្រគ្រប់គ្រាន់ហើយឬ នាងឈ្មោះអ្វី បវត្តិនីរបស់នាងឈ្មោះអ្វី ១ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



វុដ្ឋាយន្តិ អននុសិដ្ឋា[១]
សង្ឃមជ្ឈេ តថេវ ច
ឧបជ្ឈាកាហា សង្ឃាដិ
ឧត្តរន្តរវាសកោ
សង្កច្ចុទកសាដិ ច
អាចិក្ខិត្វាន បេសយេ
ពាលា អសម្មតេ កាតោ
យាចេ បុច្ឆន្តរាយិកា
ឯកតោ ឧបសម្បន្នា
ភិក្ខុសង្ឃេ តថា បុន
ឆាយា ឧតុទិវសា ច
សង្គីតិ តយោ និស្សយេ
អដ្ឋ អការណីយានិ

---

១ ឱ. ម. អនុសិដ្ឋា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



រឿងឧបសម្បទាបេក្ខា ដែលមិនទាន់បានប្រៀនប្រដៅ ក្រអិមក្រអៀម មិនហ៊ានប្រាប់អន្តរាយិកធម៌ ១ រឿងទ្រង់អនុញ្ញាតឲ្យប្រៀនប្រដៅហើយ សឹមសួរអន្តរាយិកធម៌ កណ្តាលជំនុំសង្ឃ ១ រឿងទ្រង់អនុញ្ញាតថា មុនដំបូង ត្រូវភិក្ខុនីឲ្យឧបសម្បទាបេក្ខាកាន់យកឧបជ្ឈាយ៍ ហើយត្រូវប្រាប់បាត្រនិងចីវរថា (នេះបាត្ររបស់នាង) នេះសង្ឃាដិ នេះចីពរ នេះស្បង់ នេះសំពត់ពោមពុង នេះសំពត់ងូតទឹក (របស់នាង) លុះប្រាប់ហើយត្រូវបញ្ជាប់ឲ្យឈរក្នុងឱកាសឯណោះ ១ រឿងភិក្ខុនីមួយរូប ល្ងង់ មិនឆ្លាស ទៅប្រៀនប្រដៅ ១ រឿងភិក្ខុនីដែលសង្ឃមិនទាន់សន្មតឲ្យប្រៀនប្រដៅទៅប្រៀនប្រដៅ ១ រឿងឧបសម្បទាបេក្ខាសូត្រសូមឧបសម្បទា ១ រឿងសួរអន្តរាយិកធម៌ ១ រឿងឧបសម្បទាបេក្ខា បានឧបសម្បទាចំណែកមួយ ហើយត្រូវសូមឧបសម្បទាក្នុងសំណាក់ភិក្ខុសង្ឃម្តងទៀត ១ រឿងភិក្ខុនីជាបវត្តិនីត្រូវវាស់ស្រមោល ប្រាប់ប្រមាណនៃរដូវ ប្រាប់ចំណែកថ្ងៃ ប្រាប់សង្គីតិ ប្រាប់និស្ស័យ ៣ យ៉ាង ប្រាប់អករណីយកិច្ច ៨ យ៉ាង ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


## ភិក្ខុនីខន្ធកេ ឧទ្ទានគាថា

កាលំ សត្ថុ អជ្ជជា(១)
ន បវារេន្តិ ភិក្ខុនី(២)
ភិក្ខុសង្ឃំ តថេវ ច
កោលាហលំ បុរេភត្តំ
វិកាលេ ច កុលាហលំ
ឧបោសថំ បវារណំ
សវចនំ អនុវាទំ
ឱកាសំ ចោទេ សារេន្តិ
បដិក្ខិត្តំ មហេសិនា ។
តថេវ ភិក្ខុ(៣) ភិក្ខុនី
អនុញ្ញាតំ មហេសិនា ។
យានំ គិលានំ យុត្តញ្ច
យានុគ្ឃាតញ្ច កាសិកា

---

១ ឱ. ម. អជ្ជភា ។ ២ ឱ. ម. ភិក្ខុនិយោ ។ ៣ ឱ. ភិក្ខូ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកៈ ឧទ្ទានគាថា

រឿងពួកភិក្ខុនីញុំាងភត្តកាលឲ្យកន្លងហួស ១ រឿងពួកភិក្ខុនី ៨ រូប ឃាត់អាសនៈភិក្ខុនីចាស់ក្នុងទីទាំងពួង ១ រឿងពួកភិក្ខុនីមិនបានបវារណា ១ រឿងពួកភិក្ខុនីបវារណាដោយខ្លួនឯងហើយ មិនបានបវារណាក្នុងភិក្ខុសង្ឃ ១ រឿងពួកភិក្ខុនីបវារណានឹងភិក្ខុសង្ឃហើយ កើតកោលាហល ១ រឿងពួកភិក្ខុនីបវារណាមុនភត្តហើយ ញុំាងភត្តកាលឲ្យកន្លងហួសទៅនឹងបវារណាខាងក្រោយភត្តក្នុងវេលាវិកាល ១ រឿងភិក្ខុនី-សង្ឃបវារណាហើយ ក៏កើតកោលាហល ១ រឿងពួកភិក្ខុនីឃាត់ឧបោសថ ឃាត់បវារណារបស់ភិក្ខុ ធ្វើឲ្យមានមាត់ពាក្យក្នុងអធិករណ៍ ផ្តើមអនុវាទាធិករណ៍ ឲ្យគេធ្វើឱកាស ចោទភិក្ខុនីរំលឹកភិក្ខុ ព្រះសម្ពុទ្ធអ្នកស្វែងរកនូវគុណដ៏ធំទ្រង់ឃាត់ដោយទុក្កដាបត្តិ ១ ។ រឿងពួកភិក្ខុឃាត់កម្មដ៏ទោះដែលជារបស់ពួកភិក្ខុនី ព្រះសម្ពុទ្ធព្រះអង្គអ្នកស្វែងរកគុណដ៏ធំទ្រង់អនុញ្ញាត ១ ។ រឿងពួកភិក្ខុនីជិះយាន ១ រឿងភិក្ខុនីមានជម្ងឺ ទ្រង់អនុញ្ញាតឲ្យជិះយានដែលស្រីឬបុរសអូសដោយដៃ ១ រឿងភិក្ខុនីមួយរូបមិនសប្បាយដោយទង្គិចនឹងយាន ១ រឿងនាងអឌ្ឍកាសីស្រីផ្កាមាស បួសក្នុងសំណាក់ភិក្ខុនី ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភិក្ខុ សិក្ខា សាមណេរ

សាមណេរី ច ពាលិយា

អរញ្ញេ ឧទាសកេន

ឧទ្ទោសិតោ ឧបស្សយំ

ន សម្មតិ នវកម្មំ

និសិន្នគព្ភឃតិកា

សាគារញ្ច គរុធម្មំ

អបច្ចក្ខា យា ច(១) សង្កមិ

អភិវាទន កេសា ច

នខា ច វណកម្មនា

បល្លង្កេន គិលានា ច

---

១ ឱ. បច្ចក្ខាយ ប ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



រឿងពួកភិក្ខុឲ្យឧបសម្បទា ដល់ភិក្ខុនីដែលល្អង់ ដោយភិក្ខុទូត ដោយសិក្ខមានាទូត ដោយសាមណេរទូត ដោយសាមណេរីទូត ១ រឿងពួកភិក្ខុនីនៅក្នុងព្រៃ ១ រឿងឧបាសកម្នាក់ថ្វាយឃ្លាំង (សម្រាប់ដាក់របស់) នឹងអនុញ្ញាតផ្ទះលំនៅ ៗ តែមិនគ្រប់គ្រាន់ ព្រះអង្គក៏អនុញ្ញាតឲ្យធ្វើនវកម្ម ១ រឿងស្រីម្នាក់មានគភ៌មកបួស លុះទារកប្រសូតមក នាងមិនហ៊ាននៅម្នាក់ឯងជាមួយទារក ព្រះអង្គអនុញ្ញាតឲ្យរក្សាទារកនោះ ដូចជាប្រតិបត្តិក្នុងបុរសដទៃ វៀរលែងតែផ្ទះជាមួយគ្នា ១ រឿងភិក្ខុនីមួយរូបត្រូវគរុកាបត្តិហើយប្រព្រឹត្តមានត្ត ១ រឿងភិក្ខុនីមួយរូបមិនលាសិក្ខាហើយស្រាប់តែសឹកចេញ នឹងរឿងព្រះអង្គត្រាស់ថា ភិក្ខុនីដែលចូលទៅកាន់លទ្ធិតិត្ថិយទាំងសំពត់កាសាវៈ ហើយមកបួសវិញមិនបាន ១ រឿងពួកភិក្ខុនីមានសេចក្តីរង្វៀសមិនត្រេកអរចំពោះការថ្វាយបង្គំ ការកោរសក់ការកាត់ក្រចក ការរក្សាដម្បៅមួយអន្លើដោយបុរស ១ រឿងពួកភិក្ខុនី អង្គុយពែនភ្នែន ត្រេកអរដោយសម្ផស្សនៃកែងជើងនឹងអនុញ្ញាតឲ្យភិក្ខុនីឈឺអង្គុយពែនមួយចំហៀងបាន ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកេ ឧទ្ទានគាថា

វត្ថុំ បុណ្ណេន សេសិតំ
ជ្ឈាយរេ បដិសោតេ
អតិត្ថេ បុរិសេន ច
មហាគោតមី អាយាចិ
អានន្ទោ ចាបិ យោនិសោ ។
បរិសា ចតស្សោ ហោន្តិ
បព្វជ្ជា[១] ជិនសាសនេ ។
សំវេគជននត្ថាយ
សទ្ធម្មស្ស ច វុឌ្ឍិយា[២]
អាតុរស្ស វ ភេសជ្ជំ
ឯវំ ពុទ្ធេន ទេសិតំ ។
ឯវំ វិនីតា[៣] សទ្ធម្មេ
មាតុគាមាបិ ឥតរា
តា យន្តិ អច្ចុតំ បទំ
យត្ថ គន្ត្វា ន សោចរេតិ ។

---

១ ឱ. បព្វជ្ជំ ។ ២ ឱ. ម. ពុទ្ធិយា ។ ៣ ឱ. ម. វិទិតា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## ភិក្ខុនីខន្ធកៈ ឧទ្ទានគាថា

រឿងភិក្ខុនីបន្ទោបង់នូវវច្ចៈក្នុងបត្តន់ ១ រឿងពួកភិក្ខុនីដុសខ្លួនដោយលំអិតនឹងដីដែលគេអប់ ១ រឿងភិក្ខុនីងូតទឹកក្នុងរោងសម្រាប់រក្សាកាយ ១ រឿងភិក្ខុនីងូតទឹកឈរក្នុងទីច្រាសខ្សែទឹក ងូតទឹកក្នុងទីមិនមែនជាកំពង់ និងងូតទឹកក្នុងទីជាកំពង់សម្រាប់បុរស ១ ព្រះនាងមហាបជាបតីគោតមី ក្រាបបង្គំទូលសូមបព្វជ្ជា ព្រះអានន្ទក៏ជួយសូមដោយឧបាយ (ដោយប្រការដូច្នេះ) ។ ឯពួកស្ត្រីបានបួសក្នុងសាសនានៃព្រះជិនស្រី ក៏ពប់ថាជាបរិសទ្យ ៤ ពួក (តាំងពីកាលនោះមក) ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់បានសម្តែង (ភិក្ខុនីខន្ធកៈ) ទុកមកដោយប្រការដូច្នេះ ដើម្បីប្រយោជន៍នឹងបង្កើតសេចក្តីសង្វេគផង ដើម្បីឲ្យចំរើនព្រះសទ្ធម្មផង ដូចជាថ្នាំ (ដែលពេទ្យផ្សំឡើង) បម្រុងព្យាបាលជម្ងឺ ។ សូម្បីមាតុគ្រាមក្រៅអំពីព្រះនាងមហាបជាបតីគោតមី ព្រះមានព្រះភាគក៏បានទូន្មានឲ្យឋិតនៅក្នុងព្រះសទ្ធម្មយ៉ាងនេះឯង ហើយស្ត្រីទាំងនោះបានដល់នូវឋាន គឺព្រះនិព្វាន ដែលជាឋានពួកជនដល់ហើយមិនបានសោយសោក ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# បញ្ចសតិកក្ខន្ធកំ

[២៧៨] អថខោ អាយស្មា មហាកស្សបោ ភិក្ខូ អាមន្តេសិ ឯកមិទាហំ អាវុសោ សមយំ បាវាយ កុសិនារំ អទ្ធានមគ្គប្បដិបន្នោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ អថខ្វាហំ អាវុសោ មគ្គា ឱក្កម្ម អញ្ញតរស្មឹ រុក្ខមូលេ និសីទឹ តេន ខោ បន សមយេន អញ្ញតរោ អាជីវកោ កុសិនារាយ មន្ទារវបុប្ផំ គហេត្វា បាវំ អទ្ធានមគ្គប្បដិបន្នោ ហោតិ អទ្ទសំ ខោ អហំ អាវុសោ តំ អាជីវកំ ទូរតោវ អាគច្ឆន្តំ ទិស្វាន តំ អាជីវកំ ឯតទវោចំ អបិ នាវុសោ អម្ហាកំ សត្ថារំ ជានាសីតិ អាមាវុសោ ជានាមិ អជ្ជ សត្តាហបរិនិព្វុតោ សមណោ គោតមោ តតោ មេ ឥទំ មន្ទារវបុប្ផំ គហិតន្តិ តត្រាវុសោ យេ តេ ភិក្ខូ អវីតរាគា អប្បេកច្ចេ ពាហា បគ្គយ្ហ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# បញ្ចសតិកក្ខន្ធកៈ

[២៧៨] លំដាប់នោះ ព្រះមហាកស្សប មានអាយុហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំងឡាយ សម័យមួយ ខ្ញុំគិតថានឹងត្រាច់ទៅបិណ្ឌបាតក្នុងក្រុងបាវានេះ រួចហើយនឹងទៅកាន់ក្រុងកុសិនារា ហើយក៏ដើរទៅតាមផ្លូវឆ្ងាយជាមួយនឹងភិក្ខុសង្ឃដ៏ច្រើនចំនួន ៥០០ រូប ម្នាលអាវុសោទាំងឡាយ គ្រានោះឯង ខ្ញុំគេចចៀសចេញពីផ្លូវហើយទៅអង្គុយទៀបគល់ឈើមួយដើម ក៏សម័យនោះឯង មានអាជីវក ម្នាក់កាន់ផ្កាមន្ទារវៈ (មន្ទារវបុស្ប) ពីក្នុងនគរកុសិនារា ដើរតាមផ្លូវឆ្ងាយសំដៅទៅកាន់ក្រុងបាវា ម្នាលអាវុសោទាំងឡាយ ខ្ញុំក៏បានឃើញអាជីវកនោះកំពុងដើរមកអំពីចម្ងាយ លុះឃើញហើយ ខ្ញុំនិយាយសួរទៅអាជីវកនោះដូច្នេះថា នែអាវុសោ អ្នកបានដឹងដំណឹងព្រះជាគ្រូនៃយើងដែរឬ អាជីវកនោះឆ្លើយតបថា អើអាវុសោ ខ្ញុំដឹងដែរ ព្រះសមណគោតមជាគ្រូអ្នកបរិនិព្វានកន្លងទៅ ៧ ថ្ងៃហើយ រាប់ពីថ្ងៃនេះទៅ ផ្កាមន្ទារវៈនេះខ្ញុំយកពីនគរកុសិនារានោះមក ម្នាលអាវុសោទាំងឡាយ បណ្ដាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណាដែលមិនទាន់ប្រាសចាករាគៈ[១] ភិក្ខុទាំងនោះ ពួកខ្លះ ក៏លើកដៃ

---

១ ក្នុងដីកាថា បុថុជ្ជន សោតាបន្នបុគ្គល នឹងសកទាគាមិបុគ្គល ហៅថា បុគ្គលមិនទាន់ប្រាសចាករាគៈ ក្នុងទីនេះ ។

## បញ្ចសតិកក្ខន្ធកេ អាយស្មតោ មហាកស្សបស្ស ឧភាទោ

កន្ទន្តិ ឆិន្នបាតាវ បតន្តិ(១) អាវដ្ដន្តិ វិវដ្ដន្តិ អតិខិប្បំ
ភគវា បរិនិព្វុតោ អតិខិប្បំ សុគតោ បរិនិព្វុតោ អ-
តិខិប្បំ ចក្ខុំ លោកេ អន្តរហិតន្តិ យេ បន តេ
ភិក្ខូ វីតរាគា តេ សតា សម្បជានា អធិវាសេន្តិ អនិច្ចា
សង្ខារា តំ កុតេត្ថ លព្ភាតិ អថខ្វាហំ អាវុសោ តេ ភិក្ខូ
ឯតទវោចំ អលំ អាវុសោ មា សោចិត្ថ មា បរិទេវិត្ថ
នន្វេតំ អាវុសោ ភគវតា បដិកច្ចេវ អក្ខាតំ សព្វេហេវ
បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ អញ្ញថាភាវោ
តំ កុតេត្ថ អាវុសោ(២) លព្ភា យន្តំ ជាតំ ភូតំ សង្ខតំ

---

១ ឱ. ឆិន្នបាតំ បបតន្តិ ។ ម. ឆិន្នបាតា បបតន្តិ ។ ២ ឥទំ អាលបនំ អតិរេកំ មញ្ញេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឡើងហើយយំកន្ទក់កន្ទេញ[១] ដួលដេកទៅ ហាក់ដូចជាមានជើងដាច់ ហើយបម្រាស់នរៀលទៅមក ពោលពាក្យថា ព្រះមានព្រះភាគ ដាច់បរិនិព្វានពេកណាស់ ព្រះសុគតជាម្ចាស់ដាច់បរិនិព្វានអ៊ីម៉្លេះ ចក្ខុ ពោលគឺព្រះពុទ្ធក្នុងលោក (ពុទ្ធចក្ខុ) ដាច់បាត់បង់ទៅអ៊ីម៉្លេះ ចំណែកភិក្ខុទាំងឡាយណាដែលប្រាសចាករាគៈ[២] ហើយ ភិក្ខុទាំងនោះមានស្មារ-តីតាំងមាំ មានបញ្ញាដឹងច្បាស់ ក៏អត់សង្កត់បាន ដោយពិចារណាថា សង្ខារទាំងឡាយមិនទៀងទេ ព្រោះហេតុនោះ បុគ្គលគប្បីបាន (នូវសេចក្តីទៀងទាត់) ក្នុងខន្ធប្រវត្តិនេះ អំពីណា ម្នាលអាវុសោទាំងឡាយ គ្រានោះឯង ខ្ញុំបាននិយាយហាត់ពួកភិក្ខុនោះដូច្នេះថា ម្នាលអាវុសោទាំងឡាយ ចូរអ្នកទាំងឡាយកុំសោយសោកឡើយ កុំខ្សឹកខ្សួលឡើយ ម្នាលអាវុសោទាំងឡាយ ក្រែងព្រះមានព្រះភាគ បានត្រាស់ប្រាប់សេចក្តីនេះមកពីមុនហើយថា សេចក្តីព្រាត់ប្រាសស្លាប់និរាសចាកពោលសត្វនិងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងអស់ រមែងមាននៃអាវុសោទាំងឡាយ ព្រោះហេតុនោះ បុគ្គលគប្បីបាន (នូវសេចក្តីមិនព្រាត់ប្រាស) ក្នុងខន្ធប្រវត្តិនេះ អំពីណា ធម្មជាតណា ដែលកើតឡើងហើយ ដែលមានហើយ ដែលសង្ខារតាក់តែងមកហើយ

---

១ លើកដៃទាំងពីរដាក់លើក្បាលហើយទួញយំ ។ ២ ក្នុងដីកាថា ព្រះអនាគាមិនឹងព្រះខីណាស្រព ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បលោកធម្មំ តំ វត មា បលុជ្ជីតិ នេតំ ឋានំ វិជ្ជតីតិ តេន ខោ បនាវុសោ សមយេន សុភទ្ទោ នាម វុឌ្ឍបព្វជិតោ តស្សំ បរិសាយំ និសិន្នោ ហោតិ អថខោ អាវុសោ សុភទ្ទោ វុឌ្ឍបព្វជិតោ តេ ភិក្ខូ ឯតទវោច អលំ អាវុសោ មា សោចិត្ថ មា បរិទេវិត្ថ សុមុត្តា មយំ តេន មហាសមណេន ឧបទ្ទុតា ច មយំ ហោម ឥទំ វោ កប្បតិ ឥទំ វោ ន កប្បតីតិ ឥទានិ បន មយំ យំ ឥច្ឆិស្សាម តំ ករិស្សាម យំ ន ឥច្ឆិស្សាម តំ ន ករិស្សាមាតិ ហន្ទ មយំ អាវុសោ ធម្មញ្ច វិនយញ្ច សង្គាយាម បុរេ អធម្មោ ទិប្បតិ ធម្មោ បដិពាហិយតិ អវិនយោ ទិប្បតិ វិនយោ បដិពាហិយតិ បុរេ អធម្មវាទិនោ ពលវន្តោ ហោន្តិ ធម្មវាទិនោ ទុព្វលា ហោន្តិ អវិនយវាទិនោ ពលវន្តោ ហោន្តិ វិនយវាទិនោ ទុព្វលា ហោន្តីតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





ជារបស់មានកិរិយាទ្រុឌទ្រោមវិនាសទៅវិញជាធម្មតា ធម្មជាតនោះបុគ្គលឃាត់ថា កុំវិនាសទៅវិញដូច្នេះ ពុំបានឡើយ ម្នាលអាវុសោទាំងឡាយ សម័យនោះឯង មានភិក្ខុមួយរូបឈ្មោះសុភទ្ទ បួសឯចាស់ អង្គុយនៅក្នុងបំណោមបរិសទ្យនោះ ម្នាលអាវុសោទាំងឡាយ គ្រានោះ ស្រាប់តែសុភទ្ទភិក្ខុបួសឯចាស់និយាយទៅនឹងភិក្ខុទាំងឡាយនោះយ៉ាងនេះថា នែអាវុសោទាំងឡាយ អ្នកទាំងឡាយ កុំសោយសោកឡើយ កុំខ្សឹកខ្សួលអណ្តឹតអណ្តកឡើយ យើងទាំងឡាយឈ្មោះថាផុតស្រឡះហើយអំពីមហាសមណៈនោះ ព្រោះថាយើងទាំងឡាយ មហាសមណៈនោះតែងបៀតបៀនថា អំពើនេះគួរដល់អ្នកទាំងឡាយ អំពើនេះមិនគួរដល់អ្នកទាំងឡាយទេ ឥឡូវនេះស្រួលហើយ យើងរាល់គ្នាចង់ធ្វើនូវអំពើណា នឹងធ្វើនូវអំពើនោះក៏បាន មិនចង់ធ្វើនូវអំពើណា នឹងមិនធ្វើនូវអំពើនោះក៏បាន ម្នាលអាវុសោទាំងឡាយ ណ្ហើយចុះ យើងរាល់គ្នាសង្គាយនានូវធម៌និងវិន័យ តំណទៅមុខ អកុសលធម៌មុខជានឹងរុងរឿងឡើង កុសលធម៌មុខជានឹងសាបសូន្យទៅ សភាវៈមិនមែនជាវិន័យមុខជានឹងរុងរឿងឡើង វិន័យមុខជានឹងសាបសូន្យទៅ តំណទៅមុខ ពួកបុគ្គលជាអធម្មវាទីនឹងមានកំឡាំងឡើង ពួកបុគ្គលជាធម្មវាទីនឹងថយកំឡាំងចុះ ពួកបុគ្គលជាអវិនយវាទីនឹងមានកំឡាំងឡើង ពួកបុគ្គលជាវិនយវាទីនឹងថយកំឡាំងចុះ ។

## បញ្ចសតិកក្ខន្ធកេ បញ្ចន្នំ ភិក្ខុសតានំ សម្មតិ

[២៧៩] តេនហិ ភន្តេ ថេរោ ភិក្ខូ ឧច្ចិនាតូតិ ។ អថខោ អាយស្មា មហាកស្សបោ ឯកេនូនបញ្ចអរហន្តសតានិ ឧច្ចិនិ ។ ភិក្ខូ អាយស្មន្តំ មហាកស្សបំ ឯតទវោចុំ អយំ ភន្តេ អាយស្មា អានន្ទោ កិញ្ចាបិ សេក្ខោ សមានោ(១) អភព្វោ ឆន្ទា ទោសា មោហា ភយា អគតឹ គន្តុំ ពហុ ចានេន ភគវតោ សន្តិកេ ធម្មោ ច វិនយោ ច បរិយត្តោ តេនហិ ភន្តេ ថេរោ អាយស្មន្តម្បិ អានន្ទំ ឧច្ចិនាតូតិ ។ អថខោ អាយស្មា មហាកស្សបោ អាយស្មន្តម្បិ អានន្ទំ ឧច្ចិនិ ។ អថខោ ថេរានំ ភិក្ខូនំ ឯតទហោសិ កត្ថ នុ ខោ មយំ ធម្មញ្ច វិនយញ្ច សង្គាយេយ្យាមាតិ ។ អថខោ ថេរានំ ភិក្ខូនំ ឯតទហោសិ រាជគហំ ខោ មហាគោចរំ បហូតសេនាសនំ យន្នូន មយំ រាជគហេ វស្សំ វសន្តា ធម្មញ្ច វិនយញ្ច សង្គាយេយ្យាម ន អញ្ញេ ភិក្ខូ រាជគហេ វស្សំ ឧបគច្ឆេយ្យុន្តិ ។ អថខោ អាយស្មា មហាកស្ស-

---

១ ឱ. ម. ពោត្ថកេសុ សមានោតិ សទ្ទោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បញ្ចសតិកក្ខន្ធកៈ ការសង្គីតិភិក្ខុ ៥០០រូប

(២៧៩) ភិក្ខុទាំងឡាយពោលថា បពិត្រព្រះថេរៈដ៏ចំរើន បើដូច្នោះ សូមព្រះថេរៈជ្រើសរើសនូវភិក្ខុទាំងឡាយចុះ ។ ទើបព្រះមហាកស្សបមានអាយុ ជ្រើសរើសនូវព្រះអរហន្តទាំងឡាយបានចំនួន ៤៩៩ អង្គ ។ ភិក្ខុទាំងឡាយនិយាយពាក្យនេះនឹងព្រះមហាកស្សបមានអាយុថា បពិត្រព្រះករុណាដ៏ចំរើន ព្រះអានន្ទមានអាយុនេះនៅជាសេក្ខបុគ្គលពិតមែន តែលោកមិនអាចនឹងលុះដោយឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិទេ ធម្មក្តី វិន័យក្តី ព្រះអានន្ទនេះបានសិក្សារៀនសូត្រក្នុងសំណាក់ព្រះមានព្រះភាគជាច្រើន បពិត្រព្រះករុណាដ៏ចំរើន បើដូច្នោះ សូមព្រះថេរៈជ្រើសរើសយកព្រះអានន្ទមានអាយុផង ។ ទើបព្រះមហាកស្សបមានអាយុ ជ្រើសរើសយកព្រះអានន្ទមានអាយុបញ្ចូលផង (ជា ៥០០ អង្គ) ។ លំដាប់នោះ ភិក្ខុទាំងឡាយដែលជាថេរៈមានសេចក្តីរិះគិតដូច្នេះថា យើងទាំងឡាយគប្បីសង្គាយនាធម៌និងវិន័យក្នុងទីណាហ្ន៎ ។ គ្រានោះឯង ភិក្ខុទាំងឡាយដែលជាថេរៈមានសេចក្តីរិះគិតឃើញដូច្នេះថា នគររាជគ្រឹះ ជាស្រុកមានទីគោចរច្រើន មានសេនាសនៈច្រើន បើដូច្នោះ គួរតែយើងកាល់គ្នាទៅនៅចាំវស្សាក្នុងនគររាជគ្រឹះ ទើបអាចនឹងសង្គាយនានូវធម៌និងវិន័យបាន ឯភិក្ខុទាំងឡាយឯទៀត កុំគប្បីចូលទៅនៅចាំវស្សាក្នុងនគររាជគ្រឹះឡើយ ។ លំដាប់នោះឯង ព្រះមហាកស្សបមានអាយុ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ថោ សង្ឃំ ញាបេសិ សុណាតុ មេ អាវុសោ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមានិ បញ្ច ភិក្ខុសតានិ សម្មន្នេយ្យ រាជគហេ វស្សំ វសន្តានិ[1] ធម្មញ្ច វិនយញ្ច សង្គាយិតុំ ន អញ្ញេហិ ភិក្ខូហិ រាជគហេ វស្សំ វសិតព្វន្តិ ។ ឯសា ញត្តិ ។ សុណាតុ មេ អាវុសោ សង្ឃោ សង្ឃោ ឥមានិ បញ្ច ភិក្ខុសតានិ សម្មន្នតិ រាជគហេ វស្សំ វសន្តានិ ធម្មញ្ច វិនយញ្ច សង្គាយិតុំ ន អញ្ញេហិ ភិក្ខូហិ រាជគហេ វស្សំ វសិតព្វន្តិ ។ យស្សាយស្មតោ ខមតិ ឥមេសំ បញ្ចន្នំ ភិក្ខុសតានំ សម្មតិ រាជគហេ វស្សំ វសន្តានំ ធម្មញ្ច វិនយញ្ច សង្គាយិតុំ ន អញ្ញេហិ ភិក្ខូហិ រាជគហេ វស្សំ វសិតព្វន្តិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតានិ[2] សង្ឃេន ឥមានិ បញ្ច ភិក្ខុសតានិ រាជគហេ វស្សំ វសន្តានិ ធម្មញ្ច វិនយញ្ច សង្គាយិតុំ ន អញ្ញេហិ ភិក្ខូហិ រាជគហេ វស្សំ វសិតព្វន្តិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមិ ។

---

១ ឱ. ម. វសន្តា ។ ២ ឱ. ម. សម្មតា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ប្រកាសសង្ឃឲ្យដឹងថា ម្នាលលោកមានអាយុ សង្ឃចូរស្តាប់ខ្ញុំ បើសង្គីតិកម្ម មានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុទាំង ៥០០ រូបនេះ ឲ្យនៅចាំវស្សាក្នុងនគររាជគ្រឹះ ដើម្បីសង្គាយនានូវធម៌និងវិន័យ ឯភិក្ខុទាំងឡាយដទៃមិនត្រូវនៅចាំវស្សាក្នុងនគររាជគ្រឹះឡើយ ។ នេះជាញត្តិ ។ ម្នាលលោកមានអាយុ សង្ឃចូរស្តាប់ខ្ញុំ ឥឡូវសង្ឃសន្មតភិក្ខុទាំង ៥០០ រូបនេះ ឲ្យនៅចាំវស្សាក្នុងនគររាជគ្រឹះ ដើម្បីសង្គាយនានូវធម៌និងវិន័យ ឯភិក្ខុទាំងឡាយដទៃមិនត្រូវនៅចាំវស្សាក្នុងនគររាជគ្រឹះឡើយ ។ ការសន្មតភិក្ខុទាំង ៥០០ រូបនេះ ឲ្យនៅចាំវស្សាក្នុងនគររាជគ្រឹះ ដើម្បីនឹងសង្គាយនានូវធម៌និងវិន័យ ឯភិក្ខុទាំងឡាយដទៃមិនត្រូវឲ្យនៅចាំវស្សាក្នុងនគររាជគ្រឹះទេ គាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះគប្បីពោលឡើង ។ សង្ឃបានសន្មតពួកភិក្ខុទាំង ៥០០ រូបនេះ ឲ្យនៅចាំវស្សាក្នុងនគររាជគ្រឹះ ដើម្បីសង្គាយនានូវធម៌និងវិន័យ ឯភិក្ខុទាំងឡាយដទៃមិនត្រូវនៅចាំវស្សា ក្នុងនគររាជគ្រឹះឡើយ ។ ការសន្មតិនេះគាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវសេចក្តីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បញ្ចសតិកក្ខន្ធកេ ខណ្ឌផុល្លបដិសង្ខរណាទិ

[២៨០] អថខោ ថេរា ភិក្ខូ រាជគហំ អគមំសុ ធម្មញ្ច វិនយញ្ច សង្គាយិតុំ ។ អថខោ ថេរានំ ភិក្ខូនំ ឯតទហោសិ ភគវតា ខោ អាវុសោ ខណ្ឌផុល្លបដិសង្ខរណំ វណ្ណិតំ ហន្ទ មយំ អាវុសោ បឋមំ មាសំ ខណ្ឌផុល្លំ បដិសង្ខរោម មជ្ឈិមំ មាសំ សន្និបតិត្វា ធម្មញ្ច វិនយញ្ច សង្គាយិស្សាមាតិ ។ អថខោ ថេរា ភិក្ខូ បឋមំ មាសំ ខណ្ឌផុល្លំ បដិសង្ខរឹសុ ។

[២៨១] អថខោ អាយស្មា អានន្ទោ ស្វេ សន្និបាតោ ន ខោ មេតំ បដិរូបំ យោហំ សេក្ខោ សមានោ សន្និបាតំ គច្ឆេយ្យន្តិ ពហុទេវ រត្តឹ កាយគតាយ សតិយា វីតិនាមេត្វា រត្តិយា បច្ចូសសមយំ និបជ្ជិស្សាមីតិ កាយំ អាវជ្ជេសិ ។ អប្បត្តញ្ច សីសំ ពិម្ពោហនំ ។ ភូមិតោ ច បាទា មុត្តា ។ ឯតស្មឹ អន្តរេ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចិ ។ អថខោ អាយស្មា អានន្ទោ អរហា សមានោ សន្និបាតំ អគមាសិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## បញ្ចសតិកក្ខន្ធកៈ កិច្ចមានការជួសជុលទីដែលធ្លុះធ្លាយជាដើម

(៤៨០) គ្រានោះ ភិក្ខុជាថេរៈទាំងឡាយ បានទៅកាន់នគររាជគ្រឹះ ដើម្បីសង្គាយនានូវធម៌និងវិន័យ ។ ទើបភិក្ខុទាំងឡាយជាថេរៈមានសេចក្តីរិះគិតដូច្នេះថា ម្នាលអាវុសោ បដិសង្ខរណកម្ម គឺការជួសជុលសេនាសនៈដែលដាច់ដាចធ្លុះធ្លាយ ព្រះមានព្រះភាគទ្រង់សរសើរហើយ ម្នាលអាវុសោ បើដូច្នោះ គួរតែយើងរាល់គ្នា ជួសជុលសេនាសនៈដែលដាច់ដាចធ្លុះធ្លាយអស់ខែមួយជាដំបូងសិន ដល់មកខែជាកណ្តាល យើងនឹងប្រជុំគ្នាសង្គាយនានូវធម៌និងវិន័យ ។ លំដាប់នោះ ភិក្ខុជាថេរៈទាំងឡាយ ក៏នាំគ្នាជួសជុលសេនាសនៈដែលដាច់ដាចធ្លុះធ្លាយ អស់ខែមួយជាដំបូង ។

(៤៨១) គ្រានោះ ព្រះអានន្ទមានអាយុត្រិះរិះថា ថ្ងៃស្អែកនេះនឹងប្រជុំសង្ឃ កិច្ចនោះមិនសមគួរដល់អាត្មាអញឡើយ ព្រោះថាអាត្មាអញនៅជាសេក្ខបុគ្គលនៅឡើយ ហើយទៅកាន់ប្រជុំសង្ឃ គិតដូច្នេះហើយ ក៏បំរើនកាយគតាសតិកម្មដ្ឋានអស់រាត្រីជ្រៅ លុះដល់បច្ចូសសម័យនៃរាត្រី (ជិតភ្លឺ) នោះហើយ ក៏ទំរេតកាយដោយគិតថានឹងសិង ។ ព្រះសិរពុំទាន់ដល់ខ្នើយ ។ ព្រះបាទាទើបតែនឹងផុតអំពីផែនដី ។ ព្រះទ័យ (របស់លោក) ក៏រួចស្រឡះចាកអាសវៈទាំងឡាយ ដោយមិនមានឧបាទាន ក្នុងចន្លោះនោះឯង ។ ព្រះអានន្ទមានអាយុ បានជាព្រះអរហន្តហើយ ទើបបាននិមន្តទៅកាន់ប្រជុំសង្ឃ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


[២៨២] អថ ខោ អាយស្មា មហាកស្សបោ សង្ឃំ ញាបេសិ សុណាតុ មេ អាវុសោ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ ឧបាលឹ វិនយំ បុច្ឆេយ្យន្តិ ។ អាយស្មា ឧបាលិ សង្ឃំ ញាបេសិ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អាយស្មតា មហាកស្ស-បេន វិនយំ បុដ្ឋោ វិស្សជ្ជេយ្យន្តិ ។ អថ ខោ អាយស្មា មហាកស្សបោ អាយស្មន្តំ ឧបាលឹ ឯតទវោច បឋមំ អាវុសោ ឧបាលិ បារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា ភន្តេតិ ។ កំ អារព្ភាតិ ។ សុទិន្នំ កលន្ទបុត្តំ អារព្ភាតិ ។ កិស្មឹ វត្ថុស្មិន្តិ ។ មេថុនធម្មេតិ ។ អថ ខោ អាយស្មា មហាកស្សបោ អាយស្មន្តំ ឧបាលឹ បឋមស្ស បារាជិក-ស្ស វត្ថុម្បិ បុច្ឆិ និទានម្បិ បុច្ឆិ បុគ្គលម្បិ បុច្ឆិ បញ្ញត្តិម្បិ បុច្ឆិ អនុប្បញ្ញត្តិម្បិ បុច្ឆិ អាបត្តិម្បិ បុច្ឆិ អនាបត្តិម្បិ បុច្ឆិ ទុតិយម្បនាវុសោ ឧបាលិ បារាជិកំ កត្ថ បញ្ញត្តន្តិ ។ រាជគហេ ភន្តេតិ ។ កំ អារព្ភាតិ ។ ធនិយំ កុម្ភការបុត្តំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(២៨២) គ្រានោះឯង ព្រះមហាកស្សប មានអាយុបានប្រកាស សង្ឃឲ្យដឹងថា ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ បើសង្គីតិកម្មនេះមានកាល គួរដល់សង្ឃហើយ ខ្ញុំគប្បីសួរវិន័យនឹងព្រះឧបាលិ ៗ ព្រះឧបាលិមាន អាយុបានប្រកាសសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើ សង្គីតិកម្មនេះ មានកាលគួរដល់សង្ឃហើយ ព្រះមហាកស្សបមានអាយុ ត្រូវសួរព្រះវិន័យចំពោះខ្ញុំ ៗ ក៏ត្រូវដោះស្រាយ ( ក្នុងកាលឥឡូវនេះ ) ៗ ទើបព្រះមហាកស្សបមានអាយុ បានចោទសួរដូច្នេះ ចំពោះព្រះឧបាលិ មានអាយុថា ម្នាលឧបាលិមានអាយុ បឋមបារាជិកសិក្ខាបទ ព្រះមាន ព្រះភាគទ្រង់បញ្ញត្តក្នុងទីណា ៗ ព្រះឧបាលិឆ្លើយថា ក្នុងនគរវេសាលី លោកម្ចាស់ ៗ ទ្រង់ប្រារព្ធនឹងបុគ្គលណា ៗ ទ្រង់ប្រារព្ធនឹងសុទិន្នភិក្ខុ ជាកូននៃកលន្ទសេដ្ឋី ៗ ព្រោះវត្ថុអ្វី ៗ ព្រោះសេពមេថុនធម្ម ៗ លំ-ដាប់នោះឯង ព្រះមហាកស្សប មានអាយុ សួរវត្ថុផង សួរនិទានផង សួរបុគ្គលផង សួរបញ្ញត្តិផង សួរអនុប្បញ្ញត្តិផង សួរអាបត្តិផង សួរអនា-បត្តិផង នៃបឋមបារាជិកសិក្ខាបទ ចំពោះព្រះឧបាលិមានអាយុ ហើយ សួរតទៅថា ម្នាលអាវុសោ ឧបាលិ ទុតិយបារាជិកសិក្ខាបទ ព្រះមាន ព្រះភាគទ្រង់បញ្ញត្តក្នុងទីណា ៗ ក្នុងនគររាជគ្រឹះ លោកម្ចាស់ ៗ ទ្រង់ ប្រារព្ធនឹងបុគ្គលណា ៗ ទ្រង់ប្រារព្ធនឹងធនិយភិក្ខុ ជាកូននៃនាយស្មូន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បញ្ចសតិកក្ខន្ធកេ ទុតិយបារាជិកាទីនំ សង្គាយនា

អារព្ភាតិ ។ កិស្មឹ វត្ថុស្មិន្តិ ។ អទិន្នាទានេតិ ។ អថខោ អាយស្មា មហាកស្សបោ អាយស្មន្តំ ឧបាលឹ ទុតិយស្ស បារាជិកស្ស វត្ថុម្បិ បុច្ឆិ និទានម្បិ បុច្ឆិ បុគ្គលម្បិ បុច្ឆិ បញ្ញត្តិម្បិ បុច្ឆិ អនុប្បញ្ញត្តិម្បិ បុច្ឆិ អាបត្តិម្បិ បុច្ឆិ អនាបត្តិម្បិ បុច្ឆិ តតិយម្បនាវុសោ ឧបាលិ បារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា ភន្តេតិ ។ កំ អារព្ភាតិ ។ សម្ពហុលេ ភិក្ខូ អារព្ភាតិ ។ កិស្មឹ វត្ថុស្មិន្តិ ។ មនុស្ស-វិគ្គហេតិ ។ អថខោ អាយស្មា មហាកស្សបោ អាយស្មន្តំ ឧបាលឹ តតិយស្ស បារាជិកស្ស វត្ថុម្បិ បុច្ឆិ និទានម្បិ បុច្ឆិ បុគ្គលម្បិ បុច្ឆិ បញ្ញត្តិម្បិ បុច្ឆិ អនុប្បញ្ញត្តិម្បិ បុច្ឆិ អាបត្តិម្បិ បុច្ឆិ អនាបត្តិម្បិ បុច្ឆិ ចតុត្ថម្បនាវុសោ ឧបាលិ បារាជិកំ កត្ថ បញ្ញត្តន្តិ ។ វេសាលិយា ភន្តេតិ ។ កំ អារព្ភាតិ ។ វគ្គុមុទាតីរិយេ ភិក្ខូ អារព្ភាតិ ។ កិស្មឹ វត្ថុស្មិន្តិ ។ ឧត្តរិមនុស្សធម្មេតិ ។ អថខោ អាយស្មា មហាកស្សបោ អាយស្មន្តំ ឧបាលឹ ចតុត្ថស្ស បារាជិកស្ស វត្ថុម្បិ បុច្ឆិ និទានម្បិ បុច្ឆិ បុគ្គលម្បិ បុច្ឆិ បញ្ញត្តិម្បិ បុច្ឆិ អនុប្បញ្ញត្តិម្បិ បុច្ឆិ

ផ្ទាំង ៗ ព្រោះវត្ថុអ្វី ៗ ព្រោះអទិន្នាទាន ៗ លំដាប់នោះឯង ព្រះមហាកស្សបមានអាយុ សួរវត្ថុផង សួរនិទានផង សួរបុគ្គលផង សួរបញ្ញត្តិផង សួរអនុប្បញ្ញត្តិផង សួរអាបត្តិផង សួរអនាបត្តិផង នៃទុតិយបារាជិកសិក្ខាបទ ចំពោះព្រះឧបាលិមានអាយុ ហើយសួរតទៅទៀតថា ម្នាលអាវុសោ ឧបាលិ តតិយបារាជិកសិក្ខាបទ ព្រះមានព្រះភាគទ្រង់បញ្ញត្តក្នុងទីណា ៗ ក្នុងនគរវេសាលី លោកម្ចាស់ ៗ ទ្រង់ប្រារព្ធនឹងបុគ្គលណា ៗ ទ្រង់ប្រារព្ធនឹងពួកភិក្ខុច្រើនរូប ៗ ព្រោះវត្ថុអ្វី ៗ ព្រោះមនុស្សវិគ្គហៈ គឺធ្វើរាងកាយនៃមនុស្សឲ្យធ្លាក់ចុះចាកជីវិត ៗ លំដាប់នោះឯង ព្រះមហាកស្សប មានអាយុ សួរវត្ថុផង សួរនិទានផង សួរបុគ្គលផង សួរបញ្ញត្តិផង សួរអនុប្បញ្ញត្តិផង សួរអាបត្តិផង សួរអនាបត្តិផង នៃតតិយបារាជិកសិក្ខាបទ ចំពោះព្រះឧបាលិមានអាយុ ហើយសួរតទៅទៀតថា ម្នាលអាវុសោ ឧបាលិ ចតុត្ថបារាជិកសិក្ខាបទ ព្រះមានព្រះភាគទ្រង់បញ្ញត្តក្នុងទីណា ៗ ក្នុងនគរវេសាលី លោកម្ចាស់ ៗ ទ្រង់ប្រារព្ធនឹងបុគ្គលណា ៗ ទ្រង់ប្រារព្ធនឹងភិក្ខុទាំងឡាយ នៅនាឆ្នេរស្ទឹងវគ្គមុទា ៗ ព្រោះវត្ថុអ្វី ៗ ព្រោះឧត្តរិមនុស្សធម្ម ៗ លំដាប់នោះឯង ព្រះមហាកស្សបមានអាយុ សួរវត្ថុផង សួរនិទានផង សួរបុគ្គលផង សួរបញ្ញត្តិផង សួរអនុប្បញ្ញត្តិផង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាបត្តិម្បិ បុច្ឆិ អនាបត្តិម្បិ បុច្ឆិ ឯតេនេវ ឧបាយេន ឧភតោវិនយេ(១) បុច្ឆិ ។ បុដ្ឋោ បុដ្ឋោ អាយស្មា ឧបាលិ វិស្សជ្ជេសិ ។

[២៨៣] អថខោ អាយស្មា មហាកស្សបោ សង្ឃំ ញាបេសិ សុណាតុ មេ អាវុសោ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អានន្ទំ ធម្មំ បុច្ឆេយ្យន្តិ ។ អាយស្មា អានន្ទោ សង្ឃំ ញាបេសិ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អាយស្មតា មហាកស្សបេន ធម្មំ បុដ្ឋោ វិស្សជ្ជេយ្យន្តិ ។ អថខោ អាយស្មា មហាកស្សបោ អាយស្មន្តំ អានន្ទំ ឯតទវោច ព្រហ្មជាលំ អាវុសោ អានន្ទ កត្ថ ភាសិតន្តិ ។ អន្តរា ច ភន្តេ រាជគហំ អន្តរា ច នាឡន្ទំ រាជាគារកេ អម្ពលដ្ឋិកាយាតិ ។ កំ អារព្ភាតិ ។ សុប្បិយញ្ច បរិព្វាជកំ ព្រហ្មទត្តញ្ច មាណវន្តិ ។ អថខោ អាយស្មា មហាកស្សបោ អាយស្មន្តំ អានន្ទំ ព្រហ្មជាលស្ស និទានម្បិ បុច្ឆិ បុគ្គលម្បិ បុច្ឆិ

១ ម. ឧភតោវិភង្គេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សួរអាបត្តិផង សួរអនាបត្តិផង នៃចតុត្ថបារាជិកសិក្ខាបទចំពោះព្រះឧបាលិមានអាយុ ហើយសួរវិន័យទាំងពីរចំណែក គឺភិក្ខុវិន័យ និងភិក្ខុនីវិន័យ ដោយឧបាយនេះឯង ។ ព្រះឧបាលិមានអាយុ កាលបើព្រះមហាកស្សបសួរសព្វគ្រប់ហើយ ក៏បានដោះស្រាយសព្វគ្រប់ ។

[២៨៣] ឮដ៏កាលនោះ ព្រះមហាកស្សប មានអាយុ បានប្រកាសសង្ឃឲ្យដឹងថា ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ បើសង្គីតិកម្មមានកាលគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរនូវធម៌ចំពោះព្រះអានន្ទ ។ ព្រះអានន្ទមានអាយុ បានប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើសង្គីតិកម្មមានកាលគួរដល់សង្ឃហើយ ព្រះមហាកស្សបមានអាយុនឹងសួរធម៌ចំពោះខ្ញុំ ៗ គប្បីដោះស្រាយក្នុងកាលឥឡូវនេះ ។ ទើបព្រះមហាកស្សប មានអាយុបានសួរព្រះអានន្ទមានអាយុដូច្នេះថា ម្នាលអានន្ទមានអាយុ ព្រហ្មជាលសូត្រ ព្រះមានព្រះភាគទ្រង់សំដែងក្នុងទីណា ។ ព្រះអានន្ទឆ្លើយថា បពិត្រព្រះថេរៈដ៏ចំរើន ទ្រង់សំដែងក្នុងព្រះដំណាក់នៃព្រះរាជា នៅនាអម្ពលដ្ឋិកាវ័ន ជាចន្លោះនៃក្រុងរាជគ្រឹះផង ជាចន្លោះនៃនាឡន្ទគ្រាមផង ។ ទ្រង់ប្រារព្ធនឹងបុគ្គលណា ។ ទ្រង់ប្រារព្ធនឹងសុប្បិយបរិព្វាជក និងព្រហ្មទត្តមាណព ។ គ្រានោះ ព្រះមហាកស្សប មានអាយុ សួរនិទានផង សួរបុគ្គលផង នៃព្រហ្មជាលសូត្រ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សាមញ្ញផលំ បនាវុសោ អានន្ទ កត្ថ ភាសិតន្តិ ។ រាជគហេ ភន្តេ ជីវកម្ពវនេតិ ។ កេន សទ្ធិន្តិ ។ អជាតសត្តុនា វេទេហិបុត្តេន សទ្ធិន្តិ ។ អថខោ អាយស្មា មហាកស្សបោ អាយស្មន្តំ អានន្ទំ សាមញ្ញផលស្ស និទានម្បិ បុច្ឆិ បុគ្គលម្បិ បុច្ឆិ ឯតេនេវ ឧបាយេន បញ្ច(១) និកាយេ បុច្ឆិ ។ បុដ្ឋោ បុដ្ឋោ អាយស្មា អានន្ទោ វិស្សជ្ជេសិ ។

(២៨៤) អថខោ អាយស្មា អានន្ទោ ថេរេ ភិក្ខូ ឯតទវោច ភគវា មំ ភន្តេ បរិនិព្វានកាលេ ឯវមាហ អាកង្ខមានោ អានន្ទ សង្ឃោ មមច្ចយេន ខុទ្ទានុខុទ្ទកានិ សិក្ខាបទានិ សមូហនេយ្យាតិ ។ បុច្ឆិ បន ត្វំ អាវុសោ អានន្ទ ភគវន្តំ កតមានិ បន ភន្តេ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានីតិ ។ ន ខ្វាហំ ភន្តេ ភគវន្តំ

១ ម. បញ្ចបិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ចំពោះព្រះអានន្ទមានអាយុ ហើយសួរតទៅទៀតថា ម្នាលអាវុសោអានន្ទ សាមញ្ញផលសូត្រ ព្រះមានព្រះភាគទ្រង់សំដែងក្នុងទីណា ។ ក្នុងជីវកម្ពវ័ន ក្បែរក្រុងរាជគ្រឹះ លោកម្ចាស់ ។ ទ្រង់សំដែងជាមួយនឹងបុគ្គលណា ។ ទ្រង់សំដែងជាមួយនឹងព្រះបាទអជាតសត្តុរាជ វេទេហិបុត្ត ។ គ្រានោះ ព្រះមហាកស្សប មានអាយុ សួរនិទានផង សួរបុគ្គលផង នៃសាមញ្ញផលសូត្រ ចំពោះព្រះអានន្ទមានអាយុ ហើយសួរនូវនិកាយទាំង ៥ ដោយឧបាយនេះឯង ។ ឯព្រះអានន្ទមានអាយុ កាលបើព្រះមហាកស្សប សួរសព្វគ្រប់ហើយ ក៏បានដោះស្រាយដោយសព្វគ្រប់ ។

[២៨៤] លំដាប់នោះឯង ព្រះអានន្ទមានអាយុ ពោលដូច្នេះនឹងភិក្ខុជាថេរៈទាំងឡាយថា បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន ព្រះមានព្រះភាគ កាលដែលទៀបនឹងបរិនិព្វាន បានមានព្រះបន្ទូលយ៉ាងនេះនឹងខ្ញុំព្រះករុណាថា នែអានន្ទ លុះអំណើះតទៅអំពីតថាគតទៅហើយ បើសង្ឃមានប្រាថ្នានឹងដក ក៏គប្បីដកនូវសិក្ខាបទទាំងឡាយតូច ៗ ដោយលំដាប់ (បេញខ្វះក៏បាន) ។ ព្រះថេរៈទាំងឡាយ សួរព្រះអានន្ទថា ម្នាលអានន្ទមានអាយុ ចុះលោកម្ចាស់ បានទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ឯសិក្ខាបទទាំងឡាយតូច ៗ ដោយលំដាប់នោះ តើសិក្ខាបទណាខ្លះ ដូច្នេះដែរឬ ។ ព្រះអានន្ទឆ្លើយថា បពិត្រព្រះករុណា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



បុច្ឆិ កតមានិ បន ភន្តេ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានីតិ ។ ឯកច្ចេ ថេរា ឯវមាហំសុ ចត្តារិ បារាជិកានិ ឋបេត្វា អវសេសានិ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានីតិ ។ ឯកច្ចេ ថេរា ឯវមាហំសុ ចត្តារិ បារាជិកានិ ឋបេត្វា តេរស សង្ឃាទិសេសេ ឋបេត្វា អវសេសានិ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានីតិ ។ ឯកច្ចេ ថេរា ឯវមាហំសុ ចត្តារិ បារាជិកានិ ឋបេត្វា តេរស សង្ឃាទិសេសេ ឋបេត្វា ទ្វេ អនិយតេ ឋបេត្វា អវសេសានិ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានីតិ ។ ឯកច្ចេ ថេរា ឯវមាហំសុ ចត្តារិ បារាជិកានិ ឋបេត្វា តេរស សង្ឃាទិសេសេ ឋបេត្វា ទ្វេ អនិយតេ ឋបេត្វា តឹស និស្សគ្គិយេ បាចិត្តិយេ ឋបេត្វា អវសេសានិ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានីតិ ។ ឯកច្ចេ ថេរា ឯវមាហំសុ ចត្តារិ បារាជិកានិ ឋបេត្វា តេរស សង្ឃាទិសេសេ ឋបេត្វា ទ្វេ អនិយតេ ឋបេត្វា តឹស និស្សគ្គិយេ បាចិត្តិយេ ឋបេត្វា ទ្វេនវុតិ បាចិត្តិយេ ឋបេត្វា អវសេសានិ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានីតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទាំងឡាយដ៏ចំរើន ខ្ញុំព្រះករុណា មិនបានទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ឯសិក្ខាបទទាំងឡាយតូច ៗ ដោយលំដាប់នោះ តើសិក្ខាបទណាខ្លះ ដូច្នេះទេ ។ ព្រះថេរៈទាំងឡាយពួកខ្លះពោលយ៉ាងនេះថា សិក្ខាបទទាំងឡាយដែលសល់នៅក្រៅអំពីបារាជិកទាំង ៤ ឈ្មោះថា តូច ៗ ដោយលំដាប់ ។ ព្រះថេរៈទាំងឡាយពួកខ្លះពោលយ៉ាងនេះថា សិក្ខាបទទាំងឡាយដែលសល់នៅក្រៅអំពីបារាជិក ៤ នឹងសង្ឃាទិសេស ១៣ ឈ្មោះថាតូច ៗ ដោយលំដាប់ ។ ព្រះថេរៈទាំងឡាយពួកខ្លះពោលយ៉ាងនេះថា សិក្ខាបទទាំងឡាយដែលសល់នៅក្រៅអំពីបារាជិក ៤ សង្ឃាទិសេស ១៣ នឹងអនិយត ២ ឈ្មោះថា តូចៗ ដោយលំដាប់ ។ ព្រះថេរៈទាំងឡាយពួកខ្លះពោលយ៉ាងនេះថា សិក្ខាបទទាំងឡាយដែលសល់នៅក្រៅអំពីបារាជិក ៤ សង្ឃាទិសេល ១៣ អនិយត ២ នឹងនិស្សគ្គិយបាចិត្តិយៈ ៣០ ឈ្មោះថាតូច ៗ ដោយលំដាប់ ។ ព្រះថេរៈទាំងឡាយពួកខ្លះ ពោលយ៉ាងនេះថា សិក្ខាបទទាំងឡាយដែលសល់នៅក្រៅអំពីបារាជិក ៤ សង្ឃាទិសេស ១៣ អនិយត ២ និស្សគ្គិយបាចិត្តិយៈ៣០ នឹងសុទ្ធិកបាចិត្តិយៈ ៩២ ឈ្មោះថា តូចៗ ដោយលំដាប់ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



ឯកច្ចេ ថេរា ឯវមាហំសុ ចត្តារិ បារាជិកានិ ឋបេត្វា តេរស សង្ឃាទិសេសេ ឋបេត្វា ទ្វេ អនិយតេ ឋបេត្វា តឹស និស្សគ្គិយេ បាចិត្តិយេ ឋបេត្វា ទ្វេនវុតិ បាចិត្តិយេ ឋបេត្វា ចត្តារោ បាដិទេសនីយេ ឋបេត្វា អវសេសានិ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានីតិ ។

[២៨៩] អថខោ អាយស្មា មហាកស្សបោ សង្ឃំ ញាបេសិ សុណាតុ មេ អាវុសោ សង្ឃោ សន្តម្ហាកំ សិក្ខាបទានិ គិហិគតានិ គិហិនោបិ ជានន្តិ(១) ឥទំ វោ សមណានំ សក្យបុត្តិយានំ កប្បតិ ឥទំ វោ ន កប្បតីតិ ។ សចេ មយំ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានិ សមូហនិស្សាម ភវិស្សន្តិ វត្តារោ ធូមកាលិកំ សមណេន គោតមេន សាវកានំ សិក្ខាបទំ បញ្ញត្តំ យាវមេសំ សត្ថា អដ្ឋាសិ តាវិមេ សិក្ខាបទេសុ សិក្ខឹសុ យតោ ឥមេសំ សត្ថា បរិនិព្វុតោ ន ទានិមេ សិក្ខាបទេសុ សិក្ខន្តីតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ

---

១ ម. បោត្ថកេ គិហីបិ នោ ជានន្តីតិ បាឋោ អាគតោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បញ្ចសតិកក្ខន្ធកៈ ពោលអំពីសិក្ខាបទតូចនិងតូចដោយលំដាប់

ព្រះថេរៈទាំងឡាយពួកខ្លះ ពោលយ៉ាងនេះថា សិក្ខាបទទាំងឡាយដែលសល់នៅក្រៅអំពីបារាជិក ៤ សង្ឃាទិសេស ១៣ អនិយត ២ និស្សគ្គិយបាចិត្តិយៈ ៣០ សុទ្ធិកបាចិត្តិយៈ ៩២ និងបាដិទេសនីយៈ ៤ ឈ្មោះថាតូច ៗ ដោយលំដាប់ ។

(២៨៥) គ្រានោះឯង ព្រះមហាកស្សបមានអាយុ ក៏ប្រកាសសង្ឃថា ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ សិក្ខាបទទាំងឡាយរបស់ពួកយើង ក៏មានតាំងនៅក្នុងពួកគ្រហស្ថ សូម្បីពួកគ្រហស្ថទាំងឡាយ ក៏តែងដឹងថា អំពើនេះគួរដល់លោកទាំងឡាយជាសមណសក្យបុត្តិយ៍ អំពើនេះមិនគួរដល់លោកទាំងឡាយទេ ។ បើយើងទាំងឡាយនឹងដកនូវសិក្ខាបទតូចៗដោយលំដាប់ចេញហើយ មុខជាជនទាំងឡាយជាអ្នកពោលតិះដៀលនឹងពោលថា សិក្ខាបទដែលព្រះសមណគោតម បញ្ញត្តហើយដល់សាវ័កទាំងឡាយ បានតែត្រឹមធូមកាលិក គឺកាលនៃផ្សែងភ្លើងគឺបរិនិព្វានប៉ុណ្ណោះ ព្រះសាស្តារបស់សាវ័កទាំងឡាយនេះ ឋិតនៅត្រឹមណា សាវ័កទាំងនេះនាំគ្នាសិក្សាក្នុងសិក្ខាបទត្រឹមនោះ កាលណាបើព្រះសាស្តារបស់សាវ័កទាំងនេះបរិនិព្វានហើយ ឥឡូវនេះ សាវ័កទាំងនេះ ក៏លែងសិក្សាក្នុងសិក្ខាបទទាំងឡាយដែរ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អប្បញ្ញត្តំ ន បញ្ញាបេយ្យ បញ្ញត្តំ ន សមុច្ឆិន្ទេយ្យ យថាបញ្ញត្តេសុ សិក្ខាបទេសុ សមាទាយ វត្តេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ អាវុសោ សង្ឃោ សន្តម្ហាកំ សិក្ខាបទានិ គិហិគតានិ គិហិនោបិ ជានន្តិ ឥទំ វោ សមណានំ សក្យបុត្តិយានំ កប្បតិ ឥទំ វោ ន កប្បតីតិ ។ សចេ មយំ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានិ សមូហនិស្សាម ភវិស្សន្តិ វត្តារោ ធូមកាលិកំ សមណេន គោតមេន សាវកានំ សិក្ខាបទំ បញ្ញត្តំ យាវិមេសំ សត្ថា អដ្ឋាសិ តាវិមេ សិក្ខាបទេសុ សិក្ខឹសុ យតោ ឥមេសំ សត្ថា បរិនិព្វុតោ ន ទានិមេ សិក្ខាបទេសុ សិក្ខន្តីតិ ។ សង្ឃោ អប្បញ្ញត្តំ ន បញ្ញាបេតិ បញ្ញត្តំ ន សមុច្ឆិន្ទតិ យថាបញ្ញត្តេសុ សិក្ខាបទេសុ សមាទាយ វត្តតិ ។ យស្សាយស្មតោ ខមតិ អប្បញ្ញត្តស្ស អប្បញ្ញាបនា បញ្ញត្តស្ស អសមុច្ឆេទោ យថាបញ្ញត្តេសុ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កុំគប្បីបញ្ញត្តថែមនូវសិក្ខាបទ ដែលព្រះជាគ្រូមិនបានបញ្ញត្តទេ កុំគប្បីដកចេញនូវសិក្ខាបទ ដែលព្រះជាគ្រូបញ្ញត្តមកហើយ ត្រូវសមាទានប្រព្រឹត្តតែក្នុងសិក្ខាបទទាំងឡាយដែលព្រះជាគ្រូទ្រង់បញ្ញត្តហើយ ។ នេះជាញត្តិ ។ ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ សិក្ខាបទទាំងឡាយរបស់ពួកយើងក៏មានតាំងនៅក្នុងពួកគ្រហស្ថ សូម្បីពួកគ្រហស្ថទាំងឡាយតែងដឹងថា អំពើនេះគួរដល់លោកទាំងឡាយជាសមណសក្យបុត្តិយ៍ អំពើនេះមិនគួរដល់លោកទាំងឡាយទេ ។ បើយើងទាំងឡាយនឹងដកនូវសិក្ខាបទតូច ៗ ដោយលំដាប់ចេញហើយ មុខជាជនទាំងឡាយជាអ្នកពោលតិះដៀលនឹងពោលថា សិក្ខាបទដែលព្រះសមណគោតមបានបញ្ញត្តដល់ពួកសាវ័កបានត្រឹមតែធូមកាលិក គឺកាលនៃផ្សែងភ្លើងប៉ុណ្ណោះ ព្រះសាស្តារបស់សាវ័កទាំងនេះឋិតនៅត្រឹមណា សាវ័កទាំងនេះ ក៏នាំគ្នាសិក្សាក្នុងសិក្ខាបទត្រឹមនោះ កាលបើព្រះសាស្តារបស់សាវ័កទាំងនេះ បរិនិព្វានទៅហើយ ឥឡូវសាវ័កទាំងនេះ ក៏លែងសិក្សាក្នុងសិក្ខាបទទាំងឡាយដែរ ។ សង្ឃមិនបញ្ញត្តថែមនូវសិក្ខាបទដែលព្រះជាគ្រូមិនបានបញ្ញត្តទេ មិនដកចេញនូវសិក្ខាបទ ដែលព្រះជាគ្រូបានបញ្ញត្តហើយ សមាទានប្រព្រឹត្តតែក្នុងសិក្ខាបទទាំងឡាយដែលគួរដល់ពុទ្ធប្បញ្ញត្តិ ។ ការមិនបញ្ញត្តថែមនូវសិក្ខាបទដែលព្រះអង្គមិនបានបញ្ញត្ត ការមិនដកចេញនូវសិក្ខាបទដែលព្រះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សិក្ខាបទេសុ សមាទាយ វត្តធា សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សង្ឃោ អប្បញ្ញត្តំ ន បញ្ញាបេតិ បញ្ញត្តំ ន សមុច្ឆិន្ទតិ យថាបញ្ញត្តេសុ សិក្ខាបទេសុ សមាទាយ វត្តតិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[២៨៦] អថខោ ថេរា ភិក្ខូ អាយស្មន្តំ អានន្ទំ ឯតទវោចុំ ឥទន្តេ អាវុសោ អានន្ទ ទុក្កដំ យំ ត្វំ ភគវន្តំ ន បុច្ឆិ កតមានិ បន ភន្តេ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានីតិ ទេសេហិ តំ ទុក្កដន្តិ ។ អហំ ខោ ភន្តេ អស្សតិយា ភគវន្តំ ន បុច្ឆិ កតមានិ[១] ភន្តេ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានីតិ នាហំ តំ ទុក្កដំ បស្សាមិ

១ ឱ. ម. កតមានិ បន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អង្គទ្រង់បញ្ញត្ត ការសមាទានប្រព្រឹត្តតែក្នុងសិក្ខាបទទាំងឡាយ ដែលគួរដល់ពុទ្ធប្បញ្ញត្តិ គាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះគប្បីពោលឡើង ។ សង្ឃមិនបានបញ្ញត្តថែមនូវសិក្ខាបទដែលព្រះអង្គមិនបានបញ្ញត្ត មិនដកចេញនូវសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្ត សមាទានប្រព្រឹត្តតែក្នុងសិក្ខាបទទាំងឡាយ ដែលគួរដល់ពុទ្ធប្បញ្ញត្តិ ។ ការមិនបញ្ញត្តិនឹងការមិនដកនូវសិក្ខាបទនេះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវសេចក្តីនេះ ដោយការស្ងៀមយ៉ាងនេះ ។

(២៨៦) លំដាប់នោះឯង ភិក្ខុជាថេរៈទាំងឡាយ ពោលដូច្នេះនឹងព្រះអានន្ទមានអាយុថា នែអាវុសោ អានន្ទ នេះជាអំពើអាក្រក់របស់លោក ព្រោះលោកមិនបានទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ឯសិក្ខាបទទាំងឡាយដែលតូច ៗ ដោយលំដាប់ គឺសិក្ខាបទណាខ្លះ ចូរលោកសំដែងនូវអំពើអាក្រក់នោះចេញ ។ ព្រះអានន្ទឆ្លើយថា បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណាភ្លេច បានជាមិនបានទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ឯសិក្ខាបទទាំងឡាយតូច ៗ ដោយលំដាប់គឺសិក្ខាបទណាខ្លះ ខ្ញុំព្រះករុណាមិនឃើញនូវអំពើអាក្រក់នោះទេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អបិចាយស្មន្តានំ សទ្ធាយ ទេសេមិ តំ ទុក្កដន្តិ ។ ឥទម្បិ តេ អាវុសោ អានន្ទ ទុក្កដំ យំ ត្វំ ភគវតោ វស្សិកសាដិកំ អក្កមិត្វា សិព្វេសិ ទេសេហិ តំ ទុក្កដន្តិ ។ អហំ ខោ ភន្តេ ន អគារវេន ភគវតោ វស្សិកសាដិកំ អក្កមិត្វា សិព្វេសឹ នាហន្តំ ទុក្កដំ បស្សាមិ អបិចាយស្មន្តានំ សទ្ធាយ ទេសេមិ តំ ទុក្កដន្តិ ។ ឥទម្បិ តេ អាវុសោ អានន្ទ ទុក្កដំ យំ ត្វំ មាតុគាមេហិ ភគវតោ សរីរំ បឋមំ វន្ទាបេសិ តាសំ រោទន្តីនំ ភគវតោ សរីរំ អស្សុកេន មក្ខិតំ ទេសេហិ តំ ទុក្កដន្តិ ។ អហំ ខោ ភន្តេ មាយិមា វិកាលេ អហេសុន្តិ មាតុគាមេហិ ភគវតោ សរីរំ បឋមំ វន្ទាបេសឹ នាហន្តំ ទុក្កដំ បស្សាមិ អបិចាយស្មន្តានំ សទ្ធាយ ទេសេមិ តំ ទុក្កដន្តិ ។ ឥទម្បិ តេ អាវុសោ អានន្ទ ទុក្កដំ យំ ត្វំ ភគវតា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ប៉ុន្តែខ្ញុំព្រះករុណា សំដែងនូវអំពើអាក្រក់នោះចេញ ដោយសេចក្តីជឿលោកមានអាយុទាំងឡាយ ។ នែអាវុសោ អានន្ទ នេះជាអំពើអាក្រក់របស់លោកដែរ ព្រោះលោកដាន់ដេរសំពត់វស្សិកសាដក របស់ព្រះមានព្រះភាគ ចូរលោកសំដែងអំពើអាក្រក់នោះចេញ ។ បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណាដែលដាន់ដេរសំពត់វស្សិកសាដក របស់ព្រះមានព្រះភាគ មិនមែនធ្វើដោយសេចក្តីមិនគោរពទេ ខ្ញុំព្រះករុណាមិនឃើញនូវអំពើអាក្រក់នោះឡើយ ប៉ុន្តែខ្ញុំព្រះករុណា សំដែងនូវអំពើអាក្រក់នោះចេញ ដោយសេចក្តីជឿលោកមានអាយុទាំងឡាយ ។ ម្នាលអានន្ទមានអាយុ នេះជាអំពើអាក្រក់របស់លោកដែរ ព្រោះលោកឲ្យមាតុគ្រាមថ្វាយបង្គំព្រះសរីរៈនៃព្រះមានព្រះភាគមុនគេ កាលដែលមាតុគ្រាមទាំងនោះ យំទួញសោកធ្វើសរីរៈនៃព្រះមានព្រះភាគ ឲ្យប្រឡាក់ដោយទឹកភ្នែក ចូរលោកសំដែងនូវអំពើអាក្រក់នោះចេញ ។ បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណាគិតថា កុំឲ្យពួកមាតុគ្រាមនេះនៅក្នុងវេលាវិកាល បានជាខ្ញុំព្រះករុណាឲ្យពួកមាតុគ្រាមថ្វាយបង្គំព្រះសរីរៈនៃព្រះមានព្រះភាគមុនគេ ខ្ញុំព្រះករុណាមិនឃើញអំពើអាក្រក់នោះទេ ប៉ុន្តែខ្ញុំព្រះករុណាសំដែងអំពើអាក្រក់នោះចេញ ដោយសេចក្តីជឿលោកមានអាយុទាំងឡាយ ។ ម្នាលអានន្ទមានអាយុ នេះជាអំពើអាក្រក់របស់លោកដែរ ព្រោះព្រះមានព្រះភាគ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បញ្ចសតិកក្ខន្ធកេ មារេន បរិយុដ្ឋិតចិត្តោ

ឱឡារិកេ និមិត្តេ ការិយមានេ ឱឡារិកេ ឱភាសេ ការិយមានេ ន ភគវន្តំ យាចិ តិដ្ឋតុ ភគវា កប្បំ តិដ្ឋតុ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ទេសេហិ តំ ទុក្កដន្តិ ។ អហំ ខោ ភន្តេ មារេន បរិយុដ្ឋិតចិត្តោ ន ភគវន្តំ យាចឹ តិដ្ឋតុ ភគវា កប្បំ តិដ្ឋតុ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ នាហន្តំ ទុក្កដំ បស្សាមិ អបិចាយស្មន្តានំ សទ្ធាយ ទេសេមិ តំ ទុក្កដន្តិ ។ ឥទម្បិ តេ អាវុសោ អានន្ទ ទុក្កដំ យំ ត្វំ មាតុគាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ បព្វជ្ជំ ឧស្សុក្កំ អកាសិ ទេសេហិ តំ ទុក្កដន្តិ ។ អហំ ខោ ភន្តេ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បញ្ចសតិកក្ខន្ធកៈ (ព្រះអានន្ទ) ត្រូវមារគ្របដណ្តប់ចិត្ត

កំពុងធ្វើនិមិត្តជាឧឡារិក (បញ្ចិតបញ្ចៀង) និងធ្វើនូវឱកាស (បំភឺហេតុ) ជាឧឡារិក លោកមិនបានអារាធនាព្រះមានព្រះភាគថា សូមព្រះមានព្រះភាគគង់នៅអស់មួយកប្ប (កំណត់អាយុ)ទៅ សូមព្រះសុគតគង់នៅអស់មួយកប្បទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានឹងមនុស្សទាំងឡាយ ចូរលោកសំដែងនូវអំពើអាក្រក់នោះចេញ ។ បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណាមានមារគ្របដណ្តប់ចិត្ត បានជាមិនអារាធនានិមន្តព្រះមានព្រះភាគថា សូមព្រះមានព្រះភាគគង់នៅ អស់មួយអាយុកប្បទៅ សូមព្រះសុគតគង់នៅអស់មួយអាយុកប្បទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានឹងមនុស្សទាំងឡាយ ខ្ញុំព្រះករុណាមិនឃើញនូវអំពើអាក្រក់នោះទេ ប៉ុន្តែខ្ញុំព្រះករុណា សំដែងនូវអំពើអាក្រក់នោះចេញដោយសេចក្តីជឿលោកមានអាយុទាំងឡាយ ។ ម្នាលអានន្ទមានអាយុ នេះជាអំពើអាក្រក់របស់លោកដែរ ព្រោះលោកធ្វើសេចក្តីខ្វល់ខ្វាយឲ្យមាតុគ្រាម បានបព្វជ្ជាក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ប្រកាសហើយ ចូរលោកសំដែងនូវអំពើអាក្រក់នោះចេញ ។ បពិត្រលោកដ៏ចំរើន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អយំ មហាបជាបតី គោតមី ភគវតោ មាតុច្ឆា អាបា-ទិកា បោសិកា ខីរស្ស ទាយិកា ភគវន្តំ ជនេត្តិយា កាលង្កតាយ ថញ្ញំ បាយេសិ មាតុគាមស្ស តថា-គតប្បវេទិតេ ធម្មវិនយេ បព្វជ្ជំ ឧស្សុក្កំ អកាសិ តា-ហន្តំ ទុក្កដំ បស្សាមិ អបិចាយស្មន្តានំ សទ្ធាយ ទេសេមិ តំ ទុក្កដន្តិ ។

[២៨៧] តេន ខោ បន សមយេន អាយស្មា បុរា-ណោ ទក្ខិណាគិរិស្មឹ ចារិកំ ចរតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ។ អថខោ អាយស្មា បុរាណោ ថេរេហិ ភិក្ខូហិ ធម្មេ ច វិនយេ ច សង្គីតេ ទក្ខិណាគិរិស្មឹ យថាភិរន្តំ វិហរិត្វា យេន រាជគហំ វេ-ឡុវនំ កលន្ទកនិវាបោ យេន ថេរា ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា ថេរេហិ ភិក្ខូហិ សទ្ធឹ បដិសម្មោទិត្វា ឯ-កមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ បុ-រាណំ ថេរា ភិក្ខូ ឯតទវោចុំ ថេរេហិ អាវុសោ បុរាណ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខ្ញុំព្រះករុណាគិតថា ព្រះនាងមហាបជាបតីគោតមីនេះ ជាព្រះមាតុច្ឆា (ម្តាយមីង) នៃព្រះមានព្រះភាគ បានបីបាច់រក្សាចិញ្ចឹមថ្វាយទឹកខ្សីរ កាលដែល (ព្រះនាងមាយាទេវី) ជាព្រះមាតាបង្កើត របស់ព្រះមានព្រះភាគ ធ្វើមរណកាលទៅហើយ បានបំបៅព្រះមានព្រះភាគផង បានជាខ្ញុំធ្វើនូវសេចក្តីខ្វល់ខ្វាយឲ្យមាតុគ្រាមបានបព្វជ្ជា ក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់ប្រកាសហើយ ខ្ញុំព្រះករុណាមិនឃើញនូវអំពើអាក្រក់នោះទេ ប៉ុន្តែខ្ញុំព្រះករុណា សំដែងនូវអំពើអាក្រក់នោះចេញ ដោយសេចក្តីជឿលោកមានអាយុទាំងឡាយ ។

[ ២៨៧ ] សម័យនោះឯង ព្រះថេរៈឈ្មោះបុរាណៈមានអាយុបាន ត្រាច់ទៅកាន់ចារិក ក្នុងទក្ខិណាគិរិជនបទ ជាមួយនឹងភិក្ខុសង្ឃជាច្រើន ចំនួន៥០០រូប ។ គ្រានោះឯង ព្រះបុរាណៈមានអាយុ កាលដែលភិក្ខុជាថេរៈទាំងឡាយសង្គាយនានូវធម្មវិន័យ បានទៅអាស្រ័យក្នុងទក្ខិណាគិរិជនបទ តាមសមគួរដល់អធ្យាស្រ័យ ហើយក៏ចូលទៅរកពួកភិក្ខុជាថេរៈ ដែលនៅក្នុងវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយរាក់ទាក់ជាមួយភិក្ខុជាថេរៈទាំងឡាយ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះបុរាណៈមានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបភិក្ខុជាថេរៈទាំងឡាយ និយាយយ៉ាងនេះថា ម្នាលបុរាណៈ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បញ្ចសតិកក្ខន្ធកេ ឆន្នស្ស ព្រហ្មទណ្ឌស្ស អាណាបនំ

ធម្មោ ច វិនយោ ច សង្គីតោ ឧបេហិ តំ សង្គីតិន្តិ ។ សុសង្គីតាវុសោ ថេរេហិ ភិក្ខូហិ ធម្មោ ច វិនយោ ច អបិច យថេវ មយា ភគវតោ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ តថេវាហំ ធារេស្សាមីតិ ។

(២៨៨) អថខោ អាយស្មា អានន្ទោ ថេរេ ភិក្ខូ ឯតទវោច ភគវា មំ ភន្តេ បរិនិព្វានកាលេ ឯវមាហ តេនហានន្ទ សង្ឃោ មមច្ចយេន ឆន្នស្ស ភិក្ខុនោ ព្រហ្មទណ្ឌំ អាណាបេតូតិ ។ បុច្ឆិ បន ត្វំ អាវុសោ អានន្ទ ភគវន្តំ កតមោ បន ភន្តេ ព្រហ្មទណ្ឌោតិ ។ បុច្ឆឹ ខោ អហំ ភន្តេ ភគវន្តំ កតមោ បន ភន្តេ ព្រហ្មទណ្ឌោតិ ។ ឆន្នោ អានន្ទ ភិក្ខុ យំ ឥច្ឆេយ្យ តំ វទេយ្យ ភិក្ខូហិ ឆន្នោ ភិក្ខុ នេវ វត្តព្វោ ន ឱវទិតព្វោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដ៏មានអាយុ ធម្មិក្តី វិន័យក្តី ដែលព្រះថេរៈទាំងឡាយបានសង្គាយនា ជាស្រេចហើយ លោកចូរប្រកបនូវការសង្គាយនានោះចុះ ។ ព្រះបុរាណៈ ឆ្លើយថា ម្នាលអាវុសោទាំងឡាយ ធម្មិក្តី វិន័យក្តី ដែលភិក្ខុជាថេរៈ ទាំងឡាយបានសង្គាយនាហើយ (ក៏ជាការស្រួល) ប៉ុន្តែចំណែកខាងខ្ញុំលុះ តែបានស្តាប់ បានទទួលក្នុងទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគ យ៉ាងណាមិញ ខ្ញុំនឹងទ្រទ្រង់ (ប្រតិបត្តិ) យ៉ាងនោះឯង ។

( ៤៨៨ ) លំដាប់នោះ ព្រះអានន្ទមានអាយុពោលពាក្យជូនចំពោះទីង ភិក្ខុជាថេរៈទាំងឡាយថា បពិត្រលោកដ៏ចំរើន ព្រះមានព្រះភាគជាម្ចាស់ កាលទៀបបរិនិព្វាន ទ្រង់មានបន្ទូលយ៉ាងនេះនឹងខ្ញុំព្រះករុណាថា ម្នាល អានន្ទ ណ្ហើយចុះ អំណើះតអំពីតថាគតទៅហើយ សង្ឃចូរដាក់ព្រហ្ម ទណ្ឌដល់ឆន្នភិក្ខុផង ។ ពួកភិក្ខុជាថេរៈសួរថា ម្នាលអានន្ទមានអាយុ ចុះលោកម្ចាស់ បានទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ចុះព្រហ្មទណ្ឌនោះ តើដូចម្តេចទៅ ដែរឬ ។ ព្រះអានន្ទឆ្លើយថា បពិត្រ លោកដ៏ចំរើន ខ្ញុំព្រះករុណាបានទូលសួរព្រះមានព្រះភាគដែរថា បពិត្រ ព្រះអង្គដ៏ចំរើន ព្រហ្មទណ្ឌនោះ តើដូចម្តេចទៅ ។ ព្រះអង្គមានបន្ទូល ថា ម្នាលអានន្ទ ឆន្នភិក្ខុ ចង់ពោលពាក្យណា គប្បីពោលពាក្យនោះ ចុះ (ប៉ុន្តែ) ភិក្ខុទាំងឡាយ កុំគប្បីនិយាយរក កុំគប្បីទូន្មាន កុំគប្បី

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទានៗ



ន អនុសាសិតព្វោតិ ។ តេនហាវុសោ អានន្ទ ត្វំយេវ ឆន្នស្ស ភិក្ខុនោ ព្រហ្មទណ្ឌំ អាណាបេហីតិ ។ កថាហំ ភន្តេ ឆន្នស្ស ភិក្ខុនោ ព្រហ្មទណ្ឌំ អាណាបេមិ ចណ្ឌោ សោ ភិក្ខុ ផរុសោតិ ។ តេនហាវុសោ អានន្ទ ពហុកេហិ ភិក្ខូហិ សទ្ធឹ គច្ឆាហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ថេរានំ ភិក្ខូនំ បដិស្សុត្វា មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ នាវាយ គន្ត្វា កោសម្ពឹ ឧជ្ជវនិកាយ នាវាយ បច្ចោរោហិត្វា[១] រញ្ញោ ឧទេនស្ស ឧយ្យានស្ស អវិទូរេ អញ្ញតរស្មឹ រុក្ខមូលេ និសីទិ ។

[២៨៩] តេន ខោ បន សមយេន រាជា ឧទេនោ ឧយ្យានេ បរិចារេតិ[២] សទ្ធឹ ឱរោធេន បដិវសតិ[៣] ។ អស្សោសិ ខោ រញ្ញោ ឧទេនស្ស ឱរោធោ អម្ហាកំ កិរ អាចរិយោ អយ្យោ អានន្ទោ ឧយ្យានស្ស អវិទូរេ អញ្ញតរស្មឹ រុក្ខមូលេ និសិន្នោតិ ។ អថ ខោ រញ្ញោ ឧទេនស្ស ឱរោធោ រាជានំ ឧទេនំ ឯតទវោច

---

១ ឱ. នាវាយ ឧជ្ជវនិកាយ កោសម្ពិយា បច្ចោរោហិត្វា ។ ម. នាវាយ កោសម្ពឹ ឧជ្ជវិ នាវាយ បច្ចោរោហិត្វា ។ ២ ឱ. ម. បរិចារេសិ ។ ៣ ឱ. ម. ពោត្ថកេ បដិវសតីតិ នត្ថិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ប្រៀនប្រដៅឆន្នភិក្ខុឡើយ ។ ពួកភិក្ខុជាថេរៈពោលថា ម្នាលអានន្ទដ៏មានអាយុ បើដូច្នោះ ចូរអ្នកដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុផងចុះ ។ ព្រះអានន្ទសួរថា បពិត្រលោកដ៏ចំរើន ខ្ញុំព្រះករុណាដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុដូចម្តេចបាន (ដ្បិត) ភិក្ខុនោះកាចរឹងរូសណាស់ ។ ពួកភិក្ខុជាថេរៈពោលថា ម្នាលអានន្ទមានអាយុ បើដូច្នោះ ចូរអ្នកទៅជាមួយនឹងពួកភិក្ខុច្រើនរូបទៅចុះ ។ ឯព្រះអានន្ទមានអាយុទទួលពាក្យភិក្ខុជាថេរៈទាំងឡាយដោយពាក្យថា អើលោកម្ចាស់ ហើយក៏ជិះទូកទៅកាន់ក្រុងកោសម្ពី ជាមួយនឹងភិក្ខុសង្ឃជាច្រើនចំនួន ៥០០រូប ទូកក៏លឿនទៅប្រាសខ្សែទឹក លុះចុះចាកទូកហើយ ក៏ទៅគង់ក្រោមម្លប់ឈើមួយដើម មិនឆ្ងាយពីឧទ្យាននៃព្រះរាជាទ្រង់ព្រះនាមឧទេន ។

[៤៨៩] សម័យនោះឯង ព្រះរាជាទ្រង់ព្រះនាមឧទេនទ្រង់គង់ក្រសាលក្នុងឧទ្យានជាមួយនឹងពួកព្រះមហេសី ព្រមទាំងពួករាជបរិវារ ។ ពួកព្រះមហេសីរបស់ព្រះរាជាទ្រង់ព្រះនាមឧទេន បានឮដំណឹងថា លោកម្ចាស់អានន្ទជាអាចារ្យរបស់យើងទាំងឡាយគង់ក្រោមម្លប់ឈើមួយដើមមិនឆ្ងាយអំពីឧទ្យាន ។ ទើបពួកព្រះមហេសីរបស់ព្រះបាទឧទេន បានក្រាប

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បញ្ចសតិកក្ខន្ធកេ ឧទេនរាជវត្ថុ ឧត្តរាសង្គទានំ

អម្ហាកំ កិរ ទេវ អាចរិយោ អយ្យោ អានន្ទោ ឧយ្យានស្ស អវិទូរេ អញ្ញតរស្មឹ រុក្ខមូលេ និសិន្នោ ឥច្ឆាម មយំ ទេវ អយ្យំ អានន្ទំ បស្សិតុន្តិ ។ តេនហិ(១) សមណំ អានន្ទំ បស្សថាតិ ។ អថខោ រញ្ញោ ឧទេនស្ស ឱរោធា យេនាយស្មា អានន្ទោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នំ ខោ រញ្ញោ ឧទេនស្ស ឱរោធំ អាយស្មា អានន្ទោ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ រញ្ញោ ឧទេនស្ស ឱរោធា អាយស្មតា អានន្ទេន ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា អាយស្មតោ អានន្ទស្ស បញ្ច ឧត្តរាសង្គសតានិ ទាទាសិ ។ អថខោ រញ្ញោ ឧទេនស្ស ឱរោធា អាយស្មតោ អានន្ទស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា អាយស្មន្តំ អានន្ទំ អភិវាទេត្វា បទក្ខិណំ កត្វា យេន រាជា ឧទេនោ តេនុបសង្កមឹសុ ។

---

១ ឱ. ម. តេនហិ តុម្ហេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## បញ្ចសតិកក្ខន្ធកៈ រឿងព្រះបាទឧទេននឹងការថ្វាយសំពត់ឧត្តរាសង្គៈ

បង្គំទូលព្រះបាទឧទេនដូច្នេះថា បពិត្រព្រះសម្មតិទេព ឮថាលោកម្ចាស់អានន្ទជាអាចារ្យរបស់យើងទាំងឡាយ មកគង់នៅក្រោមម្លប់ឈើមួយដើម មិនឆ្ងាយអំពីឧទ្យាន បពិត្រព្រះសម្មតិទេព យើងខ្ញុំទាំងឡាយចង់ឃើញព្រះអានន្ទជាម្ចាស់ ។ ព្រះរាជាមានព្រះរាជឱង្ការថា បើដូច្នោះ ចូរអ្នកទាំងឡាយទៅមើលសមណៈឈ្មោះអានន្ទចុះ ។ គ្រានោះឯង ពួកព្រះមហេសីរបស់ព្រះបាទឧទេន ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះអានន្ទមានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ កាលបើពួកព្រះមហេសីនៃព្រះបាទឧទេន អង្គុយក្នុងទីសមគួរហើយ ទើបព្រះអានន្ទមានអាយុឲ្យឃើញច្បាស់ ឲ្យប្រព្រឹត្តតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ គ្រានោះឯង ពួកព្រះមហេសីនៃព្រះបាទឧទេន កាលបើព្រះអានន្ទមានអាយុ ឲ្យឃើញច្បាស់ ឲ្យប្រព្រឹត្តតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ប្រគេនសំពត់ឧត្តរាសង្គៈ៥០០ ដល់ព្រះអានន្ទមានអាយុ ។ លំដាប់នោះឯង ពួកព្រះមហេសីនៃព្រះបាទឧទេន ត្រេកអររីករាយនឹងភាសិត របស់ព្រះអានន្ទមានអាយុហើយ ទើបក្រោកចាកអាសនៈ ថ្វាយបង្គំព្រះអានន្ទមានអាយុ ធ្វើប្រទក្សិណហើយ ចូលទៅគាល់ព្រះបាទឧទេន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[២៩០] អទ្ទសា ខោ រាជា ឧទេនោ ឱរោធំ ទូរតោវ អាគច្ឆន្តំ ទិស្វាន ឱរោធំ ឯតទវោច អបិ នុ ខោ(១) តុម្ហេ សមណំ អានន្ទំ បស្សិត្ថាតិ ។ អបស្សិម្ហា ខោ មយំ ទេវ អយ្យំ អានន្ទន្តិ ។ អបិ នុ តុម្ហេ សមណស្ស អានន្ទស្ស កិញ្ចិ អទត្ថាតិ ។ អទម្ហា ខោ មយំ ទេវ អយ្យស្ស អានន្ទស្ស បញ្ច ឧត្តរាសង្គសតានីតិ ។ រាជា ឧទេនោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម សមណោ អានន្ទោ តាវពហុំ ចីវរំ បដិគ្គហេស្សតិ ទុស្សវាណិជ្ជំ វា សមណោ អានន្ទោ ករិស្សតិ បគ្គាហិកសាលំ(២) វា បសារេស្សតីតិ ។ អថ ខោ រាជា ឧទេនោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា ឧទេនោ អាយស្មន្តំ អានន្ទំ ឯតទវោច អាគមា នុ(៣) ខោ អានន្ទ

---

១ ឱ. ម. បោត្ថកេ ខោសទ្ទោ ន បញ្ញាយតិ ។ ២ បគ្គាហិកសាលំ វាតិបិ បាឋោ ទិស្សតិ ។
៣ ឱ. អាគមា នុ ខ្វិធ ។ ម. អាគមា នុ ខោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



[៦៩០] ព្រះបាទឧទេន ទ្រង់ទតឃើញពួកព្រះមហេសី មកអំពីចម្ងាយ លុះឃើញហើយមានព្រះបន្ទូលសួរពួកព្រះមហេសីដូច្នេះថា អ្នកទាំងឡាយបានឃើញសមណៈឈ្មោះអានន្ទដែរឬ ។ ពួកព្រះមហេសីក្រាបទូលថា បពិត្រព្រះសម្មតិទេព យើងខ្ញុំទាំងឡាយបានឃើញព្រះអានន្ទជាម្ចាស់ហើយ ។ ចុះអ្នកទាំងឡាយបានប្រគេនវត្ថុអ្វីបន្តិចបន្តួចដល់សមណៈឈ្មោះអានន្ទខ្លះដែរឬ ។ បពិត្រព្រះសម្មតិទេព យើងខ្ញុំទាំងឡាយបានប្រគេនសំពត់ឧត្តរាសង្គៈ ៥០០ ដល់ព្រះអានន្ទជាម្ចាស់ហើយ ។ ព្រះបាទឧទេនក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើ សមណៈឈ្មោះអានន្ទទទួលយកចីវរច្រើនដល់ម៉្លេះទេ សមណៈឈ្មោះអានន្ទនឹងធ្វើជំនួញសំពត់ឬ ។ នឹងតាំងពេងលក់សំពត់ ។ គ្រានោះឯង ព្រះបាទឧទេនស្តេចទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ សំណេះសំណាលនឹងព្រះអានន្ទមានអាយុ លុះបញ្ចប់ពាក្យដែលរីករាយនឹងពាក្យដែលគួររលឹក ល្មមឲ្យកើតសេចក្តីស្និទ្ធស្នាលហើយ ក៏គង់ក្នុងទីសមគួរ ។ លុះព្រះបាទឧទេន គង់ក្នុងទីដ៏សមគួរហើយ ក៏មានព្រះបន្ទូលនឹងព្រះអានន្ទមានអាយុ យ៉ាងនេះថា បពិត្រព្រះអានន្ទ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕





អម្ហាកំ ឱរោធោតិ ។ អាគមា ខោ តេ(១) មហារាជ ឱរោធោតិ ។ អបិច(២) បន ភោតោ អានន្ទស្ស កិញ្ចិ អទាសីតិ ។ អទាសិ ខោ មេ មហារាជ បញ្ច ឧត្តរាសង្គសតានីតិ ។ កឹ បន ភវំ អានន្ទោ តាវពហុំ ចីវរំ ករិស្សតីតិ ។ យេ តេ មហារាជ ភិក្ខូ ទុព្វលចីវរា តេហិ សទ្ធឹ សំវិភជិស្សាមីតិ ។ យានិ ខោ បន ភោ(៣) អានន្ទ បោរាណកានិ ទុព្វលចីវរានិ តានិ កឹ ករិស្សថាតិ ។ តានិ មហារាជ ឧត្តរត្ថរណំ ករិស្សាមាតិ ។ យានិ បន ភោ អានន្ទ បោរាណកានិ ឧត្តរត្ថរណានិ តានិ កឹ ករិស្សថាតិ ។ តានិ មហារាជ ភិសិច្ឆវិយោ ករិស្សាមាតិ ។ យា បន ភោ អានន្ទ បោរាណកា ភិសិច្ឆវិយោ តា កឹ ករិស្សថាតិ ។ តា មហារាជ ភុម្មត្ថរណំ ករិស្សាមាតិ ។ យានិ បន ភោ អានន្ទ បោរាណកានិ ភុម្មត្ថរណានិ តានិ កឹ ករិស្សថាតិ ។ តានិ មហារាជ បាទបុញ្ឆនិយោ ករិស្សា-

១ ឱ. តេធ ។ ម. អាគមាសិ ខោ តេ ឥធ ។ ២ ឱ. ម. បោត្ថកេសុ ឋបេត្វា ន ទិស្សតិ ។ ៣ ឱ. យានិ បន ភោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ដ៏ចំរើន ពួកព្រះមហេសីរបស់យើងបានមក (ក្នុងទីនេះ) ដែរឬ ។ ព្រះអានន្ទតបថា បពិត្រមហារាជ ពួកព្រះមហេសីនៃព្រះអង្គបានមក (ក្នុងទីនេះ) ដែរ ។ ចុះ (ពួកព្រះមហេសីនោះ) បានប្រគេនវត្ថុអ្វីបន្តិចបន្តួចដល់ព្រះអានន្ទដ៏ចំរើនខ្លះដែរឬ ។ បពិត្រមហារាជ ពួកព្រះមហេសីនោះ បានប្រគេនសំពត់ឧត្តរាសង្គៈ ៥០០ ដល់អាត្មាភាព ។ ព្រះអានន្ទដ៏ចំរើននឹងយកចីវរច្រើនដល់ម៉្លេះទៅធ្វើជាអ្វីទៅ ។ បពិត្រមហារាជ ភិក្ខុទាំងឡាយណា មានចីវរទុព្វលភាព អាត្មាភាពនឹងចែកឲ្យ ដល់ភិក្ខុទាំងឡាយនោះ ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះចីវរទាំងឡាយណាដែលចាស់ទុព្វ-លភាព លោកម្ចាស់នឹងយកចីវរទាំងនោះទៅធ្វើអ្វី ។ បពិត្រមហារាជ យើងទាំងឡាយនឹងយកចីវរទាំងនោះទៅធ្វើជាកម្រាលគ្រែ ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះកម្រាលគ្រែណាដែលជារបស់ចាស់ លោកម្ចាស់នឹងយកកម្រាលគ្រែទាំងនោះទៅធ្វើជាអ្វី ។ បពិត្រមហារាជ យើងទាំងឡាយនឹងយកកម្រាលគ្រែទាំងនោះទៅធ្វើជាស្រោមពូក ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះស្រោមពូកណា ដែលជារបស់ចាស់ លោកម្ចាស់នឹងយកស្រោមពូកទាំងនោះទៅធ្វើជាអ្វី ។ បពិត្រមហារាជ យើងទាំងឡាយនឹងយកស្រោមពូកទាំងនោះទៅធ្វើជាកម្រាលផែនដី ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះកម្រាលផែនដីណា ដែលជារបស់ចាស់ លោកម្ចាស់នឹងយក

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



មាតិ ។ យា បន ភោ អានន្ទ បោរាណកា បាទបុញ្ឆនិយោ តា កឹ ករិស្សថាតិ ។ តា មហារាជ រជោហរណំ ករិស្សាមាតិ ។ យានិ បន ភោ អានន្ទ បោរាណកានិ រជោហរណានិ តានិ កឹ ករិស្សថាតិ ។ តានិ មហារាជ កោដ្ដេត្វា ចិក្ខល្លេន មទ្ទិត្វា បរិភណ្ឌំ លិម្បិស្សាមាតិ ។ អថខោ រាជា ឧទេនោ សព្វេ ឥមេ សមណា សក្យបុត្តិយា យោនិសោ ឧបនេន្តិ ន កុលវំ គមេន្តីតិ អាយស្មតោ អានន្ទស្ស អញ្ញានិបិ បញ្ច ទុស្សសតានិ អទាសិ ។ អយញ្ចរហិ អាយស្មតោ អានន្ទស្ស បឋមំ ចីវរបរិក្ខារោ[1] ឧប្បន្នំ ចីវរសហស្សំ ។

[២៩១] អថខោ អាយស្មា អានន្ទោ យេន ឃោសិតារាមោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ អាយស្មា ឆន្នោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា

១ ឱ. ចីវរភិក្ខា ។ ម. ចីវរំ ភិក្ខុំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កម្រាលផែនដីទាំងនោះទៅធ្វើជាអ្វី ។ បពិត្រមហារាជ យើងទាំងឡាយនឹងយកកម្រាលផែនដីទាំងនោះទៅធ្វើជាសំពត់ជូតជើង ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះសំពត់សម្រាប់ជូតជើងណាដែលជារបស់ចាស់ លោកម្ចាស់នឹងយកសំពត់ជូតជើងទាំងនោះទៅធ្វើជាអ្វី ។ បពិត្រមហារាជ យើងទាំងឡាយនឹងយកសំពត់សម្រាប់ជូតជើងទាំងនោះទៅធ្វើជាសំពត់សម្រាប់ជូតធូលី ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះសំពត់សម្រាប់ជូតធូលីណាដែលជារបស់ចាស់ លោកម្ចាស់នឹងយកសំពត់សម្រាប់ជូតធូលីទាំងនោះទៅធ្វើជាអ្វី ។ បពិត្រមហារាជ យើងទាំងឡាយនឹងចិញ្ច្រាំនូវសំពត់សម្រាប់ជូតធូលីទាំងនោះ ហើយប្រចាប់លាយដោយភក់ ហើយយកទៅបូកលាបជញ្ជាំង ។ គ្រានោះឯង ព្រះបាទឧទេន ទ្រង់សព្វព្រះរាជហឫទ័យថា សមណសក្យបុត្តិយ៍ទាំងអស់នេះប្រកបដោយឧបាយនៃប្រាជ្ញា មិនធ្វើសំពត់ឲ្យដល់នូវសេចក្តីវិនាសឥតប្រយោជន៍ ហើយក៏ទ្រង់ប្រគេនសំពត់ ចំនួន ៥០០ ដទៃទៀត ដល់ព្រះអានន្ទមានអាយុ ។ បរិក្ខារ គឺចីវរ ចំនួន ១ ពាន់នេះឯង ទើបតែនឹងកើតឡើងជាដំបូងដល់ព្រះអានន្ទមានអាយុ ។

(២៩១) លំដាប់នោះឯង ព្រះអានន្ទមានអាយុ ក៏ចូលទៅកាន់ឃោសិតារាម លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលទុក ។ គ្រានោះឯង ឆន្នភិក្ខុដ៏មានអាយុ ចូលទៅរកព្រះអានន្ទមានអាយុ លុះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ ឆន្នំ អាយស្មា អានន្ទោ ឯតទវោច សង្ឃេន តេ អាវុសោ ឆន្ន ព្រហ្មទណ្ឌោ អាណត្តោតិ[១] ។ កតមោ បន ភន្តេ អានន្ទ ព្រហ្មទណ្ឌោតិ ។ ត្វំ អាវុសោ ឆន្ន ភិក្ខូ[២] យំ ឥច្ឆេយ្យាសិ តំ វទេយ្យាសិ ភិក្ខូហិ ត្វំ នេវ វត្តព្វោ ន ឱវទិតព្វោ នានុសាសិតព្វោតិ ។ នន្វាហំ ភន្តេ អានន្ទ ហតោ ឯត្តាវតា យតោហំ ភិក្ខូហិ នេវ វត្តព្វោ ន ឱវទិតព្វោ នានុសាសិតព្វោតិ តត្ថេវ មុច្ឆិតោ បបតិ[៣] ។ អថខោ អាយស្មា ឆន្នោ ព្រហ្មទណ្ឌេន អដ្ដិយមានោ ហរាយមានោ ជិគុច្ឆមានោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា

---

១ ឱ. ម. អាណាបិតោតិ ។ ២ ឱ. ភិក្ខុ ។ ៣ ម. បបតោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បញ្ចសតិកក្ខន្ធកៈ រឿងព្រះឆន្នត្ថេរនឹងការដាក់ព្រហ្មទណ្ឌដល់លោក

ចូលទៅដល់ហើយ ថ្វាយបង្គំព្រះអានន្ទមានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះឆន្នៈមានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះអានន្ទមានអាយុ ក៏និយាយយ៉ាងនេះថា នែអាវុសោ ឆន្នៈ សង្ឃដាក់ព្រហ្មទណ្ឌដល់លោកហើយ ។ ឆន្នភិក្ខុសួរថា បពិត្រព្រះអានន្ទដ៏ចំរើន ព្រហ្មទណ្ឌនោះតើដូចម្តេចទៅ ។ ព្រះអានន្ទប្រាប់ថា ម្នាលឆន្នភិក្ខុមានអាយុ លោកចង់ពោលពាក្យណា គប្បីពោលពាក្យនោះចុះ ភិក្ខុទាំងឡាយមិនត្រូវនិយាយរក មិនត្រូវទូន្មាន មិនត្រូវប្រៀនប្រដៅលោកឡើយ ។ ឆន្នភិក្ខុពោលថា បពិត្រព្រះអានន្ទដ៏ចំរើន កាលណាបើភិក្ខុទាំងឡាយមិនត្រូវនិយាយរក មិនត្រូវទូន្មាន មិនត្រូវប្រៀនប្រដៅខ្ញុំដោយហេតុប៉ុណ្ណេះ បើដូច្នោះ ភិក្ខុទាំងឡាយមិនសម្លាប់ខ្ញុំហើយឬ ហើយក៏ដួលផ្ងប់ក្នុងទីនោះ ។ គ្រានោះឯង ឆន្នៈមានអាយុក៏លំបាក អៀនខ្មាសខ្ពើមព្រហ្មទណ្ឌ ក៏ចៀសចេញទៅតែម្នាក់ឯង ហើយមិនប្រមាទ មានព្យាយាមដាស់តឿនដុតកំដៅនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន កុលបុត្តទាំងឡាយដែលចេញចាកផ្ទះហើយចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីអនុត្តរធម៌ណា ក៏បានដល់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃព្រហ្មចរិយធម៌ ដោយការធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ន ដោយមិនយូរ ហើយសម្រេចសម្រាន្តដោយឥរិយាបថទាំង ៤ ហើយដឹងច្បាស់ថា ជាតិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា ឆន្នោ អរហតំ(១) អហោសិ ។ អថខោ អាយស្មា ឆន្នោ អរហត្តំ បត្តោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតទវោច បដិប្បស្សម្ភេហិ ទានិ មេ ភន្តេ អានន្ទ ព្រហ្មទណ្ឌន្តិ ។ យទគ្គេន តយា អាវុសោ ឆន្ន អរហត្តំ សច្ឆិកតំ តទគ្គេន តេ ព្រហ្ម-ទណ្ឌោ បដិប្បស្សទ្ធោតិ ។

[២៩២] ឥមាយ ខោ បន វិនយសង្គីតិយា បញ្ច ភិក្ខុសតានិ អនូនានិ អនធិកានិ អហេសុំ ។ តស្មាយំ វិនយសង្គីតិ បញ្ចសតិកាតិ(២) វុច្ចតីតិ ។

បញ្ចសតិកក្ខន្ធកេ និដ្ឋិតំ ឯកាទសមំ ។

ឥមម្ហិ ខន្ធកេ វត្ថូ តេវីសតិ ។

---

១ ម. អរហា ។ ២ ឱ. បញ្ចសតីតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



គឺសេចក្តីកើតទៀត (របស់អាត្មាអញ) អស់ហើយ មគ្គព្រហ្មចរិយៈសម្រេចហើយ កិច្ចត្រូវធ្វើ គឺសោឡសកិច្ច ក៏សម្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតគ្មានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះឆន្នៈមានអាយុ ក៏ជាអរហន្តមួយអង្គដែរ ។ លំដាប់នោះ ព្រះឆន្នៈមានអាយុ បានដល់អរហត្តហើយ ក៏ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ពោលពាក្យនេះនឹងព្រះអានន្ទមានអាយុថា បពិត្រព្រះអានន្ទដ៏ចំរើន ឥឡូវនេះ លោកចូររម្ងាប់ព្រហ្មទណ្ឌដល់ខ្ញុំ ។ ព្រះអានន្ទពោលថា នៃឆន្នៈមានអាយុ លោកបានធ្វើឲ្យជាក់ច្បាស់ហើយនូវអរហត្ត ក្នុងកាលជាទីបំផុតណា ឯព្រហ្មទណ្ឌរបស់លោក ក៏រម្ងាប់ក្នុងកាលជាទីបំផុតនោះដែរ ។

(៦៩៦) ក្នុងការសង្គាយនាព្រះវិន័យនេះឯង មានភិក្ខុចំនួន ៥០០ រូប មិនខ្វះមិនលើស ។ ព្រោះហេតុនោះ ការសង្គាយនាព្រះវិន័យនេះ ព្រះសង្គីតិកាចារ្យ ហៅថា បញ្ចសតិកាសង្គាយនា គឺសង្គាយនារបស់ភិក្ខុមានចំនួន ៥០០ រូប ។

ចប់ បញ្ចសតិកក្ខន្ធកៈ ទី ១១ ។

ក្នុងខន្ធកៈ នេះមានរឿង ២៣ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បញ្ចសតិកក្ខន្ធកេ ឧទ្ទានគាថា

តស្សុទ្ទានំ

(២៩៣) បរិនិព្វុតេ ហិ(១) សម្ពុទ្ធេ
ថេរោ ច កស្សបវ្ហយោ(២)
អាមន្តយិ ភិក្ខុគណំ
សទ្ធម្មមនុបាលកោ
បាវាយ អទ្ធានមគ្គម្ហិ
សុភទ្ទេន បវេទិតំ
សង្គាយិស្សាម សទ្ធម្មំ
អធម្មោ បុរេ ទិប្បតិ
ឯកេកនូនបញ្ចសតំ
អានន្ទម្បិ ច ឧច្ចិនិ
ធម្មវិនយសង្គីតិ
វសន្តោ គុហមុត្តមេ
ឧបាលឹ វិនយំ បុច្ឆិ
សុត្តន្តានន្ទបណ្ឌិតំ
បិដកំ តីណិ សង្គីតំ(៣)
អកំសុ ជិនសាវកា ។

---

១ ម. បោត្ថកេ ហិសទ្ទោ ន ទិស្សតិ ។ ២ ឱ. កស្សប អវ្ហយោ ។ ម. កស្សប សវ្ហយោ ។
៣ ឱ. ម. សង្គីតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បញ្ចសតិកក្ខន្ធកៈ ឧទ្ទានគាថា

ឧទ្ទាននៃបញ្ចសតិកក្ខន្ធកៈនោះ គឺ

(៤៩៣) រឿងកាលព្រះសម្ពុទ្ធជាម្ចាស់ បរិនិព្វានទៅហើយ ព្រះថេរៈឈ្មោះកស្សប ជាអ្នកគ្រប់គ្រង រក្សាព្រះសទ្ធម្មហៅពួកភិក្ខុមកថា យើងដើរតាមផ្លូវឆ្ងាយ ពីស្រុកបាវា បាន ឮពាក្យសុភទ្ទភិក្ខុ សំដែងហើយ យើងនឹងសង្គាយនានូវព្រះសទ្ធម្ម គំណរទៅមុខ ធម៌ជាអកុសលនឹងរុងរឿងឡើង ១ រឿងព្រះមហាកស្សប ជ្រើសរើសព្រះអរហន្ត ៤៩៩ អង្គ នឹងព្រះអានន្ទមួយផង ១ រឿងព្រះកស្សប គង់នៅទៀបគុហាដ៏ឧត្តម ធ្វើសង្គាយនានូវធម៌នឹងវិន័យ ១ រឿងព្រះកស្សបសួរព្រះវិន័យនឹងព្រះឧបាលិ ១ រឿងព្រះកស្សបសួរព្រះសូត្រនឹងព្រះអានន្ទ ជាបណ្ឌិត ១ រឿងពួកជិនសាវកធ្វើសង្គាយនាបិដកទាំងបី ១ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ខុទ្ទានុខុទ្ទកា ជាជា

យថាបញ្ញត្តំវត្តនា(១) ។

ន បុច្ឆិ អក្កមិត្វាបិ

វត្ថាបេសិ ន យាចិ ច

បឋមំ មាតុគាមស្ស

សក្កាយ ទុក្កដានិ មេ ។

បុរាណោ ព្រហ្មទណ្ឌំ ច

ឱរោធោ ឧទេនេន សហ

---

១ ឱ. យថាបញ្ញត្តឹ វត្តនា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



រឿងព្រះអានន្ទ ទូលព្រះថេរៈទាំងឡាយថា កាលព្រះមានព្រះភាគ ជិតបរិនិព្វានទ្រង់មានបន្ទូលថា បើសង្ឃប្រាថ្នានឹងដកសិក្ខាបទ ក៏គប្បីដកសិក្ខាបទតូច ៗ ដោយលំដាប់ដទៃ ៗ បាន ១ រឿងព្រះកស្សបបានសូត្រប្រកាសប្រាប់សង្ឃថា ត្រូវឲ្យភិក្ខុប្រព្រឹត្តតាមសិក្ខាបទដែលគួរដល់ពុទ្ធប្បញ្ញត្តិ ១ ។ រឿងព្រះថេរៈទាំងឡាយ បន្ទោសព្រះអានន្ទថា មិនទូលសួរព្រះមានព្រះភាគក្នុងសិក្ខាបទតូច ៗ ដោយលំដាប់នោះ ១ រឿងព្រះថេរៈទាំងឡាយបន្ទោសព្រះអានន្ទថា ជាន់សំពត់វស្សិក-សាដករបស់ព្រះមានព្រះភាគហើយដេរ ១ រឿងព្រះថេរៈទាំងឡាយបន្ទោសព្រះអានន្ទថា ឲ្យមាតុគ្រាមថ្វាយបង្គំសរីរៈព្រះមានព្រះភាគមុនគេ ១ រឿងព្រះថេរៈទាំងឡាយបន្ទោសព្រះអានន្ទថា មិនអារាធនាព្រះមានព្រះភាគឲ្យគង់នៅអស់អាយុ-កប្ប១ រឿងព្រះថេរៈទាំងឡាយបន្ទោសព្រះអានន្ទថា សូមបព្វជ្ជាដល់មាតុគ្រាម ១ រឿងព្រះអានន្ទទទួលថាអំពើអាក្រក់របស់ខ្ញុំគ្មានទេ ខ្ញុំទទួលដោយសេចក្តីជឿលោកម្ចាស់ទាំងឡាយ ១ ។ រឿងបុរាណត្ថេរ ១ រឿងដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុ ១ រឿងពួកព្រះមហេសីនៅក្នុងឧទ្យាន ជាមួយនឹងព្រះបាទឧទេន ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បញ្ចសតិកក្ខន្ធកេ ឧទ្ទានគាថា

តាវពហុ ទុព្ពលញ្ច

ឧត្តរត្ថរណា កិសិ

ភុម្មត្ថរណា បុញ្ឆនិយោ

រជោ ចិក្ខល្លមទ្ទនា

សហស្សចីវរំ ឧប្បជ្ជិ

បឋមានន្ទស្សវ្ហយា ។

តជ្ជិតោ ព្រហ្មទណ្ឌេន

ចតុសច្ចំ អបាបុណិ ។

វសីភូតា បញ្ចសតា

តស្មា បញ្ចសតា ឥតីតិ[១] ។

---

១ ឱ. ម. បញ្ចសតីតិ ឥតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## បញ្ចសតិកក្ខន្ធកៈ ឧទ្ទានគាថា

រឿងព្រះបាទឧទេន ពោលទោសព្រះអានន្ទថា ទទួលចីវរច្រើនដល់ម្ល៉ោះ ១ រឿងព្រះបាទឧទេន សួរព្រះអានន្ទអំពីចីវរទុព្វលភាព១ រឿងព្រះអានន្ទឆ្លើយថា ចីវរទុព្វលភាពនោះយកទៅធ្វើជាកម្រាលគ្រែ ជាស្រោមពូក ជាកម្រាលផែនដី ជាសំពត់ជូតជើង ជាសំពត់ជូតធូលីទាំងលាយដោយកក់បុកលាបជញ្ជាំង ១ រឿងចីវរមួយពាន់ កើតឡើងដល់ព្រះអានន្ទជាដំបូង ១ ។ រឿងឆន្នភិក្ខុ ដែលសង្ឃដាក់ទោស ដោយព្រហ្មទណ្ឌ ហើយបានត្រាស់ដឹងនូវសច្ចៈទាំងបួន ១ ។ រឿងព្រះថេរៈជាអ្នកស្ទាត់ជំនាញចំនួន ៥០០ អង្គ ក្នុងការសង្គាយនាធម៌និងវិន័យ ព្រោះហេតុនោះ ការសង្គាយនានោះឈ្មោះថា បញ្ចសតិកសង្គាយនា ១ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# សត្តសតិកក្ខន្ធកំ

[២៩៨] តេន ខោ បន សមយេន វស្សសតបរិនិព្វុតេ ភគវតិ វេសាលិកា វជ្ជីបុត្តកា ភិក្ខូ វេសាលិយំ ទស វត្ថូនិ ទីបេន្តិ កប្បតិ សិង្គិលោណកប្បោ កប្បតិ ទ្វង្គុលកប្បោ កប្បតិ គាមន្តរកប្បោ កប្បតិ អាវាសកប្បោ កប្បតិ អនុមតិកប្បោ កប្បតិ អាចិណ្ណកប្បោ កប្បតិ អមថិតកប្បោ កប្បតិ ជលោគឹ(១) បាតុំ កប្បតិ អទសកំ និសីទនំ កប្បតិ ជាតរូបរជតន្តិ ។

[២៩៩] តេន ខោ បន សមយេន អាយស្មា យសោ កាកណ្ឌកបុត្តោ វជ្ជីសុ ចារិកញ្ចរមានោ យេន វេសាលី តទវសរិ ។ តត្រ សុទំ អាយស្មា យសោ កាកណ្ឌកបុត្តោ វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។

---

១ ឱ. ជលោគិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# សត្តសតិកក្ខន្ធកៈ

[៤៤៨] សម័យនោះឯង កាលព្រះមានព្រះភាគទ្រង់បរិនិព្វានទៅបាន ១០០ ឆ្នាំ ពួកវជ្ជីបុត្តកភិក្ខុ(១) នៅក្នុងក្រុងវេសាលី សំដែងវត្ថុ១០ ប្រការ ក្នុងក្រុងវេសាលីថា ការកំណត់ដោយអម្បិលក្នុងស្នែង គួរ (ដល់សមណៈ)១ ការកំណត់ដោយស្រមោលព្រះអាទិត្យជ្រេទៅ ប្រមាណពីរធ្នាប់ គួរ ១ ការកំណត់ដោយចន្លោះស្រុក គួរ ១ ការកំណត់ដោយអាវាស គួរ១ ការកំណត់ដោយអនុមតិ(២) គួរ១ ការកំណត់ដោយអាចិណ្ណកប្ប(ប្រពៃណី)គួរ ១ ការកំណត់ដោយទឹកដោះដែលមិនទាន់ជូរ គួរ ១ ការផឹកនូវសុរាឆៅ គួរ ១ និសីទនៈដែលមិនមានជាយ គួរ ១ មាសនឹងប្រាក់ គួរ១ ។

[៤៤៩] សម័យនោះឯង ព្រះយសកាកណ្ឌកបុត្ត(៣) មានអាយុ ត្រាច់ទៅកាន់ចារិកក្នុងដែនវជ្ជី ហើយក៏បានទៅដល់ក្រុងវេសាលី ។ បានឮថា ព្រះយសកាកណ្ឌកបុត្ត មានអាយុ នៅក្នុងកូដាគារសាលា ព្រៃមហាវ័ន ជិតក្រុងវេសាលីនោះ ។

---

១ ពួកភិក្ខុជាបុត្តនៃជនដែលនៅក្នុងដែនវជ្ជី បានជាហៅដោយរូបរួមថា វជ្ជីបុត្តកភិក្ខុ ។
២ ប្រែថា យល់ព្រម ថា ត្រេកអរ ។ ៣ ព្រះយសត្ថេរ ជាបុត្តនៃព្រាហ្មណ៍ឈ្មោះកាកណ្ឌកៈ ហៅដោយរូបរួមថា យសកាកណ្ឌកបុត្ត ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកេ វជ្ជិបុត្តកភិក្ខុវត្ថុ យសត្ថេរវត្ថុ

[២៩៦] តេន ខោ បន សមយេន វេសាលិកា វជ្ជិបុត្តកា ភិក្ខូ តទហុបោសថេ កំសចាដឹ[១] ឧទកេន បូរេត្វា មជ្ឈេ ភិក្ខុសង្ឃស្ស ឋបេត្វា អាគតាគតេ[២] វេសាលិកេ ឧបាសកេ ឯវំ វទេន្តិ ទេថាវុសោ សង្ឃស្ស កហាបណម្បិ អឌ្ឍម្បិ បាទម្បិ មាសករូបម្បិ ភវិស្សតិ សង្ឃស្ស បរិក្ខារេន ករណីយន្តិ ។ ឯវំ វុត្តេ អាយស្មា យសោ កាកណ្ឌកបុត្តោ វេសាលិកេ ឧបាសកេ ឯតទវោច មា អាវុសោ អទត្ថ សង្ឃស្ស កហាបណម្បិ អឌ្ឍម្បិ បាទម្បិ មាសករូបម្បិ ន កប្បតិ សមណានំ សក្យបុត្តិយានំ ជាតរូបរជតំ ន សាទិយន្តិ សមណា សក្យបុត្តិយា ជាតរូបរជតំ នប្បដិគ្គណ្ហន្តិ សមណា សក្យបុត្តិយា ជាតរូបរជតំ និក្ខិត្តមណិសុវណ្ណា សមណា សក្យបុត្តិយា អបេតជាតរូបរជតាតិ ។ ឯវម្បិ ខោ វេសាលិកា ឧបាសកា អាយស្មតា យសេន កាកណ្ឌកបុត្តេន វុច្ចមានា អទំសុយេវ សង្ឃស្ស កហាបណម្បិ អឌ្ឍម្បិ បាទម្បិ មាសករូបម្បិ ។ អថខោ

---

១ ឱ. ម. កំសបាតិំ ។ ២ ឱ. អាគតេ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកៈ រឿងវជ្ជីបុត្តកភិក្ខុនិងរឿងព្រះយសត្ថេរ

(២៩៦) សម័យនោះឯង ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី បានដងទឹកដាក់ពេញភាជន៍សំរិទ្ធហើយយកទៅ តំកល់ទុកក្នុងកណ្តាលភិក្ខុសង្ឃក្នុងថ្ងៃឧបោសថនោះ ហើយពោលពាក្យយ៉ាងនេះ ចំពោះពួកឧបាសកនៅក្នុងក្រុងវេសាលីដែលមកទាំងអស់ថា ហៃអ្នកមានអាយុទាំងឡាយ ចូរអ្នកទាំងឡាយប្រគេនកហាបណៈមួយក្តី កន្លះកហាបណៈក្តី មួយបាទក្តី មាសករូបមួយក្តី ដល់សង្ឃចុះ សង្ឃមុខជានឹងមានកិច្ចដោយបរិក្ខារមិនខាន ។ កាលដែលពួកវជ្ជីបុត្តកភិក្ខុពោលយ៉ាងនេះហើយ ទើបព្រះយសកាកណ្ឌកបុត្ត មានអាយុ ក៏ពោលដូច្នេះនឹងពួកឧបាសកអ្នកនៅក្នុងក្រុងវេសាលីថា នែអ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយ កុំប្រគេនកហាបណៈមួយក្តី កន្លះកហាបណៈក្តី បាទមួយក្តី មាសករូបមួយក្តី ដល់សង្ឃឡើយ ព្រោះមាសនិងប្រាក់ មិនគួរដល់ពួកសមណៈជាសក្យបុត្តិយ៍ទេ ពួកសមណៈជាសក្យបុត្តិយ៍ មិនត្រេកអរ មិនកាន់មាសនិងប្រាក់ទេ ពួកសមណៈជាសក្យបុត្តិយ៍ លះចោលកែវមណីនិងមាសចេញហើយប្រាសចាក គឺថាលែងរវល់ ដោយមាសនិងប្រាក់ហើយ ។ ឯពួកឧបាសកដែលនៅក្នុងក្រុងវេសាលី ទុកជាព្រះយសកាកណ្ឌកបុត្ត ពោលយ៉ាងនេះហើយ ក៏នៅតែប្រគេនកហាបណៈមួយខ្លះ កន្លះកហាបណៈខ្លះ បាទមួយខ្លះ មាសករូបមួយខ្លះ ដល់សង្ឃ ។ លំដាប់នោះឯង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



វេសាលិកា វជ្ជិបុត្តកា ភិក្ខូ តស្សា រត្តិយា អច្ចយេន តំ ហិរញ្ញំ ភិក្ខុគ្គេន[១] បដិវីសំ[២] ឋបេត្វា ភាជេសុំ ។ អថខោ វេសាលិកា វជ្ជិបុត្តកា ភិក្ខូ អាយស្មន្តំ យសំ កាកណ្ឌកបុត្តំ ឯតទវោចុំ ឯតំ អាវុសោ យស ហិរញ្ញស្ស បដិវីសោតិ ។ នត្ថិ មេ អាវុសោ ហិរញ្ញស្ស បដិវីសោ នាហំ ហិរញ្ញំ សាទិយាមីតិ ។

[២៩៧] អថខោ វេសាលិកា វជ្ជិបុត្តកា ភិក្ខូ អយំ អាវុសោ យសោ កាកណ្ឌកបុត្តោ ឧបាសកេ សទ្ធេ បសន្នេ អក្កោសតិ បរិភាសតិ អប្បសាទំ ករោតិ ហន្ទស្ស មយំ បដិសារណីយកម្មំ ករោមាតិ ។ តេ តស្ស បដិសារណីយកម្មំ អកំសុ ។ អថខោ អាយស្មា យសោ កាកណ្ឌកបុត្តោ វេសាលិកេ វជ្ជិបុត្តកេ ភិក្ខូ ឯតទវោច ភគវតា អាវុសោ បញ្ញត្តំ បដិសារណីយកម្មកតស្ស ភិក្ខុនោ អនុទូតោ ទាតព្វោតិ ទេថ មេ អាវុសោ អនុទូតំ ភិក្ខុន្តិ ។ អថខោ វេសាលិកា វជ្ជិបុត្តកា ភិក្ខូ ឯកំ ភិក្ខុំ

១ ឱ. ម. ភិក្ខុគ្គេន ។ ២ បដិវីសន្តិបិ ជាហើ ឯវំ សព្វត្ថ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ពួកវជ្ជីបុត្តកភិក្ខុ អ្នកនៅក្នុងក្រុងវេសាលី លុះកន្លងរាត្រីនោះហើយ (ព្រឹកឡើង) ក៏ចែកប្រាក់នោះ ដាក់ចំណែកមួយ ៗ ដោយរាប់ចំនួនភិក្ខុ ៗ ទើបពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី ពោលនឹងព្រះយសកាកណ្ឌកបុត្តមានអាយុថា នែអាវុសោ យស នេះជាចំណែកប្រាក់របស់លោក ៗ ព្រះយសកាកណ្ឌកបុត្តពោលថា ម្នាលអាវុសោទាំងឡាយ ខ្ញុំគ្មានចំណែកនៃប្រាក់ទេ ព្រោះខ្ញុំមិនត្រេកអរនឹងប្រាក់ទេ ។

[៤៩៧] គ្រានោះឯង ពួកវជ្ជីបុត្តកភិក្ខុដែលនៅក្នុងក្រុងវេសាលី ពោលថា នែអាវុសោទាំងឡាយ ព្រះយសកាកណ្ឌកបុត្តនេះ ជេរតម្រាមធ្វើនូវការរកពាទបណ្ដាញពួកឧបាសកដែលមានសទ្ធាជ្រះថ្លាថា បើដូច្នោះ យើងរាល់គ្នាធ្វើបដិសារណីយកម្មដល់ព្រះយសកាកណ្ឌកបុត្តនោះ ។ ពួកវជ្ជីបុត្តកភិក្ខុនោះ បានធ្វើបដិសារណីយកម្ម ដល់ព្រះយសកាកណ្ឌកបុត្តនោះ ។ គ្រានោះឯង ព្រះយសកាកណ្ឌកបុត្តមានអាយុបានពោលពាក្យនេះនឹងពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលីថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគទ្រង់បញ្ញត្តថា សង្ឃត្រូវឲ្យអនុទូតដល់ភិក្ខុដែលសង្ឃធ្វើបដិសារណីយកម្មហើយ ម្នាលអាវុសោទាំងឡាយ ចូរអ្នកទាំងឡាយឲ្យភិក្ខុជាអនុទូតដល់ខ្ញុំ ៗ លំដាប់នោះ ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៗ



សន្និបតិត្វា អាយស្មតោ យសស្ស កាកណ្ឌកបុត្តស្ស អនុទូតំ អទំសុ ។ អថខោ អាយស្មា យសោ កាកណ្ឌកបុត្តោ អនុទូតេន ភិក្ខុនា សទ្ធឹ វេសាលឹ បវិសិត្វា វេសាលិកេ ឧបាសកេ ឯតទវោច អហំ កិរាយស្មន្តេ ឧបាសកេ សទ្ធេ បសន្នេ អក្កោសាមិ បរិភាសាមិ អប្បសាទំ ករោមិ យោហំ អធម្មំ អធម្មោតិ វទាមិ ធម្មំ ធម្មោតិ វទាមិ អវិនយំ អវិនយោតិ វទាមិ វិនយំ វិនយោតិ វទាមិ ។

(២៩៨) ឯកាមិទំ អាវុសោ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ អាវុសោ ភគវា ភិក្ខូ អាមន្តេសិ ចត្តារោមេ ភិក្ខវេ ចន្ទិមសុរិយានំ ឧបក្កិលេសា យេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋា ចន្ទិមសុរិយា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ ។ កតមេ ចត្តារោ ។ អព្ភា ភិក្ខវេ ចន្ទិមសុរិយានំ ឧបក្កិលេសោ យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋា ចន្ទិមសុរិយា ន តបន្តិ ន ភាសន្តិ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ក្រុងវេសាលីបានសន្មតភិក្ខុមួយរូបឲ្យជាអនុទូតដល់ព្រះយសកាកណ្ឌកបុត្តដ៏មានអាយុ ។ ឯព្រះយសកាកណ្ឌកបុត្តមានអាយុ ចូលទៅក្នុងក្រុងវេសាលីជាមួយនឹងភិក្ខុជាអនុទូត ហើយក៏ពោលពាក្យដូច្នេះនឹងឧបាសកដែលនៅក្នុងក្រុងវេសាលីថា អាត្មាគ្រាន់តែពោលនូវសភាវៈមិនមែនជាធម៌ថាមិនមែនជាធម៌ ពោលនូវធម៌ថាជាធម៌ ពោលនូវសភាវៈមិនមែនជាវិន័យថាមិនមែនជាវិន័យ ពោលនូវវិន័យថាជាវិន័យ ក៏ត្រូវឲ្យប់ទៅជាពួកពាក្យខ្ញុំរខ្លាយថា អាត្មាជេរគេប្រមាថ ធ្វើនូវការរកពានបណ្តេញពួកឧបាសកដ៏មានអាយុដែលមានសទ្ធាជ្រះថ្លាវិញ ។

(២៩៨) ម្នាលអ្នកមានអាយុទាំងឡាយ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ម្នាលអ្នកមានអាយុទាំងឡាយ កាលដែលព្រះមានព្រះភាគគង់នៅ ។ ទីនោះ ព្រះអង្គទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រនឹងព្រះអាទិត្យសៅហ្មង ដោយឧបក្កិលេសទាំងឡាយណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់ព្រះចន្ទ្រនឹងព្រះអាទិត្យទាំងនេះមាន ៤ យ៉ាង ។ ឧបក្កិលេសទាំង ៤ យ៉ាងនោះដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រនឹងព្រះអាទិត្យសៅហ្មង ដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


## វិនយបិដកេ ចុល្លវគ្គោ

ន វិរោចន្តិ មហិកា ភិក្ខវេ ចន្ទិមសុរិយានំ ឧបក្កិលេសោ យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋា ចន្ទិមសុរិយា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ ធូមរជោ ភិក្ខវេ ចន្ទិមសុរិយានំ ឧបក្កិលេសោ យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋា ចន្ទិមសុរិយា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ រាហុ ភិក្ខវេ អសុរិន្ទោ ចន្ទិមសុរិយានំ ឧបក្កិលេសោ យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋា ចន្ទិមសុរិយា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ ឯវមេវ ខោ ភិក្ខវេ ចត្តារោ ចន្ទិមសុរិយានំ ឧបក្កិលេសា យេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋា ចន្ទិមសុរិយា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ ឯវមេវ ខោ ភិក្ខវេ ចត្តារោមេ សមណព្រាហ្មណានំ ឧបក្កិលេសា យេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋា ឯកេ សមណព្រាហ្មណា ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ ។ កតមេ ចត្តារោ ។ សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា សុរំ បិវន្តិ មេរយំ បិវន្តិ សុរាមេរយបានា អប្បដិវិរតា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មិនភ្លឺត្រចះ ឧបក្កិលេសរបស់ព្រះចន្ទ្រនិងព្រះអាទិត្យនោះ គឺ ពពក១ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រនិងព្រះអាទិត្យសៅហ្មង ដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់ព្រះចន្ទ្រនិងព្រះអាទិត្យនោះគឺ ទឹកសន្សើមចុះអ័ព្ទ ១ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រនិងព្រះអាទិត្យសៅហ្មង ដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់ព្រះចន្ទ្រនិងព្រះអាទិត្យនោះ គឺ ផ្សែងនិងធូលី ១ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រនិងព្រះអាទិត្យសៅហ្មង ដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេស របស់ព្រះចន្ទ្រនិងព្រះអាទិត្យនោះគឺ រាហុអសុរិន្ទ្រ ១ ម្នាលភិក្ខុទាំងឡាយ ព្រះចន្ទ្រនិងព្រះអាទិត្យសៅហ្មង ដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេស របស់ព្រះចន្ទ្រនិងព្រះអាទិត្យនោះមាន ៤ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ សមណៈនិងព្រាហ្មណ៍ទាំងឡាយពួក ១ សៅហ្មង ដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់សមណៈនិងព្រាហ្មណ៍ទាំងនេះ ក៏មាន ៤ យ៉ាង ដូច្នោះដែរ ។ ឧបក្កិលេសទាំង ៤ យ៉ាងនោះដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មានសមណៈនិងព្រាហ្មណ៍ពួក ១ ផឹកសុរានិងមេរ័យ មិនវៀរចាកកិរិយាផឹកសុរានិងមេរ័យ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកេ សមណព្រាហ្មណានំ ចត្តារោ ឧបក្កិលេសា

អយំ ភិក្ខវេ បឋមោ សមណព្រាហ្មណានំ ឧបក្កិលេ-
សោ យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋា ឯកេ ស-
មណព្រាហ្មណា ន តប្បន្តិ ន ភាសន្តិ ន វិរោចន្តិ
បុន ចបរំ ភិក្ខវេ ឯកេ សមណព្រាហ្មណា មេថុនំ
ធម្មំ បដិសេវន្តិ មេថុនធម្មា អប្បដិវិរតា អយំ ភិក្ខវេ
ទុតិយោ សមណព្រាហ្មណានំ ឧបក្កិលេសោ យេន
ឧបក្កិលេសេន ឧបក្កិលិដ្ឋា ឯកេ សមណព្រាហ្ម-
ណា ន តប្បន្តិ ន ភាសន្តិ ន វិរោចន្តិ បុន ចបរំ
ភិក្ខវេ ឯកេ សមណព្រាហ្មណា ជាតរូបរជតំ សាទិ-
យន្តិ ជាតរូបរជតប្បដិគ្គហណា អប្បដិវិរតា អយំ
ភិក្ខវេ តតិយោ សមណព្រាហ្មណានំ ឧបក្កិលេ-
សោ យេន ឧបក្កិលេសេន ឧបក្កិលិដ្ឋា ឯកេ សម-
ណព្រាហ្មណា ន តប្បន្តិ ន ភាសន្តិ ន វិរោចន្តិ បុ-
ន ចបរំ ភិក្ខវេ ឯកេ សមណព្រាហ្មណា មិច្ឆាជីវេន
ជីវិតំ កប្បេន្តិ មិច្ឆាជីវា អប្បដិវិរតា អយំ ភិក្ខវេ
ចតុត្ថោ សមណព្រាហ្មណានំ ឧបក្កិលេសោ យេន
ឧបក្កិលេសេន ឧបក្កិលិដ្ឋា ឯកេ សមណព្រាហ្មណា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកៈ ឧបក្កិលេស ៤ យ៉ាងរបស់សមណព្រាហ្មណ៍

ម្នាលភិក្ខុទាំងឡាយ សមណៈនិងព្រាហ្មណ៍ទាំងឡាយពួក ១ សៅហ្មង ដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់សមណៈនិងព្រាហ្មណ៍នេះជាដម្បូង ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃ មានតទៅទៀត សមណៈនិងព្រាហ្មណ៍ទាំងឡាយពួក ១ សេពមេថុនធម្ម មិនវៀរចាកមេថុនធម្ម ម្នាលភិក្ខុទាំងឡាយ សមណៈនិងព្រាហ្មណ៍ពួក ១ សៅហ្មង ដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេសរបស់សមណៈនិងព្រាហ្មណ៍នេះជាគំរប់ពីរ ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃ មានតទៅទៀត សមណៈនិងព្រាហ្មណ៍ទាំងឡាយពួក ១ កាន់មាសនិងប្រាក់ មិនវៀរចាកកិរិយាទទួលមាសនិងប្រាក់ ម្នាលភិក្ខុទាំងឡាយ សមណៈនិងព្រាហ្មណ៍ទាំងឡាយពួក ១ សៅហ្មង ដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺត្រចះ ឧបក្កិលេស របស់សមណៈនិងព្រាហ្មណ៍នេះជាគំរប់បី ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃមានតទៅទៀត សមណៈនិងព្រាហ្មណ៍ទាំងឡាយពួក ១ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ មិនវៀរចាកមិច្ឆាជីវៈ ម្នាលភិក្ខុទាំងឡាយ សមណៈនិងព្រាហ្មណ៍ពួក ១ សៅហ្មងដោយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ន តបន្តិ ន ភាសន្តិ ន វិរោចន្តិ ឥមេ ខោ ភិក្ខវេ ចត្តារោ សមណព្រាហ្មណានំ ឧបក្កិលេសា យេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋា ឯកេ សមណព្រាហ្មណា ន តបន្តិ ន ភាសន្តិ ន វិរោចន្តីតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

(២៩៩) រាគទោសបរិក្កិដ្ឋា
ឯកេ សមណព្រាហ្មណា
អវិជ្ជានិវុតា បោសា
បិយរូបាភិនន្ទិនោ
សុរំ បិវន្តិ មេរយំ
បដិសេវន្តិ មេថុនំ
រជតំ ជាតរូបញ្ច
សាទិយន្តិ អវិទ្ទសូ
មិច្ឆាជីវេន ជីវន្តិ
ឯកេ សមណព្រាហ្មណា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺច្រាល ឧបក្កិលេសរបស់សមណៈនិងព្រាហ្មណ៍នេះ ជាគំរប់បួន ម្នាលភិក្ខុទាំងឡាយ សមណៈនិងព្រាហ្មណ៍ទាំងឡាយពួក ១ សៅហ្មងដោយឧបក្កិលេសណាហើយ រមែងមិនរុងរឿង មិនភ្លឺ មិនភ្លឺច្រាល ឧបក្កិលេសរបស់សមណៈនិងព្រាហ្មណ៍ មាន ៤ យ៉ាងនេះឯង ។ ម្នាលអ្នកមានអាយុទាំងឡាយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះហើយ លុះព្រះសុគតទ្រង់ត្រាស់នូវពាក្យនេះចប់ហើយ លំដាប់នោះ ព្រះសាស្តាទ្រង់សំដែងជួរច្នះតទៅទៀតថា

[៤៩៩] សមណៈនិងព្រាហ្មណ៍ទាំងឡាយពួក ១ សៅហ្មង
ហើយដោយរាគៈនិងទោសៈ ជាបុរសដែលអវិជ្ជាបិទបាំងហើយ
មានសេចក្តីត្រេកអរ ក្នុងរូបជាទីស្រឡាញ់ ផឹកសុរានិងមេរ័យ
សេពមេថុនធម្ម មិនដឹងច្បាស់(នូវទោស)ត្រេកអរបំពោះប្រាក់
និងមាស សមណៈនិងព្រាហ្មណ៍ទាំងឡាយពួក ១ ចិញ្ចឹមជីវិត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកេ ចត្តារោ ឧបក្កិលេសា

ឯតេ ឧបក្កិលេសា វុត្តា
ពុទ្ធេនាទិច្ចពន្ធុនា
យេហិ ឧបក្កិលេសេហិ
ឧបក្កិលិដ្ឋា ឯកេ សមណព្រាហ្មណា
ន តបន្តិ ន ភាសន្តិ[១]
អសុទ្ធា សរជា មិគា[២]
អន្ធការេន ឱនទ្ធា
តណ្ហាទាសា សនេត្តិកា
វឌ្ឍន្តិ កដសឹ ឃោរំ
អាទិយន្តិ បុនព្ភវន្តិ ។

(៣០០) ឯវំវាទីកិរាហំ អាយស្មន្តេ ឧបាសកេ សទ្ធេ បសន្នេ អក្កោសាមិ បរិភាសាមិ អប្បសាទំ ករោមិ យោហំ អធម្មំ អធម្មោតិ វទាមិ ធម្មំ ធម្មោតិ វទាមិ អវិនយំ អវិនយោតិ វទាមិ វិនយំ វិនយោតិ វទាមិ ។

---

១ ឥតោ បរំ ន វិរោចន្តិ តេ សមាធិបិ ញាហោ វិជ្ជតិ ។ ២ ឱ. ម. មគា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ដោយមិច្ឆាជីវៈ សមណៈនឹងព្រាហ្មណ៍ទាំងឡាយពួក ១ សៅហ្មងដោយឧបក្កិលេសទាំងឡាយណា ក៏មិនបរិសុទ្ធ ប្រកបដោយធូលី គឺកិលេស រមែងមិនរុងរឿង មិនភ្លឺ ប្រៀបដូចសត្វម្រឹគ ឧបក្កិលេសទាំងឡាយនុ៎ះ ព្រះពុទ្ធមានផៅពង្សដ៏ខ្ពង់ខ្ពស់ដូចជាព្រះអាទិត្យទ្រង់ត្រាស់សំដែងហើយ ( សមណៈនឹងព្រាហ្មណ៍ទាំងនោះ) ត្រូវងងឹត គឺ អវិជ្ជា រួបរឹតហើយ ជាទាសៈនៃតណ្ហា ប្រកបដោយតណ្ហា ដែលដឹកនាំសត្វទៅក្នុងភព តែងញ៉ាំងកង់កាយជារបស់គ្រោកគ្រាក ឲ្យចំរើនឡើង ហើយកាន់យកនូវភពថ្មីទៀត ។

(៣០០) អាត្មាគ្រាន់តែពោល នូវសភាវៈមិនមែនជាធម៌ ថាមិនមែនជាធម៌ ពោលនូវធម៌ថាជាធម៌ ពោលនូវសភាវៈមិនមែនជាវិន័យ ថាមិនមែនជាវិន័យ ពោលនូវវិន័យថាជាវិន័យ អាត្មាគ្រាន់តែពោលយ៉ាងនេះ ក៏ត្រូវឡប់ជាពុពាក្យខ្ចរខ្ចាយទៅថា អាត្មាជេរគំរាមធ្វើនូវការរុករានបណ្ដេញពួកឧបាសកមានអាយុដែលមានសទ្ធាជ្រះថ្លាទៅវិញ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## វិនយបិដកេ ចុល្លវគ្គោ

(១០១) ឯកមិទំ អាវុសោ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន រាជន្តេបុរេ រាជបរិសាយំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ កប្បតិ សមណានំ សក្យបុត្តិយានំ ជាតរូបរជតំ សាទិយន្តិ សមណា សក្យបុត្តិយា ជាតរូបរជតំ បដិគ្គណ្ហន្តិ សមណា សក្យបុត្តិយា ជាតរូបរជតន្តិ ។ តេន ខោ បនាវុសោ សមយេន មណិចូឡកោ គាមណី តស្សំ បរិសាយំ និសិន្នកោ(១) ហោតិ ។ អថ ខោ អាវុសោ មណិចូឡកោ គាមណី តំ បរិសំ ឯតទវោច មា អយ្យា(២) ឯវំ អវចុត្ថ ន កប្បតិ សមណានំ សក្យបុត្តិយានំ ជាតរូបរជតំ ន សាទិយន្តិ សមណា សក្យបុត្តិយា ជាតរូបរជតំ នប្បដិគ្គណ្ហន្តិ សមណា សក្យបុត្តិយា ជាតរូបរជតំ និក្ខិត្តមណិសុវណ្ណា សមណា សក្យបុត្តិយា អបេតជាតរូបរជតាតិ ។ អសក្ខិ ខោ អាវុសោ មណិចូឡកោ គាមណី តំ បរិសំ សញ្ញាបេតុំ ។ អថ ខោ អាវុសោ

១ ខ.ម. និសិន្នោ ។ ២ ខ.ម. អយ្យោ ។

## វិនយបិដក ចុល្លវគ្គ

(៣០១) ម្នាលអ្នកមានអាយុទាំងឡាយ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ។ សម័យនោះឯង អន្តរាកថានេះ[១] កើតឡើងដល់ជនដែលអង្គុយប្រជុំគ្នាក្នុងកណ្តាលរាជបរិសទ្យ ក្នុងព្រះបរមរាជវាំងថា មាសនឹងប្រាក់គួរដល់ពួកសមណសក្យបុត្តិយ៍ដែរ ពួកសមណសក្យបុត្តិយ៍ត្រេកអរនឹងមាសប្រាក់ដែរ ពួកសមណសក្យបុត្តិយ៍ទទួលមាសប្រាក់ដែរ ។ ម្នាលអ្នកមានអាយុទាំងឡាយ សម័យនោះឯង មានបុរសជាធំគឺនាយចៅហ្វាយម្នាក់ឈ្មោះមណិ-ចូឡកៈអង្គុយនៅក្នុងកណ្តាលបរិសទ្យនោះ ។ ម្នាលអ្នកមានអាយុទាំងឡាយ លំដាប់នោះ បុរសជាធំឈ្មោះមណិចូឡកៈពោលពាក្យដូច្នេះនឹងបរិសទ្យនោះថា បពិត្រអស់លោកទាំងឡាយ អ្នកទាំងឡាយ កុំពោលយ៉ាងនេះឡើយ មាសនឹងប្រាក់មិនគួរដល់ពួកសមណសក្យបុត្តិយ៍ទេ ពួកសមណសក្យបុត្តិយ៍មិនត្រេកអរនឹងមាសប្រាក់ទេ មិនទទួលមាសប្រាក់ទេ ពួកសមណសក្យបុត្តិយ៍លះបង់កែវមណីនឹងមាសចេញហើយប្រាសចាកគឺ ជាលែងរវល់ដោយមាសនឹងប្រាក់ហើយ ។ ម្នាលអ្នកមានអាយុទាំងឡាយ បុរសជាធំឈ្មោះមណិចូឡកៈ ក៏មិនអាចនឹងពន្យល់បរិសទ្យនោះបាន ។ ម្នាលអ្នកមានអាយុទាំងឡាយ លំដាប់នោះឯង លុះបុរសជាធំ

---

១ អន្តរកថាព្រះសូត្រថា ពាក្យជាចន្លោះនៃគុណធម៌មានកម្មដ្ឋានមនសិការនឹងបាឡីនឹងអដ្ឋក-ថាជាដើមហៅថា អន្តរកថា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកេ មណិចូឡកគាមណិវត្ថុ

មណិចូឡកោ គាមណី តំ បរិសំ សញ្ញាបេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាវុសោ មណិចូឡកោ គាមណី ភគវន្តំ ឯតទវោច ឥធ ភន្តេ រាជន្តេបុរេ រាជបរិសាយំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ កប្បតិ សមណានំ សក្យបុត្តិយានំ ជាតរូបរជតំ សាទិយន្តិ សមណា សក្យបុត្តិយា ជាតរូបរជតំ បដិគ្គណ្ហន្តិ សមណា សក្យបុត្តិយា ជាតរូបរជតន្តិ ឯវំ វុត្តេ អហំ ភន្តេ តំ បរិសំ ឯតទវោចំ មា អយ្យា ឯវំ អវចុត្ថ ន កប្បតិ សមណានំ សក្យបុត្តិយានំ ជាតរូបរជតំ ន សាទិយន្តិ សមណា សក្យបុត្តិយា ជាតរូបរជតំ នប្បដិគ្គណ្ហន្តិ សមណា សក្យបុត្តិយា ជាតរូបរជតំ និក្ខិត្តមណិសុវណ្ណា សមណា សក្យបុត្តិយា អបេតជាតរូបរជតាតិ អសក្ខឹ ខោ អហំ ភន្តេ តំ បរិសំ សញ្ញាបេតុំ កច្ចាហំ ភន្តេ ឯវំ ព្យាករមានោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកៈ រឿងអ្នកធំឈ្មោះមណិចូឡកៈ

ឈ្មោះមណិចូឡកៈពន្យល់បរិសទ្យនោះរួចហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ម្នាលអាវុសោទាំងឡាយ លុះបុរសជាធំឈ្មោះមណិចូឡកៈ អង្គុយក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន អន្តរាកថានេះ កើតឡើងដល់ពួកជនដែលអង្គុយប្រជុំគ្នាក្នុងរាជបរិសទ្យ ក្នុងព្រះបរមរាជវាំងនេះថា មាសនឹងប្រាក់គួរដល់ពួកសមណសក្យបុត្តិយ៍ដែរ ពួកសមណសក្យបុត្តិយ៍ត្រេកអរនឹងមាសប្រាក់ដែរ ពួកសមណសក្យបុត្តិយ៍ទទួលមាសនឹងប្រាក់ដែរ បពិត្រព្រះអង្គដ៏ចំរើន កាលដែលពួកបរិសទ្យនោះពោលយ៉ាងនេះ ខ្ញុំព្រះអង្គក៏ពោលពាក្យផ្ទុយប្ដុះនឹងបរិសទ្យនោះវិញថា បពិត្រអស់លោកទាំងឡាយ អ្នកទាំងឡាយ កុំពោលពាក្យយ៉ាងនេះឡើយ មាសនឹងប្រាក់មិនគួរដល់ពួកសមណសក្យបុត្តិយ៍ទេ ពួកសមណសក្យបុត្តិយ៍មិនត្រេកអរមាសនឹងប្រាក់ទេ ពួកសមណសក្យបុត្តិយ៍មិនទទួលមាសប្រាក់ទេ ពួកសមណសក្យបុត្តិយ៍លះបង់កែវមណីនឹងមាសចេញហើយ ប្រាសចាកគឺថាលែងរវល់ដោយមាសនឹងប្រាក់ហើយ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនអាចនឹងពន្យល់បរិសទ្យនោះបានទេ បពិត្រព្រះអង្គដ៏ចំរើន កាលបើខ្ញុំព្រះអង្គព្យាករ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



វុត្តវាទី ចេវ ភគវតោ ហោមិ ន ច ភគវន្តំ អភូតេន អព្ភាចិក្ខាមិ ធម្មស្ស ចានុធម្មំ ព្យាករោមិ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆតីតិ ។ តគ្ឃ ត្វំ គាមណិ ឯវំ ព្យាករមានោ វុត្តវាទី ចេវ មេ ហោសិ ន ច មំ អភូតេន អព្ភាចិក្ខសិ ធម្មស្ស ចានុធម្មំ ព្យាករោសិ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆតិ ន ហិ គាមណិ កប្បតិ សមណានំ សក្យបុត្តិយានំ ជាតរូបរជតំ ន សាទិយន្តិ សមណា សក្យបុត្តិយា ជាតរូបរជតំ នប្បដិគ្គណ្ហន្តិ សមណា សក្យបុត្តិយា ជាតរូបរជតំ និក្ខិត្តមណិសុវណ្ណា សមណា សក្យបុត្តិយា អបេតជាតរូបរជតា យស្ស ខោ គាមណិ ជាតរូបរជតំ កប្បតិ បញ្ចបិ កាមគុណា តស្ស កប្បន្តិ[១] យស្ស បញ្ច កាមគុណា កប្បន្តិ ឯកំសេនេតំ[២] គាមណិ ធារេយ្យាសិ អស្សមណធម្មោ អសក្យបុត្តិយធម្មោតិ អបិចាហំ គាមណិ

---

១ ឱ. ម. បញ្ចបិ តស្ស កាមគុណា កប្បន្តិ ។ ២ ឱ. ម. ឯកំសេន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



(ដោះស្រាយ) យ៉ាងនេះ ឈ្មោះថាជាអ្នកពោលត្រូវតាមបន្ទូលនៃព្រះមានព្រះភាគផង មិនពោលបង្កាច់នូវព្រះមានព្រះភាគ ដោយពាក្យមិនពិតផង ព្យាករនូវធម៌ ដ៏សមគួរដល់ធម៌ផង ពាក្យពោលតូចធំណាមួយដែលប្រកបដោយធម៌ មិនមកកាន់ស្ថានដែលបណ្ឌិតគប្បីតិះដៀលផង បានដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា អើ ម្ចាស់អ្នកជាធំ អ្នកព្យាករយ៉ាងនេះ ឈ្មោះថាជាអ្នកពោលត្រូវតាមពាក្យតថាគតផង មិនពោលបង្កាច់តថាគត ដោយពាក្យមិនពិតផង ព្យាករនូវធម៌ដ៏សមគួរដល់ធម៌ផង ពាក្យពោលតូចធំណាមួយដែលប្រកបដោយធម៌ មិនបានមកកាន់ស្ថានដែលបណ្ឌិតគប្បីតិះដៀលផង នែអ្នកជាធំ មាសនឹងប្រាក់មិនគួរដល់ពួកសមណសក្យបុត្តិយ៍ទេ ពួកសមណសក្យបុត្តិយ៍មិនត្រេកអរនឹងមាសប្រាក់ទេ ពួកសមណសក្យបុត្តិយ៍មិនទទួលមាសប្រាក់ទេ ពួកសមណសក្យបុត្តិយ៍លះចោលកែវមណីនឹងមាសចេញហើយ ប្រាសចាកគឺថាលែងរវល់ដោយមាសនឹងប្រាក់ហើយ នែអ្នកជាធំ មាសនឹងប្រាក់គួរដល់បុគ្គលណា កាមគុណទាំង ៥ ក៏គួរដល់បុគ្គលនោះដែរ កាមគុណទាំង ៥ គួរដល់បុគ្គលណា មាសនឹងប្រាក់ក៏គួរដល់បុគ្គលនោះដែរ នែអ្នកជាធំ អ្នកគប្បីចាំទុកនូវការសំរេចនៃកាមគុណទាំង ៥ នេះ ដោយពិតថា មិនមែនជាធម៌របស់សមណៈ មិនមែនជាធម៌របស់សក្យបុត្តិយ៍ទេ ម្នាលអ្នកជាធំ មួយវិញទៀត

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



## សត្តសតិកក្ខន្ធកេ យសោកាកណ្ឌកបុត្តត្ថេរកថា

ឯវំ វទាមិ តិណំ តិណត្ថិកេន បរិយេសិតព្វំ ទារុំ ទារុត្ថិកេន បរិយេសិតព្វំ សកដំ សកដត្ថិកេន បរិយេសិតព្វំ បុរិសោ បុរិសត្ថិកេន បរិយេសិតព្វោ ន ត្វេវាហំ គាមណិ កេនចិ បរិយាយេន ជាតរូបរជតំ សាទិតព្វំ បរិយេសិតព្វន្តិ វទាមីតិ ឯវំវាទី កិរាហំ អាយស្មន្តោ ឧបាសកេ សទ្ធេ បសន្នេ អក្កោសាមិ បរិភាសាមិ អប្បសាទំ ករោមិ យោហំ អធម្មំ អធម្មោតិ វទាមិ ធម្មំ ធម្មោតិ វទាមិ អវិនយំ អវិនយោតិ វទាមិ វិនយំ វិនយោតិ វទាមិ ។

(៣០២) ឯកមិទំ អាវុសោ សមយំ ភគវា តត្ថេវ រាជគហេ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ អារព្ភ ជាតរូបរជតំ បដិក្ខិបិ សិក្ខាបទញ្ច បញ្ញាបេសិ ។ ឯវំវាទី កិរាហំ អាយស្មន្តោ ឧបាសកេ សទ្ធេ បសន្នេ អក្កោសាមិ បរិភាសាមិ អប្បសាទំ ករោមិ យោហំ អធម្មំ អធម្មោតិ វទាមិ ធម្មំ ធម្មោតិ វទាមិ អវិនយំ អវិនយោតិ វទាមិ វិនយំ វិនយោតិ វទាមីតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



តថាគតពោលយ៉ាងនេះថា បុគ្គលអ្នកត្រូវការដោយស្មៅ គប្បីស្វែងរកស្មៅ បុគ្គលអ្នកត្រូវការដោយឈើ គប្បីស្វែងរកឈើ បុគ្គលអ្នកត្រូវការដោយរទេះ គប្បីស្វែងរករទេះ បុរសត្រូវការដោយបុរស គប្បីស្វែងរកបុរស ម្នាលអ្នកជាធំ តថាគតមិនធ្លាប់បានពោលថា សមណៈគប្បីត្រេកអរនឹងមាសប្រាក់ គប្បីស្វែងរកមាសប្រាក់ដូច្នេះ ដោយបរិយាយណាមួយឡើយ អាត្មាគ្រាន់តែពោលនូវសេចក្ដីៈមិនមែនជាធម៌ ថាមិនមែនជាធម៌ ពោលនូវធម៌ ថាជាធម៌ ពោលនូវសេចក្ដីៈមិនមែនជាវិន័យ ថាមិនមែនជាវិន័យ ពោលនូវវិន័យ ថាវិន័យ អាត្មាគ្រាន់តែពោលយ៉ាងនេះ ក៏ត្រឡប់ជាពួពាក្យខ្វះខ្វាយទៅថា អាត្មាជេរគម្រាមធ្វើការក្រោកពន បណ្ដេញពួកឧបាសកមានអាយុ ដែលមានសទ្ធាជ្រះថ្លាទៅវិញ ។

( ៣០២ ) ម្នាលអាវុសោទាំងឡាយ សម័យមួយ ព្រះមានព្រះភាគទ្រង់ប្រារព្ធនឹងព្រះឧបនន្ទសក្យបុត្តដ៏មានអាយុ ទ្រង់ហាមមាសនឹងប្រាក់ ហើយបញ្ញត្តសិក្ខាបទក្នុងនគររាជគ្រឹះ ។ អាត្មាគ្រាន់តែពោលនូវសេចក្ដីៈមិនមែនជាធម៌ ថាមិនមែនជាធម៌ ពោលនូវធម៌ថាធម៌ ពោលនូវសេចក្ដីៈមិនមែនជាវិន័យ ថាមិនមែនវិន័យ ពោលនូវវិន័យ ថាវិន័យ អាត្មាគ្រាន់តែពោលយ៉ាងនេះ ក៏ត្រឡប់ជាពួពាក្យខ្វះខ្វាយទៅថា អាត្មាជេរគម្រាមធ្វើការក្រោកពនបណ្ដេញពួកឧបាសកមានអាយុដែលមានសទ្ធាជ្រះថ្លាទៅវិញ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឯវំ វុត្តេ វេសាលិកា ឧបាសកា អាយស្មន្តំ យសំ កាកណ្ឌកបុត្តំ ឯតទវោចុំ ឯកោ វ ភន្តេ អយ្យោ យសោ កាកណ្ឌកបុត្តោ សមណោ សក្យបុត្តិយោ សព្វេ វិមេ អស្សមណា អសក្យបុត្តិយា វសតុ ភន្តេ អយ្យោ យសោ កាកណ្ឌកបុត្តោ វេសាលិយំ មយំ អយ្យស្ស យសស្ស កាកណ្ឌកបុត្តស្ស ឧស្សុក្កំ ករិស្សាម ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ។ អថខោ អាយស្មា យសោ កាកណ្ឌកបុត្តោ វេសាលិកេ ឧបាសកេ សញ្ញាបេត្វា អនុទូតេន ភិក្ខុនា សទ្ធឹ អារាមំ អគមាសិ ។

(៣០៣) អថខោ វេសាលិកា វជ្ជិបុត្តកា ភិក្ខូ អនុទូតំ ភិក្ខុំ បុច្ឆឹសុ ខមាបិតា អាវុសោ យសេន កាកណ្ឌកបុត្តេន វេសាលិកា ឧបាសកាតិ ។ ឧបាសកេហិ(១) បាបិកំ នោ អាវុសោ កតំ ឯកោវ យសោ កាកណ្ឌកបុត្តោ សមណោ សក្យបុត្តិយោ កតោ សព្វេ វ មយំ អស្សមណា អសក្យបុត្តិយា កតាតិ ។

---

១ ឧភយបិយបោត្ថកេ ឧបាសកេហីតិ បាឋោ ន បញ្ញាយតិ ។

កាលដែលព្រះយសកាកណ្ឌកបុត្តពោលយ៉ាងនេះ ហើយពួកឧបាសកដែលនៅក្នុងក្រុងវេសាលី ក៏នាំគ្នាពោលពាក្យដូច្នេះ នឹងព្រះយសកាកណ្ឌកបុត្តថា បពិត្រព្រះករុណាដ៏ចំរើន មានតែលោកម្ចាស់យសកាកណ្ឌកបុត្តមួយទេជាសមណសក្យបុត្តិយ៍ ឯភិក្ខុទាំងអស់នេះ សុទ្ធតែមិនមែនជាសមណៈ មិនមែនជាសក្យបុត្តិយ៍ឡើយ បពិត្រព្រះករុណាដ៏ចំរើន សូមព្រះយសកាកណ្ឌកបុត្តជាម្ចាស់ គង់នៅក្រុងវេសាលីចុះ យើងទាំងឡាយនឹងធ្វើសេចក្តីខ្វល់ខ្វាយដោយចីវរ បិណ្ឌបាត សេនាសនៈ នឹងគិលានបច្ច័យភេសជ្ជបរិក្ខារ ដល់ព្រះយសកាកណ្ឌកបុត្តជាម្ចាស់ ៗ គ្រានោះឯង ព្រះយសកាកណ្ឌកបុត្តមានអាយុ លុះពន្យល់ពួកឧបាសកដែលនៅក្នុងក្រុងវេសាលីហើយ ក៏ទៅកាន់អារាមជាមួយនឹងភិក្ខុអនុទូតវិញ ៗ

(៣០៣) លំដាប់នោះ ពួកវជ្ជីបុត្តកភិក្ខុដែលនៅក្នុងក្រុងវេសាលី សួរភិក្ខុជាអនុទូតថា ម្នាលអាវុសោ ព្រះយសកាកណ្ឌកបុត្ត បានសូមខមាទោសនឹងពួកឧបាសកដែលនៅក្នុងក្រុងវេសាលីហើយឬ ៗ ភិក្ខុជាអនុទូតនោះពោលថា ម្នាលអាវុសោទាំងឡាយ អំពើអាក្រក់ពួកយើងបានធ្វើហើយ ពួកឧបាសកធ្វើ គឺថាគេជឿព្រះយសកាកណ្ឌកបុត្តតែមួយ ថាជាសមណសក្យបុត្តិយ៍ ឯពួកយើងទាំងអស់ ឧបាសកធ្វើ ក៏គេទុកដាក់ថា មិនមែនជាសមណៈ មិនមែនជាសក្យបុត្តិយ៍ទៅវិញ ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកេ សម្ភូតសាណវាសិត្ថេរវត្ថុ

អថខោ វេសាលិកា វជ្ជិបុត្តកា ភិក្ខូ អយំ អាវុសោ យសោ កាកណ្ឌកបុត្តោ អម្ហេហិ អសម្មតោ គិហីនំ បកាសេសិ ហន្ទស្ស មយំ ឧក្ខេបនីយកម្មំ ករោមាតិ ។ តេ តស្ស ឧក្ខេបនីយកម្មំ កត្តុកាមា សន្និបតឹសុ ។ អថខោ អាយស្មា យសោ កាកណ្ឌកបុត្តោ វេហាសំ អព្ភុគ្គន្ត្វា កោសម្ពិយំ បច្ចុដ្ឋាសិ ។ អថខោ អាយស្មា យសោ កាកណ្ឌកបុត្តោ បាវេយ្យកានញ្ច អវន្តិទក្ខិណាបថកានញ្ច ភិក្ខូនំ សន្តិកេ ទូតំ បាហេសិ អាគច្ឆន្តុ អាយស្មន្តា ឥមំ អធិករណំ អាទិយិស្សាម យាវ(១)បុរេ អធម្មោ ទិប្បតិ ធម្មោ បដិពាហិយតិ អវិនយោ ទិប្បតិ វិនយោ បដិពាហិយតិ បុរេ អធម្មវាទិនោ ពលវន្តោ ហោន្តិ ធម្មវាទិនោ ទុព្វលា ហោន្តិ អវិនយវាទិនោ ពលវន្តោ ហោន្តិ វិនយវាទិនោ ទុព្វលា ហោន្តីតិ ។

(៣០៤) តេន ខោ បន សមយេន អាយស្មា សម្ភូតោ សាណវាសី អហោគង្គេ បព្វតេ បដិវសតិ ។ អថខោ អាយស្មា យសោ កាកណ្ឌកបុត្តោ យេន

---

១ ឱ. ម. បោត្ថកេសុ យាវាតិ បាឋោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកៈ រឿងព្រះថេរៈឈ្មោះសម្ភូតសាណវាសី

លំដាប់នោះ ពួកវជ្ជីបុត្តកភិក្ខុដែលនៅក្នុងក្រុងវេសាលីនិយាយគ្នាថា ម្នាលអាវុសោទាំងឡាយ ព្រះយសកាកណ្ឌកបុត្តនេះ យើងទាំងឡាយមិនបានសន្មតឲ្យ ក៏ទៅប្រកាសប្រាប់ដល់ពួកគ្រហស្ថ បើដូច្នោះគួរតែយើងធ្វើទុក្ខេបនីយកម្មដល់ព្រះយសកាកណ្ឌកបុត្តនោះ ។ ពួកវជ្ជីបុត្តកភិក្ខុទាំងនោះ ប៉ងនឹងធ្វើទុក្ខេបនីយកម្មដល់ព្រះយសកាកណ្ឌកបុត្តនោះ ក៏ប្រជុំគ្នា ។ គ្រានោះឯង ព្រះយសកាកណ្ឌកបុត្តមានអាយុ ហោះឡើងទៅឰដ៏អាកាស ហើយទៅចុះត្រង់ក្រុងកោសម្ពី ។ លំដាប់នោះ ព្រះយសកាកណ្ឌកបុត្តមានអាយុ ក៏បញ្ជូនទូតឲ្យទៅកាន់សំណាក់ពួកបាវេយ្យកភិក្ខុ (ភិក្ខុនៅក្នុងដែនបាវេយ្យ) ផង និងពួកអវន្តិទក្ខិណាបថកភិក្ខុផងថា បូរលោកមានអាយុទាំងឡាយនាំគ្នាមក យើងទាំងឡាយនឹងកាន់យក គឺថានឹងជម្រះនូវអធិករណ៍នេះចេញ តំណាទៅមុខ ធម៌ជាអកុសលនឹងរុងរឿងឡើង ធម៌ជាកុសលនឹងសាបសូន្យទៅ សភាវៈ មិនមែនជាវិន័យនឹងរុងរឿងឡើង វិន័យនឹងសាបសូន្យទៅ តំណាទៅមុខ ពួកបុគ្គលជាអធម្មវាទី នឹងមានកំឡាំងឡើង ពួកបុគ្គលជាធម្មវាទីនឹងថយកំឡាំងចុះ ពួកបុគ្គលជាអវិនយវាទីនឹងមានកំឡាំងឡើង ពួកបុគ្គលជាវិនយវាទី នឹងថយកំឡាំងចុះ ។

(៣០៤) សម័យនោះឯង ព្រះសម្ភូតសាណវាសីមានអាយុនៅអាស្រ័យលើភ្នំឈ្មោះអហោគង្គ ។ គ្រានោះ ព្រះយសកាកណ្ឌកបុត្តមាន

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អហោគង្គោ បព្វតោ យេនាយស្មា សម្ភូតោ សាណវាសី តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សម្ភូតំ សាណវាសឹ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា យសោ កាកណ្ឌកបុត្តោ អាយស្មន្តំ សម្ភូតំ សាណវាសឹ ឯតទវោច ឥមេ ភន្តេ វេសាលិកា វជ្ជិបុត្តកា ភិក្ខូ វេសាលិយំ ទស វត្ថូនិ ទីបេន្តិ កប្បតិ សិង្គិលោណកប្បោ កប្បតិ ទ្វង្គុលកប្បោ កប្បតិ គាមន្តរកប្បោ កប្បតិ អាវាសកប្បោ កប្បតិ អនុមតិកប្បោ កប្បតិ អាចិណ្ណកប្បោ កប្បតិ អមថិតកប្បោ កប្បតិ ជឡោគឹ បាតុំ កប្បតិ អទសកំ និសីទនំ កប្បតិ ជាតរូបរជតន្តិ ហន្ទ មយំ ភន្តេ ឥមំ អធិករណំ អាទិយាម(១) បុរេ អធម្មោ ទិប្បតិ ធម្មោ បដិពាហិយតិ អវិនយោ ទិប្បតិ វិនយោ បដិពាហិយតិ បុរេ អធម្មវាទិនោ ពលវន្តោ ហោន្តិ ធម្មវាទិនោ ទុព្វលា ហោន្តិ អវិនយវាទិនោ ពលវន្តោ ហោន្តិ វិនយវាទិនោ ទុព្វលា ហោន្តីតិ ។

---

១ ឱ· ម· អាទិយិស្សាម ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អាយុ ក៏ចូលទៅរកព្រះសម្ភូតសាណវាសី មានអាយុឯភ្នំឈ្មោះអហោគង្គ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះសម្ភូតសាណវាសី មានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះយសកាកណ្ឌកបុត្តមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ពោលពាក្យដូច្នេះនឹងព្រះសម្ភូតសាណវាសី ដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន ពួកវជ្ជីបុត្តកភិក្ខុដែលនៅក្នុងក្រុងវេសាលីនេះ សំដែងនូវវត្ថុ ១០ ប្រការ ក្នុងក្រុងវេសាលីថា ការកំណត់ដោយអម្បិលក្នុងក្លាក់ គួរ(ដល់សមណៈ) ការកំណត់ដោយស្រមោលព្រះអាទិត្យ ជ្រេប្រមាណពីរធ្នាប់ គួរ ការកំណត់ដោយចន្លោះស្រុក គួរ ការកំណត់ដោយអាវាស គួរ ការកំណត់ដោយអនុមតិ គួរ ការកំណត់ដោយអាចិណ្ណៈ (ប្រពៃណី) គួរ ការកំណត់ដោយទឹកដោះដែលមិនទាន់ជូរ គួរ ការផឹកនូវសុរាឆៅ គួរ និសីទនៈដែលមិនមានជាយ គួរ មាសនឹងប្រាក់ គួរ បពិត្រលោកម្ចាស់ដ៏ចំរើន បើដូច្នោះគួរយើងទាំងឡាយជម្រះអធិករណ៍នេះចេញ តំណទៅមុខ ធម៌ជាអកុសលនឹងរុងរឿងឡើង ធម៌ជាកុសលនឹងសាបសូន្យទៅ សភាវៈមិនមែនជាវិន័យនឹងរុងរឿងឡើង វិន័យនឹងសាបសូន្យទៅ តំណទៅមុខ ពួកបុគ្គលជាអធម្មវាទីនឹងមានកំឡាំងឡើង ពួកបុគ្គលជាធម្មវាទីនឹងថយកំឡាំងចុះ ពួកបុគ្គលជាអវិនយវាទីនឹងមានកំឡាំងឡើង ពួកបុគ្គលជាវិនយវាទីនឹងថយកំឡាំងចុះ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឯវមាវុសោតិ ខោ អាយស្មា សម្ភូតោ សាណវាសី អាយស្មតោ យសស្ស កាកណ្ឌកបុត្តស្ស បច្ចស្សោសិ ។ អថខោ សដ្ឋីមត្តា បាវេយ្យកា ភិក្ខូ សព្វេ អារញ្ញកា សព្វេ បិណ្ឌបាតិកា សព្វេ បំសុកូលិកា សព្វេ តេចីវរិកា សព្វេវ អរហន្តោ អហោគង្គេ បព្វតេ សន្និបតិំសុ ។ អសីតិមត្តា[១] អវន្តិទក្ខិណាបថកា ភិក្ខូ អប្បេកច្ចេ អារញ្ញកា អប្បេកច្ចេ បិណ្ឌបាតិកា អប្បេកច្ចេ បំសុកូលិកា អប្បេកច្ចេ តេចីវរិកា សព្វេវ អរហន្តោ អហោគង្គេ បព្វតេ សន្និបតិំសុ ។

(៣០៥) អថខោ ថេរានំ ភិក្ខូនំ មន្តយមានានំ ឯតទហោសិ ឥទំ ខោ អធិករណំ កក្ខឡញ្ច វាឡញ្ច កថំ នុ ខោ មយំ បក្ខំ លភេយ្យាម យេន មយំ ឥមស្មឹ អធិករណេ ពលវន្តតរា អស្សាមាតិ ។ តេន ខោ បន សមយេន អាយស្មា រេវតោ សោរេយ្យេ បដិវសតិ ពហុស្សុតោ អាគតាគមោ ធម្មធរោ វិនយធរោ មាតិកាធរោ បណ្ឌិតោ វិយត្តោ មេធាវី

---

១ ឱ. ម. អដ្ឋាសីតិមត្តា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



ព្រះសម្ភូតសាណវាសីមានអាយុ ក៏ទទួលពាក្យនៃព្រះយសកាកណ្ឌកបុត្ត មានអាយុថា យ៉ាងហ្នឹងហើយអាវុសោ ។ គ្រានោះឯង ពួកបាឋេយ្យកភិក្ខុប្រមាណ ៦០ រូប សុទ្ធតែជាអ្នកប្រព្រឹត្តអារញ្ញកធុតង្គ សុទ្ធតែជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ សុទ្ធតែជាអ្នកប្រព្រឹត្តបំសុកូលិកធុតង្គ សុទ្ធតែជាអ្នកប្រព្រឹត្តតេចីវរិកធុតង្គ សុទ្ធតែជាព្រះអរហន្ត ប្រជុំគ្នានៅលើភ្នំឈ្មោះអហោគង្គ ។ ឯពួកអវន្តិទក្ខិណាបថកភិក្ខុ ប្រមាណ ៨០ រូប ពួកខ្លះជាអ្នកប្រព្រឹត្តអារញ្ញកធុតង្គ ពួកខ្លះ ជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ពួកខ្លះជាអ្នកប្រព្រឹត្តបំសុកូលិកធុតង្គ ពួកខ្លះ ជាអ្នកប្រព្រឹត្តតេចីវរិកធុតង្គ សុទ្ធតែជាព្រះអរហន្ត ប្រជុំគ្នានៅលើភ្នំឈ្មោះអហោគង្គដែរ ។

[ ៣០៨ ] គ្រាកាលដែលភិក្ខុជាថេរៈទាំងឡាយ កំពុងប្រឹក្សាមានសេចក្តីត្រិះរិះដូច្នេះថា អធិករណ៍នេះឯង រឹងរូសណាស់ សាហាវណាស់ យើងទាំងឡាយ គប្បីជាបុគ្គលមានកំឡាំងក្នុងអធិករណ៍នេះ ដោយបក្សពួកណា ធ្វើដូចម្តេចយើងទាំងឡាយ គប្បីបានបក្សពួកនោះឡើង ។ សម័យនោះឯង ព្រះរេវតមានអាយុ នៅអាស្រ័យក្នុងនគរសោរេយ្យ លោកជាពហុស្សូត្រ រៀនចាំក្នុងគម្ពីរនិកាយ ហើយទ្រទ្រង់នូវធម៌ ទ្រទ្រង់នូវវិន័យ ទ្រទ្រង់នូវមាតិកា ជាបណ្ឌិតឈ្លាសវៃ មានប្រាជ្ញា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



លជ្ជី កុក្កុច្ចកោ សិក្ខាកាមោ ។ អថខោ ថេរានំ ភិក្ខូនំ ឯតទហោសិ អយំ ខោ អាយស្មា រេវតោ សោរេយ្យេ បដិវសតិ ពហុស្សុតោ អាគតាគមោ ធម្មធរោ វិនយធរោ មាតិកាធរោ បណ្ឌិតោ វិយត្តោ មេធាវី លជ្ជី កុក្កុច្ចកោ សិក្ខាកាមោ សចេ មយំ អាយស្មន្តំ រេវតំ បក្ខំ លភិស្សាម(១) ឯវំ មយំ ឥមស្មឹ អធិករណេ ពលវន្តតរា អស្សាមាតិ ។ អស្សោសិ ខោ អាយស្មា រេវតោ ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ថេរានំ ភិក្ខូនំ មន្តយមានានំ សុត្វានស្ស ឯតទហោសិ ឥទំ ខោ អធិករណំ កក្ខឡញ្ច វាឡញ្ច ន ខោ មេ តំ បដិរូបំ យោហំ ឯវរូបេ អធិករណេ ឱសក្កេយ្យំ ឥទានិ ច បន តេ ភិក្ខូ អាគច្ឆិស្សន្តិ សោហំ តេហិ អាកិណ្ណោ ន ផាសុំ វិហរិស្សាមិ(២) យន្នូនាហំ បដិកច្ចេវ គច្ឆេយ្យន្តិ ។

---

១ ឱ. លភេយ្យាម ។ ២ ឱ. គមិស្សាមិ ។ ម. ន ផាសុ គមិស្សាមិ ។

មានសេចក្ដីអៀនខ្មាស មានសេចក្ដីរង្កៀស មានប្រាថ្នានូវសិក្ខា ៗ លំដាប់នោះ ភិក្ខុជាថេរៈទាំងឡាយ មានសេចក្ដីត្រិះរិះដូច្នេះថា ព្រះរេវតមានអាយុនេះឯង នៅអាស្រ័យក្នុងនគរសោរេយ្យ លោកជាពហុស្សុត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់នូវធម៌ ទ្រទ្រង់នូវវិន័យ ទ្រទ្រង់នូវមាតិកា ជាបណ្ឌិតឈ្លាសវៃ មានប្រាជ្ញា មានសេចក្ដីអៀនខ្មាស មានសេចក្ដីរង្កៀស មានប្រាថ្នានូវសិក្ខា បើយើងទាំងឡាយបានព្រះរេវត មានអាយុ មកជាបក្ខពួក មុខជាយើងទាំងឡាយមានកំឡាំងក្លៀវក្លា ក្នុងអធិករណ៍នេះ ដោយប្រការដូច្នេះ ៗ កាលដែលភិក្ខុជាថេរៈទាំងឡាយកំពុងប្រឹក្សាគ្នា ឯព្រះរេវតមានអាយុ ក៏បានឮច្បាស់ដោយសោតធាតុ ដូចជាទិព្វស្អាតបរិសុទ្ធកន្លងបង់នូវសោតធាតុជារបស់នៃមនុស្សធម្មតា លុះឮហើយលោកមានសេចក្ដីរិះគិតដូច្នេះថា អធិករណ៍នេះ រឹងរូសណាស់ សាហាវណាស់ បើអាត្មាអញក្រាញនៅក្នុងអធិករណ៍ដូច្នេះ ហេតុនោះមិនសមគួរ ដល់អាត្មាអញឡើយ មួយទៀតភិក្ខុទាំងឡាយនោះ នឹងនាំគ្នាមកឥឡូវនេះមិនខាន អាត្មាអញសោត បើនៅប្រឡូកប្រឡំដោយភិក្ខុទាំងឡាយនោះ មុខជានៅមិនបានសេចក្ដីសប្បាយឡើយ បើដូច្នោះគួរអាត្មាអញទៅជាមុនឲ្យហើយ ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកេ រេវតត្ថេរវត្ថុ

អថខោ អាយស្មា រេវតោ សោរេយ្យា សង្កស្សំ អគ-
មាសិ ។ អថខោ ថេរា ភិក្ខូ សោរេយ្យំ គន្ត្វា បុច្ឆឹសុ
កហំ អាយស្មា រេវតោតិ ។ តេ ឯវមាហំសុ ឯសា-
យស្មា រេវតោ សង្កស្សំ គតោតិ ។ អថខោ អាយស្មា
រេវតោ សង្កស្សា កណ្ណកុជ្ជំ អគមាសិ ។ អថខោ
ថេរា ភិក្ខូ សង្កស្សំ គន្ត្វា បុច្ឆឹសុ កហំ អាយស្មា
រេវតោតិ ។ តេ ឯវមាហំសុ ឯសាយស្មា រេវតោ
កណ្ណកុជ្ជំ គតោតិ ។ អថខោ អាយស្មា រេវតោ
កណ្ណកុជ្ជា ឧទុម្ពរំ អគមាសិ ។ អថខោ ថេរា ភិក្ខូ
កណ្ណកុជ្ជំ គន្ត្វា បុច្ឆឹសុ កហំ អាយស្មា រេវតោតិ ។
តេ ឯវមាហំសុ ឯសាយស្មា រេវតោ ឧទុម្ពរំ គតោតិ ។
អថខោ អាយស្មា រេវតោ ឧទុម្ពរា អគ្គឡបុរំ អគមាសិ ។
អថខោ ថេរា ភិក្ខូ ឧទុម្ពរំ គន្ត្វា បុច្ឆឹសុ កហំ
អាយស្មា រេវតោតិ ។ តេ ឯវមាហំសុ ឯសាយស្មា
រេវតោ អគ្គឡបុរំ គតោតិ ។ អថខោ អាយស្មា រេវតោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកៈ រឿងព្រះរេវតត្ថេរ

លំដាប់នោះ ព្រះរេវតមានអាយុ ក៏ចេញអំពីនគរសោរេយ្យ ទៅកាន់នគរសង្កស្ស ។ គ្រានោះឯង ភិក្ខុជាថេរៈទាំងឡាយ ក៏នាំគ្នាទៅកាន់នគរសោរេយ្យ ហើយសួរគេថា ព្រះរេវតមានអាយុនៅក្នុងទីណា ។ មនុស្សទាំងនោះពោលយ៉ាងនេះថា ព្រះរេវតមានអាយុនុ៎ះ លោកទៅកាន់នគរសង្កស្សហើយ ។ គ្រានោះ ព្រះរេវតមានអាយុ ក៏ចេញអំពីនគរសង្កស្សហើយ ទៅកាន់នគរកណ្ណកុជ្ជទៀត ។ ទើបភិក្ខុជាថេរៈទាំងឡាយ ក៏នាំគ្នាទៅកាន់នគរសង្កស្សហើយសួរគេថា ព្រះរេវតមានអាយុ លោកនៅក្នុងទីណា ។ មនុស្សទាំងនោះពោលយ៉ាងនេះថា ព្រះរេវតមានអាយុនុ៎ះ លោកនិមន្តទៅនគរកណ្ណកុជ្ជហើយ ។ គ្រានោះឯង ព្រះរេវតមានអាយុ ចេញអំពីនគរកណ្ណកុជ្ជហើយ ទៅនគរឧទុម្ពរទៀត ។ ទើបភិក្ខុជាថេរៈទាំងឡាយ នាំគ្នាទៅកាន់នគរកណ្ណកុជ្ជហើយសួរគេថា ព្រះរេវតមានអាយុ លោកនៅក្នុងទីណា ។ មនុស្សទាំងនោះពោលយ៉ាងនេះថា ព្រះរេវតមានអាយុនុ៎ះ លោកនិមន្តទៅកាន់នគរឧទុម្ពរហើយ ។ គ្រានោះឯង ព្រះរេវតមានអាយុ ចេញអំពីនគរឧទុម្ពរហើយ ទៅកាន់នគរអគ្គឡបុរៈទៀត ។ ទើបភិក្ខុជាថេរៈទាំងឡាយ នាំគ្នាទៅកាន់នគរឧទុម្ពរហើយសួរគេថា ព្រះរេវតមានអាយុនៅក្នុងទីណា ។ មនុស្សទាំងនោះពោលយ៉ាងនេះថា ព្រះរេវតមានអាយុនុ៎ះទៅកាន់នគរគគ្គឡបុរៈហើយ ។ គ្រានោះ ព្រះរេវតមានអាយុ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៗ



អគ្គឡបុរា សហជាតឹ អគមាសិ ។ អថខោ ថេរា ភិក្ខូ អគ្គឡបុរំ គន្ត្វា បុច្ឆិំសុ កហំ អាយស្មា រេវតោតិ ។ តេ ឯវមាហំសុ ឯសាយស្មា រេវតោ សហជាតឹ គតោតិ ។ អថខោ ថេរា ភិក្ខូ អាយស្មន្តំ រេវតំ សហជាតិយា សម្ភាវេសុំ ។

(៣០៦) អថខោ អាយស្មា សម្ភូតោ សាណវាសី អាយស្មន្តំ យសំ កាកណ្ឌកបុត្តំ ឯតទវោច អយំ អាយស្មា រេវតោ ពហុស្សុតោ អាគតាគមោ ធម្មធរោ វិនយធរោ មាតិកាធរោ បណ្ឌិតោ វិយត្តោ មេធាវី លជ្ជី កុក្កុច្ចកោ សិក្ខាកាមោ សចេ មយំ អាយស្មន្តំ រេវតំ បញ្ហំ បុច្ឆិស្សាម បដិពលោ អាយស្មា រេវតោ ឯកេនេវ បញ្ហេន សកលម្បិ រត្តឹ វីតិនាមេតុំ ឥទានិ ច បនាយស្មា រេវតោ អន្តេវាសឹ សរភាណកំ ភិក្ខុំ អជ្ឈេសិស្សតិ សោ ត្វំ តស្ស ភិក្ខុនោ សរភញ្ញ-បរិយោសានេ អាយស្មន្តំ រេវតំ ឧបសង្កមិត្វា ឥមានិ ទស វត្ថូនិ បុច្ឆេយ្យាសីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា យសោ កាកណ្ឌកបុត្តោ អាយស្មតោ សម្ភូតស្ស

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



ចេញអំពីនគរអគ្គឡបុរៈ ហើយទៅកាន់នគរសហជាតិទៀត ។ ទើបភិក្ខុជាថេរៈទាំងឡាយ នាំគ្នាទៅកាន់នគរអគ្គឡបុរៈហើយសួរគេថា ព្រះរេវតដ៏មានអាយុនៅក្នុងទីណា ។ មនុស្សទាំងនោះពោលយ៉ាងនេះថា ព្រះរេវតមានអាយុនុះ ទៅកាន់នគរសហជាតិហើយ ។ លំដាប់នោះ ភិក្ខុជាថេរៈទាំងឡាយ ក៏បានទៅជួបនឹងព្រះរេវតមានអាយុក្នុងនគរសហជាតិ ។

(៣០២) គ្រានោះឯង ព្រះសម្ភូតសាណវាសីមានអាយុ បានពោលពាក្យដូច្នេះ ទៅនឹងព្រះយសកាកណ្ឌកបុត្តមានអាយុថា ម្នាលអាវុសោ ព្រះរេវតមានអាយុនេះហើយ ដែលជាពហុស្សូត ចេះចាំក្នុងគម្ពីរនិកាយ ទ្រទ្រង់នូវធម៌ ទ្រទ្រង់នូវវិន័យ ទ្រទ្រង់នូវមាតិកា ជាបណ្ឌិតឈ្លាសវៃ មានប្រាជ្ញា មានសេចក្តីអៀនខ្មាស មានសេចក្តីរង្កៀស មានប្រាថ្នានូវសិក្ខា បើយើងទាំងឡាយ សួរប្រស្នានឹងព្រះរេវតមានអាយុ ព្រះរេវតមានអាយុ អាចធ្វើឲ្យរាត្រីទាំងអស់កន្លងទៅដោយប្រស្នាតែ ១ ប៉ុណ្ណោះបាន ប៉ុន្តែឥឡូវនេះ ព្រះរេវតមានអាយុ នឹងបង្គាប់ភិក្ខុជាកូនសិស្ស ឲ្យជាអ្នកពោលនូវសរភញ្ញ (ពោលដោយសំឡេង) កាលបើចប់សរភញ្ញ របស់ភិក្ខុនោះហើយ លោកគប្បីចូលទៅជិតព្រះរេវតមានអាយុ ហើយសួរនូវវត្ថុទាំង ១០ ប្រការនេះចុះ ។ ឯព្រះយសកាកណ្ឌកបុត្តមានអាយុ ក៏ទទួលពាក្យនៃព្រះសម្ភូត-

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## សត្តសតិកក្ខន្ធកេ ទសវត្ថុបុច្ឆាវិសជ្ជនា

សាណវាសិស្ស បច្ចស្សោសិ ។ អថខោ អាយស្មា រេវតោ អន្តេវាសឹ សរភាណកំ ភិក្ខុំ អជ្ឈេសិ ។ អថខោ អាយស្មា យសោ កាកណ្ឌកបុត្តោ តស្ស ភិក្ខុនោ សរភញ្ញបរិយោសានេ យេនាយស្មា រេវតោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ រេវតំ អភិវា-ទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា យសោ កាកណ្ឌកបុត្តោ អាយស្មន្តំ រេវតំ ឯតទវោច កប្បតិ ភន្តេ សិង្គិលោណកប្បោតិ ។ កោ សោ អាវុសោ សិង្គិលោណកប្បោតិ ។ កប្បតិ ភន្តេ សិង្គិនា លោណំ បរិហរិតុំ យត្ថ អលោណកំ ភវិស្សតិ តត្ថ បរិភុញ្ជិស្សាមីតិ ។ នាវុសោ កប្បតីតិ ។ កប្បតិ ភន្តេ ទ្វង្គុលកប្បោតិ ។ កោ សោ អាវុសោ ទ្វង្គុល-កប្បោតិ ។ កប្បតិ ភន្តេ ទ្វង្គុលាយ ឆាយាយ វីតិវត្តាយ

សាណវាសីមានអាយុថា អើលោកម្ចាស់ ។ គ្រានោះ ព្រះរេវតមានអាយុ ក៏បង្គាប់ភិក្ខុជាកូនសិស្សឲ្យជាអ្នកពោលនូវសរភញ្ញ ។ លំដាប់នោះ ព្រះយសកាកណ្ឌកបុត្តមានអាយុ កាលបើចប់សរភញ្ញ របស់ភិក្ខុនោះហើយ ក៏ចូលទៅរកព្រះរេវតមានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះរេវតមានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះយសកាកណ្ឌកបុត្តមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏និយាយពាក្យនេះនឹងព្រះរេវតមានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយអំបិលក្នុងក្នាក់ គួរដែរឬ ។ ព្រះរេវតសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយអំបិលក្នុងក្នាក់នោះ តើដូចម្តេច ។ ព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ភិក្ខុរក្សានូវអំបិលដោយក្នាក់ដោយគិតថា វត្ថុសាបនឹងមានកាលណា យើងនឹងឆាន់ក្នុងកាលនោះដូច្នេះ គួរដែរឬ ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ព្រះយសកាកណ្ឌកបុត្តសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយស្រមោលព្រះអាទិត្យជ្រេប្រមាណពីរធ្នាប់ គួរដែរឬ ។ ព្រះរេវតសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយស្រមោលនៃព្រះអាទិត្យជ្រេប្រមាណពីរធ្នាប់នោះ តើដូចម្តេច ។ ព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ស្រមោលព្រះអាទិត្យកន្លងទៅប្រមាណពីរធ្នាប់ ភិក្ខុ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



វិកាលេ ភោជនំ ភុញ្ជិតុន្តិ ។ នាវុសោ កប្បតីតិ ។ កប្បតិ ភន្តេ គាមន្តរកប្បោតិ ។ កោ សោ អាវុសោ គាមន្តរកប្បោតិ ។ កប្បតិ ភន្តេ ឥទានិ គាមន្តរំ គមិស្សាមីតិ ភុត្តាវិនា បវារិតេន អនតិរិត្តំ ភោជនំ ភុញ្ជិតុន្តិ ។ នាវុសោ កប្បតីតិ ។ កប្បតិ ភន្តេ អាវាសកប្បោតិ ។ កោ សោ អាវុសោ អាវាសកប្បោតិ ។ កប្បតិ ភន្តេ សម្ពហុលា អាវាសា សមានសីមា នានុបោសថំ កាតុន្តិ ។ នាវុសោ កប្បតីតិ ។ កប្បតិ ភន្តេ អនុមតិកប្បោតិ[១] ។

---

១ សារត្ថទីបនិយំ កប្បតិ អនុមតិកប្បោតិ អនាគតានំ អាគតកាលេ អនុមតិ គហេស្សាមាតិ តេសុ អនាគតេសុយេវ វគ្គេន សង្ឃេន កម្មំ កត្វា បច្ឆា អនុមតឹ គហេតុំ កប្បតិ ។ វគ្គកម្មំ ន ហោតីតិ អធិប្បាយោតិ វុត្តំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



ឆាន់ភោជនក្នុងវេលាវិកាល គួរដែរឬ ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ព្រះយសកាកណ្ឌកបុត្តសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយចន្លោះស្រុក គួរដែរឬ ។ ព្រះរេវតសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយចន្លោះស្រុកនោះ តើដូចម្តេច ។ ព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ភិក្ខុដែលឆាន់រួចហើយ ហាមភោជនហើយ គិតថា អញនឹងទៅកាន់ចន្លោះស្រុកឥឡូវនេះ ហើយឆាន់អនតិរិត្តភោជន គឺភោជនដែលមិនបានធ្វើវិនយកម្ម ឬភោជនមិនមែនសល់ដែលអំពីភិក្ខុឈឺ គួរដែរឬ ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ព្រះយសកាកណ្ឌកបុត្តសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយអាវាស គួរដែរឬ ។ ព្រះរេវតសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយអាវាសនោះ តើដូចម្តេច ។ ព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន អាវាសច្រើននៅក្នុងសីមាជាមួយគ្នា ភិក្ខុធ្វើឧបោសថកម្មផ្សេងៗគ្នា គួរដែរឬ ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ព្រះយសកាកណ្ឌកបុត្តសួរទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយអនុមតិ (១) គួរដែរឬ ។

---

១ ក្នុងសារត្ថទីបនីថា សង្ឃគិតថា ពួកភិក្ខុដែលមិនទាន់មកដល់ លុះមកដល់ហើយ សឹមយើងកាន់យកសេចក្តីយល់ព្រម លុះគិតដូច្នេះហើយ ពួកភិក្ខុទាំងនោះមិនទាន់មកដល់នៅឡើយ សង្ឃក៏នាំគ្នាធ្វើសង្ឃកម្មជាពួក ហើយកាន់យកនូវការយល់ព្រមជាខាងក្រោយ គួរដែរ ។ កម្មជាពួកមិនមានឡើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



កោ សោ អាវុសោ អនុមតិកប្បោតិ ។ កប្បតិ ភន្តេ វគ្គេន សង្ឃេន កម្មំ កាតុំ អាគតេ ភិក្ខូ អនុមានេស្សាមាតិ[1] ។ នាវុសោ កប្បតីតិ ។ កប្បតិ ភន្តេ អាចិណ្ណកប្បោតិ ។ កោ សោ អាវុសោ អាចិណ្ណកប្បោតិ ។ កប្បតិ ភន្តេ ឥទំ មេ ឧបជ្ឈាយេន អជ្ឈាចិណ្ណំ ឥទំ មេ អាចរិយេន អជ្ឈាចិណ្ណន្តិ[2] អជ្ឈាចរិតុន្តិ ។ អាចិណ្ណកប្បោ ខោ អាវុសោ ឯកច្ចោ កប្បតិ ឯកច្ចោ ន កប្បតីតិ ។ កប្បតិ ភន្តេ អមថិតកប្បោតិ ។ កោ សោ អាវុសោ អមថិតកប្បោតិ ។ កប្បតិ ភន្តេ យំ តំ ខីរំ ខីរភាវំ វិជហិតំ អសម្បត្តំ ទធិភាវំ ភុត្តាវិនា បវារិតេន

---

១ ឱ. អនុជានេស្សាមាតិ ។ ម. អនុជានិស្សាមាតិ ។ ២ ឱ. ម. អាចិណ្ណំ តំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## សត្តសតិកក្ខន្ធកៈ ការសួរនឹងការដោះស្រាយនូវវត្ថុ ១០ ប្រការ

ព្រះរេវតសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយអនុមតិនោះ តើដូចម្តេច ៗ ព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន សង្ឃជាពួកធ្វើសង្ឃកម្ម ដោយគិតថា យើងទាំងឡាយនឹងឲ្យភិក្ខុដែលមកដល់យល់ព្រម ឬត្រេកអរជាខាងក្រោយ គួរដែរឬ ៗ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ៗ ព្រះយសកាកណ្ឌកបុត្តសួរទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយអាចិណ្ណៈគួរដែរឬ ៗ ព្រះរេវតសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយអាចិណ្ណៈតើដូចម្តេច ៗ ព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ភិក្ខុប្រព្រឹត្តដោយគិតថា អំពើនេះព្រះឧបជ្ឈាយ៍របស់យើង ធ្លាប់ប្រព្រឹត្តមកហើយ អំពើនេះអាចារ្យរបស់យើងធ្លាប់ប្រព្រឹត្តមកហើយ ដូច្នេះ គួរដែរឬ ៗ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ ការកំណត់ដោយអាចិណ្ណៈ គួរខ្លះ មិនគួរខ្លះ ៗ ព្រះយសកាកណ្ឌកបុត្ត សួរទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយទឹកដោះដែលមិនទាន់ជូរ គួរដែរឬ ៗ ព្រះរេវតសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយទឹកដោះដែលមិនទាន់ជូរនោះតើដូចម្តេច ៗ ព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ទឹកដោះស្រស់ណាដែលលះបង់ភាពជាទឹកដោះស្រស់ទៅហើយ តែនៅមិនទាន់ដល់នូវភាពជាទឹកដោះជូរនៅឡើយ ភិក្ខុឆាន់ហើយ ហាមភោជនហើយ ផឹកទឹកដោះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនតិរិត្តំ បាតុន្តិ ។ កាវុសោ កប្បតីតិ ។ កប្បតិ ភន្តេ ជលោគឹ បាតុន្តិ ។ កា សា អាវុសោ ជលោគីតិ ។ កប្បតិ ភន្តេ យា សា សុរា អសុរា[១] អសម្បត្តា មជ្ជភាវំ សា បាតុន្តិ ។ កាវុសោ កប្បតីតិ ។ កប្បតិ ភន្តេ អទសកំ និសីទនន្តិ ។ កាវុសោ កប្បតីតិ ។ កប្បតិ ភន្តេ ជាតរូបរជតន្តិ ។ កាវុសោ កប្បតីតិ ។ ឥមេ ភន្តេ វេសាលិកា វជ្ជីបុត្តកា ភិក្ខូ វេសាលិយំ ឥមានិ ទស វត្ថូនិ ទីបេន្តិ ហន្ទ មយំ ភន្តេ ឥមំ អធិករណំ អាទិយាម[២] បុរេ អធម្មោ ទិប្បតិ ធម្មោ បដិពាហិយតិ អវិនយោ ទិប្បតិ វិនយោ បដិពាហិយតិ បុរេ

---

១ ឱ. អសុរភា ។ អយំ បាឋោ មរម្មបោត្ថកេ ន ទិស្សតិ ។ ២ ឱ. ម. អាទិយិស្សាម ។

## វិនយបិដក: ចុល្លវគ្គ

ដែលជាអនតិរិត្តនោះ គឺភិក្ខុមិនបានធ្វើវិនយកម្ម ឬមិនមែនជារបស់សល់ ដែលអំពីភិក្ខុឈឺ គួរដែរឬ ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ព្រះយសកាកណ្ឌកបុត្តសួរទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន ភិក្ខុផឹកសុរាទៅ គួរដែរឬ ។ ព្រះរេវតសួរវិញថា ម្នាលអាវុសោ សុរាទៅនោះ តើដូចម្តេច ។ ព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន សុរាណាដែលខ្សោយ(១) មិនទាន់ដល់នូវភាពជាទឹកស្រវឹងនៅឡើយ ភិក្ខុផឹកសុរានោះ គួរដែរឬ ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ព្រះយសកាកណ្ឌកបុត្តសួរទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន និសីទនៈដែលមិនមានជាយគួរដែរឬ ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ព្រះយសកាកណ្ឌកបុត្តសួរទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន មាសនិងប្រាក់គួរដែរឬ ។ ព្រះរេវតឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ទើបព្រះយសកាកណ្ឌកបុត្តពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលីទាំងនេះ សំដែងវត្ថុទាំង ១០ ប្រការនេះ ក្នុងក្រុងវេសាលី បពិត្រលោកម្ចាស់ដ៏ចំរើន បើដូច្នោះគួរតែយើងរាល់គ្នាជំរះនូវអធិករណ៍នេះចេញ តំណាទៅមុខ ធម៌ជាអកុសលនឹងរុងរឿងឡើង ធម៌ជាកុសលនឹងសាបសូន្យទៅ សភាវៈមិនមែនជាវិន័យនឹងរុងរឿងឡើង វិន័យនឹងសាបសូន្យទៅ តំណាទៅមុខ

---

១ ក្នុងវិមតិវិនោទនីហា សុរាដែលគេផ្សំដោយគ្រឿងប្រុងរួចហើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អធម្មវាទិនោ ពលវន្តោ ហោន្តិ ធម្មវាទិនោ ទុព្វលា ហោន្តិ អវិនយវាទិនោ ពលវន្តោ ហោន្តិ វិនយវាទិនោ ទុព្វលា ហោន្តីតិ ។ អថ ខោ អាយស្មា រេវតោ អាយស្មតោ យសស្ស កាកណ្ឌកបុត្តស្ស បច្ចស្សោសិ ។

បឋមភាណវារំ ។

[៣០៧] អស្សោសុំ ខោ វេសាលិកា វជ្ជិបុត្តកា ភិក្ខូ យសោ កិរ កាកណ្ឌកបុត្តោ ឥមំ អធិករណំ អាទិយិតុកាមោ បក្ខំ បរិយេសតិ លភតិ ច កិរ បក្ខន្តិ ។ អថ ខោ វេសាលិកានំ វជ្ជិបុត្តកានំ ភិក្ខូនំ ឯតទហោសិ ឥទំ ខោ អធិករណំ កក្ខឡំ វាឡំ កំ[១] នុ ខោ មយំ បក្ខំ លភេយ្យាម យេន មយំ ឥមស្មឹ អធិករណេ ពលវន្តតរា អស្សាមាតិ ។ អថ ខោ វេសាលិកានំ វជ្ជិបុត្តកានំ ភិក្ខូនំ ឯតទហោសិ អយំ ខោ អាយស្មា រេវតោ ពហុស្សុតោ អាគតាគមោ ធម្មធរោ វិនយធរោ មាតិកាធរោ បណ្ឌិតោ វិយត្តោ មេធាវី លជ្ជី កុក្កុច្ចកោ សិក្ខាកាមោ

១ ម. កំ នុ ខោ ។

បុគ្គលជាអធម្មវាទីនឹងមានកំឡាំងឡើង បុគ្គលជាធម្មវាទីនឹងថយកំឡាំងចុះ បុគ្គលជាអវិនយវាទី នឹងមានកំឡាំងឡើង បុគ្គលជាវិនយវាទី នឹងថយកំឡាំងចុះ ។ ឯព្រះរេវតមានអាយុ ទទួលពាក្យព្រះយសកាកណ្ឌកបុត្តមានអាយុថា ម្នាលអាវុសោ យ៉ាងហ្នឹងហើយ ។

ចប់ ភាណវារៈ ទី ១ ។

[៣០៧] ឯពួកវជ្ជីបុត្តកភិក្ខុដែលនៅក្នុងក្រុងវេសាលី បានឮដំណឹងថា ព្រះយសកាកណ្ឌកបុត្ត ប្រាថ្នានឹងជម្រះនូវអធិករណ៍នេះ ខំស្វែងរកបក្ខពួក ក៏ឮថា ឥឡូវនេះបានបក្ខពួកហើយ ។ គ្រានោះឯង ពួកវជ្ជីបុត្តកភិក្ខុដែលនៅក្នុងក្រុងវេសាលី មានសេចក្តីត្រិះរិះគិតដូច្នេះថា អធិករណ៍នេះរឹងរូសណាស់ សាហាវណាស់ យើងទាំងឡាយគប្បីជាបុគ្គលមានកំឡាំងក្រៀវក្រាក្នុងអធិករណ៍នេះ ដោយបក្ខពួកណា ធ្វើដូចម្តេច យើងទាំងឡាយគប្បីបាននូវបក្ខពួកនោះឡើង ។ លំដាប់នោះ ពួកវជ្ជីបុត្តកភិក្ខុដែលនៅក្នុងក្រុងវេសាលី មានសេចក្តីត្រិះរិះគិតឃើញដូច្នេះថា ព្រះរេវតមានអាយុនេះឯង លោកជាពហុស្សូត្រ ចេះចាំក្នុងគម្ពីរនិកាយ ជាអ្នកទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ជាបណ្ឌិតឈ្លាសវៃ មានប្រាជ្ញា មានសេចក្តីអៀនខ្មាស មានសេចក្តីរង្កៀស មានប្រាថ្នានូវសិក្ខា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សចេ មយំ អាយស្មន្តំ រេវតំ បក្ខំ លភេយ្យាម ឯវំ មយំ ឥមស្មឹ អធិករណេ ពលវន្តតរា អស្សាមាតិ ។ អថខោ វេសាលិកា វជ្ជិបុត្តកា ភិក្ខូ បហូតំ សាមណកំ បរិក្ខារំ បដិយាទេសុំ បត្តម្បិ ចីវរម្បិ និសីទនម្បិ សូចិឃរម្បិ កាយពន្ធនម្បិ បរិស្សាវនម្បិ ធម្មករកម្បិ[(១)] ។ អថខោ វេសាលិកា វជ្ជិបុត្តកា ភិក្ខូ តំ សាមណកំ បរិក្ខារំ អាទាយ នាវាយ សហជាតឹ ឧជ្ជវិំសុ នាវាយ បច្ចោរោហិត្វា អញ្ញតរស្មឹ រុក្ខមូលេ ភត្តវិសគ្គំ ករោន្តិ ។

(៣០៨) អថខោ អាយស្មតោ សាឡ្ហស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ កេ នុ ខោ ធម្មវាទិនោ បាចីនកា វា ភិក្ខូ បាវេយ្យកា វាតិ ។ អថខោ អាយស្មតោ សាឡ្ហស្ស ធម្មញ្ច វិនយញ្ច បច្ចវេក្ខន្តស្ស ឯតទហោសិ អធម្មវាទិនោ បាចីនកា ភិក្ខូ ធម្មវាទិនោ បាវេយ្យកា ភិក្ខូតិ ។ អថខោ អញ្ញតរា សុទ្ធាវាសកាយិកា ទេវតា អាយស្មតោ សាឡ្ហស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ

---

១ ម. ធម្មករណំបិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បើយើងទាំងឡាយបាននូវព្រះរេវតមានអាយុជាបក្ខពួកហើយ យើងទាំងឡាយនឹងមានកំឡាំងក្លៀវក្លា ក្នុងអធិករណ៍នេះ ដោយអាការយ៉ាងនេះមិនខាន ។ ទើបពួកវជ្ជីបុត្តកភិក្ខុដែលនៅក្នុងក្រុងវេសាលី នាំគ្នាពាក់ចែងគ្រឿងបរិក្ខាររបស់សមណៈជាច្រើនគឺ បាត្រផង ចីវរផង សំពត់និសីទនៈផង បំពង់ម្ជុលផង វត្ថពន្ធបន្ទុះផង សំពត់តម្រងទឹកផង ធម្មក្រកផង។ គ្រានោះឯង ពួកវជ្ជីបុត្តកភិក្ខុដែលនៅក្នុងក្រុងវេសាលី នាំគ្នាយកគ្រឿងបរិក្ខារជារបស់សមណៈនោះ ហើយជិះទូកចុះឡើងទៅកាន់នគរសហជាតិលុះចុះអំពីទូកហើយ ក៏ឈប់ធ្វើភត្តកិច្ចក្រោមម្លប់ដើមឈើ ១ ។

(៣០៨) គ្រានោះ ព្រះសាឡ្ហៈមានអាយុ ទៅកាន់ទីស្ងាត់សម្ងំនៅក្នុងព្រះកម្មដ្ឋាន មានបរិវិតក្កៈកើតឡើងយ៉ាងនេះថា ពួកភិក្ខុណាហ្ន៎ដែលជាធម្មវាទី ពួកភិក្ខុអ្នកនៅខាងបាចីនទិស (ទិសខាងកើត) ឬថា ពួកភិក្ខុដែលនៅក្នុងដែនបាវេយ្យ ។ គ្រាកាលដែលព្រះសាឡ្ហៈមានអាយុពិចារណានូវធម៌និងវិន័យ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ពួកភិក្ខុដែលនៅខាងបាចីនទិសជាអធម្មវាទី ឯពួកភិក្ខុដែលនៅក្នុងដែនបាវេយ្យ ជាធម្មវាទី ។ លំដាប់នោះ ទេវតាមួយអង្គនៅក្នុងពួកសុទ្ធាវាសព្រហ្ម បានដឹងនូវសេចក្តីត្រិះរិះក្នុងចិត្តរបស់ព្រះសាឡ្ហៈមានអាយុ ដោយចិត្តរបស់ខ្លួនហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ សុទ្ធាវាសេសុ ទេវេសុ អន្តរហិតា អាយស្មតោ សាឡ្ហស្ស សម្មុខេ បាតុរហោសិ ។ អថខោ សា ទេវតា អាយស្មន្តំ សាឡ្ហំ ឯតទវោច សាធុ សាធុ[១] ភន្តេ សាឡ្ហ អធម្មវាទិនោ បាចីនកា ភិក្ខូ ធម្មវាទិនោ បាវេយ្យកា ភិក្ខូ តេនហិ ភន្តេ សាឡ្ហ យថា ធម្មោ តថា តិដ្ឋាហីតិ ។ បុព្វេ ចាហំ ទេវតេ ឯតរហិ ច យថា ធម្មោ តថា ឋិតោ អបិចាហំ ន តាវ ទិដ្ឋឹ អាវិករោមិ អប្បេវនាម[២] មំ ឥមស្មឹ អធិករណេ សម្មន្នេយ្យាតិ ។

(៣០៩) អថខោ វេសាលិកា វជ្ជិបុត្តកា ភិក្ខូ តំ សាមណកំ បរិក្ខារំ អាទាយ យេនាយស្មា រេវតោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មន្តំ រេវតំ ឯតទវោចុំ បដិគ្គណ្ហាតុ ភន្តេ ថេរោ សាមណកំ បរិក្ខារំ បត្តម្បិ ចីវរម្បិ និសីទនម្បិ

---

១ ឱ. ម. សាធូតិ សទ្ទោ ឯកោយេវ ទិស្សតិ ។ ២ ឱ. ម. អប្បេវ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកៈ រឿងវជ្ជីបុត្តកភិក្ខុ

ក៏ចុះអំពីឋានទេវលោកជាន់សុទ្ធាវាស មកប្រាកដក្នុងទីចំពោះមុខ នៃព្រះសាឡ្ហៈមានអាយុ ដោយរហ័សក្លាម ប្រៀបដូចជាបុរសដែលមានកំឡាំង លាចេញនូវដើមដៃដែលខ្លួនបត់ចូល ឬថា បត់ចូលនូវដើមដៃដែលខ្លួនលាចេញ ។ ទើបទេវតានោះ ពោលពាក្យនេះនឹងព្រះសាឡ្ហៈមានអាយុថា បពិត្រលោកម្ចាស់សាឡ្ហៈដ៏ចំរើន សេចក្តីត្រិះរិះរបស់លោកម្ចាស់ ប្រពៃណាស់ហើយ ពួកភិក្ខុដែលនៅខាងបាចីនទិស ជាអធម្មវាទី ឯពួកភិក្ខុដែលនៅក្នុងដែនបាវេយ្យ ជាធម្មវាទី បពិត្រលោកម្ចាស់សាឡ្ហៈដ៏ចំរើន បើដូច្នោះ ធម៌យ៉ាងណា សូមលោកម្ចាស់ឋិតនៅយ៉ាងនោះចុះ ។ ព្រះសាឡ្ហៈពោលថា ម្នាលទេវតា កាលពីដើមក្តី ឥឡូវនេះក្តី ធម៌យ៉ាងណា អាត្មាឋិតនៅយ៉ាងនោះ ប៉ុន្តែអាត្មាមិនទាន់ធ្វើឲ្យជាក់ច្បាស់នូវទិដ្ឋិ គឺសេចក្តីយល់ សេចក្តីចូលចិត្តនៅឡើយ ធ្វើដូចម្តេច គប្បីឲ្យសង្ឃសន្មតអាត្មាក្នុងអធិករណ៍នេះឯង ។

(៣០៩) គ្រានោះ ពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី នាំគ្នាកាន់យកនូវគ្រឿងបរិក្ខារ ជារបស់សមណៈនោះ ហើយចូលទៅរកព្រះរេវតមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យដូច្នេះ នឹងព្រះរេវតមានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមព្រះថេរៈជាម្ចាស់ទទួលយកនូវបរិក្ខារជារបស់សមណៈ គឺបាត្រផង ចីវរផង សំពត់និសីទនៈ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



សូចិយម្បិ កាយពន្ធនម្បិ បរិស្សាវនម្បិ ធម្មករកម្បីតិ ។ អលំ អាវុសោ បរិបុណ្ណំ មេ តិចីវរន្តិ ន ឥច្ឆិ បដិគ្គហេតុំ ។ តេន ខោ បន សមយេន ឧត្តរោ នាម ភិក្ខុ វីសតិវស្សោ អាយស្មតោ រេវតស្ស ឧបដ្ឋាកោ ហោតិ ។ អថខោ វេសាលិកា វជ្ជិបុត្តកា ភិក្ខូ យេនាយស្មា ឧត្តរោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មន្តំ ឧត្តរំ ឯតទវោចុំ បដិគ្គណ្ហាតុ អាយស្មា ឧត្តរោ សាមណកំ បរិក្ខារំ បត្តម្បិ ចីវរម្បិ និសីទនម្បិ សូចិយម្បិ កាយពន្ធនម្បិ បរិស្សាវនម្បិ ធម្មករកម្បីតិ ។ អលំ អាវុសោ បរិបុណ្ណំ មេ តិចីវរន្តិ ន ឥច្ឆិ បដិគ្គហេតុំ ។ មនុស្សា ខោ អាវុសោ ឧត្តរ ភគវតោ សាមណកំ បរិក្ខារំ ឧបនាមេន្តិ សចេ ភគវា បដិគ្គណ្ហាតិ តេនេវ តេ អត្តមនា ហោន្តិ នោ ចេ ភគវា បដិគ្គណ្ហាតិ អាយស្មតោ ច[1] អានន្ទស្ស ឧបនាមេន្តិ បដិគ្គណ្ហាតុ ភន្តេ ថេរោ

១ អយំ បាឋោ ឱ. ម. បោត្ថកេសុ ន ទិស្សតិ ។ ( អយស្មោ វ )

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ផង បំពង់ម្ជុលផង វត្ថពន្ធចង្កេះផង សំពត់តម្រងទឹកផង ធម្មក្រកផង ៗ ព្រះរេវតមិនប្រាថ្នានឹងទទួលដោយពាក្យថា ម្នាលអាវុសោទាំងឡាយ កុំឡើយ ខ្ញុំមានត្រៃចីវរគ្រប់គ្រាន់ហើយ ៗ សម័យនោះឯង មានភិក្ខុ ១ រូបឈ្មោះឧត្តរៈ បួសបាន ២០ វស្សា ជាឧបដ្ឋាករបស់ព្រះរេវតមានអាយុ ៗ លំដាប់នោះ ពួកវជ្ជីបុត្តកភិក្ខុដែលនៅក្នុងក្រុងវេសាលី ក៏ចូលទៅរកព្រះឧត្តរៈមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យដូច្នេះនឹងព្រះឧត្តរៈមានអាយុថា ព្រះឧត្តរៈមានអាយុ ចូរទទួលយកគ្រឿងបរិក្ខារជារបស់សមណៈ គឺបាត្រផង ចីវរផង សំពត់និសីទនៈផង បំពង់ម្ជុលផង វត្ថពន្ធចង្កេះផង សំពត់តម្រងទឹកផង ធម្មក្រកផង ៗ ព្រះឧត្តរៈមិនប្រាថ្នានឹងទទួលដោយពាក្យថា ម្នាលអាវុសោទាំងឡាយ កុំឡើយ ខ្ញុំមានត្រៃចីវរគ្រប់គ្រាន់ហើយ ៗ ពួកវជ្ជីបុត្តកភិក្ខុ ពោលអង្វរថា ម្នាលព្រះឧត្តរៈមានអាយុ មនុស្សទាំងឡាយតែងបង្អោនគ្រឿងបរិក្ខារ ជារបស់សមណៈថ្វាយ ចំពោះព្រះមានព្រះភាគ បើព្រះមានព្រះភាគ ទ្រង់ទទួលយក មនុស្សទាំងនោះ រមែងមានចិត្តត្រេកអរ ដោយការទទួលរបស់ព្រះមានព្រះភាគនោះឯង បើព្រះមានព្រះភាគ មិនទ្រង់ទទួលទេ មនុស្សទាំងនោះ តែងបង្អោនទៅ ដើម្បីព្រះអានន្ទមានអាយុ ដោយពាក្យថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមព្រះថេរៈជាម្ចាស់ ទទួលយក

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកេ វជ្ជិបុត្តកភិក្ខុវត្ថុ

សាមណកំ បរិក្ខារំ យថា ភគវតា បដិគ្គហិតោ ឯវមេវ សោ[១] កិស្សុតីតិ បដិគ្គណ្ហាតាយស្មា ឧត្តរោ សាមណកំ បរិក្ខារំ យថា ថេរេន បដិគ្គហិតោ ឯវមេវ សោ កិស្សុតីតិ ។ អថខោ អាយស្មា ឧត្តរោ វេសាលិកេហិ វជ្ជិបុត្តកេហិ ភិក្ខូហិ និប្បីឡិយមានោ ឯកំ ចីវរំ អគ្គហេសិ វទេយ្យាថ អាវុសោ យេន អត្ថោតិ ។ ឯត្តកំ អាយស្មា ឧត្តរោ ថេរំ វទេតុ ឯត្តកំ[២] ភន្តេ ថេរោ សង្ឃមជ្ឈេ វទេតុ បុរត្ថិមេសុ ជនបទេសុ ពុទ្ធា ភគវន្តោ ឧប្បជ្ជន្តិ ធម្មវាទិនោ[៣] បាចីនកា ភិក្ខូ អធម្មវាទិនោ បាវេយ្យកា ភិក្ខូតិ ។ ឯវមាវុសោតិ ខោ អាយស្មា ឧត្តរោ វេសាលិកានំ វជ្ជិបុត្តកានំ ភិក្ខូនំ បដិស្សុត្វា យេនាយស្មា រេវតោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ រេវតំ ឯតទវោច ឯត្តកំ ភន្តេ ថេរោ សង្ឃមជ្ឈេ វទេតុ បុរត្ថិមេសុ ជនបទេសុ ពុទ្ធា ភគវន្តោ ឧប្បជ្ជន្តិ

---

១ ឱ. ឯវមេសោ ។ ២ ម. ឯត្តកញ្ច ។ ៣ ឱ. ម. ធម្មវាទី ។

## សត្តសតិកក្ខន្ធកៈ រឿងវជ្ជីបុត្តកភិក្ខុ

គ្រឿងបរិក្ខារជារបស់សមណៈចុះ បរិក្ខារនោះ ក៏ដូចជាព្រះមានព្រះភាគទទួលយកដែរ សូមព្រះទត្តៈមានអាយុ ទទួលយកគ្រឿងបរិក្ខារជារបស់សមណៈចុះ បរិក្ខារនោះ ដូចជាព្រះថេរៈបានទទួលយកដែរ ៗ គ្រានោះ ព្រះទត្តៈមានអាយុ កាលបើពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលី បង្ខិតបង្ខំហើយក៏ទទួលយកតែចីវរ ១ ដោយពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយត្រូវការដោយពាក្យណា ក៏គប្បីពោលពាក្យនោះចុះ ៗ ឯពួកវជ្ជីបុត្តកភិក្ខុ ពោលតបវិញថា សូមព្រះទត្តៈមានអាយុ ទៅនិយាយពាក្យប៉ុណ្ណោះនឹងព្រះថេរៈថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមព្រះថេរៈទៅនិយាយពាក្យប៉ុណ្ណោះ ក្នុងកណ្តាលសង្ឃថា ព្រះពុទ្ធទ្រង់ព្រះភាគ កើតឡើងក្នុងជនបទទាំងឡាយដែលតាំងនៅក្នុងទិសខាងកើត ពួកភិក្ខុដែលនៅក្នុងទិសខាងកើត ជាធម្មវាទី ឯពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ ជាអធម្មវាទី ៗ ព្រះទត្តៈមានអាយុ ទទួលពាក្យពួកវជ្ជីបុត្តកភិក្ខុ ដែលនៅក្នុងក្រុងវេសាលីថា អើអាវុសោ ហើយក៏ចូលទៅរកព្រះរេវតមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យដូច្នេះ នឹងព្រះរេវតមានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមព្រះថេរៈជាម្ចាស់ ទៅពោលពាក្យប៉ុណ្ណោះក្នុងកណ្តាលសង្ឃថា ព្រះពុទ្ធទ្រង់ព្រះភាគ កើតឡើងក្នុងជនបទទាំងឡាយ ដែលតាំងនៅក្នុងទិសខាងកើត ពួកភិក្ខុដែលនៅក្នុង

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ធម្មវាទិនោ បាចីនកា ភិក្ខូ អធម្មវាទិនោ បាវេយ្យកា ភិក្ខូតិ ។ អធម្មេ មំ ត្វំ ភិក្ខុ និយោជេសីតិ ថេរោ អាយស្មន្តំ ឧត្តរំ បណាមេសិ ។ អថខោ វេសាលិកា វជ្ជិបុត្តកា ភិក្ខូ អាយស្មន្តំ ឧត្តរំ ឯតទវោចុំ កឹ អាវុសោ ឧត្តរ ថេរោ អាហាតិ ។ បាបិកំ នោ អាវុសោ កតំ អធម្មេ មំ ត្វំ ភិក្ខុ និយោជេសីតិ ថេរោ មំ បណាមេសីតិ ។ ននុ ត្វំ អាវុសោ ឧត្តរ វុឌ្ឍោ វីសតិវស្សោសីតិ ។ អាមាវុសោ អបិច មយំ គរុនិស្សយំ គណ្ហាមាតិ ។

(១១០) អថខោ សង្ឃោ តំ អធិករណំ វិនិច្ឆិនិតុកាមោ សន្និបតិ ។ អថខោ អាយស្មា រេវតោ សង្ឃំ ញាបេសិ សុណាតុ មេ អាវុសោ សង្ឃោ សចេ មយំ ឥមំ អធិករណំ ឥធ វូបសមេស្សាម[១] សិយាបិ មូលាទាយកា[២] ភិក្ខូ បុនក្កម្មាយ ឧក្កោដេយ្យុំ ។ យទិ សង្ឃស្ស បត្តកល្លំ យត្ថេវិមំ អធិករណំ សមុប្បន្នំ សង្ឃោ តត្ថេវិមំ អធិករណំ វូបសមេយ្យាតិ ។

---

១ ឱ. វូបសមេយ្យាម ។ ២ មូលាយកាតិបិ បាឋោ អត្ថិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ទំសខាងកើតជាធម្មវាទី ឯពួកភិក្ខុដែលនៅក្នុងដែនបាវេយ្យ ជាអធម្មវាទី ។ ព្រះថេរៈពោលតបវិញថា នែភិក្ខុ អ្នកឯងបញ្ចូលយើងទៅក្នុងធម៌ជាអកុសល ថាហើយក៏បណ្ដេញព្រះឧត្តរៈមានអាយុចេញទៅ ។ គ្រានោះ ពួកវជ្ជីបុត្តកភិក្ខុដែលនៅក្នុងក្រុងវេសាលី ពោលសួរដូច្នេះ នឹងព្រះឧត្តរៈមានអាយុថា ម្នាលឧត្តរៈមានអាយុ ព្រះថេរៈនិយាយ ថា ដូចម្ដេចខ្លះ ។ ព្រះឧត្តរៈប្រាប់ថា ម្នាលអាវុសោទាំងឡាយ យើងទាំងឡាយ ធ្វើអំពើអាក្រក់ហើយ ព្រះថេរៈពោលថា ម្នាលភិក្ខុ អ្នកឯងបញ្ចូលយើងទៅក្នុងធម៌ជាអកុសល ថាហើយក៏បណ្ដេញខ្ញុំចេញមក ។ ពួកវជ្ជីបុត្តកភិក្ខុពោលថា ម្នាលឧត្តរៈមានអាយុ ក្រែងលោកជាភិក្ខុចាស់ មានវស្សា ២០ ហើយឬ ។ ព្រះឧត្តរៈឆ្លើយថា អើអាវុសោទាំងឡាយ មែនហើយ ប៉ុន្តែយើងទាំងឡាយ កាន់យកនិស្ស័យនឹងលោកជាគ្រូនៅឡើយ ។

(៣១០) គ្រានោះ សង្ឃប្រាថ្នានឹងវិនិច្ឆ័យកាត់សេចក្ដីអធិករណ៍នោះ ក៏ប្រជុំគ្នា ។ លំដាប់នោះ ព្រះរេវតមានអាយុ បានប្រកាសសង្ឃឲ្យដឹងថា ម្នាលអាវុសោ សូមសង្ឃស្ដាប់ខ្ញុំ បើយើងទាំងឡាយនឹងរម្ងាប់អធិករណ៍នេះ ក្នុងទីនេះ មុខជានឹងមានពួកភិក្ខុ ដែលជាអ្នកកាន់យកវត្ថុទាំង ១០ ពីមុន ភិក្ខុទាំងនោះគប្បីសើរើ ដើម្បីកម្មថ្មីទៀតមិនខានឡើយ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អថខោ ថេរា ភិក្ខូ វេសាលឹ អគមំសុ តំ អធិករណំ វិនិច្ឆិនិតុកាមា ។ តេន ខោ បន សមយេន សព្ពកាមី នាម បថព្យា សង្ឃត្ថេរោ វីសវស្សសតិកោ[១] ឧបសម្បទាយ អាយស្មតោ អានន្ទស្ស សទ្ធិវិហារិកោ វេសាលិយំ បដិវសតិ ។ អថខោ អាយស្មា រេវតោ អាយស្មន្តំ សម្ភូតំ សាណវាសឹ ឯតទវោច អហំ អាវុសោ យស្មឹ វិហារេ សព្ពកាមី ថេរោ វិហរតិ តំ វិហារំ ឧបគច្ឆាមិ សោ ត្វំ កាលស្សេវ អាយស្មន្តំ សព្ពកាមឹ ឧបសង្កមិត្វា ឥមានិ ទស វត្ថូនិ បុច្ឆេយ្យាសីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា សម្ភូតោ សាណវាសី អាយស្មតោ រេវតស្ស បច្ចស្សោសិ ។ អថខោ អាយស្មា រេវតោ យស្មឹ វិហារេ សព្ពកាមី ថេរោ វិហរតិ តំ វិហារំ ឧបគញ្ឆិ ។ គព្ភេ អាយស្មតោ សព្ពកាមិស្ស សេនាសនំ បញ្ញត្តំ ហោតិ ។ គព្ភប្បមុខេ អាយស្មតោ រេវតស្ស ។ អថខោ អាយស្មា រេវតោ

១ ឱ. វីសំវស្សសតិកោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



បើកម្មមានកាលគួរដល់សង្ឃហើយ អធិករណ៍នេះ កើតឡើងក្នុងទីណា សង្ឃត្រូវរម្ងាប់អធិករណ៍នេះ ក្នុងទីនោះវិញ ។ គ្រានោះ ភិក្ខុជាថេរៈទាំងឡាយ ប្រាថ្នានឹងវិនិច្ឆ័យនូវអធិករណ៍នោះ ក៏នាំគ្នាទៅកាន់ក្រុងវេសាលី ។ សម័យនោះឯង មានភិក្ខុ ១ រូបឈ្មោះសព្វកាមី(១) មានវស្សា ១២០ តាំងអំពីឧបសម្បទាមក ជាសទ្ធិវិហារិករបស់ព្រះអានន្ទមានអាយុ លោកជាសង្ឃត្ថេរ (ធំ) លើផែនដី នៅអាស្រ័យក្នុងក្រុងវេសាលី ។ លំដាប់នោះ ព្រះរេវតមានអាយុ ពោលពាក្យដូច្នេះ នឹងព្រះសម្ភូតសាណវាសីមានអាយុថា ម្នាលអាវុសោ ព្រះសព្វកាមីត្ថេរ នៅក្នុងវិហារណា ខ្ញុំនឹងទៅកាន់វិហារនោះដែរ លោកគប្បីចូលទៅរកព្រះសព្វកាមីមានអាយុអំពីព្រឹក ហើយសួរវត្ថុ១០ប្រការនេះ ។ ព្រះសម្ភូតសាណវាសីមានអាយុ ទទួលពាក្យព្រះរេវតមានអាយុថា អើលោកម្ចាស់ ។ លំដាប់នោះ ព្រះសព្វកាមីត្ថេរ គង់នៅក្នុងវិហារណា ព្រះរេវតមានអាយុ ក៏ចូលទៅកាន់វិហារនោះដែរ ។ សេនាសនៈគេក្រាលទុកសម្រាប់ព្រះសព្វកាមីមានអាយុ នៅក្នុងល្វែង ។ សេនាសនៈដែលគេក្រាលទុក សម្រាប់ព្រះរេវតៈមានអាយុ ក្នុងល្វៀងនៃល្វែង ។ លំដាប់នោះ ព្រះរេវតមានអាយុ

---

២ ក្នុងវិមតិវិនោទនីយា ព្រះថេរៈ នោះចាស់ជាងភិក្ខុទាំងអស់ក្នុងលោក ក្នុងគ្រានោះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អយំ ថេរោ មហល្លកោ ន និបជ្ជតីតិ ន សេយ្យំ កប្បេតិ(១) ។ អាយស្មា សព្វកាមី អយំ ភិក្ខុ អាគន្តុកោ កិលន្តោ ន និបជ្ជតីតិ ន សេយ្យំ កប្បេសិ ។

[៣១១] អថខោ អាយស្មា សព្វកាមី រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ(២) អាយស្មន្តំ រេវតំ ឯតទវោច កតមេន ត្វំ ភុម្មិ វិហារេន ឯតរហិ ពហុលំ វិហរសីតិ ។ មេត្តាវិហារេន ខោ អហំ ភន្តេ ឯតរហិ ពហុលំ វិហរាមីតិ ។ កុល្លកវិហារេន កិរ ត្វំ ភុម្មិ ឯតរហិ ពហុលំ វិហរសិ(៣) កុល្លកវិហារោ ហេសោ(៤) ភុម្មិ យទិទំ មេត្តាតិ ។ បុព្វេបិ មេ ភន្តេ គិហិភូតស្ស អាចិណ្ណា មេត្តា តេនាហំ ឯតរហិបិ មេត្តាវិហារេន ពហុលំ វិហរាមិ អបិច មយា ចិរប្បត្តំ អរហត្តំ(៥) ថេរោ បន ភន្តេ កតមេន វិហារេន ឯតរហិ ពហុលំ វិហរតីតិ ។ សុញ្ញតាវិហារេន ខោ អហំ ភុម្មិ ឯតរហិ ពហុលំ វិហរាមីតិ ។ មហាបុរិសវិហារេន កិរ ភន្តេ

---

១ ឱ. ម. កប្បេសិ ។ ២ ឱ. ពោត្ថកេសុ បច្ចុដ្ឋាយាតិ ចេទំ ន ទិស្សតិ ។ ៣ ម. វិហរសីតិ ។ ៤ ឱ. ម. ឯសោ ។ ៥ ម. អរហត្តន្តិ ។

លោកមិនបានសិងដោយគិតថា ព្រះថេរៈនេះមានបំណាស់ហើយ លោកមិនទាន់សិងនៅឡើយ ។ ឯព្រះសព្វកាមីមានអាយុ លោកក៏មិនសិងដោយគិតថា ភិក្ខុនេះជាអាគន្តុកៈ មានសេចក្តីទឿយព្រួយ លោកក៏មិនសិងដែរ ។

(៣១១) គ្រានោះ ព្រះសព្វកាមីមានអាយុ ក្រោកឡើងក្នុងសម័យភ្លឺស្វាងនៃរាត្រី ហើយក៏ពោលដូច្នេះ នឹងព្រះរេវតមានអាយុថា ម្នាលលោកដ៏ចំរើន ឥឡូវនេះ លោកច្រើននៅដោយធម៌ជាគ្រឿងនៅដូចម្តេច ។ ព្រះរេវតឆ្លើយថា បពិត្រព្រះករុណាដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះករុណាច្រើននៅដោយធម៌ ជាគ្រឿងនៅ គឺមេត្តា ។ ព្រះសព្វកាមីពោលថា ម្នាលលោកដ៏ចំរើន ឮថា ឥឡូវនេះ លោកច្រើននៅដោយធម៌ជាគ្រឿងនៅបន្តិចបន្តួច(១) ម្នាលលោកដ៏ចំរើន ក៏ឯធម៌ជាគ្រឿងនៅបន្តិចបន្តួចនេះ គឺមេត្តានេះឯង ។ ព្រះរេវតពោលថា បពិត្រព្រះករុណាដ៏ចំរើន កាលពីដើមដែលខ្ញុំនៅជាគ្រហស្ថនៅឡើយ តែងសន្សំមេត្តាធម៌ ព្រោះហេតុនោះ បានជាក្នុងកាលឥឡូវនេះ ខ្ញុំច្រើននៅដោយធម៌ជាគ្រឿងនៅគឺមេត្តា ម្យ៉ាងទៀត ខ្ញុំបានសម្រេចនូវព្រះអរហត្ត ជាយូរដែរហើយ

២ ក្នុងសារត្ថទីបនីថា ធម៌ជាគ្រឿងនៅដ៏តូច មិនជ្រៅ ឬ ភក់ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ផ្ញើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។





ថេរោ ឯតរហិ ពហុលំ វិហរតិ មហាបុរិសវិហារោ ឯសោ ភន្តេ យទិទំ សុញ្ញតាតិ ។ បុព្វេបិ មេ ភុម្មិ គិហិភូតស្ស អាចិណ្ណា សុញ្ញតា តេនាហំ ឯតរហិបិ សុញ្ញតាវិហារេន ពហុលំ វិហរាមិ អបិច មយា ចិរបត្តំ អរហត្តន្តិ ។

[៣១២] អយញ្ចរហិ ថេរានំ ភិក្ខូនំ អន្តរាកថា វិប្បកតា ។ អថាយស្មា សម្ភូតោ សាណវាសី(១) អនុប្បត្តោ ហោតិ ។ អថខោ អាយស្មា សម្ភូតោ សាណវាសី យេនាយស្មា សព្វកាមី តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សព្វកាមឹ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សម្ភូតោ សាណវាសី អាយស្មន្តំ សព្វកាមឹ ឯតទវោច

១ ឥតោ បរំ ឧភោបិយមរម្មពោត្ថកេសុ តស្មិន្តិ ឋានេ ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកៈ ពាក្យជាបន្ទោះរបស់ពួកភិក្ខុជាថេរៈ

បពិត្រព្រះថេរ ដ៏ចំរើន ចុះចំណែកខាងព្រះថេរៈជាម្ចាស់ ឥឡូវនេះច្រើននៅដោយធម៌ជាគ្រឿងនៅដូចម្តេច ។ ព្រះសព្វកាមីឆ្លើយថា ម្នាលលោកដ៏ចំរើន ឥឡូវនេះ ខ្ញុំច្រើននៅដោយធម៌ជាគ្រឿងនៅដ៏ស្ងប់ស្ងាត់ ឬ សូន្យ (ផលសមាបត្តិ) ។ ព្រះរេវតពោលថា បពិត្រព្រះថេរៈដ៏ចំរើន ឮថាឥឡូវនេះ ព្រះថេរៈជាម្ចាស់ច្រើននៅដោយធម៌ជាគ្រឿងនៅ ជារបស់មហាបុរស បពិត្រព្រះថេរៈដ៏ចំរើន ក៏ឯធម៌ជាគ្រឿងនៅជារបស់មហាបុរសនេះគឺ សេចក្តីស្ងប់ស្ងាត់ ឬសូន្យនេះឯង ។ ព្រះសព្វកាមីពោលថា ម្នាលលោកដ៏ចំរើន កាលពីដើមដែលខ្ញុំនៅជាគ្រហស្ថនៅឡើយ តែងសន្សំនូវសេចក្តីស្ងប់ស្ងាត់ ឬសូន្យ ព្រោះហេតុនោះ បានជាក្នុងកាលឥឡូវនេះ ខ្ញុំច្រើននៅដោយធម៌ជាគ្រឿងនៅស្ងប់ស្ងាត់ ឬសូន្យ ម្យ៉ាងទៀត ខ្ញុំបានសម្រេចនូវព្រះអរហត្តជាយូរដែរហើយ ។

[៣១៤] ពាក្យជាបន្ទោះ របស់ភិក្ខុជាថេរៈនេះ នៅមិនទាន់ស្រេចនៅឡើយ ។ ក៏ស្រាប់តែព្រះសម្ភូតសាណវាសីមានអាយុមកដល់ ។ ទើបព្រះសម្ភូតសាណវាសីមានអាយុ ចូលទៅរកព្រះសព្វកាមីមានអា-យុ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះសព្វកាមីមានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសម្ភូតសាណវាសីមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបពោលពាក្យនេះនឹងព្រះសព្វកាមីមានអាយុថា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឥមេ ភន្តេ វេសាលិកា វជ្ជិបុត្តកា ភិក្ខូ វេសាលិយំ ទស វត្ថូនិ ទីបេន្តិ កប្បតិ សិង្គិលោណកប្បោ កប្បតិ ទ្វង្គុលកប្បោ កប្បតិ គាមន្តរកប្បោ កប្បតិ អាវាសកប្បោ កប្បតិ អនុមតិកប្បោ កប្បតិ អាចិណ្ណកប្បោ កប្បតិ អមថិតកប្បោ កប្បតិ ជលោគឹ បាតុំ កប្បតិ អទសកំ និសីទនំ កប្បតិ ជាតរូបរជតន្តិ ថេរេន ភន្តេ ឧបជ្ឈាយស្ស មូលេ ពហុ ធម្មោ ច វិនយោ ច បរិយត្តោ ថេរស្ស ភន្តេ ធម្មញ្ច វិនយញ្ច បច្ចវេក្ខន្តស្ស កថំ ហោតិ កេ នុ ខោ ធម្មវាទិនោ បាចីនកា វា ភិក្ខូ បាវេយ្យកា វាតិ ។ តយាបិ ខោ អាវុសោ ឧបជ្ឈាយស្ស មូលេ ពហុ ធម្មោ ច វិនយោ ច បរិយត្តោ តុយ្ហំ បន អាវុសោ ធម្មញ្ច វិនយញ្ច បច្ចវេក្ខន្តស្ស កថំ ហោតិ កេ នុ ខោ ធម្មវាទិនោ បាចីនកា វា ភិក្ខូ បាវេយ្យកា វាតិ ។ មយា ខោ ភន្តេ ធម្មញ្ច វិនយញ្ច បច្ចវេក្ខន្តស្ស

បពិត្រព្រះករុណាដ៏ចំរើន ពួកវជ្ជីបុត្តកភិក្ខុដែលនៅក្នុងក្រុងវេសាលី ទាំងនេះសំដែងវត្ថុទាំង ១០ ប្រការ ក្នុងក្រុងវេសាលីថា ការកំណត់ដោយអំបិលក្នុងស្នែង គួរ ការកំណត់ដោយស្រមោលព្រះអាទិត្យជ្រេប្រមាណពីរធ្នាប់ គួរ ការកំណត់ដោយចន្លោះស្រុក គួរ ការកំណត់ដោយអាវាស គួរ ការកំណត់ដោយអនុមតិ គួរ ការកំណត់ដោយអាចិណ្ណៈ គួរ ការកំណត់ដោយទឹកដោះ ដែលមិនទាន់ជូរ គួរ ការផឹកនូវសុរាឆៅ គួរ និសីទនៈមិនមានជាយ គួរ មាសនិងប្រាក់ គួរ បពិត្រព្រះថេរៈដ៏ចំរើន ធម៌ក្តី វិន័យក្តី ដែលព្រះថេរៈជាម្ចាស់បានរៀនសូត្រមកច្រើនហើយ ក្នុងសំណាក់នៃព្រះឧបជ្ឈាយ៍ បពិត្រព្រះថេរៈដ៏ចំរើន កាលដែលព្រះថេរៈពិចារណានូវធម៌និងវិន័យ មានសេចក្តីយល់ចិត្តដូចម្តេច ពួកភិក្ខុណាដែលជាធម្មវាទី គឺពួកភិក្ខុដែលនៅក្នុងទិសខាងកើតឬ ។ ពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យៗ ព្រះសព្វកាមីពោលតបវិញថា ម្នាលអាវុសោ ធម៌ក្តី វិន័យក្តី ជាច្រើន ដែលលោកបានរៀនសូត្រមកហើយ ក្នុងសំណាក់នៃព្រះឧបជ្ឈាយ៍ ម្នាលអាវុសោ ចុះកាលលោកពិចារណានូវធម៌និងវិន័យមានសេចក្តីយល់ចិត្តដូចម្តេច ពួកភិក្ខុណាដែលជាធម្មវាទី គឺពួកភិក្ខុដែលនៅក្នុងទិសខាងកើត ឬ ។ ពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ ។ ព្រះសម្ភូតសាណវាសីពោលថា បពិត្រព្រះថេរៈដ៏ចំរើន កាលដែលខ្ញុំពិចារណានូវធម៌និងវិន័យ

ឯវំ ហោតិ អធម្មវាទិនោ បាចីនកា ភិក្ខូ ធម្មវាទិនោ បាវេយ្យកា ភិក្ខូតិ អបិចាហំ ន តាវ ទិដ្ឋឹ អាវិករោមិ អបេ្យវនាម មំ ឥមស្មឹ អធិករណេ សម្មន្នេយ្យាតិ ។ មយ្ហំបិ ខោ អាវុសោ ធម្មញ្ច វិនយញ្ច បច្ចវេក្ខន្តស្ស ឯវំ ហោតិ អធម្មវាទិនោ បាចីនកា ភិក្ខូ ធម្មវាទិនោ បាវេយ្យកា ភិក្ខូតិ អបិចាហំ ន តាវ ទិដ្ឋឹ អាវិករោមិ អបេ្យវនាម មំ ឥមស្មឹ អធិករណេ សម្មន្នេយ្យាតិ ។

(៣១៣) អថខោ សង្ឃោ តំ អធិករណំ វិនិច្ឆិនិតុកាមោ សន្និបតិ ។ តស្មឹ ខោ បន អធិករណេ វិនិច្ឆិយមានេ អនន្តានិ[១] ចេវ ភស្សានិ ជាយន្តិ ន ចេកស្ស ភាសិតស្ស អត្ថោ វិញ្ញាយតិ ។ អថខោ អាយស្មា រេវតោ សង្ឃំ ញាបេសិ សុណាតុ មេ ភន្តេ សង្ឃោ អម្ហាកំ ឥមស្មឹ អធិករណេ វិនិច្ឆិយមានេ អនន្តានិ ចេវ ភស្សានិ ជាយន្តិ ន ចេកស្ស ភាសិតស្ស អត្ថោ វិញ្ញាយតិ ។ យទិ សង្ឃស្ស បត្តកល្លំ

---

១ ឱ. ម. អនគ្គានិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



មានសេចក្ដីចូលចិត្តយ៉ាងនេះថា ពួកភិក្ខុ ដែលនៅក្នុងទិសខាងកើតជាអធម្មវាទី ពួកភិក្ខុដែលនៅក្នុងដែនបាវេយ្យជាធម្មវាទី ប៉ុន្តែខ្ញុំព្រះករុណានៅមិនទាន់ធ្វើឲ្យជាក់ច្បាស់នូវទិដ្ឋិ (សេចក្ដីយល់) នៅឡើយ ធ្វើដូចម្ដេច សង្ឃគប្បីសន្មតខ្ញុំព្រះករុណាក្នុងអធិករណ៍នេះ ។ ព្រះសព្វកាមីពោលថា ម្នាលអាវុសោ កាលដែលខ្ញុំពិចារណានូវធម៌និងវិន័យ ក៏មានសេចក្ដីចូលចិត្តយ៉ាងនេះដែរថា ពួកភិក្ខុដែលនៅ ក្នុងទិសខាងកើតជាអធម្មវាទី ពួកភិក្ខុដែលនៅក្នុងដែនបាវេយ្យជាធម្មវាទី ប៉ុន្តែខ្ញុំក៏នៅមិនទាន់ធ្វើឲ្យជាក់ច្បាស់នូវទិដ្ឋិនៅឡើយ ធ្វើដូចម្ដេច សង្ឃគប្បីសន្មតខ្ញុំក្នុងអធិករណ៍នេះផង ។

(៣១៣) គ្រានោះ សង្ឃមានប្រាថ្នានឹងវិនិច្ឆ័យ កាត់សេចក្ដីអធិករណ៍នោះ ក៏ប្រជុំគ្នា ។ ក៏កាលដែលសង្ឃកំពុងវិនិច្ឆ័យអធិករណ៍នោះ កើតមានពាក្យជជែកគ្នារកទីបំផុតគ្មានផង ទាំងសេចក្ដីអធិប្បាយនៃភាសិតនីមួយ ក៏គ្មានអ្នកណាដឹងបានផង ។ លំដាប់នោះ ព្រះរេវតមានអាយុបានសូត្រប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ កាលដែលយើងទាំងឡាយកំពុងវិនិច្ឆ័យអធិករណ៍នេះ កើតមានពាក្យជជែកគ្នារកទីបំផុតគ្មានផង ទាំងសេចក្ដីអធិប្បាយនៃភាសិតនីមួយ ក៏គ្មានអ្នកណាដឹងបានផង ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បី

សង្ឃោ ឥមំ អធិករណំ ឧព្វាហិកាយ វូបសមេយ្យ។ សង្ឃោ ចត្តារោ បាចីនកេ ភិក្ខូ ចត្តារោ បាវេយ្យកេ ភិក្ខូ ឧច្ចិនិ បាចីនកានំ ភិក្ខូនំ អាយស្មន្តញ្ច សព្វកាមឹ អាយស្មន្តញ្ច សាឡ្ហំ អាយស្មន្តញ្ច ខុជ្ជសោភិតំ(១) អាយស្មន្តញ្ច វាសភគាមិកំ បាវេយ្យកានំ ភិក្ខូនំ អាយស្មន្តញ្ច រេវតំ អាយស្មន្តញ្ច សម្ភូតំ សាណវាសឹ អាយស្មន្តញ្ច យសំ កាកណ្ឌកបុត្តំ អាយស្មន្តញ្ច សុមនន្តិ(២)។ អថខោ អាយស្មា រេវតោ សង្ឃំ ញាបេសិ សុណាតុ មេ ភន្តេ សង្ឃោ អម្ហាកំ ឥមស្មឹ អធិករណេ វិនិច្ឆិយមានេ អនន្តានិ ចេវ ភស្សានិ ជាយន្តិ ន ចេកស្ស ភាសិតស្ស អត្ថោ វិញ្ញាយតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ចត្តារោ បាចីនកេ ភិក្ខូ ចត្តារោ បាវេយ្យកេ ភិក្ខូ សម្មន្នេយ្យ ឧព្វាហិកាយ ឥមំ អធិករណំ វូបសមេតុំ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អម្ហាកំ ឥមស្មឹ អធិករណេ

---

១ ឱ· ម· ខុជ្ជសោភិតំ ។ ២ ឧភោបិយមរម្មបោត្ថកេសុ ឥតិសទ្ទោ ន ទិស្សតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



រម្ងាប់អធិករណ៍នេះដោយឧព្វាហិកកម្ម(១) ។ ជំនុំសង្ឃជ្រើសរើសយកភិក្ខុដែលនៅក្នុងទិសខាងកើត ៤ រូប យកពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ ៤ រូប ចំណែកខាងពួកភិក្ខុដែលនៅក្នុងទិសខាងកើត គឺ ព្រះសព្វកាមីមានអាយុ ១ ព្រះសាឡ្ហៈមានអាយុ ១ ព្រះខុជ្ជសោភិតៈមានអាយុ ១ ព្រះវាសភគាមិកៈមានអាយុ ១ ពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ គឺ ព្រះរេវតមានអាយុ ១ ព្រះសម្ភូតសាណវាសីមានអាយុ ១ ព្រះយសកាកណ្ឌកបុត្តមានអាយុ ១ ព្រះសុមនៈមានអាយុ ១ ។ លំដាប់នោះ ព្រះរេវតមានអាយុ បានសូត្រប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ កាលបើយើងទាំងឡាយវិនិច្ឆ័យអធិករណ៍នេះទៅ កើតមានពាក្យដដែកគ្នារកទីបំផុតគ្មានផង ទាំងសេចក្តីអធិប្បាយនៃភាសិតនីមួយក៏គ្មានអ្នកណាដឹងបានផង ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតពួកភិក្ខុដែលនៅក្នុងទិសខាងកើត ៤ រូប ពួកភិក្ខុដែលនៅក្នុងដែនបាឋេយ្យ ៤ រូប ដើម្បីនឹងរម្ងាប់អធិករណ៍នេះ ដោយឧព្វាហិកកម្ម ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ កាលបើយើងទាំងឡាយ កំពុងវិនិច្ឆ័យអធិករណ៍នេះ

---

២ ក្នុងអដ្ឋកថាព្រះសូត្រថា ការជ្រើសរើសយកភិក្ខុអំពីគណៈសង្ឃ ដើម្បីរម្ងាប់អធិករណ៍ ដែលកើតមានឡើងហៅថា ឧព្វាហិកា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



## សត្តសតិកក្ខន្ធកេ អជិតភិក្ខុវត្ថុ

វិនិច្ឆិយមានេ អនគ្គានិ ចេវ ភស្សានិ ជាយន្តិ ន ចេកស្ស ភាសិតស្ស អត្ថោ វិញ្ញាយតិ ។ សង្ឃោ ចត្តារោ បាចីនកេ ភិក្ខូ ចត្តារោ បាវេយ្យកេ ភិក្ខូ សម្មន្នតិ ឧព្វាហិកាយ ឥមំ អធិករណំ វូបសមេតុំ ។ យស្សាយស្មតោ ខមតិ ចតុន្នំ បាចីនកានំ[1] ចតុន្នំ បាវេយ្យកានំ ភិក្ខូនំ សម្មតិ ឧព្វាហិកាយ ឥមំ អធិករណំ វូបសមេតុំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតា សង្ឃេន ចត្តារោ បាចីនកា ភិក្ខូ ចត្តារោ បាវេយ្យកា ភិក្ខូ ឧព្វាហិកាយ ឥមំ អធិករណំ វូបសមេតុំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៣១៤) តេន ខោ បន សមយេន អជិតោ នាម ភិក្ខុ ទសវស្សោ សង្ឃស្ស បាតិមោក្ខុទ្ទេសកោ ហោតិ ។ អថខោ សង្ឃោ អាយស្មន្តំបិ អជិតំ សម្មន្នតិ ថេរានំ ភិក្ខូនំ អាសនបញ្ញាបកំ ។ អថខោ

---

១ ឱ. ម. បាចីនកានំ ភិក្ខូនំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកៈ រឿងអជិតភិក្ខុ

កើតមានពាក្យដដែលគ្នាកើតទីបំផុតគ្មានផង ទាំងសេចក្ដីអធិប្បាយនៃភាសិតនីមួយក៏គ្មានអ្នកណាដឹងបានផង ។ សង្ឃបានសន្មតពួកភិក្ខុដែលនៅក្នុងទិសខាងកើត ៤ រូប ពួកភិក្ខុដែលនៅក្នុងដែនបាវេយ្យ ៤ រូប ដើម្បីរម្ងាប់អធិករណ៍នេះ ដោយឧព្វាហិកកម្ម ។ ការសន្មតិពួកភិក្ខុដែលនៅក្នុងទិសខាងកើត ៤ រូប ពួកភិក្ខុដែលនៅក្នុងដែនបាវេយ្យ ៤ រូប ដើម្បីរម្ងាប់អធិករណ៍នេះដោយឧព្វាហិកកម្ម គាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគាប់ចិត្តដល់លោកមានអាយុអង្គណា លោកមានអាយុអង្គនោះគប្បីពោលឡើង ។ សង្ឃបានសន្មតពួកភិក្ខុដែលនៅក្នុងទិសខាងកើត ៤ រូប នឹងពួកភិក្ខុដែលនៅក្នុងដែនបាវេយ្យ ៤ រូប ដើម្បីរម្ងាប់អធិករណ៍នេះ ដោយឧព្វាហិកកម្ម ។ ការសន្មតិនេះគាប់ចិត្តដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំចាំទុកនូវសេចក្ដីនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

(៣១៤) សម័យនោះឯង មានភិក្ខុ ១ រូប ឈ្មោះអជិត បួសបាន១០ វស្សា ជាអ្នកសំដែងនូវបាតិមោក្ខដល់សង្ឃ ។ លំដាប់នោះ សង្ឃក៏សន្មតអជិតមានអាយុ ឲ្យជាអ្នកក្រាលអាសនៈដល់ពួកភិក្ខុជាថេរៈ ។ គ្រានោះ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ថេរានំ ភិក្ខូនំ ឯតទហោសិ កថំ នុ ខោ មយំ ឥមំ អធិករណំ វូបសមេយ្យាមាតិ ។ អថខោ ថេរានំ ភិក្ខូនំ ឯតទហោសិ អយំ ខោ វាលិការាមោ រមណីយោ អប្បសទ្ទោ អប្បនិគ្ឃោសោ យន្នូន មយំ វាលិការាមេ ឥមំ អធិករណំ វូបសមេយ្យាមាតិ ។ អថខោ ថេរា ភិក្ខូ វាលិការាមំ អគមំសុ តំ អធិករណំ វិនិច្ឆិនិតុកាមា[1] ។

(៣១៨) អថខោ អាយស្មា រេវតោ សង្ឃំ ញាបេសិ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ អាយស្មន្តំ សព្វកាមឹ វិនយំ បុច្ឆេយ្យន្តិ ។ អាយស្មា សព្វកាមី សង្ឃំ ញាបេសិ សុណាតុ មេ អាវុសោ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ រេវតេន វិនយំ បុដ្ឋោ វិស្សជ្ជេយ្យន្តិ ។

(៣១៩) អថខោ អាយស្មា រេវតោ អាយស្មន្តំ សព្វកាមឹ ឯតទវោច កប្បតិ ភន្តេ សិង្គិលោណកប្បោតិ ។ កោ សោ អាវុសោ សិង្គិលោណកប្បោតិ ។ កប្បតិ ភន្តេ សិង្គិនា លោណំ បរិហរិតុំ យត្ថ អាលោណិកំ

១ ឱ. ម. វិនិច្ឆិតុកាមា ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្សៗ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទានៗ



ពួកភិក្ខុជាថេរៈមានសេចក្ដីត្រិះរិះដូច្នេះថា យើងទាំងឡាយគប្បីរម្ងាប់អធិ–ករណ៍នេះ ក្នុងទីណាហ្ន៎ ។ ទើបភិក្ខុជាថេរៈទាំងឡាយ មានសេចក្ដីរិះគិតដូច្នេះតទៅទៀតថា វាលិការាមនេះឯង ជាទីគួរត្រេកអរ មានសំឡេងតិច មានសូរគឹកកងក៏តិច បើដូច្នោះគួរយើងទាំងឡាយទៅរម្ងាប់អធិករណ៍នេះ ក្នុងវាលិការាមចុះ ។ លំដាប់នោះ ភិក្ខុជាថេរៈទាំងឡាយ មានសេចក្ដីប្រាថ្នានឹងរម្ងាប់អធិករណ៍នោះ ក៏នាំគ្នាទៅកាន់វាលិការាម ។

[៣១៥] គ្រានោះឯង ព្រះរេវតមានអាយុ បានសូត្រប្រកាសសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ បើសង្ឃកម្មមានកាលគួរដល់សង្ឃហើយ ខ្ញុំគប្បីសួរវិន័យនឹងព្រះសព្វកាមីមានអា-យុ ។ ព្រះសព្វកាមីមានអាយុ ក៏សូត្រប្រកាសសង្ឃឲ្យដឹងថា ម្នាលអាវុសោ សង្ឃបូរស្ដាប់ខ្ញុំ បើសង្ឃកម្មមានកាលគួរដល់សង្ឃហើយ ព្រះរេវតត្រូវសួរវិន័យចំពោះខ្ញុំ ៗ ត្រូវដោះស្រាយក្នុងកាលឥឡូវនេះ ។

[៣១៦] ទើបព្រះរេវតមានអាយុ ពោលដូច្នេះនឹងព្រះសព្វកាមីមានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយអំបិលក្នុងក្លាក់គួរដែរឬ ។ ព្រះសព្វកាមីសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយអំ-បិលក្នុងក្លាក់នោះ តើដូចម្ដេច ។ ព្រះរេវតពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ភិក្ខុរក្សាអំបិលដោយក្លាក់ ដោយគិតថា ភោជនដែលសាប

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភវិស្សតិ តត្ថ បរិភុញ្ជិស្សាមីតិ ។ នាវុសោ កប្បតីតិ ។ កត្ថ បដិក្ខិត្តន្តិ ។ សាវត្ថិយា សុត្តវិភង្គេតិ ។ កឹ អាបជ្ជតីតិ ។ សន្និធិការកភោជនេ បាចិត្តិយន្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ បឋមំ វត្ថុំ សង្ឃេន វិនិច្ឆិតំ ។ ឥតិបិទំ វត្ថុំ ឧទ្ធម្មំ ឧព្វិនយំ អបគតសត្ថុសាសនំ ។ ឥទំ បឋមំ សលាកំ និក្ខិបាមិ ។

(៣១៧) កប្បតិ ភន្តេ ទ្វង្គុលកប្បោតិ ។ កោ សោ អាវុសោ ទ្វង្គុលកប្បោតិ ។ កប្បតិ ភន្តេ ទ្វង្គុលាយ ឆាយាយ វីតិវត្តាយ វិកាលេ ភោជនំ ភុញ្ជិតុន្តិ ។

## សត្តសតិកក្ខន្ធកៈ បុច្ឆាវិសជ្ជនានូវវត្ថុ ១០ ប្រការ

មានក្នុងកាលណា អាត្មាអញនឹងឆាន់ក្នុងកាលនោះ ដូច្នេះ គួរដែរឬ ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ព្រះរេវតសួរថា ចុះព្រះមានព្រះភាគទ្រង់ឃាត់ក្នុងទីណា ។ ព្រះសព្វកាមីឆ្លើយថា ព្រះមានព្រះភាគទ្រង់ឃាត់ក្នុងសុត្តវិភង្គ[១] ក្នុងក្រុងសាវត្ថី ។ ព្រះរេវតសួរថា ភិក្ខុនោះត្រូវអាបត្តិអ្វី ។ ព្រះសព្វកាមីប្រាប់ថា ត្រូវអាបត្តិបាចិត្តិយៈ ព្រោះឆាន់វត្ថុដែលសន្សំទុក ។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុជាបឋមនេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ ។ វត្ថុនេះខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង ។ ខ្ញុំដាក់ចុះនូវស្លាកនេះជាបឋម ។

(៣១៣) ព្រះរេវតសួរទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយស្រមោលព្រះអាទិត្យជ្រេប្រមាណពីរធ្នាប់ គួរដែរឬ ។ ព្រះសព្វកាមីសួរតបវិញថា ម្នាលអាវុសោ ការកំណត់ដោយស្រមោលព្រះអាទិត្យជ្រេប្រមាណពីរធ្នាប់នោះ តើដូចម្តេច ។ ព្រះរេវតពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន កាលបើស្រមោលព្រះអាទិត្យកន្លងទៅប្រមាណពីរធ្នាប់ ភិក្ខុឆាន់ភោជនក្នុងវេលាវិកាល គួរដែរឬ ។

---

១ ក្នុងយោជនាថា ពាក្យដែលព្រះមានព្រះភាគចែកបទមាតិកា ហៅថា សុត្តវិភង្គ ក្នុងសារត្ថទីបនីដីកាថា បទភាជនីយ ហៅថា សុត្តវិភង្គ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



នាវុសោ កប្បតីតិ ។ កត្ថ បដិក្ខិត្តន្តិ ។ រាជគហេ សុត្តវិភង្គេតិ ។ កឹ អាបជ្ជតីតិ ។ វិកាលភោជនេ បាចិត្តិយន្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ ទុតិយំ វត្ថុ សង្ឃេន វិនិច្ឆិតំ ។ ឥតិបិទំ វត្ថុ ឧទ្ធម្មំ ឧព្វិនយំ អបគតសត្ថុសាសនំ ។ ឥទំ ទុតិយំ សលាកំ និក្ខិបាមិ ។

(៣១៨) កប្បតិ ភន្តេ គាមន្តរកប្បោតិ ។ កោ សោ អាវុសោ គាមន្តរកប្បោតិ ។ កប្បតិ ភន្តេ ឥទានិ គាមន្តរំ គមិស្សាមីតិ ភុត្តាវិនា បវារិតេន អនតិរិត្តំ ភោជនំ ភុញ្ជិតុន្តិ ។ នាវុសោ កប្បតីតិ ។ កត្ថ បដិក្ខិត្តន្តិ ។ សាវត្ថិយា សុត្តវិភង្គេតិ ។ កឹ អាបជ្ជតីតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ព្រះរេវតសួរថា ព្រះអង្គទ្រង់ឃាត់ក្នុងទីណា ។ ព្រះសព្វកាមីឆ្លើយថា ទ្រង់ឃាត់ក្នុងសុត្តវិភង្គ ក្នុងក្រុងរាជគ្រឹះ ។ ព្រះរេវតសួរថា ភិក្ខុនោះ ត្រូវអាបត្តិអ្វី ។ ព្រះសព្វកាមីឆ្លើយថា ត្រូវអាបត្តិបាចិត្តិយៈ ព្រោះបរិភោគក្នុងកាលខុស ។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុទី ២ នេះសង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ ។ វត្ថុនេះខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង ។ ខ្ញុំដាក់ចុះនូវស្លាកទី ២ នេះ ។

(៣១៨) ព្រះរេវតសួរទៀតថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយចន្លោះស្រុក គួរដែរឬ ។ ព្រះសព្វកាមីសួរតបវិញថា ម្នាលអាវុសោ ការកំណត់ដោយចន្លោះស្រុកនោះ តើដូចម្តេច ។ ព្រះរេវតពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ភិក្ខុគិតថា អញនឹងទៅកាន់ចន្លោះស្រុកឥឡូវនេះ ហើយឆាន់ភោជន ហាមភោជនរួចហើយក៏ឆាន់ភោជនដែលភិក្ខុមិនបានធ្វើវិនយកម្ម ឬមិនមែនជាវត្ថុសល់ដែលអំពីភិក្ខុឈឺ គួរដែរឬ ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ព្រះរេវតសួរថា ព្រះអង្គទ្រង់ឃាត់ក្នុងទីណា ។ ព្រះសព្វកាមីឆ្លើយថ: ព្រះអង្គទ្រង់ហាមឃាត់ក្នុងសុត្តវិភង្គ ក្នុងក្រុងសាវត្ថី ។ ព្រះរេវតសួរថា ភិក្ខុនោះ ត្រូវអាបត្តិអ្វី ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



អនតិរិត្តភោជនេ បាចិត្តិយន្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ តតិយំ វត្ថុ សង្ឃេន វិនិច្ឆិតំ ។ ឥតិបិទំ វត្ថុ ឧទ្ធម្មំ ឧព្ពិនយំ អបគតសត្ថុសាសនំ ។ ឥទំ តតិយំ សលាកំ និក្ខិបាមិ ។

(៣១៩) កប្បតិ ភន្តេ អាវាសកប្បោតិ ។ កោ សោ អាវុសោ អាវាសកប្បោតិ ។ កប្បតិ ភន្តេ សម្ពហុលា អាវាសា សមានសីមា នានុបោសថំ កាតុន្តិ ។ នាវុសោ កប្បតីតិ ។ កត្ថ បដិក្ខិត្តន្តិ ។ រាជគហេ ឧបោសថសំយុត្តេតិ ។ កឹ អាបជ្ជតីតិ ។ វិនយាតិសារេ ទុក្កដន្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ព្រះសព្វកាមីឆ្លើយថា ត្រូវអាបត្តិបាចិត្តិយៈ ព្រោះឆាន់ភោជនដែលភិក្ខុមិនបានធ្វើវិនយកម្ម ឬមិនមែនជាវត្ថុសល់ដែលអំពីភិក្ខុឈឺ ។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុទី ៣ នេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ ។ វត្ថុនេះ ខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង ។ ខ្ញុំដាក់ចុះនូវស្លាកទី ៣ នេះ ។

[៣១៩] ព្រះរេវតសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន កាលកំណត់ដោយអាវាស គួរដែរឬ ។ ព្រះសព្វកាមីសួរតបវិញថា ម្នាលអាវុសោ ការកំណត់ដោយអាវាសនោះ តើដូចម្តេច ។ ព្រះរេវតពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន អាវាសច្រើន មានសីមាស្មើគ្នា ភិក្ខុធ្វើឧបោសថកម្មផ្សេង ៗ គ្នា គួរដែរឬ ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ព្រះរេវតសួរថា ព្រះមានព្រះភាគទ្រង់ឃាត់ក្នុងទីណា ។ ព្រះសព្វកាមីឆ្លើយថា ទ្រង់ឃាត់ក្នុងឧបោសថសំយុត្ត (ឧបោសថក្ខន្ធកៈ) ក្នុងក្រុងរាជគ្រឹះ ។ ព្រះរេវតសួរថា ភិក្ខុនោះ ត្រូវអាបត្តិអ្វី ។ ព្រះសព្វកាមីឆ្លើយថា ត្រូវអាបត្តិទុក្កដ ព្រោះប្រព្រឹត្តល្មើសព្រះវិន័យ ។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ឥទំ ចតុត្ថំ វត្ថុំ សង្ឃេន វិនិច្ឆិតំ ។ ឥតិបិទំ វត្ថុំ ឧទ្ធម្មំ ឧព្ពិនយំ អបគតសត្ថុសាសនំ ។ ឥទំ ចតុត្ថំ សលាកំ និក្ខិបាមិ ។

[៣២០] កប្បតិ ភន្តេ អនុមតិកប្បោតិ ។ កោ សោ អាវុសោ អនុមតិកប្បោតិ ។ កប្បតិ ភន្តេ វគ្គេន សង្ឃេន កម្មំ កាតុំ អាគតេ ភិក្ខូ អនុមានេស្សាមាតិ(១) ។ នាវុសោ កប្បតីតិ ។ កត្ថ បដិក្ខិត្តន្តិ ។ ចម្បេយ្យកេ វិនយវត្ថុស្មិន្តិ ។ កិំ អាបជ្ជតីតិ ។ វិនយាតិសារេ ទុក្កដន្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ បញ្ចមំ វត្ថុំ សង្ឃេន វិនិច្ឆិតំ ។ ឥតិបិទំ វត្ថុំ ឧទ្ធម្មំ ឧព្ពិនយំ អបគតសត្ថុសាសនំ ។ ឥទំ បញ្ចមំ សលាកំ និក្ខិបាមិ ។

---

១ មរម្មពោត្ថកេ អនុមតឹ អានេស្សាមាតិ បាឋោ អាគតោ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



វត្ថុទី ៤ នេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ វត្ថុនេះ ខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង ។ ខ្ញុំដាក់ចុះនូវស្លាកទី ៤ នេះ ។

(៣២០) ព្រះរេវតសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយអនុមតិ គួរដែរឬ ។ ព្រះសព្វកាមីសួរតបវិញថា ម្នាលអាវុសោ ការកំណត់ដោយអនុមតិនោះ តើដូចម្តេច ។ ព្រះរេវតពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន សង្ឃជាពួក ធ្វើសង្ឃកម្មដោយគិតថា យើងទាំងឡាយនឹងរាប់ពួកភិក្ខុ ដែលមកដល់យល់ព្រម ឬត្រេកអរជាខាងក្រោយ គួរដែរឬ ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ព្រះរេវតសួរថា ព្រះអង្គទ្រង់ឃាត់ក្នុងទីណា ។ ព្រះសព្វកាមីឆ្លើយថា ទ្រង់ឃាត់ក្នុងវិនយវត្ថុ ក្នុងចម្បេយ្យក្ខន្ធកៈ ។ ព្រះរេវតសួរថា ភិក្ខុនោះ ត្រូវអាបត្តិអ្វី ព្រះសព្វកាមីឆ្លើយថា ត្រូវអាបត្តិទុក្កដ ព្រោះប្រព្រឹត្តល្មើសព្រះវិន័យ ។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុទី ៥ នេះសង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ ។ វត្ថុនេះ ខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង ។ ខ្ញុំដាក់ចុះនូវស្លាកទី ៥ នេះ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



(៣៦១) កប្បតិ ភន្តេ អាចិណ្ណកប្បោតិ ។ កោ សោ អាវុសោ អាចិណ្ណកប្បោតិ ។ កប្បតិ ភន្តេ ឥទំ មេ ឧបជ្ឈាយេន អជ្ឈាចិណ្ណំ ឥទំ មេ អាចរិយេន អជ្ឈាចិណ្ណន្តិ អជ្ឈាចរិតុន្តិ ។ អាចិណ្ណកប្បោ ខោ អាវុសោ ឯកច្ចោ កប្បតិ ឯកច្ចោ ន កប្បតីតិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ ឆដ្ឋំ វត្ថុ សង្ឃេន វិនិច្ឆិតំ ។ ឥតិបិទំ វត្ថុ ឧទ្ធម្មំ ឧព្វិនយំ អបគតសត្ថុសាសនំ ។ ឥទំ ឆដ្ឋំ សលាកំ និក្ខិបាមិ ។

(៣៦២) កប្បតិ ភន្តេ អមថិតកប្បោតិ ។ កោ សោ អាវុសោ អមថិតកប្បោតិ ។ កប្បតិ ភន្តេ យំ តំ ខីរំ ខីរភាវំ វិជហិតំ អសម្បត្តំ ទធិភាវំ ភុត្តាវិនា

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកៈ បុច្ឆាវិសជ្ជនានូវវត្ថុ ១០ ប្រការ

(៣២១) ព្រះរេវតសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយអាចិណ្ណៈ គួរដែរឬ ។ ព្រះសព្វកាមីសួរវិញថា ម្នាលអាវុសោ ការកំណត់ដោយអាចិណ្ណៈនោះ តើដូចម្តេច ។ ព្រះរេវតពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន កិច្ចប្រព្រឹត្តដោយគិតថា អំពើនេះ ព្រះឧបជ្ឈាយ៍របស់យើងធ្លាប់សន្សំមកហើយ អំពើនេះ អាចារ្យរបស់យើងធ្លាប់សន្សំមកហើយដូច្នេះ គួរដែរឬ ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ ការកំណត់ដោយអាចិណ្ណៈ គួរខ្លះ មិនគួរខ្លះ ។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុទី ៦ នេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ ។ វត្ថុនេះ ខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង ។ ខ្ញុំដាក់ចុះនូវស្លាកទី ៦ នេះ ។

(៣២២) ព្រះរេវតសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ការកំណត់ដោយទឹកដោះដែលមិនទាន់ជូរ គួរដែរឬ ។ ព្រះសព្វកាមីឆ្លើយតបវិញថា ម្នាលអាវុសោ ការកំណត់ដោយទឹកដោះ ដែលមិនទាន់ជូរនោះ តើដូចម្តេច ។ ព្រះរេវតពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន ទឹកដោះស្រស់ណា ដែលលះបង់ភាវៈជាទឹកដោះស្រស់ហើយ តែនៅមិនទាន់ដល់នូវភាវៈជាទឹកដោះជូរនៅឡើយ កិច្ចឆាន់ភោជនរួចហើយ ហាមភោជនៈរួចហើយ

## វិនយបិដកេ ចុល្លវគ្គោ

បវារិតេន អនតិរិត្តំ បាតុន្តិ ។ នាវុសោ កប្បតីតិ ។ កត្ថ បដិក្ខិត្តន្តិ ។ សាវត្ថិយា សុត្តវិភង្គេតិ ។ កឹ អាបជ្ជតីតិ ។ អនតិរិត្តភោជនេ បាចិត្តិយន្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សត្តមំ វត្ថុ សង្ឃេន វិនិច្ឆិតំ ។ ឥតិបិទំ វត្ថុ ឧទ្ធម្មំ ឧព្វិនយំ អបគតសត្ថុសាសនំ ។ ឥទំ សត្តមំ សលាកំ និក្ខិបាមិ ។

(៣២៣) កប្បតិ ភន្តេ ជលោគឹ បាតុន្តិ ។ កា សា អាវុសោ ជលោគីតិ ។ កប្បតិ ភន្តេ យា សា សុរា អសុ-តា អសម្បត្តា មជ្ជភាវំ សា បាតុន្តិ ។ នាវុសោ កប្បតី-តិ ។ កត្ថ បដិក្ខិត្តន្តិ ។ កោសម្ពិយា សុត្តវិភង្គេតិ ។ កឹ អាបជ្ជតីតិ ។ សុរាមេរយបានេ បាចិត្តិយន្តិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ផឹកទឹកដោះជាអនតិរិត្តនោះ គឺ ភិក្ខុមិនបានធ្វើវិនយកម្ម ឬមិនមែនជារបស់សល់ដែលអំពីភិក្ខុឈឺ គួរដែរឬ ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ព្រះរេវតសួរថា ព្រះអង្គទ្រង់ឃាត់ក្នុងទីណា ។ ព្រះសព្វកាមីឆ្លើយថា ទ្រង់ឃាត់ក្នុងសុត្តវិភង្គ ក្នុងក្រុងសាវត្ថី ។ ព្រះរេវតសួរថា ភិក្ខុនោះត្រូវអាបត្តិអ្វី ។ ព្រះសព្វកាមីឆ្លើយថា ត្រូវអាបត្តិបាចិត្តិយៈ ព្រោះឆាន់អនតិរិត្តភោជន ។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុទី៧ នេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ ។ វត្ថុនេះ ខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង ។ ខ្ញុំដាក់ចុះនូវស្លាកទី ៧ នេះ ។

[៣៤៣] ព្រះរេវតសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ភិក្ខុផឹកសុរានៅគួរដែរឬ ។ ព្រះសព្វកាមីសួរតបវិញថា ម្នាលអាវុសោ សុរានៅនោះតើដូចម្តេច ។ ព្រះរេវតពោលថា បពិត្រលោកម្ចាស់ដ៏ចំរើន សុរាណាដែលខ្សោយ នៅមិនទាន់ដល់ភាវៈជាទឹកស្រវឹងនៅឡើយ ភិក្ខុផឹកសុរានោះគួរដែរឬ ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ព្រះរេវតសួរថា ព្រះអង្គទ្រង់ឃាត់ក្នុងទីណា ។ ព្រះសព្វកាមីឆ្លើយថា ទ្រង់ឃាត់ក្នុងសុត្តវិភង្គ ក្នុងក្រុងកោសម្ពី ។ ព្រះរេវតសួរថា ភិក្ខុនោះត្រូវអាបត្តិអ្វី ។ ព្រះសព្វកាមីឆ្លើយថា ត្រូវអាបត្តិបាចិត្តិយៈ ព្រោះផឹកសុរានិងមេរ័យ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា គាំង ហ៊ួចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។



សុណាតុ មេ ភន្តេ សង្ឃោ ឥទំ អដ្ឋមំ វត្ថុំ សង្ឃេន វិនិច្ឆិតំ ។ ឥតិបិទំ វត្ថុំ ឧទ្ធម្មំ ឧព្វិនយំ អបកតសត្ថុសាសនំ ។ ឥទំ អដ្ឋមំ សលាកំ និក្ខិបាមិ ។

(៣៨៤) កប្បតិ ភន្តេ អទសកំ និសីទនន្តិ ។ នាវុសោ កប្បតីតិ ។ កត្ថ បដិក្ខិត្តន្តិ ។ សាវត្ថិយា សុត្តវិភង្គេតិ ។ កឹ អាបជ្ជតីតិ ។ ឆេទនកេ បាចិត្តិយន្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ នវមំ វត្ថុំ សង្ឃេន វិនិច្ឆិតំ ។ ឥតិបិទំ វត្ថុំ ឧទ្ធម្មំ ឧព្វិនយំ អបកតសត្ថុសាសនំ ។ ឥទំ នវមំ សលាកំ និក្ខិបាមិ ។

(៣៨៥) កប្បតិ ភន្តេ ជាតរូបរជតន្តិ ។ នាវុសោ កប្បតីតិ ។ កត្ថ បដិក្ខិត្តន្តិ ។ រាជគហេ សុត្តវិ-

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកៈ បុច្ឆាវិសជ្ជនានូវវត្ថុ ១០ ប្រការ

ព្រះរេវតត្ថេរប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុទី ៨ នេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ ។ វត្ថុនេះ ខុសពាកធម៌ ខុសពាកវិន័យ ក្រៅសពាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង ។ ខ្ញុំដាក់ចុះនូវស្លាកទី ៨ នេះ ។

(៣២៤) ព្រះរេវតត្ថេរសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន និសីទនៈដែលគ្មានជាយ គួរដែរឬ ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ព្រះរេវតត្ថេរសួរថា ព្រះអង្គទ្រង់ឃាត់ក្នុងទីណា ។ ព្រះសព្វកាមីឆ្លើយថា ទ្រង់ឃាត់ក្នុងសុត្តវិភង្គ ក្នុងក្រុងសាវត្ថី ។ ព្រះរេវតត្ថេរសួរថា ភិក្ខុនោះត្រូវអាបត្តិអ្វី ។ ព្រះសព្វកាមីឆ្លើយថា ត្រូវអាបត្តិបាចិត្តិយៈ ព្រោះវត្ថុមានកិរិយាកាត់ជាវិនយកម្ម ។ ព្រះរេវតត្ថេរប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុទី ៩ នេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ ។ វត្ថុនេះ ខុសពាកធម៌ ខុសពាកវិន័យ ក្រៅសពាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង ។ ខ្ញុំដាក់ចុះនូវស្លាកទី ៩ នេះ ។

(៣២៥) ព្រះរេវតត្ថេរសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន មាសនិងប្រាក់ គួរដែរឬ ។ ព្រះសព្វកាមីឆ្លើយថា ម្នាលអាវុសោ មិនគួរទេ ។ ព្រះរេវតត្ថេរសួរថា ព្រះអង្គទ្រង់ឃាត់ក្នុងទីណា ។ ព្រះសព្វកាមីឆ្លើយថា ទ្រង់

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



ភន្តេតិ ។ កឹ អាបជ្ជតីតិ ។ ជាតរូបរជតប្បដិគ្គហណេ បាចិត្តិយន្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ ទសមំ វត្ថុំ សង្ឃេន វិនិច្ឆិតំ ។ ឥតិបីទំ វត្ថុំ ឧទ្ធម្មំ ឧព្វិនយំ អបគតសត្ថុសាសនំ ។ ឥទំ ទសមំ សលាកំ និក្ខិបាមិ ។

(៣២៦) សុណាតុ មេ ភន្តេ សង្ឃោ ឥមានិ ទស វត្ថូនិ សង្ឃេន វិនិច្ឆិតានិ ។ ឥតិបីមានិ ទស(១) វត្ថូនិ ឧទ្ធម្មានិ ឧព្វិនយានិ អបគតសត្ថុសាសនានីតិ ។

(៣២៧) និហតមេតំ អាវុសោ អធិករណំ សន្តំ វូបសន្តំ សុវូបសន្តំ អបិច មំ ត្វំ អាវុសោ សង្ឃមជ្ឈេបិ ឥមានិ ទស វត្ថូនិ បុច្ឆេយ្យាសិ តេសំ ភិក្ខូនំ សញ្ញត្តិយាតិ ។ អថខោ អាយស្មា រេវតោ អាយស្មន្តំ សព្វកាមឹ សង្ឃមជ្ឈេបិ ឥមានិ ទស វត្ថូនិ បុច្ឆិ ។ បុដ្ឋោ បុដ្ឋោ

---

១ ឱ. ទសសទ្ទោ ន បញ្ញាយតិ ។ ម. ទស វត្ថូនិសទ្ទោ ន បញ្ញាយតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



យាត់ក្នុងសុត្តវិភង្គ ក្នុងក្រុងរាជគ្រឹះ ។ ព្រះរេវតសួរថា ភិក្ខុនោះត្រូវអាបត្តិអ្វី ។ ព្រះសព្វកាមីឆ្លើយថា ត្រូវអាបត្តិបាចិត្តិយៈ ព្រោះទទួលមាសនឹងប្រាក់ ។ ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុទី ១០ នេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ ។ វត្ថុនេះខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង ។ ខ្ញុំដាក់ចុះនូវស្លាកទី ១០ នេះ ។

(៣២៦) ព្រះរេវតសូត្រប្រកាសថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ វត្ថុទាំង ១០ ប្រការនេះ សង្ឃបានវិនិច្ឆ័យដាច់ស្រេចហើយ ។ វត្ថុទាំង ១០ប្រការនេះ ខុសចាកធម៌ ខុសចាកវិន័យ ប្រាសចាកសាសនានៃព្រះសាស្តា ដោយប្រការដូច្នេះឯង ។

(៣២៧) ព្រះសព្វកាមីពោលថា ម្នាលអាវុសោ អធិករណ៍នេះសង្ឃបានជំរះហើយ បានរម្ងាប់ស្ងប់ស្ងាត់ល្អហើយ ម្នាលអាវុសោ ម្យ៉ាងទៀត លោកគប្បីសួរវត្ថុទាំង ១០ ប្រការនេះ នឹងខ្ញុំ ក្នុងកណ្តាលសង្ឃម្តងទៀត ដើម្បីបញ្ញាក់ដល់ភិក្ខុទាំងនោះ ។ លំដាប់នោះ ព្រះរេវតមានអាយុ ក៏សួរនូវវត្ថុទាំង ១០ ប្រការនេះ នឹងព្រះសព្វកាមីមានអាយុ ក្នុងកណ្តាលសង្ឃ ម្តងទៀត ។ លុះព្រះរេវត បានសួរសព្វគ្រប់ហើយ

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៕



អាយស្មា សព្វកាមី វិស្សជ្ជេសិ ។ ឥមាយ ច បន វិនយសង្គីតិយា សត្ត ភិក្ខុសតានិ អនូនានិ អនធិកានិ អហេសុំ ។ តស្មាយំ វិនយសង្គីតិ សត្តសតិកាតិ[១] វុច្ចតីតិ ។

សត្តសតិកក្ខន្ធកំ និដ្ឋិតំ ទ្វាទសមំ ។

ឥមម្ហិ ខន្ធកេ វត្ថុ បញ្ចវីសតិ ។

តស្សុទ្ទានំ

(៣២៨) ទស វត្ថូនិ បូរេត្វា

កាម្ពុំ ទូតេន ធាវិសិ

ចត្តារោ បុន វូបញ្ញ

---

១ ឱ· សត្តសតីតិ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន៕



## សត្តសតិកក្ខន្ធកៈ ឧទ្ទានគាថា

ព្រះសព្វកាមីមានអាយុ ក៏ផ្ដើយដោះស្រាយ ។ ក៏ក្នុងការសង្គាយនាព្រះវិន័យនេះ មានភិក្ខុ ៧០០ អង្គ មិនខ្វះ មិនលើស ។ ព្រោះហេតុនោះ ការសង្គាយនាព្រះវិន័យនេះ បានឈ្មោះថា សត្តសតិកាសង្គាយនា ។

ចប់ សត្តសតិកក្ខន្ធកៈ ទី ១២ តែប៉ុណ្ណេះ ។

ក្នុងខន្ធកៈនេះ មានរឿង ២៥ ។

ឧទ្ទាននៃសត្តសតិកក្ខន្ធកៈនោះ ដូច្នេះ

(៣២៨) រឿងវជ្ជីបុត្តកភិក្ខុនៅក្នុងក្រុងវេសាលី សំដែងនូវវត្ថុ ១០ ប្រការ ១ រឿងវជ្ជីបុត្តកភិក្ខុដងទឹកដាក់ពេញភាជន៍សំរិទ្ធក្នុងថ្ងៃឧបោសថនោះ ១ រឿងពួកវជ្ជីបុត្តកភិក្ខុធ្វើបដិសារណីយកម្ម ដល់ព្រះយសកាកណ្ឌកបុត្ត ១ រឿងព្រះយសកាកណ្ឌកបុត្តចូលទៅកាន់ក្រុងវេសាលីជាមួយនឹងភិក្ខុជាអនុទូត ១ រឿងឧបក្កិលេសរបស់ព្រះចន្ទនឹងព្រះអាទិត្យមាន ៤ យ៉ាង នឹងឧបក្កិលេសរបស់សមណៈមាន ៤ យ៉ាងទៀត ១ រឿងពាក្យដដែលគ្នាថា មាសនឹងប្រាក់គួរដល់ពួកសមណៈឬទេ ១

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



កោសម្ពិ ច ធាបេយ្យកោ[១]

មគ្គោ សោរេយ្យំ សង្កស្សំ

កណ្ណកុជ្ជំ ឧទុម្ពរំ

សហជាតិ[២] ច មជ្ឈេសិ

អស្សោសិ តំ ធុ ខោ មយំ

បត្តធាភយ ឧជ្ជវិ[៣]

---

១ ឱ. ម. ធាវេយ្យកោ ។ ២ ឱ. ម. សហំជាតិ ។ ៣ ឱ. ស ឧជ្ជវី ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



រឿងព្រះយសកាកណ្ឌកបុត្ត ហោះតាមអាកាសទៅចុះក្នុងក្រុងកោសម្ពី ១ រឿងព្រះយសកាកណ្ឌកបុត្ត បញ្ជូនទូតឲ្យទៅកាន់សំណាក់នៃភិក្ខុដែលនៅ ក្នុងដែនបាឋេយ្យ និងភិក្ខុដែលនៅក្នុងដែនអវន្តិទក្ខិណាបថ[១] ១ រឿងព្រះរេវតគង់នៅក្នុងនគរសោរេយ្យ ១ រឿងព្រះរេវតចេញពីនគរសោរេយ្យទៅកាន់នគរសង្កស្ស ១ រឿងព្រះរេវតចេញពីនគរសង្កស្សទៅកាន់នគរកណ្ណកុជ្ជ ១ រឿងព្រះរេវតចេញពីនគរកណ្ណ-កុជ្ជទៅកាន់នគរឧទុម្ពរ ១ រឿងព្រះរេវតចេញពីនគរអគ្គឡបុរៈទៅកាន់នគរសហជាតិ ១ រឿងព្រះរេវត បង្គាប់ភិក្ខុជាកូនសិស្សឲ្យជាអ្នកពោលសរភញ្ញ ១ រឿងពួកវជ្ជីបុត្តកភិក្ខុឮដំណឹងថា ព្រះយសកាកណ្ឌកបុត្តប្រាថ្នានឹងជំរះអធិករណ៍ ១ រឿងវជ្ជីបុត្តកភិក្ខុ រិះគិតថា យើងបានភិក្ខុណាជាបក្ខពួក ១ រឿងវជ្ជីបុត្តកភិក្ខុចាត់ចែងសមណបរិក្ខារ មានបាត្រជាដើម ហើយនាំគ្នាជិះទូកឆ្លងឡើងទៅកាន់សហជាតិនគរ ១ រឿង

---

១ មានតែក្នុងបាលីខាងដើម ក្នុងឧទ្ទានគ្មាន មានតែ មគ្គោ វិញ ប្រហែលជា មគ្គសព្ទនេះលោកផ្លាស់ប្តូរជំនួសសព្ទ គឺ អវន្តិទក្ខិណាបថ ទេដឹង ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកេ ឧទ្ទានគាថា

រហោសិ ឧបឆាមយំ[១]

តរុ[២] សង្ឃោ ច វេសាលិ

មេត្តា សង្ឃោ ឧញ្ញាហិកាតិ ។

បុល្លវគ្គោ សមត្តោ

---

១ ឱ. ទូរហោបិ ឧទាមស្ស ។ កត្ថចិ បោត្ថកេ ទូរតោបិ ឧទាមស្ស ។ ២ ឱ. ទារុកំ ។ កត្ថចិ បោត្ថកេ ទារុណំ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



## សត្តសតិកក្ខន្ធកៈ ឧទ្ទានគាថា

ព្រះសាឡ្ហៈ មានអាយុ សម្ងំនៅក្នុងទីស្ងាត់ ១ រឿងព្រះទព្វៈ មានអាយុ ដំណាលប្រាប់ពួកវជ្ជីបុត្តកភិក្ខុថា ពួកមនុស្សតែងបង្អោនសមណបរិក្ខារទៅថ្វាយព្រះមានព្រះភាគ ១ រឿងព្រះទព្វៈមានអាយុ ដំណាលប្រាប់ពួកវជ្ជីបុត្តកភិក្ខុថា យើងកាន់យកនិស្ស័យនឹងព្រះរេវតជាគ្រូ ១ រឿងជំនុំសង្ឃប្រជុំគ្នានឹងវិនិច្ឆ័យអធិករណ៍ ១ រឿងពួកភិក្ខុជាថេរៈប្រាជ្ញានឹងវិនិច្ឆ័យអធិករណ៍ ហើយនាំគ្នាទៅកាន់ក្រុងវេសាលី១ រឿងព្រះសព្វកាមីសួរព្រះរេវតថា ឥឡូវនេះ លោកនៅដោយធម៌ជាគ្រឿងនៅដូចម្តេច ព្រះរេវតឆ្លើយថា ខ្ញុំនៅដោយអំណាចនៃមេត្តាធម៌ ១ រឿងជំនុំសង្ឃ ប្រជុំគ្នាវិនិច្ឆ័យអធិករណ៍នោះ ១ រឿងព្រះរេវត សូត្រប្រកាសសង្ឃឲ្យដឹងថា ត្រូវឲ្យសង្ឃរម្ងាប់អធិករណ៍នេះ ដោយឧព្វាហិកកម្ម ១ ។

ចប់ ចុល្លវគ្គ ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | បន្តិលេខាយំ |
|---|---|---|---|
| ទិស្សនិ | ទិស្សន្តិ | ៤ | ១៩ |
| បព្វជិស្សន្តិ | បព្ពជិស្សន្តិ | ៨ | ៩ |
| អយ្យបត្តា | អយ្យបុត្តា | " | ១៥ |
| ភិក្ខូ | ភិក្ខូ | ១០ | ១៧ |
| យសន្តរពោ | យស្សន្តរពោ | ១៣ | ៨ |
| កុមារវណ្ណំ | កុមារកវណ្ណំ | ១៤ | ១២ |
| សេក្យកុមារានំ ភគវតោ ឧបសង្កមនំ កក្កុឆកោឡិយបុត្តៈត្ត | | ១៥ | ១ |
| នាមក្ខេត្តានិ | ឆាមក្ខេត្តានិ | " | ១៧ |
| បរិយោទាតំ | បរិយោទាតំ | ២០ | ១៧ |
| ភន្ទេយ្យំ | ភន្ទេយ្យំ | ២៤ | ៤ |
| វេទ | វេឡុ | " | ១៧ |
| អាបន្ទេសិ | អាមន្តេសិ | ២៩ | ៩ |
| បក្កាសេតុំ | បកាសេតុំ | ៣០ | ៧ |
| កាយន | កាយេន | ៣១ | ៦ |
| បកាសេ កិ | បកាសេសិ | ៣២ | ៧ |
| ២ . | ២ ទ . | " | ១៧ |
| វិតមលំ | វីតមលំ | ៣៩ | ៨ |
| បរិសំ | បរិសំ | ៤០ | " |
| អញ្ញារស្មឹ | អញ្ញតរស្មឹ | " | ១៣ |
| គុំ សីលំ | គំ សិលំ | ៤២ | ១៥ |
| បរិនិញ្ញយន្តិតិ | បរិនិញ្ញយន្តីតិ ។ | ៥០ | ៩ |
| សារិបុត្តមោគ្គល្លានា | សារីបុត្តមោគ្គល្លានា | ៦៤ | ៥ |

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



# វិរុទ្ធាវិរុទ្ធបត្តិ

| វិរុទ្ធបាឋ | អវិរុទ្ធបាឋ | អង្គ | វដ្ឋុលេខាយំ |
|---|---|---|---|
| សារិបុត្តោ | សារីបុត្តោ | ៦៤ | ៨ |
| ជា មិត្តំ | ជាបមិត្តំ | ៧២ | ៧ |
| មញ្ចបដិឃាទកា | មញ្ចប្បដិឃាទកា | ៩៦ | ១២ |
| " | " | ៩៧ | ១៣ |
| ស បិ | សបេ | ៩៩ | ២ |
| វិច្ចកុដី | វិច្ចកុដិ | " | ១១ |
| " | " | " | ១២ |
| មតិកាភណ្ឌំ | មត្តិកាភណ្ឌំ | ១០៣ | ៦ |
| មញ្ចបដិឃាទកា | មញ្ចប្បដិឃាទកា | ១២៤ | ១០ |
| " | " | ១២៥ | ១១ |
| អនាទរិយ | អនាទរិយំ | ១២៨ | ១៥ |
| វិច្ចកុដី | វិច្ចកុដិ | ១៣១ | ១ |
| " | " | ១៣៣ | " |
| វិច្ចកុដីវត្ថុ | វិច្ចកុដិវត្ថុ | ១៣៤ | ៩ |
| វិច្ចកុដី | វិច្ចកុដិ | " | ១៤ |
| " | " | ១៣៥ | ១ |
| " | " | " | ៩ |
| " | " | " | ១១ |
| " | " | " | ១២ |
| កាតព្វ | កាតព្វំ | ១៤៥ | ៥ |
| ឧបជ្ឈាយវត្តំ | សទ្ធិវិហារិកវត្តំ | ១៩៩ | ១ |
| " | " | ១៥១ | " |
| សាសនទ្ទេសោ | សាសនុទ្ទេសោ | ១៩៨ | ២ |

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



# វិរុទ្ធាវិរុទ្ធបាឋ

| វិរុទ្ធបាឋ | អវិរុទ្ធបាឋ | អង្កេ | រដ្ឋុលេខាយំ |
|---|---|---|---|
| អត្ថភា | អត្ថភា– | ២១៥ | ៤ |
| ទិដ្ឋិ– | ទិដ្ឋិ– | ២៣៩ | " |
| ឧទ្ទានគា | ឧទ្ទានគាថា | ២៥៥ | ១ |
| អនគារិយេ | អនគារិយំ | ២៦៤ | ៩ |
| ធម្មវិនយេ | ធម្មវិនយេ | ២៦៥ | ៥ |
| បនិគ្គ | បនិគ្គ– | ២៨២ | ៩ |
| តេ | តេន | ៣០៦ | ៨ |
| អត្តសមតិ | អត្តសម្មតិ | ៣១៥ | ១ |
| ញតិ | ញត្តិ | ៣១៩ | " |
| យាយនិ | យាយន្តិ | ៣៣០ | ១៧ |
| គិហិទោបិ | គិហិនោបិ | ៣៦៨ | ៥ |
| អប្បញ្ញាបទា | អប្បញ្ញាបនា | " | ១៥ |
| យស្សត្តាយ | យស្សត្ថាយ | ៣៧៩ | ១៣ |
| គបន្តិ | គប្បន្តិ | ៣៩១ | ៦ |
| អម្មោតិ | អធម្មោតិ | " | ១៤ |
| វិភេចនិ | វិភេចន្តិ | " | ១៦ |
| បុតត្ថេរ | បុត្តត្ថេរ | ៣៩៥ | ១ |
| អនុមតិ | អនុមតី | ៤០៤ | ១១ |
| អធម្មភិទី | អធម្មភិទី– | ៤០៩ | ៦ |
| សុញ្ញតាវិហារេន | សុញ្ញតវិហារេន | ៤១៤ | ១៦ |
| " | " | ៤១៥ | ៥ |

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| អនុរទ្ធ | អនុរុទ្ធ | ១ | ៩ |
| នីភស | និភ.ប | ៤ | ៨ |
| កទ្ធិយភិក្ខុវត្ត | រឿងជនទាំង៣ | ៧ | ១ |
| នុះ | នេះ | ៩ | ១៥ |
| លំដាប់ នោះឯង | លំដាប់នោះឯង | ១០ | ៥ |
| រឿងជនទាំង៣ | កទ្ធិយភិក្ខុវត្ត | ១១ | ១ |
| ទេភ | ភេទ | ១៤ | ១១ |
| លុះឈរក្នុងទីដ៏សមគួរ | បពិត្រព្រះអង្គដ៏ចំរើន កក្កុធទេវបុត្ត | | |
| | លុះឈរក្នុងទីដ៏សមគួរ | ១៧ | ៥ |
| ដោយច្បាស់ថា | ដោយចិត្តច្បាស់ថា | " | ១៦ |
| ខ្លះ ។ | ខ្លះ | ២២ | ១២ |
| សង្ឃ្លឹម | សង្ឃឹម | " | ១៣ |
| សាប់សូន្យ | សាបសូន្យ | ២៤ | ២ |
| ដើម្បិ | ដើម្បី | " | ១២ |
| ដើម្ប | " | " | ១៣ |
| វនាស | វិនាស | " | ១៦ |
| ដើម្បុី | ដើម្បី | " | ១៧ |
| ដើម្បសេចក្តី | " | " | " |
| ដើម្បី | " | ២៥ | ៣ |
| ឫស្សិ | ឫស្សី | " | ១៤ |
| ព្រះអង្គ | ព្រះមានព្រះភាគ | ២៦ | ១៤ |

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ប្រទក្សិណ | ប្រទក្សិណ | ២៧ | ១០ |
| ម្យាង | ម្យ៉ាង | " | ១៧ |
| ឥទ្យូវ | ឥឡូវ | ២៨ | ៩ |
| ម្យាង | ម្យ៉ាង | " | ១១ |
| ភជិក្រឹះ | ភជិគ្រឹះ | " | ១២ |
| សង្ឃ | សង្ឃ | ២៩ | ៧ |
| ធំមាន | ធំហាន | ៣០ | ១៤ |
| សេចក្ដី | សេចក្ដីខ្ចាប | ៣៣ | ១៣ |
| នេក | អនេក | ៤០ | ២ |
| ពីនាក់រនោះ | ពីរនាក់នោះ | " | ១៨ |
| ជាសក្យបុត្ត | ជាសក្យបុត្តិយ៍ | ៥៩ | ២ |
| (ដោយធម្មីកេជា) | (ដោយឱម្មីកជា) | ៦៦ | ១០ |
| បន្ទំអប់រំហើយ | អប់រំហើយ | ៧៤ | ១៧ |
| គៀរគរ | កៀរគរ | ៨០ | ៥ |
| " | " | ៨១ | ១៣ |
| រទៅកាន់ | ទៅកាន់ | ១០៨ | ១០ |
| រួចហេយ | រួចហើយ | ១២៩ | ៧ |
| តាមទំទង | តាមទំនង | ១៥៥ | ១២ |
| ខ្វល់ ៗយ | ខ្វល់ខ្វាយ | ១៧៤ | ១៥ |
| ពិនិត | ពិនិត្យ | ១៨៤ | ១២ |
| ឈាងចីរបេស់ | ឈាងចីវរបស់ | ១៩៧ | ១០ |
| កែម្មុក្ដា | កែវមុក្ដា | ២០៨ | ៣ |

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



# សន្ទឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ករមេណ៍ | កែវមេណ៍ | ២០៨ | ៣ |
| (១២) | (១២២) | ២១០ | ២ |
| ប្តេជា | ប្តេជ្ញា | " | ១៣ |
| ដាយ | ដោយ | ២១១ | " |
| ជាតមោក្ខ | ជាតិមោក្ខ | ២២៦ | ១៦ |
| ព្រ ហ្មចារិយ | ព្រហ្មចរិយ | ២៣១ | ៤ |
| ប្រក | ប្រកប | ២៣៦ | ៥ |
| វិនិច្ឆយ | វិនិច្ឆ័យ | ២៣៧ | " |
| ក្រាបបង្គ | ក្រាបបង្គំ | ២៦៥ | ៤ |
| សោត្តាបត្តិផល | សោតាបត្តិផល | " | ១៨ |
| បុញ្ញវត្ត | បុញ្ញវត្ត | ២៦៦ | ១ |
| សោត្តាបត្តិផល | សោតាបត្តិផល | " | ៥ |
| " | " | " | ៨ |
| ព្រកាគ | ព្រះភាគ | ២៨៥ | " |
| ទាំឡាយង | ទាំងឡាយ | ២៨៦ | ៣ |
| ឌិល | ដែល | ២៨៧ | ៤ |
| មាល | ម្នាល | ២៩១ | ៨ |
| ឧភ | ឧភ័ទ | " | ១៤ |
| ភិក្ខុណាន៍មួយ | ភិក្ខុណាមួយ | ២៩៣ | ៩ |
| អក | អ្នក | " | ១៤ |
| ដែលសង្ឃបានសន្មត | សង្ឃត្រូវសន្មត | ២៩៤ | ២ |
| ភិក្ខុ | ភិក្ខុ– | ២៩៦ | ១៣ |

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។


# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ពួកគ្រហស្ថ | ពួកស្រីគ្រហស្ថ | ២៩៩ | ២ |
| ទាំងឡា | ទាំងឡាយ | " | ១៤ |
| កុលុបក(១) | កុលុបកី | ៣០៥ | ៩ |
| អនភាយកិ | អន្ធភាយិក | ៣១៨ | ១៤ |
| ត្រូវប្រាប | ត្រូវប្រាប់ | ៣២៤ | ១៦ |
| មិនត្រូវបភរណា | មិនទាន់បភរណា | ៣២៥ | ១៤ |
| មិនត្រូវមិនបភរណា | មិនត្រូវបភរណា | " | " |
| ខ្លួនឯង | ខ្លួនឯងហើយ | " | " |
| បានសង្ឃ | បានជាសង្ឃ | ៣២៧ | ១១ |
| ដោយសារទេះ | ដោយសាររទេះ | ៣៣១ | ៨ |
| ប្រហស្ថ | គ្រហស្ថ | ៣៦៨ | ៦ |
| ប្រយោជន៍ | ប្រយោជន៍ដល់ជនច្រើន | ៣៧១ | ៥ |
| ព្រះយស– | ព្រះយស | ៣៨៦ | ៤ |
| ត្រេកអរ | ត្រេកអរដោយ | ៣៩៣ | ១៣ |
| ម្ចាស់អ្នកជាធំ | ម្ចាលអ្នកជាធំ | ៣៩៤ | ៦ |
| អាទិត្យជ្រេ | អាទិត្យជ្រេ | ៣៩៨ | ៩ |
| ពហុស្សូត្រ | ពហុស្សូត | ៤០០ | ៤ |
| គគ្គឡបុរៈ | អគ្គឡបុរៈ | ៤០១ | ១៨ |
| ពហុស្សូត្រ | ពហុស្សូត | ៤០២ | ៩ |
| អៀសខ្មាស | អៀនខ្មាស | " | ១១ |
| នឹងឲ្យភិក្ខុ | នឹងឲ្យពួកភិក្ខុ | ៤០៥ | ៤ |
| ព្រះយស– | ព្រះយស | ៤១៨ | ៧ |
| កាលកំណត់ | ការកំណត់ | ៤២៣ | ៨ |
| ទំងភប់ពួកភិក្ខុ | នឹងឲ្យពួកភិក្ខុ | ៤២៤ | ៩ |

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។

# សង្ខិត្តប្រាប់មាតិកា

## ទុតិយភាគ

## សង្ឃភេទក្ខន្ធក:

លេខទំព័រ


ព្រះមានព្រះភាគគង់នៅក្នុងអនុបិយានិគម ទៀបព្រៃអនុបិយា . . . . . . ១

រឿងអនុរុទ្ធសក្កៈ នឹងភទ្ទិយសក្យរាជ . . . . . . . . . . . . . . ៣

រឿងសក្យៈ ៦ អង្គ . . . . . . . . . . . . . . . . . . . . ៧

រឿងឧបាលិកប្បកៈ . . . . . . . . . . . . . . . . . . . . ៨

ពួកសក្យៈកុមារចូលទៅគាល់ព្រះមានព្រះភាគ . . . . . . . . . ៩

ព្រះភទ្ទិយៈ បានសម្រេចនូវវិជ្ជា ៣ យ៉ាង . . . . . . . . . . . . ១០

ឧទានគាថា នឹងរឿងទេវទត្តភិក្ខុ . . . . . . . . . . . . . . ១៣

រឿងអជាតសត្តុកុមារ . . . . . . . . . . . . . . . . . . ១៤

រឿងកូនអ្នកស្រុកកោលិយៈ ឈ្មោះកក្កុធៈ . . . . . . . . . . . ១៥

រឿងព្រះមហាមោគ្គល្លាន ចូលទៅគាល់ព្រះមានព្រះភាគ . . . . . . . . ១៦

រឿងទេវបុត្រឈ្មោះកក្កុធៈ . . . . . . . . . . . . . . . . . ១៧

និយាយអំពីគ្រូ ៥ ពួក . . . . . . . . . . . . . . . . . . ១៩

រឿងព្រះអង្គស្ដេចទៅកាន់ក្រុងរាជគ្រឹះ . . . . . . . . . . . . . ២៣

និគមគាថា . . . . . . . . . . . . . . . . . . . . . . ២៥

រឿងទេវទត្តភិក្ខុ ទូលសូមត្រួតភិក្ខុសង្ឃជំនួស . . . . . . . . . . ២៦

ការធ្វើបកាសនីយកម្មដល់ទេវទត្ត . . . . . . . . . . . . . . ២៧

បកាសនីយកម្ម នឹងរឿងព្រះសារីបុត្ត . . . . . . . . . . . . . ២៩

រឿងទេវទត្តភិក្ខុ នឹងរឿងអជាតសត្តុកុមារ . . . . . . . . . . . ៣៣

សេចក្ដីវិនិច្ឆ័យនៃពួកមហាមាត្យ . . . . . . . . . . . . . . ៣៤

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# សន្ធិកាប្រាប់មាតិកា 

លេខទំព័រ

ការបញ្ជូនបុរសទៅសម្លាប់ព្រះសាស្តា. . . . . . . . . . . . . . . . ៣៦
អនុបុព្វីកថា ព្រះអង្គសំដែងចំពោះបុរសដែលទៅសម្លាប់ព្រះអង្គ. . . . . . ៣៩
ការធ្វើព្រះលោហិតនៃព្រះតថាគតឲ្យពុះពងឡើង . . . . . . . . . . . ៤២
និយាយអំពីគ្រូ ៥ ពួក . . . . . . . . . . . . . . . . . . . ៤៤
ការលែងដំរីនាឡាគិរីឲ្យព្រួចព្រះសាស្តា . . . . . . . . . . . . ៨៤
ព្រះសាស្តាសំដែងគាថាចំពោះដំរីនាឡាគិរី . . . . . . . . . . . ៥១
ពួកមនុស្សនាំគ្នាច្រៀងគាថាសរសើរព្រះបរមគ្រូ . . . . . . . . . ៥២
រឿងតិកកោជន . . . . . . . . . . . . . . . . . . . ៥៣
រឿងទេវទត្តភិក្ខុ សំដែងអំពីវត្ថុ ៥ ប្រការ . . . . . . . . . . ៥៥
រឿងទេវទត្តភិក្ខុ ក្រាបបង្គំទូលសូមវត្ថុ ៥ ប្រការ . . . . . . . . . ៥៦
ការព្យាយាម ដើម្បីទំលាយសង្ឃ និងទំលាយចក្រ . . . . . . . . . ៥៩
ឧទានគាថា . . . . . . . . . . . . . . . . . . . ៦១
រឿងព្រះសារីបុត្ត និងព្រះមោគ្គល្លាន . . . . . . . . . . . . . ៦៣
ការសំដែងធម៌របស់ទេវទត្ត . . . . . . . . . . . . . . . ៦៥
បាដិហារ្យរបស់ព្រះសារីបុត្ត និងព្រះមោគ្គល្លាន . . . . . . . . . ៦៦
អគ្គសាវ័កទាំង ២ អង្គចូលទៅគាល់ព្រះមានព្រះភាគ . . . . . . . . ៦៧
ព្រះបរមគ្រូត្រាស់សំដែងអំពីរឿងដំរី. . . . . . . . . . . . . . ៦៨
និគមគាថា និងភិក្ខុប្រកបដោយអង្គ ៨ ប្រការ . . . . . . . . . . . ៦៩
រឿងទេវទត្តភិក្ខុ និងអសទ្ធម្ម ៨ ប្រការ . . . . . . . . . . . . ៧១
រឿងទេវទត្តភិក្ខុ ត្រូវអសទ្ធម្ម ៣ ប្រការគ្របសង្កត់ និងឧទានគាថា . . . . ៧៤
រឿងព្រះឧបាលិត្ថេរ ទូលសួរអំពីការប្រេះឆានៃសង្ឃ . . . . . . . . . ៧៦
រឿងព្រះឧបាលិត្ថេរ ទូលសួរអំពីសង្ឃភេទ . . . . . . . . . . . ៧៧
រឿងព្រះឧបាលិត្ថេរ និងសេចក្តីព្រមព្រៀងនៃសង្ឃ . . . . . . . . . ៧៨

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ៊ុចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស។ ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



# សន្ធិការប្រាប់មាតិកា

លេខទំព័រ


និគមគាថា . . . . . . . . . . . . . . . . . . . . . . . . ៨២
រឿងព្រះឧបាលិត្ថេរ នឹងភិក្ខុអ្នកបំបែកសង្ឃទៅកើតក្នុងអបាយ . . . . . ៨៥
បញ្ចីរឿងនៃសង្ឃភេទក្ខន្ធកៈ . . . . . . . . . . . . . . . . . ៩០

វត្តក្ខន្ធកៈ

ហេតុនៃការទ្រង់បញ្ញត្តិអាគន្តុកវត្ត . . . . . . . . . . . . . . . ៩៣
ហេតុនៃការទ្រង់បញ្ញត្តិអាវាសិកវត្ត . . . . . . . . . . . . . . . ១០០
គមិកវត្ត . . . . . . . . . . . . . . . . . . . . . . . . ១០៣
គមិកវត្ត នឹងការអនុមោទនាក្នុងរោងភត្ត . . . . . . . . . . . . . ១០៥
វត្តដែលភិក្ខុត្រូវធ្វើក្នុងរោងភត្ត . . . . . . . . . . . . . . . . ១០៧
វត្តរបស់ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត . . . . . . . . . . . . . . . ១១៥
វត្តរបស់ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត នឹងវត្តរបស់ភិក្ខុអ្នកនៅក្នុងព្រៃ . . . . . ១១៩
សេនាសនវត្ត . . . . . . . . . . . . . . . . . . . . . . . ១២៣
ជន្តាឃរវត្ត . . . . . . . . . . . . . . . . . . . . . . . ១២៩
និទាននៃវច្ចកុដិវត្ត . . . . . . . . . . . . . . . . . . . . ១៣១
ការទ្រង់បញ្ញត្តិវច្ចកុដិវត្ត . . . . . . . . . . . . . . . . . . ១៣៤
ឧបជ្ឈាយវត្ត . . . . . . . . . . . . . . . . . . . . . . . ១៣៧
សទ្ធិវិហារិកវត្ត . . . . . . . . . . . . . . . . . . . . . . ១៤៨
អាចរិយវត្ត . . . . . . . . . . . . . . . . . . . . . . . ១៥៦
អន្តេវាសិកវត្ត . . . . . . . . . . . . . . . . . . . . . . ១៦៧
ឧទ្ទាននៃវត្តក្ខន្ធកៈ . . . . . . . . . . . . . . . . . . . . ១៧៥

បាតិមោក្ខដ្ឋបនក្ខន្ធកៈ

ព្រះអានន្ទសូមអារាធនាឲ្យព្រះអង្គសំដែងបាតិមោក្ខ . . . . . . . . . . ,,

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# សន្ធិកប្រាប់មាតិកា



លេខទំព័រ


រឿងព្រះមហាមោគ្គល្លាន . . . . . . . . . . . . . . . . . . ២០២
ធម្មតាមិនដែលកើតគួរអស្ចារ្យ ៨ យ៉ាង ក្នុងមហាសមុទ្រ . . . . . . . ២០៥
សភាពមិនដែលកើតគួរអស្ចារ្យ ៨ យ៉ាង ក្នុងធម្មវិន័យ . . . . . . . . ២០៩
ឧទានគាថា . . . . . . . . . . . . . . . . . . . . . . ២១៦
រឿងឆព្វគ្គិយភិក្ខុ . . . . . . . . . . . . . . . . . . . ២១៧
ការបញ្ឈប់បាតិមោក្ខ . . . . . . . . . . . . . . . . . . ២១៩
និយាយអំពីការបញ្ឈប់បាតិមោក្ខ ១—២ យ៉ាង . . . . . . . . . . ២២០
" " " ៣—៤ យ៉ាង . . . . . . . . . . ២២១
" " " ៤—៥ យ៉ាង . . . . . . . . . . ២២២
" " " ៦ យ៉ាង . . . . . . . . . . ២២៣
" " " ៧ យ៉ាង . . . . . . . . . . ២២៤
" " " ៨ យ៉ាង . . . . . . . . . . ២២៥
" " " ៨—៩ យ៉ាង . . . . . . . . . . ២២៦
" " " ១០ យ៉ាង . . . . . . . . . . ២២៨
និយាយពីការបញ្ឈប់បាតិមោក្ខប្រកបដោយធម៌ . . . . . . . . . . ២៣១
ព្រះឧបាលិ ក្រាបទូលសួរការកាន់យកអត្តាទាន . . . . . . . . . . ២៤១
ព្រះឧបាលិ ក្រាបទូលសួរការចោទ . . . . . . . . . . . . . ២៤៥
ព្រះឧបាលិ ក្រាបទូលសួរហេតុវិប្បដិសារៈ ចំពោះភិក្ខុអ្នកចោទ . . . . ២៤៩
ឧទាននៃបាតិមោក្ខដ្ឋបនក្ខន្ធកៈ . . . . . . . . . . . . . . ២៥៥


ភិក្ខុនីខន្ធកៈ


ព្រះនាងមហាបជាបតីគោតមី ទូលសូមបព្វជ្ជា . . . . . . . . . . . "
គរុធម៌ ៨ យ៉ាង . . . . . . . . . . . . . . . . . . . ២៦៦

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



# សង្កេតប្រាប់មាតិកា


លេខទំព័រ

ព្រហ្មចរិយធម៌ មិនតាំងនៅយូរអង្វែង . . . . . . . . . . . . ២៧១
រឿងព្រះនាងមហាបជាបតីគោតមី នឹងការសូមពរ . . . . . . . . . ២៧៣
លក្ខណៈនៃការវិនិច្ឆ័យធម្មវិន័យ . . . . . . . . . . . . . ២៧៩
ភិក្ខុមិនសំដែងអាបត្តិមោក្ខ ដល់ពួកភិក្ខុនី . . . . . . . . . . . ២៨០
ការទទួលអាបត្តិ . . . . . . . . . . . . . . . . . ២៨១
ការធ្វើកម្មដល់ពួកភិក្ខុនី . . . . . . . . . . . . . . . ២៨៣
រឿងភិក្ខុនីជាសិស្សរបស់ឧប្បលវណ្ណា . . . . . . . . . . . ២៨៥
ការបង្ហាញកាយជាដើម ទណ្ឌកម្ម នឹងអវន្ទិយបុគ្គល . . . . . . . ២៨៧
ឆព្វគ្គិយាភិក្ខុនី សាចភក់នឹងទឹកទៅលើពួកភិក្ខុ . . . . . . . . ២៨៨
ការបង្ហាញកាយជាដើម ទណ្ឌកម្ម នឹងការបញ្ឈប់ឱវាទ . . . . . . . ២៨៩
ការបញ្ឈប់ឱវាទរបស់ភិក្ខុល្ងង់ជាដើម . . . . . . . . . . . ២៩១
ការសន្មតិភិក្ខុឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី . . . . . . . . . . ២៩៣
ការទទួលឲ្យឱវាទនៃភិក្ខុទាំងឡាយ . . . . . . . . . . . . ២៩៥
ការទទួលឲ្យឱវាទហើយមិនមកប្រាប់ជាដើម . . . . . . . . . . ២៩៧
ការឲ្យដំត្រគាកដោយឈើមានសណ្ឋានដូចឆ្អឹងគោជាដើម . . . . . . ២៩៩
ការធ្វើគំនូសខាងក្រោមមាត់ជាដើម . . . . . . . . . . . . ៣០១
កាលកិរិយារបស់ភិក្ខុនី ១ រូប . . . . . . . . . . . . . ៣០៣
ភិក្ខុនី ដាក់កូនខ្ចីក្នុងបាត្រ . . . . . . . . . . . . . . ៣០៥
ភិក្ខុនី នាំគ្នាគយគន់និមិត្តបុរស . . . . . . . . . . . . . ៣០៧
ទ្រង់អនុញ្ញាតឲ្យទទួលការសន្សំ របស់ភិក្ខុទាំងឡាយ . . . . . . . ៣០៩
ទ្រង់អនុញ្ញាតឲ្យទុកចីវរ ក្នុងកេងទានជាដើម . . . . . . . . . . ៣១១
អនុភាយិកធម៌ ២៤ យ៉ាង . . . . . . . . . . . . . . . ៣១៣

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។

# សន្លឹកប្រាប់មាតិកា 

លេខទំព័រ

ការសន្មតិខ្លួនឯង នឹងសន្មតិភិក្ខុនីដទៃ . . . . . . . . . . . . . ៣១៥
ញត្តិចតុត្ថកម្មឧបសម្បទា . . . . . . . . . . . . . . . . . ៣១៧
ការហាមឃាត់នូវទីតាមលំដាប់ចាស់ទុំ នឹងការមិនបវារណា . . . . . ៣២៥
ការបវារណារបស់ភិក្ខុនីសង្ឃ. . . . . . . . . . . . . . . . ៣២៧
ការឃាត់ឧបោសថ នឹងឃាត់បវារណា . . . . . . . . . . . . . ៣២៨
ការទ្រង់អនុញ្ញាតគ្រែស្នែងជាដើម . . . . . . . . . . . . . . ៣៣១
ញត្តិចតុត្ថកម្មឧបសម្បទា ដោយទូត. . . . . . . . . . . . . . ៣៣៣
រឿងស្រីម្នាក់នឹងការសន្មតិភិក្ខុនី. . . . . . . . . . . . . . . ៣៣៧
ការសន្មតិភិក្ខុនី នឹងការមិនពោលណាសិក្ខារបស់ភិក្ខុនី . . . . . . . ៣៣៩
រឿងពួកភិក្ខុនីអង្គុយពែនភ្លែន នឹងបន្ទោបង់វច្ចៈក្នុងបង្គន់ . . . . . . . ៣៤១
ការងូតទឹក របស់ពួកភិក្ខុនី. . . . . . . . . . . . . . . . ៣៤២
ឧទ្ទានគឺបញ្ជីរឿងនៃភិក្ខុនីខន្ធកៈ. . . . . . . . . . . . . . ៣៤៤

## បញ្ចសតិកក្ខន្ធកៈ

ឧភិទរបស់ព្រះមហាកស្សប មានអាយុ . . . . . . . . . . . . ៣៥៧
ការសន្មតិភិក្ខុ ៥០០ រូប . . . . . . . . . . . . . . . . ៣៥៩
ភិក្ខុមានការជួសជុលទីដែលធ្លុះធ្លាយជាដើម. . . . . . . . . . . ៣៦១
ព្រះមហាកស្សប មានអាយុប្រកាសដំនុំសង្ឃ . . . . . . . . . . ៣៦២
ការសង្គាយនាសិក្ខាបទមានទុតិយបារាជិកជាដើម. . . . . . . . . ៣៦៣
ពោលអំពីសិក្ខាបទតូចនឹងតូចដោយលំដាប់ . . . . . . . . . . ៣៦៥
ព្រះអានន្ទត្រូវមារគ្របដណ្ដប់ចិត្ត. . . . . . . . . . . . . . . ៣៧១
ការដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុ . . . . . . . . . . . . . . ៣៧៣
រឿងព្រះបាទឧទេន នឹងការក្រាយសំពត់ឧត្តរាសង្គៈ . . . . . . . . ៣៧៤
រឿងឆន្នត្ថេរ នឹងការដាក់ព្រហ្មទណ្ឌដល់លោក . . . . . . . . . . ៣៧៩

ឯកសារគម្ពីរព្រះត្រៃបិដកនេះជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងកូនចៅ
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ទុកក្នុងគេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន។



# សង្ខេបរឿងមាតិកា

លេខទំព័រ

ឧទ្ទាននៃបញ្ចសតិកក្ខន្ធកៈ . . . . . . . . . . . . . . . . . . . . . . . . . ៣៨១

*សត្តសតិកក្ខន្ធកៈ*

រឿងវជ្ជីបុត្តកភិក្ខុ នឹងរឿងព្រះយសត្ថេរ . . . . . . . . . . . . . . . . ៣៨៥
ឧបក្កិលេស ៤ យ៉ាងរបស់ព្រះចន្ទ្រ នឹងព្រះអាទិត្យ . . . . . . . . . . . ៣៨៧
ឧបក្កិលេស ៤ យ៉ាងរបស់សមណព្រាហ្មណ៍ . . . . . . . . . . . . . . ៣៨៩
ឧបក្កិលេសទាំង ៤ . . . . . . . . . . . . . . . . . . . . . . . . . ៣៩១
រឿងអ្នកធំឈ្មោះមណិចូឡកៈ . . . . . . . . . . . . . . . . . . . . . . ៣៩៣
ពាក្យរបស់ព្រះថេរៈឈ្មោះយសកាកណ្ឌកបុត . . . . . . . . . . . . . . ៣៩៥
រឿងព្រះថេរៈឈ្មោះសម្ភូតសាណវាសី . . . . . . . . . . . . . . . . . ៣៩៧
សេចក្តីត្រិះរិះរបស់ពួកភិក្ខុជាថេរៈ . . . . . . . . . . . . . . . . . . ៣៩៩
រឿងព្រះរេវតត្ថេរ . . . . . . . . . . . . . . . . . . . . . . . . . . ៤០១
ការសួរ នឹងការដោះស្រាយនូវវត្ថុ ១០ ប្រការ . . . . . . . . . . . . . . ៤០៣
សេចក្តីត្រិះរិះរបស់ពួកវជ្ជីបុត្តកភិក្ខុ . . . . . . . . . . . . . . . . . ៤០៧
រឿងវជ្ជីបុត្តកភិក្ខុ . . . . . . . . . . . . . . . . . . . . . . . . . ៤០៩
សេចក្តីប្រាថ្នា ដើម្បីនឹងវិនិច្ឆ័យនូវអធិករណ៍ . . . . . . . . . . . . . ៤១៣
ពាក្យជាចន្លោះរបស់ពួកភិក្ខុជាថេរៈ . . . . . . . . . . . . . . . . . . ៤១៥
សេចក្តីប្រាថ្នា ដើម្បីនឹងវិនិច្ឆ័យនូវអធិករណ៍ . . . . . . . . . . . . . ៤១៧
រឿងអជិតភិក្ខុ . . . . . . . . . . . . . . . . . . . . . . . . . . . ៤១៩
បញ្ហាវិសជ្ជនានូវវត្ថុ ១០ ប្រការ . . . . . . . . . . . . . . . . . . . ៤២១
ឧទ្ទាននៃសត្តសតិកក្ខន្ធកៈ . . . . . . . . . . . . . . . . . . . . . . ៤២៩